ស្បៃកពាក់និងដំណែរតម្លាភ្លឺ

ចុងសតវត្សទី១៩ ដល់សតវត្សទី២០

SEAMS OF CHANGE

CLOTHING AND THE CARE OF THE SELF IN LATE 19TH AND 20TH CENTURY CAMBODIA

រៃយ៉ំ

REYUM

PUBLISHING

ស្នៀតពាក់និងដំណែរកង្វាខ្លួន

ចុងសតវត្សទី១៩ ដល់សតវត្សទី២០

SEAMS OF CHANGE

Clothing and the care of the self in late 19th and 20th Cambodia

រៃយ៉ៃ
REYUM
PUBLISHING

ផ្ទះលេខ ៤៧ ផ្លូវលេខ ១៧៨, ប្រអប់សំបុត្រលេខ ២៤៣៨ ភ្នំពេញ។ ទូរស័ព្ទ-ទូរសារលេខ ០២៣ ២១៧ ១៤៩
N°47, Street 178, P.O. Box 2438 Phnom Penh, Cambodia. Tel / Fax: 023 217 149
E-mail: reyum@camnet.com.kh, Website: www.reyum.org

ឧបត្ថម្ភដោយ *With the support of*

The Rockefeller Foundation

 និពន្ធដោយ

ជា ណារិន, ជា សោភារី,

កែម សុនីន, ព្រាប ចាន់ម៉ាក់

និពន្ធនាយក

លី តារាវុធ និង អាំងត្រីដ មូអាន់

ក្រមបច្ចេកទេស និងការងារផ្សេងៗ

វ៉ាន់ ចាន់រដ្ឋា, ឈន សុវណ្ណាក់, វ៉ាន់ សុវណ្ណនី

រៀបចំសៀវភៅនិងចោះពុម្ពផ្សាយដោយ

រិទ្ធាស្ថាន រៃយំ

ចោះពុម្ពផ្សាយលើកទី១ ឆ្នាំ២០០៣, ភ្នំពេញ

រក្សាសិទ្ធ រៃយំ

លេខ ISBN 1-58886-046-9

Written by
Chea Narin, Chea Sopheary,
Kem Sonine, Preap Chanmara

Editors:
Ly Daravuth
Ingrid Muan

Translator
Ingrid Muan

Technical assistance
Van Sovanny, Chhorn Sovannara,
Van Chanratha

Published by
Reyum Publishing

Printed and bound in Cambodia
First edition, December 2003

Copyright / All rights reserved

ISBN 1-58886-046-9

រូបនៅលើគ្របសៀវភៅ៖

– ខាងឆ្វេង៖ គំនូរនៅតាមជញ្ជាំងព្រះវិហារព្រះកែវមរកត។

– កណ្តាល៖ ស្ត្រីនៅខេត្តកំពង់ចាម ថតនៅដើមសតវត្សទី២០។ (រូបថត៖ បណ្ណសារជាតិ)

– ខាងស្តាំ៖ ដកស្រង់ពីសៀវភៅ "វិជ្ជាកាត់ដេរដោយខ្លួនឯង" និពន្ធដោយ អ៊ាប ប៊ុន សុត ទសវត្សរ៍៦០។

Cover Photographs
Left: Detail of a wall painting in Preah Vihear Preah Kao Morokot (Photo: Reyum)
Center: Woman in Kompong Cham Province. Early 20th century. (Photo: National Archives of Cambodia)
Right: Detail of a page from *Sewing by yourself*, by Aap Bun Soth, 1960s.

Sales and Distribution

In Cambodia: Reyum at reyum@camnet.com.kh, www.reyum.org
In Europe: Asian Studies Book Services at info@asianstudiesbooks.com, www.asianstudiesbooks.com
In the USA: Art Media Resources, Ltd. at info@artmediaresources.com, www.artmediaresources.com
In Thailand: Paragon Asia at info@paragonasia.com, www.paragonasia.com

មាតិកា / CONTENTS

កំណាត់និពន្ធនាយក *i*		Note from the editors *i*
អារម្ភកថា *១*		Introduction *1*
ប្រភេទសម្លៀកបំពាក់ *១៤*		Types of clothing *14*
ប្រភេទក្រណាត់ប្រើក្នុងស្រុក *១២៥*		Types of cloth *125*
ការកាត់ដេរ *១៥៣*		Cutting and sewing *153*
ការថែទាំសម្លៀកបំពាក់ *១៨៥*		Caring and storing *185*
ពណ៌សម្លៀកបំពាក់ *២០៣*		Colors of clothing *203*
ថែរក្សាខ្លួន *២២៣*		Care of the self *223*
បញ្ជីអ្នកដែលយើងយកសេចក្តីសម្ភាសន៍មកប្រើ *២៨៩*		List of Interviewees *289*

កំណាត់និពន្ធនាយក

រយៈពេលពីរឆ្នាំកន្លងមកនេះ វិទ្យាស្ថានរៃអំបានធ្វើការសម្ភាសន៍លោកតា លោកយាយមួយចំនួនអំពីការរីវត្តន៍នៃជីវិតផ្ទាល់ខ្លួនរបស់គាត់ តាំងពីតូចរហូតមកទល់សព្វថ្ងៃ។ តាមរយៈការរៀបរាប់អំពីខ្សែជីវិតរបស់បុគ្គលម្នាក់ៗក៏ធ្លុះបញ្ចាំងពីសង្គមខ្មែរទូទៅនាចុងសតវត្សទី១៩ និងសតវត្សទី២០ផងដែរ។ អាស្រ័យដូច្នេះ គោលបំណងនៃការសម្ភាសន៍នេះគឺកត់ត្រាទុកនូវរៈសេចក្តីចងចាំរបស់មនុស្សចាស់ដើម្បីប្រមូលផ្តុំជាទិន្នន័យ។

ទន្ទឹមនឹងការបង្កើតទន្និន័យនេះយើងខ្ញុំមានបំណងបណ្តុះបណ្តាលអ្នកស្រាវជ្រាវដែលមកធ្វើការជាមួយរៃអំឲ្យមានលទ្ធភាពរិះគិត និងស្រាវជ្រាវដោយខ្លួនឯង។ ម្ល៉ោះហើយទើបបានផ្តល់ឱកាសឲ្យពួកគេរៀបចំពិព័រណ៍ និងចងក្រងសៀវភៅ"ស្លឹកពាក់និងថែវក្បាខ្លួន៖ ពីចុងសតវត្សទី១៩ដល់សតវត្សទី២០" នេះ ដើម្បីផ្តើមមានការពិសោធន៍។ ខ្លឹមសារនៅក្នុងសៀវភៅនេះ ដកស្រង់ពីបទសម្ភាសន៍ស្ទើរទាំងស្រុង។ ឯការជ្រើសរើសប្រធានបទព្រមទាំងកំណត់ចំណងជើង និងតែងសេចក្តីជាការសម្រេចរបស់ក្រុមស្រាវជ្រាវ។ យើងខ្ញុំគ្រាន់តែជួយណែនាំ និងកែសម្រួលឲ្យសមស្របទៅតាមគំនិតរបស់គេ

Note from the editors

This book, and its accompanying exhibition, have developed out of an ongoing research project entitled The Memory Bank. Two years ago, Reyum began interviewing elderly Cambodians from all walks of life in order to accumulate a history of everyday life in late 19th and 20th century Cambodia. Teams of young researchers, recently graduated from Universities, began to interview elderly Cambodians, taping conversations which followed the line of each interviewee's life and inquired about a wide range of issues. Through these ongoing interviews, we have gathered information on many topics not generally found in official histories of 20th century Cambodia: individual memories of historical events associated with colonialism and independence; local beliefs of geography and land use; conceptions of gender and the experiences of women; and everyday accounts of modernisation and change. Compiled into a Memory Bank, these interviews preserve a rich and textured history of everyday life which we hope will serve as a base for further research. The archive of interviews which we are compiling may also suggest local ways of doing things that hold promise and potential for the future. The question Cambodia seems to be facing today is how a sediment of local understanding and behavior will adapt - or disappear - in the face of ongoing development and commercialisation.

ប៉ុណ្ណោះ។ ថ្វីត្បិតច្បាស់ជាមានការខ្វះខាត និងខុសឆ្គងយ៉ាងណា ក៏យើងយល់ថា សេចក្តីតាំងចិត្ត និងខិតខំធ្វើកិច្ចការដោយពេញទំហឹងរបស់ពួកគេ ធ្វើឲ្យសៀវភៅនិងពិព័រណ៍នេះលេចចេញជារូបរាងឡើង។ យើងមានសេចក្តីសង្ឃឹមថា តទៅមុខ ពួកគេនឹងមានឱកាសលួតលាស់ និងរីកចម្រើន។

ក្នុងដំណើរកិច្ចការនេះមានឧបសគ្គ និងការលំបាកច្រើន។ យើងបានឆ្លងកាត់រួច ក៏ដោយសារតែមានការគាំទ្រនិងលើកទឹកចិត្តពីមនុស្សយ៉ាងច្រើន។ ជាពិសេស លោកតាលោកយាយទាំងអស់ដែលបានផ្តល់ពេលវេលា និងពត៌មាន។

យើងក៏ឆ្លៀតឱកាសនេះថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះការខិតខំធ្វើការរបស់បុគ្គលិកវ័យទាំងអស់។ ជាទីបញ្ចប់យើងសូមថ្លែងអំណរគុណចំពោះមូលនិធិ រ៉ុកហ្វែល័រ ដែលបានផ្តល់ថវិកាសម្រាប់ស្រាវជ្រាវ, រៀបចំពិព័រណ៍ និងបោះពុម្ពសៀវភៅនេះ។ ម្យ៉ាងទៀតយើងសូមថ្លែងអំណរគុណចំពោះមូលនិធិ កាស៊ុមុីស៊ូ និងមូលនិធិ ត្រួសារអាល់ប៊ែរ ឃុនស្តាតឌ័រ ដែលជានិច្ចកាលតែងផ្តល់ជំនួយមកផ្តត់ផ្តង់វិយ៉ាំ។

ប្រធាន
លី តារាវុធ និង អ៊ីនគ្រីដ មូអាន់

While the primary aim of the Memory Bank is to pursue the interviews and collect the information described above, the project also intends to train a group of young researchers. After working at Reyum for more than two years, the Memory Bank research team has written the text of this book. We have simply worked with them to clarify their thoughts, and to edit and translate the text into a final form. Thus the catalogue represents the stage at which the team stands as young researchers attempting for the first time to compile a body of research into a finished form. The book is not a comprehensive survey of fashion nor does it engage in existing theoretical debates. Still we think it presents an engaging survey of a body of research which hopefully will spur others to consider the many topics touched upon here.

We want to note the special engagement and commitment of the researchers working on this project, as well as the hard work of the Reyum staff in bringing this project to completion. For their willingness to share the memories which serve as the foundation of this project, we would like to thank all the elderly people who have agreed to participate in our ongoing Memory Bank. We would also like to thank the Rockefeller Foundation for their generous support of this research, as well as the Kasumisou Foundation and the Albert Kunstadter Family Foundation for their ongoing support of Reyum Institute of Arts and Culture.

Ly Daravuth and Ingrid Muan
Co-directors

អារម្ភកថា

INTRODUCTION

ឯកសារស្តីពីប្រវត្តិសាស្ត្រខ្មែរនាចុងសតវត្ស
ទី១៩ និងសតវត្សទី២០ ដែលអ្នកស្រាវជ្រាវបរទេស
ក្តី ខ្មែរក្តីបានចោះពុម្ពផ្សាយកន្លងមក ភាគច្រើន
បង្ហាញអំពីប្រវត្តិសាស្ត្រ "ផ្លូវការ" ពោលគឺសរសេរ
សំដៅលើព្រឹត្តិការណ៍ដែលគេយល់ថាសំខាន់ៗ
ប៉ុណ្ណោះ។ តែបើយើងចង់ដឹងពីរឿងរ៉ាវដែលកើតឡើង
រៀងរាល់ថ្ងៃនៅក្នុងជីវិតមនុស្សម្នាក់ៗ និងការ
ពិសោធន៍ផ្ទាល់របស់គេ សៀវភៅ ឬឯកសារប្រៀប
ផ្លូវការទាំងនោះកម្រឲ្យយើងដឹងណាស់។ ពោលដូច្នេះ
ពុំមានន័យថា ឯកសារសរសេរជាការសែតក្តី ជា
សៀវភៅក្តី មិនមានប្រយោជន៍នោះទេ ប៉ុន្តែវាមិន
អាចផ្តល់ពត៌មានឲ្យបានក្បោះក្បាយ។ ឧទាហរណ៍នៅ
ឆ្នាំ១៩៤១ ក្នុងការសែតកម្ពុជា លេខ៤៧៧ ចុះថ្ងៃទី២១
ខែវិច្ឆិកា មានដំណឹងខ្លីមួយក្នុងផ្នែកដំណាលខ្លីៗ ចុះ
ផ្សាយថា៖ "មានមន្ត្រីរដ្ឋបាលម្នាក់ ដើរទៅស៊ើបរឿង
ចោរប្លន់នៅតំបន់តាសៀវ ឃុំប្រដាក (សៀមរាប)
បានឃើញប្រជាជនខ្មែរជាច្រើននាក់លាក់ខ្លួននៅក្នុង
ផ្ទះបញ្ចេញតែក្បាលហាន់ មន្ត្រីនោះនឹកឆ្ងល់ក៏សួរទៅ
បុរសម្នាក់ដែលមានកំណាត់ជាវរំយ៉ីវ័ណ្ណនៅចង្កេះថា
ម្តេចក៏គេពួនដូច្នោះ។ បុរសនោះឆ្លើយថា ក្នុងផ្ទះមាន
កន្ទបវ័ណ្ណតែមួយ ឥឡូវខ្ញុំយកកន្ទបមកវ័ណ្ណខ្លួនខ្ញុំទៅ
ហើយ មនុស្សឯទៀតក៏គោងនៅលាក់ខ្លួនក្នុងផ្ទះទៅ"។
រឿងនេះមានចាស់ៗជាច្រើននៅចងចាំ
ហើយពេលយើងសួរ គាត់ច្រាប់បន្តមទៀតថា គេ
មានប្រើពាក្យ "ស្ងៀកពាង, ស្ងៀកប៉ោត ឬស្ងៀកផ្ទះ"

Most research on late 19th century and 20th century Cambodian history has concerned itself with "official" history, recording events perceived as important and focusing on leaders and rulers. If we want to know about the everyday life and experiences of ordinary people during this period, these official histories do not offer us much information. For example, when we hear elderly people talking about "wearing the water jar", "wearing the tin gas can", or "wearing the house", few official histories that we know of can tell us much about these habits of the early 1940s. Through our interviews with elderly people, however, we learned that these figures of speech refer to an extreme shortage of clothing during the time of Japanese occupation in World War II. At that time, some families - especially those living in remote areas of the countryside - sometimes had only one set of clothing for all members of the family to share. Thus, while one family member went out wearing that set of clothing, the rest of the family hid themselves naked in their house. If visitors came to the house, the owner of the house would only poke his head out of the door or window in order to greet the guest. Sometimes they used a tin gas can to cover themselves, or they went and sat in the water jar to hide their nudity from the person they wanted to talk to. This everyday history produced the figures of

ដោយសារនៅសម័យជប៉ុនចូលស្រុក (១៩៤៤-
៤៥) អ្នកស្រុកខ្លះ ជាពិសេសអ្នកនៅតាមស្រុក
ស្រែក្រខ្សត់ ក្នុងមួយគ្រួសារមានខោអាវតែមួយ
សម្រាប់។ ម្ល៉ោះហើយបើមានអ្នកក្រៅមកលេងផ្ទះ
មានតែម្នាក់ទេដែលមានសម្លៀកបំពាក់ស្លៀកចេញ
មកក្រៅ ឯអ្នកដទៃទៀតត្រូវពួនក្នុងផ្ទះ ឬក្នុងពាង ឬ
ក្នុងប៉ោតអើតតែក ទើបមានពាក្យនិយាយថា "ស្លៀក
ពាង ស្លៀកប៉ោត" នេះ។ យើងយល់ច្បាស់ថា ពាក្យ
ស្លៀកពាងស្លៀកប៉ោតនេះ និងរឿងរ៉ាវយ៉ាងច្រើន
ទៀត ដែលកើតឡើងក្នុងសង្គមខ្មែរនឹងរលាយសាប
សូន្យអស់ក្រោយពេលមនុស្សចាស់ដែលធ្លាប់ឆ្លង
កាត់សម័យកាលនោះចាកលោកអស់ទៅ។ ហេតុ
ដូច្នេះហើយ ដើម្បីប្រមូលពត៌មានទាំងអស់នោះ
ទើបយើងធ្វើការសម្ភាសន៍មនុស្សចាស់ៗ ដែលមាន
អាយុច្រើន (ចាប់ពីអាយុ៦០ឆ្នាំឡើង) ពីព្រោះគាត់
អាចចងចាំរឿងផ្ទាល់របស់គាត់ផង និងចាំរឿងរ៉ាវ
ដែលឪពុកម្តាយគាត់បាននិយាយប្រាប់ថែមទៀតផង។
មានសេចក្តីថា យើងអាចកំណត់បានរយៈពេលដែល
គាត់ចងចាំនោះសំដៅលើពេលវេលាពីចុងសតវត្សទី
១៩ រហូតមកដល់បច្ចុប្បន្ន។

នៅស្រុកខ្មែរគេគ្មានទម្លាប់សរសេរទុកជា
ឯកសារនូវរឿងរ៉ាវដែលកើតឡើងជុំវិញខ្លួននោះទេ គឺ
គេចូលចិត្តនិយាយប្រាប់កូនចៅតាគ្នា។ នេះដោយ
សារកាល:ទេស:នៃនយោបាយក្នុងស្រុក (ដូច
សម័យប៉ុល ពតជាដើម) ទើបធ្វើឲ្យការសម្ភាសន៍

speech which we still hear the elderly using - "the era when we wore the water jar, wore the gas can, or wore the house." Such details of life in Cambodian society will die with the elderly people who experienced them. Our project, The Memory Bank, aims to collect such local everyday histories.

Over the last two years, we have interviewed many elderly people over the age of sixty, both about their own experiences, and about their memories of events and experiences which their parents and grandparents told them when they were little. Thus the horizon of their memory stretches back over the 20th century to the end of the 19th century.

It is not generally a habit in Cambodian culture to write down records of the everyday experiences which unfold around us. Instead, lived experiences are told orally, passed down from generation to generation by telling. Recent events, such as the Khmer Rouge Regime and the ongoing political uncertainties, have made interviewing people and asking questions about the past more difficult, since the elderly are often afraid. Society as a whole does not necessarily value the details of the lives of ordinary people, and memories seem only to be told (often in abbreviated form) to grandchildren or small circles of relatives or friends. Young people are not necessarily

និងសាកសួរនោះមានការលំបាក ដោយមនុស្សចាស់ខ្លះទៅគេភ័យខ្លាច។ មួយវិញទៀត គេមិនសូវមានទម្លាប់និយាយវែកញែករឿងនោះឲ្យបានក្បោះក្បាយក្រៅពីនិយាយប្រាប់បន្តិចបន្តួចដល់កូនចៅ និងញាតិមិត្តរបស់គាត់ឡើយ។ ក្នុងក៏គ្មានទម្លាប់សួរមនុស្សចាស់នូវរឿងបែបនោះដែរ។ ការងារដែលយើងធ្វើនេះហាក់ដូចជាប្លែកសម្រាប់មនុស្សចាស់ទាំងនោះដែលធ្វើឲ្យគេប្រុងប្រយ័ត្នក្នុងការនិយាយ។ ម្ល៉ោះហើយយើងខិតខំស្វែងរកវិធីផ្សេងៗ ដើម្បីធ្វើឲ្យគេទុកចិត្ត និងត្រូវប្រើពេលវេលាច្រើនដើម្បីសាកសួរគាត់និយាយឲ្យបានក្បោះក្បាយដោយមានថតវីដេអូនិងសំឡេងផង។ ក្រោយពីការសម្ភាសន៍អស់រយៈពេល៦ឆ្នាំកន្លងមក យើងឃើញមានផុសចេញនូវរឿងរ៉ាវ ឬពត៌មានច្រើនដែលយើងមិនបានស្មានទុកជាមុនដែលអាចប្រមូលផ្តុំមកធ្វើជាប្រធានបទអ៊ីមួយ។

រូបលេខ ១៖ សម្ភាសន៍លោកតាហង់ ភួង អាយុ៩៤ឆ្នាំ នៅខេត្តកណ្តាល ឆ្នាំ២០០២។ (រូបថត៖ រ៉ៃយ៉ំ)

Figure 1: Interviewing Hong Phuong, 94 years old, in Kandal Province, 2002. (Photo: Reyum)

accustomed to asking the elderly about their experiences. Given this context, our interview project often seemed strange at first to our elderly interviewees, and they were sometimes cautious or even hesitant to speak. We had to seek ways to make them trust us, and we spent long periods of time with them so that they would agree to be interviewed in detail on video and tape. After conducting these interviews for more than two years now, we have gathered a wealth of information which we never imagined when we began. Many possible themes and topics have emerged from our interviews.

Clothing and the care of the self is one of these topics which we choose to elaborate here as a catalogue and exhibition. Through detailed interviews, we tried to illuminate habits of clothing and the care of the self from the late 19th century to the 20th century, recording some traditional forms of clothing and ways of caring for the body which are virtually forgotten today, while also charting changes in clothing and makeup which occurred in the region today known as Cambodia during the late 19th century and the early 20th century. Up to the end of the 19th century, local people seem to have generally used and exchanged things made from the natural environment which surrounded them. For example, villagers burned the wood of the *pti* tree, the skins of

រូបលេខ ២៖ ម្ចាស់ក្សត្រី និងបុត្រីពីរអង្គ ស្លៀកពាក់របៀបប្រពៃណី ថតឆ្នាំ១៨៦៦ឬ៧៨ ដោយ Gsell។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 2: The Queen of Cambodia with her two daughters wearing traditional Khmer clothing. Photographed 1866 or 1878 by Gsell. (Photo: National Archives of Cambodia)

រូបលេខ ៣៖ ម្ចាស់ក្សត្រី ទ្រង់សម្លៀកបំពាក់របៀបបារាំង ថតឆ្នាំ ១៨៦៦ឬ១៨៧៨ ដោយ Gsell។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 3: The Queen of Cambodia wearing French clothing. Photographed 1866 or 1878 by Gsell. (Photo: National Archives of Cambodia)

"ស្លៀកពាក់ និងថែរក្សាខ្លួន" ដែលយកមកចោះផ្សាយជាសៀវភៅ គឺជាប្រធានបទមួយក្នុងចំណោមប្រធានបទជាច្រើនទៀត ដែលយើងសាកល្បងយកមកធ្វើក្នុងពេលនេះ។ យើងបានសាកសួរខ្លួនឯងថា បើសិនជាយើងពឹងផ្អែកទៅលើការចងចាំរបស់មនុស្សចាស់មួយចំនួននោះ តើយើងអាចដឹងខ្លះអំពីការវិវត្តន៍នៃសម្លៀកបំពាក់ និងការតុបតែងខ្លួនដែរឬទេ។ សៀវភៅនេះចាត់ទុកជាការសាកល្បង

bananas, and the *ko* tree seed in order to make *kbong* water used for washing both clothing and hair. Such habits gradually changed, however, as people increasingly looked to what they perceived as the modern, and came to rely on store-bought manufactured products such as shampoo and soap. The shift to a consumer society, and the influx of Western influences, accelerated in the early 20th century when the region today known as

ឆ្នើយនឹងសំណួរខាងលើ។ ក្រោយពីសម្ភាសន៍ចាស់ៗ យើងឃើញលេចចេញនូវពត៌មានមួយចំនួនបង្ហាញអំពីសម្លៀកបំពាក់ និងរបៀបថែទាំនិងតុបតែងខ្លួន ដែលធ្លាប់មានក្នុងសង្គមខ្មែរកន្លងមក ហើយស្ទើរតែបាត់បង់អស់នាពេលសព្វថ្ងៃ។ ឧទាហរណ៍អាវបំពង់វែងនៅដើមសតវត្សទី២០ ស្ត្រីខ្មែរស្ទើរគ្រប់គ្នាពាក់ប្រចាំថ្ងៃ។ សព្វថ្ងៃនេះលែងឃើញមានពាក់ទៀតហើយ។ នេះធ្វើឲ្យយើងមានការសោកស្តាយ និងគាន់តែចង់ចងក្រងសៀវភៅនេះឲ្យចេញជារូបរាងឡើង។

រហូតមកទល់ចុងសតវត្សទី១៩ខ្មែរនៅមានទម្លាប់ច្នៃធម្មជាតិជុំវិញខ្លួនសម្រាប់យកមកប្រើប្រាស់និងដោះដូរគ្នាទៅវិញទៅមក។ ឧទាហរណ៍មានយកដើមផ្តុំ, សម្បកចេក, សម្បកផ្លែត ។ល។ មកដុតយកផេះទៅធ្វើជាទឹកក្តឹងសម្រាប់កក់សក់ ឬយកល្វៀតមកធ្វើជាម្យ៉ាសាបខ្លួន។ ទំនៀមបែបនេះបាត់បង់ និងកែប្រែបន្តិចម្តងៗទៅតាមការវិវត្តន៍ទៅរក "ភាពទំនើប" នៃសង្គម។ នៅដើមសតវត្សទី២០ ល្បឿននៃការផ្លាស់ប្តូរ និងទទួលឥទ្ធិពលពីអឺរ៉ុបកាន់តែមានសន្ទុះលឿន។ ឯការជះឥទ្ធិពលបែបអឺរ៉ុបនេះធ្វើឲ្យមានការផ្លាស់ប្តូរទាំងផ្នែកម៉ូតសម្លៀកបំពាក់ ទំនៀមទម្លាប់នៃការស្លៀកពាក់ របៀបកាត់ដេរ និងប្រភេទក្រណាត់ជាដើម។ អ្នកខ្លះនៅស្លៀកពាក់តាមរបៀបខ្មែរ ខ្លះស្លៀកជារបៀបខ្មែរផងបារាំងផង និងខ្លះទៀតស្លៀករបៀបបារាំងទាំងស្រុង។ ការផ្លាស់ប្តូរនេះមុនដំបូងឃើញថាមានទំនាស់ខ្លះដែរ ដោយអ្នកខ្លះយល់ថាល្អ អ្នកខ្លះ

Cambodia was under a French Protectorate. Outside influences affected not only types of clothing and habits of dress, but also ways of making clothing and the types of cloth used to make clothing. As the 20th century proceeded, some people continued to wear traditional types of clothing, others began to wear local styles of clothing mixed with French clothing, while still others wore only French clothing. This transition was complex and controversial since some people viewed the changes as good, modern, and *civilisé*, while others - particularly the elderly - decried the changes and viewed them as destroying Khmer traditions. Still societal change proceeded and many of these changes (such as wearing shoes and dressing in Western style clothing) have today become habits of the Cambodian people.

In addition to our research on clothing and ways of making clothing, we have included information on what we call the care and decoration of the self. By this we mean the ways in which people took care of their bodies and made them attractive to others. We have not been able to research this topic in detail, but we present here some of the things that we learned through our interviews.

Many of the problems affecting research on Cambodian history in general affected our research on clothing and the care

រូបលេខ ៤៖ កូនសិស្សខ្មែរទៅសិក្សានៅប្រទេសបារាំង ឆ្នាំ ១៩១៦។ (រូបថត៖ បណ្ណសារជាតិ)

Figure 4: Khmer students going to France to study. Photographed 1916. (Photo: National Archives of Cambodia)

រូបលេខ ៥៖ សិស្សសាលាដែលជាខ្សែរាជវង្សខ្មែរ ឆតដើម សតវត្សទី២០។ (រូបថត៖ បណ្ណសារជាតិ)

Figure 5: Children of the extended royal family. Photographed at their school at the beginning of the 20th century. (Photo: National Archives of Cambodia)

ទៀត ជាពិសេសមនុស្សចាស់ គាត់គិតថាមិនល្អ ប្រាសចាកទំនៀមទម្លាប់ខ្មែរ។ តែក្រោយមកបានក្លាយជារឿងធម្មតាទៅវិញ។ សម្លៀកបំពាក់ខ្លះសព្វថ្ងៃបានទៅជាទំនៀមទម្លាប់ទៅហើយ។

ក្រៅពីការសិក្សាអំពីប្រភេទសម្លៀកបំពាក់ យើងក៏ចាប់អារម្មណ៍ និងធ្វើតបញ្ចូលជំពូកផ្សេងមួយទៀត ស្តីពីការតុបតែងខ្លួន ពោលគឺទាក់ទងនឹងការថែរក្សាខ្លួនផង និងសម្រស់ផង។ តែយើងមានការសោកស្តាយដែលមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាអំពី មួក គ្រឿងអលង្ការជាដើម ដែលទាំងនេះយើងយល់ថា មានទាក់ទងនឹងភាពស្អាតរបស់មនុស្សដែរ។

ការរាវរកប្រវត្តិសម្លៀកបំពាក់ ក៏ដូចជាការរាវរកប្រវត្តិអ្វីៗទូទៅក្នុងអារ្យធម៌ខ្មែរដែរ។ នៅមុន "សម័យទំនើប" (សតវត្សទី១៩ដល់បច្ចុប្បន្ន) អ្វី

of the self as well. There is no one who can tell us about the period prior to the end of the 19th century. We can only rely on the little that inscriptions, temple reliefs, and other documents tell us. Chinese reports, like the one written by Chou Ta-Kuan (on his 13th century visit to the region today known as Cambodia), mention clothing briefly. We cannot however definitively say what local inhabitants wore at that time. There are even fewer sources of information about clothing during the Middle Period (the 15th to 18th centuries). Some foreign visitors (Portuguese, Spanish and Dutch) came to the area, and their clothing and habits may have had some influence, although we have no proof of this. For the period after the French established

ដែលពាក់ព័ន្ធនឹងប្រធានបទនេះ គ្មានមនុស្សណាម្នាក់ ដែលអាចឲ្យយើងសាកសួរបានឡើយ គឺមានតែពីង ផ្នែកលើពតិមានតិចតួចពីសិលាចារឹក ចម្លាក់នៅលើ ប្រាសាទ ព្រមទាំងឯកសារខ្លះទៀត ដូចជារបាយ ការណ៍របស់លោកជីវតាគ្វាន់ ដែលបានមកស្រុកខ្មែរ នៅឆ្នាំ១២៩៦ជាដើម បានសរសេរខ្លះពីរបៀបស្លៀក ពាក់។ ទោះជាយ៉ាងណាក៏យើងមិនអាចសន្មត់ថា ដើមឡើយខ្មែរស្លៀកពាក់បែបណានោះទេ។ មកដល់ "សម័យកណ្តាល" (សតវត្សទី១៥ដល់១៨) ប្រភព ពតិមានអំពីការស្លៀកពាក់កាន់តែខ្សត់ខ្សោយណាស់ ទៅទៀត។ ក្នុងអំឡុងពេលនោះមានពួកបរទេស ដូចជាព័រទុយហ្គេ អេស្ប៉ាញ និងហូឡង់ជាដើម បាន ចូលមកស្រុកខ្មែរ ច្បាស់ជាមានទំនាក់ទំនងគ្នាទៅវិញ ទៅមក។ ក្នុងនោះអាចមានទទួលឥទ្ធិពលខ្លះខាង សម្លៀកបំពាក់ផងដែរ។ ចាប់ពីមានអាណាព្យាបាល ជាកាំងមក មានឯកសារច្រើនជាងមុន ដូចជារបាយ ការណ៍រដ្ឋបាលអាណាព្យាបាលជាកាំង, រូបថត ទស្សនាវដ្តី ព្រមទាំងមានមនុស្សចាស់ជាច្រើនដែល នៅចងចាំអាចឲ្យយើងសាកសួរបាន។ ក្នុងពេលនោះ ឥទ្ធិពលជាកាំងលើផ្នែកសម្លៀកបំពាក់ និងការតុបតែង ខ្លួនបានជ្រៀតចូលបន្តិចម្តងៗ និងរីកសាលដាលពីទី ក្រុងរហូតដល់ជនបទ។ ក្នុងអំឡុងពេលពីចុងទសវត្ស ១៩៣០ ដល់ដើមទសវត្ស១៩៤០ ជារយៈពេលមួយ ដែលស្រុកខ្មែរជួបប្រទះភាពក្រខ្សត់ត្រប់បែបយ៉ាង។ ក្នុងរយៈពេលនោះរបស់របរមកពីក្រៅក៏ពុំមាននាំចូល

their Protectorate in 1863, more information becomes available to us in the form of official reports, photographs, magazines, newspapers, and especially the many elderly people who still remember that time.

During the Protectorate, French clothing and habits of caring for and decorating the self entered Cambodia little by little. Such influences spread out from urban areas into the countryside. The late 1930s and early 1940s were a particularly difficult period for Cambodia. Due to World War II, trade was cut off, few goods entered the country, and there was virtually no cloth for sale in the markets. Most of our elderly interviewees called this period, "The time when the Japanese entered the country." At that time, people with money bought up cloth and stored it so that they could make clothing. Others, like Khlot Samol, did not do so. She told us, "At that time, the wings of planes were made from thick canvas. I ripped cloth from the wings of a broken plane that the Japanese had abandoned on a path in the forest. I used that canvas to make clothes to wear." Many others used the fibers of the *ko* tree seed to weave cloth and make clothing. Seeds of the *ko* tree were easy to find, but the cloth woven from their fibers was not nearly as good as that made from cotton. At that time, French officials confiscated any cloth which they saw being woven out of cotton.

These officials pressured farmers to sell their raw cotton to France. This was completely different from the period preceding the war when almost every local family grew some cotton and wove cloth from it for their own use and sometimes for small scale exchange. We do not know whether the French policy was initiated in order to destroy family weaving, to begin a cooperative industry, or to force local populations to buy imported French cloth. There is not yet enough clear information about this policy to judge it. The war years were chaotic and complex with the French administration still ruling for most of the period under a Japanese military occupation. We do know, however, that due to the lack of both clothing and soap (which was very expensive if it was available at all), many people became infected with a type of skin-burrowing flea which was tiny and white. These dire conditions lasted only for a year or so. After the war ended, conditions improved somewhat and goods began to enter the country again little by little.

After independence, Cambodians had the freedom to rule and develop their country as they wished. Perhaps because the Sangkum Reastr Niyum Government wanted to decrease the country's dependence on imported goods, its policies emphasized the development of domestic industrial production, particularly factories and

សូម្បីនៅតាមផ្សារក៏គ្មានក្រណាត់លក់ដែរ។ បើស្តាប់តាមមនុស្សចាស់និយាយ ភាគច្រើនគាត់ហៅសម័យនោះថា "សម័យជប៉ុនចូលស្រុក"។ ក្នុងសម័យនោះ អ្នកខ្លះមានលុយគេទិញបានក្រណាត់ទុក អាចមានខោអាវស្លៀកពាក់ខ្លះ អ្នកខ្លះទៀត ដូចជាលោកយាយ ខ្ញុត សំអុល និយាយថា "ពីជំនាន់នោះស្លាបកប៉ាល់ហោះ (យន្តហោះ) ធ្វើពីក្រណាត់ក្រាស់ៗ ខ្ញុំទៅហែកក្រណាត់នោះពីកប៉ាល់ហោះខូច ដែលពួកជប៉ុនបោះចោលនៅច្រងាងក្នុងព្រៃ ខ្ញុំបានក្រណាត់នោះហើយយកមកកាត់ខោអាវស្លៀក"។ ចំពោះអ្នកមួយចំនួនធំទៀត គេយកសំឡីតត្បាញជាក្រណាត់ធ្វើជាសម្លៀកបំពាក់។ សំឡីតងាយស្រួលកេ តែក្រណាត់ដែលធ្វើពីសំឡីតពុំមានគុណភាពល្អដូចធ្វើពីសំឡីកប្បាសឡើយ។ ក្នុងពេលនោះដែរ បើអ្នកណាយកសំឡីកប្បាសត្បាញ ហើយរាជការបារាំងឃើញត្រូវរឹបអូសយកក្រណាត់ដែលកំពុងត្បាញតែម្តង។ លើសពីនេះ បារាំងបានបង្ខំឲ្យប្រជាជនលក់សំឡីកប្បាសឲ្យបារាំងថែមទៀត ដែលផ្ទុយស្រឡះពីមុនពេលមានសង្គ្រាម ស្ទើរគ្រប់ក្រុមគ្រួសារគេដាំកប្បាស និងត្បាញក្រណាត់សម្រាប់ប្រើប្រាស់ដោយខ្លួនឯង ឬសម្រាប់ដោះដូរខ្លះៗ។ យើងមិនហ៊ានអះអាងច្បាស់ថា បារាំងធ្វើយ៉ាងនេះ ដោយសារចង់លុបបំបាត់ទំនៀមត្បាញជាលក្ខណៈគ្រួសារ ដោយបង្កើតទៅជាឧស្សាហកម្មរបៀបសហគមន៍មួយវិញ ឬក៏មូលហេតុចង់ឲ្យខ្មែរប្រើក្រណាត់របស់បារាំងនាំចូលមកនោះទេ។

ទោះជាយ៉ាងណាក៏យើងពុំមានពត៌មានស្តីពីរឿងនេះច្បាស់ដែរ ហើយពេលនោះជារយៈកាលមួយដូចជាច្របូកច្របល់ដែរ ដែលមានចារាំងតំពុងត្រប់ត្រងស្រុកផង និងមានជប៉ុនចូលមកទៀត ដូច្នេះយើងពិបាកក្នុងការសន្និដ្ឋានណាស់។ មិនតែប៉ុណ្ណោះក្នុងសម័យនោះខ្លះគ្មានខោអាវផ្ទាស់ប្តូរ ហើយសាប៊ូក៏មានតម្លៃថ្លៃទៀតធ្វើឲ្យមនុស្សភាគច្រើនកើតជំងឺថែចេញពីសាច់ (ជាសត្វល្អិតតូចៗ ពណិស កើតចេញពីស្បែក)។ តែការខ្វះខាតនេះមានរយៈប្រហែលជាមួយឆ្នាំប៉ុណ្ណោះ បន្ទាប់ពីចប់សង្គ្រាមលោកលើកទី២ បានធូរស្រាលឡើងជាបន្តបន្ទាប់ ការនាំចូលរបស់របរក៏មានជាបណ្តើរៗឡើងវិញដែរ។ ក្រោយពីទទួលបានឯករាជ្យ ខ្មែរមានសេរីភាពពេញលេញធ្វើជាម្ចាស់ស្រុក និងអាចអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនដោយខ្លួនឯង។ ប្រហែលជាមកពីរបបសង្គមការស្តុនិយមចង់កាត់បន្ថយទំនិញនាំចូលមកពីបរទេសខ្លះ ហើយដើម្បីអភិវឌ្ឍន៍ប្រទេសឲ្យកាន់តែសម្បូណ៌នោះ ទើបមានបង្កើតឧស្សាហកម្មច្រើននៅក្នុងស្រុក ពិសេសកោងសិប្បកម្មត្បាញសូត្រ និងក្រណាត់ដែលផលិតផលទាំងអស់នោះមិនត្រឹមតែបំពេញសេចក្តីត្រូវការត្រប់គ្រាន់ក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងនាំយកទៅលក់នៅប្រទេសក្រៅទៀតផង។ យើងនិយាយនេះមិនមែនបានន័យថា មានតែផលិតផលក្រណាត់ឡើយដែលនាំចេញសូម្បីសំឡីកប្បាស រួមទាំងផលិតផលបានពីវិស័យកសិកម្មច្រើនទៀតក៏មាននាំចេញដែរ។

artisanal industries weaving silk and cloth. This silk and cloth production was intended not only to fill domestic demand, but also to be exported abroad. In addition to cloth, raw cotton and other agricultural products began to be exported.

During the Sangkum Reastr Niyum Period, the population was encouraged to modernise and, in terms of clothing, came to particularly embrace modern French fashions. Printed materials, such as the magazine *Our Village*, tried to show rural inhabitants how to dress and present themselves. As the magazine explained, "Before, men and women in our village did not know how to dress and make themselves up. Many women tied their hair back in buns and wore *sampot* wrapped so that their belly buttons were exposed. Sometimes they didn't even close their buttons!" Such habits of wearing clothing were considered inappropriate. In cities, decrees were issued ordering people to dress properly when they went to the markets or used public places. Even just to go outside one's home, the new decrees explained, one should not wear just a *krama* or a *sarong*. While such new decrees had some effect on city dwellers, they were generally ineffectual in the face of long-standing traditions and habits of dressing among the predominantly rural population as a whole. Some people embraced such new and modern notions,

បើនិយាយពីការស្លៀកពាក់ របបសង្គម
ក៏ស្ថិតនិយមហាក់ដូចជាចង់ឲ្យប្រជាពលរដ្ឋឈានទៅ
រកការពិនិត្យមួយតាមអារ្យធម៌បរទេស ពិសេស
បារាំង។ ឧទាហរណ៍ មានទស្សនាវដ្តីមួយឈ្មោះ "ភូមិ
យើង" បានចុះផ្សាយអប់រំពីការស្លៀកពាក់តុបតែងខ្លួន
ដល់អ្នកជនបទ ដោយគេបានសរសេរថា "ពីដើម
បុរសស្ត្រីទូទៅនៅភូមិយើង មិនចេះស្លៀកពាក់ ធ្វើ
ខ្លួនទេ បើស្ត្រីវិញ ច្រើនបួងសក់ពីក្រោយ ស្លៀក
សំពត់សំយេះក្បាលពោះនៅទទេ ហើយថែមទាំង
មិនបិទខ្សែក្រវ៉ាត់ផង"។ ចំណែកនៅទីក្រុងយើញមានចេញ
សេចក្តីប្រកាសឲ្យមនុស្សទូទៅក្នុងស្រុកស្លៀកពាក់ឲ្យ

while others found them destructive and bad. In particular, people living in the countryside were used to wearing *krama* and *sarong*, and did not alter such habits easily. Today, we still see people wearing *krama* and *sarong* in a way which the 1950s decrees wished to end.

Our research has relied almost entirely on interviewing elderly people. Our particular topic here - clothing and the care of the self - draws more on our interviews with elderly women than with elderly men, since this topic has traditionally played a greater role in the lives of women than in the lives of men. Our interviewees have provided us with



រូបលេខ ៦៖ ការគូរបង្ហាញរបៀបស្លៀកពាក់ឲ្យសមរម្យ។ ស្រង់ចេញពីទស្សនាវដ្តី "ភូមិយើង" ចុះខែមករា ឆ្នាំ១៩៦១។

Figure 6: A drawing contrasting proper and improper dress from *Our Village*, January 1961.



រូបលេខ ៧៖ នារីបម្រើលើយន្តហោះ ក្រុមហ៊ុនអាកាសចរណ៍ភូមិន្ទកម្ពុជា ស្លៀកពាក់ឯកសណ្ឋានបែបខ្មែរ (ខាងឆ្វេង) និងបែបទំនើប (ខាងស្តាំ)។ ថតទស្សវត្ស១៩៦០។ (រូបថត៖ ដកស្រង់ពីទស្សនាវដ្តីអាកាសចរណ៍ភូមិន្ទកម្ពុជា ឆ្នាំ១៩៩៧)

Figure 7: Royal Air Cambodge staff. The stewardesses wear (left) traditional Khmer and (right) more modern uniforms. Photographed in the 1960s. (Photo: RAC Magazine, 1997)

ជានសមមម្យពេលចេញដើរតាមផ្សារ ឬទីសាធារណៈ ផ្សេងៗ សូម្បីតែចេញទៅក្រៅបង់ផ្ទុះក៏ដោយ ក៏មិនត្រូវស្លៀកក្រមា ឬសារុងឡើយ។ ការចេញច្បាប់រឿងស្លៀកពាក់នេះ ទោះជាបានជ្រាបចូលខ្លះចំពោះអ្នកទីក្រុងក៏ដោយ តែក៏មានផលប៉ះពាល់ខ្លះៗទៅលើទម្លាប់ស្លៀកពាក់របស់គេពីមុនមកដែរ ជានន័យថា អ្នកខ្លះគេពេញចិត្តយកភាពទំនើបនេះ អ្នកខ្លះទៀតគេយល់ថាភាពទំនើបមិនល្អទៅវិញ។ ជាពិសេសចំពោះអ្នកស្រុកស្រែ បើនិយាយពីការស្លៀកសារុង ក្រមា ក្លាយជាទម្លាប់មួយដែលមិនងាយនឹងចោលជាន។ រហូតដល់សព្វថ្ងៃ ការស្លៀកសារុង ក្រមានៅតែមានដែរ។

ក្នុងការស្រាវជ្រាវនេះ យើងផ្តោតសំខាន់ទៅលើប្រភពពត៌មានជានមកពីការសាកសួរមនុស្សចាស់ៗ។ ពត៌មានទាក់ទងទៅនឹងប្រធានបទដែលយើងកំពុងធ្វើនេះភាគច្រើនទទួលជានពីមនុស្សស្រី ពីព្រោះរឿងរ៉ាវទាំងអស់នោះទាក់ទងនឹងជីវិតមនុស្សស្រីច្រើនជាងបុរស។ ជួនកាលពួកគាត់ផ្តល់ទាំងរូបថតចាស់ដែលសេសសល់តាំងពីជំនាន់មុន ព្រមទាំងគូរបង្ហាញជារូបប្រកេទសម្លៀកបំពាក់ដែលគាត់ធ្លាប់ប្រើតាំងពីក្មេងរហូតមក។

ផ្ទៀតក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអំណរគុណដល់លោកតា លោកយាយទាំងអស់ដែលជានផ្តល់ពេលវេលាក្នុងការសំណេះសំណាល និងសាកសួរ។ យើងខ្ញុំសូមអភ័យទោសដែលមិនជានរាយឈ្មោះអស់ ដោយលើកយកតែឈ្មោះលោកតា old photographs which they have saved from the past. They have also drawn pictures of the types of clothing they wore when they were little.

We would like to thank the many elderly people who took the time to be interviewed and answered our questions patiently. We apologize that we cannot include all their names in the text that follows. We thank the following institutions for generously allowing us to access and use

រូបលេខ ៨៖ សម្លៀកបំពាក់ទំនើប បង្ហាញលើក្របទស្សនាវដ្តីលោកសេរី ចោះពុម្ពក្នុងទសវត្សរ៍១៩៥០។ (ភ្ជាលទី៥, លេខ២)

Figure 8: Modern fashion presented on the cover of the United States Information Service magazine *Lok Serei* (*Free World*) published in the 1950s (vol. 5, #2).

លោកយាយខ្លះដែលយកមកប្រើក្នុងសៀវភៅនេះតែប៉ុណ្ណោះ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ស្ថាប័នផ្សេងៗ ដូចជាបណ្ណាល័យជាតិ, បណ្ណសារដ្ឋានជាតិ, បណ្ណាល័យសារមន្ទីរជាតិ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, បណ្ណាល័យមហាវិទ្យាល័យបុរាណវិទ្យា, មជ្ឈមណ្ឌលឯកសារកម្ពុជា, បណ្ណាល័យកណ្តាលក្រសួងអប់រំជាដើម ដែលជួយផ្តល់ឯកសារក្នុងការស្រាវជ្រាវ។

ម្យ៉ាងទៀតសូមថ្លែងអំណរគុណចំពោះលោកអាំង ជូលាន, ម៉ៃខឺល វិកខឺរី ដែលបានផ្តល់យោបល់និងជួយជាគំនិតក្នុងការនិពន្ធ។ ក្នុងឱកាសនេះដែរយើងខ្ញុំសូមថ្លែងអំណរគុណដល់លោកលី តារាវុធ និងលោកស្រីអ៊ីនត្រីដ មូអាន់ ដែលបានណែនាំនិងបង្ហាត់បង្រៀនកិច្ចការស្រាវជ្រាវ ព្រមទាំងបណ្តុះបណ្តាលយើងខ្ញុំ។ ម្យ៉ាងទៀត ក៏សូមអរគុណដល់បុគ្គលិកវៃឃំទាំងអស់ដែលបានជួយក្នុងការងារនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិដែលបានផ្តល់ជំនួយថវិកាសម្រាប់ការស្រាវជ្រាវ និងបោះពុម្ពសៀវភៅនេះគឺ៖ មូលនិធិរ៉ុកហ្វែល័រ, មូលនិធិ កាស៊ុមីស៊ូ, មូលនិធិ ត្រួសារអាល់ប៊ែរ ឃុនស្តាតធ័រ។

their documents: the National Library of Cambodia, the National Archives of Cambodia, the library of the National Museum of Cambodia, the Buddhist Institute, the library of the Royal University of Fine Arts, the Documentation Center of Cambodia, and the Banneahoc Library of the Ministry of Education. We thank Dr. Ang Choulean and Dr. Michael Vickery for advising us and providing ideas for this project. We also wish to thank Ly Daravuth and Dr. Ingrid Muan for advising, supporting and helping us in realising this project. We thank all of the Reyum staff as well for their help and commitment to our project.

This project was funded by the Rockefeller Foundation with additional support provided by the Kasumisou Foundation and the Albert Kunstadter Family Foundation. We thank these Foundations for their generous support which has enabled us to pursue and publish this research. Any mistakes or confusing passages are of course our own responsibility and we hope that readers will take this book as an invitation to do more research on the topics sketched here.

ប្រភេទសម្លៀកបំពាក់
TYPES OF CLOTHING

បើយោងតាមការសាកសួរចាស់ទាក់ទងនឹងជីដូនជីតារបស់គាត់ យើងអាចដឹងបានថា ប្រភេទសម្លៀកបំពាក់ដែលគាត់ធ្លាប់ស្លៀកពាក់មានដូចជា សំពត់ចងក្បិន (ស្លៀកបានទាំងប្រុស ទាំងស្រី), សំពត់សម្ពុយ, ខោចិន (ថ្នេរ៣, ថ្នេរ៥), អាវបំពង់វែង, អាវម៉ាឡាយូ, អាវចិន, អាវសន្ទះជាដើម។ ក្រោយពេលដែលបារាំងចូលមកឆ្នាំ១៨៦៣មានសម្លៀកបំពាក់ខ្លះ គេពាក់តាមបារាំង។ ការទទួលឥទ្ធិពលពីបារាំងនេះមិនមែនមានន័យថា បារាំងចូលមកភ្លាម ខ្មែរធ្វើតាមនោះទេ។ ដំបូងជាការនិយមម៉ូតថ្មី ឬជាការស៊ីវិល័យរបស់មនុស្សមួយចំនួន ពិសេសអ្នកនៅភ្នំពេញ និងអ្នកធ្វើការជាមួយបារាំងតែប៉ុណ្ណោះ។ រហូតដល់ទសវត្ស១៩៤០ ការនិយមម៉ូតតាមបារាំងកាន់តែខ្លាំងឡើង។ អ្នកនិយមម៉ូត ឬរបស់ប្រើប្រាស់តាមបារាំងដំបូងគេផ្ញើទិញពីស្រុកបារាំងដោយរើសម៉ូតតាមសៀវភៅកាតាឡុក ព្រោះនៅស្រុកខ្មែរមិនទាន់មានលក់។ គេច្រើនផ្ញើមកវិញតាមកប៉ាល់ រយៈពេល៣ទៅ៤ខែទើបមកដល់។ សម្លៀកបំពាក់បារាំងមានដូចជាអាវបើកក, អាវសឺមិ, អាវភីសាម៉ា, អាវយឺត, អាវរ៉ូប, ខោបារាំងជើងវែង, ខោបារាំងជើងខ្លីជាដើម។ ខ្លះទៀតគេបានចម្លងម៉ូតពីបរទេសខ្លះ មានបារាំង, ចិន, យួន, សៀមជាដើម និងបញ្ចូលរបៀបខ្មែរខ្លះ។ ចំពោះរបៀបកាត់ដេរខោអាវគឺគេកាត់ដោយផាស់លើខ្លួនមនុស្សផ្ទាល់ ឬយកអាវចាស់មកធ្វើជាគំរូ។ គេដេរដោយដៃទម្រាំបានអាវ

From asking elderly people about the clothing their grandparents wore, we find that they generally wore clothing such as the *sampot* tied in the *kben* style (worn by both men and women), the *sampot* worn in the *samloy* style, the Chinese pant (three or five seam), the long tube shirt, the *malayu* shirt, the Chinese shirt, and the *santeh* shirt. After the French established a Protectorate over the area today known as Cambodia in 1863, some types of French clothing began to be worn by local inhabitants. The use of French clothing occurred gradually. In the beginning, French clothing was worn out of a love for the new or the feeling that such clothing was more *civilisé*, an attitude found particularly among those living in Phnom Penh and working with the French. Appreciation of French style clothing became more and more common however as the early 20th century progressed. At first, those wanting French fashions or French goods had to choose them from illustrated catalogues, asking those traveling to France to buy them there, since such things were not yet available for sale in Cambodia. Such ordered goods were shipped by sea and arrived three to four months after an order was placed. French style clothing adopted by locals included open necked shirts, pajamas, robes, and French style long pants and shorts. Other borrowings combined French, Chinese, Vietnamese, and

មួយត្រូវប្រើពេលយូរ ដោយសារមិនទាន់មានម៉ាស៊ីនដេរ។ ក្នុងតំនិតរបស់គេសម្លៀកបំពាក់គ្រាន់តែជាគ្រឿងសម្រាប់បិទបាំងរាងកាយ ដូច្នេះគេច្រើនកាត់ឲ្យរលុង មិនបង្ហាញរាង។ នៅទសវត្សរ៍១៩៤០ ឃើញមានតែងខ្លួនស្លៀកពាក់ស៊ីវិល័យតាមរបៀបពួកបស្ចិមប្រទេសច្រើន ពិសេសអ្នកទីក្រុង គេចាប់ដេរសម្លៀកបំពាក់ ដោយមានបញ្ចូលរាងដើម្បីបង្ហាញខ្លួន។ ទន្ទឹមនឹងនោះដែរ មានខ្លះពុំទាន់យល់ពីការស្លៀកពាក់បែបទំនើបនៅឡើយ។ នៅឆ្នាំ១៩៤៩ ឃើញមានបង្កើតសមាគមមួយឈ្មោះ "សមាគមខេមរសហជីវិនី" សម្រាប់បង្ហាត់បង្រៀនពីរបៀបរស់នៅក្នុងសង្គមទំនើប។ សមាគមនោះបង្កើតគណៈកម្មការ៤ (គណៈកម្មការសុជីវធម៌, សម្លៀកបំពាក់, គោជនាហារ និងគណៈកម្មការផ្សាយទស្សនាវដ្តី) ក្នុងនោះគេបង្កើតទស្សនាវដ្តីមួយឈ្មោះថា "ទស្សនាវដ្តីនារី" ដើម្បីជួយឲ្យស្ត្រីខ្មែរ ចានដឹងពីរបៀបប្រើសំពត់អាវឲ្យសមរម្យ។ តាមទស្សនៈ និងខ្លឹមសារក្នុងទស្សនាវដ្តីនោះពាក្យថា "សមរម្យ" មានន័យថា មានលក្ខណៈជាប្រពៃណីផង និងទំនើបផង។ គេហាក់ដូចជាមានការភ័យខ្លាចថា ភាពទំនើបនោះអាចជ្រុលហួសហេតុពេក។ មានអ្នកខ្លះមិនចូលចិត្តទំនើបសោះ ហើយថែមទាំងប្រឆាំងនឹងរបៀបតែងខ្លួនបែបទំនើបនេះទៀតផង។ នៅក្នុងឆ្នាំសិក្សា១៩៥១–១៩៥២ គេបានចងក្រងជាមេសូត្រត់មាត់ ដើម្បីបង្រៀនសិស្សគ្រប់ថ្នាក់អំពីការស្លៀកពាក់ដូចតទៅ៖

Thai elements with existing Khmer styles to create new hybrid types of clothing.

During the early 20th century, clothing was made by measuring and cutting cloth on the individual person for whom the piece of clothing was intended, or by using an old piece of clothing as a model. All sewing was by hand, and clothing took a long time to make since sewing machines were not yet available. At that time, clothing was seen as something simply to cover the body, and garments were cut loosely rather than hugging and showing off the body. In the 1940s, it became quite popular to wear clothing in foreign styles, particularly among city dwellers who began to cut their clothes to be form-fitting. Many people did not however understand the new styles of clothing that were considered modern. In 1949, the Association of Women was established to educate people about how to live in modern society. The Association formed four committees (on morality, clothing, food, and publicity) as well as publishing the magazine *Neary* which aimed to help a general readership understand how to dress in a manner the magazine considered proper. According to the Association and its magazine, proper attire combined the traditional with the modern, without the modern overpowering the traditional. There were some people who did not like the new, and who objected to modern ways of dress-

" សម្លៀកបំពាក់ "

កាលពីបុរាណ ជាតិខ្មែរត្រប់ប្រាណ សម្លៀកត្រូវគ្នា សំពត់ចង់កន្ទិន ខ្លះមានភ្ជីផ្កា ស្រីប្រុសត្រប់គ្នា រក្សាទម្លាប់។ ទំនៀមចាស់ៗ កូនចៅចាំច្បាស់ ក៏ពេញចិត្ត តាប់ បំពេញសោតទៀត ក៏តាមទម្លាប់ តាមសណ្តាប់ធ្នាប់ ជាប់ដល់សព្វថ្ងៃ។ អាវខ្មែរជាន់នោះ ទាំងស្រីទាំងប្រុស ប្លែកខុសសម័យ ប្រុសប្រើកត្រង់ ប្តុំថ្កើងពេកក្រៃ ចំណែកឯស្រី ប្រើអាវបំពង់។ ខាងក្រោមវែងយារ ព័ទ្ធស្រោបអាត្មា ធ្លាក់ដល់ជង្គង់ បង់តក្រមា សំយុងតាមអង្គ ប្រុសស្រីក៏គង់ មានបង់ត្រប់គ្នា។ សក់កាត់ជ្រងខ្លី ទាំងប្រុសទាំងស្រី ឥតវែងយូរយោរ ប៉ុន្តែខ្មែរឆាប់ យកតម្រាប់គ្នា តាមជាតិនា ប្រើជាបៃបថ្មី។

(ដកស្រង់ពី ទស្សនាវដ្តីសម្រាប់គ្រូបង្រៀន លេខ៥ ឆ្នាំ១៩៥១-៥២។)

នៅក្នុងទសវត្ស១៩៤០នោះដែរ យើញមានការបង្រៀន ឬបង្ហាញពីរបៀបកាត់សម្លៀកបំពាក់មួយបៃបទៀត ដែលយកតាមលំនាំពីបរទេសនិងដេរដោយម៉ាស៊ីន។ នៅទសវត្ស១៩៦០ ឧស្សាហកម្មកាន់តែរីកចម្រើន ធ្វើឲ្យការប្តែប្រខិតម៉ូតកាន់តែទំនើបទៅៗ គេចាំបាច់ត្រូវប្តែអ៊ីវឲ្យកាន់តែងាយស្រួល និងសម្បុណ្ណឡើង។ បច្ចុប្បន្ននេះ មានប្រភេទសម្លៀកបំពាក់កាន់តែច្រើនឡើងៗ ដោយសារការនាំចូលនូវសម្លៀកបំពាក់បរទេស ពិសេសខោអាវជជុះ និងមានរោងចក្រកាត់ដេរសម្លៀកបំពាក់កាន់តែច្រើនឡើងសម្រាប់នាំចេញ។

ing. In 1951-2, school curriculums included the following passage:

Clothing

Since long ago, all Khmer wore the same clothing: the sampot tied in the kben style. Some had patterns. Both women and men followed this tradition. Children, remember these traditions clearly, love them, and follow them. Thus traditional order has been passed down to the present. Khmer shirts before, both for male and female, were different than they are today. The men wore magnificent straight collar shirts, while the women wore long tube shirts which hung down to their knees, surrounding their bodies. Men and women wore krama around their necks, hanging down along their bodies. Hair was cut short and stood straight for both men and women. It wasn't long and hanging down. But the Khmer were quick to take models from other countries and use them as new modes." (*Magazine for School Teachers*, #5 1951-2)

In the 1940s, foreign styles of clothing began to be made on sewing machines. By the 1960s, the country was industrialising and more and more types of fashion were available. It was necessary to create comfortable clothing in an ever increasing variety of styles. Today, more and more types of clothing are available because of the import of foreign types of clothing, especially second-hand clothing. Cambodia also hosts more and more garment factories making clothing exclusively for export. Thus clothing today is made using the agreed upon system of inter-

ដូច្នេះគេចាំបាច់ត្រូវមានកម្រិតខ្នាតច្បាស់លាស់តាម
អន្តរជាតិ ទោះជាជនជាតិណាក៏អាចពាក់បានដែរ។
សព្វថ្ងៃនេះ មានការនិយមម៉ូតថ្មីៗ និងច្នៃឲ្យកាន់តែ
ប្លែកៗទាន់សម័យ ដោយគេយល់ថាភាពស្អាតរបស់
មនុស្សស្ថិតលើសម្ភារៈ មានខោអាវ ការតុបតែងខ្លួន
គ្រឿងអលង្ការជាដើម។

ចំពោះការហៅឈ្មោះសម្លៀកបំពាក់នីមួយៗ
ខ្មែរតែងហៅទៅតាមរូបរាងរបស់អាវ មានអាវបំពង់
វែង, អាវបំពង់, អាវសន្ទះ, អាវខ្លីជាដើម។ ពេលខ្លះ
ធ្វើឲ្យយើងច្រឡំ ដូចជាអាវសន្ទះ អ្នកខ្លះទៀតហៅ
អាវបំពង់។ តែអាវបំពង់ខ្លះ គេប្រើសម្រាប់ហៅអាវ
មួយប្រភេទផ្សេងទៀត ស្រេចតែលើការនិយមនៅ
តាមស្រុកភូមិរបស់គេ។ ជួនកាលគេហៅប្រភេទ
សម្លៀកបំពាក់តាមជនជាតិដែលគេយើញពាក់អាវ
នោះដំបូងគេ ដូចជាអាវចិន, ខោចិន, អាវម៉ាឡាយូ,
ខោបារាំង, អាវកជប៉ុនជាដើម។ ទោះបីជាខ្មែរខ្លួនឯង
ជាអ្នកកាត់ ជាអ្នកពាក់ ពិសេសក្លាយទៅជាសម្លៀក
បំពាក់ប្រពៃណីទៅហើយក៏ដោយ។ យោងតាមការ
សាកសួរចាស់ៗ ខាងក្រោមនេះយើងសូមលើកយក
សម្លៀកបំពាក់ដែលខ្មែរធ្លាប់មានពីមុន ហើយដែល
បច្ចុប្បន្ន ខ្លះស្ទើរតែបាត់បង់ទៅហើយមកពន្យល់៖

national sizes so that anyone all over the world can wear it. Today we see a love for new fashion and a desire for more and more different clothing. The beauty of people is seen to lie in their clothing, their jewelry, and the way in which they make themselves up.

The Khmer language seems to name types of clothing by characteristic features of the clothings' shape (the long tube shirt, the *santeh* shirt, the short shirt, etc). Sometimes however, the names are not so definitive, and some people call the *santeh* shirt (named for its panel inset at the neck) the tube shirt (after the shape of its body). We also note a difference in the names of clothing in various regions and across various provinces. Sometimes the name for a type of clothing comes from the ethnicity first wearing such a garment (the Chinese shirt, the Chinese pant, the *malayu* shirt, and the French pants) even though Cambodians make such clothing and have come to wear them with such regularity that these types of clothing have become traditional. In what follows, we describe some kinds of clothing that people liked to wear in the past. Our descriptions rely on information provided by our elderly interviewees.

ក- អាវបំពង់

អាវបំពង់មានពីរប្រភេទ គឺអាវបំពង់វែង និង
អាវបំពង់ខ្លី។ អាវបំពង់វែងមានខ្លួនកាងដូចបំពង់ វែង
ដល់ក្រោមក្បាលជង្គង់ និងដៃកាងស្តួចវែងដូចស្រោម
ដាវ (រូបលេខ៩)។ នៅពីចំហៀងអាវនេះ បើពិនិត្យ
មើលទៅឃើញមានក្រណាត់ពីរផ្ទាំងដេរភ្ជាប់គ្នាហៅ
ថា ប៉ែក។ គេតប៉ែកដើម្បីឲ្យទូលាយ ងាយស្រួល
ដើរ។ ត្រង់ក្លៀកទាំងសងខាងមានក្រណាត់មួយផ្ទាំង
ដេរភ្ជាប់ពីដៃមកប៉ែកហៅថា ហោជ៉ោ។ ហោជ៉ោនេះ
មិនមែនសំដៅលើហោជ៉ោសម្រាប់ដាក់លុយទេ គឺ
ដើម្បីឲ្យទូលាយត្រង់ក្លៀក ងាយនឹងឈោង ឬលើក
ដៃ។ អាវនេះមានដៃតូចស្តួចវែងចុះរហូតដល់កដៃ
មានកមូលតូចប៉ុនកមនុស្ស ហើយពុះមុខថ្នាក់ចុះរហូត
ដល់ចុងដង្ហើមដោយមានចាប់តូនជាការលំអ និង
ដើម្បីខ្ជិបចុងផែកផង។ ការចាប់តូននេះ ខ្លះចាប់ចេញ
ជារាងសត្វពីងពាង ខ្លះចាប់ចេញជារាងមេអំបៅ

The tube shirt

There were two kinds of tube shirts: the long tube shirt and the short tube shirt. The long tube shirt had a long, tube-like body, falling to below the knees, with narrow tapered long sleeves said to be shaped like the sheath of a sword (figure 9). On each side of the body of the shirt, an additional strip of cloth, called the *bak*, was added to make the shirt looser and easier to walk in. A diamond shaped insert, called the *hou bau,* was added to each underarm (*hou bau* also means pocket, but in this case these inserts do not have that function). The *hou bau* made it easier to stretch out or raise the arms while wearing the shirt. The shirt had narrow long sleeves which extended to the wrists of the wearer. Sometimes an extra piece of cloth was added to the end of the sleeve for persons with espe-



ផ្នែកខាងមុខ

Front of the shirt

រូបលេខ ៩៖ អាវបំពង់វែង។

Figure 9: The long tube shirt

ផ្នែកខាងក្រោយ។

Back of the shirt



រូបលេខ ១០៖ ចាប់កូនរាងសត្វព័ទ្ធពាង់នៅចុងថែកផ្នែកខាងមុខអាវបំពង់វែង។

Figure 10: The puckered point at the bottom of the neck slit of a long tube shirt, said to be shaped like a spider. (Photo: Reyum)

រូបលេខ ១១៖ ខ្សែចងខាងមុខកអាវបំពង់វែង ដោយវេញអំបោះស៊ីកសម្រាប់ចង។

Figure 11: Detail of a long tube shirt with the neck slit closed at the top by inserting cotton thread in the seams on each side of the neck and tying the thread together. (Photo: Reyum)

(រូបលេខ១០)។ ត្រង់កអាវ ជួនគេវេញអំបោះស៊ីក តាមថ្នេរកអាវសម្រាប់ចង (រូបលេខ១១) ជួនគេដាក់ ឡេវកិបមួយគ្រាប់ ជួនគេមានកន្ទាស់ត្បូងកណ្តៀង ឬ ពេជ្រសម្រាប់ខ្ចាស់ ដោយមិនចាច់ប្រើខ្សែ ឬឡេវ កិប។ អាវបំពង់វែងពីមុនគេកាត់រាងរលុង តែក្រោយ មក (ប្រហែលទសវត្ស១៩៤០) គេកាត់រីបរាងត្រង់ ចង្កេះ ហើយរីកខាងក្រោម ពិសេសអ្នកទីក្រុង។ ការ ផ្លាស់ប្តូរនេះប្រហែលមកពីពេលនោះមានម៉ូតច្រើនមក ពីបរទេស ពិសេសប្រទេសបារាំងដែលនិយមរីបរាង ដែលគេយល់ថាស្អាត ទើបខ្មែរធ្វើតាមដោយយកមក ច្នៃលើសម្បៀកបំពាក់របស់ខ្លួន។ អាវបំពង់វែងនេះ មានអ្នកខ្លះហៅថាអាវវែង។

cially long arms or if there was insufficient cloth to make the sleeves long enough. The shirt had a small round neck, about the size of the neck of the wearer, and the neck opened in a slit which ran down the chest in the front. A decorative point of cloth, gathered into a pucker and sometimes shaped like a spider or a butterfly marked the bottom of this slit (figure 10). Although this pointed pucker was primarily decorative, it also helped to prevent the split from running or unraveling further. Sometimes a cotton string was used to tie the neck closed at the top by threading a string through both sides of the neck seam and tying the string together in a bow (figure 11). Other

អាវបំពង់វែងជាអាវសម្រាប់ស្រីចាប់ពីវ័យជំទង់រហូតដល់ចាស់។ គេអាចពាក់បាននៅពេលធ្វើការងារស្រែចម្ការ នៅផ្ទះ ធ្វើដំណើរទៅឆ្ងាយ និងក្នុងពិធីបុណ្យផ្សេងៗ គ្រាន់តែខុសគ្នាត្រង់ក្រណាត់ដែលយកទៅកាត់។ អាវបំពង់វែងដែលកាត់ពីព្រៃពណិ ព្រៃមុយអា ឬទេសឯក សម្រាប់ពាក់ចូលរួមក្នុងពិធីបុណ្យទានផ្សេងៗ។ ចំណែកអាវដែលកាត់ពីក្រណាត់ផាឌិបខ្មៅ សម្រាប់ពាក់ទៅស្រែចម្ការ។ លោកយាយភី អាយុ៨៣ឆ្នាំ នៅស្រុកអង្គស្នួល ខេត្តកណ្តាល និយាយប្រាប់ថា "អាវបំពង់វែងកាត់ពីក្រណាត់ល្អ ពេលអង្គុយមិនអង្គុយពីលើអាវទេតឹលាត់អាវឡើងត្រឹមចង្កេះទើបអង្គុយ។ ធ្វើបែបនេះដើម្បីកុំឲ្យអាវសឹក ធាប់ចាស់"។

នៅសម័យបុរាណ យើងសង្កេតឃើញតាមចម្លាក់ តាមឯកសារផ្សេងៗខ្មែរអត់មានពាក់អាវឡើយ គឺគ្រាន់តែមានស្បៃរុំជារបៀបចោមពុងតែប៉ុណ្ណោះ។ រហូតដល់បច្ចុប្បន្នក៏នៅមានអ្នកខ្លះនៅរុំក្រមា ឬក្រណាត់ជារបៀបចោមពុងពេលនៅផ្ទះដែរ។ ចំពោះអាវបំពង់វែងនេះ យើងមិនដឹងថា មាននៅពេលណាឡើយ គ្រាន់តែដឹងថានៅចុងសតវត្សទី១៩ មានគេពាក់អាវនេះច្រើន ស្ទើរគ្រប់ទីកន្លែង។ បើយោងតាមការសាកសួរចាស់ទាក់ទងនឹងជីដូនជីតារបស់គាត់ យើងអាចដឹងថា អាវបំពង់វែងនេះមានពាក់តាំងពីមុនបារាំងចូលមកធ្វើអាណាព្យាបាលម៉្លេះ។ យើងពុំអាចដឹងថាអាវប្រភេទនេះមានប្រភព ឬទទួលឥទ្ធិពលពី

times, a small button was sewn at the neck so that the slit could be closed. Some wealthy people used small pins with sapphires or diamonds to hold the two sides of the neck together. Whereas earlier the long tube shirt was cut to hang loosely, beginning in the 1940s, the shirt began to be cut to fit the body tightly to the waist and then flare out at the bottom. It was particularly city dwellers who began to wear such closer fitting long tube shirts, perhaps influenced by foreign fashions, particularly French clothing which was cut to contour the body. Seeing these styles and finding them attractive, Khmer people started to modify their own ways of dressing accordingly. The long tube shirt was also sometimes simply called the long shirt.

The long tube shirt was generally worn by women of all ages. It was a versatile piece of clothing that was worn when working in the fields, when at home, when traveling, or for various ceremonial occasions; shirts made of different quality materials were worn for these different contexts. Long tube shirts made of colored *prai*, *prai muy a*, or black *des aik* were generally worn on ceremonial occasions, while shirts cut from black *pa dip* were worn for working in the fields. Phi, 83 years old living in Kandal Province, told us, "When you sat wearing a long tube shirt made of good material, you wouldn't sit on the shirt. Instead, you would lift the shirt up

រូបលេខ ១២៖ ក្មេងស្រីម្នាក់ពាក់អាវបំពង់វែងពណ៌ស ស្បៃកសំពត់សម្លុយ។ ថតឆ្នាំ១៩០២។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 12: A girl wearing a long white tube shirt over a *sampot* tied in the *samloy* style. Photographed 1902. (Photo: National Archives of Cambodia)

រូបលេខ ១៣៖ រូបស្ត្រីជាច្រើនពាក់អាវព្រៃបំពង់វែងនៅពេលប្រកួតការថែរក្សាក្មេង។ ថតឆ្នាំ១៩២៥។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 13: A group of women wearing silk long tube shirts at a competition in child care, 1925. (Photo: National Archives of Cambodia)

ណានោះឡើយ។ តែយើងដឹងថា ចាម ជ្វា មានពាក់អាវស្រដៀងនេះដែរ គឺអាវម៉ាឡាយូ។ បើតាមលោកយាយមុម សំអឿន អាយុ៧៦ឆ្នាំ និយាយថា "អាវបំពង់វែងប្រហែលទទួលឥទ្ធិពលពីពួកម៉ាឡេ ដោយសារអាវម៉ាឡាយូមានរាងស្រដៀងអាវបំពង់វែងដែរ ខុសគ្នាតែដៃ និងកមានសន្ទះមុខ"។

មកដល់សព្វថ្ងៃនេះមានមនុស្សស្រីចំណាស់តិចតួចបំផុត ដែលនៅពាក់អាវបំពង់វែងនេះ។ តែមិនពាក់រាល់ថ្ងៃដែរ គឺពាក់តែពេលបុណ្យមួងម្ភាលប៉ុណ្ណោះ។ តាមលោកយាយមុិច អាយុ៨៩ឆ្នាំ នៅ

to the waist before sitting. This was done so that the shirt would not become worn and old quickly."

From looking at sculptures and various other documents, we see that in ancient times, the Khmer did not wear sewn shirts. Instead, they simply took lengths of cloth and wrapped them around their bodies to cover the area from the upper chest to the knees as some people still do today when they are at home, using ***krama*** (the characteristic checked scarf) or simple lengths of cloth.

រូបលេខ ១៤៖ ស្ត្រីពាក់អាវបំពង់វែង ស្លៀកសំពត់សម្ពុយ នៅខេត្តស្វាយរៀង ទសវត្ស៤០។ (រូបថត៖ គ្រួសារលោកតាជុំ កេន)

Figure 14: Women from Svay Rieng Province wearing long tube shirts with *sampot* tied in the *samloy* style. Photographed in the 1940s.
(Photo: Family of the late Jum Kain)

រូបលេខ ១៥៖ យាយទី២ពាប់ពីខាងស្តាំ ពាក់អាវបំពង់វែងពាក្រមាពណ៌ស។ ថតពេលបុណ្យចូលឆ្នាំថ្មី នៅវត្តភ្នំតាពែក ក្នុងខេត្តកណ្តាល នៅទសវត្ស៥០។ (រូបថត៖ គ្រួសារតាមាត)

Figure 15: A photograph taken at Wat Phnom Ta Prek in Kandal Province in the 1950s on the occasion of Khmer New Year. The woman seated second from the right wears a long tube shirt with a white *krama* wrapped diagonally across her chest.
(Photo: Family of Meak)

ស្រុកមុខកំពូល ខេត្តកណ្តាល រៀបរាប់ថា "សព្វថ្ងៃខ្ញុំនៅពាក់អាវនេះ ព្រោះខ្ញុំស្រឡាញ់។ ម្យ៉ាងទៀត ដោយសម្លៀកបំពាក់នេះសល់ពីសម័យមុន ខ្ញុំមិនចង់ចោះបង់ចោលទេ។ ខ្ញុំច្រើនពាក់ពេលបុណ្យទាននិងពេលទៅវត្តម្តងៗ។ ពីមុនខ្ញុំមានតែសម្លៀកបំពាក់២-៣សម្រាប់តែប៉ុណ្ណោះ មិនសម្បូណិដូចឥឡូវទេ ហេតុនេះទើបខ្ញុំទម្លាប់ថែរក្សាបានល្អ" (រូបលេខ១៨)។

នៅពេលបច្ចុប្បន្ននេះ គេលែងនិយមពាក់អាវបំពង់វែង ដោយសារអាវនេះប្រើក្រណាត់ច្រើនពេក (អាវមួយប្រើក្រណាត់៤ម៉ែត្រទៅ៤ម៉ែត្រ៥តឹក) ម្យ៉ាងទៀតមកពីហួសសម័យ ព្រោះមានប្រភេទអាវផ្សេងទៀតដែលគេថ្នៃតាមរបៀបប្លែកៗច្រើន។ បើ

We do not know when the long tube shirt first appeared in the region today known as Cambodia, but by the late 19th century it was being worn by many people throughout the region. By asking the elderly about their own grandparents, we have found that the long tube shirt was probably already being worn before the French established their Protectorate. We do not know the origin of the shirt or what influences it came to incorporate, but we do know that Cham and Javanese people wore a similar kind of shirt, sometimes called the *malayu* shirt. Mom Samuen, 76 years old, told us, "The long tube shirt perhaps was influenced by the Malay,

រូបលេខ ១៦៖ ស្ត្រីពាក់អាវបំពង់វែងពេលទៅបុណ្យ។ គំនូរលើជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០។ (រូបថត៖ រៃយ៉ំ)

Figure 16: A woman (center) going to a ceremony wearing a long tube shirt, as painted on the walls of Wat Kompong Tralach Leu, early 20th century. (Photo: Reyum)

តាមលោកយាយធាយ លីមយីម អាយុ៨២ឆ្នាំ នៅខេត្តកណ្តាល និយាយថា "ខ្ញុំពីដើមពាក់តែអាវបំពង់វែង បួងសក់។ រហូតដល់ឆ្នាំ១៩៥៩ មកនៅភ្នំពេញ ខ្ញុំកាត់សក់ខ្លី ឈប់ពាក់អាវបំពង់វែង ដោយសារខ្មាស់គេ។ ព្រោះមានពាក់តែម្នាក់ឯង ហើយពេលពាក់អាវនេះមើលទៅដូចចាម"។ មានន័យថា នៅឆ្នាំ ១៩៥៩ អ្នកនៅភ្នំពេញគេលែងនិយមពាក់អាវបំពង់វែងហើយ មានតែអ្នកនៅស្រុកស្រែចម្ការនៅមានពាក់នៅឡើយ។ ចាប់តាំងពីពេលនោះមក អាវនេះមិនសូវមានទេ ហើយសព្វថ្ងៃនេះកម្រឃើញមានពាក់ណាស់ លើកលែងតែនៅពេលមានពិធីបុណ្យ។

since the *malayu* shirt has a very similar shape and differs only in the sleeves and its *santeh* [panel front]."

Today, the long tube shirt is only worn by a few elderly women, and only on rare occasions for special ceremonies. Mich, 89 years old living in Kandal Province, told us, "Today, I still wear that shirt because I like it. Also I still have the shirt and don't want to throw it away. I mostly wear it on ceremonial occasions and when I go to the *wat* [temple]. Before I only had two or three pairs of clothing, not like today when clothing is plentiful. Therefore, I am used to taking very good care of my clothing."

Today, people have stopped wearing the long tube shirt, partly because one shirt required a lot of cloth to make (two meters or more), and partly because the shirt is considered to be no longer fashionable. There are many other kinds of shirts available on the market now. Chay Lim Khim, 82 years old living in Kandal Province, told us, "Earlier, I only wore a long tube shirt and tied my long hair in a bun. Then in 1959 I came to Phnom Penh and I cut my hair short and stopped wearing the long tube shirt. I was the only one wearing long tube shirts so I was embarrassed. When I wore it, I looked like a Cham." We can see then that, by the late 1950s, city dwellers in Phnom Penh had already stopped wearing the long tube shirt,

រូបលេខ ១៧៖ នាត់អាវបំពង់វែងពេលធ្វើការ។ ដកស្រង់ចេញពីសៀវភៅ Cambodia Land of Contrasts, ដោយ Ruth Tooze, 1962។

Figure 17: A woman wearing a long tube shirt while working in the late 1950s. (Photo: *Cambodia Land of Contrasts*, Ruth Tooze, 1962)

រូបលេខ ១៨៖ លោកយាយមុិច (ស្តាំ) អាយុ៨៩ឆ្នាំ ខេត្តកណ្តាល និងអ្នកជិតខាង។ បច្ចុប្បន្នទៅនាត់អាវបំពង់វែងនេះពេលទៅបុណ្យម្តងៗ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 18: Mich (right), 89 years old living in Kandal Province standing with her neighbor, both wearing long tube shirts. Photographed 2003. (Photo: Reyum)

ការកាត់អាវបំពង់វែង មានកាត់តួខ្លួន ប៉ែក ហោជ៉ៅ និងដៃ។ ដោយសារអាវបំពង់វែង និងអាវ ម៉ាឡាយូស្រដៀងគ្នា ហើយវិធីកាត់ក៏ដូចគ្នា ដូច្នេះ សូមមើលពីរបៀបកាត់អាវនេះ នៅត្រង់ចំណុចដែល និយាយពីវិធីកាត់អាវម៉ាឡាយូនៅទំព័រ៣២។

ចំណែកឯអាវបំពង់ខ្លីវិញ យើងមិនដឹងថាជាប្រភេទអាវផ្សេងដាច់ស្រឡះពីអាវបំពង់វែង ឬគ្រាន់តែជាអាវបំពង់ដែលមានសម្រុងខ្លីតែប៉ុណ្ណោះទេ (រូបលេខ១៩-២០)។ អ្នកខ្លះហៅអាវនេះថាអាវខ្លី។ អាវ

although villagers in the countryside continued to wear it. The shirt gradually became less and less common; today one rarely sees someone wearing the long tube shirt except sometimes at special ceremonies.

The cloth for making a long tube shirt was cut into the body, *bak*, *hou bau*, and sleeves. Because the *malayu* shirt and the long tube shirt were so similar, both in their appearance and in the way that they are cut and sewn, please see the detailed description for making the *malayu* shirt on page 32.

បំពង់ខ្លីគេពាក់នៅផ្ទះ និងចូលរួមក្នុងពិធីបុណ្យផ្សេងៗ ហើយពាក់ជាមួយក្បិន ឬសម្ពុយ។

អាវបំពង់វែង និងអាវបំពង់ខ្លីនេះយើងមិនដឹងថាមួយណាមានមុន មួយណាមានក្រោយទេ។ យើងគ្រាន់តែដឹងថានៅដើមសតវត្សទី២០ មានគេប្រើអាវទាំងពីរនេះរួចទៅហើយ។

រូបលេខ ១៩៖ ក្មេងពាក់អាវបំពង់ខ្លី គំនូរនៅលើជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០។ (រូបថត៖ រៃយ៉ំ)

Figure 19: Child wearing a short tube shirt, as painted on the walls of Wat Kompong Tralach Leu, early 20th century. (Photo: Reyum)

We do not know if the short tube shirt was considered a completely different type of shirt from the long tube shirt, or was simply considered a short version of the long tube shirt (figures 19-20). Some people simply called this shirt, the short shirt. The short tube shirt was worn at home and on various ceremonial occasions; the shirt is worn with the *sampot* tied in the *kben* or *samloy* style. We do not know whether the long or short version of the tube shirt was created first; by the early 20th century, both versions of the shirt were being worn in the region today known as Cambodia.

រូបលេខ ២០៖ អាវបំពង់ខ្លី។ គំនូរនៅលើជញ្ជាំងព្រះវិហារវត្តបូពិ ដើមសតវត្សទី២០។ (រូបថត៖ រៃយ៉ំ)

Figure 20: Woman wearing a short tube shirt, as painted on the walls of Wat Bo, early 20th century. (Photo: Reyum)

១- អាវម៉ាឡាយូ

អាវម៉ាឡាយូនេះ មានភាគស្រដៀងនឹងអាវបំពង់វែងដែរ។ អ្នកខ្លះកាត់មានតបែក និងហោប៉ៅខ្លះទៀតគ្មាន។ បើគ្មានតបែក និងហោប៉ៅទេ គេកាត់ភាគធ្លាក់ស្មា ដើម្បីឲ្យទូលាយងាយនឹងឈោង ឬលើកដៃ។ ខ្នងវែកខាងក្រោម ដើម្បីឲ្យទូលាយងាយស្រួលដើរ ហើយច្រើនអ្នកនៅទីក្រុងពាក់ (រូបលេខ២១-២២)។ អាវម៉ាឡាយូខុសពីអាវបំពង់វែងត្រង់ដៃធំស្មើវែងស្មើខ្លី មានសន្ទះ ពុះមុខធ្លាក់ហួតដល់ចុងដង្កើម និងខ្លួនខ្លីជាងអាវបំពង់វែង ហើយមិនសូវដាក់ឡេវែបទេ ច្រើនប្រើកន្ទាស់ក។

ប្រភពអាវម៉ាឡាយូនេះ បើយើងពិនិត្យលើពាក្យហៅ ប្រហែលទទួលឥទ្ធិពលពីពួកម៉ាឡេ។ មុនដំបូងអ្នកនិយមពាក់អាវនេះ ច្រើនតែស្ត្រីអ្នកនៅ

The *malayu* shirt

The *malayu* shirt is a very similar to the long tube shirt. Some *malayu* shirts, especially those worn in the countryside, had added *bak* and *hou bau*. If no *bak* or *hou bau* were added, then the shirt was cut with slightly dropped shoulder seams to make the garment wider so that it was easier to raise the arms; the body of the garment was cut to flare slightly in order to make walking easier (figure 21 and 22). *Malayu* shirts without *bak* and *hou bau* were worn primarily by city and town dwellers. The *malayu* shirt differed from the long tube shirt in that it had wider three quarter length sleeves and a panel opening, or *santeh*, down the front of the chest; the *malayu* shirt was generally slightly shorter than the long tube shirt as well. The *malayu* shirt usually did not have metal snap buttons,



រូបលេខ ២១៖ អាវម៉ាឡាយូរបៀបអ្នកទីក្រុងពាក់។

Figure 21: *Malayu* shirt as worn by city dwellers.



រូបលេខ ២២៖ អាវម៉ាឡាយូ ផ្នែកខាងក្រោយ។

Figure 22: *Malayu* shirt, seen from the back.



រូបលេខ ២៣៖ អាវម៉ាឡាយូ ដែលមានរូបរាងស្រដៀងអាវបំពង់វែង។

Figure 23: Front of the *malayu* shirt as worn by villagers in the countryside

ទីក្រុង ជាប្រពន្ធចៅហ្វាយស្រុក ពិសេសអ្នកដែលទាន់សម័យ (សម័យនោះគេហៅថាអ្នកលេងម៉ូត) និងស្ត្រីចាម។ ក្រោយមកទើបឃើញមានអ្នកនៅតាមស្រុកស្រែចម្ការពាក់។ ការផ្លាស់ប្តូរប្រហែលស្រដៀងនឹងអាវបំពង់វែងដែរ គឺសម័យក្រោយមកគេដេរបែបរាងជាងមុន។ រហូតដល់ចុងទសវត្ស១៩៦០ នៅមានពាក់អាវនេះខ្លះក្នុងឱកាសណាមួយ។

តាមលោកយាយមុម សំអឿន អាយុ៧៦ឆ្នាំ និយាយថា "អាវម៉ាឡាយូដែលអ្នកម្តាយខ្ញុំពាក់មានសន្ទះមុខ ដៃធំស្មើវែងស្មើខ្លី ស្មារាងធ្លាក់បន្តិចហើយខ្លីជាងអាវបំពង់វែង មិនតប៉ែក និងហោជ៉ោទៀយ។ ខុសពីអាវម៉ាឡាយូអ្នកនៅស្រុកស្រែចម្ការ។ ប្រហែលនៅទសវត្ស១៩៤០ អាវនេះនៅភ្នំពេញឃើញមានពាក់មួយរា ហើយពាក់តែក្នុងពិធីតែប៉ុណ្ណោះ"។ ទោះបីជាអាវម៉ាឡាយូមានរូបរាងខុសគ្នា but rather was closed at the neck with a pin or ornamental needle.

Given the name of this shirt, we can surmise that the shirt came from, or was initially influenced by, Malay clothing. At first, it was mostly rich and fashionable city dwellers, wives of officials, and Cham women who wore these kinds of shirts. Later, people in the countryside started to wear *malayu* shirts as well. The *malayu* shirt changed over the decades in a similar manner to the long tube shirt. By the 1940s, the shirt began to be cut to be more form-fitting. The *malayu* shirt continued to be worn on special occasions through the 1960s.

According to Mom Samuen, 76 years old, "The *malayu* shirt that my mother wore had a *santeh* [or panel opening] at the front, wide three-quarter sleeves, and slightly dropped shoulder seams. It was shorter than

រូបលេខ ២៤៖ រូបស្ត្រីនៅកណ្តាល ពាក់អាវម៉ាឡាយូផ្ការាគំនូរលើជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០។ (រូបថត៖ រៃយ៉ំ)

Figure 24: The woman in the center wears a *malayu* shirt made of flowered cloth. Wall painting in Wat Kompong Tralach Leu, dating from the early 20th century. (Photo: Reyum)

រូបលេខ ២៥៖ រូបឧកញ៉ាវិសុទ្ធពេទ្យាសួស ម៉ម និងលោកយាយ ខាំគួន ថតទសវត្សរ៍១៩៣០។ (រូបថត៖ លោកយាយមុម សំអឿន)

Figure 25: Okhna Visoth Paet and Kham Phun. Photographed 1930s.
(Photo: Collection of Mom Someun)

the long tube shirt, and did not have *bak* or *hou bau*. [My mother's city *malayu* shirt] was different from those worn by women in the countryside. Maybe in the 1940s, you could see a few *malayu* shirts being worn in Phnom Penh, but only on ceremonial occasions." Despite variations in *malayu* shirts (with or without *bak*, with or without *hou bau*), the shirt is characterised by its *santeh* or paneled front opening, its wide three-quarter sleeves, and its slightly shorter length than the long tube shirt (some *malayu* shirts ended above the kneecaps, while others ended a little below

រូបលេខ ២៦៖ នៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បច្ចុប្បន្នចាមនៅមានពាក់អាវម៉ាឡាយូក្នុងពិធីបុណ្យប្រចាំឆ្នាំ។ ថតឆ្នាំ២០០១។ (រូបថត៖ អាំង ជូលាន)

Figure 26: The Cham still wear the *malayu* shirt for their annual traditional ceremonies. Photographed in 2001 in Kompong Chhnang Province. (Photo: Dr. Ang Choulean)

ខ្លះក៏ដោយ ក៏អាវនេះគេសម្គាល់បានដោយមានសន្ទះមុខ ដៃធំស្មើវែងស្មើខ្លី និងខ្លួនខ្លីជាងអាវបំពង់វែង (ខ្លះលើកជ្រាលជង្គង់ ខ្លះក្រោមក្បាលជង្គង់បន្តិច)។ គេអាចយកក្រណាត់គ្រប់ប្រភេទមកកាត់ ចំពោះព្រៃពណ៌ និងព្រៃមុយអាគេទុកពាក់ក្នុងពិធីសំខាន់ៗ។

អាវបំពង់វែង គេច្រើនពាក់សម្រាប់ចុះស្នូងឬធ្វើចម្ការ។ រីឯអាវម៉ាឡាយូវិញ គេមិនពាក់សម្រាប់ចុះស្នូងទេ គេច្រើនពាក់ទៅបុណ្យ ឬចូលរួមក្នុងពិធីមង្គលការជាដើម។ រហូតដល់បច្ចុប្បន្ន អាវម៉ាឡាយូនេះ គេនៅឃើញពួកចាមមានពាក់ ពិសេសពេលបុណ្យប្រពៃណីរបស់គេ (រូបលេខ២៦) ចំណែកខ្មែរលែងឃើញមានពាក់ហើយ។

the kneecaps). Only women wore the *malayu* shirt. The shirt could be made from all types of cloth, although *malayu* shirts made from colored *prai* or *prai muy a* were reserved for special ceremonies. While the long tube shirt was worn to transplant rice or to work in the vegetable fields, the *malayu* shirt was generally not worn for such kind of work but was instead reserved for ceremonial occasions, weddings, and for going to the temple.

Even today, the *malayu* shirt is worn by Cham women, particularly on the occasion of their traditional ceremonies (figure 26). The Khmer have virtually stopped wearing the *malayu* shirt.



រូបលេខ ២៧៖ ទ្រង់ទ្រាយក្រណាត់សម្រាប់កាត់អាវម៉ាឡាយូ។

Figure 27: Layout of the cloth for cutting the *malayu* shirt.

របៀបកាត់អាវម៉ាឡាយូ

អាវម៉ាឡាយូមួយប្រើក្រណាត់បណ្តោយប្រវែង២ម៉ែត្រ ទទឹង៩០សង់ទីម៉ែត្រ (រូបលេខ២៧)។ តាមចាស់ទុំនិយាយថា បើកាលណាមានអាវស្រាប់ គេយកក្រណាត់ទៅវាស់ជាមួយតួខ្លួនអាវនោះ។ តែបើគ្មានទេ គេយកក្រណាត់ទៅវាស់ទំហំស្មាអ្នកពាក់តែម្តង។ ការបង្ហាញខាងក្រោមនេះជាវិធីកាត់របស់លោកយាយមុិច អាយុ៨៩ឆ្នាំ នៅខេត្តកណ្តាល ដោយវាស់តាមគំរូអាវចាស់របស់គាត់។

- តួខ្លួន៖ ដំបូងលាក្រណាត់តាមសាច់ទទឹងដោយដាក់ជាយក្រណាត់ខាងធ្វេងលើស្មាអាវធ្វេងទាញលាតឲ្យទាល់តែដល់ស្មាស្តាំអាវចាស់ រួចកាត់ផ្តាច់តាមបណ្តោយក្រណាត់។ ក្រណាត់មួយផ្ទាំង

Cutting the *malayu* shirt

A *malayu* shirt requires a piece of cloth approximately 2 meters long and 90 centimeters wide (figure 27). According to our elderly interviewees, if an old shirt was available as a model, the cloth would be measured from the old shirt and cut accordingly. If no model was available, the cloth was measured on the shoulders of the intended wearer. In what follows, Mich, 89 years old living in Kandal Province, shows us how to cut a *malayu* shirt using an old shirt of hers as a model.

The body of the garment: The cloth is spread out flat, and then is held along its width from the left shoulder of the intended wearer (or



រូបលេខ ២៨៖ ក្រណាត់តួខ្លួនអាវបត់ជាពីរ។

Figure 28: The folded length that will form the body of the garment. (Photo: Reyum)

រូបលេខ ២៩៖ ប្រើវង្វាស់ "ទោម" ដើម្បីកាត់ដៃអាវ។ (រូបថត៖ រ៉ៃយ៉ំ)

Figure 29: Using the *dome* measurement to cut the sleeves of the shirt. (Photo: Reyum)

ដែលកាត់រួចធ្វើជាតួខ្លួននោះត្រូវបត់ជាពីរតាមទទឹងសាច់ក្រណាត់ យើងនឹងបានខ្លួនអាវផ្នែកខាងមុខនិងខាងក្រោយ (រូបលេខ២៨)។

– ដៃអាវ៖ ក្រោយពីកាត់ខ្លួនរួច គេចាប់កាត់ដៃអាវ។ យកក្រណាត់ដែលនៅសល់មកវាស់ប្រវែងប្រហែលមួយទោម (ប្រហែល១៨សង់ទីម៉ែត្រ) តាមបណ្តោយសាច់ក្រណាត់ រួចបត់ជាពីរ ដើម្បីធ្វើជារង្វង់ក្បៀក (រូបលេខ២៩)។ រួចកាត់ផ្តាច់ទទឹងសាច់

the left shoulder seam of the model garment) to the right shoulder of the intended wearer (or to the right shoulder seam of the model garment). The cloth is then cut lengthwise down from this shoulder mark to form the entire body of the garment. This long vertical strip of cloth, usually about 40 centimeters by 2 meters, is then folded in half along its width to form the front and back of the garment. The neck hole has not yet been cut in the folded side of the cloth.

Sleeves: After cutting the length for the body of the shirt, the sleeves are cut. One *dome* is measured along the length of the remaining strip of cloth, which is then folded along the line of this one *dome* measurement and cut off from the remaining cloth (figure 29). This creates one sleeve of the shirt. The same process is followed again, measuring one *dome* in along the length of the remaining strip of cloth, then folding along this one



រូបលេខ ៣០៖ ដៃអាវ។ Figure 30: Sleeves.



រូបលេខ ៣១៖ ក្រណាត់ដែលសល់សម្រាប់កាត់ប៉ែកនិងហោរបៅ។

Figure 31: The cloth that remains for cutting the *bak* and *hou bau*.

ក្រណាត់ យើងនឹងបានដៃអាវមួយចំហៀង ហើយមួយចំហៀងទៀតធ្វើដូចគ្នាដែរ (រូបលេខ៣០)។ ចំណែកសម្រុងដៃ គេយកប្រវែងទទឹងក្រណាត់ដែលសល់មកធ្វើជាសម្រុងដៃតាមការនិយម។

– ប៉ែក៖ យកក្រណាត់ដែលសល់ពីកាត់ខ្លួន និងដៃអាវមកវាស់ឲ្យស្មើតាមបណ្តោយសាច់ក្រណាត់ និងសម្រុងខ្លួនអាវ។ តែដកប្រវែងរង្វង់ក្បៀក (មួយទោម) ហើយកាត់ផ្តាច់ក្រណាត់ដែលនៅសល់ចេញ (រូបលេខ៣១–៣២)។ យកក្រណាត់ដែលកាត់បានមកបត់តាមបណ្តោយក្រណាត់ រួចបត់ជាកង់ប៉ែក (រូបលេខ៣៣–៣៤)។ តាមធម្មតា គេកាត់ប៉ែកមាន ៤ផ្តាំងប៉ុនគ្នា។

dome line, and cutting the folded cloth off from what remains to form another sleeve.

The *bak*: The cloth remaining after cutting the body and the sleeves of the shirt is laid next to the body of the garment. After subtracting an additional *dome* from the length of the body of the garment for the arm holes, the *bak* are cut from the remaining cloth to fit the length of the body of the garment. The long lengths of the *bak* are then folded diagonally lengthwise and cut in flaring long shapes (figures 33-34). Two long pieces of cloth make up the *bak* on each side of the garment.

The *hou bau*: The remaining cloth is laid out straight in order to cut the *hou bau*. One *hou bau* requires perhaps 25 square centimeters of cloth.

រូបលេខ ៣២៖ រៀបវាស់ដើម្បីកាត់ប៉ែក។ (រូបថត៖ រៃយ៉ំ)

Figure 32: Measuring to cut the *bak*. (Photo: Reyum)

រូបលេខ ៣៣៖ របៀបកាត់បែ័ក។ (រូបថត៖ រៃយុំ)

Figure 33: Cutting the *bak*. (Photo: Reyum)



រូបលេខ ៣៤៖ ទ្រង់ទ្រាយបែ័ក។

Figure 34: Typical shapes for the *bak*.



រូបលេខ ៣៥៖ ទ្រង់ទ្រាយហោច៉ាវ។

Figure 35: Shapes of the *hou bau* - on the left cut from a single piece of cloth, on the right, cut from a folded piece of cloth.

រូបលេខ ៣៦៖ របៀបកាត់ហោច៉ាវ។ (រូបថត៖ រៃយុំ)

Figure 36: Cutting the *hou bau*. (Photo: Reyum)

– ខោោច៉ាវ៖ ក្រណាត់ដែលសល់ត្រូវលៃដើម្បីស្មានកាត់ហោច៉ាវ។ ហោច៉ាវមួយប្រហែលប្រើក្រណាត់អស់ ៤តឺកន្លះ (រូបលេខ៣៥–៣៧)។

– កអាវ៖ ក្រោយពីដេរភ្ជាប់ខ្លួនរួច ទើបគេកាត់កអាវ និងពុះមុខ (ឬសន្លះមុខ) ដើម្បីកុំឲ្យរសាត់ក្រណាត់។ ការកាត់កអាវ និងពុះមុខនេះដើម្បី

The neck The neck of the shirt is only cut into the folded side of the body of the garment after the various parts of the shirt have been provisionally basted together. The sewing of the *santeh* is explained in the description of the *santeh* shirt (see page 37).

រូបលេខ ៣៧៖ រៀបភ្ជាប់ហោប៉ៅ។ (រូបថត៖ រៃយ៉ំ)

Figure 37: Joining the *hou bau* to the garment. (Photo: Reyum)



រូបលេខ ៣៨៖ ការផ្គុំជាកង់អាវម៉ាឡាយូ។ (រូបថត៖ រៃយ៉ំ)

Figure 38: Assembling the basic parts of the *malayu* shirt. (Photo: Reyum)

ឲ្យទូលាយពេលសឹកក្បាល (សូមមើលវិធីកាត់កអាវ នៅផ្នែកកាត់កអាវសន្ទុះទំព័រ៤១)។ ចំពោះអាវបំពង់វែងមានចាប់កង់កូនពីង់ពាង់នៅត្រង់ចុងឆែកសម្រាប់លំអនិងខ្ចិបចុងឆែកផង។ ក្រោយពីកាត់រួចគេផ្គុំជារូបកង់អាវសិនមុននឹងដេរភ្ជាប់ ដើម្បីមើលថា សមឬមិនសម (រូបលេខ៣៨)។

រៀបដេរ

ការដេរអាវបំពង់វែងក៏ដូចជាអាវម៉ាឡាយូដែរ មុនដំបូងគេដេរថ្នរដាន ដើម្បីភ្ជាប់ចេញជារូបកង់អាវទាំងមូលសិន។ ការធ្វើរបៀបនេះ គេហៅឡើង់ខ្លួន។ ឡើង់ខ្លួនរួច ទើបគេដេរថ្នរសម្រេច៖

- គឺដេរប៉ែកភ្ជាប់ជាមួយហោប៉ៅ។
- ហើយទើបយកមកភ្ជាប់ជាមួយដៃ។
- រួចហើយបានយកមកភ្ជាប់នឹង់ខ្លួន។

Sewing the shirt

Both the *malayu* shirt and the long tube shirt are first basted together provisionally to see that the whole shirt fits. This is called "raising the form". When this provisionally basting is completed and checked, either on the intended wearer, or on the model shirt, the final seams are then sewn as follows:

- the *bak* is sewn to the *hou bau*
- the *bak* and the *hou bau* are sewn to the sleeves
- the *bak*, *hou bau*, and sleeves are sewn to the body of the garment
- the neck of the shirt is cut. The *santeh* (*malayu* shirt) or the slit which will end in the spider ornament (long tube shirt) is inserted.

The sleeves of the long tube shirt are generally sewn together with separated seams since the sleeves of the garment are quite tight

– ក្រោយពីភ្ជាប់ខ្លួនរួចហើយ (ឬឡើងខ្លួន) ទើបចាប់កាត់កអាវ និងសន្ទះជាក្រោយ។

នៅលើដៃអាវបំពង់វែងគេដេរថ្នេរបំបែកព្រោះដៃអាវបំពង់វែងគេដេរដៃតូចរឹបជាប់នឹងដៃ (ខ្លះហៅដៃស្រោមដាវ)។ នៅពេលដែលចុងដៃរឹបពេកគេអាចពុះថ្នេរចុងដៃអាវនេះជាពីរ មិនធ្វើឲ្យក្រណាត់រសាត់ ឬពិបាកដេរម្តងទៀត (ដោយដាក់ឡេវកិបនៅចុងដៃអាវ)។ តែដៃអាវម៉ាឡាយូ គេដេរថ្នេរមូលដូចតួអាវដែរ ហើយចុងដៃ និងជាយអាវ គេដេរថ្នេរថយហ្គ័ង។ ចំពោះកអាវ បើសិនជាគេដាក់ឡេវកិប ឬខ្នាស់កន្ទាស់ គេដេរថ្នេរថយហ្គ័ងពីរជួរទន្ទឹមគ្នា។ តែបើដាក់ខ្សែចង គេស៊កខ្សែក្នុងកអាវ ហើយដេរថ្នេរធិត។ ខ្សែនោះ ជួនកាលគេយកអំបោះ៤–៥សរសៃមកវេញបញ្ចូលគ្នា ឬប្រើក្រណាត់ ហើយនៅផ្នែកខាងចុងខ្សែ អ្នកខ្លះមានចង់ធ្វើជារំយោលផ្កា។

គ– អាវសន្ទះ

អាវនេះមានខ្លួនខ្លី កមូលទំហំប៉ុនកមនុស្សពុះមុខធ្លាក់មកដល់ចុងដង្ហើម មានថ្នេរចំហៀងមួយគ្មានឆែក។ នៅកន្លែងដែលគេពុះធ្លាក់ដល់ចុងដង្ហើមនេះមានដេរក្រណាត់ធ្វើជាសន្ទះឲ្យរឹងបន្តិច។ តាមពាក្យចាស់ៗនិយាយ កាលពីមុន អាវសន្ទះ គេទម្លាប់កាត់ក្រណាត់តែមួយផ្ទាំងឲ្យចេញជាពាងអាវគ្មានតស្នាគ្មានតដៃ គ្មានឆែក ហើយដាក់ហោប៉ៅពីរ

and are sometimes even called "sword sheathes." If the end of the sleeves of the long tube shirt are too tight to insert the hands, the wrists can be made into slits so that the cloth does not tear or unravel (snap metal buttons are sometimes added at the wrist). The sleeves of the *malayu* shirt are sewn together with round seams as is the body of the garment. Hems on the sleeves and at the bottom of the garment are finished with the backwards stitch. The neck of the garment, if it is closed with a metal snap button, or an ornamental pin, is finished using two rows of backwards stitching. If a string is to be used to close the neck, then the *chet* stitch is used to finish the neck. Sometimes four or five cotton threads are wound together to form this string.

The *santeh* shirt

This type of shirt was short with a close fitting round neck. The shirt was split down the middle of the front by a panel called the *santeh* made of doubled cloth which was slightly heavier than the rest of the shirt. According to our elderly interviewees, the *santeh* shirt was generally cut from a single piece of cloth with no shoulder seams. The shirt usually had two pockets attached to its lower front.



រូបលេខ ៣៩៖ អាវសន្ទះស្រីផ្នែកខាងមុខ។

Figure 39: Woman's *santeh* shirt, seen from the front.



រូបលេខ ៤០៖ អាវសន្ទះស្រីផ្នែកខាងក្រោយ។

Figure 40: Woman's *santeh* shirt, seen from the back.

នៅផ្នែកខាងក្រោម។ អាវមួយប្រើអស់ក្រណាត់១ ម៉ែត្រទៅ១ម៉ែត្រ៥តឹក (រូបលេខ៣៩-៤០)។

អាវសន្ទះអាចកាត់ដៃវែងក៏បាន ខ្លីក៏បាន។ អាវស្រីតែច្រើនកាត់ដៃខ្លី និងដៃស្មើរវែងស្មើខ្លី។ បើអាវប្រុស តែកាត់ដៃវែងដល់កដៃ (ដៃអាវបែបនេះអាចហៅថា ដៃស្រោមដាវ) តែជាទូទៅនិយមកាត់ដៃខ្លី។ ប៉ុន្តែមកដល់ពាក់កណ្តាលសតវត្សទី៦០ តែកាត់អាវសន្ទះមានតដៃ និងច្នៃឲ្យមានវាងសមជាងមុន ដោយដេរបញ្ចូលវាងនៅចង្កេះ។ ក្រណាត់ដែលគេយកមកកាត់អាវនេះ ច្រើនជាក្រណាត់ស្តើងពាក់ទៅត្រជាក់ ដូចជាក្រណាត់សារូឡាត, ក្រណាត់សារូផ្កា, ក្រណាត់ទេសឯកជាដើម។ ចំណែកពណ៌ តែប្រើតាមការនិយមរបស់មនុស្សម្នាក់ៗ។ អាវសន្ទះ តែពាក់បានទាំងស្រី ទាំងប្រុសពាក់នៅផ្ទះក៏បាន ចេញក្រៅក៏បាន។ ជាទូទៅអាវនេះមានពាក់តាំងពីអ្នកមានឋានៈខ្ពស់រហូតដល់អ្នកស្រុកធម្មតា គ្រាន់តែខុសប្លែក

The *santeh* shirt could be cut to have either long or short sleeves. Most women's *santeh* shirts had short sleeves or three-quarter sleeves. Men's *santeh* shirts often had long sleeves reaching to the wrists; these long sleeves were sometimes called sword sheath sleeves. The most popular *santeh* shirts, however, were short-sleeved. In the mid-20th century, *santeh* shirts began to have attached sleeves with seams, and were cut to be more form fitting at the waist. *Santeh* shirts were generally made from light cool fabrics such as plain and patterned *saru* or *des aik* cloth. The *santeh* shirt was worn by both men and women, either in the home or in public places. All classes of people seem to have liked to wear the *santeh* shirt; the only variance in the shirt between classes and genders was the type of cloth used to make it and the decoration on the *santeh* closing the shirt. Ordinary

រូបលេខ ៤១៖ ខាងឆ្វេង ជាបុរសស្លៀកសំពត់ចង់ក្បិនពាក់អាវសន្ទះ។ កណ្តាល ជាស្ត្រីស្លៀកសំពត់ចង់ក្បិនពាក់អាវសន្ទះនិងកាន់កន្សែងក្រហម។ ខាងស្តាំ ជាស្ត្រីស្លៀកសំពត់ចង់ក្បិនពាក់អាវសន្ទះ។ គំនូរលើជញ្ជាំងព្រះវិហារវត្តកំពង់ក្រឡាចលើ ដើមសតវត្សទី២០។ (រូបថត៖ រៃយ៉ំ)

Figure 41: A man (left) and a woman (center) wearing *santeh* shirts with *sampot* tied in the *kben* style with *santeh* shirts. On the right, a woman wears a *santeh* shirt with a *sampot* tied in the *kben* style. Painting in Wat Kompong Tralach Leu, dating to the early 20th century. (Photo: Reyum)

រូបលេខ ៤២៖ អ៊ឹង ធនវណ នៅភ្នំពេញ ពាក់អាវសន្ទះដៃខ្លី។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 42: Dr. Pou Thonevath wearing a short-sleeved *santeh* shirt. Photographed 2003. (Photo: Reyum)

គ្នាក្នុងការប្រើក្រណាត់ និងការលំអលើសន្ទះអាវ។ បើប្រជាជនធម្មតា ស្រីច្រើនប្រើឡែកិប ប្រុសចោះដាក់ឡែចាន។ ចំណែកអ្នកមានមុខមាត់មិនដាក់ឡែទេ គឺខ្ចាស់កន្ទាស់ពេជ្រ ឬមាស។ មនុស្សស្រីនិយមពាក់អាវសន្ទះ និងស្លៀកសំពត់ចង់ក្បិនបង់កក្រមាទម្លាក់ជាយមកខាងមុខ (បើពាក់អាវពណ៌ស៊ីនួន បង់កក្រមាពណ៌ស៊ីនួនខ្លី) កាត់សក់ស្តើក្តោប លាបក្រមួនមាត់ ពាក់ក្រវិលទំហូ។ ឯមនុស្សប្រុសនិយមស្លៀកជាមួយសំពត់សម្ពយ (ភាគច្រើនជាសារុង៍សូត្រ) ឬខោជ្នេរ៉ែ បង់កក្រមាទម្លាក់ជាយទៅក្រោយ។

women generally used metal clasp buttons to close the *santeh* at the neck, while men generally closed the *santeh* with *chan* buttons. Rich and high class wearers generally did not use buttons on their *santeh*, but rather closed it using diamond or gold ornamental pins. Women tended to wear the *santeh* shirt with a *sampot* tied in the *kben* style. They sometimes wrapped a *krama* around their neck, letting it fall to the front of the shirt (if they wore a dark colored shirt, the *krama* worn was often the same color but lighter). They

រូបលេខ ៤៣៖ អាវសន្ទះដៃវែង និងដៃខ្លី។ រូបគំនូរលើជញ្ជាំងព្រះវិហារវត្តគំរាន់ក្រឡាចលើ ដើមសតវត្សទី២០។ (រូបថត៖ រៃយ៉)

Figure 43: Figures wearing short and long sleeved *santeh* shirts, as painted on the walls of Wat Kompong Tralach Leu, early 20th century. (Photo: Reyum)

របៀបកាត់អាវសន្ទះ

ក្រណាត់ដែលយកមកកាត់អាវសន្ទះមួយយ៉ាងហោចណាស់ប្រើក្រណាត់ពី១ម៉ែត្រទៅ១,២ម៉ែត្រ ហើយទទឹងក្រណាត់០,៩០ម៉ែត្រ ឬលើសពីនេះក៏បាន។ ពេលកាត់ ជួនកាលគេយកអាវដែលមានស្រាប់មកធ្វើជាគំរូកាត់ក៏បាន។ ខាងក្រោមនេះជាវិធីកាត់អាវសន្ទះដៃខ្លីរបស់លោកយាយមុិច អាយុ៨៩ឆ្នាំ។ ដំបូងលោកយាយកាត់តួខ្លួននិងដៃ, វង្វង់ក, សន្ទះ, ក្រណាត់ចំក និងកាត់ក្រណាត់សម្រាប់ទ្រាប់សន្ទះ។

– **តួខ្លួននិងដៃអាវ៖** ដំបូងបត់ក្រណាត់ជាពីរភាគឲ្យស្មើគ្នាតាមសាច់ទទឹង រួចបន្តបត់ឲ្យបានជា

wore their hair in the cabbage style, waxed their lips, and wore *domhu* earrings. Men liked to wear the *santeh* shirt with the *sampot* worn in the *samloy* style, or with five seamed pants, again wrapping a *krama* around their neck and letting the ends fall behind them.

Cutting the *santeh* shirt

The *santeh* shirt required a piece of cloth at least one meter to one meter and twenty centimeters in length and 90 centimeters in width or wider. Old shirts, if available, were used as models for cutting the cloth. Below we show one way of cutting a short-sleeved *santeh* shirt as demonstrated by Mich, 89 years old.

Body and sleeves of the shirt: The cloth is folded along its width into two equal pieces. It is then folded again along its long axis. With the longer side facing up, one *chom am* is measured down on each side for the width of the sleeves. From the bottom of this measurement on each side, the ends of the scissors are used to score a sweeping line in and then down to the bottom of the cloth. Each side is then cut to form the body and arms of the shirt (figure 44-45). When the cloth is already cut, this basic shirt form is tried out on the person who will wear the shirt. If the shirt seems too long, some of the cloth at the bot-

រូបលេខ ៤៤៖ បត់ក្រណាត់ជាបួនរួចគូសស្នាមដើម្បីកាត់។ (រូបថត៖ រៃយ៉ំ)

Figure 44: The cloth is folded four times and then scored with the scissors to mark the line of the cut. (Photo: Reyum)



រូបលេខ ៤៥៖ កាត់បានតួ និងដៃអាវ។ (រូបថត៖ រៃយ៉ំ)

Figure 45: Cutting the body and arms of the shirt. (Photo: Reyum)

បួនភាគទៀតតាមសាច់បណ្តោយម្តង។ បន្ទាប់មកយកចុងកន្ត្រៃគូសឲ្យឃើញស្នាមលើក្រណាត់ដើម្បីកាត់ដោយទុកវង្វង់ដៃប្រហែលមួយចំអាម (រូបលេខ៤៤) រួចហើយចាប់កាត់ក្រណាត់តាមស្នាមគូសនោះនឹងបានតួខ្លួន និងដៃអាវ (រូបលេខ៤៥)។ ក្រោយពីកាត់ហើយ គេយកតួខ្លួននោះទៅដាក់វាស់លើខ្លួន (មនុស្សដែលត្រូវពាក់) បើឃើញសម្រុងវែងពេក គេកាត់សាច់ក្រណាត់ជាយផ្នែកខាងក្រោមចោលខ្លះឲ្យសមល្មមតាមគេចង់បាន។

– កអាវ៖ ជាដំបូងគេកាត់ក្រដាសគំរូ (បើប្រើក្រដាសរឹងកាន់តែល្អ) ដោយកាត់ជារាងវង្វង់ទំហំប៉ុនកមនុស្ស (អ្នកពាក់) រួចបត់ជាពីរឲ្យស្មើគ្នា (រូបលេខ៤៦)។ គេចាប់លាតួខ្លួនអាវតាមបណ្តោយសាច់ក្រណាត់វិញ (រូបលេខ៤៧) ហើយយក

tom is cut off and the whole shape is adjusted to better fit the form of the intended wearer.

Cutting the neck: First a paper model for the neck is cut out of stiff paper, making a round shape slightly larger than the intended wearer's neck. This paper circle is folded in half (figure 46). The single piece of cloth for the body and sleeves, described above, is folded along its length and laid flat on the ground. The folded paper circle is then pinned to the left of the central fold in the garment and the neck is cut, following the edge of the paper model to create a even neck hole in the middle of the garment (figures 48-49).

Backing of the neck seam: A left-over or unused piece of cloth, measuring between 30



រូបលេខ ៤៦៖ ក្រដាសគំរូសម្រាប់កាត់កអាវ។

Figure 46: Paper model for cutting the neck of the shirt.

រូបលេខ ៤៧៖ លាដើម្បីកាត់កអាវ។ (រូបថត៖ រៃយ៉ំ)

Figure 47: Spreading the cloth of the body of the garment, folded lengthwise, in preparation for cutting the neck hole. (Photo: Reyum)



រូបលេខ ៤៨៖ រៀបខ្ទាស់ក្រដាសគំរូកាត់កអាវ។

Figure 48: Pinning the neck model to the cloth.

រូបលេខ ៤៩៖ កាត់កអាវតាមគំរូក្រដាស។ (រូបថត៖ រៃយ៉ំ)

Figure 49: Cutting the neck following the paper model. (Photo: Reyum)

ក្រដាសគំរូកអាវមកខ្ទាស់ ដោយដាក់ខិតមកផ្នែកខាងធ្វេងជាប់ស្នាមបត់ក្រណាត់ (តាមសាច់ទទឹង) (រូបលេខ៤៨)។ បន្ទាប់មក គេកាត់ខ្វៀលតាមរាងក្រដាសនោះនិងបានរង្វង់កអាវ (រូបលេខ៤៩)។

– ក្រណាត់ចំកអាវ៖ គេយកក្រដាសគំរូសម្រាប់កាត់កអាវដែលបត់ជាពីរ ហើយនោះមក

and 40 square centimeters in length, is folded in half. The round model for the neck hole is again folded in half and pinned to this folded cloth. An initial outer semi-circle is cut in the cloth, 3 or 4 centimeters outside the edge of the paper model. Then a second semi-circle is cut closely following the edge of the paper model (figure 50), resulting in a doughnut

ខ្ចាស់លើសាច់ក្រណាត់មួយផ្ទាំងកាងបួនជ្រុងស្មើ ទំហំប្រហែល៣០សង់ទីម៉ែត្របត់ជាពីរដែរ។ រួចគេកាត់ជាយក្រណាត់ចោលខ្លះ ដើម្បីយកកាងដូចក្រដាសគំរូកអាវ តែទំហំធំជាងប្រហែល២-៣សង់ទីម៉ែត្រ ហើយគេកាត់ដោយដាក់កន្ត្រៃចំជាយក្រដាសកាត់តែម្តង (រូបលេខ៥០)។ ពេលកាត់បានក្រណាត់ចំក គេក៏កាត់ផ្តាច់ចំស្នាមបត់ម្ខាង (រូបលេខ៥១)។

- សន្ទះ៖ ក្រោយពីកាត់កហើយគេលាតួខ្ចីនអាវបត់ជាសាច់ទទឹងវិញទើបគេចាប់កាត់ផ្តាច់សាច់ក្រណាត់ពីត្រឹមរង្វង់កតាមស្នាមបត់ក្រណាត់ (ចំពាក់កណ្តាលតួខ្ចី) ចុះមកក្រោម ដោយយកប្រវែងមួយចំអាម (រូបលេខ៥២)។

- ក្រណាត់ទ្រាប់សន្ទះ៖ កាត់ក្រណាត់កាងបួនជ្រុងទទឹងប្រហែល៩សង់ទីម៉ែត្រ និងបណ្តោយ២០សង់ទីម៉ែត្រ (រូបលេខ៥៣)។

shaped cloth semi-circle (figure 51). One side of the folded cloth is cut through while the other side is left uncut. The resulting open circle mirrors the form of the neck of the shirt and is sewn to the neck and then folded in to create a finished neck seam.

Cutting the *santeh*: After the neck hole has been cut, the cloth of the shirt is refolded along its width. A cut is then made from the front of the neck hole, along the fold crease, down the garment for about the length of one *chom am* [the outstretched palm of the hand] (figure 52).

Backing of the *santeh*: A long rectangular piece of cloth about 20 centimeters long and nine centimeters wide is cut to form the backing of the *santeh* (figure 53).

រូបលេខ ៥០៖ កាត់ក្រណាត់ចំកអាវ។ (រូបថត៖ រៃយ៉ំ)

Figure 50: Cutting the cloth for the neck seam. (Photo: Reyum)



រូបលេខ ៥១៖ ក្រណាត់ចំកអាវ។

Figure 51: Cloth for the neck seam.



រូបលេខ ៥២៖ ការកាត់សន្ទះ។

Figure 52: Cutting the *santeh*.

រូបលេខ ៥៣៖ កាត់ក្រណាត់ចំសន្ទះ។ (រូបថត៖ រៃយ៉ំ)

Figure 53: Cutting the backing for the *santeh*. (Photo: Reyum)

រៀបដេរ

ដំបូងគេដេរថ្នេរនៅសង៍ខាងតួខ្លួនចាប់ពីចុងដៃរហូតដល់ជាយអាវខាងក្រោម ដោយប្រើថ្នេរមូល។ បន្ទាប់មកដេរចំក និងសន្ទះ។ ពេលដេរសន្ទះ គេបត់ក្រណាត់ដែលកាត់ទ្រាប់សន្ទះនោះឲ្យនៅទំហំប្រហែល ៤,៥សង៍ទីម៉ែត្រ និង២០សង៍ទីម៉ែត្រ (បត់ជាយសងខាងចូលគ្នា) រួចចាប់ដេរភ្ជាប់ ដោយថ្នេរថយហ្គ័ន។

Sewing the *santeh* shirt

First the long side seam joining the front and back of the garment is sewn from the end of the sleeves all the way to the bottom of the shirt at the waist, first basting the seam and then sewing a final round seam. The backings for the neck and the *santeh* are then attached. The backing of the *santeh* is folded to add thickness and is attached by backwards stitching.

ឃ- អាវកមូល

មានអាវមួយប្រភេទទៀតស្រដៀងនឹងអាវសន្ទះដែរ គ្រាន់តែគ្មានសន្ទះមុខ ខ្លួនរាងដូចបំពង់ ដៃខ្លី គ្មានតស្មានិងដៃ កមូលធំអាចសឹកក្បាលចូលចុះ។ អាវនេះគេហៅថា អាវកមូល ឬអាវសឹក។ អាវនេះមានសម្រាប់មនុស្សប្រុស និងមនុស្សស្រី។ អាវក

Round neck shirts

A variety of shirts had round necks and short sleeves of various types, generally without shoulder seams. These shirts were generally pulled on over the head of the wearer, and were called round neck or pullover



រូបលេខ ៥៤៖ អាវកមូល។

Figure 54: Cap sleeved round neck shirt seen from the front.

មូលសម្រាប់មនុស្សប្រុសពាក់នៅផ្ទះ (រូបលេខ៥៤) ហើយពាក់បានទាំងចាស់ទាំងក្មេង។ អ្នកដែលមានជីវភាពធូរធារនិយមពាក់អាវប្រភេទនេះនៅផ្ទះ ហើយស្លៀកជាមួយខោថ្នេរ៣ ឬថ្នេរ៥ ធ្វើពីព្រៃពណ៌ ឬស្លៀកសារុងសូត្រ។ ក្រណាត់ដែលគេយកមកកាត់អាវនេះច្រើនតែជាក្រណាត់ស្តើងធ្វើអំពីសាច់អំបោះសុទ្ធ ពាក់ត្រជាក់។ របៀបកាត់អាវកមូលប្រភេទនេះប្រហែលនឹងរបៀបកាត់អាវសន្ទះដែរ គ្រាន់តែគេកាត់កធំជាង និងមិនកាត់សន្ទះ ហើយនៅជុំវិញកគេដេរថ្នេរថយហ្វ័ងត្រួតពីរជួរ។

shirts. These types of shirts were worn by young and old, men and women, although men generally only wore them at home. Well-to-do men wore such shirts at home with three or five seam pants made of colored *prai* or with silk *sarong*. Round neck shirts were generally made of light cool fabrics such as pure cotton. The round neck shirt was cut and sewn in a similar fashion to the *santeh* shirt, although with a larger neck hole and no front panel. The round neck was finished with two rows of backward stitching. Women's round neck shirts generally had added waist-



រូបលេខ៥៥៖ អាវកមូលឥតដៃ។

Figure 55: Sleeveless round neck shirt.



រូបលេខ ៥៦៖ អាវកមូលដៃខ្លី។

Figure 56: Short sleeve round neck shirt.

ចំណែកអាវកមូលសម្រាប់មនុស្សស្រីវិញ គេច្រើនកាត់មានតចង្កេះ ហើយវែងគ្របត្រគៀក ឯដៃវិញ ខ្លះកាត់វាលគ្រៀក ខ្លះដៃខ្លី ខ្លះដៃវែង តាមចំណូលចិត្តអ្នកពាក់ (រូបលេខ៥៥-៥៦)។ អាវនេះមានពាក់ចាប់ពីទសវត្ស១៩៤០មកហូតដល់សព្វថ្ងៃ។

bands and were longer to cover the hips. They were sleeveless, had cap or short sleeves, or sometimes had long sleeves depending on the individual taste of the wearer (figures 54-56). Round neck shirts began to be worn in the 1940s and are still worn today.

ង- អាវចិន

អាវនេះមានកមូល ឡេវមុខ ដៃវែង ខ្លួនមានឆែកចំហៀងទាំងសងខាង ពាក់បានទាំងស្រីទាំងប្រុស គ្រាន់តែមានរូបរាងខុសប្លែកគ្នាបន្តិចបន្តួច។ អាវចិនប្រុសមានហោប៉ៅបី ខាងក្រោមពីរ ខាងលើផ្នែកខាងឆ្វេងមួយ ជួនកាលមានដាក់ហោប៉ៅបង្កប់មួយខាងក្នុងខាងស្តាំបន្ថែមទៀត។ ដៃអាវវែងមកដល់ចុងដៃ ខ្លួនអាវវែងស្រុង។ ចំណែកអាវចិនស្រីច្រើនដេរមានហោប៉ៅពីរនៅផ្នែកខាងក្រោម ដៃអាវមានពីរបែបគឺ ដៃស្មើវែងស្មើខ្លី (ដៃត្រកា) និងដៃខ្លី។ ឯសម្រុងខ្លួនអាវមិនវែងស្រុងដូចអាវចិនប្រុសទេ។

អាវចិននេះយើងមិនដឹងថា មានយកមកពីចិនផ្ទាល់ ឬតាមរយៈការផ្ទាស់ប្តូរទំនិញ និងក្នុងរយៈកាលណាមួយច្បាស់លាស់ទេ គ្រាន់តែយើងសង្កេតឃើញថា ចិនដែលរស់នៅស្រុកខ្មែរ និងកូនខ្មែរកាត់ចិនដែលរស់នៅតាមមាត់ទន្លេ ពាក់អាវរបៀបនេះ។ តាមការសាកសួរចាស់ៗ និងរូបថតដែលនៅសេសសល់ពីសម័យមុនៗ យើងអាចដឹងថា នៅក្នុងទសវត្ស

The Chinese Shirt

This shirt had a round neck, buttons down the front, long sleeves, and slits at the sides of the body of the garment. There were slightly different versions of the Chinese shirt for male and female wearers. The male version of the shirt (figures 57-58) generally had three pockets in the front, two at the bottom and one on the top left. Sometimes a fourth pocket was hidden inside the garment as well. The sleeves of the garment were long, stretching to the wrists, and the body of the garment was long as well. The female version of the shirt generally only had two lower front pockets, and either three-quarter or short sleeves. The female version of the shirt was cut shorter than the male version.

We do not know whether or when this type of shirt was introduced from China. Chinese and Khmer of Chinese descent, living along the rivers, wore these types of shirts. According to our elderly interviewees, as well as from looking at the old photographs that



រូបលេខ ៥៧៖ អាវចិនប្រុសផ្នែកខាងមុខ។

Figure 57: The Chinese shirt for men seen from the front.



រូបលេខ ៥៨៖ អាវចិនប្រុសផ្នែកខាងក្រោយ។

Figure 58: The Chinese shirt for men seen from the back.

រូបលេខ ៥៩៖ អាវចិនស្រីដៃខ្លី ផ្នែកខាងមុខ។

Figure 59: The Chinese shirt for women seen from the front.



រូបលេខ ៦០៖ អាវចិនស្រីដៃខ្លី ផ្នែកខាងក្រោយ។

Figure 60: The Chinese shirt for women seen from the back.



រូបលេខ ៦១៖ អាវចិនស្រីនេះគេប្រើឡេវមាស ហើយឡេវមួយភ្ជាប់ខ្នាដោយខ្សែមាស សម្រាប់អ្នកដែលមានឋានៈខ្ពស់។

Figure 61: A Chinese shirt for women with gold buttons and a gold chain connecting the buttons. This shirt would be worn by wealthy women.

រូបលេខ ៦២៖ លោកយាយម្នាក់នៅខេត្តកំពត ពាក់អាវចិនដៃស្មើរ វែងស្មើរខ្ញី ស្លៀកសំពត់ចង់ក្បិន។ ឆ្នាំ២០០២។ (រូបថត៖ ឈៃ)

Figure 62: An old woman in Kampot Province wearing a three-quarter sleeve Chinese shirt with a *sampot* tied in the *kben* style. Photographed 2002. (Photo: Reyum)



រូបលេខ ៦៣៖ លោកតាឈុំ ឃុត អាយុ៧០ឆ្នាំ នៅខេត្តសៀមរាប ពាក់អាវចិនដៃវែង។ ឆ្នាំ២០០៣។ (រូបថត៖ ឈៃ)

Figure 63: Chum Kut, 70 years old, wearing a long sleeved Chinese shirt. Photographed in Siem Reap Province in 2003. (Photo: Reyum)

១៩៣០ យើញមានអាវប្រភេទនេះប្រើស្មើរជាទូទៅ ក្នុងស្រុកខ្មែរ។ សម័យនោះមានពាក់អាវចិនទាំងក្មេង ទាំងចាស់។ តែក្រោយមកពេលសម្លៀកបំពាក់កាន់តែ សម្បូណ៌បែប ក្មេងៗមិនសូវពាក់ទេ ដោយយល់ថា ពាក់អាវនេះយើញដូចមនុស្សចាស់។ មនុស្សដែល មានវ័យចំណាស់ (យ៉ាងហោចណាស់ចាប់ពីអាយុ ៣០ឆ្នាំឡើង) នៅពាក់អាវបែបនេះ និងច្រើនពាក់ ពេលមានពិធីបុណ្យទាន និងទៅវត្ត។

we collected, it seems that by the 1930s, Chinese shirts were being widely worn throughout Cambodia by people of all ages. However, as various kinds of clothing became more and more abundant, the young stopped wearing the Chinese shirt because it came to be associated with old people. Middle age and elderly people still wore this kind of shirt for ceremonial occasions and to go to the temple.

រូបលេខ ៦៤៖ លោកយាយគុជ ឡង ពាក់អាវចិន ស្លៀកសំពត់សម្ពុយ មុយអា និងប្តីរបស់គាត់។ ថតឆ្នាំ១៩៦៤។ (រូបថត៖ គ្រួសារ លោកយាយគុជ ឡង)

Figure 64: Kuch Long (left) wearing a Chinese shirt with a *sampot* tied in the *samloy* style made of *prai muy a*. She is standing with her husband. Photographed 1964. (Photo: Collection of the family of Kuch Long)

ស្រីៗពាក់អាវចិនជាមួយសំពត់ចង់ក្បិន ឬសំពត់សម្ពុយ កាត់សក់ជ្រង ឯប្រុសៗច្រើនពាក់អាវចិនជាមួយខោចិន ឬខោថ្នេរ៥។ អ្នកដែលមានជីវភាពគ្រាន់បើ គេច្រើនយកក្រណាត់សារូវស្តើង, សារូមានផ្កាមួយៗ, ទេសឯកផ្កាមកកាត់។ ចំណែកអ្នកមិនសូវមានលុយ ច្រើនយកក្រណាត់ទេសឯក ឬជាឱបមកកាត់ ហើយប្រើពណ៌ទៅតាមការនិយមរបស់មនុស្សម្នាក់ៗ។ សព្វថ្ងៃអាវចិន ច្រើនតែមនុស្សប្រុសវ័យចំណាស់នៅនិយមពាក់ ហើយច្រើនតែពណ៌ស ដូចជាចាស់ការ៉ាស់សីល និងអាចារ្យជាដើម។ ចំណែកមនុស្សស្រីវ័យចំណាស់មិនសូវឃើញមានពាក់ទេ។

Women generally wore the Chinese shirt with a *sampot* tied in the *kben* or *samloy* styles, and cut their hair in the *chrung* style. Men mostly wore the Chinese shirt with Chinese pants or five seam pants. Wealthier people generally use thin plain or patterned *saru* cloth, or patterned *des aik* cloth to make Chinese shirts. Poorer people used *des aik* or *pa dip* cloth to make Chinese shirts of whatever colors they liked. Today, old men still like to wear the Chinese shirt. They generally wear white Chinese shirts when they begin to observe the eight precepts, or serve as *achar* of the temple. We do not see elderly women wearing Chinese shirts as much.

របៀបកាត់អាវចិនប្រុស

ក្រណាត់ដែលយកមកកាត់អាវចិនប្រុសមានប្រវែងបណ្តោយ២ម៉ែត្រ និងប្រវែងទទឹង១,២ម៉ែត្រ។ (រូបលេខ៦៥)

– តួអាវ៖ មុនដំបូងគេវាស់សម្រុងអាវដោយចាប់យកជាយក្រណាត់មកវាស់លើខ្លួនតាមបណ្តោយសាច់ក្រណាត់ គឺចាប់វាស់ពីស្មាចុះមករហូតមកដល់ត្រគៀកដោយមានតួសចំណាំសម្រុងតួខ្លួនអាវ។ បានសម្រុងហើយយកមកបត់ជាពីរតាមទទឹងសាច់ក្រណាត់ (សម្រុងអាវគុណនឹង២) គេបានជាតួខ្លួនអាវទាំងមុខ ទាំងក្រោយ (រូបលេខ៦៦)។ បន្ទាប់មកចាប់យកកន្លែងបត់ក្រណាត់ជាពីរនោះមកវាស់លើស្មាតាមទទឹងសាច់ក្រណាត់។ អាវចិននេះគេមិនវាស់ត្រង់ចុងស្មាឆ្វេងមកចុងស្មាស្តាំទេ គឺគេវាស់

Cutting the male Chinese shirt

The male version of the shirt requires a piece of cloth 2 meters in length and 120 centimeters in width.

The body of the shirt: The size of the shirt is measured by letting the entire length of cloth fall down from the shoulder to the hip of the intended wearer. The appropriate length is marked, and the length of the cloth is then folded at this mark to be doubled, thus forming the front and back of the shirt. This cloth is then held to the shoulders of the intended wearer to measure the width of the shirt. For the Chinese shirt, the shoulder seams are dropped and fall at the upper arms; thus the width of the body of the shirt is measured from the right to the left upper arm (or vice



រូបលេខ ៦៥៖
ក– ក្រណាត់កាត់តួអាវផ្នាំងមុខនិងផ្នាំងក្រោយ
ខ– ក្រណាត់កាត់ដៃអាវទាំងពីរ
គ– ក្រណាត់កាត់កវិល
ឃ– ក្រណាត់កាត់សន្ទះខ្យល់
ង– ក្រណាត់ទ្រាប់ឆែក
ច– ក្រណាត់កាត់ហោប៉ៅ និងចំក

Figure 65: A. Cloth for the body of the garment, front and back; B. Cloth for the two sleeves of the garment; C. Cloth for the neck and front facing; D. Cloth for the wind *santeh*, an extra panel of cloth which covers the flesh when bending or stretching; E. Cloth for the slit seams; F. Cloth for the pockets and neck.



រូបលេខ ៦៦៖ ក្រណាត់កាត់តួខ្លួនអាវ។

Figure 66: Cloth for the body of the shirt.



រូបលេខ ៦៧៖ តួខ្លួនអាវ។

Figure 67: Body of the shirt.

ឲ្យជ្ងាក់មកដល់ពាក់កណ្តាលដើមដៃទាំងសងខាង រួចកាត់ក្រណាត់ដែលលើសនោះចេញ។ អាវចិនគេមិនដេរភ្ជាប់ដៃពីត្រឹមចុងស្មាដូចអាវផ្សេងៗទេ គឺគេតដៃចាប់ពីពាក់កណ្តាលដើមដៃ។ បន្ទាប់មកបត់ក្រណាត់នេះជាពីរទៀតតាមបណ្តោយសាច់ក្រណាត់ (ទំហំស្មាចែកនឹង២)។ កន្លែងបត់តាមបណ្តោយសាច់ក្រណាត់នេះ គេកាត់ផ្តាច់ជាពីរផ្នាំង រួចបត់ផ្នាំងទាំងពីរនោះ តាមទទឹងសាច់ក្រណាត់។ គេកាត់ខ្វៀលក្រណាត់ឲ្យចេញជារាងដៃ និងតួខ្លួន ដោយវាស់ទំហំជុំវិញដើមដៃប្រហែល៣០សង់ទីម៉ែត្រ (រូបលេខ៦៧)។

– រន្ធធំកអាវ (រូបលេខ៦៨–៦៩)៖ គឺគេកាត់ពុម្ពក្រដាសឲ្យប៉ុនកមនុស្ស (គេមិនកាត់ឲ្យធំជាង

versa). When the proper width of the shirt is determined, the remaining cloth is cut away. The doubled cloth (i.e. the front and the back with the fold along the shoulder) is then folded lengthwise and cut into two along this fold, producing each side of the body of the shirt (i.e. half of the front and half of the back, attached together). Each side is then cut to form the shape of the body of the shirt, leaving about 20 centimeters at the top folded side for the arm holes (figure 67).

The neck hole: A paper model for the neck hole is cut. For the Chinese shirt, the neck hole is generally cut about the size of the neck



រូបលេខ ៦៨៖ របៀបលាក្រណាត់កាត់វង្វង់កអាវ។

Figure 68: The cloth for the body of the shirt spread out for cutting the neck hole.



រូបលេខ ៦៩៖ តួខ្លួនអាវក្រោយពីកាត់វង្វង់កសួច។

Figure 69: The body of the shirt with the cut neck hole and the joined side sections.



រូបលេខ ៧០៖ កវិល។

Figure 70: Neck basting.

of the wearer so that when the shirt is finished, the neck is neither too tight or too loose. The round paper model is folded in half and pinned to the front side of the shirt (figure 68). The neck hole is then cut following the edge of this paper model.

Finishing the neck: A piece of cloth, five centimeters longer than the length of the front of the shirt and about 28 centimeters wide is folded in half along its length. The paper model for the neck hole is attached five centimeters below the top of this folded strip of



រូបលេខ ៧១៖ ដៃអាវ។ Figure 71: Sleeves.

cloth. One circle is cut directly along the edge of the paper model, and a larger outer circle is cut about five centimeters out from the inner circle (figure 70). The resulting tie shaped piece of cloth forms the facing for the neck and button panel of the Chinese shirt.

Cutting the sleeves: The length of the sleeves for the Chinese shirt are measured from the middle of the top of the arm to the wrist. The cloth for the sleeves is cut after measuring the circumference of the armhole (a) and the circumference of the wrist (b) (figure 71).

Cutting the wind *santeh*: A long strip of cloth is measured from the neck to the waist, slightly below the navel where the last button will be, but above the bottom hem of the shirt. This piece of cloth is cut to be about six centimeters wide, and then is folded along its length to form the wind *santeh*. The wind *santeh* is sewn to the right side of the shirt, attached inside where the buttons are sewn. When the shirt is buttoned up, the wind *santeh* extends inside the shirt to cover the skin of the wearer when they bend forward or stretch during working. The left side of the shirt, with the buttonholes, does not have a wind *santeh* attachment. The Chinese shirt for men generally had button holes, while the Chinese shirt for women often used metal snap buttons to close the shirt.

កអ្នកពាក់នោះទេ ព្រោះកអាវចិន ពេលដេរួចយក មកពាក់ល្មមក មិនឲ្យចង្អៀតឬលុងពេក) យកមកបត់ ជាពីរដាក់ខ្នាស់លើអាវ រួចកាត់តាមរាងក្រដាស។

– កវិល (រូបលេខ៧០)៖ គេយកក្រណាត់ ប្រវែងសម្រុងអាវ និងទទឹងប្រហែល២៨សង់ទីម៉ែត្រ មកបត់ជាពីរតាមបណ្តោយសាច់ក្រណាត់ រួចយក ក្រដាសពុម្ពដែលកាត់កអាវនោះមកវាស់កាត់កវិល ដោយដាក់ក្រដាសពុម្ពចុះក្រោម៥សង់ទីម៉ែត្រ រួច កាត់ចេញជារាងកវិល ដើម្បីយកមកទ្រាប់ជុំវិញរង្វង់ កអាវ និងកន្លែងដាក់ឡេវ។

– ដៃអាវ (រូបលេខ៧១)៖ សម្រុងដៃ គឺ គេវាស់ចាប់ពីពាក់កណ្តាលដើមដៃ គឺវាស់បន្តពី កន្លែងវាស់ស្មារហូតមកត្រឹមកដៃ។

– សង្ហៀរឡស់ (រូបលេខ៧២)៖ កាត់សង្ហៀរ ឡស់ គេយកក្រណាត់វាស់ពីត្រឹមកចុះមកដល់ត្រឹម



រូបលេខ ៧២៖ សន្ទះខ្យល់ និងក្រណាត់ទ្រាប់ផែក៤សន្លឹក។

Figure 72: The wind *santeh* (left) and the four strips of cloth used to line the side slits (right).



រូបលេខ ៧៣៖ ហោចេ៉ា និងក្រណាត់ចំក។

Figure 73: The pockets and the neck facing.

ចង្កេះ (ក្រោមជ្រុងបន្តិច) គេមិនដាក់សន្ទះខ្យល់នេះដល់ជាយអាវទេ គឺត្រឹមចង្កេះ ឬត្រង់កន្លែងដាក់ឡវក្រោមគេ។ ប្រវែងទទឹងសន្ទះខ្យល់ យក១សង់ទីម៉ែត្រដោយបត់ជាពីរតាមបណ្តោយសាច់ក្រណាត់។ សន្ទះខ្យល់គេដាក់តែខាងស្តាំ គឺខាងដាក់ឡវ ចំណែកម្ខាងទៀតសម្រាប់ចោះរន្ធឡវនោះ គេមិនដាក់សន្ទះខ្យល់ទេ។ ចំពោះអាវចិនប្រុស ជាទូទៅគឺចោះរន្ធដាក់ឡវតែអាវចិនស្រីគេដាក់ឡវគឺប។

– ក្រណាត់ទ្រាប់ផែក (រូបលេខ៧២)៖ គេកាត់ក្រណាត់ឲ្យវែងជាងផែកតាមបណ្តោយសាច់ក្រណាត់ចំនួន៤សន្លឹក។

– ហោចេ៉ា (រូបលេខ៧៣)៖ គេកាត់ហោចេ៉ាពីរខាងក្រោមទំហំប៉ុនគ្នា ឯហោចេ៉ាខាងលើគេកាត់ឲ្យតូចជាងបន្តិច។

– ក្រណាត់ចំក (រូបលេខ៧៣)៖ គេកាត់ក្រណាត់បញ្ចិតមួយបន្ទះ ដើម្បីធ្វើជាក្រណាត់ចំកអាវ។

Facing for the side slits: Four strips of cloth are cut to be slightly longer than the side slits. These cloth strips form the facing or lining of the side slits.

The pockets: The two bottom pockets of the Chinese shirt are cut to be equal in size. The upper pocket of the male Chinese shirt is cut to be slightly smaller than the two bottom pockets.

The neck: The neck finishing is a long, diagonally cut strip of cloth, attached to the neck to finish the seam.

Sewing the shirt

The Chinese shirt is characterised by its back and side seams, and by sleeve seams which are found at the upper arm, rather than at the shoulder. The pieces of the shirt are first

រៀបដេរ

លក្ខណៈពិសេសរបស់អាវចិន គឺមានថ្នេរខ្ពង មានផៃកទាំងសងខាង និងតែងដៃអាវត្រឹមពាក់កណ្តាលដើមដៃ។

- *ត្រូវដេរភ្ជាប់ខ្នង (ប្រើថ្នេរមូល)*
- *ត្រូវដេរភ្ជាប់កវិល, សន្ទះខ្យល់ (ប្រើថ្នេរថយហ្គ័ង)*
- *ត្រូវដេរចំក (ប្រើថ្នេរថយហ្គ័ង)*
- *ត្រូវដេរផៃក (ប្រើថ្នេរថយហ្គ័ង)*
- *ត្រូវភ្ជាប់ដៃជាមួយតួអាវ (ប្រើថ្នេរមូល)*
- *ត្រូវភ្ជាប់ខ្លួន (ប្រើថ្នេរមូល)*
- *ត្រូវដេរហោជ៉ា (ប្រើថ្នេរថយហ្គ័ង)*
- *ត្រូវបត់ជាយអាវ (ប្រើថ្នេរថយហ្គ័ង)*
- *ត្រូវបត់ចុងដៃ (ប្រើថ្នេរថយហ្គ័ង)*
- *ត្រូវចោះរន្ធឡេវ ជាទូទៅមានចំនួន៥*
- *ត្រូវដាក់ឡេវ។*

ជ- អាវម៉ាទីណេ

យើងមិនដឹងថាពាក្យ"ម៉ាទីណេ" មានន័យយ៉ាងណានោះទេ តែស្មានថាប្រហែលជាឈ្មោះសម្រាប់សម្គាល់ម៉ូតអាវនេះ ឬជាឈ្មោះមនុស្សដែលចេញម៉ូតអាវនេះ ឬជាឈ្មោះយីហោណាមួយ។ អាវម៉ាទីណេមានសម្រុងខ្លួនខ្លីត្រឹមចង្កេះ ដីបរាង ដៃខ្លី ថ្ងៃត្រង់ស្មា រីកធំនៅចុងដៃ អត់មានសន្លឹកកមានឡេវមុខ។ អាវម៉ាទីណេទើបមានប្រើនៅស្រុកខ្មែរ

provisionally sewn together using a loose basting stitch. The garment is then adjusted to fit the intended wearer. Seams are finalised as follows. The back and side seams of the shirt are sewn with a round seam; the neck lining and the wind *santeh* are sewn with backwards stitching; the neck and slit lining are finished with backwards stitching. The sleeves are fastened to the body of the garment with round seams. The pockets are attached with backwards stitching, and all hems are finished with backwards stitching. The male Chinese shirt generally has five buttons and buttonholes.

Matinet shirt

We are not sure what the name of this shirt means, but perhaps *matinet* was a brand name, designer, or store name associated with this kind of shirt. The *matinet* shirt is short, ending at the waist. The sleeves of the shirt are short and puff out at the shoulders. The shirt has no collar and is buttoned down the front. The *matinet* shirt began to be worn when the French came to Cambodia. It was a shirt generally worn by women who had married already, and few younger unmarried women wore this shirt. *Matinet* shirts were worn to weddings or ceremonies. They were worn with a *sampot* tied in the *kben* or *samloy* style. According to our elderly interviewees,

រូបលេខ ៧៤៖
អាវម៉ាទីណេ កមូល ដៃខ្លី។

Figure 74: A *matinet* shirt with a round neck and short sleeves.



រូបលេខ ៧៥៖
អាវម៉ាទីណេកអែន ដៃខ្លី។

Figure 75: A *matinet* shirt with a curving scallop neck and short sleeves.

នៅពេលចាកាំងចូលមក ជាអាវដែលស្រីរៀបការរួចនិយមពាក់។ ឯអ្នកនៅលីវតម្រូវឃើញមានពាក់អាវនេះណាស់។ នៅពេលរៀបការនិងក្នុងពិធីផ្សេងៗ គេនិយមពាក់អាវម៉ាទីណេជាមួយសំពត់ចងក្បិន ឬសំពត់សម្ពុយ។ តាមពាក្យចាស់ខ្លះនិយាយថា នៅក្នុងទសវត្សរ៍១៩៤០ អាវនេះជាប្រភេទអាវធើតជាងគេនិងជាអាវដែលអ្នកនៅភ្នំពេញនិយមពាក់។ គេអាចថ្មែបានច្រើនឲ្យប្លែកៗនៅលើកអាវ និងដៃអាវ។ គេច្រើនថ្មែកអាវទៅជាកមូល, កកំពត, កស្លឹកពោធិ៍, កជប៉ុន, កជ្រុងស្មោះ, កជ្រុងអែន (រូបលេខ៧៥), កអ៊ុយ។ នៅលើអាវមានលំអដូចជា ចំកជាក្រណាត់ប៉ាក់ឱិន, ជាបួ។ រីឯដៃមានដាក់ជរ ជួនជីបជាកងប៉ោងទៅតាមការនិយម។ តាមសម្តីលោកយាយសួង ម៉ាលី អាយុ៧១ឆ្នាំ នៅខេត្តកំពង់ធំ និយាយថា "គេចនាម៉ូតលើដៃ និងកអាវ គឺដើម្បីឲ្យមើលឃើញកងធើតតាមសម័យនិយម"។ លោកយាយស្រី សម្បត្តិ អាយុ

in the 1940s, the *matinet* shirt was considered very beautiful and was worn especially by those living in Phnom Penh. The type of neck and sleeves of the shirt had many possible variations. The neck of the shirt could be round, V-necked, U-necked, shawl collared, square collared, or in a curving scalloped shape (figure 75). The shirt could also be embroidered with gold or silver thread around the neck, or decorated with bows. Sleeves could be embroidered, and were often made to puff out by cutting the sleeves larger and making little pleats in them before attaching them to the body of the shirt. According to Suong Mali, 71 years old living in Kompong Thom Province, "The decorating of the sleeves and neck was so that the shirt would look beautiful according to fashion." Sambet, 77 years old living in Kandal Province, told us, "I wore the *matinet* shirt

រូបលេខ ៧៦៖ លោកយាយសរ ខាត់ ពាក់អាវម៉ាទីណៃដៃខ្លី កមូលស្លៀកសំពត់ចង់ក្បិន។ ថតឆ្នាំ១៩២៥។
(រូបថត៖ ត្រូសារអ្នកមីងយក់ ប៊ុច)

Figure 76: Sar Khat wearing a short sleeved, round collar *matinet* shirt with a *sampot* tied in the *kben* style. Photographed in 1925.
(Photo: Collection of the family of Yok Pech)



រូបលេខ ៧៧៖ លោកយាយ យ៉ៅ ហូរ ពាក់អាវម៉ាទីណៃក្រណាត់ ប៉ាក់ ស្លៀកសំពត់ចង់ក្បិន ថតជាមួយប្តីនៅឆ្នាំ១៩៥៩។
(រូបថត៖លោកយាយយ៉ៅ ហូរ)

Figure 77: Yau Ho wearing a *matinet* shirt made of *bak* cloth with a *sampot* tied in the *kben* style. Photographed with her husband in 1959.
(Photo: Collection of Yau Ho)

៧៧ឆ្នាំ នៅខេត្តកណ្តាល និយាយថា "ខ្ញុំពាក់អាវម៉ាទីណៃដែធំខ្លីមានជីបជ៉ាង ហើយជីបកាងបន្តិច ស្លៀកជាមួយសំពត់ចង់ក្បិន។ កាលខ្ញុំនៅអាយុ១៧-១៨ឆ្នាំ ពាក់អាវហ្នឹងពេលទៅបុណ្យ"។

អាវម៉ាទីណៃមួយប្រើក្រណាត់១,២ម៉ែត្រ ហើយក្រណាត់ដែលយកមកកាត់អាវនេះអាចប្រើ

with big short sleeves that had puffy pleats in them. The shirt had darts which made it somewhat form-fitting. That *matinet* shirt, I wore it with a *sampot* tied in the *kben* style when I went to ceremonies when I was 17 and 18 years old."

One *matinet* shirt required one meter and twenty centimeters of cloth. Many types of

រូបលេខ ៧៨៖ លោកយាយថង សុីម ពាក់អាវម៉ាទីណៃដៃខ្លី។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 78: Thong Sem wearing a *matinet* shirt with short sleeves. Photographed 2002. (Photo: Reyum)

រូបលេខ ៧៩៖ លោកយាយ ភី អាយុ ៨៣ឆ្នាំ ពាក់អាវម៉ាទីណៃក្លាយដោយថ្នៃជាដៃវែង។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 79: Phi wearing a *matinet* shirt which has been adapted to have long sleeves. Photographed 2002. (Photo: Reyum)

ក្រណាត់បានច្រើនប្រភេទទៅតាមលទ្ធភាពរបស់អ្នកពាក់ ដូចជាទេសឯក, សារូ, ប៉ាក់, ឈុនទីវជាដើម។ បច្ចុប្បន្ននៅមានអ្នកនិយមពាក់អាវម៉ាទីណៃនៅឡើយភាគច្រើនជាមនុស្សចាស់ចាប់ពីអាយុ៥០ឆ្នាំ។ អាវម៉ាទីណៃខ្លះ គេថ្នៃឲ្យមានដៃត្រកៃ (៣ ៤) ហើយគេហៅថាអាវម៉ាទីណៃក្លាយ។ ដោយសារអាវនេះមានគេនៅប្រើច្រើនហួតសព្វថ្ងៃ យើងមិនបានលើកយកវិធីបែបកាត់មកបង្ហាញទេ។

cloth were used for the shirt depending on the taste and wealth of the wearer. Types of fabric used to make matinet shirt included *des aik*, *saru*, *bak*, and *chun teo* cloth. Today, elderly people over the age of fifty still like to wear the *matinet* shirt. It is sometimes adapted to have three-quarter sleeves, and this type of shirt is called the changed *matinet*. Since the *matinet* shirt is still quite commonly worn today, we don't show the way that it is cut and sewn.

ជ- អាវកុតកត្រង់

ជាប្រភេទអាវដែលមានកណ្ឌត្រង់ ដៃវែង ខ្លួនធំស្រុងត្របត្រគាក មានឡវមុខ។ ដោយសារមានកណ្ឌត្រង់ទើបអ្នកខ្លះហៅថាអាវកត្រង់។ អាវនេះច្រើនប្រើក្រណាត់ក្រាស់ៗ។ អាវកុតជាប្រភេទអាវ

The *kut* shirt

This type of shirt has a distinctive straight collar, long sleeves, a generous body that covers the hips, and buttons down the front. Some people call this shirt the straight collar shirt. The shirt was generally made from quite thick cloth. The *kut* shirt was con-

ដែលបញ្ជាក់ពីឋានៈ មុខងារផ្សេងៗនៅក្នុងសង្គម។ អ្នកដែលពាក់អាវកុតស្បៃកសំពត់ចងក្បិនច្រើនជាអ្នកធ្វើជំទប់ មេឃុំ មេស្រុក ពិសេសអ្នកធ្វើរាជការ។ នៅចុងសតវត្សទី១៩ អ្នកធ្វើរាជការនិយមពាក់អាវកុតកត្រង់ ស្បៃកសំពត់ចងក្បិនគ្មានពាក់ស្បែកជើង។ ក្រោយមក (ដើមសតវត្សទី២០) ឃើញមានអ្នកខ្លះពាក់អាវកុតកត្រង់ស្បៃកសំពត់ចងក្បិនពាក់មួកសស្បែកជើងខ្វៃនិងមានស្រោមជើងផង។ ចំពោះសំពត់ចងក្បិនជាទម្លាប់ខ្មែរ ឯការពាក់មួក ពាក់ខ្វៃជាទម្លាប់ជាវាំង។ បច្ចុប្បន្នអាវកុត ឃើញមានពាក់តែក្នុងពិធីមង្គលការ និងពិធីបុណ្យផ្សេងៗតែប៉ុណ្ណោះ។

sidered a sign of high rank and, at the end of the 19th century, government officials generally went barefoot and wore the *kut* shirt with the *sampot* tied in the *kben* style. At the beginning of the 20th century, some officials started to wear the straight necked *kut* shirt and a *sampot* tied in the *kben* style with white hats, shoes, and socks to cover their feet, thus borrowing French habits and adding them to an existing Khmer tradition of dress. Today the *kut* shirt is only worn on ceremonial occasions and for weddings.

រូបលេខ ៨០៖ ចៅហ្វាយខេត្តសៀមរាប ថត ឆ្នាំ១៩០០។ (រូបថត៖ បណ្ណសារជាតិ)

Figure 80: Governor of Siem Reap Province. Photographed 1900. (Photo: National Archives of Cambodia)

រូបលេខ ៨១៖ ក្រុមរាជការ ពាក់អាវកុតកត្រង់ ស្បៃកសំពត់ចងក្បិន ដង្ហែស្តេចមាយក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ឆ្នាំ២០០៣។ (រូបថត៖ ព្រាប ចាន់ម៉ារ៉ា)

Figure 81: A group of officials wearing *kut* shirts with straight collars and *sampot* tied in the *kben* style on the occasion of the Royal Ploughing Ceremony, 2003. (Photo: Preap Chan Mara)

រូបលេខ ៨២៖ បុរសមួយក្រុមពាក់អាវកុតកត្រង់ស្លៀកសំពត់ចង្កឹង។ គំនូរនៅលើជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០។ (រូបថត៖ រៃយ៉ំ)

Figure 82: A group of men wearing *kut* shirts with straight collars and *sampot* tied in the *kben* style, as painted on the walls of Wat Kompong Tralach Leu, early 20th century. (Photo: Reyum)

៨- ក្បិន និង សម្ពុយ

តាមទំនៀមទម្លាប់ខ្មែរមានស្លៀកសំពត់ជាយូរមកហើយ គឺគេយកមកវ័ណ្ឌ។ សំពត់ជាសម្លៀករបស់មនុស្សប្រុស និងស្រី។ គេអាចស្លៀកបានពីររបៀប គឺស្លៀកជាក្បិន និងស្លៀកជាសម្ពុយ។

ក្បិន

នៅសម័យបុរាណមានតែបុរសទេ ដែលស្លៀកសំពត់ចង្កឹង ស្ត្រីមិនឃើញស្លៀកទេ។ តែមកដល់ចុងសតវត្សទី១៩ សំពត់ចង្កឹងឃើញស្លៀកបានទាំងស្រី ទាំងប្រុស។ ដើម្បីស្លៀកជាសំពត់ចង្កឹងត្រូវប្រើក្រណាត់ប្រវែងបណ្តោយ៣ម៉ែត្រទៅ៣ម៉ែត្រ ៦តឹកចំពោះមនុស្សស្រី ហើយ៣ម៉ែត្រ៦តឹកចំពោះ

Sampot tied in the *kben* and *samloy* styles

Khmer have worn *sampot* for a long time, wrapping the simple length of cloth around their bodies. The *sampot* was worn by both men and women. The *sampot* could be worn either in the *kben* or in the *samloy* style.

Kben

In ancient times, only men wore the *sampot* tied in the *kben* style. By the end of the 19th century however, both men and women wore the *sampot* tied in the *kben* style. The female version of the *sampot* tied in the *kben* style required a length of cloth 3 meters to 3 meters 20 centimeters, while the male

មនុស្សប្រុស។ ពេលស្លៀក ភាគច្រើននិយមទុកជាយ
សងខាង ដោយមិនដេរភ្ជាប់គ្នាឡើយដើម្បីផ្ដុំធ្វើជា
រមូរកន្ទុយក្បាល។ របៀបស្លៀក គឺដំបូងគេយកសំពត់
មកលាត្រង់ កាន់ចុងសងខាងតាមបណ្ដោយសំពត់
រួចយកមករុំត្រឹមចង្កេះពីក្រោយមកមុខដោយលៃយ៉ាង
ណាផ្ដួបចុងសំពត់សងខាងឲ្យស្មើគ្នា (ទោះបីខុសគ្នាក៏
ខុសត្រឹមមួយទះ គឺប្រហែល៩សង់ទីម៉ែត្រ) ហើយ
គេចាប់ជាយសងខាងសំពត់ខាងលើដែលនៅជិតពោះ
មកតួចចុងឲ្យជាប់ ហើយស៊កចូលក្នុងចង្កេះសិន ទើប
គេមូរជាយខាងមុខ។ មូរបណ្ដើរច្បូតបណ្ដើរដល់ចុង
ជាយ (រូបលេខ៨៤) ពេលកំពុងមូរនោះគេត្រូវឈរ
កន្លែកជើងបន្តិច ដើម្បីងាយស្រួលដើរពេលចងក្បាល
រួច។ រួចគេស៊កកន្ទុយក្បាលតាមប្រឡោះជើងយកទៅ
ចុកនៅចង្កេះក្រោយ (រូបលេខ៨៥)។ ឯសម្រុងសំពត់



*រូបលេខ ៨៣៖ ស្លៀកសំពត់ចងក្បាល បង់គ្រមា (ពេលនៅផ្ទះ)។
គំនូរលើជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០។
(រូបថត៖ រៃយំ)*

Figure 83: At home, wearing *krama* and *sampot* tied in the *kben* style. Painting on the walls of Wat Kompong Tralach Leu, early 20th century. (Photo: Reyum)

version required a *sampot* that was generally 3 meters and 60 centimeters in length. In general, the *sampot* to be worn as a *kben* was left as a long length of cloth, not sewn together at the ends. In order to wear the *sampot* in the *kben* style, the *sampot* was first smoothed and straightened, holding onto both of its ends. The *sampot* was then held behind the waist and pulled around to the front, joining the two ends so that they extended out evenly in the front (or were only slightly different in length). At the stomach, each side of the top edge of the *sampot* was clutched and pulled into a bunch of cloth which was then wound around the other one and tucked into the waistband. The long ends of the *kben* still extending out to the front of the stomach were then rolled along their upper edge into a long roll or tail (figure 84). While rolling, the wearer stood with their legs slightly apart so that when the *kben* was tied, it was still easy to walk. This rolled length of cloth - the tail of the *kben* - was tucked between the legs and up over the buttocks to be inserted into the waist at the back (figure 85). In the front, the *sampot* tied in the *kben* style fell to the lower leg (figure 86). At home, the *sampot* tied in the *kben* style was worn without a belt or string to hold it up. However, on long trips or when joining in various ceremonies, they would generally wear a belt, both in order to hold the *sampot* up and as decoration. Fabrics

រូបលេខ ៨៤៖ របៀបស្លៀកសំពត់ចង្កេះ ក្បិន (លោកយាយយ៉ៅ ហូវ នៅខេត្តសៀមរាប)។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយំ)

Figure 84: You Hou showing how to tie the *sampot* in the *kben* style. Siem Reap Province, Photographed 2003. (Photo: Reyum)

រូបលេខ ៨៥៖ មើលពីក្រោយ។ (រូបថត៖ រៃយំ)

Figure 85: The *sampot* tied in the *kben* style seen from the back. (Photo: Reyum)



រូបលេខ ៨៦៖ មើលពីមុខ។ (ពាក់អាវម៉ាទីណេ)។ (រូបថត៖ រៃយំ)

Figure 86: You Hou wearing a *sampot* tied in the *kben* style with a white *matinet* shirt, an outfit worn on ceremonial occasions. (Photo: Reyum)

ត្រូវស្លៀកធ្លាក់ចុះនៅត្រឹមពាក់កណ្តាលស្មងជើង (រូបលេខ៨៦)។ នៅផ្ទះគេស្លៀកសំពត់ចង្កេះក្បិន ដោយមិនចាប់ប្រើខ្សែចង ឬខ្សែក្រវាត់ឡើយ។ ប៉ុន្តែពេលធ្វើដំណើរឆ្ងាយ និងពេលទៅបុណ្យផ្សេងៗ គេមានដាក់ខ្សែក្រវាត់ពីលើដើម្បីឲ្យជាប់ និងស្អាតផង។ គេច្រើនយកជាមួង, ខៀន, ក្រណាត់អ៊ូ, ក្រណាត់ទេសឯកជាដើមមកស្លៀកជាសំពត់ចង្កេះក្បិន។

ជាទម្លាប់ពេលធ្វើការ ស្ត្រីនិយមពាក់អាវបំពង់វែងពណ៌ខ្មៅជាមួយសំពត់ចង្កេះក្បិន។ ម្យ៉ាងទៀត

popularly used for the *sampot* tied in the *kben* style include *pamuong*, *kien*, *ou*, and *des aik*.

When working, women traditionally wore long black tube shirts with *sampot* tied in the *kben* style. The thick rolled tail of the *kben* could protect from staining when women were menstruating (in earlier times, women did not wear underpants. See page 95). When there were special ceremonies, women wore *sampot* tied in the *kben* style with long tube shirts of various colors, or

រូបលេខ ៨៧៖ ស្ត្រីនៅខេត្តកំពង់ចាម ថតនៅដើមសតវត្សទី២០។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 87: Woman in Kompong Cham Province. Early 20th century.
(Photo: National Archives of Cambodia)

រូបលេខ ៨៨៖ កុង្សីយ៍ក្រសួងយុត្តិធម៌ ថត ឆ្នាំ១៨៨៨ ដោយលោក Faraut។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 88: Minister of Justice. Photographed 1888 by Faraut.
(Photo: National Archives of Cambodia)

រូបលេខ ៨៩៖ មន្ត្រីខ្មែរ ថតប្រហែលឆ្នាំ១៩០០។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 89: Cambodian officials photographed around 1900.
(Photo: National Archives of Cambodia)

រមូរក្បិននេះ អាចការពារការប្រឡាក់ពេលស្ត្រីមានរដូវ (ស្ត្រីពីមុនមិនមានខោទ្រនាប់សម្រាប់ស្លៀកឡើយ)។ នៅពេលមានបុណ្យទាន គេស្លៀកសំពត់ចង់ក្បិនជាមួយអាវបំពង់វែងពណិផ្សេងៗ មានអាវម៉ាឡាយូ, អាវម៉ាទីណេ, អាវចិនជាដើម ដោយមានបង់កក្រមា និងអ្នកហូបមួយមានសៀតកន្សែងក្រហមទុកជូតទឹកមាត់ស្អាតផង។ ចំណែកមនុស្សប្រុសគេនិយមស្លៀកសំពត់ចង់ក្បិនជាមួយអាវកត្រង់, អាវចិន, អាវសន្ទះជាដើម។ ជួនកាល គេស្លៀកសំពត់ចង់ក្បិនបង់កក្រមាទម្លាក់ជាយទៅក្រោយដោយលែងខ្លួនទទេ។

malayu, *matinet*, or Chinese shirts. On these occasions, they would wrap a *krama* around their neck and tuck a red cloth into their clothing for wiping their mouths when chewing betel. Men wore the *sampot* tied in the *kben* style with the straight neck *kut* shirt, the Chinese shirt, or the *santeh* shirt. Sometimes they wore the *sampot* tied in the *kben* style and simply went shirtless, wrapping a *krama* around their neck and letting the ends of it fall to the back.

រូបលេខ ៩០៖ ស្ត្រីស្លៀកសំពត់ចង់ក្បិនទៅខេត្តសៀមរាប។ ថតឆ្នាំ១៩៩៩។ (រូបថត៖ ព្រាប ចាន់ម៉ារ៉ា)

Figure 90: Women wearing *sampot* tied in the *kben* style. Photographed in Siem Reap Province, 1999. (Photo: Preap Chan Mara)

បើពិនិត្យមើលលើរូបចម្លាក់តាមប្រាសាទបុរាណ និងលើបដិមាជាច្រើនមុនសម័យអង្គរឃើញសុទ្ធតែមនុស្សប្រុសស្លៀកសំពត់ចង់ក្បិន។ មានខ្លះស្លៀកសំពត់ចង់ក្បិនខ្លី ខ្លះស្លៀកសំពត់ចង់ក្បិនវែង។ ចំណែកមនុស្សស្រីស្លៀកសំពត់សម្លូយ។ នៅសម័យអង្គរ ឃើញស្ត្រីខ្លះស្លៀកសំពត់ខ្លីត្រឹមពាក់កណ្តាលភ្លៅ ហើយមួរកន្ទុយក្បិនបត់ទៅក្រោយស្រដៀងក្បិនសព្វថ្ងៃដែរ។

នៅទសវត្ស១៩៤០ មានសង្គ្រាមលោកលើកទី២ ស្រុកច្របូកច្របល់ ជាកង់ត្រប់ត្រង់មិនបានហ្មត់ចត់ សៀមក៏ជ្រៀតចូលមកត្រប់ត្រង់ខេត្តបាត់ដំបង ខេត្តសៀមរាបឡើងវិញ។ ពេលនោះមានចាស់ៗចាំថា សៀមបានបង្ខំឲ្យខ្មែរឈប់ស្លៀកក្បិន និងមិនឲ្យស៊ីម្ហូ។ នេះប្រហែលជាស្របជាមួយនឹងស្រុក

If we look at the reliefs found on the ancient temples as well as the sculptures dating to before Angkorian times, we find that it was only the men who were depicted wearing *sampot* tied in the *kben* style, either short or long in length. Women were depicted wearing *sampot* in the *samloy* style. In Angkorian times, women were sometimes represented wearing a kind of short *sampot* which reached only to the middle of their thighs. This garment was wound into a rolled tail which was tucked between the legs and drawn up to the waist in the back as in the *kben* style.

In the 1940s, during the chaos and confusion of World War II, the Thai briefly ruled Battambang and Siem Reap Provinces again. Our elderly interviewees remember that the Thai forced the Khmer to stop wear-

សៀមកំពុងឈានទៅរកគាពទំនើប ម្ល៉ោះហើយ រាជការក៏មានការបង្ខំឲ្យប្រជាជនខ្លួនចោះបង់ទម្លាប់ចាស់ដែរ។ ឧទាហរណ៍ លោកយាយចៃង សួន អាយុ៧៩ឆ្នាំ នៅខេត្តបាត់ដំបង រៀបរាប់ថា "នៅពេលដែលខ្ញុំអាយុជាង២០ឆ្នាំ សៀមបានមកគ្រប់គ្រងខ្មែរ គេបង្ខំស្រីខ្មែរឲ្យឈប់ស្លៀកក្បិនប្តូរមកស្លៀកសំពត់សម្ពុយវិញ និងមិនឲ្យស៊ីស្លាម្ព។ តែដោយខ្ញុំមិនធ្លាប់ ទើបពេលទៅវត្ត និងទៅផ្សារ ខ្ញុំតែងស្លៀកសម្ពុយពីក្រៅ ក្បិនពីក្នុង ដើម្បីបំភ័ន្តរាជការសៀម។ ហេតុនេះហើយ ទើបខ្ញុំនៅតែស្លៀកក្បិនរហូតដល់សព្វថ្ងៃនេះ"។ បើតាមលោកយាយមុម សំអឿន អាយុ ៧៧ឆ្នាំ និយាយថា "អ្នកស្រុកទូទៅតែងយល់ថា នៅ

ing the *kben* style and to stop chewing betel. This perhaps coincided with similar national policies of modernisation within Thailand at that time which wished to dissuade Thai citizens from practicing certain traditional habits. According to Jaing Suon, 79 years old living in Battambang Province, "When I was more than 20 years old, the Thai came to rule over the Khmer. They forced Khmer women to stop wearing the *kben* style in favor of the *samloy* style. They also wouldn't let us chew betel either. Since I wasn't used to wearing a *samloy*, I wore it to the temple or to the market over a *kben* which I wore underneath, thus fooling the Thai authorities. That's why

រូបលេខ ៥១៖ ក្មេងប្រុសស្លៀកក្បិនពេលទៅបុណ្យ។ គំនូរនៅលើជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០។ (រូបថត៖ រៃយំ)

Figure 91: A young boy going to a ceremony wearing a *sampot* tied in the *kben* style. Painting on the walls of Wat Kompong Tralach Leu, early 20th century. (Photo: Reyum)

ពេលស្លៀកសម្ពុយខ្លាចព្រះធរណីឃើញត្រពោក និងពិបាកក្នុងការអង្គុយ ទើបមានពាក្យដំណៀលរបស់អ្នកបាត់ដំបងដៀលអ្នកភ្នំពេញថា គេមិនស្លៀកស្តើតដូចអ្នកភ្នំពេញទេ គេស្លៀកសំពត់ចង់ក្បិន ដើម្បីកុំឲ្យនាងតន្លឹងឃើញត្រពោក (មានន័យថាអ្នកខាងកើតស្លៀកស្តើតតឹសម្ពុយ តែគេហៅស្តើតតាមភាសាអង់គ្លេស)"។ ហេតុនេះរហូតមកដល់បច្ចុប្បន្ន ទម្លាប់ស្លៀកសំពត់ចង់ក្បិននៅតែមានច្រើននៅខេត្តបាត់ដំបង ខេត្តសៀមរាប។ សំពត់ចង់ក្បិន គេអាចស្លៀកបានគ្រប់ពេល ទាំងពេលបុណ្យ ពេលធ្វើការ និងពេលនៅផ្ទះ។

សម្ពុយ

ជាសំពត់ដែលគេស្លៀកទម្លាក់ជាយម្ខាងចុះក្រោមដូចជាស្លៀកស្បង់ ឬស្លៀកសារុងដែរ។ តាមវចនានុក្រមសម្តេចសង្ឃ រាជ ជួន ណាត បានពន្យល់ថា សម្ពុយមកពីពាក្យថាស្ពុយ មានន័យថាយារសម្រុងចុះក្រោម។ យើងសង្កេតឃើញ សំពត់សម្ពុយមានស្លៀកតាំងពីយូរណាស់មកហើយ។ ភាគច្រើនសំពត់សម្ពុយសម្រាប់មនុស្សស្រី។ បើយើងសង្កេតមើលលើបដិមាបុរាណ ព្រះនាងទុគ៌ា នៅសតវត្សទី ៧ (ក្នុងសារមន្ទីរជាតិ ភ្នំពេញ) មានស្លៀកសំពត់សម្ពុយដែលមានជើបផ្តត់អង្ករាញ់រមកខាងមុខ ហើយស្រុងវែងរហូតដល់ភ្នែកគោល។

I still wear the *sampot* tied in the *kben* style today." According to Mom Samuen, 77 years old, "All the people in the countryside thought that if you wore the *samloy*, the earth god would see your buttocks. It was also difficult to sit in. People in Battambang would mock people from Phnom Penh saying, 'We don't wear skirts like people in Phnom Penh. We wear *sampot* tied in the *kben* style so that the earth goddess doesn't see our genitals and get embarrassed'." Thus, even today, many people living in Battambang and Siem Reap Provinces still have the habit of wearing the *sampot* tied in the *kben* style. *Sampot* tied in the *kben* style can be worn for all occasions including ceremonies, work, and simply for staying at home.

Samloy

According to the 1967-68 Buddhist Institute Cambodian Dictionary, the word *samloy* comes from *sloy* which means to hang down. *Sampot* worn in the *samloy* style have been worn for a long time, particularly by women. An ancient sculpture of Preah Neang Dukea, dating to the 7th century and presently on display at the National Museum in Phnom Penh, depicts her wearing a *sampot* in the *samloy* style with an accordion pleat extending all the way down to the hem at the front of the garment. The *sampot* in the *sam-*

រចៀបស្លៀកសំពត់សម្ពុយ គឺយកក្រណាត់សំពត់ប្រវែង១ម៉ែត្រ៨តឹកទៅ២ម៉ែត្រមកដេរភ្ជាប់ជាយបានជាថង់សំពត់។ នៅពេលស្លៀក គេចាប់ចុងថង់សំពត់មកជីបជាផ្នត់ រួចចុកនៅត្រង់ពោះចំពីមុខ។ នេះជាទម្លាប់តាំងពីមុនមក។ ក្រោយមកយើងឃើញមានរចៀបស្លៀកផ្សេងមួយទៀត គឺគេបត់ចុកនៅចំហៀង ផ្នែកខាងធ្វេង ឬខាងស្តាំ ស្លៀកបានទាំងស្រីទាំងប្រុស។ ទម្លាប់ស្លៀកបែបនេះ ខ្លះថាស្លៀកដូចចាម ព្រោះចាមនិយមស្លៀកបែបនេះ។ ចំពោះសំពត់សម្ពុយខ្មែរ ពីមុនគេច្រើនយកក្រណាត់មុយអា, ក្រណាត់ទេសឯក, ហូលជាដើម មកស្លៀកធ្វើជាសំពត់សម្ពុយ។ ក្រោយមកប្រហែលនៅទសវត្សរ៍ ១៩៤០ មានសំពត់សម្ពុយម្យ៉ាងទៀតហៅថា សារុង។

loy style required a length of cloth between 1 meter and 80 centimeters to 2 meters, the ends of which were sewn together to form a kind of bag or cylinder of cloth. To wear the *sampot* in the *samloy* style, one stepped into this bag-like cylinder of cloth, pulling it tightly around the back of the waist and drawing the excess cloth to the front of the stomach. The large portion of cloth extending out from the stomach was folded back towards the body in a series of accordion like pleats which were then tucked into the waistband. This was the traditional way of wrapping the *sampot* in the *samloy* style.

Later on, different ways of folding the *sampot*, still called the *samloy* style, developed.

រូបលេខ ៩២៖ មនុស្សប្រុសស្លៀកសារុងសូត្រពេលធ្វើការ នៅដើមសតវត្សទី២០។ (រូបថត៖ បណ្ណសារជាតិ)

Figure 92: Men wearing silk *sarong* while working. Photographed in the early 20th century. (Photo: National Archives of Cambodia)

រូបលេខ ៩៣៖ ស្ត្រីស្លៀកសំពត់សម្ពុយ ប្រុសស្លៀកក្បិនទៅវត្ត រូបគំនូរលើជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០ (រូបថត៖ រ៉ៃយ៉ំ)

Figure 93: Women wearing *sampot* in the *samloy* style and men wearing *sampot* tied in the *kben* style when going to the temple. Painting on the walls of Wat Kompong Tralach Leu, early 20th century. (Photo: Reyum)

រូបលេខ ៩៤៖ រូបឃាយឈរខាងស្តាំពាក់អាវចិន ស្លៀកសំពត់សម្ពុយ និងឃាយឈរខាងឆ្វេងពាក់អាវម៉ាទីណេ ស្លៀកសំពត់សម្ពុយ។ ថតឆ្នាំ១៩៧០។ (រូបថត៖ គ្រួសារលោកតាជុំ កេន)

Figure 94: The woman on the right is wearing a Chinese shirt with a *sampot* in the *samloy* style. The woman on the left is wearing a *matinet* shirt with a *sampot* in the *samloy* style. The men are wearing Western clothing. This family photograph was taken in 1970. (Photo: Collection of the late Jum Kain)

រូបលេខ ៩៥៖ ពេលនៅផ្ទះ គេស្លៀកសារុងសូត្រ។ ថតទសវត្សរ៍១៩៦០។ (រូបថត៖ លោកមៃខឺល វិកខឺរី)

Figure 95: At home, men often wore checked silk *sarong*. Photographed 1960s. (Photo: Dr. Michael Vickery)

សារុងក៏ស្លៀកដូចសម្ពុយដែរ គ្រាន់តែគេហៅតាមប្រភេទសំពត់ដែលគេនាំចូលមក។ ចំពោះសារុងដែលខ្មែរប្រើមានពីរប្រភេទគឺ សារុងស្រែ និងសារុងប្រុស។ សារុងស្រីសុទ្ធតែមកពីបរទេស ហើយអាចស្លៀកបានតាមទម្លាប់ខ្មែរដូចសម្ពុយដែរ។ ឯសារុងប្រុសច្រើនតែត្បាញក្នុងប្រទេស ហើយស្លៀកបានតែក្នុងផ្ទះដោយពុំទម្លាប់ស្លៀកដើរចេញក្រៅផ្ទះឡើយ។ ព្រោះពីមុនមកប្រុសមានទម្លាប់ស្លៀកតែសំពត់ចង្កឹន។ សារុងប្រុសច្រើនជាសារុងសូត្រ ដោយសារគេច្រើន

Sometimes the excess cloth was simply folded once either to left or the right side of the garment and then tucked under the waistband. Both men and women wore the *samloy* like this. Some called this way of wearing the *samloy* the Cham way, since ethnic Cham people liked to wear *sampot* in this way. *Sampot* worn in the *samloy* style traditionally were made out of *prai muy a*, *des aik*, or *hol*. Later on, perhaps in the 1940s, another kind of *sampot* appeared on the market which became known as the

ត្បាញអំពីអំបោះសូត្រ។ រហូតមកដល់បច្ចុប្បន្ននេះក៏
នៅមានមនុស្សប្រុសស្លៀកសារុងសូត្រដែរ។

បច្ចុប្បន្ននេះ គេស្លៀកសំពត់ចងក្បិន និង
សំពត់សម្ពុយបានទាំងប្រុសទាំងស្រី ហើយគេស្លៀក
ក្បិននៅពេលមានពិធីផ្សេងៗ ពិសេសក្នុងព្រះរាជ
ពិធីរបស់ព្រះមហាក្សត្រ (ប្រើពណ៌តាមថ្ងៃនីមួយៗ)។
ចំពោះពេលធម្មតា គេមិនសូវស្លៀកទេ លើកលែង
ចាស់ៗនៅខេត្តសៀមរាប ខេត្តបាត់ដំបង និងតំបន់ខ្លះ
ទៀតដែលនៅរក្សាទំនៀមទម្លាប់ស្លៀកសំពត់ចងក្បិន
នេះ។ ឯសំពត់សម្ពុយគេនៅស្លៀកជាធម្មតា។

រូបលេខ ៩៦៖ លោកតាជា រ័ត្ន អាយុ៩០ឆ្នាំ នៅខេត្តកណ្តាល
ស្លៀកសារុងសូត្រពេលនៅផ្ទះ។ ឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 96: Chea Rot, 90 years old living in Kandal Province, wearing a silk *sarong* in his home. Photographed 2002. (Photo: Reyum)

sarong. The *sarong* is really just a *sampot*, or length of cloth, but the term *sarong* seems to have been used in order to designate *sampot* imported from abroad. *Sarong* were said to come in male and female versions. Women's *sarong* all came from abroad and could be worn in the traditional *samloy* style. Men's *sarong* came to be woven in Cambodia, and men generally wore them only in their homes; it was not considered to be a traditional habit for men to wear them outside, since previously they wore the *kben* style in public. The men's *sarong* generally came to be woven from a silk cotton mix. The habit of men wearing silk *sarong* in the home continues today. Today, many women wear *sampot* in the *samloy* style. It is only in Battambang, Siem Reap, and a few other particular regions - as well as for official palace ceremonies and cultural events - that women still regularly wear the *sampot* tied in the *kben* style.

In addition to these styles of wearing a *sampot*, the *sampot juppe* developed from European influences. The *juppe* is similar to the *samloy*, except for that the *sampot juppe* has a hook and eye clasp so that the ends are not tucked into the waist to hold it up.

ឯកសារខាងក្រោមនេះ យើងគ្រាន់តែដកស្រង់តាគខ្លះៗនៃអត្ថបទដែលកាសែតកម្ពុជាបានចុះ ដោយមានការតែសម្រួលអក្ខរាវិរុទ្ធ ដើម្បីជាគំនិតបន្ថែមប៉ុណ្ណោះ។ យើងមិនអាចវាយតម្លៃថា ឯកសារនេះត្រឹមត្រូវល្អនោះទេ។ តែជាឯកសារមួយធ្វើឲ្យយើងគិតពិចារណា និងខិតខំស្វែងរកពត៌មានបន្ថែមទៀត។

ការវិះរកខាងសម្លៀកបំពាក់ស្ត្រីខ្មែរ

(អត្ថបទដកស្រង់ពីកាសែតកម្ពុជា លេខ១៧៧៦ ថ្ងៃទី៥ កក្កដា ១៩៥១)

"An analysis of Khmer women's clothing", *Kampuchea*, July 5th, 1951

សម្លៀកបំពាក់ជាគ្រឿងសម្គាល់នៃជាតិ។ ប្រទេសណាក៏ដោយគេតែងតែមានសម្លៀកបំពាក់សម្រាប់ជាតិរបស់គេ។ ទោះបីអារ្យធម៌នៃប្រទេសនោះ ប្រែប្រួលទៅយ៉ាងណាក្តី សម្លៀកបំពាក់ក៏នៅតែដដែល បើនឹងប្រែប្រួលទៅខ្លះក៏ពុំចោលលំនាំដើមឡើយ។ ការរក្សាអប់រំនូវប្រពៃណីបែបនេះ គេទុកជាការធំបំផុត សម្រាប់សម្គាល់អារ្យធម៌របស់ប្រទេស។ ជាតិឥណ្ឌាដែលមានអារ្យធម៌បុរាណាប់ពាន់ឆ្នាំមកហើយ គេក៏បានរក្សាសម្លៀកបំពាក់គេនៅគង់វង់ទាំងអស់។ ប្រទេសជប៉ុន, ចិន, ភូមា បើកាប់តែប្រទេសដែលនៅជិតខាងយើង ក៏គេបានរក្សាប្រពៃណីរបស់គេដូច្នេះដែរ ដោយហោចទៅសូម្បីតែឆ្នង់ក៏គាន់ប្រពៃណីរបស់ខ្លួនមិនឲ្យសាបសូន្យឡើយ។ គេសួរឆ្នង់ថា ហេតុអ្វីក៏មិនស្លៀកខោ ពាក់អាវដូចជាខ្មែរ យួន ចិនទៅ។ ឆ្នង់តែងឆ្លើយតបមកវិញថា ខ្ញុំខ្លាចគេមិនស្គាល់ថា ខ្លួនខ្ញុំនេះជាឆ្នង់។ ការនេះសម្តែងឲ្យឃើញថា ជនជាតិនីមួយៗដែលស្រឡាញ់ជ័រជាតិរបស់ខ្លួននោះ គេតែងតែសប្បាយចិត្តនឹងការស្លៀកពាក់ តាមជាតិកំណើតរបស់គេដោយឥតគិតថា គេសើច គេយំយ៉ាងណាឡើយ។ ប្រទេសកម្ពុជាយើងក៏មានសម្លៀកបំពាក់ពិសេសសម្រាប់ជាតិដែរ។ អារ្យធម៌ខាងស្លៀកពាក់នេះ បានទាំងហៀរហូរទៅដល់ប្រទេសជិតខាង ក្នុងសុវណ្ណភូមិទៀតផង។ ព្រោះជាតិយើងកាលក្នុងសម័យព្រេងនាយជាមហាអំណាចទីបីបន្ទាប់ពីប្រទេសចិននិងឥណ្ឌាមក។ ហេតុដូច្នេះ គួរណាស់តែយើងវិះរករបៀបស្លៀកពាក់របស់យើងនៅគ្រប់សម័យយកមកតម្កល់ទុកប្រតិបត្តិកុំឲ្យសាបសូន្យ។

ប៉ុន្តែដើម្បីកុំឲ្យនិក្ខេបបទធំទូលាយពេក នាំឲ្យសន្និសីទនេះវែងហួសប្រមាណ យើងសុំរិះរកតែអំពីសម្លៀកបំពាក់ស្ត្រីប៉ុណ្ណោះសិន។ តើស្ត្រីខ្មែរយើងពីបូរាណមកមានសម្លៀកបំពាក់យ៉ាងណាខ្លះទៅ?

បើយើងតយតន់មើលចម្លាក់បុរាណដែលមាននៅលើផែនជញ្ជាំងអង្គរក្តី លើផែនជញ្ជាំងប្រាសាទបុរាណនានាទៀតក្តី យើងឃើញថា ស្ត្រីខ្មែរសម័យបុរាណមានស្លៀកត្រឹមតែសម្ពុយ ឥតមានពាក់អាវទេ។ រូបខ្លះស្លៀកសម្ពុយ ហើយមានស្បៃពានាព័ន្ធលើស្មាឆ្វេង សំយ៉ុងចុះទៅក្រោយខ្នងរបៀបបែបសារីរបស់ស្ត្រីឥណ្ឌា។ ការស្លៀកពាក់បែបនេះ ល្ងានក្បាច់បុរាណបានរក្សាទុកទាំងមូលឥតបោះបង់ចោលត្រង់ណាបន្តិចសោះ។ មិនត្រឹមតែប៉ុណ្ណោះទេ ក្នុងពិធីបុណ្យធំៗ ដែលគេតែងតែយកទំនៀមទម្លាប់បុរាណមកប្រើដោយខានពុំបាន ដូចជាការអាពាហ៍ពិពាហ៍ជាដើមនោះ គេក៏យកសម្លៀកបំពាក់បែបនេះមកប្រើដែរ។ កូនក្រមុំគេឲ្យស្លៀកសម្ពុយពាក់ស្បៃព័ន្ធទៅលើស្មាឆ្វេង សំយ៉ុងចុះមកក្រោយខ្នង ក្រវាត់ខ្សែក្រវាត់ក្បាលធំចនាដោយត្បូងពេជ្រ ពាក់កងទ្រវែលពាក់កងដៃជាដើម។ ប៉ុន្តែក្នុងជីវភាពធម្មតាអ្នកស្រុកសម័យឥឡូវនេះរក្សាទុកតែត្រឹមសំពត់សម្ពុយ បោះបង់ស្បៃចោលផ្ទាស់យកអាវពាក់វិញ។ ប្រហែលជាគេយល់ថាស្បៃគ្របដណ្តប់ភាគាយមិនជិតល្អ លែងស្មាស្តាំចោលទទេជាការពុំគប្បីដល់សេចក្តីរម្យទមរបស់ស្ត្រីនោះហើយ ទើបគេបោះបង់ស្បៃនោះចោលយកអាវមកពាក់ជំនួសវិញ ព្រោះគត់មត់ជាង។ ស្ត្រីដែលមានវ័យចាស់ទៅហើយក៏យកក្រមាបង់ដណ្តប់ពីលើដើម្បីឲ្យកាន់តែគត់មត់ថែមទៅទៀត។ ក្រមាដែលបង់កនេះ ប្រហែលជាការរំលឹកដល់ស្បៃពីបុរាណនេះទេដឹង? ក៏ប៉ុន្តែបើទុកជាយ៉ាងណាក៏ដោយ យើងសរុបសេចក្តីបានថា សម្លៀកបំពាក់របស់ស្ត្រីខ្មែរតឹយកសំពត់សម្ពុយនេះឯងជាគោល ព្រោះសំពត់សម្ពុយនេះនៅតង់រង់តាំងពីបុរាណាចារ្យមកមិនដែលប្រែប្រួលសោះ។ ពោលដូច្នេះទៅមានអ្នកខ្លះអាចសួរមកយើងថា ប្រហែលជាយើងភ្លេចសំពត់ចងក្បិនហើយទេដឹង បានជាពុំព្នៃនិយាយដល់សោះ។ យើងឆ្លើយបានភ្លាមថា យើងមិនភ្លេចទេ។ សំពត់ចងក្បិនអ្នកផងតែងទុកជាសម្លៀកបំពាក់របស់ខ្មែរយើងដែរ សូម្បីតែហ្លួងពិបុលសង្គ្រាម (ថៃ) កាលដែលលោកធ្វើនាយករដ្ឋមន្ត្រីលើកមុននៅគ្រិស្តសករាជ១៩៤០ លោកក៏បានពោលថាសំពត់ចងក្បិននេះជារបស់ខ្មែរដែរ។ ក្នុងរឿងនេះយើងសូមអភ័យទោសទុកជាមុនថា ក្នុងការរិះរកសម្លៀកបំពាក់ស្ត្រីនេះ យើងគ្មានបំណងនឹងចង់បង្កហេតុឲ្យមានផលរម៉ាស់ដល់មេត្រីភាពរវាងប្រទេសយើងនិងប្រទេសថៃនោះទេ គឺយើងស្រាវជ្រាវយកមកនិយាយគ្រាន់តែសម្រាប់សេចក្តីរិះគិត ចំពោះសម្លៀកបំពាក់ស្ត្រីតែប៉ុណ្ណោះ។ ឯយោបល់នេះទៀតក៏ជាយោបល់ផ្ទាល់ខ្លួនមិនមែនជាផ្លូវការឡើយ។

ចំពោះសំពត់ចងក្បិននេះយើងសូមប្រកាសជាដាច់ខាតថា មិនមែនជាសម្លៀកបំពាក់របស់ស្ត្រីខ្មែរទេ បើជាសម្លៀកបំពាក់របស់បុរសខ្មែរនោះពិតប្រាកដមែន។ ឯសម្លៀកបំពាក់របស់ស្ត្រីខ្មែរ គឺសំពត់សម្ពុយ និងស្បៃ ដូចជាយើងបានពោលមកពីខាងលើមកហើយ។ ទើបមានបុច្ឆាមួយឡើងថា ហេតុអ្វីបានជាស្ត្រីខ្មែរស្លៀកសំពត់ចងក្បិនដែរ?

ដើម្បីឆ្លើយនឹងសំនួរនេះ គេត្រូវសាវរទៅរកប្រវត្តិសាស្ត្រទៀត ដែលពោលថាជាតិថៃមានដើមកំណើតនៅប្រទេសចិន ហើយបានចុះពីខាងជើងមក មកសុំជ្រកនៅក្នុងប្រទេសកម្ពុជា ដែលកាលជាន់នោះមានអាណាចក្រលាតសន្ធឹង ខាងជើងទៅដល់សួគ៌ាលោក ហើយខាងត្បូងទៅពាក់លើឧបទ្វីបមល្លយូ ហើយខាងលិចទល់នឹងមេសតប្រទេសភូមា។ កាលដែលនៅក្នុងប្រទេសចិននៅឡើយ ជាតិថៃស្លៀកខោទាំងស្រីទាំងប្រុស។ លុះតមកនៅក្នុងប្រទេសកម្ពុជាត្រង់ក្រុងបឹងស្នោរ ជាតិថៃក៏លុះក្នុងអារ្យធម៌របស់ខ្មែរ គឺប្រុសៗផ្លាស់ខោចោលយកសំពត់ចងក្បិនមកស្លៀកដូចជាបុរសខ្មែរវិញ។ ហើយដោយស្ត្រីថៃធ្លាប់ស្លៀកខោដូចជាបុរសដែរ ក៏នាំគ្នាស្លៀកសំពត់ចងក្បិនដូចជាបុរស---។ ដោយសំអាងលើកស្តុតាងនេះ ទើបយើងថាស្ត្រីស្លៀកចងក្បិន គឺស្លៀកតាមសៀម។ ការស្លៀកតាមនេះមានកស្តុតាងជាក់ស្តែងណាស់។ យើងគ្រាន់តែសង្កេតមើល នៅខេត្តបាត់ដំបងនិងសៀមរាបជាដើម ដែលជាខេត្តជាប់ព្រំដែននឹងប្រទេសថៃ ហើយដែលលុះទៅក្នុងអារ្យធម៌របស់ថៃគ្រប់យ៉ាង យើងតង់នឹងឃើញបានថាស្ត្រីខ្មែរនៅខេត្តទាំងពីរនេះនិយមស្លៀកសំពត់ចងក្បិនខ្លាំងណាស់។ ទោះនៅផ្ទះក្តី ទៅបុណ្យង៉ានចេញមុខ ចេញមាត់ក្តី ស្ត្រីទាំងនេះស្លៀកតែសំពត់ចងក្បិនជាដរាប។ ការលុះទៅក្នុងអារ្យធម៌ថៃនេះខ្លាំងពេកណាស់ទៅ សូម្បីតែស្ត្រីណាហ៊ានស្លៀកសម្ពុយក៏នឹងត្រូវអ្នកជិតខាងតិះដៀល ទុកបីដូចជាស្រីផ្តាមាស។ ស្រីនៅខេត្តទាំងពីរនេះទើបនឹងហ៊ានស្លៀកសម្ពុយចេញមុខ ចេញមាត់តាំងពីឆ្នាំ១៩៤០មកនេះទេ គឺជាសម័យដែលប្រទេសថៃបានមកគ្រប់គ្រងខេត្តទាំងពីរនេះវិញ ហើយដែលជាតិថៃបានប្រែប្រួលប្រពៃណីស្លៀកពាក់បង្ខំស្ត្រីឲ្យចោលសំពត់ចងក្បិនយកសម្ពុយយកមកស្លៀកជាផ្លូវការ។ ចំណែកខាងអ្នកដែលនៅឆ្ងាយពីព្រំដែនថៃដូចជាខេត្តកំពង់ចាម ព្រៃវែងជាដើមដែលអារ្យធម៌ថៃឈោងទៅមិនដល់នោះ ស្ត្រីយកសម្ពុយជាត្រីមុខ បើនឹងស្លៀកចងក្បិនខ្លះក៏គ្រាន់ជាការផ្លាស់ទម្លាប់ម្តងៗក្នុងត្រួសារតែប៉ុណ្ណោះ។ ម្យ៉ាងទៀតយើងសង្កេតបានថា ខ្មែរយើងគ្មានឈ្មោះឲ្យសំពត់ចងក្បិនសម្រាប់ស្ត្រីទេ គឺគេហៅតាមសៀមថា ខៀនឬផាឡាយ ដែលប្រែថាសំពត់គំនូរទៅវិញ។

គេអាចសួរមកយើងទៀតថា បើសំពត់ចង្កឹនមិនមែនជាប្រពៃណីរបស់ខ្មែរ តើហេតុអ្វីបានជាគេយកសម្លៀកបំពាក់បែបនេះជាផ្លូវការ ដូចជាស្ត្រីប្រពន្ធនាម៉ឺនត្រូវតែស្លៀកសំពត់ចង្កឹនចូលព្រះបរមរាជវាំងជាដើម? យើងសូមឆ្លើយថា ការស្លៀកពាក់ក៏ដូចជាអក្សរសាស្ត្រដែរ រមែងតែងតែប្រែប្រួលទៅតាមកាល:ទេស:។ ប្រទេសនីមួយៗកាលបើនៅក្នុងសម័យដែលខ្លួនមានឥទ្ធិឫទ្ធិ អារ្យធម៌របស់ខ្លួនក៏មានឥទ្ធិឫទ្ធិឲ្យគេនិយមតាមទៅដែរ។ ប្រទេសខ្មែរក្នុងសម័យក្រោយនេះបានធ្លាក់ក្នុងការដុនដាបជាខ្លាំង ស្ទើរតែនឹងរលត់រលាយសូន្យ។ អារ្យធម៌របស់ខ្មែរក៏ទីមទាមងាករកអារ្យធម៌របស់ប្រទេសជិតខាងដែលមានឥទ្ធិឫទ្ធិជាងខ្លួននឹកស្មានជាអារ្យធម៌របស់គេទាំងនេះ បើនឹងយកមកប្រើប្រាស់---ឲ្យប្រទេសខ្មែរថ្កុំថ្កើនឡើងវិញបាន។ នេះជាធម្មជាតិរបស់អារ្យធម៌។ ប្រទេសខ្មែរយើងចាប់តាំងពីរជ្ជកាលព្រះបាទអង្គអេងតមក បានឃើញជនជាតិសៀមទាំងស្រីទាំងប្រុសមកនៅកុះករពេញទាំងប្រទេស។ បុរសសៀមខ្លះទាំងបានឡើងជានាម៉ឺនមុខមន្ត្រីក្នុងព្រះបរមរាជវាំងផង, ស្ត្រីសៀមខ្លះក៏បានមកថ្វាយខ្លួនជាព្រះស្នំ, អស់អ្នក, អស់នាង ចំពោះព្រះមហាក្សត្រិយ៍ខ្មែរ។ ស្រីស្នំក្រមការទាំងនេះ តែងតែស្លៀកសំពត់ចង្កឹន តាមប្រពៃណីរបស់គេ ម្ល៉ោះហើយស្ត្រីខ្មែរក៏នាំគ្នាស្លៀកចង្កឹនតាមទៅ។ ដំបូងគិតថាជាការចំឡែកស្លៀកកុំផាន សប្បាយរីករាយតែប៉ុណ្ណោះទេ ដល់ក្រោយមកក៏បែរទៅជាទំនៀមទម្លាប់។ ហេតុដូច្នេះហើយទើបនៅខុត្តង្គមានជ័យ ស្ត្រីនិយមស្លៀកចង្កឹនណាស់ ដល់ទៅសំពះមង្គលការទៀត ក៏មានស្លៀកចង្កឹនដែរ ដូចជាខ្ញុំអ្នកសរសេរមានសំណាងបានឃើញចំពោះភ្នែកពិតៗ។

ឈ្មោ - ខោ

តាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត "ខោ" មកពីពាក្យចិនថា "ខូវ" ដែលមានន័យថា ជាសម្លៀកធ្វើដោយសំពត់មានសណ្ឋានផ្សេងៗ មានជើង មានចង្កេះ ដូចជាខោជើងវែង ខោស្មាប់ភ្លៅ។ ដំបូងប្រហែលមានអ្នកស្រុកទន្លេខ្លះដែលមានស្លៀកខោ តែមិនច្រើនប៉ុន្មានទេ។ នេះប្រហែលជាពីមុន ទំនាក់ទំនងរកស៊ីជាមួយបរទេសច្រើនប្រព្រឹត្តទៅតាមផ្លូវទឹក។ ដូច្នេះទើបអ្នករស់នៅតាមដងទន្លេ ជាអ្នកទទួលឥទ្ធិពលនេះមុនគេ។ ម្យ៉ាងទៀតពួកចិនដែលមករស់នៅស្រុកខ្មែរ និយមរស់នៅតាមដងទន្លេ ព្រោះងាយស្រួលទាក់ទងក្នុងការរកស៊ី។ ខ្មែរហៅខោនេះថា ខោចិន។ លោកយាយសួង ម៉ាលី អាយុ៧១ឆ្នាំ នៅខេត្តកំពង់ធំ (សព្វថ្ងៃជាជនជីស្នាក់នៅវត្តនន្ទមុនី) និយាយថា "ឪពុកខ្ញុំច្រើនតែស្លៀកខោ ព្រោះគាត់ជាអ្នកស្រុកទន្លេ មិនមែនអ្នកស្រែដូចម្តាយខ្ញុំទេ អ្នកទន្លេមិនសូវចូលចិត្តស្លៀកសំពត់ចង់កងទេ"។

នៅដើមសតវត្សទី២០ ឃើញមានស្លៀកខោចិនច្រើន ទាំងមនុស្សចាស់ ទាំងកូនក្មេង។ ខោនេះទំនងជាខ្មែរមានប្រើមុនពេលដែលបារាំងចូលមក (នៅឆ្នាំ១៨៦៣)។ ខោចិននេះ ពេលដែលចូលមកស្រុកខ្មែរដំបូងមិនដឹងថាមានរូបរាងបែបណាទេ បើតាមការសាកសួរចាស់ៗ ខោចិនដែលគេប្រើនៅដើមសតវត្សទី២០នេះមានពីរប្រភេទ គឺខោចិនថ្នេរ និង

Pants

According to the 1967-68 Buddhist Institute Cambodian Dictionary, the word for pants in Khmer - *cow* - comes from a Chinese word *co* which means a kind of garment made from *sampot* which comes in various types. These garments had legs and a waistband; some had long legs while others were short and hugged the thighs.

At first, only some people living on or near rivers in the region today known as Cambodia wore garments which the Khmer called Chinese pants. Exchange with foreigners occurred along the waterways, and it was the people living on or near the rivers who were the first to be influenced by foreign customs. Chinese who came to live in Cambodia liked to live along the rivers since it was easy to do business exchanges there. Suong Mali, 71 years old today living in Wat Non Moni (Phnom Penh), told us, "My father mostly wore pants because he was from the river region, not from the rice field region like my mother. The river people didn't like to wear *sampot* tied in the *kben* style that much."

By the beginning of the 20th century, many people, both young and old, were wearing Chinese pants. We can assume that Chinese pants were worn before the French established the Protectorate in 1863. We are not exactly sure what these early Chinese pants looked like. Our elderly interviewees

ខោចិនថ្នេរ៣។ ពេលបារាំងចូលមក ខ្មែរយើញខោ
ដែលបារាំងស្លៀក ខុសប្លែកពីខោចិន និងដើម្បីកុំឲ្យ
ច្រឡំនឹងខោចិន ខ្មែរហៅខោនោះថា ខោបារាំង។ មុន
ដំបូងមានតែត្រកូលក្សត្រមួយចំនួនដែលជិតដិតជាមួយ
បារាំងនិយមស្លៀកខោរបៀបបារាំង ព្រោះពេលនោះ
បារាំងមានឋាន:ខ្ពស់ជាងគេក្នុងសង្គម។ ដូច្នេះគេខិតខំ
ធ្វើខ្លួនឲ្យដូចជាបារាំង។ ក្រោយមកនៅចុងសតវត្សទី
១៩ ទើបមានមន្ត្រីរាជការថ្នាក់ខ្ពស់ខ្លះធ្វើការឲ្យបារាំង
ចេះស្លៀកខោរបៀបបារាំង។ លោកតាជា សំរិទ្ធ
អាយុ៧៥ឆ្នាំ នៅច្បារអំពៅ ក្រុងភ្នំពេញ និយាយថា
"កាលខ្ញុំនៅក្មេង (ទសវត្ស១៩៤០) ស្លៀកតែខោចិន
អាវចិន។ នៅស្រុកខ្ញុំមានតែម្នាក់ទេដែលស្លៀកខោ
បារាំងជើងខ្លី ដោយសារឪពុករបស់គេធ្វើការជាមួយ
បារាំង។ បើគ្រូពេលទៅបង្រៀនស្លៀកខោបារាំងជើង
ខ្លី យូរៗស្លៀកខោជើងវែងម្តង តែមិនសូវមានទេ"។

ក្នុងទសវត្ស១៩៦០ ស្ត្រីភាគច្រើននៅតែ
និយមស្លៀកសំពត់ច្រើនជាងខោ ខុសពីសព្វថ្ងៃដែល
មនុស្សស្រីភាគច្រើនចូលចិត្តស្លៀកខោជាងស្លៀក
សំពត់។ ឥឡូវខោបារាំងនេះខ្មែរហៅត្រឹមតែខោ
ចំណែកឯខោចិនវិញនៅតែហៅខោចិនដដែល។

told us that at the beginning of the 20th century, there were two types of Chinese pants: three seam Chinese pants and five seam Chinese pants. When the French came to Cambodia, they brought another type of pants which was different from the Chinese pants. In order not to confuse these pants with Chinese pants, the Khmer called them French pants. At first, it was only members of the royal family close to the French who began to wear such pants. Since the French held power, Khmer started to imitate their outer appearance. By the end of the 19th century, ministers and officials working with the French wore French pants, while local officials still usually wore *sampot* tied in the *kben* style.

Jea Somrith, 75 years old living near Phnom Penh, told us, "When I was little [in the 1940s], they only wore Chinese pants and shirts. Only one boy wore short French pants because his father worked with the French. When the teachers went to teach, they wore short French pants. Once in a while, they wore long French pants, but that was not so common." In the 1960s, women still liked to wear *sampot* more than pants. This was different from today when more women like to wear pants than *sampot*. Today Cambodians call the French or Western type pants simply pants, or *cow*, while Chinese pants are still called Chinese pants today.

ខោចិនថ្នេរ៥

ខោចិនថ្នេរ៥ មានពីរប្រភេទគឺ ខោជើងវែង និងខោជើងខ្លី។ ខោចិនថ្នេរ៥ដែលមានជើងវែង គេអាចហៅឈ្មោះបានច្រើន ដូចជាខោថ្នេរ៥, ខោចែវ, ខោថ្នេរ៤, ខោស្លឹកឫស្សី, ខោអាចារ្យជាដើម។ ការហៅនេះ គឺប្លែកៗគ្នាទៅតាមតំបន់ តែជាទូទៅគេនិយមហៅខោថ្នេរ៥ជាងគេ ដោយគេរាប់ថ្នេរដែលមាននៅលើខោ គឺថ្នេរចំហៀងមុខ២, ថ្នេរចំហៀងក្រោយ២ និងថ្នេរគូទមួយ ទាំងអស់គឺ៥។ តំបន់ខ្លះហៅខោថ្នេរ៤ ព្រោះគេមិនរាប់ថ្នេរគូទ។ ម្យ៉ាងទៀត សព្វថ្ងៃអាចារ្យចូលចិត្តស្លៀកខោបែបនេះ ទើបមាន

Five seam Chinese pants

Five seam Chinese pants were made in full length or as shorts. Our elderly interviewees called the full length five seam Chinese pants by many names such as oar pants, four seam pants, bamboo leaf pants, or *achar* pants, depending on the region from which the speaker came. The most common name for this kind of pants, however, was the five seam pants, a name derived from counting the number of seams on the pants (two front seams, two back seams, and one buttock seam). In some areas, the pants were called four seam pants because the buttock seam was



រូបលេខ ៩៧៖ ខោចិនថ្នេរ៥។

Figure 97: Five seam Chinese pants (Photo: Reyum)

អ្នកខ្លះគេនិយមហៅខោនេះថាខោអាចារ្យ។ ចំណែកខោចិនថ្នេរជើងខ្លី អ្នកនៅស្រុកខ្លះ គេនិយមហៅខោខុងម៉ូវ ឬកុងម៉ូវ។

យើងអាចសម្គាល់ខោចិនបាន ដោយសារខោនេះមានស្លឹកឫស្សី ជើងបាក់ និងតចង្កេះ។ ផ្នែកខាងមុខមានតជើងបាក់នៅជើងខាងឆ្វេងមួយ ផ្នែកខាងក្រោយតជើងបាក់នៅជើងខាងស្តាំមួយ និងមានថ្នេរចំហៀងខាងមុខពីរ ខាងក្រោយពីរ (រូបលេខ ៩៧)។ ខោនេះ គេមិនប្រកាន់ខាងណាមុខ ខាងណាក្រោយទេ គឺអាចស្លៀកបានទាំងសងខាង។ បើកាត់ពីក្រណាត់ផាឌិប ជ្រលក់ខ្មៅ ឬក្រណាត់អ៊ី សម្រាប់ស្លៀកពេលធ្វើការ។ បើសិនគេដេរថ្នេរមូល គឺអាចស្លៀកបានទាំងខាងខុសនិងខាងត្រូវ។ ខោថ្នេរ៥

not counted. Because *achar* [lay elders in the temples] liked to wear this kind of pants, some people called them *achar* pants. Short legged five seam pants were sometimes called *kong mao* pants.

The five seam Chinese pants had an added waist panel, a small triangular insert of cloth called the bamboo leaf, and a sewn panel on each leg called the *bak*. The bamboo leaf insert and the *bak* were particular characteristics of the Chinese pants. The *bak* were placed on opposite sides of the leg; if the *bak* was on the front of the left leg, then it was on the back of the right leg (figure 97). Chinese pants had no front or back, and could be worn either way. If Chinese pants were sewn together with round seams, then the pants could be worn inside out as well. Five seam pants made of shiny materials such as colored *prai*, patterned *prai*, *prai muy a*, and *prai kam dru* were worn to ceremonies. Poor people generally made five seam pants out of *des aik* dyed black. Five seam pants were also made from *pa dip* and *ou* cloth, dyed black for use as work clothing.



រូបលេខ ៩៨៖ លោកតាទន់ ឡឺក អាយុ៧៦ឆ្នាំ ស្លៀកខោចិនថ្នេរ៥។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 98: Dun Leuk, 76 years old, wearing five seam Chinese pants. Photographed 2002. (Photo: Reyum)

កាត់ពីក្រណាត់រលោងភ្លឺ ដូចជាព្រៃពណ៌, ព្រៃផ្កា, ព្រៃមុយអា, កាំទ្រីជាដើម គេនិយមស្បៀកចូលក្នុងពិធី។ ចំណែកអ្នកក្រ គេច្រើនយកក្រណាត់ទេសឯក មកកាត់ខោថ្នេរ៥ រួចយកទៅជ្រលក់ពណ៌ខ្មៅ។

របៀបកាត់ខោចិនថ្នេរ៥

គឺគេយកក្រណាត់បណ្តោយ២ម៉ែត្រ និងទទឹង ១ម៉ែត្រមកបត់ជាពីរតាមទទឹងសាច់ក្រណាត់ (រូបលេខ៩៩) រួចគេកាត់ផ្តាច់។ ហើយបត់ក្រណាត់នោះជាពីរទៀតតាមបណ្តោយសាច់ក្រណាត់ និងកាត់តាមបណ្តោយសាច់ក្រណាត់នោះជាពីរ (រូបលេខ១០០)។ មួយផ្នែក (ដែលមានក្រណាត់ពីផ្ចាំងស្មើគ្នា) ជាតួខោ គេមិនធ្វើអ្វីទៀតទេ គេទុកវាសម្រាប់ភ្ជាប់ជា

Making and sewing five seam Chinese pants

A cloth two meters long and one meter wide is necessary in order to make one pair of five seam Chinese pants. The cloth is folded in half along its width and cut into two separate pieces along this fold (figure 99). The resulting one meter square pieces of cloth are again folded and cut into two, resulting in four equal size pieces of cloth (figure 100). Two of these pieces are reserved for the legs of the pants, while the other two are cut to form the seat of the pants, the *bak* of the legs, and the bamboo leaf.

To cut the seat of the pants, they fold one set of cloth diagonally to form a triangle (figure 101). Measuring down two *chom am*



រូបលេខ ៩៩៖ ក្រណាត់បត់ជាពីររួចកាត់ផ្តាច់។

Figure 99: The cloth is folded in half and cut along the fold.



រូបលេខ ១០០៖ កាត់ក្រណាត់ជាពីរទៀតតាមស្នាមគំនូស។

Figure 100: The cloth is folded lengthwise and then cut again along the fold.

មួយគូទខោ។ ចំណែកមួយផ្នែកទៀត គេយកមកកាត់ជាគូទខោ ជើងថ្នាក់ និងស្លឹកឫស្សី។ របៀបកាត់គូទខោ គឺគេយកក្រណាត់នោះមកបត់ជាវាងត្រីកោណ (រូបលេខ១០១) រួចគេវាស់ពីខាងលើមកប្រវែងពីរចំអាម (ប្រហែល៤០សង់ទីម៉ែត្រ) ហើយចាប់គូសខ្វៀលគូទ ហើយគូសត្រង់ចុះមកក្រោម (រូបលេខ ១០២)។ នៅសម័យមុនមិនទាន់មានដីសគូស គេ

from one side of this fold (figure 102), they draw a curved chalk line that will form the buttocks and inner legs of the pants. Before store bought chalk was available, the end of the scissors was used to press a line into the cloth and the cloth was then cut following the indented line. The small bamboo leaf triangle is also cut from this cloth, which thus is divided into three sections (figure 103): (a) the



រូបលេខ ១០១ Figure 101



រូបលេខ ១០២ Figure 102



រូបលេខ ១០៣ Figure 103



រូបលេខ ១០៤៖ ក- តួខោ, ខ- ជើងជាក់, គ- ស្លឹកឫស្សី, ឃ- ក្រណាត់សម្រាប់តចំហៀង, ង- ក្រណាត់តចង្កេះ។

Figure 104: a - pant leg; b - *bak*; c - bamboo leaf; d - material added to the outer sides of the legs; e - cloth for the waistband

គ្រាន់តែយកចុងក្រណាត់ទ្រែមកតូសចេញជាស្នាម ហើយគេកាត់តាមស្នាមនោះ។ ការកាត់តួទខោនេះ បើជាក្រណាត់ផាឌិប ឬទេសឯកមិនមានបញ្ហាទេ ព្រោះក្រណាត់ខាងខុសនិងខាងត្រូវស្ទើរតែដូចគ្នា។ តែបើជាក្រណាត់ព្រៃ គេត្រូវមានការប្រុងប្រយ័ត្នបន្តិច។ ពេលកាត់ គេត្រូវពិនិត្យមើលក្រណាត់ទាំងពីរផ្ទាំង មិនត្រូវដាក់ខាងខុសនិងខាងខុស ឬខាងត្រូវនិងខាងត្រូវបែរមុខចូលគ្នាទេ។ ព្រោះក្រណាត់ព្រៃផ្នែកខាងខុសមិនរលោង ឯផ្នែកខាងត្រូវរលោង ពេលដេរជាខោរួចនឹងឃើញតួទខោម្ខាងដេរក្រណាត់ខាងត្រូវ ម្ខាងទៀត

inner leg and seat of the pants, (b) the *bak* of the legs, and (c) the bamboo leaf. The *bak* are traditionally shorter than the legs of the pants, so a piece of cloth is generally added to the bottom of the *bak*. Since the cloth is still folded, two of each of these pieces are created by cutting the cloth.

If Chinese pants are made of *pa dip* or *des aik*, there is no problem with their reversibility since these fabrics are identical on both sides. If the Chinese pants are made from *prai*, the sewer has to be careful to make

ខាងខុស។ ដូច្នេះត្រូវដាក់ក្រណាត់ផ្គុយខាងគ្នា។ ក្រោយពេលកាត់រួច គេបានជា៣ផ្នែក (រូបលេខ ១០៣) មួយផ្នែកជាតួទខោ (ក)។ មួយផ្នែក (ខ) យកមកកាត់ជាជើងបាក់ឲ្យមានទំហំប៉ុន (ក១) ជើងបាក់ជាទូទៅខ្លីជាងតួខោ ដូច្នេះគេតែងមានតក្រណាត់បន្ថែមទៅត្រង់ផ្នែកខាងក្រោមនៃជើងបាក់ជានិច្ច ទាំងជើងបាក់ខាងមុខ និងខាងក្រោយ។ មួយផ្នែកទៀតមានរាងត្រីកោណ (គ) យកមកកាត់ស្លឹកឫស្សី សម្រាប់ដេរភ្ជាប់នឹងកន្លែងតស្លឹកឫស្សី (រូបលេខ១០៤)។

របៀបដេរ

មុនដំបូងគេដេរភ្ជាប់តួទខោ និងជើងបាក់។ បន្ទាប់មកដេរភ្ជាប់ស្លឹកឫស្សី ទើបដេរភ្ជាប់នឹងតួខោចុងក្រោយដេរភ្ជាប់ក្រណាត់តចង្កេះ។ ក្រណាត់តចង្កេះជាទូទៅគេយកក្រណាត់ទេសឯកខ្មៅ ឬជាខ្មៅ (ទទឹង២០សង់ទីម៉ែត្រ និងបណ្តោយពី១,២ម៉ែត្រទៅ១,៥ ម៉ែត្រ អាស្រ័យទៅតាមទំហំចង្កេះខោ) ព្រោះបើគេយកក្រណាត់ព្រៃ ឬព្រៃមុយអាមកកាត់ខោហើយតចង្កេះក្រណាត់ដូចគ្នា នាំឲ្យរអិលពិបាកស្ងៀក។ ដូច្នេះគេប្រើក្រណាត់ទេសឯកទើបស្ងៀកទៅជាប់ មិនរអិល។ ចំពោះថ្នេរដេរ គេប្រើថ្នេរមូលទាំងអស់លើកលែងតែជាយជើងខោដែលដេរថ្នេរថយហ្គ័ន។

sure the side of the cloth used is the same for all pants pieces that will be sewn together. *Prai* is shiny on one side and matte on the other, so the method of cutting has to be adjusted to make sure one side of the pants is all shiny and the other side is all matte.

Sewing the pants

When all pieces of the Chinese pants have been cut (figure 104), the inner legs and seat of the pants are sewn to the *bak*. The bamboo leaf is attached to the top of the seat of the pants, and then the seams on the outer sides of the legs are sewn. The last piece to be added to the pants is the waist panel which is usually made out of black *des aik* or *pa dip* cloth (about 20 centimeters wide and 120 to 150 centimeters long, depending on the size of the wearer). If colored *prai* or *prai muy a* is used for both the legs and the waist of the pants, the pants are difficult to wear since these fabrics are slippery and do not stay tucked at the waist. Therefore they use *des aik* cloth for the waist since it is not slippery and can be folded and tucked in, holding up the pants. All the final seams of the Chinese pants are round seams except for the hems of the pants which are finished with backwards stitching.

ខោចិនថ្នេរ៣

ខោនេះមិនខុសពីខោចិនថ្នេរ៥ប៉ុន្មានទេ គឺមានជើងបាក់ មានស្លឹកឫស្សីដូចគ្នា គ្រាន់តែគេមិនកាត់ផ្តាច់តួខោ គឺថ្នេរចំហៀងយើញមានតខាងមុខមួយ និងខាងក្រោយមួយ ខុសប្លែកពីខោចិនថ្នេរ៥ តថ្នេរចំហៀងខាងមុខពីរ និងខាងក្រោយពីរ (រូបលេខ ១០៥)។ ចំពោះខោចិនថ្នេរ៣ គឺថ្នេរចំហៀងមុខមួយ ថ្នេរចំហៀងក្រោយមួយ ថ្នេរគូទមួយ ទាំងអស់គឺ៣ ហើយគ្មានឈ្មោះហៅច្រើនដូចខោថ្នេរ៥ទេ។ គេអាចកាត់ជាខោជើងវែងក៏បាន ខោជើងខ្លីក៏បានតាមការនិយម។ ប៉ុន្តែខោចិនថ្នេរ៣ជើងខ្លី ក៏ដូចខោចិនថ្នេរ៥ជើងខ្លី មានតែមនុស្សប្រុសទេ ដែលស្លៀក ចំណែកមនុស្សស្រីមិនដែលយើញស្លៀកទេ។ ខោចិនថ្នេរ៣ច្រើនកាត់ស្លៀកនៅផ្ទះ និងស្លៀកពេលធ្វើការ។ ក្រណាត់ដែលគេយកមកកាត់ខោចិនថ្នេរ៣ គឺច្រើនតែក្រណាត់ផាឌិបខ្មៅ ទេសឯកខ្មៅ ឬក្រណាត់ត្បាញខ្លួន

The three seam Chinese pants

Three seam Chinese pants are not very different from five seam Chinese pants. Three seam Chinese pants have the *bak* and the bamboo leaf, just like the five seam Chinese pants. The only real difference is that each leg of the pants does not have two seams. Instead, larger pieces of fabric are used for the legs so that the resulting pants only have three main seams: a buttock (or seat of the pants) seam, and one seam on each leg attaching the *bak* to the leg. Three seam Chinese pants are not generally called by other names. Three seam Chinese pants can have long or short legs but only men wear the short leg versions of either the three or five seam Chinese pants. Three seam Chinese pants were worn in the house and to work in the fields. Three seam Chinese pants were generally made from black *pa dip* or *des aik* cloth, or from cloth woven at home for making work clothes. If the clothing was intended for wearing in the house rather than the fields, slightly better quality cloth was generally used; *prai* was used sometimes for such three seam Chinese pants worn in the house.



រូបលេខ ១០៥៖ ខោចិនថ្នេរ៣។

Figure 105: Three seam Chinese pants.

ឯង សម្រាប់ស្លៀកពេលធ្វើការ។ ចំណែកស្លៀកនៅផ្ទះគេច្រើនយកក្រណាត់ល្អបន្តិច ជួនកាលគេក៏យកក្រណាត់ព្រៃមកកាត់សម្រាប់ស្លៀកនៅផ្ទះដែរ។

របៀបកាត់ខោចិនថ្នេរ៣

របៀបកាត់ខោនេះខុសពីរបៀបកាត់ខោចិនថ្នេរ៥បន្តិច។ មុនដំបូងយកក្រណាត់ប្រវែងបណ្តោយ២



រូបលេខ ១០៦ Figure 106

Cutting the pants

The fabric for sewing three seam Chinese pants is cut slightly differently from fabric for five seam Chinese pants. A length of cloth, two meters long, is folded along its width and cut in two. One side of this cloth is folded again so that about 20 centimeters of doubled cloth overlap (figure 106). This cloth will form the entire outer part of each leg without requiring any seams. Thus, the three seam Chinese pant is different from the five seam Chinese pant which has seams running down the middle of each leg in the front and the back. The cloth is then folded on the other side into the overlapping triangle but without this triangle extending over the edge of the cloth as with the five seam pant (figure 107). As with the five seam pant, the end of



រូបលេខ ១០៧ (រូបថត៖ រៃយ៉ំ) Figure 107 (Photo: Reyum)

ម៉ែត្រមកបត់ជាពីរតាមទទឹងសាច់ក្រណាត់ រួចគេកាត់ផ្តាច់។ បន្ទាប់មកគេបត់ម្ខាងទៀតម៉ែត្រតាមបណ្តោយសាច់ក្រណាត់ ហើយមិនកាត់ផ្តាច់ទេ ព្រោះផ្នែកចំហៀងគេមិនកាត់ផ្តាច់ រួចទើបយកមកដេរភ្ជាប់ដូចខោចិនថ្នេរ៥ទេ។ ខោចិនថ្នេរ៣ខុសពីខោចិនថ្នេរ៥ត្រង់នេះឯង គឺខាងមុខយើញថ្នេរចំហៀងមួយ និងខាងក្រោយយើញថ្នេរចំហៀងមួយ។ បន្ទាប់មកគេបត់ចុងម្ខាងទៀតនៃក្រណាត់ជារាងត្រីកោណ (រូបលេខ១០៦) ដូចខោចិនថ្នេរ៥ដែរ គេយកកន្ត្រៃមកតូសចេញជារាងតួខោ និងតូទខោ (រូបលេខ១០៧) ទើបគេកាត់ផ្តាច់មួយផ្នែកជាតួខោ មួយផ្នែកសម្រាប់កាត់ជើងបាក់ និងមួយផ្នែកទៀតសម្រាប់កាត់ជាស្លឹកឫស្សី (រូបលេខ ១០៨)។ ខោចិនថ្នេរ៣មានរបៀបដេរដូចខោចិនថ្នេរ៥ដែរ សូមមើលរបៀបដេរខោចិនថ្នេរ៥នៅទំព័រ៨១។

the scissors or a white piece of chalk is used to trace the curving line that will separate the *bak* from the legs of the pants (figure 107). The fabric is cut along this line and the pointing triangular piece for the bamboo leaf is cut off as well, and trimmed to be the size of "a" in figure 107. Three resulting pieces make up the pants below the waist: the wide curving leg and buttock pieces, the two *bak* trimmed to fit the lower legs on opposite sides and legs of the garment, and the bamboo leaf that are inserted in the front and back of the garment (figure 108). An additional cotton cloth panel is added for the waistband.

Our elderly interviewees told us that Chinese pants were popular with young and old, male and females. Women who wore



រូបលេខ ១០៨៖ ក– តួខោ, ខ– ជើងបាក់, គ– ស្លឹកឫស្សី, ឃ– ក្រណាត់សម្រាប់តចង្កេះ។

Figure 108: a - leg of the pant and buttocks, still folded up; b - *bak*; c - bamboo leaf; d - cloth for the waist panel

ចាស់ៗនិយាយថា ខោចិនគេចូលចិត្តស្លៀកទាំងចាស់ ទាំងក្មេង ស្រីប្រុស។ ប៉ុន្តែស្ត្រីដែលស្លៀកខោនេះ ភាគច្រើនជាកូនកាត់ចិន។ ចំណែកស្ត្រីខ្មែរមិនសូវចូលចិត្តស្លៀកខោនេះទេ។ របៀបស្លៀកខោចិនដូចរបៀបស្លៀកសំពត់សម្ពុយដែរ។ សព្វថ្ងៃ គេហៅខោចិន គឺសំដៅទៅលើខោចិនថ្នេរ៥ មានន័យថា គេស្លៀកខោចិនថ្នេរ៥ច្រើនជាងខោចិនថ្នេរ៣។ លោកយាយពិន អាយុ៧៦ឆ្នាំ ខេត្តកណ្តាល និយាយថា "ជាទូទៅគេចូលចិត្តស្លៀកខោចិនថ្នេរ៥ ជាងខោចិនថ្នេរ៣ ព្រោះខោចិនថ្នេរ៥ ពេលស្លៀកទូលាយត្រង់គូទស្រួលស្លៀក។ ចំណែកខោចិនថ្នេរ៣ ស្លៀកច្រើនតឹងត្រង់គូទខោ ហើយធាប់សឹករហែកត្រង់គូទខោ"។ លោកយាយធាយ លីមយីម អាយុ៨២ឆ្នាំ ខេត្តកណ្តាល (ជាកូនកាត់ចិន) និយាយប្រាប់ថា "ខ្ញុំចូលចិត្តស្លៀកខោថ្នេរ៥ជាងខោថ្នេរ៣ ព្រោះខោថ្នេរ៥ស្រួលស្លៀកជាង។ កាលយាយនៅក្មេង ពេលនៅផ្ទះស្លៀកខោថ្នេរ៥ តែកាត់ក្រណាត់ផាឌិប រួចយកទៅជ្រលក់មក្ការីឲ្យខ្មៅ ហើយពេលទៅវត្ត ឬទៅបុណ្យទានផ្សេងៗ យាយស្លៀកខោថ្នេរ៥ដែរ តែកាត់ក្រណាត់ព្រៃ"។ រហូតមកដល់សព្វថ្ងៃអ្នកស្លៀកខោចិនភាគច្រើនជាមនុស្សចាស់ ចំពោះក្មេងៗមិនសូវឃើញមានស្លៀកទេ។

such pants were usually of part Chinese descent, and Khmer women did not generally wear Chinese pants. The pants were worn tucked in at the waist in much the same manner as the *sampot* worn in the *samloy* style. Today, the term Chinese pants generally refers to the five seam version which is worn more often than the three seam version.

Pin, 76 years old living in Kandal Province, told us, "In general, they liked to wear the five seam pants more than the three seam pants because the five seam pants were wider at the seat of the pants and thus easier and more comfortable to wear. The three seam pants were tight at the buttocks and tore easily there." Chay Lim Khim, 82 years old living in Kandal Province, told us, "I liked to wear the five seam pants more than the three seam pants, because the five seam pants were easier to wear. When I was young, I wore five seam pants at home. They were made of *pa dip* fabric that we took to dye black using *mcleur*. When I went to the temple or to various ceremonies, I wore five seam pants too but they were made of *prai*." Even today, elderly people still wear three and five seam Chinese pants; younger people however do not wear these kinds of pants very much anymore.

ញ- អាវខ្នែងទាប់

ប្រហែលជានៅដើមសតវត្សទី២០ គេចាប់មានអាវក្នុង (អាវទ្រនាប់) សម្រាប់ប្រើហើយ។ តាមការសាកសួរចាស់ៗដែលមានអាយុ៨០ឆ្នាំឡើង អាចឲ្យយើងដឹងថា អាវទ្រនាប់ដែលម្តាយរបស់ពួកគាត់ធ្លាប់ប្រើមានតែមួយបែប ដូចអាវដែលគាត់ពាក់សព្វថ្ងៃដែរគឺវាលក្អៀក កកំពត ឡើងមុខ ខ្ចីត្រឹមចង្កេះ មានដាក់ហោចប៉ៅពីរ។ ជាទូទៅគេហៅអាវបែបនេះថា "អាវគាក់" ប្រើបានទាំងក្មេងទាំងចាស់ (រូបលេខ ១០៩)។ ចំពោះស្ត្រីក្រមុំ និយមពាក់អាវទ្រនាប់រឹបទ្រូងខ្លាំងដើម្បីកុំឲ្យឃើញដើមទ្រូងធំ។ ប្រសិនបើមានទ្រូងធំពេលចេញទៅណា គេបង់កក្រមាពីលើមួយជាន់ទៀតដោយទម្លាក់ជាយមកមុខ ដើម្បីជាការសមរម្យ។ នេះជាមូលហេតុមួយដែលពីមុនគេចូលចិត្តយកក្រមាតាមខ្លួន។ លោកយាយជូ សារឿន អាយុ

Underwear

Undershirts

We know that at the beginning of the 20th century, undershirts were already being worn. According to elderly interviewees over the age of eighty, there was only one type of undershirt worn by their mothers. This undershirt was like the *kak* shirt, still worn today, which is sleeveless with a low v-neck and buttons down the front. The undershirt ended at the waist and had two pockets (figure 109). Women of all ages wore them. Unmarried adolescent girls generally wore *kak* shirts sewn to pull tightly across the chest so that their breasts would not appear too large. If an unmarried girl had large breasts, she would generally add a *krama* wrapped around her neck with the ends falling over her chest in



រូបលេខ ១០៩៖ អាវគាក់ រូបខាងឆ្វេង ជាផ្នែកខាងមុខ និងរូបខាងស្តាំ ជាផ្នែកខាងក្រោយ។

Figure 109: The *kak* undershirt, on the left seen from the front, on the right from the back.

៧៧ឆ្នាំ នៅខេត្តព្រៃវែង និយាយថា "អាវក្នងកាត់ខ្លួនឯង មានដៃតូច ហើយខ្លះគេដាក់ឡេវខាងមុខ គ្មានអាវទ្រនាប់ទេ (អាវទ្រនាប់ត្រង់នេះគឺសំដៅលើអាវទ្រនាប់ដែលលក់ស្រាប់នៅផ្សារ)។ ពីដើមគេកាត់អត់ឲ្យមានទ្រូងទេ គឺវបឲ្យតឹងឡើងរាប គេនិយមអញ្ចឹង។ ស្រីណាដោះធំ គេសង្ស័យហើយ។ ពេលដើរទៅណា គេថាយី! កូននេះទ្រូងធំដូចជាយ៉ាងម៉េចទេ! នៅក្មេងច្រើនតែម៉ែឪបញ្ជោះថា កូនឯងពាក់អាវតឹងវិប កុំឲ្យគេសើច។ វិបទាល់តែមែនទែន គ្មានឃើញអីទេ"។

អាវកាក់ច្រើនកាត់ពីក្រណាត់ទេសឯកស។ ចំពោះអ្នកមានកូនតូចនៅជៅ ចូលចិត្តកាត់ក្រណាត់ផ្កា ឬពណ៌ ព្រោះមិនសូវឃើញស្នាមប្រឡាក់។ អាវកាក់ គេច្រើនកាត់កកំពត (កវាលជ្រៅ) ព្រោះពេលពាក់អាវកមូល ឬកជ្រុងពីក្រៅកុំឲ្យឃើញអាវក្នង។ ជាទូទៅអាវនេះ មានសម្រុងខ្លីត្រឹមចង្កេះ គឺពេលពាក់

order to appear modest. This is one reason for the habit of always carrying a *krama.* Ju Saroeun, 76 years old, living in Prey Veng Province, told us, "We made our own undershirts with small sleeves [the straps of the sleeveless shirt are still called sleeves]. Some put buttons down the front. There were no *aow dranaup* [readymade bra] then. In earlier times, they cut the undershirts so that they were tight across the chest and made the breasts flat. They liked it like that. Women whose breasts appeared large were viewed with suspicion. When they walked, people exclaimed, 'Yi! That girl has a big chest! What's with her?' When one was little, parents taught girls to wear tight shirts so that other people wouldn't laugh. They were really tight, those shirts! You couldn't see anything."



រូបលេខ ១១០៖ អាវកាក់ មានថ្នេរចំហៀងម្ខាងមួយ។

Figure 110: The *kak* undershirt with back seams.

អាវនេះទៅយើញឆ្អឹកក្បាល។ ភាគច្រើនដាក់ឡើងតិបច្រាំ គ្មានជីបវាង់ទាំងមុខទាំងក្រោយ ហើយមានដាក់ហោចប៉ៅពីរទុកដាក់លុយ ឬរបស់មានតម្លៃ ព្រោះពីមុន គេគ្មានកាបូបដាក់ទេ។ សម័យក្រោយមកពេលមានឥទ្ធិពលបារាំង គេកែច្នៃអាវនេះឲ្យមានជីបវាង់និងជីបត្រង់ដោះដើម្បីឲ្យសមជាង់មុន និង់មានអ្នកខ្លះចោះរន្ធដាក់ឡើងចាន (រូបលេខ១១០)។

អាវទ្រនាប់សម្រាប់ពាក់នៅខាង់ក្នុង់។ តែក្នុង់តំនិតខ្មែរ អាវនេះមិនមែនជាការលាក់បាំង់ ឬសម្រាប់តែពាក់ពីក្នុង់នោះទេ។ គេអាចពាក់អាវនេះនៅផ្ទះ ឬ

រូបលេខ ១១១៖ លោកយាយសែម ឡាប អាយុ ៧៧ឆ្នាំ នៅស្រុកពួក ខេត្តសៀមរាប, ពាក់អាវតាក់នៅផ្ទះរាល់ថ្ងៃ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 111: Saim Laap, 77 years old, still wears a *kak* undershirt in her home everyday. Photographed in Siem Reap Province, 2003. (Photo: Reyum).

The *kak* undershirt was generally made from white *des aik* cloth. However, women with small children who were breast-feeding liked to make *kak* undershirts out of patterned or colored material so that it was not so easy to see stains on them. The neck of the *kak* undershirt was generally cut low in the shape of a "v" or a "u" so that it could not be seen when wearing a round or square necked shirt over it. The *kak* undershirt was generally cut short, ending at the waist, so that when wearing a *kben*, the undershirt ended above the characteristic knotted waist,

រូបលេខ ១១២៖ លោកយាយហង់ ឈួន អាយុ៨៣ឆ្នាំ នៅខេត្តកណ្តាល, ពាក់អាវតាក់។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 112: Hong Chuon, 83 years old, wearing her *kak* undershirt. Photographed in Kandal Province, 2003. (Photo: Reyum)

រូបលេខ ១១៣៖ អាវត្រដោកដៃក។ (រូបថត៖ រៃយ៉)

Figure 113: The *tradauk daik* undershirt. (Photo: Reyum)

ដើរទៅផ្ទះអ្នកជិតខាង ហើយមិនចាច់ពាក់អាវពីក្រៅមួយជាន់ទៀតក៏បាន។ ទាល់តែមានភ្ញៀវ ឬចេញដើរទៅណាធ្ងាយ ទើបពាក់អាវក្រៅមួយជាន់ទៀត ដើម្បីជាការសមរម្យ។ ទង្វើបែបនេះ មានតែមនុស្សចាស់ ឬមនុស្សស្រីដែលរៀបការហើយប៉ុណ្ណោះ។

អាវត្រដោកដៃក (រូបលេខ១១៣) មានកាង់ដូចអាវកាក់ដែរ តែមានតចង្កេះ។ ផ្នែកខាងមុខមានជ័រចង្កេះម្ខាង២ និងមានដេរថ្នេរកាង២ ឬ៤ទៀត។ ចំណែកខាងខ្នងមានថ្នេរពុះខ្នង១ និងមានដេរថ្នេរកាង២ ឬ៤ដូចខាងមុខដែរ។ អាវបែបនេះច្រើនតែអ្នកស្រុកបាត់ដំបងនិយមពាក់។

អាវពង ឬអាវត្រចៀកចប ឬអាវសង្រែកបំពង (រូបលេខ១១៤) ច្រើនតែក្មេងជំទង់ពាក់ (ប្រហែលពីអាយុ១៤–១៧ឆ្នាំ)។ ដល់ធំជាងនេះបន្តិច

or *chnok*, of the *kben*. Traditionally, the *kak* undershirt had five metal snap buttons closing it, with no darts or pleats in the front or the back. The undershirt had two front pockets for putting money or things of value; in earlier times, wallets or bags for keeping money were not in use. It was only later, in the period of French influence, that form-fitting darts were added to the breast and torso area of the undershirt. Some undershirts began to have buttonholes and *chan* buttons down the front as well.

In modern society, undershirts are generally thought to be garments worn on the inside, covered by other garments. Traditionally, in Khmer culture however, the undershirt was not necessarily hidden by

រូបលេខ ១១៤៖ អាវពង់ ឬអាវត្រចៀកចប ឬអាវសង្រែកបំពង់។ (រូបថត៖ ឈៃ)

Figure 114: The *pong* undershirt. (Photo: Reyum)

គេពាក់អាវកាក់។ ចំណែកចាស់ៗ ពាក់អាវស្រដៀងនេះដែរ តែវែងដល់ជង្គង់សម្រាប់ពាក់ដេកយប់។

អាវដៃមួយចំហៀង (រូបលេខ១១៥–១១៦) កាលជំនាន់មុន ច្រើនតែដូនជីនៅខេត្តបាត់ដំបងពាក់។ ប៉ុន្តែមកដល់សព្វថ្ងៃ លែងឃើញពាក់ហើយ។ លោកយាយមុម សំអឿន អាយុ៧៦ឆ្នាំ និយាយថា "អ្នកស្រុកធម្មតាដែលមានវ័យចំណាស់នៅខេត្តបាត់ដំបងក៏មានពាក់ដែរ ស្រដៀកជាមួយក្បិនហើយខ្លះមានពាក់ខ្សែក្រងធ្វើពីមាស ឬទង់ហ្វាំ។ គេពាក់នៅផ្ទះ និងទៅផ្សារ។ ក្នុងរាជហ្លួងមុនីវង្ស អ្នកវាំងក៏មានពាក់អាវបែបនេះដែរ តែផុតរាជនេះលែងឃើញមានពាក់ហើយ (ប្រហែលទសវត្ស១៩៤០)"។ អាវនេះ គេពាក់ស៊ីក

older women who were already married. Instead, they wore undershirts openly without additional shirts when at home or when visiting neighbors nearby. Only when less familiar visitors came, or when one went farther than the immediate neighborhood, was an outer shirt traditionally added over the undershirt in order to appear appropriate.

The *tradauk daik* undershirt (figure 113) was like the *kak* undershirt but had an added waist panel. In the front, this shirt had two seams on each side as well as two or four additional darts. In the back, the *tradauk daik* undershirt had a seam running up the middle, as well as two or four side seams. The *tradauk daik* undershirt was mostly worn in Battambang Province.

The *pong*, blade of the hoe, or carrying shirt shaped like a tube (figure 114) was generally worn by adolescent girls from the age of 12 to 17 who would later wear the *kak* undershirt. Older people wore a similar shirt which was longer, reaching to the knees and worn as a sleeping outfit.

The undershirt with one strap (figures 115-116) was worn by elderly women in Battambang Province. This type of undershirt is no longer worn today. Mom Samuen, 76 years old, told us, "Old people in Battambang Province wore that shirt with the *kben*. Some wore an ornamental chain made



រូបលេខ ១១៥៖ អាវដៃមួយចំហៀង។

Figure 115: The one strap undershirt.

រូបលេខ ១១៦៖ អាវដៃមួយចំហៀង។ (រូបថត៖ រៃយ៉ំ)

Figure 116: The one strap undershirt. (Photo: Reyum)

ពីលើក្បាល គ្មានដាក់ខ្សែ សម្រុងមិនវែងទេ គឺខើចនៅលើចង្កេះដូចអាវកាក់ដែរ។ អាវខ្លះមានតថ្នេរចំហៀងទាំងមុខ ទាំងក្រោយ។

ប្រហែលទសវត្ស១៩៣០ ចាប់ផ្តើមមានអាវមួយប្រភេទទៀត គឺអាវបន្ដោង ឬអាវសង្រែក ឬអាវស៊ូជាង។ លោកយាយកៃ រឿង អាយុ៧៣ឆ្នាំ នៅខេត្តកណ្ដាល និយាយថា "អាវស៊ូជាង មុនដំបូងយើងគ្មានពាក់ទេ មានតែស្រីខូចពាក់។ ដល់ពួកហ្នឹងពាក់ យើងចេះតែតាមមើល យើងពាក់អត់បានទេ គេរិះគន់យើងច្រើន។ ពាក់តែអាវកាក់ ហោចុ៉ាមុខ ពាក់ទៅអត់ឃើញខ្ជិន"។ ក្រោយមកមានគេចម្លងគំរូអាវទ្រនាប់ប្រភេទថ្មីនេះ តាមសៀវភៅគំរូពីបរទេស ឬគំរូអាវដែលមានលក់នៅផ្សារ។ តែអ្នកស្រុកធម្មតាគេមិនទិញស្រាប់ទេ គ្រាន់តែចម្លងម៉ូតតាម កាត់

of gold or copper alloy over the bare shoulder. They wore the one strapped undershirt at home or to go to the market. During the reign of King Monivong, people associated with the Royal Palace wore this type of undershirt, but after his reign was over [ie. in the 1940s], people did not wear it anymore." The undershirt was drawn on over the head. It had no buttons and was generally cut short above the waist, like the *kak* undershirt. Some of these undershirts had additional darts on the sides of the front and the back.

It seems that in the 1930s, another type of undershirt appeared called variously the suspended, carrying, or *sujeang* shirt. Kai Rueng, 73 years old living in Kandal Province, told us, "In the beginning, we did



រូបលេខ ១១៧៖ អាវទ្រនាប់ដៃធំ។ (រូបថត៖ រៃយ៉ំ)

Figure 117: The big arm undershirt. (Photo: Reyum)



រូបលេខ ១១៨៖ អាវទ្រនាប់ដេរទ្រនាប់បកចេញក្រៅ ខាងឆ្វេងជាផ្នែកខាងមុខ ខាងស្តាំជាផ្នែកខាងក្រោយ។ (រូបថត៖ រៃយ៉ំ)

Figure 118: Undershirt with sewn supports, seen from the front (left) and the back (right). (Photo: Reyum)

ដោយខ្លួនឯង។ ដោយឡែរលើក្រណាត់ ដំបូងមានភាងដូចអាវកាក់ដែរ តែក្វៀលខ្នងមានដៃតូច ឡេវមុខ (រូបលេខ១១៧-១២១)។ អាវនេះគ្មានលក់ស្រាប់ទេ តេរច្រីនដេរខ្លួនឯង ឬជួលជាងដេរ។ ពីមុនអាវសម្រាប់មនុស្សស្រីវ័យចំណាស់ (អាយុ៤០ឆ្នាំឡើង) ច្រីនកាត់វែងដល់ផ្ទៃត ព្រោះគាត់ច្រីនពាក់អាវនេះនៅផ្ទះដែរដោយមិនពាក់អាវក្រៅមួយជាន់ទៀតទេ។ តែសម្រាប់ក្មេងស្រីច្រីនកាត់អាវខ្លីក្រោមចុងដង្កើមបន្តិច។ មកដល់ចុងទសវត្ស១៩៦០ មានអាវទ្រនាប់លក់ស្រាប់កាន់តែច្រីន ដែលជាហេតុនាំឲ្យឈប់ប្រើអាវសង្រែកដែលដេរខ្លួនឯងបន្តិចម្តង។ តែអ្នកនៅតាមស្រុកភូមិឆ្ងាយពីទីប្រជុំជននៅមានប្រើរហូតដល់សព្វថ្ងៃ (រូបលេខ១២២)។

not wear the *sujeang* shirt. Only bad women wore them. When they began to wear them, we saw them, but we didn't wear them because people would criticize us very much. Wearing the *kak* undershirt with pockets in the front, no one could see the back strap [as one does with bras]." Later though, the bra became accepted and was copied from foreign catalogues, or from readymade bras sold in the markets. At first, they used the shape of the *kak* shirt but cut it lower in the back with small straps and buttons down the front (see figures 117-121). These early bras were sewn by the individual wearer or commissioned from seamstresses, following the model of



រូបលេខ ១១៩៖ អាវសង្រែកក្លាយមានហោប៉ៅពីរ និងថ្នេរខ្នងពីរ មានដៃតូច។ អាវបែបនេះមានតែមនុស្សចាស់ទេដែលនៅមានពាក់ ខាងឆ្វេងជាផ្នែកខាងមុខ ខាងស្តាំជាផ្នែកខាងក្រោយ។ (រូបថត៖ រៃយ៉ំ)

Figure 119: *Sangraik* undershirt with two pockets and two back seams. This undershirt was worn by elderly women. On the left, seen from the front; on the right, seen from the back. (Photo: Reyum)



រូបលេខ ១២០៖ អាវសង្រែកជីបក្រោមដោះ ខាងឆ្វេងជាផ្នែកខាងមុខ ខាងស្តាំជាផ្នែកខាងក្រោយ។ (រូបថត៖ រៃយុំ)

Figure 120: *Sangraik* undershirt with darts under the breast, seen from the front (left) and the back (right). (Photo: Reyum)



រូបលេខ ១២១៖ អាវសង្រែកដេរសាប់ត្រង់ដោះ ខាងឆ្វេងជាផ្នែកខាងមុខ ខាងស្តាំជាផ្នែកខាងក្រោយ។ (រូបថត៖ រៃយុំ)

Figure 121: *Sangraik* undershirt with a thick seam across the breasts, seen from the front (left) and the back (right). (Photo: Reyum)

រូបលេខ ១២២៖ អ៊ីស្រីគុណ នៅខេត្តសៀមរាប នៅពាក់អាវទ្រនាប់ ស្លៀកសំពត់ចង្កឹនៅផ្ទះរាល់ថ្ងៃ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 122: Khun in Siem Reap Province wearing an undershirt with a *sampot* tied in the *kben* style. Photographed 2003. (Photo: Reyum)

៨- ខោទ្រនាប់

ខោទ្រនាប់ជាប្រភេទខោសម្រាប់ស្លៀកទ្រាប់ខាងក្នុង។ អ្នកខ្លះហៅខោទ្រនាប់ អ្នកខ្លះទៀតហៅខោក្នុង។ ចំណែកពាក្យថា ខោស្លីប (slip) គឺហៅតាមពាក្យបារាំង។ យើងដឹងថា ខោគឺខ្មែរទទួលឥទ្ធិពលមក

imported bras. Undershirts for older women, over the age of forty, were generally cut longer to reach to the navel. These undershirts could be worn in the house without wearing an additional shirt over them. The undershirts of younger women were cut shorter though, and generally ended below the sternum. By the end of the 1960s, more and more readymade bras were available, slowly causing people to stop wearing such earlier homemade undershirts as the *kak* or the carrying undershirt. Still, villagers in remote areas today wear the earlier types of undershirts (figure 122).

Underpants

There are several names for underpants in Khmer. Some call them *cow dranoap*, others call them *cow knong* [inside pants], while still others use the French word *slip*. Khmer traditionally were not used to wearing pants but instead wore the *sampot* tied in the *kben* and *samloy* style. Ong Sok, 80 years old living in Kandal Province, told us, "My mother's generation did not wear underpants. They weren't used to wearing them and underpants were not sold in the markets either. If they had been sold, perhaps people would have worn them. When I was little, I didn't have underpants to wear either.

រូបលេខ ១២៣៖ ខោស្លីបសម្រាប់មនុស្សស្រី។ (រូបថត៖ រៃយ៉ំ)

Figure 123: *Slip* underpants. (Photo: Reyum)

រូបលេខ ១២៤៖ ខោស្នាប់ភ្នៅស្លៀកបានទាំងស្រី ទាំងប្រុស។ (រូបថត៖ រៃយ៉ំ)

Figure 124: Short underpants worn by women and men. (Photo: Reyum)

ពីចិន។ នៅពេលបាកាំងចូលមក ខ្មែរបានស្គាល់ខោមួយប្រភេទទៀត ដែលខ្មែរហៅខោបាកាំង។ ខ្មែរប្រហែលគ្មានទម្លាប់ស្លៀកខោទេ គឺស្លៀកតែកន្សែង និងសម្ពុយ។ ចំណែកខោទ្រនាប់ ឬខោក្នុងក៏ប្រហែលជាមិនដែលមានស្លៀកដែរ។ លោកយាយអ៊ុង សុក អាយុ៨០ឆ្នាំ នៅខេត្តកណ្តាល និយាយថា "ពីជំនាន់ម្តាយយាយគេគ្មានខោក្នុងស្លៀកទេ ដោយសារគេមិនធ្លាប់ស្លៀក មក៉ាងមកពីគ្មានលក់ផង បើមានលក់ប្រហែលមានគេទិញស្លៀកហើយ។ ពេលយាយនៅក្មេង ក៏គ្មានខោក្នុងស្លៀកដែរ ហើយពេលមានរដូវម្តងៗ យាយយកក្រមាមកបត់ចងកន្សែងដើម្បីទ្រាប់។ ក្រោយមកគេមានខោក្នុងស្លៀកដែរ ខោនោះស្រដៀងខោថ្នេរ៣ និងខោថ្នេរ៥ដែរ។ ប៉ុន្តែខ្លីត្រឹមពាក់កណ្តាលភ្នៅ រលុង និងមានចង្កេះខ្សែនៅចង្កេះ ហើយស្លៀកបាន

When I had my period, I took a *krama* [checked scarf] and folded it in the *kben* style as protection. Later on, there started to be underpants. Those underpants were similar to the three and five seam pants, but short, falling only to about the middle of the thigh. They were loose and were tied at the waist with a string. Men and women wore them and they came to be called inside pants. It was only at the time that I had children [the 1940s] that they started to have tight form-fitting underpants that they called *slip* [after the French]. I never wore those because they were too tight and hot and I wasn't used to them. They used *des aik* (pure cotton) to make the *slip* type of underpants. Only women wore those *slip* underpants."

ទាំងប្រុសទាំងស្រី គេហៅថាខោក្នុង។ រហូតដល់ជំនាន់កូនយាយ (ប្រហែលទសវត្សរ៍១៩៤០) ទើបមានខោក្នុងរឹបស្លៀក គេហៅថាខោស្លីប។ តែយាយមិនចេះស្លៀកព្រោះខោនោះរឹបពេកស្អុះស្អាប់ ម្យ៉ាងមិនធ្លាប់ផង។ ខោស្លីបនេះគេយកក្រណាត់ទេសឯកមកកាត់ខ្វៀល តែខោប្រភេទនេះស្លៀកបានតែមនុស្សស្រីទេ (រូបលេខ ១២៣)។ តាមសម្តីលោកយាយឆាយ លីមយីម អាយុ ៨២ឆ្នាំ នៅខេត្តកណ្តាល និយាយថា "យាយគ្មានខោទ្រនាប់ស្លៀកទេ នៅពេលមានរដូវម្តងៗ ជួនកាលយកខោឪពុក ឬខោបង់ប្រុសចាស់ដែលគាត់ឈប់ស្លៀកយកមកស្លៀកដោយដេរដានក្រណាត់ទ្រាប់ភ្ជាប់ទៅនឹងខោកុំឲ្យរបូត រួចហើយរុះថ្នេរចេញ យកទៅបោក"។ ក្រៅពីនេះ មានស្ត្រីខ្លះនៅពេលមានរដូវគេស្លៀកសំពត់ពីរជាន់។ ខ្លះទៀត គេស្លៀកក្បិនហើយពាក់អាវវែងលុបពីលើ ដើម្បីបិទបាំង។ ចំពោះខោស្នាប់ភ្លៅ (រូបលេខ ១២៤) ខោនេះស្លៀកបានទាំងប្រុស និងស្រីនៅត្រង់ចង្កេះមានដាក់ខ្សែសម្រាប់ចង រហូតដល់ពេលមានខ្សែយឺត (ប្រហែលទសវត្សរ៍១៩៥០) គេដាក់ខ្សែយឺត ឬកៅស៊ូកង់ជំនួសវិញ។ ប៉ុន្តែអ្នកខ្លះគេនៅតែចូលចិត្តដាក់ខ្សែចង់ដដែល។ ខោនេះគេនៅប្រើរហូតដល់សព្វថ្ងៃ។ ទាំងនេះបញ្ជាក់ថា ខ្មែរទើបតែចេះស្លៀកខោក្នុងនៅសម័យបារាំង។ តែដំបូងប្រភេទខោដែលមានជើងខ្លីធំ ក្រោយមកគេចេះឆ្នៃតាមរបៀបម៉ូតខោរបស់បារាំងដែលមានខ្វៀលហើយរីបៗ

According to Chay Lim Khim, 82 years old living in Kandal Province, "I didn't have any underpants when I was little. When I got my period, sometimes I wore pants of my father or of my older brother that they had stopped wearing. I took those pants and sewed in padding, adding seams to keep it from falling out. I took those seams out in order to wash the pads." During menstruation, other women would wear two *sampot*, one over the other, or they would wear a *sampot* tied in the *kben* style with a long shirt hanging over it to cover any staining.

Short loose underpants were worn by both men and women. These loose underpants were at first held on by drawstring; in the 1950s, elastic waistbands or rubber bands generally replaced these drawstrings, although some people continued to prefer drawstring underpants. These types of loose fitting shorts are still worn as underpants today. The Khmer really only began to wear underpants during the French Protectorate. At first, underpants were quite loose, but later, perhaps under the influence of French fashion, they began to be made tighter and form-fitting.

៧- ក្រមាជាសម្លៀកបំពាក់

ប្រជាជនខ្មែរទូទៅស្ទើរគ្រប់តំបន់និយមប្រើក្រមាសម្រាប់វេចខ្ចប់ ក្រាល ទទួរ រហូតដល់ប្រើស្លៀកដណ្តប់រាងកាយទៀតផង។ យើងឃើញក្រមាមានប្រយោជន៍ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃ តែពេលនេះយើងសូមលើកយកតែការប្រើក្រមាជាសម្លៀកបំពាក់មកនិយាយប៉ុណ្ណោះ។

- ក្រមាធ្វើជាសំពត់ស្លៀក៖ ក្រមាត្បាញពីអំបោះឆៅដែលវៃពីសំឡីកប្បាស ឬម្យ៉ាង



រូបលេខ ១២៥៖ លោកអឹង សាមឿន អាយុ៦៥ឆ្នាំ ស្លៀកក្រមានៅផ្ទះ។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 125: Gin Sameun wearing a *krama* with a rolled waist at his house. Photographed 2002. (Photo: Reyum)

The *krama* as clothing

People all over the region today known as Cambodia liked to use the *krama* (checked scarf) to wrap objects, to cover things, to wrap around their head as protection from the sun, or to catch sweat. *Krama* were also used for covering the body. *Krama* had many uses in everyday life, but here we simply discuss its use as a form of clothing or covering for the body.

The *krama* as a *sampot*

Krama were woven from raw cotton thread spun from cotton fiber or, today, from nylon or other synthetic threads. The *krama* is really simply a length of cloth which can be large or small according to the wishes of the user. The *krama* worn as a *sampot* is generally at least one and a half meters in length, and seventy centimeters wide. We see men, starting from adolescence, wearing *krama* wrapped around their waist and falling as a simple short skirt-like garment. The *krama* is worn like this at home, when working around the home, in the fields, and especially when going to bathe in the rivers or lakes. The *krama* worn in this way is considered the most ordinary and easiest type of everyday garment. The *krama* is held and simply wrapped tightly around the waist from the back, with one end overlapping

ទៀតដែលសព្វថ្ងៃគេមានគ្នាញញីអំបោះដែលផលិតដោយបច្ចេកទេសឧស្សាហកម្ម (គេហៅថាអំបោះហ៊ុងមានជាតិនីឡុង)។ ក្រមាប្រៀបដូចជាក្រណាត់មួយផ្ទាំងមានទំហំធំ ឬតូចទៅតាមចិត្តរបស់អ្នកប្រើ។ ក្រមាដែលគេយកមកស្លៀកយ៉ាងហោចណាស់ក៏មានបណ្តោយមួយម៉ែត្រកន្លះ ទទឹង៧តឹកដែរ។ យើងតែងឃើញបុរសចាប់ពីវ័យជំទង់ឡើងទៅស្លៀកក្រមានៅផ្ទះ ឬធ្វើការងារក្បែរផ្ទះ ឬធ្វើស្រែចម្ការ ឬមួយធ្វើដំណើរទៅណាមកណាជិតៗ ពិសេសពេលងូតទឹក។ គេទុកក្រមាជាសម្លៀកយ៉ាងសាមញ្ញ ហើយងាយស្រួលបំផុត គឺគ្រាន់តែយកក្រមាមកពុំពីក្រោយត្រឹមចង្កេះបត់មកខាងមុខ ដោយជាយមួយចំហៀងផ្អិបជាប់ទៅនឹងចង្កេះផ្នែកម្ខាង។ ឯជាយក្រមាមួយចំហៀងទៀតបត់មកផ្អិបលើចង្កេះផ្នែកម្ខាងទៀត រួចចុកជាយខាងលើនៅចន្លោះជាយក្រមានឹងចង្កេះ ឬផ្អិបជាយក្រមាផ្នែកខាងលើជាប់មកតម្បាពោះ រួចមូរជាយនោះចេញក្រៅដោយយកបាតដៃទាំងពីរសង្កត់ ហើយរុញចុះក្រោមបន្តិចជាការស្រេច។ ការស្លៀកក្រមារបៀបនេះច្រើនតែជាមនុស្សប្រុស (រូបលេខ១២៥–១២៦)។

– ក្រមាធ្វើជាអៀម ឬពាតថា៖ គេអាចយកក្រមាមកស្លៀកដណ្តប់ធ្វើជាអៀមបានយ៉ាងងាយ។ តាំងពីក្មេងតូចរហូតដល់មនុស្សចាស់ គេអាចប្រើក្រមាធ្វើជាអៀមបានដែរ គឺគ្រាន់តែយកក្រមាមកពុំពីផ្នែកខាងខ្នងបត់មកមុខតាមក្រោមក្អែកហើយបត់ក្រមាខ្វែងគ្នា ដោយយកជាយខាងឆ្វេងព័ទ្ធ

រូបលេខ ១២៦៖ ក្មេងចង់ក្បិនក្រមាកំពុងជាន់ស្នប់ទឹក។ ថតនៅសៀមរាប ឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 126: A child wearing a *krama* tied in the *kben* style using a water pump in Siem Reap Province. Photographed 2003. (Photo: Reyum)

the other in the front. The overlapping end is then tucked inside the inner layer of cloth at the waist to hold the garment closed against the stomach. Alternately, the ends are simply overlapped and then rolled down along the waist with the palms of both hands. It is men who generally wear the *krama* in this manner (figures 125-126).

The *krama* tied as an *eam* or *peat ba*

It is also easy to use the *krama* to cover the body from the chest to the thighs, wrapping the cloth from the back to the front under the armpits. People of all ages can wear

រូបលេខ ១២៧៖ ស្ត្រីចាស់ចងអៀមក្រមាលើអាវពេលលេងល្បែងដណ្តើមស្ពរ ក្នុងពិធីសែនអ្នកតាចាស់ស្រុករបស់ជនជាតិសួយ នៅខេត្តកំពង់ស្ពឺ។ ឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 127: Women wearing *krama* tied as an *eam* while playing a ritual game of the Suoy ethnic group. Photographed in Kompong Speu, 2002. (Photo: Reyum)

ទៅលើស្មាស្តាំ និងយកជាយខាងស្តាំព័ទ្ធខ្នែងទៅលើស្មាខាងឆ្វេង រួចចងជាយទាំងពីរភ្ជាប់គ្នាត្រង់កញ្ចឹងក នោះកើតបានជាអៀមតែម្តង។ អៀមក្រមានេះបើក្មេងមិនចាំបាច់ស្លៀកខោឡើយ តួរតែក្រមាធំអាចគ្របដណ្តប់រាងកាយជិតតែម្តង។ សម្រាប់ស្ត្រី ខ្លះគេពាក់អាវហើយចងអៀមក្រមាពីលើមួយជាន់ថែមទៀតនៅពេលធ្វើការងារផ្សេងៗ ដើម្បីកុំឲ្យប្រឡាក់អាវ (រូបលេខ ១២៧)។ ជួនកាលម្ខាងទៀតក៏ចូច ឬក្តៅស្អុះស្អាប់គេចងអៀមក្រមានេះដោយមិនពាក់អាវទេ។ អៀមគ្រាន់តែពាក់ជាបណ្តោះអាសន្ន។ ចំពោះមនុស្សចាស់ត្រូវស្លៀកខោ ឬសំពត់ថែមទៀត ព្រោះអៀមក្រមាអាចបិទបាំងរាងកាយតែផ្នែកខាងលើប៉ុណ្ណោះ។

the *krama* in this way. The *krama* is wrapped around the back, at armpit level, and both ends are brought to the front and crossed over each other. The left end is brought over the right shoulder and the right end is brought over the left shoulder. The two ends are then tied together at the back of the neck. Young children wear the *krama* like this with no pants or lower garments. If the *krama* is big enough, it can cover the whole body adequately. Women sometimes wear a shirt and then add a *krama* tied in this manner over it, especially when they are working. The *krama* protects their shirt from staining. When bathing or in case of extreme heat, they wear

- ក្រមាធ្វើជាអាវ៖ ចំពោះមនុស្សប្រុសគេអាចយកក្រមាមកចង់ជាអាវពាក់បណ្តោះអាសន្នពេលនៅផ្ទះ និងធ្វើការជិតៗផ្ទះប៉ុណ្ណោះ។ គេអាចយកក្រមាមកធ្វើជាអាវបានពីរបែប គឺមួយបែបគេយកក្រមាមកបត់ជាពីរ ហើយចង់ចុងជាយសងខាងភ្ជាប់គ្នាខាងលើ និងខាងក្រោម បានជាទម្រង់ស្មើរដូចថង់។ គេយកផ្នែកម្ខាងដែលចំហមកចង់ជាយភ្ជាប់គ្នានៅត្រង់មួយភាគបីនៃផ្នែកម្ខាងដែលចំហនោះជាពីរចំណុចដើម្បីធ្វើជាក និងដៃអាវទាំងពីរ។ អាវប្រភេទនេះមានចំហៀងតួខ្លួនម្ខាងចំហរ ម្ខាងជិត ហើយអាចធ្វើបានលុះត្រាតែក្រមានោះធំ។ អាវនេះពាក់បានតែចំពោះតែក្មេងប្រុសប៉ុណ្ណោះ (រូបលេខ១២៨-១២៩)។

the *krama* wrapped as described above with no shirt. This is only a temporary garment worn in private. In general, adults wear the *krama* tied as an *eam* with pants or a *sampot*, since the *krama* can only really cover the upper part of the body.

The *krama* worn as a shirt

Boys and men sometimes wear the *krama* tied as an informal shirt or covering when at home or working near the house. There are two types of these *krama* shirts. For one, the *krama* is folded in half and the ends are tied together to form a kind of bag shape. One open side of this bag is then tied in thirds to make three holes, the center one for the



រូបលេខ ១២៨៖ ក្រមាធ្វើជាអាវ ផ្នែកខាងមុខ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 128: A *krama* shirt seen from the front. Photographed 2003. (Photo: Reyum)

រូបលេខ ១២៩៖ ក្រមាធ្វើជាអាវ ផ្នែកខាងក្រោយ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 129: A *krama* shirt seen from the back. Photographed 2003. (Photo: Reyum)

រូបលេខ ១៣០៖ ក្រមាធ្វើជាអាវ ផ្នែកខាងមុខ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 130: A *krama* shirt seen from the front. Photographed 2003. (Photo: Reyum)



រូបលេខ ១៣១៖ ក្រមាធ្វើជាអាវ ផ្នែកខាងក្រោយ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 131: A *krama* shirt seen from the back. Photographed 2003. (Photo: Reyum)

មួយបែបទៀតគេយកចុងជាយក្រមាម្ខាងមកចងត្រង់ចំណុចមួយភាគបីនៃជាយក្រមាម្ខាងធ្វើជាដៃម្ខាង ហើយចុងជាយក្រមាម្ខាងទៀតមកចងត្រង់ចំណុចមួយភាគបីនៃជាយក្រមាដដែលនោះដែរ ដើម្បីធ្វើជាដៃម្ខាងទៀត។ អាវប្រភេទនេះគ្មានកទេ ពេលគេពាក់ចំហទ្រូង មើលទៅដូចជាអាវវាលក្បៀត (រូបលេខ ១៣០-១៣១)។ អាវដែលគេយកក្រមាមកធ្វើនេះចំពោះស្ត្រីគេមិនពាក់ទេ។ ប៉ុន្តែបើក្មេងស្រីនៅតូចខ្លះក៏ពាក់បានដែរ។

head and the two side ones for the arms. This type of covering can be made from a quite large *krama* and is generally only worn by small boys (figures 128-129). Another kind of *krama* shirt is made by tying each end of the *krama* together to form sleeves. Each end of the *krama* is tied a third of the way from one side and the arms are inserted into the resulting holes. This type of *krama* shirt leaves the chest and neck bare (figures 130-131). Sometimes little girls wear shirts like this, although no older girls or women wear them.

រូបលេខ ១៣២៖ ក្មេងស្រីចោមពុងក្រមា ថតប្រហែលឆ្នាំ១៩០០ នៅមុខប្រាសាទអង្គរវត្ត។ (រូបថត៖ បណ្ណសារជាតិ)

Figure 132: Young people in front of Angkor Wat wearing *krama* wrapped as *choam pong*. Photographed around 1900. (Photo: National Archives of Cambodia)

រូបលេខ ១៣៣៖ លោកយាយសែម ឡាប អាយុ៧៧ ឆ្នាំ នៅខេត្តសៀមរាប ចោមពុងក្រមា។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 133: Saim Laap, 77 years old living in Siem Reap Province wearing a *krama* as a *chaom pong*. Photographed 2002. (Photo: Reyum)

– ចោមពុង ឬចង្ហពុងក្រមា៖ ចំពោះស្រីពេញវ័យ គេច្រើនចោមពុងក្រមានៅផ្ទះ និងពេលធ្វើការងារស្រាលៗក្បែរផ្ទះ។ របៀបចោមពុង គេយកក្រមាមកបុំលើខ្លួនត្រឹមក្រោមក្លៀកចុះមកក្រោម ហើយចុកជាយម្ខាងឲ្យជាប់ (រូបលេខ១៣២–១៣៣)។

Choam pong or *chang pong*

Adolescent girls and women often wore the *krama* wrapped as a *choam pong* when they were at home or working around the house. The *krama* was wrapped around the body just under the armpits, closing the garment by tucking one end inside the other end, or tying the ends together (figures 132-133).

๓- សម្លៀកបំពាក់ "សម័យ"

មុនទសវត្ស១៩៥០ នៅក្នុងស្រុកខ្មែរយើង អាចនិយាយថាមិនសូវសម្បូណិប្រភេទសម្លៀកបំពាក់នៅឡើយទេ។ មនុស្សម្នាក់ក្នុងគ្រួសារមានត្រឹម២-៣កំប្លេ ហើយបើនៅឯជនបទវិញស្ទើរតែមួយកំប្លេប៉ុណ្ណោះ។ ចាប់ពីទសវត្ស១៩៥០មក ដោយសារ

រូបលេខ ១៣៤៖ រូបក្នុងសៀវភៅតាឡុតដែលបង្ហាញពីរបៀបកាត់ដេរម៉ូតតាមសម័យទំនើប ទសវត្ស១៩៦០ "វិជ្ជាកាត់ដេរដោយខ្លួនឯង" ដោយអ៊ាប-ប៊ុន-សុត។

Figure 134: Modern evening wear in a clothing catalogue from the 1960s. (Photo: *Sewing by yourself*, by Aap Bun Soth, 1960s)

Modern types of clothing

Before the 1950s, there were not so many different types of clothing. In general, people only owned two or three sets of clothing, and in the countryside sometimes they often only had one set of clothing if that. With the end of World War II and the coming of independence in 1953, standards of living gradually improved and the country

រូបលេខ ១៣៥៖ សម្លៀកបំពាក់នេះ ពាក់ចូលក្នុងពិធីមង្គលការ។ ឆ្នាំ១៩៧០។ (រូបថត៖ អឹស្រី យិនណារ៉ា)

Figure 135: Yen Nara dressed to attend a wedding, 1970. (Photo: Collection of Yen Nara)

រូបលេខ ១៣៦៖ ស្ត្រីពាក់អាវសម័យទំនើបទៅវត្ត គំនូរនៅលើជញ្ជាំងព្រះវិហារ វត្តកំពង់ថ្ម ខេត្តកំពង់ធំ គួរឆ្នាំ១៩៥៨។
(រូបថត៖ រៃយ៉ំ)

Figure 136: Women wearing various kinds of modern shirts. Painting on the walls of Wat Kompong Thmei, Kompong Thom Province, 1958. (Photo: Reyum)

រូបលេខ ១៣៧៖ នារីបម្រើតាមយន្តហោះស្បៀកពាក់ជាឯកសណ្ឋានតាមសម័យទំនើប។ ថតនៅទសវត្សរ៍១៩៦០។
(រូបថត៖ បណ្ណសារជាតិ)

Figure 137: Royal Air Cambodge stewardesses wearing modern short skirts, 1960s.
(Photo: National Archives of Cambodia)

សង្គ្រាមលោកលើកទី២ត្រូវបញ្ចប់ ហើយមានការអភិវឌ្ឍន៍ក្នុងវិស័យសេដ្ឋកិច្ច និងបច្ចេកវិទ្យា។ ព្រមទាំងក្នុងសម័យសង្គមរាស្ត្រនិយមមានបង្កើតរោងចក្រឧស្សាហកម្ម ទើបសម័យនោះយើញមានលេចចេញនូវប្រភេទខោអាវ និងក្រណាត់ថ្មីៗច្រើន ដែលចាស់ៗគាត់កំណត់ហៅថា ខោអាវទំនើប ឬស៊ីវិល័យ។ ប៉ុន្តែខោអាវទាំងនោះច្រើនតែអ្នកទីក្រុងប្រើ មិនទាន់ចាន ជ្រាបជាទូទៅដល់ជនបទឡើយ។ អ្នកនៅទីក្រុងនិយមម៉ូតមកពីបរទេសច្រើន ពិសេសម៉ូតមកពីបារាំង ព្រមទាំងចាប់ផ្តើមនិយមម៉ូតអាវដែលមានដេរជើបរាង។ ការលេចចេញច្រើននូវម៉ូតថ្មីៗ មិនត្រឹមតែមានខាងសម្លៀកបំពាក់ទេ ក្នុងវិស័យតុបតែងខ្លួន សម្ភារកា

began to develop industrially and technologically. By the end of the 1950s, domestic factories were producing cloth, and increasing numbers and varieties of imported cloth and clothing entered the country. Elderly people called the new styles and fashions of clothing modern or *civilisé*. It was mostly city dwellers who turned to the new kinds of clothing, and we should not think that the countryside was filled with people wearing such clothing. City dwellers liked foreign fashions, particularly French fashions, and they began to appreciate form-fitting clothing which showed off the body. It was not only in the realm of clothing that new fashions emerged and proliferated.



រូបលេខ ១៣៨៖ សិស្សអនុវិទ្យាល័យ ខេត្តកំពង់ធំ ឆ្នាំ១៩៥៨។
(រូបថត៖ លោកម៉ៃខឺល វិកខឺរី)

Figure 138: High school students in Kampong Thom Province. Photographed 1958.
(Photo: Dr. Michael Vickery)

រូបលេខ ១៣៩៖ សម្លៀកបំពាក់ក្នុងពិធីរៀបការមួយ នៅខេត្តកំពង់ធំ ឆ្នាំ១៩៥៨។ (រូបថត៖ លោកម៉ៃខឺល វិកខឺរី)

Figure 139: A wedding ceremony, Kampong Thom Province. Photographed 1958.
(Photo: Dr. Michael Vickery)

មានបែបបទថ្មីៗច្រើនដែរ។ ហេតុដូច្នេះទើបឃើញមានការផ្សាយពាណិជ្ជកម្មសម្លៀកបំពាក់ ម្សៅលាបមុខ ក្រែមតាមរយៈសៀវភៅតាតាឡុក ព្រមទាំងមានការបង្ហាញម៉ូតដូចនៅអឺរ៉ុបដែរ។

ខាងក្រោមនេះយើងលើកយកប្រភេទសម្លៀកបំពាក់ខ្លះមកបង្ហាញ ដោយមិនលម្អិតពីវិធីកាត់ដូចសម្លៀកបំពាក់មុនៗឡើយ។ ព្រោះយល់ថាបច្ចុប្បន្ននេះម៉ូតសម្លៀកបំពាក់ទាំងនោះ គាត់ច្រើននៅមានអ្នកនិយមពាក់ និងចេះកាត់នៅឡើយ។

Make-up, hairstyles and the decoration of the self also changed greatly and came to rely on new products and processes. Advertisements in the 1960s promoted facial products, lipsticks and other beauty products in addition to clothing in the European style.

On the following pages, we show various kinds of clothing considered modern. We do not detail how these types of clothing were made as they remain quite popular today. Although the vast majority of these types of clothing are now manufactured in factories and sold readymade, individual seamstresses in Cambodia still know how to make them and pursue a business of undercutting the price of such readymade fashions by their sewn imitations.



រូបលេខ ១៤០៖ ខ្សែអាវនេះខ្លះធ្វើពីមាស ពេលពាក់តែងត្រូបស្បៃពីលើ ទសវត្សរ៍១៩៥០។

Figure 140: The straps of this shirt were sometimes made of gold. The shirt was worn under a shawl.



រូបលេខ ១៤១៖ អាវមួយប្រភេទដែលគេប្រើទសវត្សរ៍១៩៥០។

Figure 141: A type of shirt worn in the 1950's.



រូបលេខ ១៤២៖ អៀមខោងជើងជាសម្លៀកបំពាក់ក្មេងរបៀបបារាំង។

Figure 142: Infant outfit in the French style.



រូបលេខ ១៤៣៖ អៀមដាក់ឡេវក្រោមជាសម្លៀកបំពាក់ក្មេងរបៀបបារាំង។

Figure 143: Infant outfit with snap buttons in the French style.



រូបលេខ ១៤៤៖ សម្លៀកបំពាក់ក្មេង។

Figure 144: Child's outfit in the French style.



រូបលេខ ១៤៥៖ សម្លៀកបំពាក់ក្មេងប្រុសរបៀបបារាំង។

Figure 145: French style boy's outfit.



រូបលេខ ១៤៦៖ សម្លៀកបំពាក់ក្មេងស្រីរបៀបបារាំង។

Figure 146: French style girl's outfit.



រូបលេខ ១៤៧៖ សម្លៀកបំពាក់ក្មេងរបៀបខ្មែរ។

Figure 147: Khmer style children's outfit.

រូបលេខ ១៤៨៖ អាវស៊ីមិបើកក។

Figure 148: An open neck *chemise.*



រូបលេខ ១៤៩៖ អាវកកំពត មានប្រើប្រហែលតាំងពីទសវត្សរ៍១៩៥០។

Figure 149: The *kampot* neck shirt worn beginning in the 1950s.



រូបលេខ ១៥០៖ អាវកដក់។

Figure 150: Shirt with a *dauk* neck.



រូបលេខ ១៥១៖ អាវតវិល
មានពាក់តាំងពីទសវត្សរ៍១៩៥០។

Figure 151: Shirt with a whirl collar, worn since the 1950s.



រូបលេខ ១៥២៖ អាវវាលក្លៀក កជ្រុងមានពាក់តាំងពីទសវត្សរ៍១៩៥០។

Figure 152: The *veal kliek* shirt (*veal kliek* is the area around the armpit) with a square neck. This style of shirt was worn starting in the 1950s.

រូបលេខ ១៥៣៖ អាវប៉ូការេ កជប៉ុន។

Figure 153: *Bo kare* shirt with a so-called Japanese neck.



រូបលេខ ១៥៤៖ អាវសម្រាប់ពាក់នៅផ្ទះ។

Figure 154: Shirt worn in the house.



រូបលេខ ១៥៥៖ អាវតាខិប ទសវត្សរ៍១៩៤០។

Figure 155: *Takeb* shirt, 1940s.

ឈ- សម្លៀកបំពាក់សម័យ ខ្មែរក្រហម

បើនិយាយពីសម្លៀកបំពាក់សម័យខ្មែរ ក្រហម គេអាចចាត់ទុកជាប្រធានបទទូលំទូលាយមួយ ដែលអាចចំណាយពេលស្រាវជ្រាវ និងអធិប្បាយ ច្រើនបើសិនជាយើងត្រូវធ្វើលម្អិត។ ប៉ុន្តែការសម្រេច របស់យើងគឺមានបំណងគ្រាន់តែលើកយកសម្លៀក បំពាក់ខ្លះៗដូចជាខោអាវ ក្រមា ស្បែកជើង ជាដើម មកបង្ហាញត្រួសៗតែប៉ុណ្ណោះ។

រូបលេខ ១៥៦៖ កូនស្រីកម្មាភិបាល ថតនៅភ្នំពេញ ប្រហែលក្នុងឆ្នាំ១៩៧៦។ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 156: Female Khmer Rouge cadres. Photographed in 1976 in Phnom Penh. (Photo: Documentation Center of Cambodia)

Clothing during Democratic Kampuchea

According to our elderly interviewees, there was a clothing shortage during Democratic Kampuchea (the Khmer Rouge Regime which ruled Cambodia from 1975 to 1979). Many urban dwellers left the cities precipitously in April of 1975, thinking that they would return home in a few days, so they took



រូបលេខ ១៥៧៖ សម្លៀកបំពាក់ស្ត្រីដែលមានឋានៈជាមេកង ឬមេក្រុម។ ថតឆ្នាំ១៩៧៥។ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 157: Clothing for female Khmer Rouge leaders. Photographed 1975. (Photo: Documentation Center of Cambodia)

តាមការសាកសួរមនុស្សដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបង្ហាញថា ក្នុងជំនាន់ខ្មែរក្រហមពុំមានខោអាវសម្រាប់ស្លៀកពាក់គ្រប់គ្រាន់ឡើយ។ ជាពិសេសអ្នកនៅភ្នំពេញមួយចំនួនធំពុំបានយកខោអាវទៅតាមខ្លួនពេលខ្មែរក្រហមជម្លៀសចេញពីទីក្រុង។ គេគិតថា ត្រូវចេញពីផ្ទះតែ៣ថ្ងៃប៉ុណ្ណោះ។ ប្រជាជនខ្លះបាននាំយកសម្លៀកបំពាក់តាមខ្លួនខ្លះៗ។ ខោអាវទាំង



រូបលេខ ១៥៨៖ មហោស្រព នៅខេត្តកំពង់ចាម សម័យប៉ុល ពត។ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 158: Theater Performance, Kompong Cham Province. (Photo: Documentation Center of Cambodia)

few clothes with them. What clothing they did take was quickly dyed black using *mcleur*, mud, or anything else that would turn the cloth black and thus make the clothing wearable under the new regime. The typical outfit worn by all people during the Khmer Rouge Regime was long black pants with an elastic waistband, a long sleeved black shirt with an open neck, and a *krama* wrapped around the neck. Female cadres wore *sampot bot* (folded *sampot* like the *sampot juppe*), or pants with elastic waistbands. Elderly women could wear *sampot* in the *samloy* style to work in and around their homes. Most survivors of the Khmer Rouge Regime remember vividly the acute shortages of many kinds including clothing. Few people had cloth to make their own clothing, and thus they wore what old and tattered clothing they had. According to Hong

រូបលេខ ១៥៩៖ សម្លៀកបំពាក់កូនកម្មាភិបាល ពេលចូលរួមក្នុងកម្មវិធីមួយនៅភ្នំពេញ។ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 159: Clothing for child cadres participating in a ceremony in Phnom Penh. (Photo: Documentation Center of Cambodia)

នោះត្រូវយកទៅជ្រលក់ផ្អែមក្រឿ ជាន់តក់ ឬអ៊ីផ្សែង ទៀតឲ្យតែខោអាវឡើងពណ៌ខ្មៅទើបអាចស្លៀកបាន។

ជាទូទៅមនុស្សទាំងអស់ក្នុងជំនាន់ខ្មែរក្រហម ស្លៀកខោជើងវែង ចង្កេះដាក់ខ្សែយឺត (កៅស៊ូ) ពាក់អាវដៃវែងបើកកពណ៌ខ្មៅ បង់កក្រមា។ កងទ័ពស្រី ស្លៀកសំពត់បត់ ឬស្លៀកខោដាក់ខ្សែយឺត។ ចំពោះស្ត្រីចាស់ៗស្លៀកសម្លុយធ្វើការក្នុងភូមិជិតផ្ទះ។ តាមការចងចាំរបស់មនុស្សស្ទើរគ្រប់គ្នាដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម គឺខ្វត់ទាំងម្ហូបអាហារ ទាំងសម្ភារៈប្រើប្រាស់។ ម្ល៉ោះហើយប្រជាជនទូទៅគ្រមានក្រណាត់យកមកដេរខោអាវខ្លួនឯង។ ដូច្នេះខោអាវដែលស្លៀកពាក់មានច្រើនបំណះ។ លោកតា ហង់ ហ៊ីវ អាយុ៦៤ឆ្នាំ នៅខេត្តសៀមរាបនិយាយថា "បើទាហានខ្មែរក្រហមគេបើកខោអាវឲ្យមួយឆ្នាំម្តង"។ ជាទូទៅមានតែថ្នាក់ដឹកនាំនៅតាមមន្ទីរនានា ប្រធានសហករណ៍ ប្រធានក្រុម ប្រធានភូមិ និង

រូបលេខ ១៦០៖ សម្លៀកបំពាក់ថ្នាក់ដឹកនាំប្រទេសពេលទៅទទួលគណៈប្រតិភូ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 160: Leaders of the Khmer Rouge Regime receiving a foreign delegation. (Photo: Documentation Center of Cambodia)

Heo, 64 years old living in Siem Reap Province, "[the Khmer Rouge] soldiers were given clothing once a year." Only the local leadership and soldiers seem to have received sets of clothing on a regular basis. In general, they were given two shirts, two pants, one *krama*, a pair of shoes, and a hat each year. Ordinary people in cooperative labor groups made do with the clothing they had from before. Mom Samuen, 76 years old, told us, "Those who took away my husband wore black shirts and pants, and new red *krama* wrapped around their necks. They smelled good because they had scented soap to wash with." Although the leadership and soldiers, even at local levels, had new and better clothing than ordinary people, all clothing was the same style: long pants and long-sleeved shirts in black with *krama* wrapped around the neck.

The *kadep* or beret-like cap, worn by cadres during the Khmer Rouge regime, was at first imported from China. Later the *kadep* was sewn domestically, using the Chinese hat as a model. Only Khmer Rouge cadres wore these hats. Some ordinary people fashioned hats from palm leaves, while others covered their heads with *krama*. In Phnom Penh during the Khmer Rouge Regime, a clothing factory was established in the area where O'Russey Market stands today. This clothing factory made clothing for Ministry officials and leaders of the Khmer Rouge throughout the country. The Khmer Rouge allowed some

រូបលេខ ១៦១៖ សម្តេចបំពាក់ថ្នាក់ដឹកនាំពេលទៅទទួលតណ: ប្រតិភូចិន នៅពោធិចិនតុង។ ថតឆ្នាំ១៩៧៧។ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 161: Leaders of the Khmer Rouge Regime greeting a delegation at Pochentong Airport, 1977. (Photo: Documentation Center of Cambodia)

កងទ័ពប៉ុណ្ណោះដែលទទួលរបបខោអាវទៀងទាត់ គឺ ក្នុងមួយឆ្នាំម្តង មានអាវ២ ខោ២ ក្រមា១ ស្បែកជើង មួយគូ និងមួកកាតឹប១។ ឯប្រជាជនតាមសហករណ៍ នានាស្លៀកខោអាវជារបស់ផ្ទាល់ខ្លួនបន្តិចបន្តួច ដែលសល់ពីសម័យមុនៗប៉ុណ្ណោះ។ លោកយាយ មុម សំអឿន អាយុ៧៦ឆ្នាំ និយាយថា "កម្មាភិបាលដែលមកយកប្តីខ្ញុំទៅ គេពាក់ខោអាវខ្មៅ និង ក្រមាក្រហមថ្មីបង់ក ហើយខ្លួនគេធុំក្លិនក្រអូប ព្រោះ គេមានសាប៊ូក្រអូបដុស"។ ឯអ្នកមានឋាន:ចាប់ពីមេ ក្រុមឡើង សម្លៀកបំពាក់របស់ពួកគេ មានពណ៌ខ្មៅ ស្អាតហើយថ្មីជាងខោអាវប្រជាជន។ ចំណែកខោអាវ កងទ័ពមិនខុសពីខោអាវប្រជាជនប៉ុន្មានទេ គឺខោវែង អាវដៃវែង មានពណ៌អាចម៍សេះ និងពណ៌ខ្មៅ។

ចំពោះមួកកាតឹប មុនដំបូងនាំយកមកពីចិន ក្រោយមកមានដេរក្នុងស្រុកតែម្តង ដោយយកគំរូតាម មួកចិន។ មានតែកងទ័ពប៉ុណ្ណោះ ទើបពាក់មួកកាតឹប។ ឯប្រជាជនធម្មតាខ្លះមានពាក់មួកធ្វើពីស្លឹកត្នោត ខ្លះ ប្រើក្រមា។ នៅជំនាន់ខ្មែរក្រហម នៅភ្នំពេញម្តុំផ្សារ អូរឫស្សីមានរោងជាងកាត់ដេរខោអាវសម្រាប់ចែក តាមក្រសួង មន្ទីរ និងប្រធានសហករណ៍នានាទូទាំង ប្រទេស។ នៅតាមតំបន់ខ្លះមានត្បាញក្រណាត់ សូត្រទុកសម្រាប់ធ្វើជាអំណោយដល់ជនបរទេស។ ពេលមានភ្ញៀវបរទេសមកធ្វើទស្សនកិច្ចម្តងៗ អ្នកធ្វើ ការនៅមន្ទីរ ក្រសួងក្នុងក្រុងភ្នំពេញដែលត្រូវស្នើឲ្យ ទៅឈរទទួលភ្ញៀវនៅព្រលានយន្តហោះនោះ ត្រូវ

silk weaving to continue in some areas; silk produced was offered as gifts to official foreign visitors. Ministry officials assigned to greet such visitors were permitted to go to a special storeroom for clothing. Each official could choose a proper size shirt, pants or *sampot*. For such receptions, women wore a *sampot* of *hol* with a white shirt, while men wore black French pants with white shirts. When their official duties were completed, they were required to return the clothing to the storeroom. High government leaders generally seem to have worn French style black pants



រូបលេខ ១៦២៖ សកម្មភាពវៃអំបោះ នៅសម័យខ្មែរក្រហម។ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 162: Spinning cotton thread during the Khmer Rouge regime..(Photo: Documentation Center of Cambodia)



រូបលេខ ១៦៣៖ រោងចក្រតម្បាញ នៅភ្នំពេញ។ ប្រហែលថតឆ្នាំ១៩៧៦។ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 163: Weaving factory in Phnom Penh, probably photographed in 1976. (Photo: Documentation Center of Cambodia)

ចូលទៅកាន់តន្លែងឃ្លាំងមួយមានខោអាវដេរស្រាប់។ ម្ខាក់ៗត្រូវរើសរកខោអាវ ឬសំពត់ដែលត្រូវនឹងទំហំខ្លួន ស្ត្រីត្រូវស្លៀកសំពត់ហូល អាវស បុរសពាក់អាវស ស្លៀកខោជាវាំងពណ៌ខ្មៅ។ នៅពេលចប់ពិធី ពួកគេត្រូវដោះសម្លៀកបំពាក់នោះទុកនៅក្នុងឃ្លាំងវិញ។ ចំណែកថ្នាក់ដឹកនាំប្រទេសមានឯកសណ្ឋានខោជាវាំងពណ៌ខ្មៅ អាវកត្រង់ពណ៌ខ្មៅ។

ទោះបីមានរោងចក្រតម្បាញក្រណាត់ក្នុងស្រុក ក៏ផលិតផលនៅតែពុំគ្រប់គ្រាន់សម្រាប់មនុស្សទូទាំងប្រទេសដែរ។ ព្រោះថាមានក្រណាត់មួយចំនួននាំចូលមកពីបរទេស ពិសេសប្រទេសចិន ដោយយកផលិតផលកសិកម្មក្នុងស្រុកទៅដោះដូរវិញ។

ខ្មែរមានទម្លាប់ប្រើក្រមា ពិសេសអ្នកស្រុកស្រែចម្ការ។ ក្រមាក្រឡាក្រហមលាយស ជានក្លាយ

with straight collared long sleeve black shirts. Although there were factories weaving clothing, not nearly enough cloth was produced to clothe the population as a whole. Cloth was imported from China in exchange for agricultural products produced by Democratic Kampuchea.

Traditionally, people in the countryside of the region today known as Cambodia had wore *krama*, the characteristic checked scarves described on page 98. The Khmer Rouge adopted the red and white checked *krama* as a symbol for their regime, and this fact is still remembered today in the statement "wearing a krama like Pot." According to one of our elderly interviewees who wished to remain anonymous, *krama* were woven domestically during Democratic Kampuchea.

ទៅជាសញ្ញាសម្គាល់សម័យខ្មែរក្រហម ដូចមានពាក្យថា "បង់ក្រមាដូចអាពត" យើងមិនដឹងច្បាស់មូលហេតុអ្វីទេ។ តាមសម្តីលោកម្នាក់[1] ដែលយើងបានសម្ភាសន៍ថា "នៅជំនាន់ខ្មែរក្រហម ក្រមាសុទ្ធតែត្បាញនៅក្នុងស្រុក ហើយជាទូទៅ គេប្រើក្រមាសលាយក្រហម លើកលែងខេត្តនៅភាគខាងកើតទើបមានប្រើក្រមាក្រឡាសលាយខៀវ"។

ចំណែកស្បែកជើង រដ្ឋាភិបាលខ្មែរក្រហមមានគោលការណ៍យករបស់ទាំងអស់ដែលសល់ពីជំនាន់លន់ នល់ មកកែច្នៃប្រើ។ ដូច្នេះខ្មែរក្រហមមិនចាំបាច់នាំចូលស្បែកជើងពីបរទេសឡើយ។ ហើយប្រជាជនជាទូទៅ ពាក់ស្បែកជើងធ្វើដោយដៃ គឺធ្វើពីសំបកកង់ឡាន ស្រដៀងនឹងស្បែកជើងសង្រែក ដោយមានចោះរន្ធ៤ ដាក់ខ្សែខាងមុខ២ខ្វែងគ្នា និងត្រង់កែងជើងដាក់ខ្សែ២ទៀតធ្វើពីពោះវៀនកង់ឡាន។ តែក្រោយមកមានប្រើពុម្ពចាក់ស្បែកជើងកៅស៊ូ។

ឯម៉ូតសក់វិញ គឺមនុស្សស្រី (ចាស់, ក្មេង) កាត់សក់ខ្លីរាងការេ មនុស្សប្រុសកាត់សក់ឡុងសុង។

ដូច្នេះការប្រើសម្លៀកបំពាក់នៅជំនាន់នោះដូចជាមានលំនាំប្រហែលនឹងទំនៀមទម្លាប់ខ្មែរតាមស្រុកស្រែចម្ការ ដែលនិយមស្លៀកពាក់ខ្មៅដែរព្រោះយល់ថាពុំសូវប្រឡាក់ ស្រួលបោកសម្អាតផង។

រូបលេខ ១៦៤៖ រោងចក្រតម្បាញភួយ នៅស្ទឹងមានជ័យ។ ប្រហែលថតឆ្នាំ១៩៧៦។ (រូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

Figure 164: Factory for weaving blankets in Stung Mean Chhay, 1976. (Photo: Documentation Center of Cambodia)

He remembered that Khmer Rouge cadres liked to wear red and white checked *krama*, while people in the eastern provinces wore blue and white checked *krama*.

The Khmer Rouge Regime had a policy of recycling and reusing things left over from the Lon Nol Regime. Instead of importing shoes, the Regime introduced shoes handmade from the rubber of tires. These shoes were in the style of *sangraik* shoes with four straps. Later in the Regime, there seem to have been molds used for making rubber shoes. Hair styles during the Khmer Rouge were standardized as well. Women wore their hair cut short in square bob styles while men wore their hair in the *long song* style.

Habits of clothing during the Regime eerily echoed reasons that peasants a hundred years earlier had favored black clothing. Black clothing hid stains and made washing easier.

[1] តាត់សុំមិនប្រាប់ឈ្មោះ។

ត- ស្បែកជើង

តាមតំបន់ខ្លះ គេហៅស្បែកជើង ខ្លះហៅទ្រនាប់ជើង។ ចំពោះអ្នកស្រែចម្ការច្រើនដើរផ្ដោលនឹងដី ធ្វើឲ្យស្បែកជើងឡើងក្រាស់ហើយក្រិន។ នៅក្នុងស្រុកខ្មែរ បើនិយាយពី ស្បែកជើង គឺជារបស់មួយទើបតែឃើញមានប្រើនៅសតវត្សទី១៩-២០នេះ។ បើមើលតាមរូបចម្លាក់បុរាណមិនឃើញមានពាក់ស្បែកជើងឡើយ។ ម្យ៉ាងទៀតតាមឯកសាររបស់លោកជីវ តាកូវ៉ាន់ ក៏បានសរសេរដែរថា ខ្មែរដើរដោយជើងទទេ។ នៅពេលបារាំងចូលមកមានប្រើស្បែកជើងយុប ខ្លៀរ ជាពិសេសក្នុងមជ្ឈដ្ឋានអ្នកធ្វើការជិត

Shoes

It was only in the late 19th and early 20th century that wearing shoes became a habit in the region today known as Cambodia. Most ancient sculptures and reliefs depict people as going barefoot, and the 13th century Chinese traveler, Chou Ta-Kuan, noted that the Khmer walked barefoot without shoes. With the establishment of the French Protectorate, European style dress shoes began to be introduced. It was particularly in the Royal Palace, among officials working with the French, that shoes began to be worn.

រូបលេខ ១៦៥៖ រូបធ្នាំកាំង ក្នុងកាតប៉ូស្តាល់ រាង់ឆ្នាំ១៩០០។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 165: Palace Guards pictured in a postcard around 1900. (Photo: National Archives of Cambodia)



រូបលេខ ១៦៦៖ ប្រកាសចែកស្រោមជើង, ដកស្រង់ពីកាសែតកម្ពុជា លេខ៤៥៤ ចុះថ្ងៃទី១៧ តុលា ១៩៤៦។

Figure 166: An advertisement for socks. *Kampuchea*, #454, October 17, 1946.

ចាកាំង និងព្រះមហាក្សត្រ។ ស្បែកជើងឈូប ខ្វៀរ ធ្វើ
នៅអឺរ៉ុបគឺតម្រូវអាកាសធាតុស្រុកគេ ទើបគេពាក់
ស្បែកជើងដោយមានស្រោមជើងផង (អឺរ៉ុបភាគ
ច្រើនធាតុអាកាសត្រជាក់)។ តែនៅស្រុកខ្មែរ ការ
ពាក់ស្បែកជើងផ្សេងពីគេទៅវិញ។ អ្នកនៅទីក្រុង មុន
ដំបូងពាក់ស្បែកជើងគ្រាន់តែពាក់តាមគេប៉ុណ្ណោះ
ដោយយល់ថាស្អាត ហើយទាន់សម័យច្រើនជា
ប្រភេទស្បែកជើងដែលនាំចូលពីបរទេស។ ចំពោះអ្នក
នៅស្រុកស្រែចម្ការវិញ គឺពាក់ដើម្បីការពារជើង
ហើយច្រើនជាប្រភេទស្បែកជើងដែលធ្វើពីដើមឈើ
ស្រាលៗ (ដើមគ, ដើមរលួស, គាវត្នោតជាដើម)
ធ្វើបានស្បែកជើង ហើយយកវល្លិ, ខ្សែកាតាបចាស់ៗ

Those who considered themselves fashionable or *civilisé* [a term used locally to define one's own refinement according to French standards] wore shoes imported from abroad which at first were mostly *clup kwear* shoes [men's dress shoes]. These shoes were worn with socks, thus importing habits from cooler climates. In the late 19th century Cambodian context, wearing shoes was perceived as unusual. Urban dwellers increasingly wore imported shoes, considering them beautiful and fashionable. People in the countryside began wearing shoes to protect their feet and to make walking easier. Since they did not have money to buy imported

រូបលេខ ១៦៧៖ ស្ត្រីពកក្មេងអត់ពាក់ស្បែកជើង។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 167: Young mother and baby. Photographed in the early 1900s.
(Photo: National Archives of Cambodia)

រូបលេខ ១៦៨៖ ពេលធ្វើដំណើរស្មានពាក់ស្បែកជើងទេ។ រូបគំនូរ
លើជញ្ជាំងវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០។
ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 168: Barefooted travelers, as depicted on the walls of Wat Kompong Tralach Leu, early 20th century.
(Photo: Reyum)

ឬកៅស៊ូកង់ មកធ្វើជារៀ។ ខ្លះធ្វើខ្លួនឯង ខ្លះទៀតទិញពីពួកចិន យួនធ្វើលក់។ ភាគច្រើនមនុស្សដែលមានវ័យចំណាស់ទើបពាក់ស្បែកជើងនេះ គេតែងហៅថា ស្បែកជើងស៊ក, ស្បែកជើងចម្ការ, ស្បែកជើងសង្រែក (រូបលេខ១៦៥–១៣១)។

លោកយាយស៊ីម សារិន អាយុ៧៩ឆ្នាំ នៅខេត្តព្រៃវែង និយាយថា "ពីដើម គេពាក់ស្បែកជើងក្រាស់ ពេលឈ្លោះគ្នា ច្រើនយកស្បែកជើងវ៉ៃគ្នាបែកក្បាល ដល់អញ្ចឹង គេលែងឲ្យពាក់។ ក្រោយមកទើបមានស្បែកជើងផ្ចាត់។ ពេលទៅស្រែ ខ្ញុំដើរជើងទទេ ដល់ពេលទៅបុណ្យបានពាក់ស្បែកជើង"។

ស្បែកជើងផ្ចាត់, ស្បែកជើងជីបតុង ទើបតែមានប្រើចាប់ពីសម័យខ្មែរបានទទួលឯករាជ្យ មានបង្កើតជារោងចក្រធ្វើស្បែកជើងអំពីកៅស៊ូ។ ចំពោះពាក្យថាស្បែកជើងផ្ចាត់ គឺជាពាក្យអ្នកស្រុកនិយមហៅ ប្រហែលដោយសារស្បែកជើងនេះនៅពេលពាក់ដើរទៅវារលាស់ និងមានផ្ចាត់ធូលីឡើងផង។ ចំណែកស្បែកជើងជីបតុង បើតាមស្មានប្រហែលហៅតាមឈ្មោះរបស់សហគ្រាសធ្វើស្បែកជើងជីបតុងដែលគេបង្កើតឡើងនៅសម័យសង្គមរាស្ត្រនិយម ហើយមានគុណភាពល្អផង។ បច្ចុប្បន្ន បើគេនិយាយពីស្បែកជើងជីបតុង ឬស្បែកជើងផ្ចាត់ គឺសំដៅលើស្បែកជើងធ្វើពីកៅស៊ូមានខ្សែរាងជាចម្ការ។

ចាស់ៗនិយាយប្រាប់ថា នៅជំនាន់ឪពុកម្តាយគាត់ មិនធ្លាប់មានពាក់ស្បែកជើងឡើយ លុះដល់

shoes, villagers began making their own shoes. They used light types of wood (*ko* and *roluos* wood and palm fronds) for the soles of the shoes, fashioning straps out of vine or strips of old canvas or rubber to hold the shoes to their feet. Mostly it was elderly adults who wore this kind of shoe, which was called the *soak* (to insert) shoe, the *chompeam* (forked stick) shoe, or the *sangraik* (a hanging basket carrier) shoe. Sim Saren, 79 years old living in Prey Veng Province, told us, "Before, they wore thick shoes. When there were fights, they would use their shoes to hit each other on the head. So they stopped wearing thick shoes. Afterwards there were thinner thongs. When I went to the fields, I still went barefoot. When I went to ceremonies, I wore shoes."

Thongs (*ptoat* shoe or *jip tong* shoe) appeared in the period after independence when a factory making shoes out of rubber was established. The name *ptoat* is a popular term for these shoes which make a slapping sound and kick up dust as one walks. The name *jip tong* seems to have come from the name of the company producing high quality thongs during the Sangkum Reastr Niyum Period. Today they still call rubber thongs *jip tong* shoes even thought the factory no longer produces them.

Our elderly interviewees told us that at the time of their parents, people in the



រូបលេខ ១៦៩៖ ទ្រនាប់ជើងធ្វើពីតាវត្នោត ខ្សែធ្វើពីវល្លិយាវ សម្រាប់ពាក់ចូលព្រៃ និងនៅផ្ទះ។ ធ្វើដោយលោកតាអឿន ខ្ញិញ ខេត្តសៀមរាប ឆ្នាំ២០០៣។ (រូបថត៖ រៃយំ)

Figure 169: Simple shoes: the bottom of the shoe is made of palm tree bark while the straps are made from vine. Made in 2003 by Oeun Klainh, Siem Reap Province. (Photo: Reyum)



រូបលេខ ១៧០៖ ទ្រនាប់ជើងស៊ីកនេះពាក់បានទាំងប្រុសទាំងស្រី ធ្វើពីដើមល្វេស ខ្សែធ្វើពីពោះវៀនកង់ឡាន ឬអាចធ្វើពីសំបកកង់ក៏បាន។ ធ្វើដោយលោកតាអឿន ខ្ញិញ ខេត្តសៀមរាប ឆ្នាំ២០០៣។ (រូបថត៖ រៃយំ)

Figure 170: *Soak* (or insert) shoes which can be worn by both men and women. The bottoms are made of *roluos* wood and the strap is made from tire rubber. Made in 2003 by Oeun Klainh, Siem Reap Province. (Photo: Reyum)

ឃើញមានអ្នកពាក់ម្នាក់ ឬពីរនាក់នៅក្នុងភូមិធ្វើឲ្យគេពេបជ្រាយខ្លះដែរ ពិសេសគេយល់ថា ធ្វើអីខុសប្លែកតែម្នាក់ឯង។ បើតាមលោកយាយអ៊ុង សុក អាយុ៨០ ឆ្នាំ នៅខេត្តកណ្តាល និយាយថា "តាំងពីយាយកើតមកមិនដែលឃើញម្តាយឪពុកពាក់ស្បែកជើងឡើយ នៅពេលមាននរណាម្នាក់ពាក់ ម្តាយយាយពេបជ្រាយឲ្យគេហើយ។ អ្នកស្រុកភូមិរបស់យាយក៏មិនពាក់ដែរ។ រហូតដល់យាយពេញវ័យ ទើបឃើញឪពុកយាយពាក់ស្បែកជើងធ្វើពីក្តារមានដាក់ខ្សែចម្តាមសម្រាប់ពាក់ទៅតាប់អុសក្នុងព្រៃ។ តែពេលនោះម្តាយយាយក៏នៅតែមិនពាក់ដដែល។ ចំណែកយាយមិនពាក់ស្បែកជើងទេពីមុន (មុនទសវត្ស១៩៧០)



រូបលេខ ១៧១៖ ទ្រនាប់ជើងស៊ីកធ្វើពីដើមល្វេស ខ្សែធ្វើពីខ្សែកាតាបទ័ន្តង់។ ស្បែកជើងនេះមិនសម្គាល់ឆ្វេងស្តាំឡើយ ធ្វើដោយលោកតាសួន នៅខេត្តកណ្តាល ឆ្នាំ២០០៣។ (រូបថត៖ រៃយំ)

Figure 171: The base of these *soak* shoes is made from *roluos* wood and the strap is made from an old nylon bag. The shoes are identical with no right or left shoe. Made in 2003 by Sgnuon, Kandal Province. (Photo: Reyum)

ទើបជើងយាយឡើងបែកក្រហែងមានធូតាដូចគេយកកាំបិតមកអារ ហើយស្បែកឡើងក្រិនអស់ តែមិនឈឺទេ ព្រោះធ្លាប់ទៅហើយ។ រហូតដល់ឆ្នាំ១៩៧០ គេមានស្បែកជើងជីបតុងច្រើនទើបយាយចេះពាក់តាមគេ។ តែបច្ចុប្បន្ន បើត្រូវដើរទៅឆ្ងាយ មិនពាក់ស្បែកជើងទេ គឺដើរទៅមិនរួច ព្រោះតែធ្លាប់ពាក់"។ ចំណែកលោកយាយម៉ី យោង អាយុ៧២ឆ្នាំ នៅខេត្តកំពង់ចាម និយាយថា "ពេលទៅចម្ការអត់មានពាក់ស្បែកជើងទេ ដោយសារត្រូសារក្រគ្មានលុយទិញ។ ខ្ញុំចេះពាក់ស្បែកជើងឆ្នាំ១៩៥៥ ពេលកូនខ្ញុំការ។ ពីដើមគេមានពាក់ដែរ តែធ្វើពីគារវត្តោត"។

និយាយពីស្បែកជើង ចំពោះមន្ត្រីរាជការ គេយល់ថាស្អាត ទើបគេពាក់តាមចាំង តែបើចំពោះអ្នកស្រែវិញ ដោយឃើញមានគេពាក់ច្រើន ក៏មានទម្លាប់ពាក់ដែរ តែមានអ្នកខ្លះនៅតែមិនទម្លាប់ពាក់រហូតដល់សព្វថ្ងៃ។ លោកយាយកែ រឿង អាយុ៧៨ឆ្នាំ នៅខេត្តកណ្តាល និយាយថា "កាលពីមុនខ្ញុំមិនដែលពាក់ស្បែកជើងទេ គឺដើរដោយជើងទទេឡើងក្រាំងអស់ហើយរហូតលែងឈឺជើង។ លុះដល់បងខ្ញុំរៀបការ ទើបខ្ញុំមានស្បែកជើងពាក់ ដោយសារបងថ្លៃស្រីជាអ្នកទាន់សម័យបានទិញកាបូប និងស្បែកជើងឲ្យខ្ញុំពាក់ឲ្យស្អាត សម្រាប់ហែទានវស្សា។ ពេលនោះបងប្រុសខ្ញុំថា យី! ឯងឡើងកាបូប ស្បែកជើងអីដែរ។ អត់បានទេ! គឺចង់បង្ហាប់ខ្ញុំកុំឲ្យពាក់ស្បែកជើងព្រោះដូចជាអាក្រក់មើល ហើយប្លែកខុសពីគេ"។

countryside were not used to wearing shoes. When one or two people in the village started to wear shoes, others saw them and recognised them as unusual, causing the wearer to stand out. Ong Sok, 80 years old living in Kandal Province, told us, "When I was little, I never saw my mother or father wear shoes at all. When someone wore shoes, my mother would stare and criticize them. People in our village didn't wear them. Only when I was grown up did I see my father wearing shoes made from wood with a forked string [or *chompeam* holding the shoes to the feet between the big toe] to go and cut firewood in the forest. Even then my mother still did not wear shoes. I didn't wear shoes either [before the 1970s]. My feet were covered with fissures and crevices as if cut with a knife. They didn't hurt though, since I was used to walking barefoot. Only in the 1970s, when there were lots of *jip tong* shoes did I start to wear them, following the others. Today, if I have to walk far and don't wear shoes, I can't do it any longer because I have become used to wearing shoes!" Mai Yaung, 72 years old living in Kompong Cham Province, told us, "When we went to the fields, we didn't wear shoes because we were poor and didn't have money to buy them. I wore shoes in 1955 when my child got married. Before that, I had worn shoes too but they were made of palm frond."

លោកតាស្នួន អាយុ៧៨ឆ្នាំ នៅខេត្តកណ្តាល និយាយថា "តាំងពីខ្ញុំដឹងក្តីមក ខ្ញុំឃើញគេមានពាក់ស្បែកជើងឈើហ្នឹងហើយ ខ្ញុំផ្ទាល់ក៏ធ្លាប់ប្រើកាលពីនៅក្មេងដែរ។ ប៉ុន្តែសម្រាប់ពាក់នៅផ្ទះ នៅពេលដើរធ្លាយខ្ញុំមិនដែលពាក់ឡើយ ព្រោះស្បែកជើងនោះធ្ងន់ ហើយពាក់ទៅឈឺជើងទៀតផង។ ពេលខ្ញុំអាយុ១៦-១៧ឆ្នាំ ខ្ញុំទៅភ្នំពេញ នៅពេលយប់ឮសូរតែសំឡេងស្បែកជើងដើរក្រិចក្រកៗតាមថ្នល់។ ព្រោះស្បែកជើងទាំងនោះសុទ្ធតែធ្វើពីឈើ ហើយក្រាស់។ ឃើញមានពួកយួនរ៉ៅធ្វើស្បែកជើង និងជួសជុល (ផ្ងាស់ខ្សែ និងប្តូរបាតស្បែកជើង) នៅតាមចិញ្ចើមថ្នល់ និងមានហាងគេផ្សេងក៏មានធ្វើស្បែកជើងដែរ ប៉ុន្តែធ្វើតែស្បែកជើងទាន់សម័យ។ ប្រហែលជានៅទសវត្សរ៍ ១៩៥០ គេចាប់ផ្តើមលែងពាក់ស្បែកជើងធ្វើពីឈើ ព្រោះមានកោងចក្រធ្វើស្បែកជើងពីកៅស៊ូទន់ស្រាល



រូបលេខ ១៧២៖ ហាងធ្វើស្បែកជើងសម័យ យីហោ "មាស សារ៉ែត" ដកស្រង់ពីកាសែតកម្ពុជា លេខ៤៧៣ ចុះថ្ងៃទី១៦·ខែ១១·១៩៤៦។

Figure 172: The shoe shop of Meas Saraet *Kampuchea*, #473, November 16, 1946.

Today, there are still a few old people in the countryside who walk barefoot, keeping to the traditional way of not wearing shoes.

Kai Rueng, 74 years old living in Kandal Province, told us, "Earlier I didn't wear shoes. I walked barefoot and my feet became so callused that they didn't hurt anymore. When my older brother married, then I had shoes to wear because my sister-in-law was fashionable and bought me a purse and shoes to wear. My brother said, 'Yi! Now you have a purse and shoes! That's not right!' He didn't want me to wear them because he thought they were ugly and it made me look different from everyone else."

According to Sgnuon, 78 years old living in Kandal Province, "From the very beginning, I saw them wearing those wooden

រូបលេខ ១៧៣៖ សហគ្រាសជីបតុង ធ្វើស្បែកជើងផ្ទាត់។ ដកស្រង់ពីសៀវភៅអនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជា ទស្សាហកម្ម ឆ្នាំ១៩៥៥-៦៩។

Figure 173: The Jip Tong Shoe Factory. (Photo: *Photos-Souvenirs du Cambodge Sangkum Reastr Niyum 1955-1969, Urbanisme & Tourisme.*)

រូបលេខ ១៧៤៖ សហគ្រាសជើងតុង។ ដកស្រង់ពីសៀវភៅ អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជា ខុសប្លែកគ្នា ឆ្នាំ១៩៥៥–៦៩។

Figure 174: The Jip Tong Shoe Factory.
(Photo: *Photos-Souvenirs du Cambodge Sangkum Reastr Niyum 1955-1969, Urbanisme & Tourisme.*)

មានតម្លៃល្មម ងាយស្រួលពាក់មិនឈឺជើងផង។ ប៉ុន្តែមានចាស់ៗខ្លះនៅតែពាក់ស្បែកជើងឈើនៅផ្ទះ ឬទៅផ្សារខ្លះដែរ"។ នៅពាក់កណ្តាលសតវត្សទី២០ មានហាងទាន់សម័យខ្លះបានបើក ដូចជាហាងមាសសាវ៉ាតជាដើម (រូបលេខ១៧៦) ធ្វើតែស្បែកជើងទាន់សម័យ។ នេះមិនមែនមានអ្នកទូទៅចេះតែមានលទ្ធភាពទិញនោះទេ គឺច្រើនជាអ្នកធូរធារពិសេសអ្នកនៅទីក្រុង។ បើអ្នកនៅជនបទតេមានលទ្ធភាពទិញ សម្រាប់ពាក់ក្នុងឱកាសបុណ្យទានម្តងម្កាលតែប៉ុណ្ណោះ។ ឯពេលនៅផ្ទះ តេច្រើនធ្វើដោយខ្លួនឯង។

នៅពាក់កណ្តាលទសវត្ស១៩៥០ មានបង្កើតរោងចក្រធ្វើស្បែកជើង ដូចជារោងចក្រគីម ឆៃហាង នៅចាក់អង្រែលើ, រោងចក្រស្បែកជើងជីបតុង នៅទួលគោក (រូបលេខ១៧៣–១៧៤) និងមានហាងធ្វើស្បែកជើងខ្លះទៀតកាន់តែច្រើនឡើង។ ហេតុនេះទើប

shoes already. I wore them myself when I was little. They were for wearing in the house, not for walking long distances since those wooden shoes were heavy and made your feet hurt. When I was 16 or 17, I went to Phnom Penh, and at night all you could hear was the slap of shoes along the road because everyone's shoes were the thick wooden kind. I saw Vietnamese making and repairing shoes along the roadside (changing straps and soles). There were stores making shoes too, but they only made modern and fashionable shoes. Maybe in the 1950s, they began to stop wearing the shoes made from wood because at that time there started to be a factory that made shoes from rubber which were light, cheap, easier to wear, and didn't hurt your feet. Some elderly people still wore the wooden shoes at home though, or to go to the market too." It seems that by the middle of the 20th century, some stores had opened which made and sold modern fashionable shoes. Not everyone had the opportunity to buy these shoes however, and it was mostly wealthy city dwellers who patronized them. Those in the countryside who were poor made their own shoes to wear at home; if they could afford it, they bought one pair of store-made shoes for ceremonies and special events as well as for long trips. In the mid-1950s, several shoe factories opened such as the Kem Chay Heng in Chak Angre Leu and the Jip Tong Factory in

ការពាក់ស្បែកជើងទៅជាទម្លាប់ធម្មតា។ មកដល់ទសវត្ស១៩៦០ ស្បែកជើង ឬទ្រនាប់ជើង ជាពិសេសស្បែកជើងផ្ដាត់មានប្រើស្ទើរតែទូទៅក្នុងប្រទេស (រូបលេខ១៧៥) និងមានការផ្សាយពាណិជ្ជកម្មលក់ជាទូទៅកាន់តែសម្បូណ៌ និងមានច្រើនប្រភេទ (រូបលេខ១៧៦-១៧៧)។ ឯស្បែកជើងឃុប ខ្វៀរឬតែងចោទមានតែក្នុងទីក្រុងដែលនិយម។ គួរឲ្យចាប់

Tuol Kork (figures 173-74). More and more shoe shops opened as well. By the 1960s, many kinds of rubber shoes were being manufactured in Cambodia and wearing shoes had become a habit. Shoe advertisements had become commonplace as well. European style dress shoes remained popular in the cities. Today if someone does not wear shoes, particularly in the city, they are regarded as

រូបលេខ ១៧៥៖ កាវ៉ង់ក្នុងពិធីរៀបការមួយ នៅខេត្តកំពង់ធំ ថតទសវត្ស១៩៦០។ (រូបថត៖ លោកម៉ៃខឺល វិកទ័រ)

Figure 175: Dancing at a wedding in Kompong Thom Province, 1960. (Photo: Dr. Michael Vickery)

អារម្មណ៍បច្ចុប្បន្ន អ្នកមិនចេះពាក់ស្បែកជើង គឺជារឿងមួយប្លែកសម្រាប់អ្នកនៅទីក្រុង។ មកទីក្រុងបើមិនពាក់ស្បែកជើង គេតិតថាជាអ្នកមកពីខេត្ត ឬហៅថាអ្នកស្រែ។ ផ្ទុយទៅវិញ ពីមុនអ្នកដែលពាក់ស្បែកជើង គឺគេសើច និងរិះគន់ទៀតផង។

strange and will be called a peasant, or someone from the provinces. This ironically is precisely the opposite from a little more than one hundred years ago when those wearing shoes were laughed at and criticised.



រូបលេខ ១៧៦៖ ស្បែកជើងផ្ចាត់សញ្ញារូបរទេះសេះ។ ដកស្រង់ពីទស្សនាវដ្តីអ្នកជាតិនិយម, ចុះថ្ងៃទី ១៦ ខែ៥·ឆ្នាំ១៩៦០។

Figure 176: Advertisement for the Horse Cart brand of rubber thongs.
The Nationalist, May 16, 1960.

រូបលេខ ១៧៧៖ ស្បែកជើងកៅស៊ូសញ្ញាយន្តហោះ។ ដកស្រង់ពីទស្សនាវដ្តីអ្នកជាតិនិយម, ចុះថ្ងៃទី២៧·ខែ១១ ឆ្នាំ១៩៦០។

Figure 177: An advertisement for rubber shoes of the Airplane brand.
The Nationalist, November 11, 1960.

ប្រភេទក្រណាត់ប្រក្នង់ស្រុក

TYPES OF CLOTH

ពាក្យ "ក្រណាត់" ដែលខ្មែរប្រើបច្ចុប្បន្ន ប្រហែលនិយាយកាត់មកពីពាក្យ "កំណាត់" ប៉ុន្តែយើងមិនបានដឹងច្បាស់ថា ចាប់ផ្តើមមានប្រើតាំងពីពេលណានោះទេ។ នៅមុនទសវត្ស១៩៧០ យើញមានប្រើតែពាក្យ "កំណាត់" និងពាក្យ "សំពត់"។ នៅក្នុងវចនានុក្រមខ្មែរបស់សម្តេចជួន ណាត ចោះពុម្ពឆ្នាំ ១៩៦៧ យើងពុំប្រទះយើញមានពាក្យថា "ក្រណាត់" ឡើយ មានតែពាក្យ "កំណាត់" និង "សំពត់"។ ពាក្យ "កំណាត់" គឺអ្វីដែលគេកាត់ ឬដាច់ដាច ដូចជាកំណាត់ឈើ ឫស្សី១កំណាត់ជាដើម។ កំណាត់សំពត់ គឺសំពត់ចាស់ដាច់ដាចសម្រាប់ជូតអ្វី ជាសំពត់ថយថោក ឯសំពត់ថ្មីដែលកាត់ហើយ គេហៅថាសំពត់ ១អាវ, សំពត់១ត្បូង ឬហៅថាសំពត់១ម៉ែត្រ។ ឯពាក្យ "សំពត់" គឺរបស់កើតអំពីការត្បាញដោយអំបោះ ឬសូត្រសម្រាប់ស្លៀកដណ្តប់ជាដើម។ ខ្មែរបច្ចុប្បន្នប្រើពាក្យ "ក្រណាត់" សំដៅលើប្រភេទក្រណាត់សម្រាប់កាត់ជាសម្លៀកបំពាក់។

នៅដើមសតវត្សទី២០ ឬអាចមុននោះទៀត ក្រណាត់ដែលប្រើក្នុងស្រុកមានច្រើនប្រភេទខុសគ្នា មានទាំងក្រណាត់ត្បាញក្នុងស្រុកផង និងក្រណាត់នាំចូលមកពីបរទេសផង។ ក្នុងជំនាន់នោះ ក្រណាត់ដែលគេចូលចិត្តប្រើច្រើនជាងគេគឺ ប្រភេទក្រណាត់ព្រៃ, ទេសឯក, ផាឌិប, ខៀន, និងក្រណាត់សូត្រខ្មែរ។ ប៉ុន្តែមកដល់បច្ចុប្បន្ន ប្រភេទក្រណាត់ខ្លះក៏មាននៅសេសសល់ និងខ្លះទៀតបានបាត់ឈ្មោះ លែងមានអ្នក

The word for cloth in Khmer, *kranat*, perhaps evolved from the word *komnat*, which means piece, portion, or fragment. We do not know when the term *kranat* began to be used widely to mean cloth of all kinds, but in the 1960s, the word was not yet in use and cloth was still called either *komnat* or *sampot*. The 1967-68 Cambodian Dictionary published by the Buddhist Institute does not contain the word *kranat*. This dictionary tells us that the word *komnat* means a piece cut off, detached, torn off, or separated from a larger thing, as in *komnat cheu* [a piece of wood], or *russey muoy komnat* [one piece of bamboo]. *Sampot* is defined as something woven from cotton or silk, and worn as a covering. A *komnat sampot*, however, is described in the dictionary as meaning a rag or piece of cloth torn from an old worn *sampot*. The length of cloth generally used for a piece of clothing is described as *sampot muoy aow* [a length of cloth for one shirt], *sampot muoy tbong* [a length of cloth of a certain measure] or *sampot muoy metre* [one meter of cloth]. Today the Khmer use the word *kranat* to describe all kinds of cloth before it is cut into the lengths required for various kinds of clothing. In current usage, the word *sampot* seems to refer to a particular length of cloth needed for a specific type of garment.

There were many types of cloth with various colors and patterns that were used to make clothing during the early 20th century in the region today known as Cambodia. There were types of cloth woven in the country and types of cloth imported from abroad.

ស្គាល់ទៅហើយ។ ក្នុងដំពូកនេះយើងលើកយកតែប្រភេទក្រណាត់មួយចំនួនដែលមនុស្សចាស់ធ្លាប់ស្គាល់ និងធ្លាប់ប្រើជាសម្លៀកបំពាក់ពីនៅវ័យក្មេង។

ក- ប្រភេទព្រៃ

ព្រៃជាប្រភេទក្រណាត់មរ៉ាងមានសាច់រលោង ហើយរអិល។ ត្បាញពីសរសៃសូត្រសុទ្ធ មានប្រភេទសាច់លាត និងផ្ការ។ ព្រៃមានច្រើនយ៉ាង អាស្រ័យលើគុណភាពនៃសាច់ក្រណាត់ ពណ៌ និងការចនានៅលើផ្ទៃក្រណាត់។ ក្នុងនោះមានប្រភេទព្រៃឡា, ព្រៃឡាញ់, ព្រៃលាត (ព្រៃខ្មែរ), ព្រៃមុយអា, ព្រៃកាំទ្រីជាដើម។

ព្រៃឡា

ជាព្រៃមានសាច់រហោកា មកពីប្រទេសចិន ជាប្រភេទក្រណាត់ស្តើងទន់ ត្រជាក់ ហើយមានគ្រប់ពណ៌។ ចំពោះពណ៌សដែលនាំចូលមកស្រុកខ្មែរ គេនិយមយកទៅជ្រលក់ផ្ទៃខ្លួញ (ផ្ទៃមក្លឺ) ឲ្យទៅជាពណ៌ខ្មៅ ដើម្បីកាត់ជាសម្លៀកបំពាក់ពេលធ្វើការងារប្រចាំថ្ងៃ និងប្រើព្រៃពណ៌ ពេលបុណ្យទានឬមង្គលការ។ លោកយាយជូ សារឿន អាយុ៧៧ឆ្នាំ នៅខេត្តព្រៃវែង និយាយថា "ព្រៃឡាមានលក់មុនព្រៃមុយអា បើគិតពីតម្លៃព្រៃឡាជាប្រភេទថ្នាក់កណ្តាល (គុណភាព) បើប្រៀបជាមួយព្រៃមុយអានិងព្រៃឡាញ់"។

The most popular types of cloth used in those days were types of *prai*, *des aik*, *pa dip*, *kien* and Khmer silks. Some of these types of cloth are still used today, while others of them are now being forgotten because they are no longer used. Here we simply describe some types of cloth that our elderly interviewees remember and have used to make clothing when they were little.

1. *Prai*

Prai is a type of smooth, slippery cloth that is woven from pure silk. It can be plain or patterned. There are different names for the various kinds of *prai* which differ in terms of quality, color, or pattern. Here we briefly describe *prai lau*, *prai lahn*, *prai leat* (or *prai khmer*), *prai muy a*, and *prai kam dru*.

Prai lau

Prai lau was a type of silk cloth with a loose weave which was imported from China. It was a thin soft cloth which was cool to wear and which came in all different colors. The white plain *prai* which was imported into Cambodia during the Protectorate was generally taken and dyed black using *mcleur* dye. This black fabric was then used to make everyday work clothes. Colored *prai lau* was used to make clothes for wearing to ceremonies and weddings. According to Ju Saroeun, 77 years old living in Prey Veng

ព្រៃឡាញ់

ជាប្រភេទព្រៃធ្វើពីសូត្រមានគ្រប់ពណ៌ ហើយស្តើង។ បើតាមវចនានុក្រមរបស់សម្តេចជួន ណាត ពន្យល់ថា តាមភាសាយួនហៅឡាន់ "Lanh" មានន័យថា "ត្រជាក់" ជាឈ្មោះព្រៃយួនមានសាច់ជិតម៉ដ្ឋ រលើប។ ព្រៃឡាញ់មានប្រភេទលាតនិងផ្កា គេចូលចិត្តយកទៅកាត់ជាសំពត់ ខោ ឬអាវ តាមការនិយមរបស់គេម្នាក់ៗ។ ព្រៃឡាញ់ធូរថ្លៃជាងប្រភេទព្រៃផ្សេងទៀតដែលនាំមកពីបរទេស។ គេចូលចិត្តស្លៀកក្រណាត់ព្រៃនេះដោយសារត្រជាក់ ហើយថោកសមល្មម ភាគច្រើនគេមានលទ្ធភាពទិញស្លៀកពាក់បាន។ មនុស្សប្រុសច្រើនយកទៅកាត់ខោថ្នេរ៣ ឬខោថ្នេរ៥ ដែលគេនិយមហៅថា "ខោឡាញ់"។ ឯមនុស្សស្រីច្រើនយកទៅកាត់អាវបំពង់វែង ឬស្លៀកជាសម្ពត់។ អ្នកមានលទ្ធភាពខ្លះ ប្រើព្រៃឡាញ់ពណ៌ខ្មៅ (ជ្រលក់ផ្ទៃខ្លួញ) សម្រាប់ស្លៀកពាក់ប្រចាំថ្ងៃ ហើយប្រើព្រៃពណ៌ពេលមានពិធីបុណ្យ ឬរៀបមង្គលការ។

ព្រៃលាត ឬព្រៃខ្មែរ

របៀបត្បាញព្រៃលាតស្រដៀងនឹងការត្បាញផាមួងដែរ គឺគេត្បាញពីសូត្រក្បាល (សូត្រយកពីដង្កូវនាង មិនទាន់ស្ងោរ និងជ្រលក់ល័ក្ត)។ ព្រៃលាតមានវង់ជើងទឹកមាសបីជួរ ផ្ទៃក្រណាត់លាត។ ច្រើនមានត្បាញនៅស្រុកកោះធំ និងស្វាយមេ។ ចំពោះគុណភាព និងតម្លៃ ប្រហាក់ប្រហែលនឹងព្រៃឡាញ់មក

Province, "*Prai lau* was sold in Cambodia before *prai muy a* became available in the markets. *Prai lau* was considered of medium quality and price when compared to *prai muy a* and *prai lahn*."

Prai lahn

Prai lahn was another kind of thin silk cloth which came in all different colors. According to the 1967-68 Cambodian Dictionary published by the Buddhist Institute, the word *lahn* means cool in Vietnamese; this Dictionary tells us that *prai lahn* was a kind of Vietnamese *prai* that was finely woven, smooth, and shiny. *Prai lahn* was available in plain colors as well as patterns, and people made *sampot*, pants, and shirts out of it. *Prai lahn* was cheaper than other kinds of *prai* imported into the country. Because *prai lahn* was cool to wear and affordable, the average Cambodian during the late Protectorate could buy it to make clothing to wear. Men usually used it to make three or five seam pants which they liked to called *lahn* pants, while women mostly used *prai lahn* to make long tube shirts. As with *prai lau*, *prai lahn* was dyed black using *mcleur* dye; the dyed cloth was used for making everyday working clothes. Colored and patterned *prai lahn* were used for making special clothing for ceremonies and weddings.

Prai leat

Prai leat (or *prai khmer*) was woven from silk that was not boiled or dyed before

ពីវៀតណាម តែថោកជាង៣ដងបើប្រៀបធៀបជាមួយប្រភេទព្រៃមុយអា (តម្លៃគិតក្នុងទសវត្ស១៩៣០ អាចប្រែប្រួលនៅពេលក្រោយមក)។ អ្នកមានជីវភាពមិនសូវធូរធារអាចទិញព្រៃខ្មែរស្អិតពាក់ពេលបុណ្យទាន ឬមង្គលការ។ សព្វថ្ងៃពុំយើញមានគ្បាញប្រភេទព្រៃនេះទៀតឡើយ។ យើងពុំបានដឹងមូលហេតុយ៉ាងណានោះទេ តែយើងគ្រាន់តែស្មានថាគេឈប់គ្បាញព្រៃនេះបន្តិចម្តងៗទំនងជាចាប់ពីពេលកើតមានរោងចក្រគ្បាញព្រៃនាសម័យសង្គមរាស្ត្រនិយមនោះហើយ។ គួរកត់សម្គាល់ថា ការបាត់បង់ការគ្បាញជាលក្ខណៈគ្រួសារក្នុងស្រុកបន្តិចម្តងៗ ឬក៏លែងសូវមានការនិយម ដោយសារបច្ចេកទេសឧស្សាហកម្មផលិតក្រណាត់ក្នុងពិភពលោកកាន់តែរីកចម្រើន មាននាំចូលគ្រប់ប្រភេទក្រណាត់មកពីបរទេសកាន់តែច្រើនឡើងៗ ហើយមានតម្លៃថោកជាងក្រណាត់ក្នុងស្រុក រួមទាំងមានបង្កើតរោងចក្រតម្បាញនៅចុងទសវត្ស១៩៥០មកនោះ ធ្វើឲ្យតម្បាញតាមគ្រួសារមានការថយចុះជាលំដាប់។ សព្វថ្ងៃអ្នកគ្បាញខ្លះរត់ទៅធ្វើការរោងចក្រ ហើយការប្រើប្រភេទក្រណាត់គ្បាញក្នុងស្រុកដូចជា ហូល, ជាមួង, ចរបាប់, អន្ទូញ ។ល។ គ្រាន់តែដើម្បីទៅចូលរួមពិធីផ្សេងៗម្តងម្កាលប៉ុណ្ណោះ។

ព្រៃមុយអា (ឬមួយអា)

ជាប្រភេទព្រៃមានគ្រប់ពណ៌ មានសាច់

weaving. *Prai leat* generally did not have patterns, but its plain white surface had a decorative edge consisting of three gold lines of stitching. *Prai leat* was once woven on the island of Koh Thom and in Lovea Em in Kandal Province. The quality and price of *prai leat* was similar to that of the *prai lahn* imported from Vietnam in the late Protectorate. In those days, *prai leat* was almost three times cheaper than *prai muy a*. People who were quite poor could still afford to buy *prai leat* in order to make special clothing to wear to ceremonies and weddings. Although *prai leat* was once an indigenous cloth woven by the Khmer, today it has almost completely disappeared and we could find no one who is weaving it. We are not sure why this is so, although we note the gradual decline in home weaving throughout the country. The development of industrial weaving technologies led markets of the 20th century to be increasingly flooded with many kinds of imported cloth which were cheaper than cloth woven by hand locally. In the late 1950s, Cambodia established its own domestic factories for weaving cloth, causing a further decline in hand weaving in family settings. Today, some young women, who might have been weavers, instead work in the garment factories. We should not, however, sentimentalise the past by imagining a country once filled with people wearing clothing made of high quality traditional woven cloths such as *pamuong*, *hol*, *cha robab* and *anloin*. Such high quality cloth was always

រលោង ម៉ដ្ឋ ទន់ ហើយក្រាស់។ ពាក្យ "មុយអា" នេះយើងមិនច្បាស់ពីអត្ថន័យយ៉ាងណាឡើយ គឺគ្រាន់តែស្មានថា ខ្មែរហៅតាមភាសាចិន ដែលប្រហែលជាយីហោ ឬជាឈ្មោះសម្រាប់ហៅសម្ពាល់ក្រណាត់ធ្វើពីសូត្រមកពីស្រុកចិន មានគុណភាពល្អលើសព្រៃនានា។ យើងមិនមានប្រភពពិតមានច្បាស់ថា ព្រៃមុយអានាំចូលមកស្រុកខ្មែរតាំងពីពេលណាឡើយ។ បើតាមលោកតាអៀង តិច អាយុ៨៥ឆ្នាំ នៅភ្នំពេញ និយាយថា "ព្រៃមុយអាមានយូរណាស់

considered special, and clothing made from them was worn only for ceremonies, important events, and weddings rather than for everyday wear. With the return of peace to Cambodia, a tourist market has developed for indigenous hand-woven types of cloth, in addition to its local use for making special clothing for ceremonies.

Prai muy a

This is a kind of silk cloth that is smooth, supple, and somewhat thick; *prai*

រូបលេខ ១៧៨៖ សំពត់សម្ពុយព្រៃមុយអា ស្លៀកចូលរួមក្នុងពិធីមង្គលការ ខេត្តកំពង់ធំ ឆ្នាំ១៩៦១។ (រូបថត៖ ម៉ៃខឺល វិកខឺរី)

Figure 178: *Sampot* in the *samloy* style made of *prai muy a*, worn to a wedding in Kompong Thom Province in 1961. (Photo: Dr. Michael Vickery)

រូបលេខ ១៧៩៖ កូនសិស្សថ្នាក់ទី៣ និងទី៤ នៅវិទ្យាល័យកំពង់ធំ ស្លៀកសំពត់ហ្ស៊ីបពីព្រៃមុយអា។ ថតឆ្នាំ១៩៦១-៦២។ (រូបថត៖ ម៉ៃខឺល វិកខឺរី)

Figure 179: Third and fourth level students at the Kompong Thom College wearing *sampot* in the *juppe* style made of *prai muy a*. Photographed 1961-2. (Photo: Dr. Michael Vickery)

ហើយ យាយខ្ញុំគាត់លក់តែក្រណាត់ហ្នឹង"។ ព្រៃមុយអាជាផលិតផលក្រណាត់ល្អលេខ១ មកពីសៀងហៃ ប្រទេសចិន។ ខ្មែរតែងហៅប្រភេទព្រៃនោះថា "មុយអាសៀងហៃ ឬមុយអាស្លឹកឫស្សី" គឺជាព្រៃដែលខ្លះមានសាច់លាត, ខ្លះផ្កា និងខ្លះមានលំអដោយរូបស្លឹកឫស្សី នៅលើផ្ទៃក្រណាត់។ ដូច្នេះហើយទើបមានប្រជាជនខ្មែរខ្លះហៅខោដែលកាត់ពីព្រៃមុយអានេះថា "ខោស្លឹកឫស្សី"។

នៅសម័យចារាំង ព្រៃមុយអាមានតម្លៃលើសព្រៃខ្មែរពាដង។ នៅជំនាន់សង្គមរាស្ត្រនិយម ទោះបីក្នុងស្រុកខ្មែរមានបង្កើតរោងចក្រតម្បាញព្រៃមុយអាឯកជនមួយនៅភ្នំពេញឈ្មោះសេងថៃ ស្ថិតនៅត្រង់ម្តុំតីឡាម៉ែត្រលេខ៦ក៏ដោយ ក៏មិនបានធ្វើឲ្យព្រៃមុយអាចុះតម្លៃថោកដែរ។ ព្រៃមុយអាសៀងហៃដែលមកពីចិន និងព្រៃមុយអាសេងថៃ ធ្វើនៅក្នុងស្រុកនោះមានតម្លៃនិងគុណភាពប្រហាក់ប្រហែលគ្នា។ លោកតាលីវ សាឯម អាយុ៦៧ឆ្នាំ នៅខេត្តតាកែវ និយាយថា "មុយអាសេងថៃ ធ្វើក្នុងស្រុកខ្មែរ និងមុយអាមកពីចិន គេចូលចិត្តប្រើដូចគ្នា។ នៅសង្គមលន់ នល់ មួយសំពត់ស្មើ១ម៉ែត្រ៨តឹកហ្នឹង ថ្លៃ៦០០រៀល"។ ក្នុងអំឡុងដើមសតវត្សទី២០ ព្រៃមុយអាគេច្រើនយកទៅកាត់ អាវបំពង់វែង, អាវម៉ាឡាយូ, ខោថ្នេរ៣, ខោថ្នេរ៩ និងស្បៃកជាសំពត់សម្លៀកដើម។ គេនិយមព្រៃមុយអាពណ៌ខ្មៅជាងព្រៃមុយអាពណ៌។ នៅទសវត្ស១៩៦០ មានកូនសិស្សស្រីៗ

muy a comes in all different colors. The meaning of the word *muy a* is uncertain to us, although perhaps it was a brand name or the Chinese name for such silk cloth, since *prai muy a* was imported from China. *Prai muy a* was considered the highest quality *prai*. We are not sure exactly when *prai muy a* started to be sold in Cambodia. Ieng Tech, 85 years old, told us, "Oh! *Prai muy a*! We had that already for a long time! My grandmother already sold that cloth!" The best *prai muy a* was thought to come from the region of Shanghai, and Cambodians called this cloth *muy a Shanghai*. Others sometimes called the cloth *muy a sluck russey* (*muy a* bamboo leaves) because the cloth was sometimes decorated with a pattern of bamboo leaves. Pants made of *prai muy a* were sometimes called bamboo leaf pants.

During the French Protectorate, *prai muy a* was three times as expensive as *prai leat*. Even after independence, during the Sangkum Reastr Niyum Period when a private factory weaving *prai muy a* was established in Phnom Penh, the price of *prai muy a* did not drop dramatically. The Seng Tai Factory produced *prai muy a* similar in quality and price to that imported from Shanghai. The late Liv Sa Aem told us, "The Seng Tai *prai muy a* made in Cambodia, and the *prai muy a* imported from China was equally popular. In the time of the Lon Nol Regime, a *sampot* one meter and eighty centimeters long cost 600 riel."

និងអ្នកវាជការខ្លះស្លៀកសំពត់ហ្វាប្រែធ្វើពីក្រណាត់ព្រៃមុយអាទៅសាលារៀន និងទៅធ្វើការ។ ក្រណាត់ព្រៃមុយអាលែងមាននាំចូលតាំងពីសម័យខ្មែរក្រហម (ឆ្នាំ១៩៧៥) ហើយរោងចក្រសេងថៃ ដែលត្បាញព្រៃនេះក៏បញ្ឈប់តាំងពីពេលនោះមកដែរ។ សព្វថ្ងៃព្រៃមុយអាដែលមានលក់នៅទីផ្សារជាប្រភេទព្រៃមកពីស្រុកយួនពុំដូចព្រៃមុយអាពីសម័យមុនដែលចាស់ៗធ្លាប់ប្រើនោះឡើយ។ យើងមិនបានដឹងពីមូលហេតុដែលលែងនាំព្រៃប្រភេទនេះចូលមកស្រុកខ្មែរនាពេលបច្ចុប្បន្នទេ។ ប្រហែលដោយសារលែងសូវមានតេនិយម ឬអាចមកពីមានចេញលក់ប្រភេទព្រៃកាំទ្រីច្រើន ហើយមានតម្លៃថោកជាង ឬដោយសារសម្បុរណាប្រភេទក្រណាត់មកពីបរទេស។

ព្រៃកាំទ្រី

ជាព្រៃលាតនិងព្រៃផ្កា នាំមកពីប្រទេសវៀតណាម។ ពាក្យ "កាំទ្រី" នេះប្រហែលជាខ្មែរហៅតាមភាសាវៀតណាម។ ព្រៃកាំទ្រី មានសាច់ជិតស្អ (អាចយកទៅដាក់ទឹកបាន) មានពណ៌ខ្មៅ រលោងក្រាស់ហើយរឹង តែទៅជាទន់ក្រោយពីបានប្រើប្រាស់និងបោកគក់ច្រើនសារ។ ព្រៃកាំទ្រីទើបតែនាំចូលមកក្នុងស្រុកខ្មែរនាសម័យសង្គមកាស្ត្រនិយមប៉ុណ្ណោះ។ ការជ្រលក់ពណ៌ឲ្យខ្មៅយើងមិនបានដឹងច្បាស់ថាជ្រលក់នៅក្នុងស្រុក ឬក៏នាំចូលមកមានពណ៌ខ្មៅស្រាប់នោះទេ។ សព្វថ្ងៃព្រៃកាំទ្រីដែលលក់នៅទីផ្សារ

In the early 20th century, *prai muy a* was used to make long tube shirts, *malayu* shirts, three and five seam pants, as well as *sampot* worn in the *samloy* style. In the countryside, colored *prai muy a* was used only to make clothing for weddings and various ceremonial occasions. City dwellers also used colored *prai muy a* for special ceremonies and weddings. In the 1960s, female students and office workers sometimes wore *sampot* in the *juppe* style made from *prai muy a* to school or work.

Prai muy a seems to have completely disappeared with the coming of the Khmer Rouge Regime when the Seng Tai Factory ceased production. Although today there is a cloth being sold in the markets which they call *prai muy a*, this cloth comes from Vietnam and is different from the *prai muy a* that our elderly interviewees remember. We are not sure why *prai muy a* is no longer being imported from China today. Perhaps tastes have changed, or other types of cheaper *prai* (*kam dru*) became readily available and thus replaced it. Many other kinds of imported cloth are now available in markets, and a lot of readymade clothing in all kinds of styles are imported into the country as well.

Prai kam dru

Prai kam dru is a plain or patterned black cloth similar to *prai muy a*, but imported from Vietnam. The name *kam dru* is perhaps a Vietnamese word which the Khmer became accustomed to using to describe this

មានពណ៌ខ្មៅស្រាប់ មានគុណភាពអន់ជាង និងតម្លៃថោកជាងព្រៃមុយអា។ ម្ល៉ោះហើយមានអ្នកទិញស្លៀកច្រើន។ គេច្រើនយកមកស្លៀកជាសំពត់សម្លុយកាត់ខោថ្នេរ៣ ឬថ្នេរ៥។

លោកតាអៀង តិច ដែលធ្លាប់រកស៊ីលក់ក្រណាត់នៅភ្នំពេញបានឲ្យដឹងថា ប្រភេទព្រៃមុយអាជាព្រៃលេខ១ ទាំងគុណភាព និងតម្លៃ។ ព្រៃឡាចាត់ទុកជាថ្នាក់កណ្តាល បន្ទាប់មកព្រៃឡាញ់មានតម្លៃនិងគុណភាពប្រហាក់ប្រហែលគ្នានឹងព្រៃលាតត្បាញនៅក្នុងស្រុកខ្មែរ។ ព្រៃនាំចូលពីបរទេសមានចម្រុះគ្រប់ពណ៌ ដោយដឹកតាមកប៉ាល់ពីស្រុកចិន និងទូកប៉ុកចាយពីស្រុកយួន មកចតនៅកំពង់ផែភ្នំពេញដើម្បីចោះដុំឲ្យឈ្មួញ ឬមូស់ហាងលក់ក្រណាត់។ អ្នកនៅស្រុកស្រែចម្ការច្រើនស្លៀកពាក់ពណ៌ខ្មៅព្រោះងាយចោកគក់ និងមិនសូវឃើញប្រឡាក់។ ដូច្នេះព្រៃមួយចំនួនត្រូវថោកៗហាងក្រណាត់ធំៗ យកទៅជ្រលក់ឲ្យមានពណ៌ខ្មៅ សម្រាប់បម្រើសេចក្តីត្រូវការនៃអ្នកប្រើប្រាស់។

១- ក្រណាត់សក្តាត

ជាក្រណាត់ដែលមានសាច់ក្រាស់មានច្រើនពណ៌។ តាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត "សក្តាត" គឺដូចទៅនឹងពាក្យសំស្ក្រឹតសម្តាល់ក្រណាត់វិសេសមួយប្រភេទធ្វើពីរោមសត្វមានសាច់

cloth. *Prai kam dru* is so tightly woven that it can hold water. It is smooth, thick, and stiff, almost as if it has been laminated or treated with water repellent. When *prai kam dru* is worn and washed a lot, it becomes soft and supple. *Prai kam dru* began to be imported into Cambodia during the Sangkum Reastr Niyum Period. We are not certain whether the cloth imported at that time was dyed in Cambodia or was already dyed before it entered the country. Today, the *prai kam dru* available in the market is already all black. The quality and price of *prai kam dru* when it began to be imported into Cambodia was lower than that of *prai muy a*, and it became very popular. Ordinary people could afford to buy *prai kam dru* to make *sampot* in the *samloy* style, and three or five seam pants.

According to Ieng Tech, who used to sell cloth in Phnom Penh, *prai muy a* was considered the best quality and most expensive type of *prai* for sale in Cambodia during the late Protectorate. *Prai lau* was considered average quality and price, while *prai lahn* was considered to be the cheapest and lowest quality *prai*, equivalent to *prai leat*, the *prai khmer* woven domestically. *Prai* imported into Cambodia came in many colors and patterns. Cloth came on boats from China, and on merchant transport boats from Vietnam. The boats carrying cloth docked at the port in Phnom Penh in order to deliver their bolts of cloth to traders and store owners. Since most people living in the countryside liked to wear

ក្រាស់ជិត ប្រើធន់ជាងយូរ មានច្រើនបែប។ នៅដើមសតវត្សទី២០ អ្នកមានឋានៈជាមន្ត្រី, នាម៉ឺន, គហបតី ពេលចូលគាល់ព្រះមហាក្សត្រ ឬធ្វើការងារ ភាគច្រើនស្លៀកសំពត់ចង់ក្បិន ពាក់អាវកុតកាត់ពីក្រណាត់សក្ងាត។ លោកយាយជូ សារឿន អាយុ ៧៧ឆ្នាំ និយាយថា "អាវតន្លង់របស់មនុស្សប្រុស គេយកក្រណាត់សក្ងាតកាត់ មានពណ៌ស ពណ៌ខ្មៅ ដែលគេចូលចិត្តប្រើ"។ យើងមិនមានពត៌មានច្រើនស្តីពីប្រភេទក្រណាត់នេះឡើយ ហើយក៏មិនបានដឹងថានាំចូលមកពីណា ឬតាំងពីពេលណានោះដែរ។ អាវពណ៌ស ធ្វើពីក្រណាត់សក្ងាត គេនិយមបំផុតនៅជំនាន់នោះ ជាពិសេសអ្នកធ្វើការរាជការនៅជាប់ជាមួយចាក់ង។

គ- ក្រណាត់សាតាំង

ជាឈ្មោះក្រណាត់មកពីបរទេសមានសាច់រលើបរលោងហើយម៉ដ្ឋ មានពណ៌ផ្សេងៗ ទន់ហើយភ្ញី ធ្វើពីអំបោះខ្សែន ឬសូត្រ។ គេនិយមហៅក្រណាត់សាតាំងថា "ព្រៃសាតាំង" គឺទំនងជាហៅតាមភាសាចាក់ង ព្រោះជាផលិតផលមកពីស្រុកចាក់ង។ គេអាចយកក្រណាត់សាតាំងពណ៌ ទៅតាត់អាវបានត្រប់ប្រភេទ សម្រាប់ពាក់ក្នុងពេលរៀបការ ឬពិធីបុណ្យ។ សព្វថ្ងៃ នៅតែមានគេនិយមយកក្រណាត់នេះទៅតាត់ជាម៉ូតសម្លៀកបំពាក់ផ្សេងៗ។

black clothing, *prai* brought to the port at Phnom Penh was taken by store owners to those who made a business of dying *prai* black using *mcleur* dye.

2. *Saklat*

This is a type of thick cloth which comes in various colors. According to the 1967-68 Buddhist Institute Cambodian Dictionary, *saklat* was derived from a Sanskrit word for a kind of superb cloth made from animal hair which was thick and closely woven. It could be worn for a long time, and came in many different types. At the beginning of the 20th century, government officials of high rank and other dignitaries mostly wore *sampot* tied in the *kben* style with *kut* shirts made of *saklat* cloth when they went to meet the King or to work in their offices. Ju Saroeun told us, "The straight collared *kut* shirt for men was made of white or black *saklat* cloth." We were unable to collect much more information about this type of cloth. We do not know where *saklat* came from, or when it began to be available in the area today known as Cambodia.

3. Satin

Satin is the name for a shiny and smooth fabric, exported from abroad, which

៤- ក្រណាត់ឌេសអ៊ីក

ជាក្រណាត់មួយប្រភេទធ្វើពីអំបោះ មានគ្រប់ពណ៌ ជាប្រភេទលាត និងផ្លា ដែលមានសាច់ម៉ដ្ឋរលោង ហាប់ណែនល្អជាងក្រណាត់ផាឌិប។ តាមចាស់ៗនិយាយថា ក្រណាត់ទេសឯកមានមកពីឥណ្ឌា សៀម វៀតណាមជាដើម។ លោកយាយជូ សារឿន អាយុ៧៧ឆ្នាំ និយាយថា "ទេសឯកូរបបង្គងដូចជាមកពីយួន។ នៅលើក្រណាត់មានបិទផ្លាកក្រដាសរូបបង្គងគុណភាពល្អមិនចាញ់ផាមួងប៉ុន្មានទេ ១ម៉ែត្រ១កាក់៥សេនទៅ២កាក់។ អ្នកមានទេសឯកស្លៀកពាក់ គេថាអ្នកថ្លៃថ្នូរហើយ"។ នៅដើមសតវត្សទី២០ គេយកក្រណាត់ទេសឯកទៅស្លៀកជាសំពត់ចងក្បិន កាត់អាវត្រប់ម៉ូត និងកាត់ខោថ្នេរ៣ ថ្នេរ៥ ។ល។ ចំពោះក្រណាត់ទេសឯកខ្មៅ អ្នកខ្លះហៅថា "ក្រណាត់អ៊ូ" ច្រើនយកធ្វើជាសម្លៀកបំពាក់ប្រចាំថ្ងៃ និងធ្វើស្រែចម្ការ។ ឯទេសឯកពណ៌ ច្រើនស្លៀកពាក់ទៅបុណ្យទានផ្សេងៗ។ លោកយាយមុម សំអឿន អាយុ៧៦ឆ្នាំ និយាយថា "ខ្ញុំច្រើនយកក្រណាត់ទេសឯកផ្លាកាត់ខោអាវតែងយប់ ព្រោះងាយបោកអ៊ុត។ នៅសម័យសង្គមរាស្ត្រនិយម មានការពង្រីកដីដាំកប្បាសច្រើន និងបានបង្កើតរោងចក្រត្បាញក្រណាត់ទេសឯកផ្លានៅខេត្តកំពង់ចាម ហើយបានដាក់ឈ្មោះក្រណាត់នោះថាក្រណាត់សង្គមរាស្ត្រនិយម"។ តែសព្វថ្ងៃនៅក្នុងស្រុកពុំមានផលិតក្រណាត់ទេសឯកទៀតឡើយ គឺពីងលើ

came in many different colors. It was a soft and shiny cloth made from cotton or silk. Cambodians sometimes called it *prai satin*, combining French and Khmer words. Colored satin was used for making shirts to be worn on ceremonial occasions and to weddings. Today, satin is still a popular fabric used to make various clothing in styles fashionable today.

4. *Des Aik*

Des aik is a kind of cotton cloth that comes in all colors and can be plain or patterned. *Des aik* is smooth and more tightly woven than *pa dip*. According to our elderly interviewees, at the beginning of the 20th century, *des aik* was imported from India, Thailand, and Vietnam. Ju Saroeun, 77 years old living in Prey Veng Province, told us, "Shrimp brand *des aik* came from Vietnam and was marked with a white label that had a picture of a shrimp on it. The quality of that cloth was good, almost as good as *pamuong*. One meter of *des aik* cost 1 *kak* (10 centime) 5 *centime*. People who wore *des aik* were considered comfortable, middle class." At the beginning of the 20th century, they generally used *des aik* to make *sampot* tied in the *kben* style, shirts of all types, and three or five seam pants. Black *des aik* was sometimes called *ou* cloth; it was used to make work clothing. Colored *des aik* cloth was generally used to

ការនាំចូលពីបរទេសទាំងស្រុង។ ក្រណាត់ទេសឯក ដូចពីជំនាន់មុននោះក៏គម្រមានដែរ។

ចំណែកទេសឯកពណ៌ក្រហម គេនិយមហៅ "ជាតិ ឬជាតិក្រហម"។ ជាតិក្រហមមិនសំដៅចំពោះតែទេសឯកប៉ុណ្ណោះទេ សូម្បីក្រណាត់ផាឌិបពណ៌ក្រហមក៏គេហៅជាតិដែរ គឺគេហៅសំដៅលើពណ៌ក្រណាត់ច្រើនជាង។ លោកយាយខ្ចត សំអុល អាយុ ៧០ឆ្នាំ និយាយថា "កាលពីខ្ញុំនៅក្មេងបានក្រណាត់ជាតិក្រហមស្លៀកទៅវត្តចាត់ទុកជាល្អលេខ១ ហើយបើអ្នកមាន គេស្លៀកជាមួង ហូល"។ ចំពោះចាស់ៗពីជំនាន់មុនក៏ដូចបច្ចុប្បន្ន តែងយកក្រណាត់ជាតិក្រហមកាត់ជាកូនកន្សែងតូចៗទុកជូតទឹកមាត់ស្លា និងច្រើនប្រើសម្រាប់តចង្អែះសំពត់ ឬខោដែលធ្វើពីព្រៃ ឬសូត្រងាយក្នុងពេលស្លៀកមិនឲ្យអិល។

ជ-កម្ចី

ជាឈ្មោះក្រណាត់ពណ៌ផ្សែងៗ មានរោមខ្លីៗ សាច់ជិតល្អ ហើយក្រាស់ ធ្វើដោយសរសៃសូត្រក៏មាន សរសៃអំបោះក៏មាន មកពីប្រទេសក្រៅ។ យើងមិនសូវដឹងច្បាស់អំពីប្រភេទក្រណាត់នេះឡើយ គ្រាន់តែដឹងថា ក្នុងអំឡុងដើមសតវត្សទី២០ គេច្រើនយកក្រណាត់នេះទៅកាត់អាវដៃខើច ខ្លួនខ្លីត្រឹមត្រគាក រីបកាងសម្រាប់ស្លៀកជាមួយសំពត់ចង់ក្បិនពេលរៀបការ ឬចូលរួមពិធីបុណ្យផ្សែងៗម្តងម្កាល មិនស្លៀក

make clothes for wearing to ceremonies and special occasions. Mom Samuen, 76 years old, told us, "I usually used patterned *des aik* cloth to make pajamas for wearing at night because it was easy to wash and iron. During the Sangkum Reastr Niyum Period, the area of land on which cotton was grown expanded dramatically. A factory producing *des aik* cloth was established in Kompong Cham Province. *Des aik* began to be called Sangkum Reastr Niyum cloth." Today in Cambodia, no *des aik* is produced domestically.

Red *des aik* is called *jeati* or red *jeati*. This term is used not only for *des aik* but also for red *pa dip* cloth as well. Thus we can suppose the term *jeati* designates the color rather than the type of cloth. Khlot Somol, 70 years old, told us, "When I was little, we wore red *jeati* cloth to the temple which we considered the best cloth. Rich people wore *pamuong hol*." Elderly people, both in the old days and today, use *jeati* cloth to make small handkerchiefs for wiping betel juice from their mouths. *Jeati* was also used to make waistbands for *sampot* and pants made of *prai* so that the garment would not slip off the body of the wearer.

5. *Komni*

Komni is a thick cloth, like velour, with small hairs on its tightly woven surface. *Komni* can be made from silk or cotton. It is imported from abroad, but we are not sure of

ជាញឹកញាប់ ឬប្រចាំថ្ងៃឡើយ។ នៅសម័យសង្គម
កស្ត្រនិយម និងលន់ នល់ អ្នកខ្លះពិសេសអ្នកទីក្រុង
យកអាវដៃលធ្វើពីក្រណាត់កម្ទីទៅប៉ាក់រចនាផ្កាភ្ជី
បន្ថែមទៀត ដើម្បីឲ្យកាន់តែស្អាតស្រស់ ពាក់ក្នុង
ពិធីសមោសរ ឬពេលរៀបការ។ លើសពីនេះ
ក្រណាត់កម្ទីអាចយកទៅដេរធ្វើជាស្បែកជើងជំនួស
ស្បែកបាន និងធ្វើជាកម្រាលតុ ស្រោមខ្នើយ ឬអាច
ធ្វើជាក្រណាត់ដណ្តប់ខ្លួន។ ក្នុងអំឡុងទសវត្ស១៩៨០
ឃើញមានគេនៅនិយមពាក់អាវធ្វើពីក្រណាត់កម្ទីនៅ
ឡើយ។ ប៉ុន្តែសព្វថ្ងៃប្រភេទក្រណាត់នេះស្ទើរតែលែង
មានគេយកមកកាត់ជាសម្លៀកបំពាក់ទៅហើយ។

៦- ខៀន

ជាក្រណាត់ម្យ៉ាងត្បាញពីអំបោះមានផ្កា
ល្អិតៗ សាច់ក្រណាត់ស្រដៀងនឹងសារុង តែក្រាស់
ជាង។ ក្នុងវចនានុក្រមសម្តេច ជួន ណាត ពន្យល់ថា
"ខៀនជាសំពត់ផាឌិប ឬសំពត់ទេសមានផ្កា មានពណ៌
ផ្សេងៗ ធ្វើមកពីប្រទេសក្រៅ សម្រាប់តែស្លៀកចង
ក្បិនប៉ុណ្ណោះ"។ បើតាមការសាកសួរចាស់ៗដែល
ធ្លាប់បានស្លៀកខៀន បានឲ្យដឹងថា ខៀនដែលគេចូល
ចិត្តស្លៀកមានពណ៌បៃតង, ពណ៌ខ្លាញ់ក្តាម, ពណ៌ខៀវ,
ពណ៌ខ្មីមខ្មុរ, ពណ៌ក្រមៅ មានបន្តក់ផ្កាពណ៌ក្រហម
ដែលចាស់ៗនិយមហៅខៀន "ស៊ីដែក" (ពាក្យនេះ
អាចមកពីភាសាសៀមថា "ស៊ីខែង" ប្រែថាក្រហម)

its source. During the early 20th century, people liked to use this type of cloth for making short cap-sleeved shirts which ended at the hips and were form-fitting. These shirts are worn with the *sampot* tied in the *kben* style on the occasion of weddings or to participate in ceremonies. This type of shirt was not worn frequently or in everyday life. During the Sangkum Reastr Niyum and Lon Nol Periods, shirts made of *komni* were embroidered with sequins to make them even more beautiful; party and wedding clothing were often decorated in this manner. In the 1980s, shirts made of *komni* were quite popular still, but today this material is rarely used for clothing.

6. *Kien*

Kien was a type of cloth woven from cotton that had tiny patterns. *Kien* was similar to the cloth of *sarong*, but slightly thicker. In the 1967-68 Buddhist Institute Cambodian Dictionary, *kien* is described as a *sampot pa dip* or *sampot des* with patterns of various colors. It was imported from abroad and was only worn tied in the *kben* style. From asking elderly people who used to wear *kien*, we found that the most popular colors for *kien* were green, orange (crab oil color), yellow-orange (color of the heart of the jackfruit wood), black with drop-like tiny red flower patterns, or maroon (color of the tamarind seed). According to Mom Samuen,

រូបលេខ ១៨០៖ សំពត់ខៀនគ្មានជាយ
របស់លោកយាយយ៉ោ ហួរ
នៅខេត្តសៀមរាប។
(រូបថត៖ រៃយ៉ំ)

Figure 180 : *Kien* belonging to Hor, Siem Reap. This *kien* has no decorative border. (Photo: Reyum)

និងពណ៌ត្រាប់អំពិល ហៅខៀនស៊ីធួ។ លោកយាយ មុម សំអឿន អាយុ៧៧ឆ្នាំ និយាយថា "នៅផ្ទះគេ មិនប្រកាន់ពណ៌ទេទាល់តែទៅបុណ្យ ដូចថាទៅបុណ្យ កឋិន គេស្លៀកត្រូវពណ៌តាមថ្ងៃ ពិសេសទៅហែសព គឺគេប្រើសំពត់ចង៍ក្បិនពណ៌ស្វាយ បើមិនអញ្ចឹង ស្លៀកខៀនពណ៌ខ្មៅ ផ្កាក្រហម"។ ជាទូទៅគេលក់ខៀនជាសំពត់ចង៍ក្បិន គឺក្នុងមួយសំពត់មានប្រវែង៣ ម៉ែត្រ៦តឹក។ ខៀនមានពីរប្រភេទ គឺខៀនមានជាយជាផ្កា និងខៀនគ្មានជាយជាផ្កា (ជាយសងខាងមានផ្កា ខុសពីផ្ទៃសំពត់)។ ខៀនមានជាយជាផ្កាថ្លៃជាង និងមានមុនខៀនគ្មានជាយជាផ្កា។ នៅដើមសតវត្សទី២០ អ្នកមានជីវភាពធូរធារនិយមស្លៀកខៀនប្រចាំថ្ងៃ ទៅវត្ត ចូលរួមពិធីបុណ្យ ឬពិធីរៀបការ។ អ្នកស្រុកសៀមរាបនិងបាត់ដំបងចូលចិត្តស្លៀកខៀនជាងអ្នករស់នៅខេត្តផ្សេងទៀត។ ហើយសព្វថ្ងៃក៏នៅមានចាស់ៗខ្លះនិយមស្លៀកខៀនគ្មានជាយជាផ្កានាំមកពីប្រទេសថៃនៅឡើយ។ តែប្រភេទខៀននោះពុំដូចខៀនដែលចាស់ធ្លាប់ប្រើពីមុននោះទេ។

77 years old, "In the house, they didn't worry about the color of clothes, but when you went to a ceremony, like a *Kathan* [a ceremony to raise funds for the temple], they would wear the color for that particular day. For funerals, one generally wore *sampot* tied in the *kben* style in the color of mangoes. If one didn't wear that color, then they wore black *kien* with red patterns." *Kien* was generally sold in lengths of a little more than three meters, sufficient cloth for wearing it as a *sampot* tied in the *kben* style. There were two types of *kien*: *kien* with a patterned border that had larger patterns on each end of the length of cloth, contrasting with the overall pattern of the cloth, and patterned *kien* without such ornamental borders. The bordered *kien* was more expensive and was an older type of *kien* than the *kien* without a border. At the beginning of the 20th century, people who were well off wore *kien* both in everyday life and when they went to the temple or to special ceremonies such as weddings. *Kien* was especially popular among villagers living in Siem Reap and Battambang Provinces. Still today, some eld-

៧- ក្រណាត់ឈុនឌីវ

តាមចាស់ៗនិយាយថាឈុនឌីវជាក្រណាត់ម្យ៉ាងមកពីស្រុកចិន ស្រដៀងនឹងក្រណាត់ទេសឯកដែរ តែមានគុណភាពល្អជាង និងក្រាស់ជាង ហើយតម្លៃប្រហាក់ប្រហែលនឹងទេសឯកដែរ។ ក្រណាត់នេះមានពណ៌ផ្សេងៗ មានសាច់លាត និងផ្កា។ ភាគច្រើនគេយកក្រណាត់ឈុនឌីវទៅកាត់អាវម៉ាទីណេ, អាវចិន, អាវសន្ទះ, អាវបំពង់ ។ល។ នៅសម័យសង្គមរាស្ត្រនិយម គេនិយមប្រើក្រណាត់ឈុនឌីវធ្វើសម្លៀកបំពាក់ទៅសាលារៀន ឬទៅធ្វើការ។ ក្នុងសម័យខ្មែរក្រហម នៅឃើញមានប្រភេទក្រណាត់នេះនៅឡើយ ដល់ទសវត្ស១៩៨០ទើបចាប់ផ្តើមខ្វត់បន្តិចម្តងៗ ហើយសព្វថ្ងៃនេះស្ទើរតែលែងមាន។

៨- ក្រណាត់ចាក់

ជាក្រណាត់នាំមកពីបរទេស មានច្រើនពណ៌និងច្រើនប្រភេទ។ យើងពុំមានពត៌មានច្រើនពីប្រភេទក្រណាត់នេះឡើយ។ បើតាមស្មានប្រហែលចាប់នាំចូលមកស្រុកខ្មែរក្នុងរវាងចុងទសវត្ស១៩៤០។ លោកយាយជូ សារឿន អាយុ ៧៧ឆ្នាំ នៅខេត្តព្រៃវែងនិយាយថា "ខ្ញុំរៀបការមានកូន២-៣ហើយ ចានមានក្រណាត់ចាក់ពាក់ តែបើនៅក្រុងគេអាចមានមុននៅស្រែ។ គេមិនសូវយកមកលក់ទេ ព្រោះគិតថាអ្នក

erly women in the two provinces wear *kien* without ornamental borders, imported from Thailand. This contemporary *kien* differs slightly from *kien* described to us by our elderly interviewees.

7. *Chun teo*

Chun teo was a type of cloth imported from China which was similar to *des aik* but of better quality and thicker. *Chun teo* came in different colors and could be plain or patterned. In the past, *chun teo* was popularly used to make long tube shirts as well as *matinet*, *malayu* and *santeh* shirts. In the Sangkum Reastr Niyum Period, *chun teo* was used to make school uniforms and working clothes. During the Khmer Rouge Regime, *chun teo* was available, but after the fall of the Regime, the cloth gradually disappeared, and today, *chun teo* is not often sold in the markets.

8. *Bak*

Bak is an imported cloth which comes in many colors and types. We were unable to find much information about this type of cloth. It was perhaps imported into Cambodia at the end of the 1940s. Ju Saroeun, 77 years old living in Phnom Penh, told us, "I was married and had two or three children already when *bak* cloth started to be available. In the

ស្រែមិនសូវមានលុយមានគាត់"។ ក្រណាត់ចាក់ គេនិយមគាត់អាវខ្លីខ្លី ដូចជាអាវចិន, អាវម៉ាទីណេ, អាវបំពង់ សម្រាប់ពាក់ក្នុងពិធីផ្សេងៗ។

ឈ- ក្រណាត់សារូ

ជាក្រណាត់មួយប្រភេទសាច់ស្តើង ម៉ដ្ឋ មកពីប្រទេសក្រៅ។ ក្រណាត់សារូមានពីរប្រភេទ គឺសារូទទឹក (ទន់, ត្រជាក់) និងសារូស្រួយ។ សារូមានប្រភេទសាច់លាត និងផ្កា មានពណ៌ចម្រុះ។ គេអាចយកក្រណាត់សារូគាត់អាវបានគ្រប់ប្រភេទ ដើម្បីពាក់ចូលរួមក្នុងពិធីផ្សេងៗ ពិសេសពិធីមង្គលការ បុណ្យចូលឆ្នាំ ឬចូលរួមពិធីកត្រីសមោសរ។ លើសពីនេះគេយកទៅកាត់ប្រភេទអាវផាយ (ដៃវែងខ្លួនវែងដល់ជង្គង់) សម្រាប់កូនកំលោះពាក់ពេលពិធីលាងជើង និងតោងជាយស្បៃក្នុងពិធីមង្គលការ។ ក្រៅពីនេះសារូអាចយកទៅធ្វើវាំងននលំអផ្ទះបានដែរ។ សព្វថ្ងៃក្រណាត់សារូនៅតែមានគេនិយមយកទៅធ្វើសម្លៀកបំពាក់តាមម៉ូតបែបទាន់សម័យ។

ញ- ប្រភេទក្រណាត់សូត្រខ្មែរ

សូត្រខ្មែរមានតម្លៃ គេចូលចិត្តប្រើតាំងពីបុរាណមក។ សព្វថ្ងៃនេះជនជាតិបរទេសមួយចំនួន ក៏និយមស្លៀកពាក់ក្រណាត់សូត្រខ្មែរដែរ។ ក្រណាត់

city maybe they had that cloth before people in the countryside had it, since people in the countryside didn't have much money." *Bak* cloth was used to make short shirts such as the Chinese shirt, the *matinet* shirt, and the tube shirt. Such shirts were worn to weddings and special ceremonies.

9. *Saru*

Saru was a thin, smooth, almost sheer cloth imported from abroad. There were two types of *saru* cloth: the soaked *saru* which was soft and cool to wear, and a crisp *saru* which was stiffer and slightly thicker. Both types of *saru* cloth came in many colors, and could be plain or patterned. *Saru* cloth was used to make all types of shirts worn for ceremonial occasions, parties, or special holidays. *Saru* cloth was also used for the *pai* shirt (a type of long sleeved shirt that fell to the knees) worn by the groom during some of the rituals of the wedding ceremony. Today *saru* cloth is still popular for making modern styles of clothing.

10. Types of Khmer Silk

Khmer silk has been valued and appreciated since ancient times. Types of woven silk cloth made in the region today known as Cambodia included: *pamuong, hol, kraneu, cha robab,* and *anloin.* All of these different kinds of cloth were woven from the

សូត្រត្បាញនៅក្នុងស្រុកមានច្រើនប្រភេទ ដូចជា ផាមួង, ហូល, ក្រនៀវ, ចរបាប់, អន្ទូញជាដើម។ ប្រភេទក្រណាត់ទាំងនេះសុទ្ធតែត្បាញពីសរសៃសូត្រ បានមកពីដង្កូវនាង ដោយប្រើបច្ចេកទេសត្បាញស្មុគស្មាញនិងខុសគ្នា។ ប៉ុន្តែពេលនេះយើងមិនបង្ហាញអំពីរបៀបត្បាញឡើយ ត្បិតមានឯកសារច្រើនបានសរសេរពីរឿងនេះហើយ។ យើងលើកយកតែប្រភេទក្រណាត់សូត្រមួយចំនួនមកនិយាយ ដោយយោងតាមពត៌មានបានពីមនុស្សចាស់ដែលធ្លាប់ប្រើកន្ទងមក។

silk of silkworms, using different and often very complicated weaving techniques. Here we do not elaborate on the methods of weaving such types of silk since many documents on this exist already. Instead, we simply describe several different kinds of traditional Khmer silk, relying on information provided by our elderly interviewees who used to use such types of silk.

ហូល

ត្បាញពីសរសៃសូត្រមានចង្កាធ លើកជាក្បាច់តាមផ្សែងរាតាមចំណោះ និងសេចក្តីពេញចិត្តនៃអ្នកត្បាញ។ ហូលមានប្រភេទមានរង៉ជើង និងគ្មានរង៉ជើង។ ប្រជាជនខ្មែរមិនដែលចោលសំពត់ហូលឡើយ ពេលមានពិធីបុណ្យទាន ឬពេលរៀបការ។

នៅតាមតំបន់ខ្លះគេប្រើហូលក្បិនពិសេសម្យ៉ាង (ប្រវែង៣ទៅ៧ម៉ែត្រ៦តឹក) ជាប្រភេទសំពត់ហូលផ្ទាល់ខ្លួន ដែលសម្រាប់បុរសជាអ្នកស្មៀក។ សំពត់ហូលនេះត្រូវកូនក្រមុំដែលជិតរៀបការជាអ្នកត្បាញទុកជូនកូនកំលោះស្មៀកនៅព្រឹកនៃថ្ងៃរៀបការ។ គេប្រកាន់ទម្លាប់ដូច្នោះមានតែតាមតំបន់ខ្លះប៉ុណ្ណោះ ពុំមែនជាទំនៀមទម្លាប់ក្នុងស្រុកខ្មែរទូទៅឡើយ ហើយទំនៀមនេះសព្វថ្ងៃក៏លែងមានទៀតដែរ។ សំពត់ហូលសម្លុយ និងសំពត់ហូលក្បិនខុសគ្នាត្រង់រង

Hol

Hol is a type of silk cloth made from silk thread which is first tied and dyed according to a pattern. Some *hol* has a decorative band on one side along the length of the cloth, while some others do not. Bordered *hol* generally only has this patterned decorative band, and is not patterned over the entire cloth. Today, Cambodians continue the tradition of wearing *hol* on the occasion of special ceremonies and weddings.

One type of *hol* called *hol kben* was particularly woven for men to wear. *Hol kben* was generally woven in three to four meter lengths. Young women close to marrying age wove *hol kben* in order to give it to their future husband on the morning of their wedding day for him to wear. Today, such *hol kben* is no longer woven and even in earlier times, the *hol kben* was only woven in certain regions of the countryside. *Hol* woven for *sampot samloy* differs slightly from *hol kben*. *Hol* woven for *hol kben* is thicker and has a larger decorative patterning along its bottom

រូបលេខ ១៨១៖ សំពត់ហូលមានអាយុ៥២ឆ្នាំ របស់លោកយាយ គង់ គីម នៅខេត្តបាត់ដំបង។ (រូបថត៖ ឈៃ)

Figure 181: A 52 year old piece of *hol* owned by Kong Kem in Battambang Province.
(Photo: Reyum)

ជើង។ ហូលក្បិនមានសាច់ក្រាស់ និងមានវង់ជើងជំជាងហូលសម្លុយ។ ហូលដែលត្បាញមានឆ្នូតា និងក្បាច់តូចរលើផ្ទៃ ជាហូលសម្រាប់ស្ត្រីរៀបការរួច ឬស្ត្រីចំណាស់ស្លៀក។ ការត្បាញហូលលំបាកជាងត្បាញផាមួង ដោយសារហូលមានក្បាច់គោមច្រើន ហើយតម្លៃក៏ថ្លៃជាងដែរ។ លោកយាយ មុម សំអឿន បាននិយាយថា "ហូលដែលល្បីជាងគេគឺមានធ្វើនៅស្រុកបាទី, ស្រុកព្រៃកប្បាស, ស្រុកសំរោង ខេត្តតាកែវ និងនៅព្រៃតចង្រ្កាន ខេត្តព្រៃវែង។ ក្រៅពីនេះនៅមានត្បាញខ្លះតាមភូមិចាមក្នុងខេត្តកំពង់ចាម និងនៅខាងសាលារចនា នៅភ្នំពេញក៏មានត្បាញហូលមានគុណភាពល្អដែរ"។ ក្បាច់ហូលខ្មែរមានច្រើនប្រភេទខុសគ្នា ហើយអាចសម្គាល់ជាផលិតផលក្រណាត់ខ្មែរល្អមួយ និងអាចចាត់ទុកជាសញ្ញាណរបស់ជាតិមួយដែរ។ មិនតែប៉ុណ្ណោះជន

edge than the *hol* used for *sampot samloy*. Another kind of *hol* with small striped decorative patterning on the surface of the cloth was worn by married or elderly women.

Weaving *hol* was considered more difficult than weaving *pamuong* because *hol* has so many decorative patterns. Accordingly, *hol* was more expensive than *pamuong* as well. Mom Samuen told us, "The most famous *hol* was made in Srok Bati, Srok Prek Kabas, and Srok Somrong (Takeo Province), as well as at Prek Changkran (Prey Veng Province). There was also some weaving in Cham villages as well as at *Sala Rajana* [the School of Cambodian Arts] in Phnom Penh where *hol* of high quality was woven." Many different *kbach*, or ornamental patterns, were used on Khmer *hol*. *Hol* was one of the best quality cloth produced in Cambodia, and it has come to stand as a symbol for Cambodia. Today, foreigners greatly appreciate Khmer *hol*. According to the late Liv Sa Aem, whose ancestors wove *hol* in Preak Kabas, "The French love my *hol* and have commissioned a lot from me to take to sell in France, but I have trouble filling orders in time."

Pamuong

Pamuong is a plain unpatterned cloth woven from silk which can be worn either as a *sampot* tied in the *kben* or *samloy* style. Today, most *pamuong* is woven from a mix of silk and cotton which makes the cloth stiff and thick. These mixed *pamuong* are three to

បរទេសមួយចំនួន ស្រឡាញ់ពេញចិត្តហូលខ្មែរណាស់ដែរ។ លោកតាលី វ សាឯម ជាអ្នកប្រកបរបរត្បាញហូលនៅស្រុកព្រៃកប្បាសតាំងពីជំនាន់ដូនតាដល់សព្វថ្ងៃ ច្រាប់ថា "ជនជាតិបារាំងស្រឡាញ់ប្រភេទហូលខ្ញុំណាស់ គេបានទិញច្រើនពីខ្ញុំ យកទៅលក់នៅស្រុកបារាំង។ ប៉ុន្តែខ្ញុំអត់លទ្ធភាពត្បាញទាន់ពេល"។

ជាមួង

ជាមួងជាក្រណាត់មួយប្រភេទត្បាញពីសរសៃសូត្រ មានផ្ដែលាត សម្រាប់ស្លៀកជាសំពត់ចងក្បិន ឬសំពត់សម្លុយ។ សព្វថ្ងៃជាមួងភាគច្រើនត្បាញដោយមានលាយអំបោះ ធ្វើឲ្យសាច់ក្រណាត់កាន់តែងើយក្រាស់ និងមានតម្លៃថោកជាង៣ ឬ៤ដងពីជាមួងធ្វើពីសរសៃសូត្រសុទ្ធ។ តាមការសង្កេតសព្វថ្ងៃយើងឃើញជាមួងមានច្រើនពណ៌។ ជាមួងកន្ទាជាប្រភេទជាមួងពណ៌បៃតង មានស្លៀកច្រើន ទាំងចាស់ទាំងក្មេង។ នៅសម័យបារាំង គេយកជាមួងមកចាប់ផ្តន់ស្លៀកចងក្បិនពេលទៅចូលរួមក្នុងពិធីបុណ្យផ្សេងៗ ចូលគាល់ព្រះមហាក្សត្រ ឬស្លៀកទៅធ្វើការ (មេឃុំ មេស្រុក)។ ជាមួងមានត្បាញច្រើនកន្លែង តែជាមួងដែលល្បីមានត្បាញនៅខាងកោះសូទិន ខេត្តកំពង់ចាម។ លោកយាយឆួក អាយុ៨២ឆ្នាំនិយាយថា "ឥឡូវគេត្បាញសូត្រលាយអំបោះ ពីដើមគេធ្វើសុទ្ធល្អ ឲ្យតែជាមួងហូលមកពីបាទី ឬស្រុកព្រៃកប្បាសគឺល្អទាំងអស់។ ពីមុនជាមួងគ្មានរង្វេងទេ។ រង្វេងដូច

four times cheaper than *pamuong* woven from pure silk. Today, we see many different colors of *pamuong* being sold. *Pamoung kaw deer* (*pamuong* the color of the duck's neck) is a green colored *pamuong* that was once very popular and was worn by old and young alike. During the French Protectorate, *pamuong* was generally not worn everyday, but instead was reserved for special ceremonies, holidays, and audiences with the King, although government officials wore it frequently for work and official duties.

Pamuong was woven in many places throughout Cambodia; one of the most famous areas where it was woven was Koh Sutin (Kompong Cham Province). Duock, 82 years old, told us, "Today, they weave cloth mixing cotton with silk. But before, they wove pure silk. *Pamuong hol* from Tonle Bati and

រូបលេខ ១៨២៖ ជាមួងពណ៌អត់មានរង្វេង។ ថតឆ្នាំ១៩៦៨។ (រូបថត៖ អ្នកស្រីដួង សារ៉ី)

Figure 182: The colors of the day. *Pamuong* with no decorative border. Photographed 1968. (Photo: Duong Saree)

ជារឿយមានតម្លៃវែងទេ បើហូលមានរង៉ជើង តែបើផាមួងមានបន្តក់ផ្កាមួយវាអានោះមាន ខ្ញុំធ្លាប់ស្លៀកអស់ហើយ"។ ប៉ុន្តែពេលនោះ អាចមានព្រះមហាក្សត្រ ឬអ្នកមានឋានៈខ្ពស់មានផាមួងមានរង៉ជើងស្លៀក។ ផាមួង ឬហូលដែលត្បាញពីសរសៃសូត្រសុទ្ធ ហើយប្រើល័ក្ខធម្មជាតិ (ល័ក្ខយកមកពីដើមឈើ) ច្រើនមានសាច់ទន់ អាចជោកគក់ទឹកបានដោយមិនចេញពណ៌។ តែសព្វថ្ងៃគេច្រើនប្រើល័ក្ខគីមីមកពីបរទេស ព្រោះងាយស្រួលរក និងតម្លៃថោក។

Srok Prek Kabas were all excellent. Earlier, *pamuong* did not have a decorative border. It's only now that decorative border *pamuong* becomes available. *Hol* had decorative borders but *pamuong* only had little patterns all over it. I used to wear it." *Pamuong* with decorative bordering was perhaps worn in the past by the King or high ranking officials. *Pamuong* or *hol* woven from pure silk and dyed with *leak* from the trees generally was soft and supple, and could be washed without the color coming out of it. Today, chemical dyes, imported from abroad, are used since they are readily available and cheap.

អន្លូញ

មានពីរប្រភេទ គឺអន្លូញត្បាញពីអំបោះ និងអន្លូញត្បាញពីសូត្រ។ គេអាចស្គាល់អន្លូញបានដោយសារផ្ទៃមានឆ្នូតទទឹងពីរពណ៌ឆ្លាស់គ្នា។ អន្លូញត្បាញពីអំបោះរំលេចដោយឆ្នូតក្រហមឆ្លាស់ខ្មៅ គេច្រើនហៅថា"អន្លូញប៉ប៉ក"។ អន្លូញប៉ប៉កភាគច្រើនសម្រាប់ស្លៀកនៅផ្ទះ ឬពេលធ្វើការជាប្រចាំបាន។ យើងពុំបានដឹងពីវិធីត្បាញអន្លូញយ៉ាងណានោះទេ គឺដឹងតែត្រឹមថា នៅដើមសតវត្សទី២០ នៅក្នុងស្រុកខ្មែរមានត្បាញអន្លូញ។ អ្នកស្រុកបាត់ដំបងនិយមត្បាញក្រណាត់លាត (ប្រហែលជាផាឌិប) និងអន្លូញប៉ប៉ក ធ្វើជាសម្លៀកបំពាក់គេហៅថា"សំពត់ប៉ប៉ក ឬសំពត់ឆ្នូត"។[២] អន្លូញត្បាញពីសូត្រភាគច្រើន

Anloin

Anloin was a type of cloth woven from cotton or silk. *Anloin* was characterised by its two color striped pattern. Cotton *anloin* generally had red and black stripes which were called *anloin babak*. *Anloin babak* was worn in the house or for everyday tasks. We do not know how *anloin* was woven, but we do know that it was being woven in villages beginning in the 20th century. Villagers in Battambang Province liked to weave plain cloth (probably *pa dip*) and *anloin babak* for making their clothing which they called *babak sampot* or striped *sampot*.[1] *Anloin* woven from silk was mostly only worn to ceremonies and weddings by those rich enough to buy it. Today, *anloin* is still being woven in very small quan-

[២] តួច ឈួង, "ចាត់ដំបងសម័យលោកម្ចាស់" ភ្នំពេញ ១៩៩៤, ទំព័រ៩២។

[1] Tauch Chhuong, *Battambang during the time of the Lord Governor East West Center*, Hawaii, 1994.

សម្រាប់ស្លៀកពេលចូលរួមក្នុងពិធីបុណ្យ និងពិធីមង្គលការ ហើយអ្នកមានទើបមានអន្ទូញនេះស្លៀក។ សព្វថ្ងៃ អន្ទូញមាននៅតា្បាញតិចតួចបំផុតតាមតំបន់ខ្លះ ដូចជានៅព្រែកចង្រ្កានជាដើម តែខុសពីប្រភេទអន្ទូញដែលចាស់ៗធ្លាប់ប្រើពីសម័យមុន។

ក្រនៀវ

ស្តាប់តាមចាស់ៗនិយាយថា ក្រនៀវជាប្រភេទក្រណាត់តា្បាញពីសូត្រ។ ក្រនៀវស្រដៀងនឹងសារុងសូត្រដែរ មានលំអជាក្បាច់ក្រឡាបួនជ្រុង។ ប៉ុន្តែគេតា្បាញក្រនៀវដោយវេញសូត្រ ឬអំបោះចម្រុះពណ៌បញ្ចូលគ្នា ចាប់ពីបីពណ៌ឡើងទៅ។ ឧទាហរណ៍ គេវេញសូត្រពណ៌លឿង ពណ៌ស្វាយ ពណ៌ទឹកក្រូចបញ្ចូលគ្នា ទើបយកទៅចាក់តា្បាញ។ តែយើងពុំដឹងពីវិធីតា្បាញក្រនៀវ ឬមានរូបរាងបែបណានោះទេ។ ក្រនៀវជាប្រភេទសំពត់មានតម្លៃណាស់ អាចស្លៀកបានទាំងស្រីទាំងប្រុស។ អ្នកមានក្រនៀវស្លៀកភាគច្រើនជាអ្នកមាន ឬមានឋានៈខ្ពស់ ហើយមានវ័យចំណាស់បន្តិច។ លោកយាយមុម សំអឿន អាយុ៧៧ឆ្នាំ និយាយថា "ក្រនៀវមានសាច់ក្រាស់ ហើយរលោង ចាំងពណ៌ដូចជ្រាក់។ ព្រះករុណា ស៊ីសុវត្ថិ មុនីវង្ស ពេលទ្រង់យាងទៅណាក៏ទ្រង់ស្លៀកសំពត់ក្រនៀវនេះដែរ"។ មុនសម័យខ្មែរក្រហម ក្រនៀវច្រើនមានតា្បាញនៅស្រុកខ្ជាប់កណ្តាល ស្រុកល្វាឯម ក្នុងខេត្តកណ្តាលនិងនៅព្រែកចង្រ្កាន ក្នុងខេត្ត

រូបលេខ ១៨៣៖ នារីបម្រើលើយន្តហោះ យកអន្ទូញមកតាត់ជាសំពត់ខ្លី បែបទាន់សម័យ។ ថតឆ្នាំ១៩៦០។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 183: A stewardess for Royal Air Cambodge, photographed in the 1960s. Her modern skirt is made from *anloin*. (Photo: National Archives of Cambodia)

tities in some areas such as Prek Changkran, although this *anloin* is said to be different from the one our elderly interviewees described to us.

Kraneu

Kraneu was a kind of cloth woven from silk or cotton. It was similar to the cloth of checkered silk *sarong*, but *kraneu* was woven by using silk or cotton that had been

ព្រៃវែង។ បច្ចុប្បន្នពុំឃើញមានត្បាញក្រនៀវពីអំបោះសូត្រទេ តែមានត្បាញពីអំបោះ ដោយវេញតែពីរពណ៌បញ្ចូលគ្នា។

twisted into strands of three of more colors. Yellow, purple and orange strands of cotton or silk were twisted together, for example, and then were used for the weft of the cloth. We do not know exactly how this cloth was woven, since we could not find anyone weaving *kraneu* anymore. *Kraneu* was a very expensive cloth worn by both men and women who are generally elderly. In the past, it was the wealthy and those of high standing who could buy and wear *kraneu*. Mom Samuen told us, "*Kraneu* was thick, smooth, and shiny like silver. King Sisowath Monivong wore *sampot* made of *kraneu* when His Majesty went out." Before the Khmer Rouge Regime, *kraneu* was mostly woven in Srok Ksaich Kandal and Srok Lovea Em in Kandal Province, and in Prek Changkran, Prey Veng Province. We could not find anyone still weaving *kraneu* today.

ចរចាប់ (សារចាប់ ឬចារចាប់)

ជាក្រណាត់ត្បាញពីសូត្រ ដោយប្រើតិត្បាញមានថ្ពរច្រើនជាងតិត្បាញហូល ឬផាមួង។ ចរចាប់មានសាច់ក្រាស់ ធូន ត្បាញដោយសរសៃសូត្រលាយចេសមាស ឬចេសប្រាក់ លើកគោមមានរំលេចក្បូរក្បាច់ទៀតផង។ ពីជំនាន់មុនក៏ដូចបច្ចុប្បន្នដែរ សំពត់ចរចាប់មានតម្លៃខ្ពស់ ដូច្នេះគេស្ទៀតចរចាប់មួងម្តាល ក្នុងពិធីពិសេសណាមួយ។ ការត្បាញចរចាប់ ពុំសូវមានអ្នកចូលចិត្តត្បាញទេ ព្រោះមានការលំបាក និងស្មុគស្មាញ។ សព្វថ្ងៃនៅ

Chara bab

Chara bab was a type of cloth woven from silk on a loom with more foot pedals than those used to weave *hol* or *pamuong*. *Chara bab* is a thick supple cloth woven out of silk mixed with gold or silver thread; it has many diagonally patterned intricate designs. A *sampot* of *chara bab* had great value and was worn only on very special occasions. Weaving *chara bab* was a complex and difficult process, and thus not many weavers liked to weave it. Today, some people still wear *chara bab* but it is not sold as much as *hol* or *pamuong* in the

រូបលេខ ១៨៤៖ សំពត់ចរចាប់ស្ទៀតក្នុងពិធីច្រត់ព្រះនង្គ័ល ឆ្នាំ ២០០៣។ (រូបថត៖ ព្រាប ចាន់ម៉ារ៉ា)

Figure 184: *Sampot chara bab* worn for the Ploughing Festival. Photographed 2003 (Photo: Preap Chan Mara)

markets. Small quantities of *chara bab* are still woven in Prek Ta Ong and Prek Takow, Srok Ksaich Kandal.

11. *Pa dib*

Pa dib is woven in Cambodia as well as imported from abroad. *Pa dip* is woven out of raw cotton thread which is wetted with fermented rice during weaving. *Pa dib* has a rough surface and is not smooth like *des aik*. The name *pa dib* probably comes from Thailand. The 1967-68 Buddhist Institute Cambodian Dictionary tells us, "There is a cloth called *pa dip*, woven in a factory and treated with fermented rice which is imported from abroad to Thailand. The Thai first called this cloth *pa dip*. This cloth then gradually came to Cambodia and the Khmer called the cloth by the Thai *pa dip*." When *pa dip* was just woven, it was quite stiff and yellow from the fermented rice. *Pa dip* was considered one of the cheapest cloth to buy. During the early 20th century, either the cloth itself or clothing already made from *pa dib* was dyed black using *mcleur* dye. Almost everyone had everyday clothing and clothes for working in the fields made of *pa dip*. White *pa dip* was used for wrapping corpses and in funerary ceremonies. Red *pa dip* (*jeati*) was used as a waistband for silk pants or *sampot*, or as a handkerchief for wiping up betel juice. Today, because many other fabrics are available, *pa dip* is not

មានស្ទើរនៅឡើយ តែនៅតាមផ្សារពុំសូវមានលក់ច្រើនដូចផាមួង ឬហូលឡើយ។ ហើយចរបាប់នៅមានត្បាញតិចតួចនៅភូមិព្រែកតាអុង ព្រែកតាកូវ ស្រុកខ្សាច់កណ្តាល។

៨- ផាឌិប

ជាក្រណាត់ត្បាញក្នុងស្រុកផង និងមាននាំមកពីប្រទេសក្រៅផង។ ខ្មែរត្បាញក្រណាត់ផាឌិបពីអំបោះដៅ មានឲ្យថាយជូរ។ ក្រណាត់ផាឌិបមានសាច់ត្រឹម មិនរលោងម៉ដ្ឋដូចសាច់ក្រណាត់ទេសឯកឡើយ។ ខ្មែរហៅ "ផាឌិប" ទំនងជាហៅតាមសៀម។ តាមការពន្យល់នៅក្នុងវចនានុក្រមសម្តេចជួន ណាត ថា "មានក្រណាត់ផាឌិបដែលត្បាញដោយគ្រឿងចក្រ តែឥតឲ្យថាយជូរ បាននាំមកពីបរទេសចូលទៅក្នុងប្រទេសសៀម ជាដំបូងសៀមហៅក្រណាត់នោះថា "ផាឌិប" ហើយក្រណាត់ផាឌិបនោះបានបន្តហូរចូលមកក្នុងស្រុកខ្មែរ។ ខ្មែរក៏ហៅក្រណាត់នោះថា"ផាឌិប" តាមសៀមដែរ"។ ក្រណាត់ផាឌិបដែលទើបត្បាញហើយកាន់រឹងរា និងមានលាយពណ៌លឿងរា ដោយសារតេឲ្យថាយ។ ផាឌិបមានតម្លៃថោកជាងគេក្នុងចំណោមក្រណាត់ទាំងឡាយ។ នៅដើមសតវត្សទី២០ ជាទូទៅគេយកសម្លៀកបំពាក់ធ្វើពីក្រណាត់ផាឌិបទៅជ្រលក់ផ្លែខ្ចីឲ្យឡើងពណ៌ខ្មៅ ឬយកក្រណាត់ទៅជ្រលក់ហើយ ទើបយកមកកាត់ជាសម្លៀកបំពាក់។

ន:ណាក៏មានខោអាវធ្វើពីក្រណាត់ផាឌុបស្រាំកពាក់ដែរ តែសម្រាប់ពាក់ប្រចាំថ្ងៃ ធ្វើការងារស្រែចម្ការ។ សព្វថ្ងៃដោយសារក្រណាត់សម្បុណ៌បៃបៈ គេមិនសូវយកផាឌុបកាត់ជាខោអាវដូចពីជំនាន់មុនទេ សូម្បីតែក្បាញក៏គ្មានដែរ តែមានតែផាឌុបនាំមកពីបរទេស។ ក្រណាត់ផាឌុបពណ៌សអាចយកទៅត្រប ឬរុំសព និងប្រើក្នុងពិធីបុណ្យបង្សុកូល។ ចំណែកផាឌុបក្រហម "ជាតិ" អាចប្រើជាក្រណាត់ប៉ាន់ចង្កេះខោ ឬសំពត់ ឬកន្ទែងជូតទឹកមាត់ស្លា។

របររកស៊ីលក់ក្រណាត់

ប្រភេទក្រណាត់ទាំងអស់ដែលបានរៀបរាប់ខាងលើមានទាំងក្រណាត់ធ្វើក្នុងស្រុក និងនាំចូលមកពីបរទេស។ តាមសម្តីលោកតាអៀង តិច អាយុ៨៥ឆ្នាំ នៅភ្នំពេញ បានឲ្យដឹងថា ចាប់ពីចុងសតវត្សទី១៩រហូតមក ភាគច្រើនអ្នកនៅភ្នំពេញ អាចរកទិញក្រណាត់បាននៅតាមហាង់លក់ក្រណាត់ម្តុំមាត់ទន្លេ ចាប់ពីផ្សារកណ្តាលរហូតដល់ផ្សារចាស់។ ក្រោយមក (ទសវត្សរ៍១៩៤០) មានហាង់នៅម្តុំជុំវិញផ្សារថ្មី ភាគច្រើនជាហាង់របស់ភ្ញីឆ្ន និងចិន។ ហាង់ទាំងនេះមានលក់ក្រណាត់គ្រប់ប្រភេទ ហើយលក់រហូតដល់សម័យខ្មែរក្រហម។

ប្រហែលចាប់ពីទសវត្សរ៍១៩៤០ ចាប់ផ្តើមមានខ្នាតវាស់ដោយប្រើម៉ែត្រ តែក្នុងអំឡុងពេលមិន

used as much anymore for clothing. *Pa dip* today is generally imported from abroad.

The cloth trade

The types of cloth described above were either made in Cambodia or were imported from abroad. Ieng Tech, 85 years old living in Phnom Penh, told us that inhabitants of Phnom Penh could find cloth for sale in stores along the waterfront from Psar Kandal (the Middle Market) to Psar Chas (the Old Market). Later on, in the 1940s perhaps, stores began to appear around Psar Thmei (the New Market) which were generally owned by Indians and Chinese. These fabric stores sold all kinds of fabric until the start of the Khmer Rouge Regime in 1975.

By the 1940s, some stores were using the metric system of measuring and had wooden or metal meter sticks (straight or folding) which they called *sampot metre*. In those days though, meter sticks were not yet widely available and people also still used the *hot* as a unit of measure. When buying cloth, people generally asked for one *sampot* of cloth (1 *sampot* = 7 *hot* = 1 *kben* = 3.7 meters). Out of the length called one *sampot kben*, you could cut two Chinese pants with some fabric left over, or three short shirts. One long tube shirt could be made from four *hot* and one *chom am* of cloth. Today, one *sampot* generally means a length of cloth 1.8 to 2 meters

ទាន់មានម៉ែត្រវាស់គេច្រើនប្រើហត្ថ។ ពេលទៅទិញក្រណាត់គេនិយាយថា "ទិញក្រណាត់មួយសំពត់" (ជាមធ្យម១សំពត់=៧ហត្ថ=១ក្បិន=៣ម៉ែត្រ៥តឹក) គេមិននិយាយ១អាវ ឬ១ខោដូចសព្វថ្ងៃឡើយ។ ១សំពត់ក្បិនបើកាត់ខោបាន២ (ខោចិន) ហើយនៅសល់ក្រណាត់ខ្លះ តែបើកាត់អាវបានបីចំពោះអាវខ្លួនខ្លី បើអាវបំពង់វែងមួយត្រូវប្រើក្រណាត់អស់៤ហត្ថថែមមួយចំអាម។ សព្វថ្ងៃគេនិយាយថា "ទិញក្រណាត់មួយសំពត់ ឬមួយអាវ" គឺសំដៅលើក្រណាត់យកទៅកាត់សំពត់ដែលមានប្រវែងត្រឹមតែ១,៨ម៉ែត្រ ឬ២ម៉ែត្រ អាចកាត់បានសំពត់ហ្ការ៉ែបមួយ ឬស្មៀកជាសំពត់សម្លៀក។ "មួយអាវ" គឺសំដៅលើក្រណាត់សម្រាប់កាត់អាវដែលមានប្រវែងពី០,៨ម៉ែត្រដល់១,៥០ម៉ែត្រ។ ចំពោះអ្នកលក់ក្រណាត់ និងជាងកាត់ដេរខោអាវ គេ

long out of which they can either make a *sampot juppe* or a *sampot* in the *samloy* style. Cloth for one shirt means a length of cloth measuring anywhere from 80 centimeters to 1.5 meters.

In the provinces, cloth was generally sold at the larger markets. Ly El, 80 years old of Cham descent living in Kandal Province, told us that travelling peddlers walked through the countryside, selling fabric and beauty products as well as buttons, needles and scissors to individual households in more remote areas of the countryside. These peddlers were generally of Cham descent and travelled in groups, leaving their homes for periods of half a month or one month in order to sell their goods in exchange for money or rice. At night, they either stayed in temples, cooking their rice and sleeping there,

រូបលេខ ១៨៥៖ រូបគំនូរនៅលើជញ្ជាំងព្រះវិហារវត្តបូពិ ខេត្តសៀមរាប ដើមសតវត្សទី២០។ (រូបថត៖ រៃយ៉ំ)

Figure 185: Cloth merchants as pictured on the walls of Wat Bo, Siem Reap Province, late 19th century. (Photo: Reyum)



រូបលេខ ១៨៦៖ រោងចក្រតម្បាញនៅកំពង់ចាម (ដកស្រង់ពីឯកសារអនុស្សាវរីយ៍ដោយរូបភាពនៃសង្គមរាស្ត្រនិយម ទស្សាហកម្មឆ្នាំ១៩៥៥-៦៩)។

Figure 186: The Kompong Cham cloth weaving factory. (Photo: *Photo Souvernirs du Cambodge Sangkum Reastr Niyum 1955-1969*)

or asked to stay at the houses of local authorities. When they had sold all their goods, they would return home and prepare for another trip to another area of the countryside. After a period of three or four months, they would start to once again visit each area where they had previously sold their goods. Duock, 82 years old, told us, "When I was a teenager, in the months when the rice was harvested [February, March], they would come with such things as *hol*, *pamuong*, *sarong*, and *kien*. They would walk, carrying these things and selling them all over the region. My father was the leader of the *srok*. At night, the peddlers asked to sleep at our house. They were afraid of thieves, so they looked for the house of an official to sleep in. Now there aren't people like that anymore, ever since the country



រូបលេខ ១៨៧៖ រោងចក្រតម្បាញសូត្រ។
(រូបថត៖ បណ្ណសារជាតិ)

Figure 187: Silk weaving factory.
(Photo: National Archives of Cambodia)

និយមប្រើម៉ែត្រត្រង់ធ្វើពីឈើហៅថា "ម៉ែត្រសំពត់" ឬ ម៉ែត្របត់ធ្វើពីឈើ ឬដែក។ ចំណែកនៅតាមខេត្ត នានាក្រណាត់ច្រើនមានលក់នៅក្នុងផ្សារទីរួមខេត្ត ឬ ស្រុក ឬឃុំជាដើម។ លោកតាលី អ៊ែល ជនជាតិ ចាម អាយុ ៨០ឆ្នាំ នៅខេត្តកណ្តាល ពន្យល់ថា សម័យមុនមានអ្នករកស៊ីដើរលក់ក្រណាត់ និងអ្នក លក់ប្រេងម្បៅមានឡេវ ម្ហូល កន្ត្រៃ ។ល។ នៅតាម ស្រុកស្រែចម្ការ ឬតំបន់ឆ្ងាយដាច់ស្រយាលភាគ ច្រើនជាជនជាតិចាម។ អ្នកទាំងនោះច្រើនធ្វើដំណើរ ជាក្រុមជាមួយគ្នាត្រូវចេញពីផ្ទះរយៈពេលកន្លះខែទៅ មួយខែដើម្បីដើរលក់ដូរយកប្រាក់និងដូរស្រូវ។ ពេល យប់ត្រូវសម្រាកនិងដាំបាយបរិភោគនៅតាមវត្ត ឬ ទៅសុំស្នាក់នៅផ្ទះមេស្រុក ឬមេឃុំក៏បាន។ ពេល លក់អស់ទើបត្រឡប់មកផ្ទះវិញ ហើយជើងក្រោយ ទៀត ត្រូវទៅលក់នៅតំបន់ផ្សេងទៀត។ ក្នុងរយៈ ពេល ៣ទៅ ៤ខែទើបទៅលក់នៅតំបន់ដែលធ្លាប់លក់ នោះទៀត។ លោកយាយឡុក អាយុ ៨៤ឆ្នាំ ប្រាប់ថា "កាលពីខ្ញុំនៅជំទង់ឲ្យតែដល់ខែមាឃ ខែបុស្ស ដែល ជាខែស្រូវទុំហ្នឹង មានពួកដើរស្តាយបង្វិចមាន ហូល ជាមួង សារុង ខៀន ស្តាយដើរលក់គ្រប់ស្រុកទាំង អស់។ ឪពុកខ្ញុំធ្វើមេស្រុក ពេលយប់ឡើងពួកនោះមក សុំដេកពេញផ្ទះ ពួកគេខ្លាចចោរប្លន់ ម្ល៉ោះហើយរកផ្ទះ មេស្រុកដេក។ ឥឡូវលែងមានហើយតាំងពីស្រុកបែក មក (បែកឆ្នាំ ១៩៧៥)"។ ដូច្នេះអ្នកនៅតំបន់ឆ្ងាយ ពីផ្សារកម្រនឹងបានឡើងមកផ្សារណាស់ ភាគច្រើនគេ

ដោះដូរក្រណាត់ជាមួយអ្នកដើរលក់ក្រណាត់ទាំងនោះតែម្តង។ សព្វថ្ងៃមានអ្នកដែលដើរលក់មុង ភួយ និងរបស់ប្រើប្រាស់ផ្សេងទៀតភាគច្រើនជាជនជាតិឥណ្ឌា តែគម្រោងើញមានលក់ជាក្រណាត់ណាស់ គេដើរលក់តាមភូមិស្រុកខ្លះ និងទីក្រុង។

សរុបមកនៅដើមសតវត្សទី២០ក្រណាត់មិនទាន់សម្បូណិនៅឡើយ ភាគច្រើនខ្មែរនិយមប្រើក្រណាត់មកពីចិន វៀតណាម ឥណ្ឌា និងបារាំង។ នៅពេលខ្មែរបានទទួលឯករាជ្យក្នុងឆ្នាំ១៩៥៣ ស្រុកចាប់ផ្តើមសម្បូណិបន្តិចម្តងៗទាំងក្រណាត់នាំចូល និងក្រណាត់ធ្វើក្នុងស្រុក។ មានរោងចក្រត្បាញក្រណាត់ច្រើនត្រូវបង្កើត ហើយផលិតផលទាំងអស់សម្រាប់ទុកប្រើប្រាស់ក្នុងប្រទេសប៉ុណ្ណោះ។ លើសពីនេះនៅមានតម្បាញតាមគ្រួសារ និងជាសិប្បកម្មត្បាញក្រណាត់សូត្រ ដើម្បីនាំចេញទៅបរទេស និងលក់ឲ្យភ្ញៀវទេសចរទៀតផង។

broke up [in 1975]." Most of those who lived in remote areas and did not have the possibility to go to markets often, depended on these traveling peddlers for fabric for their clothing. Today we once again see vendors walking and selling mosquito nets, pillows, and various household things. Many of these vendors are Indians, and we see them in the city as well as the countryside. Few of these walking vendors sell cloth today however.

In the early 20th century, cloth was not yet abundant and most Khmer used cloth imported from France, China, Vietnam, and India to make their clothing. After independence, more and more cloth was imported as well as being manufactured domestically. Factories weaving cloth were established and cloth produced in them fulfilled domestic demand. There was also still weaving within families and small artisanal workshops where traditional types of Khmer silk cloth were woven for the tourist market and for export.

រូបលេខ ១៨៨៖ តម្បាញជាគ្រួសារនៅគោះដាច់ ខេត្តកណ្តាល។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 188: Family weaving in Kandal Province. Photographed 2003. (Photo: Reyum)

ការកាត់ដេរ

CUTTING AND SEWING

ក- ថ្នេរ

ថ្នេរដេរដែលលើកយកមកសិក្សានៅពេលនេះ គឺយកតែថ្នេរខ្លះដែលបានមកពីការសម្ភាសន៍ ហើយក៏ជាថ្នេរដែលចាស់ធ្លាប់ប្រើការពីនៅដេរដោយដៃ។ នៅពេលមិនទាន់មានម៉ាស៊ីនដេរ គេដេរសម្លៀកបំពាក់ដោយដៃ។ ស្ត្រីភាគច្រើនចេះដេរសម្លៀកបំពាក់ដោយខ្លួនឯង គ្រាន់តែអ្នកខ្លះដេរស្អាត ខ្លះដេរមិនស្អាត។ ចំពោះអ្នកដែលដេរថ្នេរស្អាត តែងមានគេទៅពីងពាក់ឲ្យជួយដេរ។ លោកយាយធាយ លីមយីម អាយុ៨២ឆ្នាំ នៅខេត្តកណ្តាល និយាយថា "ការខ្ញុំនៅពីក្មេងអាយុជាងដប់ឆ្នាំ ធ្លាប់ស៊ីឈ្នួលដេរអាវបំពង់វែង ក្រណាត់ផាឌិបបានឈ្នួលតែ ៨សេន។ ព្រោះខ្ញុំនៅក្មេងដេរមិនសូវស្អាតដូចគេចាស់ ទើបដេរបានថោកជាងគេ។ អាវមួយខ្ញុំដេរបីថ្ងៃ បើបងខ្ញុំអាវមួយដេរបាន១កាក់ មួយថ្ងៃមួយយប់គាត់ដេរបានអាវបំពង់វែងមួយ"។ នៅពេលដែលមានម៉ាស៊ីនដេរហើយក៏ដោយ សំពត់ខ្លះគេមិនដេរម៉ាស៊ីនទេ គឺគេនៅតែនិយមដេរដោយដៃដដែល ដូចជាសំពត់ហូល ឬក្រណាត់ព្រៃដែលមានតម្លៃខ្ពស់។ ព្រោះគេយល់ថាដេរម៉ាស៊ីនធ្វើឲ្យខូចសាច់ក្រណាត់ ហើយមិនស្អាតដូចដេរដៃ។ សម័យដើមបើគេចង់ស្តីដណ្តឹងកូនក្រមុំ គេមិនត្រឹមតែពិនិត្យមើលពូជពង្ស មើលចង្ក្រានបាយនោះទេ គេក៏សង្កេតមើលថ្នេរដេររបស់កូនស្រីដែរ។ គេអាចវាយតម្លៃថានាងគឺជាមនុស្សដែល

Stitches and seams

Here we discuss some of the types of stitches and seams which were described to us in interviews and which were used by our elderly interviewees when sewing garments by hand before there were sewing machines. In the past, almost all girls were taught to sew. Some could sew very well, while others sewed less well. Those who were skilled at sewing were often asked to help others sew. Chay Lim Khim, 82 years old living in Kandal Province, told us, "When I was still little, just over ten years old, I was paid for sewing long tube shirts out of *pa dip*. I got eight *centime*. I was still young and didn't sew as well as the others, so I asked a cheaper price. It took me three days to sew one shirt. My older sister got 1 *kat* for one shirt, and it took her only one day and night to sew a long tube shirt." Even when there began to be sewing machines, clothing made of *hol* or expensive *prai* was still sewn by hand. Sewing such materials by machine could ruin the precious material, and hand stitching was still more beautiful than machine seams. In the past, when a girl was becoming engaged, the family of her prospective groom would not only look at her family line and the state of cleanliness around her cooking stove, but they would also ask to see the stitching of the girl to see if she was industrious or lazy. Below we describe some of the stitches and

ខុសគ្នាហ៍ ឬខ្ជិល។ ខាងក្រោមនេះគឺជាថ្នេរដៃ ដែលចាស់ធ្លាប់ប្រើពីមុន៖

– ថ្នេរដាន៖ មានច្រើនប្រភេទ ដូចជាដានសាក, ដានញឹក, ដានបង្កប់ ហើយជាទូទៅគេដេរអំពោះតែមួយសរសៃ។ ថ្នេរដានសាក គេដេរឆ្ងាយសម្រាប់ដេរជាបណ្តោះអាសន្ន ឬដានសាកឲ្យចេញជារាងអាវសិន រួចទើបចាប់ផ្តើមដេរសម្រេច។ ក្រោយពីដេររួច គេហួតថ្នេរសាកនេះចេញ (រូបលេខ ១៨៩)។ ថ្នេរដានញឹក ជាថ្នេរដែលញឹកជាងថ្នេរដានសាក ហើយសម្រាប់ដេរចំកអាវ, ចុងដៃអាវ, ជាយអាវ, ជើងខោ ឬប៉ះខោអាវដែលរហែក (រូបលេខ ១៨៩)។ គេប្រើថ្នេរដានញឹកសម្រាប់ដេរអោវទាក ព្រោះវាទន់ មិនធ្វើឲ្យកកិត ឬប៉ះពាល់ដល់សាច់ទាក។ ចំពោះមនុស្សធំគេមិនសូវប្រើថ្នេរនេះដើម្បីដេរអោវពាក់ទេ ចាស់ៗតែងរិះគន់អ្នកប្រើថ្នេរបែបនេះថា ជាមនុស្សខ្ជិល។ ថ្នេរដានបង្កប់គឺគេដេរមិនឲ្យ



រូបលេខ ១៨៩៖ ថ្នេរដានសាក (ខាងលើ) និងថ្នេរដានញឹក (ខាងក្រោម)។ (រូបថត៖ រៃយ៉ំ)

Figure 189: Basting (top), and close straight stitching (below). (Photo: Reyum)

seams which our elderly interviewees used to use when sewing clothing.

Thnai dan or straight stitch

By straight stitch we mean a simple stitching in which the needle moves forward by simply going in and out. Basting, close stitching, and buried stitching are all types of such straight stitching, which generally used a single thread (figure 189). Basting uses long loose straight stitches to temporarily hold together pieces of cloth. Such basting stitches are used to initially piece together a garment before sewing the final seams. After the final seams are finished, the basting is removed. Close straight stitching is a tighter type of straight stitching used for finishing the neck of shirts, the ends of sleeves, the hems of shirts and pants, or to mend torn clothes. Simple close stitching is often used for sewing clothing for babies because it is soft and does not irritate the skin. Close stitching is not so often used for adult clothing. Elderly people whom we interviewed called these types of straight stitching the stitch of the lazy. Buried straight stitching is sewn so that the thread is not visible on one side of the cloth after the seam is sewn. The needle catches only a tiny piece of the fabric of the outer layer (figures 190-191). This type of stitching is typically used to hem the ends of sleeves, the bottom of shirts, and the legs of pants.



រូបលេខ ១៩០៖ ថ្នេរដានបង្គប់ ផ្នែកខាងខុស។ (រូបថត៖ រៃយ៉ំ)

Figure 190: The buried straight stitch, seen from the wrong side of the cloth. (Photo: Reyum)



រូបលេខ ១៩១៖ ថ្នេរដានបង្គប់ ផ្នែកខាងត្រូវ។ (រូបថត៖ រៃយ៉ំ)

Figure 191: The buried straight stitch, seen from the right side of the cloth. (Photo: Reyum)

ឃើញសរសៃអំបោះ ថ្នេរនេះគេក៏និយមដេរលើចុងដៃអាវ ជាយអាវ និងជើងខោជាដើម (រូបលេខ ១៩០-១៩១)។

- ថ្នេរថយហ្វ័ង៖ ថយហ្វ័ងមានន័យថាថយក្រោយ។ ថ្នេរនេះគេចូលចិត្តប្រើ ព្រោះជាប់ជាងថ្នេរដានញឹក។ ឯរបៀបដេរមានលក្ខណៈស្មុគស្មាញជាងថ្នេរដាន ហើយក៏ប្រើអំបោះតែមួយសរសៃដែរ។ មុនដំបូងដេរទៅមុខមួយ រួចថយក្រោយមួយថ្នេរ និងដេរទៅមុខឲ្យហួសថ្នេរមុនមួយថ្នេរ គឺដេរត្រឡប់ទៅត្រឡប់មក (រូបលេខ១៩៦-១៩៨)។ ថ្នេរថយហ្វ័ងខាងត្រូវមានលក្ខណៈដូចថ្នេរម៉ាស៊ីន តែផ្នែកខាងខុសមិនដូចគ្នាទេ។ គេច្រើនដេរថ្នេរថយហ្វ័ង នៅលើតួអាវ ឬខោ ប៉ុន្តែគេច្រើនប្រើថ្នេរនេះសម្រាប់ដេរខោអាវពាក់នៅផ្ទះ ឬទៅធ្វើស្រែចម្ការ។ តែបើគេខុសប្រាហ៍ គេច្រើនដេរថ្នេរមូល ព្រោះស្អាត ហើយជាប់ល្អជាង។

The backwards stitch

This type of stitching loops backwards over itself and is often used since it is stronger than close straight stitching although it too only uses a single thread. Backwards stitching is more complicated than the simple straight stitch. One somewhat long stitch is taken going forward, then a stitch is taken backwards, covering half of the first stitch. Another forward stitch then goes past the initial stitch, so that the stitching always crosses back over itself (figure 194). On the right side of the cloth, the stitching looks like the regular stitching of a sewing machine, while on the wrong side of the cloth, the stitching crosses over itself (figures 192-194). Backwards stitching is generally used to sew together shirts or pants that are worn at home or in the fields for working.



រូបលេខ ១៩២៖ ថ្នេរថយហ្គ័ង ផ្នែកខាងត្រូវ។ (រូបថត៖ រៃយំ)

Figure 192: The backwards stitch, seen from the right side of the cloth. (Photo: Reyum)



រូបលេខ ១៩៣៖ ថ្នេរថយហ្គ័ង ផ្នែកខាងខុស។ (រូបថត៖ រៃយំ)

Figure 193: The backwards stitch, seen from the wrong side of the cloth. (Photo: Reyum)



រូបលេខ ១៩៤៖ របៀបដេរថ្នេរថយហ្គ័ង។ (រូបថត៖ រៃយំ)

Figure 194: The backwards stitch. (Photo: Reyum)

– ថ្នេរជិត៖ ដេរថ្នេរធិតដើម្បីកុំឲ្យរសាត់ សាច់ក្រណាត់ និងផ្នែកខាងត្រូវមិនឲ្យឃើញស្រវៃ អំបោះដេរ គ្រាន់តែឃើញស្នាមបន្តិចៗ។ របៀបដេរ គឺមូរចុងសាច់ក្រណាត់ដាក់ទៅក្នុង ហើយគេចាប់ផ្តើម ធិតដោយយកសាច់ក្រណាត់ខាងក្រោមប្រហែលមួយ ប្លុកពីស្រវៃមកភ្ជាប់ចុងក្រណាត់ដែលបានមូរ (រូប

Round seams are still considered better and stronger for joining pieces of cloth together.

The *chet* or small diagonal stitch

The *chet* stitch is often used to finish seams so that the cloth does not ravel. On the front of the cloth, if the stitch is done well, the thread of the stitch will be almost invisible with only a few threads of the cloth taken up by it. Generally, the edge of the cloth that is to be finished is folded or rolled over slightly. The single cloth just below this fold is pricked to pick up one or two threads of the cloth; the needle then goes through the bottom of the rolled cloth, securing the two together with tiny, slightly diagonal stitches (figure 195). The *chet* stitch is used on collars, sleeve ends, and hems of shirts, as well as for finishing the edges of *krama*.



រូបលេខ ១៩៥៖ ថ្នេរធិត ផ្នែកខាងខុស។ (រូបថត៖ រៃយ៉ំ)

Figure 195: The *chet*, or diagonal stitch, seen from the wrong side of the cloth. (Photo: Reyum)

លេខ១៩៥) ដោយចាក់ម្ជុលរាងបញ្ចិតបន្តិច ហើយចេះតែធ្វើបែបនេះរហូត។ គេច្រើនប្រើថ្នេរនេះធិតចំកអាវ, ចុងដៃអាវ, ជាយអាវ, ជាយក្រមាជាដើម។

– ថ្នេរម្ជុល៖ ស្តាប់ចាស់ៗនិយាយថា ថ្នេរដែលខ្មែរនិយមប្រើជាងគេគឺថ្នេរម្ជុល។ ថ្នេរម្ជុលប្រើសម្រាប់ដេរលើតួអាវ និងតួខោ គេអាចដេរបាននៅលើក្រណាត់គ្រប់ប្រភេទ។ ប្រយោជន៍របស់ថ្នេរនេះ គឺស្អាត ជាប់មាំ មិនរសាត់សាច់ក្រណាត់។ ដើម្បីដេរថ្នេរនេះគេប្រើម្ជុលតូចមាស ព្រោះម្ជុលនេះតូចធ្នាមិនធ្វើឲ្យសាច់ក្រណាត់ប្រហោងធំ ហើយដេរថ្នេរបានតូចល្អ។ ការដេរថ្នេរនេះត្រូវអត់ធ្មត់ច្រើន ព្រោះគេប្រើថ្នេរបីប្រភេទ (ដេរបីដង) គឺមានថ្នេរដានសាក ថ្នេរថយហ្គ័ង និងថ្នេរធិត។ របៀបដេរថ្នេរនេះ មុនដំបូងគេដានសាកឲ្យត្រង់ចោលសិន (ដើម្បីភ្ជាប់ក្រណាត់កុំឲ្យរអិលចុះឡើង និងពេលបត់ក្រណាត់ស្រួលដេរថ្នេរ

The round seam

The round seam was the most popular kind of seam used in the past for sewing clothing, according to our elderly interviewees. This type of seam was used to sew the seams of shirts or pants made from all types of cloth. The round seam was considered a beautiful and strong seam which secured the cloth of the garment from running or raveling. To sew this kind of seam, they used a needle with a golden eye, a brand of needle which was small and sharp, allowing for small stitching that did not make large holes in the fabric. Sewing round seams demanded great patience since this type of seam required three separate stitches: basting, backwards stitching, and *chet* stitching.

To make a round seam, the two pieces of fabric that were to be joined by the seam were first basted together with long loose straight stitches (figure 196).[2] The edge of the basted together fabric was then folded to one side, along the line of the basting (figure 197), and a row of backwards stitching was added running parallel just below this fold (figure 198). The front of the backwards stitching faces the opposite side from the folded cut cloth ends (figure 199). The edges of the

[2] This basting held the two pieces of cloth together for the next step of backward stitching; after the backward stitching was completed, the basting was removed.



រូបលេខ ១៩៦៖ ថ្នេរដានសាក។ (រូបថត៖ រៃយ៉ំ)

Figure 196: Basting the two sides together. (Photo: Reyum)



រូបលេខ ១៩៧៖ បត់ក្រណាត់តាមថ្នេរដាន។ (រូបថត៖ រៃយ៉ំ)

Figure 197: Folding to one side along the line of the basting. (Photo: Reyum)



រូបលេខ ១៩៨៖ ថ្នេរថយហ្គ័ងខាងខុស ដេរមកដាយក្រណាត់បត់។ (រូបថត៖ រៃយ៉ំ)

Figure 198: The backwards stitching seen from the side onto which the cut cloth ends have been folded. (Photo: Reyum)



រូបលេខ ១៩៩៖ ថ្នេរថយហ្គ័ង ដែលយើងមើលទៅម្ខាងទៀត។ (រូបថត៖ រៃយ៉ំ)

Figure 199: The backwards stitching seen from the side opposite to the one onto which the cut cloth ends have been folded. (Photo: Reyum)

ថយហ្គ័ងបានស្មើល្អផង។ ពេលដេរថយហ្គ័ងរួច គេនឹងហូតថ្នេរនេះចេញ) (រូបលេខ១៩៦)។ បន្ទាប់មកគេបត់ក្រណាត់តាមស្នាមដាន (រូបលេខ១៩៧) ហើយដេរថ្នេរថយហ្គ័ងជាន់ពីលើឲ្យកៀកនឹងស្នាមបត់ (រូបលេខ ១៩៨–១៩៩)។ រួចគេចៀរដាយក្រណាត់ដោយប្រយ័ត្នឲ្យមកកៀកថ្នេរថយហ្គ័ង តែគេមិនចៀរម្តងស្រេចទេ គឺ

folded cloth on the back side were cut off, just below the line of backwards stitching. Only small sections of the cloth edges were cut off at a time, and the final *chet*, or tiny diagonal stitches, were sewn to anchor the top of the fold to the cloth just below the line of backwards stitching, tucking the cut edge



រូបលេខ ២០០៖ ថ្នេរមូល ផ្នែកខាងខុស។ គេបត់ក្រណាត់រួចដេរធិត ឲ្យផ្នែកថ្នេរជេយហ្គ័ងខាងខុសនៅខាងក្នុងថ្នេរធិត។ (រូបថត៖ រៃយ៉ំ)

Figure 200: Sewing the round seam using *chet* stitching to pull the cut edges of cloth and the line of backwards stitching inside the seam. (Photo: Reyum)



រូបលេខ ២០១៖ ថ្នេរមូល ផ្នែកខាងត្រូវ។ (រូបថត៖ រៃយ៉ំ)

Figure 201: The finished round seam seen from the right side of the garment. (Photo: Reyum)

ចៀរបណ្តើរដេរធិតបណ្តើរ ដើម្បីកុំឲ្យក្រណាត់រសាត់។ ចៀរក្រណាត់ចេញបានបន្តិច គេចាប់ផ្តើមដេរថ្នេរធិតដោយធ្លុះក្រណាត់ផ្នែកខាងក្រោមបន្តិចមកភ្ជាប់ជាមួយក្រណាត់ផ្នែកខាងលើបន្តិច (រូបលេខ ២០០)។ ថ្នេរនេះ បើអ្នកដេរបុិនប្រសព្វ គឺដេរបានតូចឆ្នារ មើលទៅឃើញមូលនៅផ្នែកខាងខុស និងផ្នែកខាងត្រូវឃើញស្នាមអំបោះប៉ុនពងចៃមួយជួរស្មើគ្នា (រូបលេខ២០១)។

– ថ្នេរបំបែក៖ គេប្រើថ្នេរនេះសម្រាប់ដេរនៅលើដៃអាវបំពង់វែង ព្រោះដៃអាវនេះ គេច្រើនដេរតូចរឹបជាប់សាច់ បើដៃអាវរឹបដៃពេក គេអាចពុះថ្នេរនេះជាពីរ ហើយមិនធ្វើឲ្យរសាត់សាច់ក្រណាត់។ ថ្នេរនេះប្រើសម្រាប់ដេរភ្ជាប់សំពត់សម្លុយហូលផងដែរ។ របៀបដេរថ្នេរបំបែកមុនដំបូងគេយកជាយសងទៅរបណ្តើរដេរធិតបណ្តើរ ដើម្បីកុំឲ្យក្រណាត់រសាត់។ ចៀរក្រណាត់ចេញបានបន្តិច គេចាប់ផ្តើមដេរថ្នេរធិតដោយធ្លុះក្រណាត់ផ្នែកខាងក្រោមបន្តិចមកភ្ជាប់ជាមួយក្រណាត់ផ្នែកខាងលើបន្តិច (រូបលេខ ២០០)។ ថ្នេរនេះ បើអ្នកដេរបុិនប្រសព្វ គឺដេរបានតូចឆ្នារ មើលទៅឃើញមូលនៅផ្នែកខាងខុស និងផ្នែកខាងត្រូវឃើញស្នាមអំបោះប៉ុនពងចៃមួយជួរស្មើគ្នា (រូបលេខ២០១)។

inside the seam and thus preventing the cloth from unraveling (figure 200). If the sewer was skilled, the resulting seam made a smooth round line with tiny marks of the *chet* stitching visible in one straight line (figure 201).

The separated seam

The separated seam was similar to the round seam, only both edges of the joined cloth were not folded over to the same side. First the two pieces of cloth were basted together by a line of loose straight stitching (figure 202). The two cut edges of cloth were folded down away from this seam on either side, and a row of small backwards stitching was added just below this fold, thus sewing through both sides of the cloth and both folded edges (figure 203). The edges of cloth



រូបលេខ ២០២៖ ថ្នេរដោនសាក។ (រូបថត៖ រៃយ៉ំ)

Figure 202: Basting the two sides together. (Photo: Reyum)



រូបលេខ ២០៣៖ បំបែកក្រណាត់ដោយដេរថ្នេរថយហ្គ័ន។ (រូបថត៖ រៃយ៉ំ)

Figure 203: The cut edges are folded back on each side and then all four layers of cloth are sewn together using the backward stitch. (Photo: Reyum)

ខាងនៃក្រណាត់មកដាក់លើគ្នា រួចដេរដោនសាក (រូបលេខ២០២)។ បន្ទាប់មកព្រែកក្រណាត់ជាពីរ ហើយបត់ទៅម្ខាងៗ រួចដេរថ្នេរថយហ្គ័នសង្កត់ពីលើឲ្យខិតមកជិតកន្លែងបត់ព្រែក (រូបលេខ២០៣)។ ដំណាក់កាលបន្ទាប់មកទៀត ចៀរក្រណាត់ឲ្យមកកៀកថ្នេរថយហ្គ័ន ហើយចាប់ដេរធិត គឺគេធ្វើដូចថ្នេរមូលដែរ។ គេធ្វើបែបនេះដដែលនៅផ្នែកម្ខាងទៀត (រូបលេខ ២០៤)។ ក្រោយពីដេររួចយើញហាក់ដូចជាមានថ្នេរមូលពីរនៅទន្ទឹមគ្នា ភ្ជាប់គ្នាដោយថ្នេរថយហ្គ័ន។

ថ្នេរដោន ថ្នេរធិត នៅមានប្រើរហូតដល់សព្វថ្ងៃ ព្រោះម៉ាស៊ីនដេរមិនអាចជំនួសបាន។ ចំពោះថ្នេរថយហ្គ័ន នៅមានប្រើខ្លះ ពិសេសអ្នកនៅស្រុកស្រែអ្នកក្រ ដែលគេនៅដេរខោអាវស្លៀកដោយខ្លួនឯង និងដោយសារគេគ្មានលុយជួលជាងដេរម៉ាស៊ីន។

extending below this line of backwards stitching were trimmed away, and the edges of the seam on both sides were finished with small diagonal *chet* stitches as described for the round seam (figure 204). The resulting separated seam consisted of two adjoining round seams held together in the middle by the line of backwards stitching (figure 204).

The various types of straight stitches and the *chet*, or diagonal stitch, are still used today. The backwards stitch is also still used, particularly by people in the countryside and poor people who sew their own clothes because they do not have the money to hire a seamstress to make clothes for them using a machine. The round and separated types of seams have almost completely disappeared from use since these are difficult seams to



ផ្នែកខាងខុស

The cloth end on each side of the seam is trimmed and finished with *chet* or diagonal stitches.



ផ្នែកខាងត្រូវ

The finished seam seen from the right side.

រូបលេខ ២០៤៖ ថ្នេរបំបែក។ (រូបថត៖ រៃយ៉ំ) Figure 204: The separated seam. (Photo: Reyum)

ប៉ុន្តែថ្នេរមូល និងថ្នេរបំបែកវិញ លែងឃើញមានប្រើទៀតហើយ ដោយសារថ្នេរទាំងពីរនេះពិបាកដេរ និងត្រូវចំណាយពេលយូរ។ យើងមិនដឹងថាថ្នេរមូល និងថ្នេរបំបែក ខ្មែរមានប្រើតាំងពីពេលណាមកទេ។ នៅពេលដែលមានម៉ាស៊ីនដេរចូលមក ថ្នេរនេះចាប់ផ្តើមបាត់បង់បន្តិចម្តងៗ។ ម្យ៉ាងដោយសារគេមានម៉ាស៊ីនផុង មិនឲ្យរសាត់ក្រណាត់។ ថ្នេរមូលគេអាចដេរដោយម៉ាស៊ីនបាន គ្រាន់តែមិនបានស្អាត ហើយតូចដូចដេរដៃ តែដេរបានរហ័សជាងដេរដោយដៃ។ ថ្នេរមូលដែលដេរដោយម៉ាស៊ីន គេមិនហៅថ្នេរមូលទៀតទេ គេហៅថាថ្នេរត្រឡប់។ សព្វថ្ងៃមនុស្សដែលមានអាយុ៤០ឆ្នាំឡើង នៅស្គាល់ថ្នេរមូលខ្លះ តែថ្នេរបំបែកគេលែងស្គាល់ទៅហើយ មានតែមនុស្សដែលមានអាយុ៦០ឆ្នាំឡើងដែលភាគច្រើនស្គាល់ និងខ្លះនៅចេះដេរថ្នេរទាំងពីរនេះ។

make and require a lot of time. We do not know when the round and separated seams first came into use, but they began to disappear when sewing machines appeared that could make equally strong seams. A type of round seam can be made on the machine much faster than by hand. Today, those under the age of forty will generally have heard of the round seam, but will not necessarily have heard of the separated seam. Only among the elderly, above the age of sixty, do most women remember the two seams and still know how to sew them.

១- ជាងដេរ

ជាទូទៅរហូតដល់ឆ្នាំ១៩៥០ ខ្មែរមានទម្លាប់កាត់សម្លៀកបំពាក់ជាប្រពៃណី និងមានលក្ខណៈជាគ្រួសារ។ តាមសម្តីចាស់ៗបាននិយាយប្រាប់ថា មានតែជាកំង និងយួន ដែលមានបើកហាង ហើយមានតែនៅទីក្រុង ឯហាងកាត់ដេរខ្មែរគ្មានទេ។ បើគេចង់កាត់ខោអាវ គេទៅពឹងអ្នកចេះកាត់ឲ្យជួយកាត់ គឺគេពឹងពាក់គ្នាទៅវិញទៅមក ដោយយកខោអាវដែលកាត់ហើយនោះមកដេរដៃខ្លួនឯង។ បើអ្នកនោះចង់បានខោអាវដែលមានថ្នេរស្អាត គេយកទៅពឹងអ្នកដែលមានថ្នេរដៃស្អាតឲ្យដេរ តែចាស់ៗនិយាយថា ការពឹងនេះត្រូវឲ្យលុយគេ ដែលផ្ទុយពីការកាត់ខោអាវ។ ការកាត់ដេរនោះធ្វើតាមទម្លាប់បុរាណ ពោលគឺមិនប្រើម៉ែត្រដូចឥឡូវទេ គឺគេវាស់កាត់ខោអាវដោយស្មានប្រើតែចម្ងាម និងក្តាប់សម្រាប់វាស់ ឬយកក្រណាត់មកវាស់លើខ្លួនផ្ទាល់។ ជួនកាលគេកាត់តាមគំរូអាវចាស់ដែលមានពីមុនមក ឬក៏ទៅខ្ចីអាវអ្នកណាម្នាក់ដែលសមល្មមនឹងខ្លួនគេ រួចយកអាវនោះទៅធ្វើជាគំរូឲ្យជាងកាត់តាម។ ម្យ៉ាងទៀតពេលនោះម៉ូតខោអាវក៏មិនសូវមានច្រើន ដូច្នេះមិនពិបាកក្នុងការកាត់ដេរដែរ។ គ្រួសារខ្លះមានញាតិចាស់ទុំដែលចេះកាត់ដេរ គេក៏ពឹងពាក់ឲ្យជួយកាត់ដេរសម្លៀកបំពាក់ឲ្យ។ ឧទាហរណ៍ លោកយាយជួ សារឿន អាយុ៧៧ឆ្នាំ នៅខេត្តព្រៃវែង និយាយថា "ខ្ញុំកាត់ដេរខោអាវតែខ្លួន

Sewers

Up until the 1950s, sewing was not yet really a full-time job or an established profession. Most women in those days simply made the clothes necessary for their family's use. According to our elderly interviewees, there were only a few French and Vietnamese tailors who opened sewing shops in urban areas. In those days, those who made clothing (mostly women) learned to cut cloth and sew clothing from their parents or relatives. Those skilled at cutting cloth were asked by neighbors to help in cutting clothing which the neighbors then sewed by themselves. If one wanted particularly beautiful seams, one would ask those known to sew well for help. According to our elderly interviewees, early on, people who sewed well began to ask for money for their seams, while cutting cloth remained a skill that was done as a favor to neighbors. At that time, they did not yet have standardized measuring systems, instead using their outstretched hands or their clenched fists as measuring devices, in addition to simply hanging the cloth on the intended wearer and using their body as a measure. Sometimes clothes were made from an old example, or people would borrow a piece of clothing from someone else of similar size to use as a model. In those days, there were not as many styles of

ឯងមិនដែលជួលគេទេ។ ពីដើមគ្មានជាងឯណាទេ គ្រាន់តែរកអ្នកណាដែលចេះកាត់ ជួយកាត់គ្នាទៅ។ ជួននៅស៊ីបាយផ្ទះអ្នកកាត់នោះមួយពេលផង។ បើដេរដូចអាវវែងអី ចង់បានថ្នេរស្អាតយកមកជួលគេដេរ ថ្លៃឈ្នួល៥កាក់ ដេរបួនទៅប្រាំថ្ងៃមិនទាន់រួចផង។ ហើយអ្នកគេជួលដេរនោះច្រើនតែអ្នកអត់ការងារធ្វើ ដូចជាអ្នកនៅក្នុងម្ជុំជាដើម (ចូលម្ជុំ)។ ពីដើមយើងអត់មានម៉ែត្រទេ កាត់ខោអាវគ្មានអ្នកណាគេវាស់ទេ។ បើកាត់អាវវែង យកក្រណាត់មកវាស់លើខ្លួន វាស់ស្មា និងសម្រុងខ្លួនប៉ុណ្ណា គឺគេហែកចំណាំ។ អាវគ្មានម៉ូតច្រើនទេ ហើយខោគ្មានដាក់ឡវទេ មានតែខោថ្នេរ៥ ថ្នេរ៣"។ ចំណែកលោកតាជា រ័ត្ន អាយុ៩០ឆ្នាំ នៅស្រុកពញាឮ ខេត្តកណ្តាល និយាយថា "ពីដើមច្រើនតែស្លៀកខ្មៅ ពាក់ខ្មៅពេលតាចង់កាត់អាវ ទៅកាត់នៅភ្នំពេញ"។ ក្នុងទសវត្ស១៩៣០ នៅក្រុងភ្នំពេញ ក្មេងស្រីមួយចំនួនតូចបានចូលរៀនដូចជាសាលាម៉ាលីកា, សាលាជ៉ាវី, សាលាសុធាវសជាដើម មានបង្រៀនវិជ្ជាមេផ្ទះ។ ក្នុងនោះមានបង្រៀនដេរជ៉ាក់ និងកាត់ដេរផង ហើយរបៀបកាត់ដេរ ខុសប្លែកពីរបៀបបុរាណ មានប្រើម៉ែត្រសម្រាប់វាស់។

ចាប់ពីទសវត្ស១៩៥០-៦០ នៅតាមសាលាមានបញ្ចូលមេរៀនវិជ្ជាមេផ្ទះក្នុងកម្មវិធីសិក្សាដោយមានបង្រៀនវិជ្ជាកាត់ដេរដែរ។ នៅក្នុងឆ្នាំ១៩៤៩ សមាគមសហជីវនីបានបង្កើតគណៈកម្មការ៨ ក្នុង

clothing, so cutting cloth for clothing was still a relatively simple affair.

Some families had elderly members who would cut and sew clothing for the entire family. For example, Ju Saroeun, 77 years old living in Prey Veng Province, told us, "I cut my own clothing. I never paid anyone to do it. Earlier, there weren't people sewing for money. We would only go and find someone who knew how to cut cloth and ask them to help us. Sometimes we would go and eat at the cutter's house once [because we were cutting an outfit]. If you wanted a long shirt with beautiful seams, then you could pay someone to sew it. The price was 5 *kak* and it would take them four or five days to sew it. Those who sewed for money were generally those who didn't have any work to do, especially girls *chol mlup* [a period of confinement at the beginning of puberty]. Earlier, we didn't use meters. When cutting cloth for clothing, they didn't measure it. If they were cutting cloth to make a long shirt, they would hold the cloth on the intended wearer, measuring the actual shoulder width and height of the person, and tearing the cloth accordingly. There weren't many styles of shirts. Pants didn't have buttons then, only five or three seams." Chea Rot, 90 years old living in Kandal Province, told us, "Earlier, we mostly wore black. When I wanted to have a shirt made, I went to Phnom Penh to have it cut."

នោះក៏មានគណៈកម្មការរៀបចំសម្លៀកបំពាក់ ដើម្បី
ជួយពន្យល់ពីសុជីវធម៌ និងរបៀបស្លៀកពាក់ឲ្យបាន
សមស្របតាមសម័យកាល។ គេមានចេញជា
ទស្សនាវដ្តី ដែលមានបង្រៀនពីរបៀបកាត់ដេរ
សម្លៀកបំពាក់តាមក្បួន ដែលគេបានកំណត់មក ដូច
ជាទស្សនាវដ្តីនារីជាដើម។ វិធីបែបនេះមានតែអ្នក
រៀនសូត្រចេះអក្សរ ទើបមើលយល់អាចធ្វើបាន។
ចំពោះអ្នកដែលមិនចេះអក្សរ នៅប្រើវិធីកាត់ដេរ
តាមទម្លាប់ចាស់ដដែល។ នៅក្នុងទសវត្ស១៩៦០
មានសាលាបង្រៀនកាត់ដេរឯកជនជាច្រើន បាន
បង្កើតឡើង មានទាំងនៅទីក្រុង និងនៅតាមខេត្ត។

រូបលេខ ២០៥៖ ជាងកាត់ដេរសម័យ។ ស្រង់ពីសៀវភៅ"វិជ្ជាកាត់
ដេរដោយខ្លួនឯង" ដោយអ៊ាប-ប៊ុនសុត ទសវត្ស១៩៦០។

Figure 205: A seamstress in the 1960s. (Photo: *Sewing by yourself*, by Aap Bun Soth, 1960s)

In the 1930s in Phnom Penh, a small number of girls were sent to schools such as the Malika, the Pavie, and the Sothearos Schools. In these schools, they were taught housekeeping skills which included embroidery and sewing. The ways of cutting and sewing clothes which they were taught in these French influenced schools were different from traditional ways of making clothes found in local Khmer communities, and they were considered a modern method which used the metric system of measuring.

After independence, secondary school curriculums began to include lessons in sewing as well. In 1949, the Association of Women established four committees, one of which was a clothing committee. This committee was supposed to explain and promote proper attire and comportment appropriate to the times. Magazines such as *Neary* appeared which included set patterns for cutting certain styles of clothing. These documents were of course only accessible to women who had studied and could read; those who could not read continued to make clothing in the traditional ways. In the 1960s, private sewing schools were established in stores, both in the city and in the provinces. Om Yuem, 64 years old living in Siem Reap Province, told us, "When I was 19 years old [probably around 1958], I went to study cutting and sewing clothes in Siem Reap at a



រូបលេខ ២០៦៖ របៀបវាស់អាវតាមបែបទំនើប។ ស្រង់ពីសៀវភៅ"វិជ្ជាកាត់ដេរដោយខ្លួនឯង" ដោយអ៊ាប-ប៊ុន-សុត។ ទសវត្ស១៩៦០។

Figure 206: The way to measure a shirt using modern methods. (*Sewing by yourself*, by Aap Bun Soth, 1960s)

វិធីវាស់អាវសុង

តារាងវាស់ "ខ្នាតគំរូ"

លេខរៀង	ប្រភេទវាស់ត្រូវវាស់	វាស់ជាន	ចំនួនចេញ	ចែកនឹង	ត្រូវស់ សំរាប	សេចក្តីផ្សេង ។
១	ទទឹងក	36 សម.	ភ្នាន	6	6 សម.	
២	ដើមទ្រូង	88 សម.	,,	4	22 សម.	
៣	បន្ថែម	–	–	–	–	មិនចាំបាច់វាស់ក៏បានដែរ
៤	ទ្រមាក	88 សម.	,,	4	22 សម.	
៥	ស្មា	40 សម.	,,	2	20 សម.	
៦	បន្ទាត់ដេរ	19 សម	,,	2	9 សម. 5	
៧	ជុំវិញដៃ	28 សម.	ភ្នាន	2	14 សម.	
៨	ទទឹង	26 សម.	–	2	13 សម.	
៩	ទទឹងក្រៅ (សរសៃខាង)	36 សម.	2	2	17 សម.	
៩ស្តួច	ទទឹងក្រៅ (សរសៃខាង)	36 សម.	4	2	16 សម.	
១០	សំរុងវាស	58 សម.	ភ្នាន	ភ្នាន	58 សម.	
១១	សំរុងបន្ថែមក្រោយ	–	–	–	–	
១២	សំរុងបន្ថែមមុខ	–	–	–	–	មិនចាំបាច់វាស់ទេ
១៣	ជំរះក្រវាត	–	–	–	–	
១៤	សំរុងដេរ	23 សម.	ភ្នាន	ភ្នាន	23 សម.	
១៥	សំរុងដៃ	16 សម.	ភ្នាន	ភ្នាន	16 សម.	

រូបលេខ ២០៧៖ តារាងបង្ហាញពីរបៀបវាស់អាវតាមបែបទំនើប។ ស្រង់ពីសៀវភៅ "វិជ្ជាកាត់ដេរដោយខ្លួនឯង" ដោយអ៊ាប-ប៊ុន-សុត។ ទសវត្ស១៩៦០។

Figure 207: A chart of shirt measurements for sewing a shirt. (*Sewing by yourself*, by Aap Bun Soth, 1960s)

លោកយាយអ៊ុំ យឿម អាយុ៦៤ឆ្នាំ នៅខេត្តសៀមរាប និយាយថា "នៅអាយុ១៥ឆ្នាំ (ប្រហែលឆ្នាំ១៩៥៨) បានទៅរៀនកាត់ដេរនៅសៀមរាបនៅហាងឈ្មោះ បុទ្ធីសែន ជាហាងបើកបង្រៀនកាត់ដេរមុនគេនៅសៀមរាប"។ ពេលនោះមានសៀវភៅបង្រៀនកាត់ដេរដោយខ្លួនឯង និងមានសៀវភៅភាសាឡុកជារបស់ខ្មែរ។ ទាំងអស់នេះធ្វើឲ្យវិស័យកាត់ដេរតាមរបៀបថ្មីនៅស្រុកខ្មែរកាន់តែរីកចម្រើន ហើយរបៀបកាត់ដេរតាមទម្លាប់ចាស់ក៏ចាប់បាត់បង់ជាបណ្តើរៗ។ រហូតមកដល់សព្វថ្ងៃ នៅមានអ្នកកាត់ដេរតាមរបៀបនោះតិចណាស់ ហើយភាគច្រើនជាមនុស្សចាស់ (ដូចជាលោកយាយមុំច ដែលមានអាយុ៨៩ឆ្នាំ គាត់ប្រើរបៀបកាត់អាវតាមបែបបុរាណសម្រាប់ពាក់ខ្លួនឯង)។

គ- ហាងកាត់ដេរ

នៅឆ្នាំ១៩០៧ ក្រុងបាត់ដំបងមិនទាន់មានជាងកាត់ដេរតាំងយីហោដូចសព្វថ្ងៃទេ[៣] គេជួលកាត់ដេរខោអាវនៅតាមផ្ទះ។ ជាងកាត់ដេរល្បីឈ្មោះនៅតាមភូមិ ភាគច្រើនដេរខោអាវដោយដៃ។ តែពេលនោះគេឃើញមានម៉ាស៊ីនដេរវៃដោយដៃ ពុំមែនធាក់ដោយជើងដូចសព្វថ្ងៃទេ ហើយក៏ប្រើត្រស់វែង មិនមែនត្រស់មូលដូចសព្វថ្ងៃនេះដែរ។ ចំណែកនៅក្រុង

store called Rithy Sain which was the first place to start teaching sewing." There also started to be books on learning to sew by oneself, as well as Khmer language catalogues of various fashions. All of these developments made sewing change rapidly, and traditional ways of measuring and sewing began to disappear. Today, very few people make clothing in the traditional way and those who do are elderly. For example, Mich, 89 years old, still cuts shirts following the traditional methods for her own use.

Sewing stores and tailors

In Battambang in1907, there was not yet a professional sewer who had put out a shop sign.[3] Instead, those who were known as cloth cutters and sewers worked out of their homes, sewing clothing by hand. There were some sewing machines already which ran by a hand wheel rather than by the foot pedal common today. In Phnom Penh and in other provincial population areas it was probably not much different than in Battambang; local Khmer cloth cutters and sewers did not generally put out signs or rent stores separate from their homes. Those skilled at cutting and

[3] Tauch Chhuong, *Battambang during the time of the Lord Governor,* East West Center, Hawaii, 1994.

[៣] តូច ឈួង "បាត់ដំបងសម័យលោកម្ចាស់" ភ្នំពេញ, ១៩៩៤។

ភ្នំពេញនិងខេត្តក្រុងផ្សេងទៀតក៏មិនខុសពីនៅក្រុងបាត់ដំបងដែរ គឺជាទូទៅជាងដេរខ្មែរមិននិយមតាំងយីហោទេ។គេច្រើនតែដេរនៅផ្ទះរបស់គេ ហើយចេះតែដឹងឮតាគ្នានៅក្នុងភូមិ គេក៏មកជួលកាត់ដេរខោអាវ។ ខោអាវដែលគេយកមកជួលឲ្យកាត់មានដូចជា អាវចិន, ខោចិន, អាវបំពង់ដែង, អាវសន្ទះ, អាវម៉ាទីណាជាដើម។ ចំពោះហាងកាត់ដេរដែលមានតាំងយីហោវិញ តាមការសម្ភាសន៍លោកយាយមុម សំអឿន អាយុ៧៧ឆ្នាំ និយាយថា "ហាងកាត់ដេរតាំងយីហោនៅស្រុកខ្មែរមុនដំបូង ភាគច្រើនជាហាងរបស់យួន (ច្រើនតែពួកយួនវៀតពីតុងគីង) ហើយកាត់តែខោអាវរបស់មនុស្សប្រុស កាត់តាមគំរូអាវអឺរ៉ុប ដូចជា

រូបលេខ ២០៨៖ ហាងកាត់ដេរម៉ែន ប៉ិច (ដកស្រង់ចេញពី ខសន្ទារវត្តី អ្នកជាតិនិយម ឆ្នាំ១៩៥០, បណ្ណសារដ្ឋានជាតិ)។

Figure 208: Advertisement for the Men Pich Tailor Store in *The Nationalist*, 1950. (National Archives of Cambodia)

sewing clothes were known by word of mouth within their village. The clothing which these cutters and sewers were hired to make included Chinese shirts, Chinese pants, the long tube shirt, the *santeh* shirt, and the *matinet* shirt. According to Mom Samuen, 77 years old living in Phnom Penh, "The first shops to put out signs advertising themselves as commercial tailors were owned by Vietnamese. They only cut clothing for men based on European models such as the *ouvert* shirt. Women's clothing at that time was still ordered from Khmer sewers working out of their houses. When I was grown up [in the 1940s], there began to be stores sewing women's clothing as well. The well known stores were mostly owned by Vietnamese, and these stores made fashionable clothing, not clothing following traditional Khmer styles. The most famous stores were *Femme Chique* and *Meilleure Lingerie*." Traditional clothing like the long tube shirt and the Chinese shirt were still being made by Khmer seamstresses in their homes, which were unmarked by shop signs. In the 1950s, Khmer seamstresses and tailors began to advertise their services and put signs in front of their shops and homes; the number of tailors and sewing establishments increased steadily throughout the Sangkum Reastr Niyum Period. Om Yuem told us, "Later on [in the 1960s], I opened a sewing store in Srok Puk. I called it

អាវអ៊ូវែរជាដើម។ ចំណែកអាវមនុស្សស្រី គឺជួលជាងខ្មែរនៅតាមផ្ទះកាត់ដដែល។ តែនៅពេលដែលខ្ញុំធំពេញវ័យ (ប្រហែលទសវត្ស៤០) ទើបមានហាងកាត់ដេរសម្លៀកបំពាក់មនុស្សស្រី។ ចំពោះហាងដែលល្បីឈ្មោះ ច្រើនជារបស់យួន ហើយហាងទាំងនោះកាត់តែខោអាវម៉ូតទាន់សម័យ មិនកាត់ខោអាវប្រពៃណីខ្មែរទេ។ ហាងទាំងនោះមានដូចជាហាងកាត់ដេរ ហ្វាមស៊ីច *(Femme Chique)*, ម៉ីយីឡង់សេរី *(Meilleure Lingerie)* ជាដើម"។ តាមលោកយាយមុម សំអឿន ឲ្យយើងដឹងថា មុនទសវត្ស១៩៤០ មានតែហាងកាត់ដេរខោអាវមនុស្សប្រុស។ លុះមកដល់ទសវត្ស១៩៤០ ទើបមានហាងកាត់ដេរខោអាវមនុស្សស្រី ហើយកាត់តែខោអាវទាន់សម័យ។ ចំណែកអាវបំពង់វែង ឬអាវចិនជាដើមនៅតែកាត់ជាងខ្មែរ ដែលគ្មានផ្ទាកយីហោដដែល។ រហូតដល់ទសវត្ស១៩៥០ ទើបចាប់ផ្តើមឃើញមានជាងកាត់ដេរខ្មែរ តាំងយីហោឡើងជាបណ្តើរៗ។ មកដល់សម័យសង្គមកាស្ត្រនិយម ហាងតាំងយីហោមានកាន់តែច្រើនឡើងៗ។ លោកយាយអ៊ុំ យៀម និយាយថា "ក្រោយមក (ប្រហែលទសវត្ស ១៩៦០) ខ្ញុំបានបើកហាងកាត់ដេរនៅស្រុកពួកឈ្មោះ ហាងកាត់ដេរទំនើប។ មានតែហាងខ្ញុំបើកមុនគេ"។

រហូតមកដល់សព្វថ្ងៃ នៅមានជាងដេរខ្លះមិនតាំងយីហោដែរ ក្នុងគំនិតរបស់គេ គឺគេមិនចង់ចេញមុខចេញមាត់។ ម្យ៉ាងទៀតប្រជាជនខ្មែរ ភាគច្រើនមិនសូវហ៊ានចូលកាត់ដេរខោអាវនៅហាងតាំង

the Modern Sewing Store. I was the first to put out a sign and establish a store there." Even today, some seamstresses work out of their unmarked homes. Perhaps they refuse to advertise out of a wish not to show off their skill. Also local people generally tended to think that ordering clothing from a store with a sign will be more expensive than clothing ordered from unmarked sewers' homes. When commissioning clothing, the client sometimes drew a picture of the clothing they wanted. Other times they looked at catalogues and picked from the clothing pictured in them, or they asked the sewer or store owner to pick a style of clothing for them.



រូបលេខ ២០៩៖ ផ្ទះកាត់ដេរស៊ូលីដា (ដកស្រង់ចេញពីទស្សាវដ្តី អ្នកជាតិនិយម ឆ្នាំ១៩៥០, បណ្ណសារដ្ឋានជាតិ)។

Figure 209: The sewing house Su Ly Da. *The Nationalist*, 1950 (National Archives of Cambodia)

យីហោទេ ព្រោះគេគិតថាហាង់ទាំងនោះយកតម្លៃឈ្នួលថ្លៃជាង់ហាង់ដែលមិនតាំង់យីហោ។ ឯម៉ូតខោអាវអ្នកដែលមកជួលកាត់ដេរ ខ្លះគេគួរគំរូអាវ ខ្លះមើលតាមកាតាឡុក ខ្លះទៀតជាង់កាត់ដេរលើសម៉ូតឲ្យ។

ឃ- ម៉ាស៊ីនដេរ

លោកយាយមុម សំអឿន និយាយថា "នៅពេលខ្ញុំដឹង់ក្តីឡើង (ទសវត្ស១៩៣០) នៅផ្ទះរបស់ខ្ញុំឃើញមានម៉ាស៊ីនដេររួចហើយ គឺមានទាំង់ម៉ាស៊ីនដេរជាក់ជើង និង់ម៉ាស៊ីនដេរវៃដៃ"។ ចំណែកលោកយាយសួង ម៉ាលី និយាយថា "ម៉ាស៊ីនដេរមិនសូវសម្បូណ៌ប៉ុន្មានទេ អ្នកដែលមានម៉ាស៊ីនដេរប្រើពេលនោះ ច្រើនតែអ្នកមាន និង់អ្នកមានឋាន:ខ្ពស់ក្នុង់សង្គម។ ចំណែកនៅតាមខេត្តទាល់តែផ្ទះចៅហ្វាយស្រុក ផ្ទះអុង់ច៉ាង់ជាដើម ទើបមានម៉ាស៊ីនដេរប្រើ។ លោកអ៊ំរបស់ខ្ញុំ ជាចៅហ្វាយស្រុក ពេលខ្ញុំធំដឹង់ក្តីផ្ទះគាត់មានម៉ាស៊ីនដេរហើយ។ ម៉ាស៊ីនដេរនោះចាស់ហើយមិនដឹង់ថាគាត់មានតាំង់ពីពេលណាទេ"។ តាមការចង់ចាំទាំង់នេះ យើង់ស្មានថាម៉ាស៊ីនដេរចូលមកស្រុកខ្មែរប្រហែលជាតាំង់ពីដើមសតវត្សទី២០ គ្រាន់តែមិនសូវសម្បូណ៌ គឺមានតែនៅតាមផ្ទះអ្នកមាន និង់តាមហាង់កាត់ដេរធំៗ។ មកដល់សម័យសង្គមរាស្ត្រនិយមទើបមាននាំចូលម៉ាស៊ីនដេរកាន់តែច្រើន។ នៅពេលនោះគេមិនហៅម៉ាស៊ីនដេរទេ គេហៅយន្តដេរ

Sewing Machines

Mom Samuen told us, "When I was a teenager [in the 1930s], our house already had sewing machines. We had one run by a foot pedal and another one run by turning a wheel with a handle by hand." Suong Mali told us, "There weren't many sewing machines then. The people who had sewing machines at that time were rich people and high officials. In the provinces, it was only the house of the provincial leader and the Chinese who had sewing machines to use. My grandfather was a provincial leader and when I was a teenager, his house had a sewing machine already. That machine was old already, and I don't know how long he had had it."

According to these recollections, we can assume that sewing machines had already come to Cambodia in the early 20th century. At first there weren't many machines and only rich households or tailor shops had them. During the Sangkum Reastr Niyum Period, many sewing machines were imported into the country. At that time, they didn't call them *machine de* using the French word *machine* with the Khmer term for sewing as they do today; instead they called them *yun de*, using a Sanskrit word for machine. Early sewing machines were generally of the Singer brand and were imported from France. Chay Lim Khim, 82 years old, told us, "Before they

ដែលមានត្រាសាំងហ្សឺរ នាំមកពីប្រទេសបារាំង។ លោកយាយធាយ លីមយីម អាយុ៨២ឆ្នាំ និយាយថា "ពីមុនគេហៅយន្តដេរ តែមានក្រណាត់ល្អយកទៅដេរយន្តហើយ"។ លោកយាយឌួក អាយុ៨២ឆ្នាំ នៅខេត្តព្រៃវែង មានប្រសាសន៍ថា "យាយបានមកទិញម៉ាស៊ីនដេរពីភ្នំពេញទុកឲ្យកូនស្រីយាយដេរនៅផ្ទះ។ ពេលយាយទំនេរពីធ្វើស្រែ បានយកខោអាវដែលកូនដេររួច ដើរលក់តាមភូមិ ខ្លះយកស្រូវមកដូរខ្លះទិញជាលុយ។ នៅភូមិរបស់យាយ មានតែផ្ទះយាយទេដែលមានម៉ាស៊ីនដេរប្រើមុនគេ"។ មកដល់ទសវត្ស ១៩៦០ នៅភ្នំពេញ និងទីប្រជុំជននានាមានម៉ាស៊ីនដេរប្រើកាន់តែច្រើនឡើងវា។

called them *yun de*, and anything made of good cloth would be taken to be sewn by machine." Duock, 82 years old living in Prey Veng Province, told us, "I bought a sewing machine from Phnom Penh for my daughter to use when sewing at home. When I was free, and wasn't working in the rice fields, I would take the clothing my daughter had sewn and walk through the villages selling it. Some people gave me rice in exchange, while others bought the clothes with money. My house was the first one in our village to have a sewing machine." It was only in the 1960s, that many sewing machines came to be used, particularly in households in Phnom Penh.

រូបលេខ ២១០៖ ការដេរដោយម៉ាស៊ីន។ ស្រង់ពីសៀវភៅ "វិជ្ជាកាត់ដេរដោយខ្លួនឯង" ដោយអ៊ាប-ប៊ុនសុត ទសវត្ស១៩៦០។

Figure 210: Using a sewing machine. (*Sewing by yourself*, by Aap Bun Soth, 1960s)

ដំណឹងពីក្រសួងឧស្សាហកម្មពាណិជ្ជកម្ម

(កាសែតកម្ពុជា លេខ១៧៥៦, ថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៥១)

ភ្នំពេញ- មានជនជាច្រើនរកទិញយន្តដេរ "ត្រាសាំងហ្សឺរ" មិនបានដោយពុំមានដល់ថ្មីមកទៀត។ ក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មសូមជម្រាបមហាជនថា យន្តដេរត្រានេះនិងមានដល់មកទៀតក្នុងពេលឆាប់ៗនេះ បើជនឯណាត្រូវការសូមទៅចុះឈ្មោះនៅហាងលុយស៊ីយ៉ា លេខ៣០-៣២មហាវិថីឌូដាដីឡាក្រ ភ្នំពេញ។ យន្តដេរទាំងនេះ ប្រហែលជានឹងមកដល់នៅខែកក្កដាក្រោយនេះហើយ នឹងចែកជាលំដាប់មុនក្រោយតាមកាលបរិច្ឆេទនៃសំបុត្រដែលចុះឈ្មោះ។ ចំពោះថ្ងៃដែលដាក់លក់ក្រសួងពាណិជ្ជកម្មនិងឧស្សាហកម្មនឹងផ្សាយជូនដឹងថ្ងៃក្រោយ។

Announcement by the Ministry of Industry and Commerce explaining that a new shipment of sewing machines is expected. *Kampuchea*, January 9th, 1951.

ជ- អំបោះ

- អំបោះធ្វើពីសរសៃធាង់ម្នាស់ ៖ នៅពេលជប៉ុនចូលមកស្រុកខ្មែរ ភាគច្រើននៅក្នុងប្រទេសខ្វត់សម្លៀកបំពាក់ ដោយសារពេលនោះមានសង្គ្រាមលោកលើកទី២កើតឡើង ធ្វើឲ្យការទំនាក់ទំនងខាង់ពាណិជ្ជកម្មមានការពិបាក។ ម្យ៉ាង់ក៏មិនសូវមានអ្នកដាំកប្បាស ដោយសាររាជការទារពន្ធថ្លៃលើដំណាំផ្សេង់ដែលប្រជាជនដាំដុះ។ មានការហាមដាំកប្បាស និង់ត្បាញពីសំណាក់រាជការចាក់ង់ផង និង់ខ្លាចប្រជាជនលក់ផលិតផលនេះឲ្យជប៉ុន។ រហូតដល់ពេលដែលជប៉ុនមកគ្រប់គ្រង ទើបមានការធូរស្រាលឡើង់វិញ។ ហេតុនេះទើបពេលដែលខោអាវរហែក គេច្រើនប៉ះទុកប្រើបន្ត។ ពេលនោះនៅតំបន់ខ្លះក៏ខ្វត់អំបោះធ្វើអំពីកប្បាសដែរ ទើបគេយកធាង់ម្នាស់មកធ្វើជាអំបោះប៉ះខោអាវ។ សរសៃធាង់ម្នាស់នេះ គេយកមកប្រើសម្រាប់ប៉ះខោអាវតែប៉ុណ្ណោះ ដោយសារមានសរសៃខ្លី និង់មិនសូវមាំ។

មុនបានជាសរសៃ ត្រូវយកធាង់ម្នាស់ស្រស់មកចៀរបន្ទាសង់ខាង់ចេញ ហើយយកចានមកគោស រួចទាញសរសៃមកច្បូតឲ្យស្អាតរៀបបញ្ចូលគ្នា២-៣សរសៃ ទើបរូតនឹង់ក្រមួន ហើយយកទៅដេរលើសាច់ក្រណាត់។

ខាង់ក្រោមនេះជាការធ្វើបង្ហាញពីរបៀបយកសរសៃធាង់ម្នាស់របស់លោកយាយស៊ីម សារិន អាយុ៧៦ឆ្នាំ នៅខេត្តព្រៃវែង។ បើតាមសម្តីរបស់

Thread

Thread from pineapple frond

When the Japanese occupied Cambodia during World War II, there was a shortage of clothing since the war largely cut off commercial exchange with the outside. In the country, not that many people grew cotton at that time since government officials extracted high taxes on various crops. Some people told us of a ban on growing and weaving cotton during the early 1940s, perhaps enforced because French officials were worried that people would sell cotton and cloth to the Japanese. According to these elderly interviewees, when the Japanese administered the Protectorate for a brief period in 1945, things became a little bit easier. Clothing remained in short supply, however, and old ripped clothing was usually repeatedly repaired and worn. Cotton thread was scarce in some areas during this time as well, so villagers began to use the fibers of pineapple fronds as thread with which to mend their clothing. This pineapple frond thread was usually only used to mend clothing since it was generally quite short and not so strong.

In order to make the thread, a green fresh pineapple frond was first trimmed to remove the barbs on both sides. The frond

គាត់និយាយថា "នៅពេលខ្ញុំអាយុ១០ឆ្នាំ ខ្ញុំឃើញ យាយខ្ញុំយកធាង់ម្នាស់មកធ្វើជាអំបោះដេរ។ បើមិន យកសរសៃធាង់ម្នាស់ទេ គេហូតយកអំបោះពីរឹម ក្រណាត់សម្រាប់ដេរដែរ។ ចំពោះអំបោះហុងគាត់មិន ដែលឃើញឡើយ"។ (រូបលេខ២១១-២១៧)។



រូបលេខ ២១១៖ ដំបូងគេចៀរបន្ទាសង់ខាងធាង់ម្នាស់ចេញ។ (រូបថត៖ រៃយ៉ំ)

Figure 211: Trimming barbs off both sides of the pineapple frond. (Photo: Reyum)

រូបលេខ ២១២៖ បន្ទាប់មកគេយកចានកោសស៊ើរាលើធាង់ម្នាស់។ (រូបថត៖ រៃយ៉ំ)

Figure 212: Scraping the pineapple frond. (Photo: Reyum)

was scraped with ceramic shards, or rubbed across the bottom of an overturned clay dish or a hard surface until the individual fibers detached and could be grasped by the fingers and rubbed smooth. Several fibers were wound and twisted together and rubbed with wax before using them as thread to patch clothing. In the following pictures, we offer a demonstration by Sim Saren, 79 years old living in Prey Veng Province.

According to Sim Saren, "When I was ten years old, I saw my grandmother making thread from pineapple frond. In addition to pineapple fronds, they sometimes used threads unraveled from edges of cloth in order to mend clothes. I never saw rolls of thread in those days."



រូបលេខ ២១៣៖ រួចចាប់ផ្តើមប្រមូលយកសរសៃធាង់ម្នាស់។ (រូបថត៖ រៃយ៉ំ)

Figure 213: The detached fibers are pulled up. (Photo: Reyum)

រូបលេខ ២១៤៖ គេចាប់ហូតទាញយកសរសៃឆ្មារចេញ។ (រូបថត៖ រៃយ៉ំ)

Figure 214: The fibers are pulled away from the frond. (Photo: Reyum)

រូបលេខ ២១៥៖ បានសរសៃហើយគេយកក្រណាត់មកជូតឲ្យស្អាត។ (រូបថត៖ រៃយ៉ំ)

Figure 215: Using a cloth to smooth and clean the fibers. (Photo: Reyum)

រូបលេខ ២១៦៖ គេយក២-៣សរសៃវេញបញ្ចូលគ្នាដើម្បីឲ្យមាំល្អ រួចយកមកូតក្រមួនដើម្បីងាយស្រួលដេរ។ (រូបថត៖ រៃយ៉ំ)

Figure 216: Two or three fibers are wound together to make a stronger thread. This twisted fiber is rubbed with wax so that it will enter the cloth easily. (Photo: Reyum)

រូបលេខ ២១៧៖ ប៉ះខោអាវដោយប្រើសរសៃធាង់ម្នាស់។ (រូបថត៖ រៃយ៉ំ)

Figure 217: Sim Saren demonstrating how to mend a shirt using pineapple frond thread. (Photo: Reyum)

– អំបោះឆៅ៖ កប្បាសអាចយកមកត្បាញធ្វើជាក្រណាត់, ក្រមាជាដើម។ ក្រៅពីត្បាញគេអាចយកមកធ្វើជាអំបោះដេរលើខោអាវក៏បានដែរ គេតែងហៅថាអំបោះឆៅ។ អំបោះឆៅនេះមិនសូវមាំ ហើយមានសរសៃធំ មិនដូចអំបោះនីឡុង

Raw cotton thread

Cotton was woven into cloth for shirts, pants, *sampot*, and *krama*. Cotton also was made into a thread called raw cotton which was not very strong. Homespun cotton thread was quite thick, not like the thread

ដែលនាំចូលពីបរទេសឡើយ។ ចំពោះសម្លៀកបំពាក់ធម្មតា គេច្រើនយកអំបោះឆៅមកដេរ។ លោកយាយ នោង អាយុ៨២ឆ្នាំ នៅខេត្តសៀមរាប រៀបរាប់ថា ដើម្បីធ្វើអំបោះឆៅ គឺគេយកកប្បាសទុំមកបកសម្បកចេញ ហើយយកសាច់សំឡីទៅហាលមួយថ្ងៃឬពីរថ្ងៃឲ្យស្ងួត ទើបគេប្រឡេះយកគ្រាប់ចេញពីសំឡី។ បានជាសំឡីហើយ គេយកទៅត្រសុសឲ្យស្ទើគ្នាល្អកុំឲ្យដិបរដុប រួចគេចាប់ជាដុំតូចៗជារមូរប្រវែងមួយចំអាមៗ ហើយហូតចេញជាសរសៃប្រវែងប្រហែលពីរចំអាមយកទៅរុំនឹងត្រសាលដែក។ ដៃឆ្វេងកាន់សំឡី ដៃស្តាំកាន់រហាត់ (ធ្វើពីឫស្សី) រំវៃឲ្យចេញជាអំបោះ។ អំបោះដែលបានហើយ គេយកទៅរំវៃដាក់ក្នុងហុងទុកប្រើ។ មុននឹងដេរ គេយកអំបោះទៅរូតនឹងក្រមួនសិន ដើម្បីកុំឲ្យសរសៃអំបោះជំពាក់គ្នា។

wound on rolls imported from abroad. Raw cotton thread was generally used for sewing ordinary working clothes. Nong, 82 years old living in Siem Reap Province, described to us how cotton thread was made by hand. Ripe cotton was picked and then pounded to remove its husk. The cotton was dried in the sun for a day or two. Seeds were then picked out of the cotton and the cotton fibers were fluffed and spread evenly. Small clumps of cotton were rolled and pulled into strands about one *chom am* in length. These lengths were then pulled out to be two *chom am* in length and were wound onto a metal shuttle. A *rohat,* or wheel made of bamboo, was used to spin the thread. Spun thread was wound onto rolls and stored for sewing. Raw cotton thread was first rubbed with wax before using

រូបលេខ ៦១៨៖ កប្បាសនៅតំបន់អណ្តើកហែប ខេត្តបាត់ដំបង។ ថតទស្សវត្ស១៩៥០។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 218: Picking cotton in Battambang Province, 1950s. (Photo: National Archives of Cambodia)



រូបលេខ ៦១៩៖ លោកយាយនោងកំពុងរំវៃកប្បាសធ្វើអំបោះឆៅ។ (រូបថត៖ រៃយ៉ំ)

Figure 219: Nong spinning raw cotton thread in 2003. (Photo: Reyum)

នៅតំបន់ខ្លះក្រៅពីអំបោះផៅ ឬអំបោះធ្វើពីសរសៃធាតុម្នាស់ គេក៏យកសរសៃធាតុចេកងាប់ សរសៃក្រណាត់ចាស់ អំបោះរឹមក្រណាត់ មកដេរ ឬប៉ះសម្លៀកបំពាក់បានដែរ។

it to sew; this ensured that the thread would not tangle.

In some regions, in addition to raw cotton thread and thread made from pineapple frond, thread was also made from the fibers of dead banana leaves or from strings pulled from old bags or unraveled cloth.

ខ- ខ្នាត

ខ្មែរមានរបៀបវាស់តាមបែបបុរាណដែលអាស្រ័យទៅលើដងខ្លួនមនុស្ស ដោយប្រើខ្នាតស្មូង, ហត្ថ, ចំអាម, ទោម, ក្តាប់ ។ល។ ហើយវិធីវាស់តាមខ្នាតបុរាណនេះ នៅមានប្រើរហូតដល់សព្វថ្ងៃ។

- ហាត្ថ៖ គេវាស់ពីកួយដៃដល់ចុងម្រាមដៃតណ្តាល។ មួយហត្ថមានប្រវែងប្រហែល០,៤០ម៉ែត្រ ទៅ០,៥០ម៉ែត្រ (រូបលេខ២២០)។

- ត្បូង៖ ជាខ្នាត ដែលមានប្រវែង១០ ហត្ថ (ប្រហែល៥ម៉ែត្រ)។

- ចំអាម៖ គេវាស់ពីចុងមេដៃដល់ចុងម្រាមដៃតណ្តាល។ មួយចំអាមមានប្រវែងប្រហែល ០,២០ម៉ែត្រ ទៅ០,២២ម៉ែត្រ (រូបលេខ២២១)។

- ក្តាប់៖ គេក្តាប់ដៃ ហើយវាស់ពីខាងក្នុងដៃដល់ខាងមេដៃ។ មួយក្តាប់មានប្រវែងប្រហែល ៧-៨សង់ទីម៉ែត្រ (រូបលេខ២២២)។

- ទោម៖ គេវាស់ពីចុងមេដៃដល់ចុងម្រាមចង្អុលដៃ។ មួយទោមមានប្រវែងប្រហែល០,១៨ ម៉ែត្រទៅ០,១៩ម៉ែត្រ (រូបលេខ២២៣)។

Units of measure

Before the French Protectorate, Khmer used traditional units of measure which made use of parts of the body. These types of measurements were not standardized, and varied slightly depending on the size of the person measuring. Even today, these traditional ways of measuring are still sometimes used. Traditional measures include:

Hot

The length from the elbow to the tip of the middle finger. One *hot* is approximately 40 to 50 centimeters (figure 220).

Tbong

Ten *hot* (or about 5 meters).

Chom am

The length of the outstretched hand, from the tip of the thumb to the tip of the middle finger (figure 221). One *chom am* is approximately 20 to 22 centimeters.

Kdap

The length of a fist measured across (figure



រូបលេខ ២២០៖ មួយហត្ថ។

Figure 220: One *hot*.



រូបលេខ ២២១ ៖ មួយចំអាម។

Figure 221: One *chom am*.

រូបលេខ ២២២ ៖ មួយក្តាប់។

Figure 222: One *kdap*.



រូបលេខ ២២៣៖ មួយទោម។

Figure 223: One *dome*.

ចំពោះក្រណាត់មួយអាវស្មើនឹង៤ហត្ថ (ប្រហែល១,៦ម៉ែត្រទៅ២ម៉ែត្រ) ដោយសារគេគិតទៅលើអាវបំពង់វែងដែលប្រើក្រណាត់អស់២ម៉ែត្រ។ តែបើហត្ថមនុស្សខ្លីមិនគ្រប់២ម៉ែត្រ គេត្រូវថែម១ចំអាមទៀតទើបគ្រប់១អាវ។ បើសំពត់គេនិយមនិយាយថា សំពត់៤ហត្ថ ឬ៧ហត្ថ (សំពត់៤ហត្ថគេគិតលើសំពត់សម្លូយ ហើយសំពត់៧ហត្ថគេគិតទៅលើសំពត់ក្បិន)។

ក្រោយពីបាកាំងមកគ្រប់គ្រង គេបានបង្ខំខ្មែរឲ្យប្រើប្រាស់ខ្នាតតាមបាកាំង តាមរយៈ"ដេក្រែនលោកវេស៊ីដង់ស៊ីបពេរីយើ" ចុះថ្ងៃទី១៣ មិថុនា ឆ្នាំ

222). One *kdap* is approximately 7 to 8 centimeters.

Dome

The length of the outstretched hand from the thumb to the tip of the pointing finger (figure 223). One *dome* is approximately 18 to 19 centimeters.

Elderly people told us that, traditionally, cloth for one shirt was called four *hot*, since the shirt to be made was a long tube shirt which used almost two meters of cloth. If the person measuring cloth was small, they would add one *chom am* to any measurement in order to ensure that there

was sufficient cloth to make the long tube shirt. For making a *sampot*, people would say they needed four *hot* or seven *hot* (four *hot* for a *sampot* worn in the *samloy* style and seven *hot* for a *sampot* tied in the *kben* style).

After the French established their Protectorate, metric ways of measuring were introduced and decrees announced that local inhabitants should use them.[4] The Khmer did not, however, begin to use the new metric system of measurement, and another circular dated May 4, 1925 and distributed to the provinces, urged authorities to publicise and implement the new measuring system in order to make the transition from the Khmer measuring system complete. Still people did not forget the traditional ways of measuring. In the city and markets, the French system of measuring gradually became a convention. In the remote countryside, however, the Khmer system of measuring continued to be used. This meant that when clothing was cut, size was still measured using the *hot*, the *chom am*, the *dome*, and the *kdap*.

Tools used for measuring in the French manner included the wooden meter stick, sometimes called the *sampot metre*, the meter tape, and the folding meter stick. The

[4] Decree of the Résident Superieur, June 13, 1914 and Royal Decree by King Sisowath, December 29, 1914. This and the following decree of May 4, 1925 are quoted in *About measurements and weights used in Cambodia 1967-1968* by Saik Chnou Som.

១៩១៨ និងប្រកាសអនុវត្តជាផ្លូវការដោយព្រះរាជបញ្ញត្តិ ចុះថ្ងៃទី២៩ ធ្នូ ឆ្នាំ១៩១៨ នៃព្រះមហាក្សត្រខ្មែរ ព្រះបាទស៊ីសុវត្ថិ។ ប៉ុន្តែខ្មែរមិនបានអនុវត្តតាមឡើយ។ ក្រោយមកបារាំងបានចេញសារាចរមួយទៀតលេខ៣៦ ចុះថ្ងៃទី៤ ឧសភា ឆ្នាំ១៩២៥ រំលឹកដល់រេស៊ីដង់នៅភ្នំពេញ និងតាមខេត្តនានាឲ្យខិតខំយកចិត្តទុកដាក់ក្នុងការផ្សាយ និងចាត់ការឲ្យអនុវត្តឲ្យបានហ្មត់ចត់ចំពោះការផ្លាស់ប្តូរពីរបៀបខ្មែរនេះ។[4] ទោះបីជាយ៉ាងណាក៏ខ្មែរមិនអាចបំភ្លេចរបៀបវាស់ប្រវែងតាមបុរាណបានដែរ។ នៅក្នុងក្រុង តាមទីផ្សារគេបានអនុវត្តការវាស់តាមខ្នាតបារាំង ដោយសារមានគេទទួលស្គាល់ច្រើន។ ប៉ុន្តែចំពោះប្រជាជនដែលនៅតាមខេត្តឆ្ងាយៗ នៅតែនិយមវាស់តាមរបៀបខ្មែរនៅឡើយ។ នៅពេលត្រូវការកាត់សម្លៀកបំពាក់ គេតែងស្មានតាមហត្ថ, ចំអាម, ទោម, ក្តាប់ របស់គេផ្ទាល់។

ខ្នាតបារាំងដែលគេប្រើសម្រាប់វាស់សំពត់មាន ម៉ែត្របន្ទាត់ (ធ្វើពីឈើ) ម៉ែត្រសំពត់ ជួនគេមានប្រើម៉ែត្របត់ដែរ (រូបលេខ២២៤-២២៦)។ មានពួកឈ្មួញក្រណាត់មួយចំនួនបានប្រើដំបូងគេបង្អស់។ បន្តិចម្តងៗទើប ខ្មែរប្រើតាមខ្លះ ដោយយល់ថាមានប្រវែងច្បាស់លាស់ជាងការវាស់លើដៃមនុស្ស។ ពិសេសមានគេទទួលស្គាល់ជាទូទៅផង។

[4] សេក-ឆ្នៅ-សុំម "សិក្ខាឯកសេខនា" អំពីរង្វាស់រង្វាល់ និងទម្ងន់ដែលប្រើប្រាស់នៅប្រទេសកម្ពុជា ឆ្នាំ១៩៦៧-៦៨។

រូបលេខ ២២៤៖ ម៉ែត្របន្ទាត់ ឬម៉ែត្រឈើ។

Figure 224: Metric ruler.



រូបលេខ ២២៦៖ ម៉ែត្រសំពត់។

Figure 226: Metric measuring tape.

ជ- កន្ត្រៃ

ចាស់ៗនិយាយច្រាប់ថា កាលជំនាន់គាត់នៅក្មេង គេប្រើកន្ត្រៃធ្វើពីដែក (រូបលេខ២២៧)។ លោកយាយមុិច អាយុ៨៥ឆ្នាំ និយាយថា "កន្ត្រៃពីដើមធ្វើពីដែក អត់មានកន្ត្រៃមុខសដូចឥឡូវទេ ធំក៏មាន តូចក៏មាន ហើយមានជាងខ្មែរធ្វើកន្ត្រៃ, កាំបិត, ពូថៅ ច្រើននៅតាមភូមិស្រុក។ ចំណែកភូមិរបស់យាយក៏មានជាងម្នាក់ដែរដែលចេះធ្វើ"។



រូបលេខ ២២៧៖ កន្ត្រៃដែក។ (រូបថត៖ រៃយ៉ំ)

Figure 227: Metal scissors (Photo: Reyum)



រូបលេខ ២២៥៖ ម៉ែត្របត់។

Figure 225: Folding metric measuring stick.

first to make use of such tools were the *sampot* merchants. Slowly others followed their lead since they found the French system of measuring to be more precise than using parts of the human body for measuring. In addition, the French measuring system was recognised internationally.

Scissors

In the past, scissors were made from metal (figure 227). According to Mich, 88 years old, "In the old days, scissors were made of metal and there weren't scissors with white blades [shiny stainless steel cutting blades] like today. Scissors came in big and small sizes, and there were many Khmer craftsmen in the villages who made scissors, knife blades, and ax blades. My village had someone who knew how to make them too."

was sufficient cloth to make the long tube shirt. For making a *sampot*, people would say they needed four *hot* or seven *hot* (four *hot* for a *sampot* worn in the *samloy* style and seven *hot* for a *sampot* tied in the *kben* style).

After the French established their Protectorate, metric ways of measuring were introduced and decrees announced that local inhabitants should use them.[4] The Khmer did not, however, begin to use the new metric system of measurement, and another circular dated May 4, 1925 and distributed to the provinces, urged authorities to publicise and implement the new measuring system in order to make the transition from the Khmer measuring system complete. Still people did not forget the traditional ways of measuring. In the city and markets, the French system of measuring gradually became a convention. In the remote countryside, however, the Khmer system of measuring continued to be used. This meant that when clothing was cut, size was still measured using the *hot*, the *chom am*, the *dome*, and the *kdap*.

Tools used for measuring in the French manner included the wooden meter stick, sometimes called the *sampot metre*, the meter tape, and the folding meter stick. The

[4] Decree of the Résident Superieur, June 13, 1914 and Royal Decree by King Sisowath, December 29, 1914. This and the following decree of May 4, 1925 are quoted in *About measurements and weights used in Cambodia 1967-1968* by Saik Chnou Som.

ឆ្នាំ១៩១៤ និងប្រកាសអនុវត្តជាផ្លូវការដោយព្រះរាជបញ្ញត្តិ ចុះថ្ងៃទី២៩ ធ្នូ ឆ្នាំ១៩១៤ នៃព្រះមហាក្សត្រខ្មែរ ព្រះបាទស៊ីសុវត្ថិ។ ប៉ុន្តែខ្មែរមិនបានអនុវត្តតាមឡើយ។ ក្រោយមកបារាំងបានចេញសារាចរមួយទៀតលេខ៧៦ ចុះថ្ងៃទី៤ ឧសភា ឆ្នាំ១៩២៥ រំលឹកដល់រេស៊ីដង់នៅភ្នំពេញ និងតាមខេត្តនានាឲ្យខិតខំយកចិត្តទុកដាក់ក្នុងការផ្សាយ និងចាត់ការឲ្យអនុវត្តឲ្យបានហ្មត់ចត់ចំពោះការផ្លាស់ប្តូរពីរបៀបខ្មែរនេះ។[4] ទោះបីជាយ៉ាងណាក៏ខ្មែរមិនអាចបំភ្លេចរបៀបវាស់ប្រវែងតាមបុរាណបានដែរ។ នៅក្នុងក្រុង តាមទីផ្សារគេបានអនុវត្តការវាស់តាមខ្នាតបារាំង ដោយសារមានគេទទួលស្គាល់ច្រើន។ ប៉ុន្តែចំពោះប្រជាជនដែលនៅតាមខេត្តឆ្ងាយៗ នៅតែនិយមវាស់តាមរបៀបខ្មែរនៅឡើយ។ នៅពេលត្រូវការកាត់សម្លៀកបំពាក់ គេតែងស្មានតាមហត្ថ, ចំអាម, ទោម, ក្តាប់ របស់គេផ្ទាល់។

ខ្នាតបារាំងដែលគេប្រើសម្រាប់វាស់សំពត់មាន ម៉ែត្របន្ទាត់ (ធ្វើពីឈើ) ម៉ែត្រសំពត់ ជួនគេមានប្រើម៉ែត្របត់ដែរ (រូបលេខ២២៤-២២៦)។ មានពួកឈ្មួញក្រណាត់មួយចំនួនបានប្រើដំបូងគេបង្អស់។ បន្តិចម្តងៗទើប ខ្មែរប្រើតាមខ្លះ ដោយយល់ថាមានប្រវែងច្បាស់លាស់ជាងការវាស់លើដៃមនុស្ស។ ពិសេសមានគេទទួលស្គាល់ជាទូទៅផង។

[4] សេក-ឆ្នោវ-សុំម "សិក្ខាឯកសេខនា" អំពីរង្វាស់រង្វាល់ និងខ្នាតដែលប្រើប្រាស់នៅប្រទេសកម្ពុជា ឆ្នាំ១៩៦៧-៦៨។



រូបលេខ ៦២៤៖ ម៉ែត្របន្ទាត់ ឬម៉ែត្រឈើ។

Figure 224: Metric ruler.



រូបលេខ ៦២៦៖ ម៉ែត្រសំពត់។

Figure 226: Metric measuring tape.

ជ- កន្ត្រៃ

ចាស់ៗនិយាយច្រាប់ថា កាលជំនាន់គាត់នៅក្មេង គេប្រើកន្ត្រៃធ្វើពីដែក (រូបលេខ៦២៧)។ លោកយាយមុំច អាយុ៨៩ឆ្នាំ និយាយថា "កន្ត្រៃពីដើមធ្វើពីដែក អត់មានកន្ត្រៃមុខសដូចឥឡូវទេ ធំក៏មាន តូចក៏មាន ហើយមានជាងខ្មែរធ្វើកន្ត្រៃ, កាំបិត, ពូថៅ ច្រើននៅតាមភូមិស្រុក។ ចំណែកភូមិរបស់យាយក៏មានជាងម្នាក់ដែរដែលចេះធ្វើ"។



រូបលេខ ៦២៧៖ កន្ត្រៃដែក។ (រូបថត៖ រៃយ៉ំ)

Figure 227: Metal scissors (Photo: Reyum)



រូបលេខ ៦២៥៖ ម៉ែត្របត់។

Figure 225: Folding metric measuring stick.

first to make use of such tools were the *sampot* merchants. Slowly others followed their lead since they found the French system of measuring to be more precise than using parts of the human body for measuring. In addition, the French measuring system was recognised internationally.

Scissors

In the past, scissors were made from metal (figure 227). According to Mich, 88 years old, "In the old days, scissors were made of metal and there weren't scissors with white blades [shiny stainless steel cutting blades] like today. Scissors came in big and small sizes, and there were many Khmer craftsmen in the villages who made scissors, knife blades, and ax blades. My village had someone who knew how to make them too."

៨- ម្ជុល

ក្នុងភាសាខ្មែរបុរាណ គេហៅថា "អញ្ជុល" សម្រាប់សម្គាល់ពាក្យម្ជុល។ តាមឯកសារជីវតាខ្វាន់ បានសរសេរថា ខ្មែរមិនចេះធ្វើម្ជុលប្រើទេ គេប្រើតែម្ជុលដែលចិនយកមកលក់តែប៉ុណ្ណោះ។ រហូតដល់បច្ចុប្បន្ន ខ្មែរនៅតែមិនធ្វើម្ជុលប្រើដដែល គឺច្រើនយកមកពីស្រុកយួន។ បើតាមការស្មាន គេមិនធ្វើម្ជុលអាចមកពីខ្មែរគ្មានបច្ចេកទេសផលិត ឬមកពីសម្លៀកបំពាក់ប្រពៃណីខ្មែរមិនតម្រូវឲ្យដេរ ដូចជាសំពត់ក្បិនសម្ពុយជាដើម។ នៅពេលត្បាញរួច គេគាត់យកមកស្លៀកដោយមិនចាំបាច់ដេរក៏បានដែរ។

ពីមុន គេច្រើនប្រើម្ជុលគូទមាស ដែលមានភ្នែកតូចធ្នាវ ហើយគូទតូចពណ៌ក្រហមដូចមាស។ គេនិយមប្រើម្ជុលគូទមាសសម្រាប់ដេរលើក្រណាត់ល្អ ដូចជាក្រណាត់មុយអា ហូល ជាមួងជាដើម។ ម្ជុល



រូបលេខ ២២៨៖ ម្ជុល និងម្ជុលគូទមាស។ (រូបថត៖ រៃយ៉ំ)

Figure 228: A larger regular needle (middle) with two gold eye needles above and below. (Photo: Reyum)

Needles

In the past, Khmer didn't use the modern word *mjul* for needle, instead calling them *anyjul*. The 13th century Chinese traveler Chou Ta-Kuan wrote that the Khmer did not know how to make needles, but instead used needles bought from Chinese merchants. Even today, no needles are manufactured in Cambodia and most needles are imported from Vietnam. The lack of needle production is perhaps due to early types of Khmer clothing (the *sampot* tied in the *kben* and *samloy* style) which were simple lengths of cloth, woven and then wrapped around the body, not requiring sewing.

The most popular needle when clothing was still sewn by hand was the golden eye needle (the needle had a golden eye) which was small and sharp. It was particularly used to sew good fabrics such as *prai muy a*, *hol*, and *pamuong*. This type of needle could make beautiful seams which were almost invisible. The golden eye needle was also used to sew intricate sequins onto dance costumes. In addition to the golden eye needles, there was another kind of needle which was slightly larger and was used to sew ordinary work clothing made from common fabrics such as *pa dip*.

នេះ ពេលដេរធ្វើឲ្យថ្នេរល្អិតស្អាតហើយស្មើមើលពុំ
ឃើញ និងអាចប្រើដើម្បីដេរទិនដៃរ។ ក្រៅពីមូលតួទ
មាសក៏មានមូលម្យ៉ាងទៀតរាងធំជាងបន្តិច សម្រាប់
ដេរលើក្រណាត់ ឬសម្លៀកបំពាក់ធម្មតា ដូចជា
ក្រណាត់ផាឌិប ក្រណាត់ត្បាញអាយជាដើម។

ឈ– ឡេវ

រហូតមកដល់បច្ចុប្បន្ន គេនៅតែមានប្រើឡេវ
កិប, ឡេវចាន ឡេវកុំ និងឡេវខូប់ជាដើម។ ឡេវកិបធ្វើ
ពីលោហៈមានរាងមូល ម្ខាងញី ម្ខាងឈ្មោល
សម្រាប់ដាក់ភ្ជាប់នឹងសាច់សំពត់ (រូបលេខ២២៩)។
សព្វថ្ងៃ ឡេវកិបនេះគេមិនសូវប្រើឡើយ។ ឡេវចាន
មានរាងសំប៉ែត ហើយនៅកណ្តាលមានរន្ធ២ ឬ៤
សម្រាប់ដេរភ្ជាប់នឹងអាវ។ ឡេវនេះ គេធ្វើពីត្រឡោក
ដូង, ឈើ, ភ្នុក, មាស, ប្រាក់, ស្ពាន់។ ចំណែកឡេវ
ចានដែលធ្វើពីជ័រ ទើបតែមានប្រើនៅសម័យក្រោយ
មកទៀត (រូបលេខ២៣០)។ ឡេវកុំមានរាងមូល
ត្រមោងក៏មាន រាងស្រួចចុងបន្តិចដូចជាផ្កាម្ជិះក្រពុំក៏
មាន ធ្វើពីខ្សែអំបោះឬពីក្រណាត់សម្រាប់ពាក់
បញ្ចូលក្នុងអន្លាក់កុំ (រូបលេខ២៣១)។ ឡេវខូប់ គឺ
គេកាត់ក្រណាត់រាងមូលយកមកខូប់ឡេវចាន (ទំហំ
តាមការស្រឡាញ់) ដោយមានញាត់សំឡីតឲ្យណែន
(សំឡីតល្អជាងសំឡីកប្បាស ព្រោះមិនសូវជក់ទឹក)
ហើយដេរដានជុំវិញ រួចទាញរួតដេរប្រទាក់ឲ្យណែន

Buttons

Buttons used in the past which still remain in use today include the *keb* button, the *chan* button, the *kdom* button, and the *kjop* button. *Keb* buttons were round and made of metal with a male and female side that snapped together (figure 229). *Chan* buttons were flat with two holes in the middle for attaching them to the cloth. *Chan* buttons were made of coconut shell, wood, ivory, gold, silver, and brass. Later on, *chan* buttons were also made from plastic (figure 230). *Chan* buttons required a hole in the facing cloth for a buttonhole. *Kdom* buttons were shaped like round protrusions, sometimes with a pointed middle like jasmine buds. This type of button was made from cotton thread or cloth and was inserted into a noose like circle to close it (figure 231). *Kjop* or wrapped

រូបលេខ ២២៩៖ ឡេវកិប។ (រូបថត៖ ឈៃ)

Figure 229: The *keb* or snap button. (Photo: Reyum)



រូបលេខ ៦៣០៖ ឡែវចាន។ (រូបថត៖ រៃយ៉ំ)

Figure 230: *Chan* buttons. (Photo: Reyum)



រូបលេខ ៦៣១ ៖ ឡែវក្តំ។ (រូបថត៖ រៃយ៉ំ)

Figure 231: *Kdom* button. (Photo: Reyum)



រូបលេខ ៦៣២៖ ឡែវខូប់។ (រូបថត៖ រៃយ៉ំ)

Figure 232: *Kjob* buttons. (Photo: Reyum)

buttons used *chan* buttons of various sizes. To make a *kjop* button, a round piece of cloth was cut and its edges basted; the cloth was fitted on the *chan* button with the front stuffed with the cotton-like inside of the *ko* tree seed (*ko* tree seed was considered better than cotton since it did not absorb water as much). The cloth edges were tucked behind the button, drawing the basted edges together and wrapping them tightly together with



រូបលេខ ២៣៣ ៖ ឡៅធ្វើពីលោហៈមានដាំត្បូង។ (រូបថត៖ ឈៃ)

Figure 233 : Metal buttons with inset stones. (Photo: Reyum)

(រូបលេខ២៣២)។ ឡៅនេះ គេចោះរន្ធដាក់ក៏បាន ធ្វើជាតម្ពក់ក្រណាត់សម្រាប់ដាក់ក៏បាន ដោយយកក្រណាត់ប្រវែង១តឹកមកដេរជាខ្សែ រួចបត់ជាពីរដេរភ្ជាប់នឹងអាវធ្វើជាតម្ពក់។ ឡៅខ្លះមានប្រើក្រោយឡៅកិបនិងឡៅចាន។ សម័យមុន គេច្រើនទិញឡៅមកខ្លះដោយខ្លួនឯង តែបច្ចុប្បន្នមានឧបករណ៍សម្រាប់ខ្លះ។ ឡៅមួយប្រភេទទៀតធ្វើពីស្ពាន់ ខ្លះធ្វើពីប្រាក់ ឬមាស មានដាំត្បូងរាងមូលខ្ពស់ និងមានទង់សម្រាប់ភ្ជាប់នឹងអាវ ហើយលើអាវមានចោះធ្វើជារន្ធឡៅ (រូបលេខ២៣៣)។

អាវខ្លះក្រៅពីដាក់ឡៅ គេធ្វើជាខ្សែចង់ឬកន្ទាស់ដែលមានលំអជារូបសត្វផ្សេងៗ។

another thread. The noose through which the button was inserted to close it was sometimes made of cloth rolled into a yarn-like length. The *kjop* button appeared later than the *keb* and *chan* buttons. It was usually made by hand, but today there are tools for making such buttons. There was another kind of button made of brass, silver, or gold which had inset gem stones. This type of button had a back loop for attaching it to the garment (figure 233); a button hole was sewn in the facing cloth into which the button was inserted. Sometimes buttons of any of the types described here were decorated with bows or with pins in the shape of animals.

ការ ថែរក្សាសម្ភារៈ
CARING AND STORING

សព្វថ្ងៃសម្បូរណាវបស់បរទេសប្រើសម្រាប់ធ្វើគក់ ដូចជាសាប៊ូទឹក សាប៊ូម្សៅ សាប៊ូដុំ។ មិនតែប៉ុណ្ណោះ មានទាំងម៉ាស៊ីនធ្វើគក់ ឆ្នាំងអ៊ុតអគ្គិសនី ជាដើម។ ត្បិតនៅស្រុកខ្មែរសម្ភារៈធ្វើគក់ទាំងនោះមិនទាន់មាននាំចូលមកច្រើន និងមានតម្លៃថ្លៃ។ សម្ភារៈធ្វើគក់ទាំងនោះទើបតែសម្បូណ៌ក្នុងពេលបច្ចុប្បន្ននេះទេ បើស្តាប់ចាស់ៗនិយាយតាំងពីប៉ុន្មាន៥០ឆ្នាំមុនមិនសម្បូណ៌អញ្ចឹងទេ។ ឯគ្រឿងសង្ហារឹមសម្រាប់ទុកដាក់ខោអាវក៏មិនសម្បូណ៌ដែរ ដូច្នេះការធ្វើគក់និងថែទាំសម្លៀកបំពាក់នោះ ក៏គេធ្វើទៅតាមការខ្វះខាតនោះដែរ។ ពោលគឺគេប្រើកម្លាំងបាយ និងចម្រាញ់អ៊ីវពីធម្មជាតិសម្រាប់យកមកប្រើ។ ក្នុងជំពូកការថែទាំសម្លៀកបំពាក់នេះ យើងចង់ស្វែងយល់ពីរបៀបគេពីមុនមក ដោយលើកយកចំណុច៣មកបង្ហាញ គឺធ្វើគក់ ការអ៊ុត និងវិធីទុកដាក់សម្លៀកបំពាក់ឲ្យស្អាតបាត រៀបរយ និងសមរម្យ។

ក- ធ្វើគក់សម្លៀកបំពាក់

បច្ចុប្បន្នសាប៊ូមានគ្រប់ប្រភេទ នាំចូលមកពីប្រទេសថៃ, វៀតណាម, កូរេ, ចាវ៉ាំង, ជប៉ុន ។ល។ ក្រៅពីសាប៊ូ តើមានអ្វីផ្សេងទៀតដែលខ្មែរប្រើដើម្បីធ្វើគក់សម្អាតសម្លៀកបំពាក់ប្រឡាក់ញើស ក្អែល ឬធូលីផ្សេងៗ។ យើងមិនបានដឹងច្បាស់ថាសាប៊ូដុំចាប់ផ្តើមមានប្រើនៅស្រុកខ្មែរតាំងពីពេលណានោះទេ។

Today there are all kinds of commercial soaps in bar, liquid, or powder forms, as well as machines to wash and dry clothing. Modern appliances are still quite expensive in Cambodia however, and are not imported in large quantities yet. Still, readymade soaps and commercial washing products are widely available today, unlike fifty years ago. Our elderly interviewees illuminated local ways of washing, ironing, and storing clothing prior to the availability of such store-bought products.

Washing clothing

We are not sure when commerical bar soaps first became available in the region today known as Cambodia. Elderly people, over the age of seventy, told us that when they were young, there was little ready-made manufactured soap to use. Instead, people used *deuk kbong* for washing clothes. This liquid soap was made from the ash of banana peels, the ash of the *samrong* fruit, the ash of the *ko* tree, the ash of *pti* and *sankai* woods, and the ash of the male palm flower. *Deuk kbong* was used both for washing clothing as well as hair. Some people also used the ripe fruit of the palm tree to wash clothing. The late Long Than told us, "My family was very poor. We washed our clothes in pond water

បើតាមការសាកសួរពេត៌មានពីមនុស្សចាស់អាយុចាប់ពី៧០ឆ្នាំឡើងទៅ អ្នកខ្លះបានប្រាប់ឲ្យដឹងថា តាំងពីពួកគាត់នៅក្មេងវា ពុំសូវសម្បូណ៌សាប៊ូប្រើនៅឡើយ គាត្រេីនគេប្រើទឹកក្បុងធ្វើពីសម្បក ផ្លែ ឬដើមរុក្ខជាតិមួយចំនួនដូចជា៖ សម្បកផ្លែចេក, ផ្លែសំរោង, សម្បកផ្លែត, ដើមដ្តី, ដើមសង្កែ, ផ្កាត្នោតឈ្មោលជាដើម។ គេយកទឹកក្បុងមកបោកគក់ខោអាវ និងកក់សក់។ អ្នកខ្លះទៀតគេប្រើផ្លែត្នោតទុំសម្រាប់បោកខោអាវ។ ចំពោះលោកយាយឡុង តាន់ អាយុ៨៩ឆ្នាំ នៅពោធិចិនតុង និយាយថា "គ្រួសារខ្ញុំក្រណាស់ បោកខោអាវនឹងទឹកត្រពាំង អត់មានសាប៊ូបោកទេ បើនៅភ្នំពេញប្រហែលគេមានសាប៊ូ។ ខ្ញុំមិនដែលឡើងផ្សារ ឬស្គាល់ផ្សារនឹងគេទេ ដាក់ខោអាវត្រាំទឹកទៅ រួចបោក"។ អ្នកដែលជិតទីប្រជុំជន ហើយមានជីវភាពធូរធារដែរ ទើបគេអាចមានលទ្ធភាពទិញសាប៊ូប្រើ។ដូចជាលោកយាយអ៊ុន ឈុំ អាយុ៨៦ឆ្នាំ នៅព្រែកលាប ក្រុងភ្នំពេញ និយាយថា "ខ្ញុំពីក្មេងមានសាប៊ូដុំប្រើ ទាំងបោកខោអាវ និងកក់សក់។ សាប៊ូនោះមានលក់នៅផ្សារ ១ដុំថ្លៃ១សេន តែមិនទាន់មានសាប៊ូម្យ៉ាងទេ"។ លោកយាយហួន អាយុ៧៧ឆ្នាំ នៅខេត្តកំពង់ចាម រៀបរាប់ថា "ចិន (អ្នកលក់ចាប់ហួយ) មានលក់សាប៊ូដុំ ទិញទុកត្រាន់បោកខោអាវ និងដុសខ្លួន។ សាប៊ូនោះមិនក្រអូបដូចសាប៊ូឥឡូវទេ គេហៅសាប៊ូឆ្លាប ពណ៌កាឆេវឿង"។ ចំពោះជាមួងហូល ខៀនជារដើម បើសិនជាមិនប្រលាក់ក្រាយពី

and had no soap. In Phnom Penh maybe they had soap, but I never had the chance to go to the big markets. We just soaked our clothes in the pond water and then washed them." Those people who lived near urban areas and had a better standard of living could afford to buy soap to use. Oun Chum, 86 years old living near Phnom Penh, told us, "From the time I was little, we had bar soap to use for washing clothing as well as hair. That bar soap was sold in the market and one bar cost one *centime*. There were no powdered detergents yet." Huon, 77 years old living in Kompong Cham Province, told us, "The Chinese merchants were selling bar soap which we bought for washing clothes and washing our bodies. That soap didn't smell nice, like soap today. They called it *chaap* soap and it was yellow."

If *pamuong, hol, or kien* were not stained after wearing, clothing made of these fabrics was simply laid out in the sun to dry the sweat before being folded and stored. If *hol* or *pamuong* were washed, they used clear rain water rather than turbid lake or river water. Such fabrics were not frequently washed because washing aged the fabric more quickly and could make the colors run. To clean such fabrics in between washing, the *sampot* was sprinkled with water and then pressed and pulled with the hands so that it became flat and smooth. Sometimes a wet cloth was used to brush the *sampot* while

ស្ងៀកហើយ គេត្រាន់តែដាក់សំដិលឲ្យស្ងួតញើស រួចបត់ទុក។ បើសិនជាចង់ជោកហួល ជាមួងនោះ គេជោកនឹងទឹកត្នៀង ព្រោះវាថ្លាល្អ។ តែគេមិនសូវជោកទឹកញឹកញាប់ទេ ព្រោះធាប់ចាស់ និងហើរពណ៌។ ភាគច្រើនគេត្រាន់តែសម្អាតដោយបត់សំពត់ ឬសំពត់ក្បិននោះមួយផ្ដាំងល្មមងាយសម្អាតឲ្យសព្វ ហើយត្រាន់តែប្រោះទឹកបន្តិចរួចក្បឹត (យកជាតដៃសង្កត់ហើយអូសចុះឡើងលើផ្ទៃសំពត់ឲ្យរាបល្អ) ឬយកក្រណាត់ជ្រលក់ទឹកមកជូតក្បឹត។ មើលតែស្អាតហើយគេបត់មួយផ្ដាំងទៀត ដើម្បីសម្អាតបន្តទៀត។ គេចេះតែធ្វើបែបនេះរហូតចប់ម្ខាងប្រែទៅម្ខាងទៀត (សម្អាតទាំងខាងត្រូវ ទាំងខាងខុស) ទាល់តែសព្វសាច់សំពត់ឬក្បិននោះ។ រួចរាល់ហើយគេយកអន្ទង់មកតប់លើសាច់សំពត់ ឬសំពត់ក្បិននោះ ដើម្បីឲ្យសាច់ម៉ដ្ឋល្អ ទើបយកទៅហាលឲ្យស្ងួត បត់ទុក។ ចំពោះខៀនពេលប្រើយូរទៅសាច់ទន់ ពេលស្ងៀកចង់ក្បិន មិនឡើងប៉ោងល្អ ដូច្នេះគេត្រូវឲ្យជាយម្ដងទៀត។ ការឲ្យជាយគេមិនប្រើទឹកជាយទេ គេប្រើសាគូ។ គេដាំម្សៅសាគូឲ្យរលួយលែងឃើញគ្រាប់ ទុកឲ្យត្រជាក់បានយកមកក្បឹតលើខៀននោះ រួចសំដិលហាលក្នុងម្ល៉ប់។

នៅសម័យសង្គមរាស្ត្រនិយម សាប៊ូជោកគក់សម្លៀកបំពាក់សម្បូណ៌ជាងមុន ព្រោះមានចាំចូលកាន់តែច្រើន។ ទន្ទឹមនឹងនោះនៅក្នុងស្រុកក៏មានបង្កើតរោងចក្រធ្វើសាប៊ូដុំដែរ (រូបលេខ ២៣៤–២៣៦)។

pressing and smoothing it with the hands. This process of wetting and pressing was done on both sides of the cloth. An *anlong*, or wooden hammer-like beater, was sometimes used to gently pound the wetted cloth so that it became smooth. After gently pounding the *hol* or *pamuong*, it was hung out to dry before being folded and stored. *Kien* cloth, when worn for a long time, became soft and flexible and thus could no longer hold the bulging pleats of the *kben* style. To stiffen the cloth, they boiled sago palm until the seeds dissolved and were no longer visible. The mixture was allowed to cool and then was sprinkled onto the *sampot*, pressing and pulling the cloth smooth. The *sampot* was then dried in the shade.

Ironing Clothes

Clothing are generally smoothed and pressed using a hot iron. Today, in urban areas, people can iron their clothes easily using electric store-bought irons. Electricity is still not available today in large areas of the Cambodian countryside, however, and people still use old methods of smoothing and taking the wrinkles out of clothing. What methods did people use to smooth and pleat washed clothing before electricity and store-bought irons were available?



រូបលេខ ២៣៤៖ រោងចក្រសាប៊ូសម័យសង្គមរាស្ត្រនិយម។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 234: The soap factory established during the Sangkum Reastr Niyum Period.
(Photo: National Archives of Cambodia)

រូបលេខ ២៣៥៖ ផ្នែកខាងក្នុងរោងចក្រសាប៊ូ។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 235: Interior of the soap factory.
(Photo: National Archives of Cambodia)

រូបលេខ ២៣៦៖ ផ្នែកខាងក្នុងរោងចក្រសាប៊ូ។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 236: Interior of the soap factory.
(Photo: National Archives of Cambodia)

In the past, people in the countryside did not think much about ironing their clothing since their everyday work was more urgent and they did not really have nice clothes to wear. Mich, 88 years old living in Kandal Province, told us, "Before, we were very poor. Clothing was not like it is today. They patched pants so many times, and wore them for so long, that they became heavy. There were so many patches that the pants really became just patches. In one year, we would only make two pairs of clothing to wear interchangeably. There were two pairs of clothing for house wear, two pairs of clothing for working, and two pairs of clothing for ceremonial occasions, that was it. We didn't have a lot of clothes, and we didn't throw

១- អ៊ុតសម្លៀកបំពាក់

អ៊ុតមានន័យថាសង្កត់ធ្វើឲ្យរាបសាច់សំពត់ឬអាវដោយធ្នាំងក្តៅ (ធ្នាំងអ៊ុត)។ សព្វថ្ងៃអ្នកនៅទីក្រុងអ៊ុតសម្លៀកបំពាក់មានភាពងាយស្រួលដោយសារមានធ្នាំងអ៊ុតដែលប្រើដោយចរន្តអគ្គិសនី។ ចំណែកអ្នកនៅតំបន់ជនបទធ្លាយៗគ្មានប្រព័ន្ធអគ្គិសនីគេនៅតែប្រើវិធីពង្រាបខោអាវមិនឲ្យជ្រួញតាមទម្លាប់ចាស់ គឺប្រហែល៧០ ឬ៨០ឆ្នាំមុននេះ។ តើសម័យនោះគេប្រើវិធីអ្វីខ្លះដើម្បីពង្រាបសម្លៀកបំពាក់ និងធ្វើឲ្យមានផ្នត់ស្អាតល្អ?

ចំពោះអ្នកនៅជនបទស្រែចម្ការស្ទើរតែមិនបានគិតគូរ ឬយកចិត្តទុកដាក់ក្នុងការអ៊ុតសម្លៀកបំពាក់ឡើយ ព្រោះការងារប្រចាំថ្ងៃមមាញឹក និងស្ទើរតែគ្មានខោអាវល្អៗសម្រាប់ស្លៀកពាក់ផង។ លោកយាយមុិច អាយុ៨៨ឆ្នាំ នៅភូមិកោងំ ខេត្តកណ្តាល និយាយថា "ពីដើមក្រណាស់ ខោអាវមិនដូចឥឡូវទេ ខោប៉ះស្លៀកយូរទៅធ្ងន់ទៅ។ ព្រោះបំណាស់ច្រើនពេក ប៉ះសុទ្ធតែត្រួតគ្នា មួយឆ្នាំកាត់តែ២បន្ទាស់ប៉ុណ្ណោះ ដើម្បីស្លៀកពាក់ផ្ទាស់ប្តូរគ្នា។ ខោអាវនៅផ្ទះ២កំប្លេ ខោអាវស្លៀកទៅធ្វើការពីរកំប្លេ ហើយសម្រាប់ទៅបុណ្យទានពីរកំប្លេ តែប៉ុណ្ណឹង អត់មានច្រើនទេ។ ហើយមិនងាយគ្រាត់ចោលទៅណាទេ បើដូចឥឡូវតែខោអាវចាស់បន្តិចបន្តួចចោល ជាន់ថ្មីប៉ុន្មានយកមកស្លៀកទាល់តែអស់ អត់ចេះទុកដាក់ទេ។ អូ! ពីដើមប្រិតប្រៀងណាស់ រឿងអាវសំពត់អីនេះ

them away easily either. Today, clothes only have to be a little old and they get rid of them, buying lots of new clothes to wear until those are a little old too. People don't know how to keep clothing anymore. Oh! Earlier, we were very disciplined regarding clothing! One couldn't wear clothing the wrong way either [as a young woman in puberty]. Oh! My mother would beat me! My God! When we had worn a *sampot* and shirt already, we would fluff and shake them, laying them out straight to let the sweat on them dry. We would smooth them with our hands so that they were flat. If the clothes were made of *pamuong* or *hol*, we would smooth and press them carefully, sprinkling them with water to moisten them, and then stroking and pulling them straight again. Washing clothing often made them get old too quickly, so we would just sprinkle water on them and spread or hang the clothes out to dry. Then we would fold them up and store them. That was how we did it then. Today, they wear clothes and then wash them immediately, so they get old very quickly. I wore *kien* on special occasions from the time I was young. When I came home, I spread it out and pulled it straight, sprinkling it with water, but not so much water that the garment became soaked. Then I spread or hung the garment out to dry. After ten years, that *kien* was still like new! I only wore it once in a long while".

ស្បៀកពាក់ខុសមិនបានទេ ម៉ែគាត់វ៉ៃរកពុទ្ធោហើយ។ សំពត់អាវដៃលស្បៀកហើយយើងជជុះរលាស់ លាដាក់ឲ្យត្រង់រហូតដល់ស្ងួតញើស ហើយដៃយើងហ្នឹងចេះតែក្បៀសា (កៀស) ឲ្យវាត្រង់។ បើជាមួងហូលអី យើងក្បៀសវាឲ្យស្រួល ជូតទឹកបន្តិចៗឲ្យសើមទន់ យើងក្បៀសាក៏ត្រង់ដែរ។ ចោកញឹកធាប់ចាស់ ម្ល៉ោះហើយគេជូតទឹកបន្តិចបន្តួចត្រដាងឲ្យស្ងួតគេបត់ទុកហើយ។ អាហ្នឹងចាស់ពីដើម ឥឡូវនេះតែពាក់ភ្លាម គេចោកភ្លាមហើយ ធាប់ចាស់ណាស់។ ពីនៅក្រមុំពេលខ្ញុំស្បៀកខៀនម្តងៗ ពេលមកវិញខ្ញុំទាញវាឲ្យត្រង់ជូតទឹកបន្តិចៗ មិនជូតច្រើនឲ្យជោកទេ ត្រដាងទៅ។ ១០ឆ្នាំហើយនៅថ្មីចែស"។

ពេលនោះមានតែសម្លៀកបំពាក់ល្អៗស្បៀកពាក់ក្នុងឱកាសចូលរួមក្នុងពិធីផ្សេងៗដូចជាបុណ្យទាន រៀបការ ឬពិធីផ្លូវការ ។ល។ ទើបគេយកទៅអ៊ុត។ ម្យ៉ាងទៀតអ្នកមានឋានៈខ្ពង់ខ្ពស់ ឬមន្ត្រីរាជការ មេស្រុក មេឃុំ មេភូមិ គេច្រើនយកសម្លៀកបំពាក់ទៅអ៊ុត បើជាផាមួង ខៀន គេច្រើនចាប់ផ្ចត់។ ចំពោះអ្នកសាមញ្ញ ឬគ្មានលទ្ធភាព គេមិនបានអ៊ុតទេ។

របៀបចាប់ផ្ចត់សំពត់

ចាស់ៗបាននិយាយប្រាប់ថា នៅដើមសតវត្សទី២០ គេនិយមជីបផ្ចត់លើផាមួង ខៀន សម្រាប់យកមកចង់ក្បិន និងកន្ទែងពានា។ ចំពោះហូលគេស្បៀកមិនជីបផ្ចត់ទេ។ អ្នកដែលនិយមបែបនេះ

At that time, only important clothes worn for special ceremonies such as marriages or when gathering together on official occasions were ironed. It was mostly high class people, like government ministers and provincial authorities, who ironed their clothes. Ordinary people generally did not iron their clothing in those days.

Making pleats in the *sampot*

According to our elderly interviewees, throughout the early 20th century until the 1970s, it was popular among middle and upper class people to pleat *sampot* tied in the *kben* style that were made of *pamuong* or of *kien*. *Sampot* of *hol* were not generally pleated. Pleated *sampot* were worn to enter the Royal Palace, at official work places, and when participating in special ceremonies. Mom Samuen, 76 years old living in Phnom Penh, told us, "My older sister was a teacher in the 1940s. Sometimes when she went to teach, she wore a pleated *sampot* tied in the *kben* style, and sometimes she wore a *sampot* that was not pleated." Suong Mali, 71 years old living in Kompong Thom Province, told us, "Old people in the past liked to wear *pamuong* that was pleated. My mother wore that and it looked very beautiful. My uncle was the district leader in those days and he had twelve different colored *sampot* made of *pamuong* for entering the Royal Palace. When he had to go

ច្រើនតែអ្នកមានជីវភាពធ្យម និងអ្នកមានឋានៈខ្ពស់ក្នុងសង្គម។ ក្បិនជីបផ្ដត់នេះគេច្រើនស្លៀកចូលវាំងទៅធ្វើការនិងចូលរួមក្នុងពិធីបុណ្យផ្សេងៗ។ លោកយាយមុម សំអឿន អាយុ៧៦ឆ្នាំ នៅភ្នំពេញ និយាយថា "បងស្រីខ្ញុំធ្វើគ្រូបង្រៀន (ទសវត្ស ១៩៤០) ពេលទៅបង្រៀនជួនកាលស្លៀកសំពត់ចងក្បិនជីប ជួនកាលក៏អត់ជីប"។ លោកយាយសួង ម៉ាលី អាយុ៧១ឆ្នាំ នៅខេត្តកំពង់ធំ និយាយថា "ចាស់ៗពីដើមចូលចិត្តស្លៀកជាមួយចាប់ផ្ដត់ ម្ដាយខ្ញុំ

រូបលេខ ២៣៧៖ ស្ត្រីរបាំក្នុងវាំងស្លៀកសំពត់ជាមួយចងក្បិនចាប់ផ្ដត់។ ថតឆ្នាំ១៩០២។ (រូបថត៖ សារមន្ទីរជាតិ)

Figure 237: Dancers in the Royal Palace wearing pleated *sampot* made from *pamuong* tied in the *kben* style. Photographed in 1902. (NMC Photography Collection)

to the Royal Palace, they would pleat the *sampot* three days in advance."

To make the pleats, a clean washed *sampot* was folded along its width to make small pleats down the entire length of the cloth. Each pleat was made by grasping the ends of the cloth and folding it into a two or three centimeter wide pleat which was pressed and scored along the fold with the hands. Each fold was flattened and pressed to match the previous fold. Sometimes after a series of pleats had been made, the pleats would be pinned together to hold them in place and make it easier for the person folding the *sampot* to hold and pleat the remaining length of cloth. When the entire *sampot* had been pleated, it was folded in three and tied to hold the pleats together. The pleats were untied when the garment was worn. After wearing, the *sampot* was dried in the sun and then folded along the old pleats and retied for storage. If the *sampot* was washed, then the pressing of the pleats had to be redone as described above. White scarves worn diagonally across the chest were also sometimes pleated in the same manner. Since the 1940s, the habit of pleating *sampot* has gradually disappeared and today, pleated *sampot* are no longer worn.

ស្លៀកទៅឃើញស្អាតណាស់។ ឯលោកអ៊ំខ្ញុំជាចៅហ្វាយស្រុកជំនាន់ដើម មានផាមួង១២ពណ៌សម្រាប់ស្លៀកចូលវាំង។ ដល់ពេលត្រូវចូលវាំងសុទ្ធតែចាប់ផ្តត់ទុកពីរថ្ងៃមុន"។

របៀបចាប់ផ្តត់ក្បិនគឺ ដំបូងគេយកសំពត់ក្បិនដែលបោកសម្អាតហើយ មកចាប់ផ្តត់ដោយបត់ត្រឡប់ចុះត្រឡប់ឡើងតូចៗ (ពីមួយផ្តត់ទៅមួយផ្តត់



រូបលេខ ២៣៨៖ ព្រះអង្គម្ចាស់អាវ៉ៃ (ខាងឆ្វេង) និងលោកយាយ ខាំកួន (ខាងស្តាំ) ស្លៀកសំពត់ផាមួងចងក្បិនចាប់ផ្តត់។ ថតដើមសតវត្សទី២០។ (រូបថត៖ លោកយាយមុម សំអឿន)

Figure 238: Princess Auvai (left) and Kam Puon (right) wearing pleated *sampot* made of *pamuong* tied in the *kben* style. Photographed at the beginning of the 20th century. (Photo: Collection of Mom Samuen)

The Iron

Irons used one hundred years ago were made of metal. They had handles to hold when using or carrying them that were covered with wood to protect the hand from the heat while ironing. There were two types of irons: the iron into which charcoal was put, and the iron which was heated on charcoal. These two types of irons were different in that one had an inner hole to put charcoal which had a cover that was opened and closed. The cover had a metal chicken whose legs served as the hook holding the cover closed. Inside this type of iron was an air hole as well as a metal sheet or grill for holding the charcoal. When using this kind of iron, they heated

រូបលេខ ២៣៩៖ ចាប់ផ្តត់សំពត់ ថតឆ្នាំ២០០៣។ (រូបថត៖ រ៉ៃយ៉ំ)

Figure 239: Making pleats in a *sampot*. (Photo: Reyum)

ប្រហែល៦សង់ទីម៉ែត្រ) និងចាប់ចុងទាំងសងខាងឲ្យ
ស្មើគ្នា (ចាប់តាមទទឹងសាច់) ដោយយកដៃច្បូតមួយ
ផ្នត់ឲ្យស្មើល្អហើយ ទើបចាប់មួយផ្នត់ទៀត (រូបលេខ
៦៣៥)។ គេចេះតែធ្វើរបៀបនេះរហូត ពេលចាប់បាន
ច្រើនគេរលាក់ផ្នត់ជាបណ្តើរៗ ដើម្បីឲ្យស្មើគ្នា។
អ្នកខ្លះក្រោយចាប់បានផ្នត់បន្តិចគេយកមួលមកខ្ចាស់
សិនទើបចាប់បន្តទៀត ដើម្បីកុំឲ្យផ្នត់របូត។ ក្រោយ
ពេលចាប់ផ្នត់រួច គេបត់ជាបីគន្លាក់ដោយយកខ្សែមក
ចង់ដើម្បីកុំឲ្យរលាផ្នត់។ នៅពេលស្លៀកទើបគេ
ស្រាយខ្សែហើយលា និងបានជាផ្នត់ៗ។ ក្រោយពេល
ស្លៀកហើយ គេដាក់សំដិលឲ្យស្អួតញើស រួចចាប់
បត់តាមផ្នត់ចាស់ យកមកចង់ទុកវិញ។ តែបើត្រូវ
ជោគសម្ពាតនោះ គេត្រូវចាប់ផ្នត់ឡើងវិញម្តងទៀត។
ចំពោះកន្ទែងពានាក៏គេចាប់ផ្នត់បែបនេះដែរ។ ការ
និយមស្លៀកក្បិនចាប់ផ្នត់នេះ ក្រោយទសវត្ស១៩៤០
ចាប់បាត់បន្តិចម្តងៗមកដល់សព្វថ្ងៃលែងឃើញមាន
ស្លៀកសំពត់ចង់ក្បិនចាប់ផ្នត់របៀបនេះហើយ។

ធ្នាំងអ៊ុត

ធ្នាំងអ៊ុតជាឧបករណ៍ម្យ៉ាងធ្វើពីដែក មាន
បាតរាបស្មើ ហើយរលោង មានដៃសម្រាប់កាន់ ឬ
យួរដែលមានស៊ិកឈើ ដើម្បីការពារកុំឲ្យក្តៅដៃពេល
កាន់អ៊ុត។ ធ្នាំងអ៊ុតមាន២ប្រភេទ គឺធ្នាំងអ៊ុតដាក់ធ្យូង
មានប្រអប់សម្រាប់ដាក់ធ្យូង និងមានគម្របអាចបិទ
បើកបាន នៅលើគម្របនោះគេមានធ្វើរូបមាន់មាន

charcoal in a stove first and only put the coals into the body of the iron when they were glowing. If the iron began to cool while ironing and no longer pressed the cloth sufficiently, they would open the cover of the iron and either fan the coals inside or add new glowing coals to the iron. This was done quite frequently while ironing.

The other type of iron did not have an interior space with a cover, but rather was heated before use. This type of iron was thin and made of solid metal. It was heated on a stove of glowing charcoal and then was quickly wiped clean before using it to iron clothes. Mom Samuen, 76 years old living in Phnom Penh, told us, "When I was little, our house already had an iron to use. Irons in those days used glowing coals. There weren't any electric irons yet. In the laundries and wash houses, they used a thin iron that was heated in the coals before ironing. It was mostly men who used that kind of iron since it was quite heavy. At home, we used an iron shaped like a little boat into which we put glowing coals. When we were finished ironing, we would take candles and rub them on the iron so that wax covered its face. Then we would put it away. When we had to use the iron again, it wouldn't be rusty. When we heated it, the wax dissolved and we would first iron on a rag in order to make sure that all the wax was gone from the face of the

ជើងជាតម្ពក់។ នៅផ្នែកចំហៀងខាងក្រោមជិតបាត
មានរន្ធតូចដើម្បីឲ្យខ្យល់ចេញចូលបាន។ ហើយនៅ
ខាងក្នុងមានបន្ទះធ្វើពីអាលុយមីញ៉ូមសម្រាប់ទ្រធ្យូង
និងឲ្យផេះធ្លាក់ចុះទៅក្រោម ដើម្បីរក្សាកំដៅទៅធ្នាំង
អ៊ុត (រូបលេខ២៤០)។ រៀបអ៊ុតគេបង្ហាត់ភ្លើងក្នុង
ចង្ក្រានឲ្យផេះសិន ទើបគេចាប់រើកភ្លើងដាក់ក្នុងធ្នាំង
អ៊ុតនោះពេលក្តៅទើបគេយកមកអ៊ុត។ ពេលកំពុងអ៊ុត
បើសិនជាថយកំដៅ អ៊ុតមិនសូវរាប គេបើកគម្រប
ឡើងហើយយកធ្យូតមកបក់ឲ្យរើកភ្លើងក្នុងនោះផេះ ឬ
បន្ថែមធ្យូងទៀត។ គេតែងតែធ្វើបែបនេះជារឿយៗ។
ចំណែកធ្នាំងអ៊ុតមួយប្រភេទទៀត គឺធ្នាំងអ៊ុតដុតលើ
ធ្យូង (ធ្នាំងអ៊ុតដុត) មានរាងសំប៉ែតហើយតាន់។
ពេលអ៊ុតគេយកវាដាក់ដុតលើចង្ក្រានធ្យូងឲ្យក្តៅ រួច
ជូតបាតឲ្យស្អាត ទើបយកមកអ៊ុតលើសម្លៀកបំពាក់។
លោកយាយមុម សំអឿន អាយុ៧៦ឆ្នាំ នៅភ្នំពេញ
និយាយថា "ពេលដែលខ្ញុំនៅតូចឃើញនៅផ្ទះខ្ញុំមាន
ធ្នាំងអ៊ុតប្រើហើយ។ ធ្នាំងអ៊ុតពីដើមដាក់ធ្យូងអត់មាន
ធ្នាំងអ៊ុតខ្សែភ្លើងទេ។ បើនៅតាមហាងបោកអ៊ុតគេប្រើ
ធ្នាំងអ៊ុតមានរាងសំប៉ែត គេដាក់ដុតលើធ្យូង ច្រើន
មនុស្សប្រុសប្រើ ព្រោះធ្នាំងអ៊ុតប្រភេទនេះធ្ងន់ (រូប
លេខ២៤១-២៤២)។ បើនៅតាមផ្ទះប្រើធ្នាំងអ៊ុតរាង
ដូចកប៉ាល់ គេដាក់ធ្យូងខាងក្នុងហ្នឹង។ ធ្នាំងអ៊ុតហ្នឹង
ពេលយើងឈប់អ៊ុត គេយកទៀនទៅរូតពីលើ ហើយ
ទៀនវាប្រឡាក់បាតធ្នាំងអ៊ុតហ្នឹង គេយកទៅទុកទៅ។
ដល់យើងយកមកអ៊ុតទៀតវាអត់ប្រែ។ ដល់ដាក់ភ្លើង

iron." These kind of charcoal irons seem to have been in use throughout the early 20th century. We are not sure whether there were irons before that time, nor do we know where the charcoal irons came from or whether they were made in Cambodia. Today, no irons with the hole for charcoal are produced in Cambodia. These irons are still popular in the countryside, however, and they are imported from Vietnam. Up to ten years ago or so, commercial laundries and wash houses were still using the solid metal irons heated on charcoal. The irons were sometimes heated on kerosene stoves since this was easier and cheaper. These types of solid metal irons can be made in Cambodia today, but the laundries and wash houses have to commission them as they are not sold



រូបលេខ ២៤០៖ ធ្នាំងអ៊ុតធ្យូង។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 240: An iron with a cover and interior for hot charcoal. Photographed in 2003 (Photo: Reyum)

រលាយទៀន យើងយកវាអ៊ុតលើក្រណាត់ផ្សេងសិន ដើម្បីជូតទៀនឲ្យស្អាតឆ្នាំង"។ ដូច្នេះឆ្នាំងអ៊ុតខ្មែរមានប្រើតាំងពីដើមសតវត្សទី២០រហូតមក ឯសម័យមុននោះទៀតក៏យើងមិនច្បាកដថាមានប្រើ ឬក៏អត់ឡើយ។ ឆ្នាំងអ៊ុតនោះយើងមិនបានដឹងថា នាំចូលមកពីស្រុកក្រៅ ឬមួយធ្វើនៅក្នុងស្រុកខ្មែរទេ។ ប៉ុន្តែបច្ចុប្បន្ន ឆ្នាំងអ៊ុតដាក់ធ្យូងនេះនាំមកពីប្រទេសវៀតណាម នៅស្រុកខ្មែរពុំមានធ្វើឆ្នាំងអ៊ុតប្រភេទនេះឡើយ ទោះបីប្រជាជនខ្មែរនៅតាមជនបទស្រែចម្ការនៅប្រើក៏ដោយ។ ប្រហែល១០ឆ្នាំមុននេះ នៅតាមហាងចោកអ៊ុតខោអាវនៅតែប្រើឆ្នាំងអ៊ុតដុតលើធ្យូង។ តែនៅហាងខ្លះគេយកឆ្នាំងអ៊ុតនេះដុតលើចង្ក្រានប្រេងកាតវិញ ព្រោះវាងាយស្រួល និងចំណាញ់ថវិកាជាងប្រើធ្យូង។ ឆ្នាំងអ៊ុតបែបនេះសព្វថ្ងៃធ្វើនៅក្នុងស្រុក ប៉ុន្តែគ្មានលក់នៅផ្សារទេ បើចង់បានទាល់តែឲ្យជាងដែកធ្វើឲ្យ។ សព្វថ្ងៃហាងខ្លះនៅភ្នំពេញគេមិនសូវប្រើឆ្នាំងអ៊ុតបែបនេះទេ ច្រើនប្រើឆ្នាំងអ៊ុតខ្សែភ្លើងវិញ។

ការចាប់ផ្តត់ ឬអ៊ុតសម្លៀកបំពាក់ នៅតាមស្រុកស្រែចម្ការមិនសូវជាយកចិត្តទុកដាក់ ឬគិតគូរប៉ុន្មានឡើយ ព្រោះត្រូវប្រើពេលវេលាច្រើន ប្រដាប់ប្រដាប្រើក៏ខ្វាត់ខ្វាយ។ ចំពោះអ្នកនៅទីក្រុងក៏ច្រើនតែអ្នកមានជីវភាពធូរធារ ដែលយកចិត្តទុកដាក់ក្នុងការចាប់ផ្តត់ ឬអ៊ុតសម្លៀកបំពាក់។ បើប្រៀបធៀបនឹងពេលបច្ចុប្បន្នខុសគ្នាខ្លាំង។ ការចាប់ផ្តត់សំពត់សម័យ



រូបលេខ ២៤១៖ ឆ្នាំងអ៊ុតដុតលើធ្យូង ច្រើនប្រើនៅក្នុងហាងចោកអ៊ុត។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 241: A solid metal iron heated on charcoal. Photographed 2003. (Photo: Reyum)



រូបលេខ ២៤២៖ ប្រើឆ្នាំងអ៊ុតដុតលើធ្យូងអ៊ុតសម្លៀកបំពាក់។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 242: Using an iron, heated on charcoal, in a commercial laundry. Photographed 2003. (Photo: Reyum)

readymade in the markets. Some commercial laundries and wash houses in Phnom Penh today have stopped using these irons and instead use electric irons.

Ironing or pleating clothing was not an everyday habit in the countryside during

នេះ គេមានប្រភេទថ្នាំម្យ៉ាងជាញ៉ៅលើក្រណាត់ដែលថ្នាំទាំងនោះសុទ្ធតែនាំចូលពីបរទេស។ រួចហើយគេគ្រាន់តែចាប់បត់ជាផ្នត់ត្រង់ រួចជាញ៉ៅថ្នាំនោះ ហើយអ៊ុតគេនឹងបានសំពត់ដែលមានផ្នត់ស្អាត។ ទោះបីយកទៅជោកទឹក ឬស្ងើកញីកញាប់ក៏មិនធ្វើឲ្យផ្នត់នោះរលោ ឬខូចខាតឡើយ។ តែគេចាប់ផ្នត់លើក្រណាត់មិនមែនចាប់ផ្នត់លើជាមួង និងខៀនដូចសម័យមុនទេ។

គ- ទុកដាក់សម្លៀកបំពាក់

ក្នុងអំឡុងដើមសតវត្សទី២០ ខ្មែរមានទម្លាប់តាគ្នាក្នុងការទុកដាក់សម្លៀកបំពាក់ ខុសប្លែកពីសម័យបច្ចុប្បន្ន។ ព្រោះថាសព្វថ្ងៃមានគ្រឿងសង្ហារឹមល្អ។ និងទំនើបគ្រប់បែបយ៉ាង។ បើនិយាយពីគ្រឿងសង្ហារឹមសម្រាប់ទុកដាក់សម្លៀកបំពាក់មានទូច្រើនប្រភេទ ដូចជាទូឈើ ទូកញ្ចក់ ទូដែកជាដើម។ ប៉ុន្តែរបស់ទាំងអស់នេះលុះត្រាអ្នកមានប្រាក់គ្រប់គ្រាន់ទើបមានលទ្ធភាពទិញប្រើប្រាស់បាន។

នៅចុងសតវត្សទី១៩ ដើមសតវត្សទី២០ អ្នកស្រែភាគច្រើនប្រើស្មុក (ធ្វើពីស្លឹកស្នោត ស្លឹកទ្រាំង ឬវល្លិរពាក់)។ ឯអ្នកចម្ការ ឬអ្នកមានជីវភាពមធ្យមច្រើនប្រើហឹប (ធ្វើពីផ្តៅ, ឈើ, ស្បែក) និងភាគតិចបំផុតដែលមានទូប្រើ។ លោកតាលីវ សាងម អាយុ៦៨ឆ្នាំ និយាយថា "ហូលជាមួងស្ងើកហើយគេរក្សាទុកក្នុងហឹប ឬស្មុក។ ស្រុកពីដើម គេច្រើនប្រើ

the early 20th century. Ironing required both time and irons, both of which were considered a luxury. More well-to-do city dwellers ironed their clothing and sometimes pleated *sampot*. Today, ironing is a very different matter as there are imported spray starches which allow us to make pleats and folds that remain in clothing permanently. These pleats are no longer made in *pamuong* or *kien*, however, but rather are ironed into modern forms of clothing that are fashionable today.

Caring for and storing clothing

At the beginning of the 20th century, habits of storing clothing, passed down from generation to generation, were somewhat different from those used today. Today there are closets and dressers of all kinds, decorated with beautiful ornaments and made from metal and all kinds of wood. Such furniture was expensive however.

At the end of the 19th and early 20th centuries, rice farmers liked to use *smok*, or small trunks made of palm fronds, thorny palm, or a rattan like vine; wealthier farmers used *heb* (or chests) made of wood, leather, or rattan. Only a few very rich people had the kind of closets, cabinets, and dressers that we find today. The late Liv Sa Aem told us, "*Hol*

ស្មុកធ្វើពីស្លឹកត្នោត សម្រាប់ទុកដាក់របស់របរ និង
ខោអាវ។ គេច្រើនយក (ខោអាវ) ទៅទុកនៅក្នុង
បន្ទប់"។ អ្នកខ្លះមានទូប្រើដែរ ប៉ុន្តែមិនមែនសម្រាប់
ដាក់ខោអាវទេ គឺសម្រាប់ដាក់តាំងរបស់របរផ្សេងៗ
ឬចានឆ្នាំងល្អៗ។ លោកយាយមុិច ប្រាប់ថា "គេមាន
ហឹបខោអាវ ដាក់តែៗនឹងកន្លែងយើងដេកហ្នឹងទៅ។
ជាងខ្មែរជាអ្នកធ្វើ អ្នកណាគេចេះធ្វើហឹបហ្នឹង គេធ្វើ

រូបលេខ ២៤៣៖ ទូឈើសម្រាប់ដាក់តាំងរបស់របរ។ ថតឆ្នាំ ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 243: A wooden cabinet for storing and displaying objects. Photographed 2003.
(Photo: Reyum)

or *pamuong*, after they were worn, were kept in a *heb* or *smok*. In the countryside in earlier times, they mostly used *smok* made from palm fronds for keeping clothing and things. They kept their clothing [in these containers] in their room." Some people did have wooden cabinets, but these were used for displaying fine china or valuable things rather than for storing clothing. Mich, living in Kandal Province, told us "We had a *heb* for clothing near where we slept. Khmer craftsmen made *heb*. Whoever knew how to make *heb*, they made *heb*. Whoever knew how to make cabinets, they made cabinets. Mostly they were made of wood, not of metal. The cabinets were for putting dishes and precious things. Clothing was stored in *heb* so that the mice and roaches couldn't eat them. In my area, the *heb* were all made of wood. They had a lock and key. The opium *heb* were made of wood inside with metal on the outside. My father had bought one of those when he was still a monk, and he used it to keep his monk's robes. When he left the monkhood and married, he used that *heb* for clothing. It had a metal panel with the keyhole. *Smok* were only found in the countryside. I used a *smok sla* [a container for betel ingredients]. They brought them from the countryside to sell. We put areca palm in them and carried them on our heads when we



រូបលេខ ២៤៤៖ ស្មុកធ្វើពីស្លឹកត្នោតសម្រាប់ដាក់សម្លៀកបំពាក់។ ថតឆ្នាំ ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 244: A *smok* made from palm frond for keeping clothing. Photographed 2003. (Photo: Reyum)



រូបលេខ ២៤៥៖ កន្ត្រកធ្វើពីរាក់សម្រាប់ដាក់សម្លៀកបំពាក់។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 245: A rattan basket used for storing clothing. Photographed 2003. (Photo: Reyum)

ហឺបទៅ អ្នកណាគេចេះធ្វើទូ ធ្វើទូទៅ សុទ្ធតែធ្វើពីឈើ មិនមែនដែកទេ។ ទូ គឺសម្រាប់ដាក់ចាន និងរបស់ល្អា តែខោអាវមិនដាក់ក្នុងទូទេ។ គេដាក់តែក្នុងហឺបកណ្តុរ កន្ទាតអត់កាត់ទេ ចំណែកខាងខ្ញុំ (រកា គោង) ហឺបធ្វើពីឈើអត់មានធ្វើពីស្លឹទៀតទេ មានចាក់សោរ។ ឯហឺបអាភៀនគេធ្វើឈើពីក្នុង រួចក្រាលដែកពីក្រៅ។ ឥឡូវខ្ញុំគាត់ទិញហឺបហ្នឹងមួយតាំងពីគាត់បួសទិញដាក់ស្បង់ចីពរគាត់ រួចដល់គាត់មានប្រពន្ធគាត់យកមកដាក់ខោអាវ មានដែកសម្រាប់ដាក់សោរ។ស្មុកមានតែនៅស្រុកស្រែទេ បើស្មុកស្លា ខ្ញុំមានប្រើគេយកពីស្រុកស្រែមកលក់ ដាក់ស្លាទូលទៅធ្វើការ"។ ចំពោះលោកយាយឆាយ លីមយីម អាយុ

went to work." Chay Lim Khim, 83 years old living in Kandal Province, told us, "The *heb* made of rattan had wood facing inside. They called them *valise*. They had a handle. We didn't have any cabinets or anything like that. Even when I married and went to live at my mother-in-law's house, we didn't have cabinets, just *heb*. Those who had money bought *heb* made from leather. All the time until my children were grown up, I made *smok* out of palm fronds for them to put their clothes. Sometimes a mouse or insects would get inside and start eating the *hol*." Mom Samuen told us, "In our family, the cabinet was only for keeping silk cloth."

ជាទូទៅ នៅដើមសតវត្សទី២០ ខ្មែរប្រើស្មុក ហឹប កន្ត្រក និងទូខ្លះៗសម្រាប់ដាក់ខោអាវ ដើម្បីការពារសត្វល្អិត កណ្តុរ ឬកន្លាតកាត់។ ភាគច្រើនគេយកស្មុក ឬហឹបសម្ងៀកបំពាក់នោះទុកនៅក្បែរកន្លែងដេករបស់គេ។ ម្យ៉ាងទៀតជំនាន់នោះ ពិតជាមានគេធ្វើទូលក់។ ប៉ុន្តែប្រហែលមានតម្លៃថ្លៃពេក ទើបមានតែអ្នកជូរធារ ឬជាគ្រួសារក្នុងឋានៈខ្ពង់ខ្ពស់ទើបមានលទ្ធភាពទិញទូប្រើបាន។ សម្រាប់អ្នកខ្លះទៀតគ្រាន់តែយកក្រណាត់មួយផ្ទាំងមករុំ ឬវេចខ្ចប់ខោអាវដែលត្រូវទុកនោះក៏ជាការស្រេច។ យើងអាចនិយាយបានទៀតថា ដោយសារជំនាន់នោះមិនសូវសម្បូណ៌ខោអាវច្រើនដូចសព្វថ្ងៃ ការទុកដាក់ ថែទាំក៏ងាយស្រួល ជាពិសេសគេរក្សាឲ្យហ្មត់ចត់ចំពោះសម្ងៀកបំពាក់សម្រាប់ពាក់ម្តងម្កាលក្នុងពិធីសំខាន់។



រូបលេខ ២៤៦៖ ហឹបឈើសម្រាប់ដាក់សម្ងៀកបំពាក់។ ថតឆ្នាំ២០០៣ (រូបថត៖ រៃយ៉ុំ)

Figure 246: A wooden *heb* for keeping clothing. Photographed 2003. (Photo: Reyum)

In general, at the beginning of the 20th century, Khmer used *smok*, *heb*, baskets, and cabinets for storing their clothing from mice and insects. Mostly the *smok* or *heb* were stored on the bed or near the sleeping area. There were cabinets for sale at that time as well, but they were expensive and only rich high-ranking families could afford to buy them. The poorest families simply used lengths of cloth in which they wrapped their clothing to store them. Because people did not have as much clothing then as they do today, the storing and taking care of clothing was easier. They took especially good care of special clothing which was worn only once in a while for ceremonial occasions.



រូបលេខ ២៤៧៖ ហឺបឈើសម្រាប់ដាក់សម្លៀកបំពាក់ មានបាតធ្វើពីដែក។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 247: A wooden *heb* with a metal bottom for keeping clothing. Photographed 2003. (Photo: Reyum)

រូបលេខ ២៤៨៖ ហឺបឈើដាក់សម្លៀកបំពាក់។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 248: A wooden *heb* for keeping clothing. Photographed 2003. (Photo: Reyum)

រូបលេខ ២៤៩៖ ទូបច្ចុប្បន្នធ្វើពីឈើមានមុខបីសម្រាប់ដាក់សម្លៀកបំពាក់។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 249: A wooden cabinet for keeping clothing. (Photo: Reyum)

រូបលេខ ២៥០៖ ទូបច្ចុប្បន្នធ្វើពីឈើមកពីថៃសម្រាប់ដាក់សម្លៀកបំពាក់។ ថតឆ្នាំ២០០៣ (រូបថត៖ រៃយ៉ំ)

Figure 250: A modern wooden cabinet for keeping clothing. (Photo: Reyum)



ពណ៌សម្លៀកបំពាក់

COLORS OF CLOTHING

The color of clothing varies, like the style of clothing, according to the era, the region, and the tastes of individuals. Colors of clothing have traditionally been determined by the age of the person wearing the clothing as well. For ceremonies such as Khmer New Year, *Pchum Ben*, *Chol Vosa*, *Kathen*, and weddings, people generally wore bright colors such as red, yellow, blue, and green. For everyday clothing, most people wore black or dark clothing. White has traditionally been understood by the Khmer as a special color worn for ceremonial occasions rather than for everyday wear.

Our elderly interviewees who live in the provinces explained to us that, whether at home or working in the fields, villagers generally liked to wear black clothing. If the cloth out of which they were to make clothing was white, they would generally either take it and repeatedly push it in mud to make it darker, or they would dye the cloth black before wearing it. Villagers thought that stains were not so visible on black clothing and they found black clothing easier to wash. Even when they were so busy in the fields that they did not have time to wash their clothes everyday, black clothes did not show mud stains, sweat, or dirt as much. The use of black clothing also related to belief systems. Phi, 83 years old living near Phnom Penh, told us, "When we went to transplant the rice, we

នៅក្នុងទំនៀមទម្លាប់ខ្មែរ ពណ៌សម្លៀកបំពាក់ក៏មិនខុសប្លែកពីម៉ូតសម្លៀកបំពាក់ដែរ គឺប្រែប្រួលទៅតាមការនិយមរបស់មនុស្ស តាមពេលវេលា, ទីកន្លែង និងវ័យរបស់មនុស្ស។ នៅពេលមានបុណ្យទានដូចជា ចូលឆ្នាំ, ភ្ជុំបិណ្ឌ, ចូលវស្សា, កឋិន, រៀបមង្គលការជាដើម គេនិយមស្លៀកពាក់ពណ៌ដែលភ្លឺ ដូចជាពណ៌ក្រហម, លឿង, ខៀវ, បៃតង ។ល។ ចំណែកសម្លៀកបំពាក់ដែលគេប្រើប្រាស់រាល់ថ្ងៃច្រើនពណ៌ខ្មៅ ឬក្រមៅ។ ចំពោះពណ៌ស ខ្មែរយល់ថា ជាពណ៌ដែលសំខាន់សម្រាប់ប្រើក្នុងពិធីផ្សេងៗ។ ហេតុអ្វីបានជាខ្មែរនិយមប្រើសម្លៀកបំពាក់ពណ៌ខ្មៅ ឬក្រមៅសម្រាប់ស្លៀកពាក់រាល់ថ្ងៃជាងពណ៌ដទៃ?

តាមការសម្ភាសន៍មនុស្សចាស់ជាច្រើនដែលរស់នៅតាមខេត្តមួយចំនួន យើងអាចដឹងជារួមថា ទោះជានៅផ្ទះ ឬទៅធ្វើស្រែចម្ការ ជាទូទៅគេនិយមស្លៀកពាក់ពណ៌ខ្មៅ។ ទោះជាក្រណាត់នោះមានពណ៌សក៏គេយកទៅជាន់នឹងភក់ ឬជ្រលក់ឲ្យទាល់តែទៅជាខ្មៅសិន ទើបយកមកពាក់។ គេយល់ថា ស្លៀកពាក់ពណ៌ខ្មៅមិនសូវឃើញប្រឡាក់ភក់ជ្រាំ ញើស ក្អែល និងងាយស្រួលបោកគក់ ទោះបីជាគេជាប់រវល់ក្នុងការងារស្រែចម្ការ មិនបានបោកគក់រាល់ថ្ងៃក៏ដោយ។ ម្យ៉ាងទៀតការប្រើសម្លៀកបំពាក់ពណ៌ខ្មៅហាក់ដូចជាមានជាប់ជំពាក់ទៅនឹងជំនឿផងដែរ។ ឧទាហរណ៍ លោកយាយភី អាយុ៨៣ឆ្នាំ នៅស្រុកអង្គស្នួល ខេត្តកណ្តាល និយាយថា "ពេលទៅ

ស្លឹងស្លៀកពាក់ពណ៌ខ្មៅ ដើម្បីឲ្យស្រូវរបស់ខ្ញុំខ្មៅតាម"។ មានន័យថាឲ្យស្រូវដុះល្អ និងផលបានច្រើន។

ក្នុងទសវត្ស១៩៥០ មានការយល់ផ្សេងទៀតពីពណ៌ខ្មៅ ឧទាហរណ៍ ក្នុងកាសែត "កម្ពុជា" ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៥១ ក្រោមចំណងជើងថា"ពណ៌ខ្មៅជាពណ៌អពូមង្គលដែលទំនៀមទម្លាប់ខ្មែរមិនបានរាប់រង"។ ដោយគេយល់ថា ពណ៌ខ្មៅជាពណ៌អពូមង្គលដែលជាតិនានាទុកជាពណ៌កាន់ទុក្ខ, ជាពណ៌ស្លូបនូវកម្តៅ និងពន្លឺ, ជាពណ៌លាក់មន្ទិលក្រខូក់។ គេយល់ទៀតថា អ្នកនិយមស្លៀកខ្មៅជាមនុស្សស្មោកគ្រោក ខ្ជិលច្រអូសនឹងសម្អាតសម្លៀកបំពាក់។ ម្យ៉ាងទៀតគេយល់ថា ស្លៀកខ្មៅបណ្តាលឲ្យប្រទេសក្រៅមើលងាយថាប្រទេសយើងគ្មានអារ្យធម៌ មិនសមជាជនជាតិមានឯកភាជ្យ។ មានតែពណ៌ស ឬពណ៌ទើបជាពណ៌ប្រពៃ។ ចំពោះបញ្ហានេះ មានការប៉ះពាល់ខ្លាំងដល់អារម្មណ៍ប្រជាជនដែលធ្លាប់តែស្លៀកពាក់ពណ៌ខ្មៅ ដូចមានចុះក្នុងទស្សនាវដ្តីនារី ឆ្នាំ១៩៥១ សរសេរជំទាស់ថា "ចោលសំពត់ខ្មៅមិនបានទេ"។

ពណ៌សជាពណ៌ដែលខ្មែរមិនប្រើប្រាស់រាល់ថ្ងៃ និងជាពណ៌ដែលគេគិតថាមិនមែនធម្មតា។ គេយល់ថាពណ៌ស មានទាក់ទងនឹងសេចក្តីស្លាប់។ ដូចជាពេលមានមនុស្សស្លាប់គេយកសំពត់សមកពុំ។ លោកសាស្ត្រាចារ្យអាំង ជូលាន មានប្រសាសន៍ថា "សំពត់ពណ៌សក្នុងគំនិតរបស់មនុស្ស គេប្រៀបដូចជាសុកម្តាយ ព្រោះមុនយើងកើតមក យើងនៅក្នុងសុក

wore black so that the rice would be black too." By this, she means that the rice would grow well, and the harvest would be plentiful.

In the period after independence, different ideas about the meaning of black emerged. For example, an article in *Kampuchea* (see page 218), entitled "Khmer tradition has not recognised that black is an unfortunate color", tells us that black is an unfortunate color which other peoples have regarded as a color of sadness. In these cultures, the article explains, black is thought to be a color which absorbs heat and light; black also hides what is really dirty. Thus the author claims that people who like to wear black are dirty and lazy in cleaning their clothing. Wearing black, the author continues, makes other countries look down on Cambodia as if it does not have any civilisation and as if its people were not independent. White and colored clothing are really traditional clothing, the author continues. This author's opinion appears to have affected those accustomed to wearing black clothing since a counter argument appeared in the magazine *Neary* in 1951 entitled "We can't throw away the black sampot" (see page 221).

White was a color which in traditional Khmer culture was not worn every day, and rather was considered a special color worn on ceremonial occasions. White was a

ដើម្បីកើតជាមនុស្សត្រូវចេញពីសុក។ ដូច្នេះដល់ពេលយើងស្លាប់ គេយកសំពត់សមកគុំ គឺយើងត្រូវមានសុកមកគុំជាថ្មីដើម្បីទៅចាប់ជាតិទៀត"។ ឧទាហរណ៍ ក្នុងពិធីរំដោះគ្រោះ នៅពេលលោកសង្ឃសូត្រធម៌បង្គុំគូល គេឧបកិច្ចថា ជនដែលត្រូវរំដោះគ្រោះ ជាសាកសពដែលត្រូវបង្គុំគូល។ លោកអាចារ្យយកសំពត់សមកគ្របពីលើអ្នកដែលត្រូវរំដោះគ្រោះ ហើយស្រាយអំបោះសបន្ទាយព័ទ្ធជុំវិញចុងអំបោះទាំងពីរ និងសំពត់សលោកសង្ឃជាអ្នកកាន់។ លោកសង្ឃសូត្រធម៌ដោយចាប់ទាញសំពត់គ្របពីលើបន្តិចម្តងៗ ព្រមទាំងចាប់ទាញអំបោះជាបណ្តើរៗផងដែរ។ នៅពេលសូត្រធម៌ចប់សំពត់សដែលគ្របពីលើ និងអំបោះព័ទ្ធជុំវិញនោះក៏រលេះចេញពីខ្លួនអ្នកដែលត្រូវរំដោះគ្រោះនោះអស់ដែរ។ កាលដែលគេគ្របសំពត់សពីលើ គឺបានសេចក្តីថា អ្នកនោះលាចាកលោកនេះហើយ។ កាលដែលទាញសំពត់សចេញ គឺហាក់ដូចជាមនុស្សនោះកំពុងតែប្រសូតចេញមក។ ដូច្នេះរូបដែលទៅជាមនុស្សថ្មីម្ខាក់ទៀត។ ឧទាហរណ៍មួយទៀត នៅខេត្តសៀមរាបពេលគេរើព្រះវិហារមួយចោលដើម្បីកសាងឡើងវិញ គឺគេដោតទង់សមួយ និងទង់លលកមួយ[៥] គឺដូចជាមនុស្សដែលស្លាប់ហើយបានចាប់ជាតិថ្មីដែរ។ នៅក្នុង

color associated with death, and dead bodies were wrapped in a white *sampot* before cremation. Dr. Ang Choulean told us, "The white *sampot* is compared to the placenta. Before we are born, we are in the placenta. In order to be born as a person, we have to leave the placenta. When we die, they wrap us in a white cloth. We need this new placenta in order to be born into another life again."

In the ceremony performed to free someone from danger, as the monk chants the *bongsokol* prayers, they pretend that the person who is sick or in trouble is the corpse that must be covered with a cloth to be prayed over. The *achar* takes a white cloth and lays it over the person in trouble, unwinding a white thread around that person and giving the ends of the thread as well as an edge of the cloth to the monk to hold. The monk chants prayers while pulling the cloth and thread slowly, little by little, from the person in danger. When the monk finishes chanting the prayers, the white cloth and thread have been removed from the person in danger. With the removal of the white cloth, the person is symbolically born into a new life as a new person.

In Siem Reap Province, when they knock down an old *vihear*, or temple building, to build a new one, they fly a white flag, shaped like a crocodile (sewn from two white *sampot*), and a colored flag of the same shape. These flags symbolise a person who has

---

[៥] ទង់សគឺជាទង់ក្រពើ ដេរពីសំពត់ពណ៌ស។ ឯទង់លលកមានរូបភាពដូចទង់ក្រពើដែរ តែដេរដោយសំពត់ពណ៌។

ទ្រឹស្តីព្រះពុទ្ធសាសនា ពេលមានមនុស្សស្លាប់ សមាជិកក្រុមគ្រួសារខ្លះស្លៀកសំពត់អាវពណ៌សកាន់ទុក្ខសព។ គេមិនត្រឹមតែនិយមប្រើពណ៌សចំពោះពិធីបុណ្យសពប៉ុណ្ណោះទេ គឺថែមទាំងចាត់ទុកពណ៌សជាពណ៌ដែលល្អបរិសុទ្ធ ដូចជាមនុស្សចាស់ដែលវដ្តនៃជីវិតរបស់គាត់ដើរមកជិតសេចក្តីស្លាប់។ ម្ល៉ោះហើយគាត់ស្លៀកពាក់ស កោរសក់ គឺគាត់មានបំណងធ្វើឲ្យជីវិតចុងក្រោយគាត់បរិសុទ្ធ ជ្រះថ្លា នៅពេលស្លាប់បានស្ងប់សុខ។ នៅក្នុងជំនឿមួយទៀតដែលទាក់ទងនឹងពណ៌សដែរគឺអំពោះស។ ខ្មែរនិយមចងដៃអំពោះផៅក្នុងពិធីជាមង្គលដូចជាអាពាហ៍ពិពាហ៍ក្តី ពិធីបុណ្យសពក្តី ដើម្បីឲ្យមានសិរីសួស្តីដល់មនុស្សម្នាក់ៗ។

ដូច្នេះសំពត់ពណ៌សមានអត្ថន័យសំខាន់ក្នុងទំនៀមទម្លាប់ គឺខ្មែរមិននិយមប្រើសំពត់ពណ៌សសម្រាប់ស្លៀកពាក់ក្នុងឱកាសធម្មតាទេ គឺសម្រាប់ប្រើតែក្នុងពិធី។ គួរឲ្យចាប់អារម្មណ៍ដែរ ពេលបារាំងចូលមក គេមិនបានគិតពីទំនៀមទម្លាប់ខ្មែរទេ។ បារាំងនិយមស្លៀកពាក់ឯកសណ្ឋានស ហើយដោយសារបារាំងជាអ្នកគ្រប់គ្រង ធ្វើឲ្យមន្ត្រីខ្មែរមួយចំនួនចង់ធ្វើខ្លួនឲ្យដូចបារាំង ឬក៏មកពីបារាំងតម្រូវឲ្យពាក់អាវសមួកស ដូចបារាំង។ តែស្លៀកសំពត់ចង្កៀនពណ៌ត្រាប់អំពិលបែបខ្មែរ។

ចំពោះពណ៌ភ្លឺដូចជាពណ៌ក្រហម, លឿង, ខៀវ, ស្វាបកំភេម, កទា, ស៊ីនួន ។ល។ គេនិយមស្លៀកពាក់ក្នុងពិធីធំៗ និងក្នុងពិធីរីករាយ។

died and one who has taken on a new life already. In Buddhist belief, when a person dies, some of his family wears white clothing to mourn. White is not only used for funerals, but is also considered a color of purity. Elderly people at the end of their lives wear white and shave their heads, wishing to make the end of their lives pure and clear so that when they die they will be at peace. Another belief concerning white relates to the white cotton thread that Cambodians like to wear tied on their wrist for occasions such as weddings and funerals; these tied threads are believed to bring good fortune.

Thus the white *sampot* had important meanings in traditional beliefs and was not generally worn for ordinary days but rather was reserved for special occasions and ceremonies. When the French came to Cambodia, they didn't consider Khmer customs. The French liked to wear white uniforms. Because the French had a high standing in the society of the Protectorate, Khmer ministers began to imitate the French by wearing white shirts and hats. Cambodian officials still however wore *sampot* the color of the tamarind seeds tied in the *kben* style.

Clothing with bright colors such as red, yellow, blue, green of the shiny wings of the *kompain* insect, green of the neck of the duck, and a light yellow cream color called *si nuon* were worn to big ceremonies and parties.

រូបលេខ ២៥១៖ រាជការចាវាំងនិយមប្រើសម្លៀកបំពាក់ពណ៌ស។ ថតឆ្នាំ ១៩០២។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 251: French officials liked to wear white clothing during the Protectorate. Photographed 1902. (Photo: National Archives of Cambodia)

រូបលេខ ២៥២៖ មន្ត្រីរាជការខ្មែរ និងចាវាំង។ ថតនៅរវាងឆ្នាំ ១៩០០។ (រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 252: Cambodian and French officials around an ox cart. Photographed around 1900. (Photo: National Archives of Cambodia)

ក្នុងសង្គមខ្មែរ រហូតមកដល់សព្វថ្ងៃ មានចាត់ពណ៌ផ្សេងៗប្រចាំថ្ងៃក្នុងមួយអាទិត្យ ដើម្បីលើកកាសី និងឲ្យមានសិរីសួស្តី។ ការចាត់ពណ៌ប្រចាំថ្ងៃនេះ មិនសូវមានសារសំខាន់ប៉ុន្មានទេចំពោះអ្នកស្រុកជម្មតា លើកលែងមានករណីពិសេស។ ឧទាហរណ៍ អ្នកខ្លះមានជំនឿថា ពេលមានជំងឺគេឲ្យអ្នកឈឺស្លៀកពាក់តាមពណ៌ប្រចាំថ្ងៃ ដើម្បីលើកកាសីអ្នកជំងឺឲ្យធាប់ជាសះស្បើយ។ ចំពោះអ្នកធំដូចមន្ត្រី ឬអ្នកនៅក្នុងរាជវាំង គេនិយមស្លៀកពាក់ទៅតាមពណ៌ប្រចាំថ្ងៃជាពិសេសពេលមានពិធីជាផ្លូវការ។ ឧទាហរណ៍ចូលទៅជំនុំ ធ្វើបុណ្យ ឬទៅគាល់ព្រះមហាក្សត្រក្នុងវាំង។ ខាងក្រោមនេះ គឺជាពណ៌ប្រចាំថ្ងៃទាំងប្រាំពីរ៖ ថ្ងៃអាទិត្យ ពណ៌ក្រហម, ថ្ងៃច័ន្ទ ពណ៌លឿងខ្ចី, ថ្ងៃអង្គារ

Traditionally, colors were associated with the days of the week and the use of a particular color on its proper day was believed to bring luck and happiness. The colors assigned to the days of the week did not have much importance for people in the countryside except on special occasions. Some people, for example, believed that when someone was sick, that person should wear the color of the day in order to increase their luck and make them get better quickly. Ministers and people associated with the Royal Palace generally wore the color of the day, especially on official occasions, for example, when they attended meetings, participated in ceremonies, or went to meet the King. The seven colors of the day are:

ពណ៌ស្វាយ, ថ្ងៃពុធ ពណ៌ស៊ីលាប, ថ្ងៃព្រហស្បតិ៍ ពណ៌បៃតង, ថ្ងៃសុក្រ ពណ៌ខៀវ, ថ្ងៃសៅរ៍ ពណ៌និលឬពណ៌ត្រចៀកទុំ។

ក- ការជ្រលក់ពណ៌

នៅពេលមិនទាន់មានល័ក្តគីមី ប្រជាជនខ្មែរនិយមប្រើល័ក្តយកពីធម្មជាតិ។ ល័ក្តធ្វើពីវត្ថុធាតុនេះពណ៌មិនស្រស់ដូចល័ក្តគីមីទេ។ ប៉ុន្តែល័ក្តធម្មជាតិមិនងាយចេញពណ៌ និងរក្សាពណ៌បានយូរជាង។ ល័ក្តធម្មជាតិអាចផ្តល់បានពណ៌ផ្សេងៗ តែគេចែកជាពណ៌មេមាន៤ គឺក្រហម លឿង ខៀវ និងខ្មៅ។

- ល័ក្តពណ៌ក្រហម៖ បានពីខ្លឹមដើមស្បៃង, គ្រាប់ជម្ពូ (សម្រាប់ជ្រលក់សូត្រ)។ ពណ៌ក្រហមស្រស់ បានពីក្រមរល័ក្ត ឬល័ក្តជុំក្រឡង់។ ពណ៌ក្រហមស្រាលបានមកពីសម្បកដើមឈើទាល។

រូបលេខ ២៥៣៖ គ្រាប់ជម្ពូ។ (រូបថត៖ រៃយ៉ំ)

Figure 253: Seeds of the *jumpuh* tree. (Photo: Reyum)

Sunday, red; Monday, dark yellow; Tuesday, purple (the color of mangoes); Wednesday, light green of the leaves of the *leap* tree; Thursday, green; Friday, blue; and Saturday, a dark maroon called the color of sapphires or the color of the ripe *pring* fruit.

Dyes

Before there were chemical dyes for coloring cloth, Khmer used natural dyes which were also called *leak*. The colors produced by natural dyes were not as bright as those produced by today's chemical dyes. Natural dyes did not generally give off color when washed, and clothing dyed with them kept its color for a long time. *Leak* from nature were used to make many colors but, according to our elderly interviewees, colors from natural sources were generally categorized into four main groups: red, yellow, blue, and black.

A strong simple red was made from the heart of *sbaing* tree wood or the seeds of the *jumpuh* fruit. Various other shades of red were made from the residue of the *leak* insect, and from the bark of the *teal* tree, the *smai* tree, the *smaich* tree, the *kandaol* tree, the *tnug* tree, and the *pangro* tree.

Yellow was made from *preah ankaol* root, or from saffron pounded and mixed with

រូបលេខ ២៥៤៖ ក្រមរល័ក្ត។ ថតឆ្នាំ២០១១។ (រូបថត៖ រៃយ៉ំ)

Figure 254: *Leak*, a kind of insect residue. (Photo: Reyum)

រូបលេខ ២៥៥៖ គេស្ងោរសម្បកដើមព្រហូតរហូតដល់ចេញពណ៌ ទើបគេយកមកច្រោះ។ (រូបថត៖ រៃយ៉ំ)

Figure 255: Boiled bark of the *prahoat* tree being sieved once the liquid has turned color. (Photo: Reyum)

ពណ៌ក្រហមជាំ បានពីសម្បកដើមស្នែ។ ពណ៌ក្រហមប្រផេះ បានពីសម្បកដើមស្នាច់។ ពណ៌ក្រហមប្រមឹក បានពីសម្បកដើមកណ្តាល។ ពណ៌ក្រហមក្រមៅ បានពីសម្បកដើមឆ្នូង និងដើមពង្រ។

– ល័ក្តពណ៌លឿង៖ បានពីមើមព្រះអង្គារ និងមើមរមៀត (បុកលាយទឹក)។ ពណ៌លឿងទុំ បានពីសម្បកដើមព្រហូត។ ពណ៌លឿងខ្ចី បានពីសម្បកដើមពោធ៍, ដើមខ្នុរ, ដើមចន្ទ្រីក, ដើមដកព, ដើមសង្កែ, ដើមអំពិលបាកាំង, ដើមអញ្ជ។

– ល័ក្តពណ៌ខៀវ៖ ដើម និងស្លឹកត្រុំស្រស់ អាចយកមកបង្កើតជាពណ៌ខៀវបាន តែអាចប្រែប្រួលទៅជាពណ៌ខៀវចាស់ ឬពណ៌បៃតងអាស្រ័យលើរយៈពេលដែលគេត្រាំដើមត្រុំ។ ប្រសិនបើគេត្រាំដើមត្រុំមួយយប់ គេនឹងបានពណ៌បៃតងខ្ចី តែបើគេត្រាំដើមត្រុំចាប់ពី២យប់ឡើងទៅ គេនឹងបាន

some water. Dark yellow dye was made from the bark of the *prahoat* tree. Light yellow dye was made from the bark of the banyan tree, or the wood of the jackfruit tree, the *chong reak* tree, the *dok po* tree, the *sangkai* tree, the French tamarind tree, or the *an jay* tree.

Blue was made by soaking the wood and leaves of indigo shrubs. A range of greens and blues could be made from indigo, depending on how long the leaves and wood were soaked. If the leaves and wood were soaked for only one night, a light green dye resulted; after soaking the leaves and wood for two nights or more, the dye became blue. In addition to indigo, blue and green dyes were made from the leaves of green and red pepper plants, the *bhas* vine, or the tamarind tree.

Black dyes were made from the leaves of the *tros* tree, the leaves of the *phnus* tree, the



រូបលេខ ២៥៦៖ ទឹកព្រហូតច្រោះរួច។ (រូបថត៖ រៃយ៉ំ)

Figure 256: Decanted dye from *prahoat* tree bark. (Photo: Reyum)

ពណ៌ខៀវ។ ចំពោះពណ៌ខៀវ ឬពណ៌បៃតង បើសិនគ្មានដើមត្រុំ គេអាចប្រើស្លឹកម្ទេស, ស្លឹកវល្លិជាស, ស្លឹកអំពិលជំនួសក៏បាន។

– ល័ក្ខពណ៌ខ្មៅ៖ បានពីស្លឹកដើមត្រស់, ស្លឹកដើមភ្ជួស, ផ្លែពុល, ខ្ចីញ (មក្លឺ)។ ដើម្បីបានពណ៌ខ្មៅល្អគេយកសូត្រ ឬសំពត់ដែលត្រូវជ្រលក់នោះទៅជ្រលក់ពណ៌បៃតងឲ្យឆ្អែតសិន រួចហាលឲ្យស្ងួត ទើបយកទៅជ្រលក់ខ្មៅជាក្រោយ។

ចំពោះពណ៌ផ្សេងទៀតដូចជា ពណ៌សាច់ ឬពណ៌កាកអំពៅ បានមកពី សម្បកដើមចន្ទ្រីក។ ពណ៌ផ្កាត្របែកព្រៃ បានពីសម្បកដើមស្វាយ។ ពណ៌ប្រផេះ បានមកពីជ្រលក់ទឹកក្បុងធ្វើពីផេះដើមដ្តី។

១– វិធីធ្វើល័ក្ខធម្មជាតិ

– សត្វល័ក្ខ៖ គឺជាប្រភេទសត្វល្អិតប៉ុន

pkol fruit, or the *kmuin* fruit (*mcleur*). In order to make a deep black cloth, silk was sometimes dyed in green dye, drying it in the sun before dyeing it again in black dye afterwards.

Other color dyes with flesh color or the color of sugar cane were made from the bark of the *chong reak* tree. A pinkish purple dye called *trabaek prei* (after a plant with flowers that color) was made from the bark of the mango tree, while a grey dye was made from *deuk kbong* of the ash of the *pti* shrub.

Making dye from trees

Leak

The *leak* is a tiny insect that is red in color. It lives attached to tree branches, and the queen produces a sticky substance when she has children. When the queen dies, a nest-like residue, or scaly scab remains surrounding the tree branch. This scab-like form is also called *leak chum kralong* or *leak khmer*. When villagers needed red dye, they removed this scab-like form from the tree branch, pounding and grinding it into a powder which they boiled. A clear red dye was produced.

Tree bark

Bark was peeled or cut off trees and brushed or scraped to remove the outer layer

សត្វស្រមោល រស់នៅតោងជាប់នឹងមែកឈើ ហើយមានជាតិស្អិតដែលកើតចេញពីមេល័ក្តនៅពេលមានកូន និងមេល័ក្តងាប់ គកើតចេញជាដុំក្រមរឡើងក្រាស់រុំជាប់នឹងមែកឈើ។ ក្រមរនេះខ្មែរនិយមហៅថា ល័ក្តជុំក្រឡង់ ឬល័ក្តខ្មែរ។ ពេលត្រូវការជ្រលក់ពណ៌ក្រហម គេបេះយកក្រមរដែលនៅជាប់មែកឈើយកមកហាលឲ្យស្ងួត បុក ឬកិនឲ្យបែកជាដុំតូចា រួចយកទៅស្មោរ។ ជាតិដែលចេញពីក្រមរបានជាពណ៌ក្រហមស្រស់។

– សម្បកឈើ៖ មុនដំបូងគេយកសម្បកឈើដែលស្មោះបានមកច្រេះក្រមរខាងក្រៅចេញយកមកដំឲ្យទន់ លាងទឹកឲ្យស្អាត រួចយកមកត្រាំទឹកឲ្យលិចសម្បក និងទុករយៈពេលពីរទៅបីម៉ោងសិនទើបយកទៅស្មោរ។ ពេលស្មោរចេញពណ៌ គេយកមកច្រោះយកទឹកទៅប្រើ។

– ស្វឹកឈើ៖ ចំពោះរុក្ខជាតិខ្លះដែលគេយកស្វឹកមកធ្វើជាពណ៌ គឺគេយកស្វឹកនោះទៅបុកឲ្យម៉ដ្ឋចាក់ទឹកលាយ ហើយពូតយកកាកចេញ យកទឹកទៅប្រើសម្រាប់ជ្រលក់។

វិធីធ្វើល័ក្តបែបនេះ អ្នកណាក៏អាចធ្វើបាន។ ប៉ុន្តែជាទូទៅការលាយពណ៌របស់គេច្រើនតែធ្វើតាមការស្មាន។ ម្ល៉ោះហើយពណ៌ដែលគេទទួលបានមកពីការជ្រលក់ម្តងៗ មានការប្រែប្រួល មិនងាយនឹងបានដូចគ្នាទេ គ្រាន់តែបានពណ៌ប្រហែលគ្នា។

– ដើមត្រែ៖ គេយកដើម និងស្វឹកស្រស់ of the bark. The bark was then broken into small pieces and washed in water. The bark was covered with water and left to soak for two to three hours. The mixture was then boiled until the bark gave off color. The bark was removed and the remaining dye was decanted and ready for use.

Tree leaves

Leaves were pounded into a powder, and water was added. When the water became colored, the mixture was strained to remove the leaf material. The remaining colored water was used as a dye.

These ways of preparing dyes are very simple and almost anyone can do them. In general, in earlier times, those making dyes did not use fixed standard measurements, but instead estimated the proper amounts each time they made a dye. Thus the color of the dyes were similar but not exactly the same each time a dye was made.

Indigo

The branches and leaves of the indigo shrub were put in a large water jar which was then filled with water. The indigo was left to soak for two or three days and nights, depending on the desired color. Then the shrub material was removed from the water and some lime was added. The mixture was stirred until it became what was called *mor*.

រូបលេខ ២៥៧៖ ដើមត្រុំ។ (រូបថត៖ រៃយ៉ំ)

Figure 257: Indigo. (Photo: Reyum)

របស់វាទៅដាក់ក្នុងពាង រួចចាក់ទឹកចូលឲ្យលុម ដាក់ត្រាំពីរ ឬបីយប់ (តាមពណ៌ដែលគេចង់បាន) រួចស្រង់យកដើមចេញដាក់កំបោរចូលក្នុងទឹកនោះ និងកូរឲ្យទាល់តែកើតជា "មរ"។ ទុកមរនោះឲ្យរង ចាក់ទឹកចោលទុកកាកដែលរងនៅបាតក្រោម។ ចាក់ទឹកក្បុងចូលក្នុងកាកនោះ និងដាក់ស្ករត្នោតចូលបន្តិច បើសិនពណ៌ឡើងខ្លាំងពេក (ឡើងខ្មៅពេក) គេដាក់ចេកណាំវ៉ាទុំមួយ ឬពីរចូល កើតបានជា "ធ្នះ" ឬហៅថាតម្លើង "ធ្នះ" មានពណ៌ខៀវ។ គេអាចយកក្រណាត់ជ្រលក់បាន។ ធ្នះនេះគេអាចទទួលពណ៌បានច្រើនទៀត ឧទាហរណ៍ បើគេយកសំពត់ពណ៌ក្រហមទៅជ្រលក់ គឺបានពណ៌ខ្មៅរលោង។ បើគេយកសំពត់ពណ៌លឿងទៅជ្រលក់វិញ គឺបានពណ៌ខៀវចាស់។ បើគេយកសំពត់សទៅជ្រលក់ធ្នះ គឺបានពណ៌បៃតងចាស់ ឬពណ៌ធ្នះ។ បើគេចង់បានពណ៌ខ្មៅគេជ្រលក់ធ្នះហើយយកទៅជ្រលក់មក្លឺទៀត។

The mixture was left to stand until it became clear, and the water was removed, leaving behind a layer of sediment at the bottom of the water jar. Onto this sediment, *deuk kbong* (ash water) was poured, adding a little palm sugar as well. If the color was too strong (that is too black), one or two peeled ripe *namvar* bananas were put in the dye to turn it bluer. The mixture was then ready to be used as dye. Indigo was used with different colored cloths to make many other colors as well. For example, a dark red *sampot* dyed in indigo turned a shiny black, a yellow *sampot* dyed in indigo turned dark blue, and a white *sampot* dyed in indigo turned either green or blue depending on the strength of the dye. For a deep black fabric, cloth was sometimes dyed in indigo and then in *mcleur*.

Dying with mcleur

Dyeing with *mcleur* was done in the windy dry season between November and February. During this period, there was little rain and lots of sun for drying; it was also the season when the *mcleur* fruit were ripe. Dyeing with *mcleur* was done both on a small scale by families, and sometimes as a larger scale business. In families, cloth woven by the family was dyed with *mcleur* along with lengths of *prai* imported from abroad. Dyeing businesses generally dyed large quantities of *prai*, especially *prai muy a*, most of which was

imported from abroad. Imported *prai muy a* was mostly white, and it was dyed black in Cambodia before being sold. Local people liked to use *prai muy a* that had been domestically dyed because it had a smooth shiny black color which lasted long and did not turn red like the *prai muy a* imported from abroad that was already black before it got to Cambodia. Even if they bought this black imported *prai muy a*, which was cheaper than the domestically dyed *prai*, people liked to take it and have it dyed with *mcleur* again, although its black coloring would not last as long since the imported black *prai muy a* had a kind of oily finish to which the *mcleur* dye did not stick very well. Businesses which specialised in dyeing with *mcleur* were generally located along the rivers since this made it easy to rinse dyed clothing. Such businesses generally had large fields of grass so that when they had dyed the cloth and laid it out to dry, it would not be dirtied by dirt or sand that would make the *prai muy a* less smooth. In the past, *mcleur* dyeing businesses prospered in Preah Brasop, Preak Takong, and Preak Tamak in Kandal Province, but today these businesses no longer exist.

In order to dye cloth with *mcleur*, the *mcleur* fruit was pounded with a foot powered mortar and pestle for businesses, and a small hand mortar and pestle for family dyeing.

– ការជ្រលក់ ឬផ្តេកផ្លែមក្រឿ [៦]៖ ការជ្រលក់ ឬផ្តេកផ្លែមក្រឿ ច្រើនធ្វើនៅរដូវរំហើយ (ចាប់ពីខែ១០ ដល់ខែ២)។ ព្រោះគ្មានភ្លៀង ហើយមានកម្តៅខ្លាំង ហាលឆាប់ស្ងួត ពិសេសជារដូវមក្រឿផ្លែ។ ការផ្តេកមក្រឿនេះមានទាំងផ្តេកតូចតាចតាមគ្រួសារ និងជាមុខរបរកសិដ្ឋ។ ការផ្តេកតាមគ្រួសារមានផ្តេកគ្រណាត់ត្បាញខ្លួនឯង និងព្រៃដែលនាំចូលពីបរទេស។ ឯការផ្តេកជាមុខរបរកសិ ច្រើនផ្តេកគ្រណាត់ព្រៃដែលនាំចូលពីបរទេស មានព្រៃមុយអាជាដើម។ ប្រភេទព្រៃមុយអានេះនាំចូលមកច្រើនតែពណិស ហើយយកមកផ្តេកខ្មៅនៅក្នុងស្រុក។ ខ្មែរនិយមប្រើព្រៃមុយអាដែលផ្តេកក្នុងស្រុក ព្រោះមានពណិខ្មៅរលោងល្អ ជាប់ជ្រានយូរ មិនឡើងក្រហមដូចព្រៃដែលនាំចូលមកមានពណិខ្មៅស្រាប់នោះទេ។ ទោះបីតេទិញព្រៃមានពណិខ្មៅស្រាប់ក៏តេនិយមយកមកផ្តេកមក្រឿបន្ថែមទៀត។ តែមិនជាប់ខ្មៅល្អដូចព្រៃដែលផ្តេកក្នុងស្រុក (ដោយសារមានជាតិប្រៃ)។ ព្រៃដែលនាំចូលមកមានពណិខ្មៅស្រាប់មានតម្លៃថោកជាងព្រៃដែលផ្តេកក្នុងស្រុក។ នៅស្រុកខ្មែរកន្លែងផ្តេកច្រើននៅតាមមាត់ទន្លេ ព្រោះងាយដោកគក់ និងមានវាលស្មៅធំ ដើម្បីហាលព្រៃដែលគេផ្តេករួច កុំឲ្យប្រឡាក់ដី ឬជាប់គ្រាប់ខ្សាច់ធ្វើឲ្យសាច់ព្រៃមិន

---

[៦] លោកតាសួន អាយុ៧៨ឆ្នាំ នៅស្រុកមុខកំពូល ខេត្តកណ្តាល។ បើសិនគេជ្រលក់ពណិផ្សេង គេច្រើនហៅថាជ្រលក់ពណិ តែបើជ្រលក់ពណិខ្មៅ គេច្រើនហៅថាផ្តេក។

រូបលេខ ២៥៨៖ ផ្លែមក្ដី។ (រូបថត៖ រៃយំ)

Figure 258: *Mcleur*, the fruit used to dye clothing black. (Photo: Reyum)

រលោងល្អ។ តំបន់ផ្តេកព្រៃ មាននៅព្រះប្រសព្ធ, ព្រៃតាតង៌, ព្រៃតាមាក់ ក្នុងខេត្តកណ្តាលជាដើម តែបច្ចុប្បន្ននេះពុំឃើញមានផ្តេកទៀតទេ។

ដើម្បីផ្តេកមក្ដី គេយកផ្លែមក្ដីមកបុក (ជាន់ត្បាល់ក្តឹង) ហើយយកមកលាយជាមួយទឹក។ មុនដំបូងគេលាយទឹកឲ្យខាប់បន្តិច យកទៅច្រោះយកកាកចេញ ចាក់ទឹកមក្ដីចូលក្នុងធុងឈើវែងមួយ (មានប្រវែងជាង១ម៉ែត្រ កម្ពស់ប្រហែល៣-៤តឹក) ដោយយកធុងនោះដាក់នៅពីក្រោមស្នូមួយ។ ពេលយកព្រៃមកផ្តេក គេច្របាច់ព្រៃនោះឲ្យទឹកមក្ដីចូលជោកសាច់ព្រៃល្អហើយ គេលើកយកមកគង៌លើស្នូនោះ ដើម្បីឲ្យទឹកមក្ដីស្រក់ចូលក្នុងធុងវិញ (ធ្វើបែបនេះកុំឲ្យខាតមក្ដីច្រើន)។ រួចទើបគេយកទៅហាលលើស្នូ ដោយដាក់ផ្នែកព្រៃឲ្យត្រូវថ្ងៃ (គេមិនហាលនៅលើស្នូទេ ព្រោះទឹកមក្ដីនឹងហូរចុះមក

The pounded pulp was mixed with a little water to make a thick liquid.[5] This liquid was strained and decanted to remove dregs and material residue. The remaining liquid was poured into a long container (more than one meter long and 30-40 centimeters high) made of wood. A *snow* or simple rod for hanging cloth was placed over this container. When the *prai* was dyed, it was pushed into the container with the *mcleur* water and kneaded to make sure it was completely soaked with dye. The *prai* was then lifted out of the dye and hung over the *snow*, letting the *mcleur* water drip back into the container (this method meant that not much dye was wasted). Then the *prai* was spread out to dry in the sun. The *prai* was not dried on the *snow* since this would make the dye run down to the bottom of the cloth resulting in an uneven black color. When the *prai* was dry, it was dyed once again and then dried once again. In one day, they dyed and dried a length of *prai* two to three times. In the late afternoon, they took the *prai* that they had dyed with *mcleur* that day and washed it so that there was not too much *mcleur* deposited in it. This process of dyeing and drying was repeated for three or four days on the same

5 Only enough *mcleur* was pounded for one day. If *mcleur* water was kept overnight, it became foamy and the dye no longer stuck to the cloth well.

ក្រោម ធ្វើឲ្យព្រៃមានពណ៌ខ្មៅមិនស្មើគ្នា)។ ពេលស្ងួតគេយកព្រៃនោះទៅជ្រលក់ និងហាលម្តងទៀត។ ក្នុងមួយថ្ងៃគេជ្រលក់ព្រៃនោះពីរទៅបីដង។ ដល់ពេលល្ងាចបន្តិចគេយកព្រៃដដែលនោះទៅជោកទឹកចេញ និងហាលឲ្យស្ងួតកុំឲ្យមក្ងឹកច្រើនពេក។[៧] គេធ្វើបែបនេះរយៈពេល៣ថ្ងៃ។ ដល់ថ្ងៃទី៤ គេលាយទឹកមក្ងឹកវាជាងមុន និងដាក់កំបោរ[៨] លាយបន្តិចដើម្បីឲ្យឆាប់ខ្មៅ (ជួនកាលគេយកព្រៃពណ៌សនេះទៅជ្រលក់ធ្ងន់សិន ទើបយកមកផ្តេកមក្ងឹជាក្រោយ ធ្វើបែបនេះចំណេញមក្ងឹ)។ គេវាល់ទឹកមក្ងឹ៦ធុង (មួយធុងប្រហែល៦០លីត្រ) ដាក់លាយទឹកកំបោរ៣ទៅ៤ផ្តិល ដើម្បីឲ្យឆាប់ខ្មៅ (មួយផ្តិលប្រហែល១លីត្រ) ហើយគូរឲ្យលាយចូលគ្នាបន្តាប់មកយកព្រៃជ្រលក់។គេធ្វើបែបនេះរយៈពេល៣ ឬ៤ថ្ងៃទៀតទាល់តែព្រៃខ្មៅល្អហើយ ចានគេយកទៅណេង។

ណេងគឺគេយកមក្ងឹសាគូមកលាយជាមួយទឹកឲ្យវាល្មមកុំឲ្យខាប់ពេក (បើខាប់ធ្វើឲ្យសាច់ព្រៃរឹងមិនល្អ) ហើយយកព្រៃនោះមកជ្រលក់ជាមួយមក្ងឹ

piece of cloth. On the fourth day, the *mcleur* dye was made more watery and some lime was added to the dye, causing the cloth to turn black more quickly.[6] Six containers (20 liter volume each) of *mcleur* dye were mixed with three or four *ptel* (1 liter bowl) of lime and stirred until the lime dissolved before using the mixture as dye. *Prai* was dyed in this *mcleur* and lime mixture for three to four days until it really became black. Then it was taken to *neng*.

Through the process of *neng*, sago palm was mixed with water into a thin liquid (if this liquid was too thick, the surface of the *prai* would become too stiff). The dyed *prai* was submerged in this liquid, pressing and pushing the *prai* so that it was thoroughly soaked. Then it was dried and the process is repeated over a period of two days.

---

[៧] គេបុកសម្រាប់ប្រើតែមួយថ្ងៃ។ បើបុកទុកមួយយប់ទឹកមក្ងឹឡើងពពុះរង្គើជ្រលក់មិនជាប់។

[៨] គេដាក់កំបោរក្នុងភាជនៈមួយ ចាក់ទឹកចូលកូរឲ្យលាយ។ ដំបូងគេប្រើទឹកកំបោរភាជនៈខាប់បន្តិច ចាក់លាយជាមួយទឹកមក្ងឹ ក្រោយពីលាយកំបោរបាន៤ថ្ងៃ ព្រៃឡើងខ្មៅហើយ គេលែងដាក់ទឹកកំបោរខាប់។ គេទុកទឹកកំបោរនោះឲ្យរង្គើ រួចគេដួសយកទឹកថ្លាខាងលើមកលាយជាមួយទឹកមក្ងឹ។ ធ្វើបែបនេះកុំឲ្យវារឹងពោះសាច់ព្រៃស្អាតល្អ អត់មានក្រមរ និងរឹងល្មម ។

---

[6] In order to dye white *prai* quickly, it was sometimes dyed in indigo first before dyeing it with *mcleur*. To add lime to the *mcleur* dye, lime was first put in a jar with water and stirred. At first, fairly thick lime liquid was mixed with *mcleur* dye. After two days of dyeing with this *mcleur* lime mixture, *prai* cloth would already be quite dark, and thinner lime liquid was used to continue the dyeing process. For this thinner lime, the lime liquid was allowed to settle until the water at the top was clear. This clear lime water was skimmed off and mixed with the *mcleur* dye. This thinner final dye avoided making the *prai* too stiff or scaly, and left a smooth cloth of average stiffness.

សាគូ ច្រចាច់វាឲ្យជ្រាកសព្វសាច់ព្រៃ។ គេធ្វើបែបនេះពីរថ្ងៃទើបឈប់។ គេណែនដើម្បីឲ្យសាច់ព្រៃរឹងហើយរលោងល្អ។

ចំពោះការផ្តេកមក្ងើតាមគ្រួសារ គេប្រើត្បាល់បុកតូចៗ និងមិនប្រើកំបោរលាយទេ ព្រោះគេយល់ថាមិនខ្មៅរលោងល្អ គឺគេផ្តេកមក្ងើសុទ្ធរហូតដល់ឡើងពណ៌ខ្មៅដែលគេពេញចិត្ត។ ជួនកាលខោអាវចាស់មានបំណះច្រើនក៏គេយកមកផ្តេកមក្ងើឲ្យឃើញខ្មៅស្មើដែរ។ នៅស្រុកភូមិខ្លះដែលគ្មានផ្លែមក្ងើ ឬរដូវដែលមក្ងើគ្មានផ្លែ គេយកខោអាវជ្រលក់ស្លឹកត្រស់ (យកស្លឹកត្រស់មកស្ងោរ យកទឹកមកជ្រលក់) រួចយកមកជាន់ភក់ ហើយយកទៅបោកទឹកហាល។ បន្ទាប់មកយកខោអាវដដែលនោះមកជ្រលក់ជាន់ភក់ និងបោកហាលទៀត គេធ្វើបែបនេះរហូតឡើងពណ៌ខ្មៅទើបឈប់។

ល័ក្តបានមកពីរុក្ខជាតិ ដូចជាពណ៌ក្រហមពណ៌លឿងជាដើម គេច្រើនយកមកជ្រលក់អំបោះសូត្រ តែមិនសូវជ្រលក់អំបោះធ្វើពីកប្បាសទេ លើកលែងតែមក្ងើ។ អំបោះកប្បាស គេច្រើនយកមកត្បាញជាក្រណាត់ យកមកកាត់អាវ ហើយទើបយកមកផ្តេកពណ៌ខ្មៅ។ បើចង់បានទេសឯក ឬក្រណាត់អំបោះដែលមានពណ៌ គេទិញក្រណាត់ពណ៌ស្រាប់នាំចូលពីបរទេសមកកាត់ជាសម្លៀកបំពាក់តែម្តង។

When dyeing with *mcleur* in family settings, a hand mortar and pestle was used to crush the *mcleur* fruit. Lime was generally not used in family dyeing since it was thought not to produce a good black shiny cloth. Instead, cloth was dyed with *mcleur* until it was dark enough, regardless of how many days of repeated dyeing it took to get the desired darkness. Sometimes old clothing with many patches was dyed with *mcleur* as well so that it looked black all over again. In some areas of the countryside that did not have *mcleur* fruit, or in seasons when the fruit was not available, clothing was dyed black using the leaves of the *tras* tree (the leaves were boiled and the resulting colored water was used as dye). Clothing was also sometimes stamped into the mud before being taken to wash and dry. This method was repeated until the clothing became black.

Red and yellow dyes derived from nature were generally used to dye silk thread for weaving cloth. Cotton thread was generally left white, or was dyed black using *mcleur*. Cotton thread was mostly woven into cloth for making work clothing dyed with *mcleur*. Imported color cotton cloth was generally bought in the markets.

ឯកសារ

ពណ៌ខ្មៅជាពណ៌អពមង្គលដែលទំនៀមទម្លាប់ខ្មែរមិនបានរ៉ាប់រង

"Khmer tradition has not recognised that black is an unfortunate color"

Kampuchea, July 6-7, 1951

ដកស្រង់ចេញពីអត្ថបទការសែតកម្ពុជា លេខ១៧៧៧-១៧៧៨ ថ្ងៃទី៦-៧ ខែកក្កដា ១៩៥១
(ក្នុងអត្ថបទនេះមានការកែសម្រួលអក្ខរាវិរុទ្ធខ្លះ)

និមន្តទៅទស្សនាទៅតំបន់នានា សម្តេចព្រះសុមេធាធិបតី បានឲ្យឱវាទផ្សេងៗ ដល់ប្រជាជនជាតិខ្មែរ អំពីសុជីវធម៌ ដែលជនជាតិឯកភាជ្ញត្រូវតែចេះដឹងដោយខានពុំបាន។ ក្នុងចំណោមដំបូន្មាននេះ យើងសូមលើកយកខ្លះតែមួយទេមកពណ៌នា ជូនអស់លោកអ្នកស្តាប់ គឺការកុំស្លៀកពាក់ពណ៌ខ្មៅ។

ឱវាទនេះល្អប្រសើរក្រៃលែងគួរតែប្រជាជនខ្មែរទាំងប្រុសទាំងស្រី ប្រតិបត្តិតាមកុំបីឲ្យល្អៀង ហើយឲ្យបានរួសរាន់។ ពណ៌ខ្មៅ មិនគួរនឹងយកមកស្លៀកពាក់ជាធម្មតានោះទេ ព្រោះជាពណ៌ឲ្យទោសបីប្រការគឺ៖
ប្រការ១- ជាពណ៌អពមង្គល ដែលជាតិនានាទុកជាពណ៌កាន់ទុក្ខ។ ប្រទេសខ្មែរយើងដែលគេសម្គាល់បានថា ជាប្រទេសមួយសម្បូណ៌ ដោយគោគ់សម្បត្តិប្រជាជនរកទទួលទានបានដោយស្រួល ពុំបាច់ខំពេក គួរណាស់តែបណ្តាអ្នកស្រុកមានចិត្តរីករាយសប្បាយស្លៀកពាក់ស្រស់បស់។ នេះមិនដូច្នោះឡើយ នៅទីប្រជុំជននីមួយៗ គេឃើញតែមនុស្សស្លៀកពាក់ខ្មៅងងឹតទាំងអស់ ប្រៀបដូចជាហ្វូងក្អែកទីក។ ជនបរទេសដែលមកទស្សនាប្រទេសយើងម្តងៗ ប្រហែលជាធ្លល់ថា ជនជាតិខ្មែរកាន់ទុក្ខទេដឹង បានជាស្លៀកពាក់ខ្មៅងងឹតយ៉ាងនេះ។ នេះហើយជាហេតុមួយ ដែលបណ្តាលឲ្យអ្នកប្រទេសក្រៅគេមើលងាយថា ប្រទេសយើងគ្មានអារ្យធម៌។ ចំណែកខ្លួនយើងទៀត យើងក៏អាចសង្កេតបានថា ពណ៌ខ្មៅពុំមែនជាពណ៌លើកលំអរាងកាយរបស់យើងទេ បើទុកជារូបឆោមលោមពណ៌ល្អយ៉ាងណាក៏ដោយ តែយកពណ៌ខ្មៅនេះ មកស្លៀកដណ្តប់ហើយក៏លំអនោះបែរទៅជាឌិនថយទៅវិញ។

មិនមែនគ្រាន់តែជាពណ៌អពមង្គលប៉ុណ្ណោះទេ ពណ៌ខ្មៅនេះអាចនាំឲ្យមានការភ័ន្តច្រឡំ ដល់អ្នកទេសចរក្នុងគ្រឿងសម្គាល់នៃសាសនាទៀត គឺនាំឲ្យគេស្មានមុនថាប្រជាជនខ្មែរទាំងអស់គឺជាអ្នកបួសក្នុងសាសនាមួយ

ដែលនិយមការស្លៀកពាក់ខ្មៅ។ នៅក្នុងទំនៀមទំលាប់នៃប្រទេសឥណ្ឌាកាលពីសម័យបុរាណ ពណ៌ខ្មៅគេទុកជាពណ៌នៃពួកសូទ្រៈ ដែលជាវណ្ណៈទី៤ យ៉ាងទាបបំផុត ហើយដែលពុទ្ធសាសនា ក៏មិនរាប់រង់ពណ៌នេះយកមកប្រើជាផ្លូវការដែរ។ ដូចយ៉ាងព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ញត្តិហាមមិនឲ្យបព្វជិតប្រើប្រាស់ពណ៌ខ្មៅ ដោយលើកយកសុភទ្ទភិក្ខុដែលកាលនោះ ស្លៀកដណ្តប់ពណ៌ខ្មៅអង្គាសភត្តថ្វាយព្រះអង្គមកជាដើមបញ្ញត្តិ។

យើងមិនមែនបដិសេធថា សម្លៀកបំពាក់ពណ៌ខ្មៅ គឺជាប្រដាប់ប្រើប្រាស់សម្រាប់ប្រកបការងារយ៉ាងស្រួលសំរាប់ប្រជាជនខ្មែរខ្លះ ដែលមិនសូវនិយមប្រើសាច្បិ ហើយដែលធន់ និងការប្រឡាក់ប្រឡូសនោះទេ ប៉ុន្តែទំនៀមទម្លាប់ខ្មែរគ្មានរាប់រង់ពណ៌ខ្មៅនេះ ចូលទៅក្នុងបុណ្យង៉ានណាមួយសោះ។ នៅក្នុងសេចក្តីកត់ហេតុនៃអ្នកដំណើរចិនម្នាក់ឈ្មោះចៀវតាកួាន ដែលមកប្រទេសយើងក្នុងសម័យអង្គរធំនោះ បានសរសេរថា ប្រជាជនខ្មែរនិយមប្រើប្រាស់សម្លៀកបំពាក់មានពណ៌ ដូចជានៅប្រទេសឥណ្ឌាដែរ គឺព្រះមហាក្សត្រិយ៍ទ្រង់ព្រះពស្ត្រពណ៌ក្រហម ក្រៅពីនេះពណ៌ស និងពណ៌ដទៃទៀតតាមវណ្ណៈ។

ជាការពិតដូច្នោះមែន នៅក្នុងសម្លៀកបំពាក់ខ្មែរបុរាណ គេឃើញមានតែហូល, ផាមួង, អន្ធញ, ល្បើក នឹងក្រមាពណ៌ផ្សេងៗ ដែលក្នុងអាតរណៈទាំងនេះ គ្មានពណ៌ខ្មៅមួយសោះ។ ហើយនៅក្នុងផ្លូវការតាំងពីសម័យបុរាណមក អ្នករាជការតែងតែប្រើស្លៀកសំពត់ចង្កេះ ហើយពាក្រមា ដែលទំនៀមនេះ គេបានផ្ទាស់នៅក្នុងរាជ្យព្រះបាទឧទ័យសម័យឥដ្ឋ។ សូម្បីតែឈ្មោះសម្លៀកបំពាក់ គឺខោ និងអាវពណ៌ខ្មៅដែលខ្មែរយើងចូលចិត្តប្រើក្នុងបុណ្យង៉ានសព្វថ្ងៃនេះ ក៏បានបញ្ជាក់ឃើញច្បាស់ថា មិនមែនជារបស់ខ្មែរយើងសោះ គឺហៅថា"ខោចិន, អាវចិន"។

ប្រការ២– ក្នុងរូបនិយមវិទ្យា, គេបានពិសោធន៍ឃើញថា ពណ៌ខ្មៅជាពណ៌ស្រូបទប់នូវចំហាយក្តៅនឹងពន្លឺ, ឯពណ៌សជាពណ៌ផាត់ជះចំហាយក្តៅ នឹងពន្លឺទៅក្រៅវិញ។ ដូចជានៅក្នុងបន្ទប់មួយលាបខ្មៅ ទោះគេអុជចង្កៀងភ្លឺយ៉ាងណាក៏ដោយ បន្ទប់នោះក៏នៅតែងងឹត ព្រោះពណ៌ខ្មៅស្រូបយកពន្លឺអស់។ ឯក្នុងបន្ទប់លាបពណ៌សវិញ គេសង្កេតឃើញថាជញ្ជាំងជះពន្លឺ បណ្តាលឲ្យយើងព្រិលភ្នែក។ ដោយហេតុនេះហើយបានជាបន្ទប់ដេក គេមិននិយមលាបពណ៌សទេ ព្រោះនាំឲ្យចាំងភ្នែកដេកមិនលក់។ បើពណ៌ខ្មៅស្រូបចំហាយក្តៅយ៉ាងនេះ តើយើងគប្បីយកមកស្លៀកពាក់ ឬទេ នៅប្រទេសដែលក្តៅ ដូចជាប្រទេសយើងនេះ? ថាពុំគួរទេ។ យើងស្លៀកពាក់ក៏ដើម្បីការពារខ្លួនយើងនឹងកំដៅព្រះអាទិត្យ បើសម្លៀកបំពាក់ពណ៌ខ្មៅ មិនអាចការពារកាយយើងបាន ដោយពណ៌នេះ

ស្រូបចំហាយក្តៅ តើយើងយកមកប្រើធ្វើអ្វី។ មកពីស្លៀកខ្មៅយ៉ាងនេះហើយ បានជានៅប្រទេសយើងពុំមានមនុស្សអាយុវែងដូចប្រទេសគេសោះ ព្រោះសម្លៀកបំពាក់ខ្មៅ ធ្វើឲ្យកាងកាយក្តៅក្រហាយទ្រុឌទ្រោមធាប់ណាស់។ ហេតុនេះគួរគប្បីយើងបោះចោលសម្លៀកបំពាក់ពណ៌នេះចេញ ហើយនិយមប្រើពណ៌សវិញ ដែលជាពណ៌មានគុណសម្បត្តិផាត់ចំហាយក្តៅឲ្យឆ្ងាយចេញ។ ចំហាយក្តៅមិនប៉ះពាល់ដល់កាងកាយហើយខ្លួនយើងក៏បានត្រជាក់ស្រួល មិនបែកញើសអន្ទះអន្ទែង ការងារដែលយើងធ្វើក៏បានចម្រើនតាមនេះទៅដែរ។ បើការងារចម្រើនទៅហើយ សម្បត្តិទ្រព្យក៏នឹងរត់មករកយើង ហើយប្រទេសទៀត ក៏នឹងសម្បូណ៌ដោយធនធានទៅដែរ។

ចោលសម្លៀកបំពាក់ខ្មៅ មកយកសម្លៀកបំពាក់សនេះ ជាឧបាយមួយក្នុងកិច្ចការពារខ្លួនយើង ចំពោះសេចក្តីវិនាសដែលបណ្តាលមកពីកំដៅព្រះអាទិត្យ។ បើយើងធ្វើបានយ៉ាងនេះជនជាតិបរទេសគេក៏អាចនឹងសរសើរយើងបានថា យើងនេះជាបុគ្គលមានប្រាជ្ញា ចេះដឹងក្បួនវិទ្យាសាស្ត្រ រកឧបាយប្រយុទ្ធនឹងកំហឹងទិនវ័ន៍។

ប្រការ៣- ពណ៌ខ្មៅជាពណ៌លាក់មន្ទិលក្រខូក់ មានញើសក្អែលជាដើម។ មានជនខ្លះបានថ្លែងថា ពណ៌ខ្មៅជាពណ៌ស្រណុកស្លៀកពាក់ ពីព្រោះមិនសូវប្រឡាក់។ បើយើងសួរជនទាំងនេះទៅវិញថា ហេតុអ្វីក៏សម្លៀកបំពាក់ខ្មៅ មិនសូវប្រឡាក់, ញើសក្អែលមិនហ៊ានជាប់នឹងសម្លៀកបំពាក់នេះ ឬអ្វី? ជនទាំងនេះនឹងឆ្លើយថាប្រឡាក់ដែរ តែគេមើលពុំឃើញ។ អស់លោក-អ្នក សត្រូវដែលមើលពុំឃើញនេះហើយជាសត្រូវគាចបំផុតដែលយើងពុំអាចនឹងការពារបាន។ សម្លៀកបំពាក់ក្រខូក់ នាំបណ្តាលឲ្យយើងមានជម្ងឺគ្រប់យ៉ាង មានជម្ងឺកមរមាស់ជាដើម។ មិនត្រឹមតែប៉ុណ្ណោះទេ ថែមទាំងជះសម្ផុយទៅលើអ្នកជិតខាងផង។ បើមន្ទិលក្រខូក់ទាំងនោះយើងមើលឃើញទៅវ៉ា យើងអាចនឹងមានសេចក្តីខ្មាស់អៀនយកសម្លៀកបំពាក់នោះទៅបោកសម្អាត។ បើសម្លៀកបំពាក់ខ្មៅលាក់កំបាំងមន្ទិលក្រខូក់ទាំងនោះហើយ សេចក្តីខ្ជិលក៏កើតមានឡើងក្នុងសណ្ឋានចិត្តរបស់យើង បណ្តាលឲ្យយើងស៊ូទ្រាំស្លៀកពាក់ទាំងក្រខូក់ដូច្នេះទៅ ព្រោះមានអ្នកណាគេដឹង គេឮ គេឃើញផង នឹងនាំឲ្យយើងមានសេចក្តីខ្មាស់អៀន។ ម្ល៉ោះហើយជម្ងឺរោគា ក៏នឹងមានដល់រូបកាយយើង ព្រោះយើងបានបើកទ្វារចំហទុកទទួលស្រាប់។ សារុបសេចក្តីទៅឃើញថា អ្នកនិយមស្លៀកខ្មៅជាមនុស្សស្មោគគ្រោក ខ្ជិលច្រអូសនឹងសម្អាតសម្លៀកបំពាក់, ជាមនុស្សធ្វើកម្មវេទនាដល់ខ្លួន, ជាមនុស្សដេកស្រែកហៅរកតែជម្ងឺព្យាធិ, ជាមនុស្សមានពុតត្បុតចង់តែលាក់ការក្រខូក់។ ឯមនុស្សត្រង់ដែលមានសណ្ឋានចូលចិត្តនឹងការស្អាត គេរមែងនិយមស្លៀកស

ព្រោះស្រណុកដីធ្លាប្រឡាក់ ឬមិនប្រឡាក់។ មិនតែប៉ុណ្ណោះទេ, អ្នកស្លៀកពាក់ខ្មៅ គឺជាមនុស្សស្រួលនឹងរាងកាយខ្លួន ដែលកំពុងតែត្រូវការសេចក្តីតាក់តែងនឹងត្រូវការអនាម័យ។ យើងសូមជម្រាបជាពិសេសថាក្នុងពេលដែលអាមេរិចកាំងទម្លាក់គ្រាប់បែកបរមាណូនៅហ៊ីរ៉ូជីម៉ា ប្រទេសជប៉ុននោះ គេបានសង្កេតឃើញថា បណ្តាជនដែលនៅចម្ងាយពីទីគ្រាប់បែកធ្លាក់ចំនួន២គីឡូម៉ែត្រ ក៏បានទទួលគ្រោះថ្នាក់ដែរ។ អ្នកដែលទទួលគ្រោះថ្នាក់នោះ គឺសុទ្ធតែអ្នកដែលស្លៀកពាក់ខ្មៅទាំងអស់។ ជនណាដែលស្លៀកពាក់សំពត់ប្រភ្នាក់សខ្មៅ ត្រូវខ្លោចតែកន្លែងពណ៌ខ្មៅទេ ត្រង់កន្លែងសនៅជាទាំងអស់។ អ្នកសង្កេតការណ៍ខាងវិទ្យាសាស្ត្រ បានអធិប្បាយពន្យល់ថា បានជាអ្នកស្លៀកខ្មៅត្រូវគ្រោះថ្នាក់យ៉ាងនេះមកពីពណ៌ខ្មៅស្រូបចំហាយបរមាណូ។

សេចក្តីដែលយើងបានវិពណ៌នាមកនេះ នាំឲ្យពិធីបុណ្យខ្មែរទាំងឡាយ មានសេចក្តីទង្គិចចិត្តនឹងពណ៌ខ្មៅដែលនាំឲ្យអន់ថយដល់តម្លៃនៃសម្លៀកបំពាក់ខ្មែរ ក្នុងសម័យដែលប្រទេសយើងកំពុងតែឈានជំហានយ៉ាងធំទៅកាន់អារ្យធម៌នេះ។ យើងមានសង្ឃឹមយ៉ាងមាំថា យោបល់របស់យើងនេះ នឹងបានជាទីត្រិះរិះនៃប្រជាជនទូទៅ ហើយនឹងបានជាគ្រឿងសម្អាត ទំនៀមទម្លាប់មិនល្អ ដែលចូលមកជ្រៀតជ្រែកក្នុងប្រពៃណីយើង ដែលនាំឲ្យមានសេចក្តីរិះគន់ដល់ប្រជាជាតិយើង នឹងដល់ការគោរពលទ្ធិសាសនាសម្រាប់រដ្ឋរបស់យើងនោះផង។

ការតបនឹងកាសែតកម្ពុជាដែលចេញថាពណ៌ខ្មៅជាពណ៌អពមង្គលដែលទំនៀមទម្លាប់ខ្មែរមិនបានរាប់រង

(ដកស្រង់ចេញពីអត្ថបទទស្សនាដ្ឋីនារី លេខ៩, ថ្ងៃទី៨ មករា ឆ្នាំ១៩៥១)

Reply to the *Kampuchea* article in *Neary*, 1951 Volume 9

កាសែតកម្ពុជាលេខ១៧៧៧–១៧៧៨ ពីថ្ងៃទី៦–៧ កក្កដា ១៩៥១ ទៅទំព័រទី២ មានអធិប្បាយជាយ៉ាងពិស្តារថាកុំឲ្យស្ត្រីខ្មែរស្លៀកសំពត់ខ្មៅឲ្យសោះដោយអ្នកនិពន្ធកាសែតនេះបានយល់ឃើញថា: "ពណ៌ខ្មៅជាពណ៌អពមង្គល" ហើយមួយទៀតតាំងពីបូរាណមក ខ្មែរមិនដែលមានទំនៀមទម្លាប់និយមស្លៀកពាក់ខ្មៅសោះ។

កាលបើយើញរឿងនេះហើយ នារីខ្មែរទាំងឡាយក៏បានតវ៉ាថា: "ចោលសំពត់ខ្មៅមិនបានទេ!" ដូចមានលិខិតអ្នកស្រីស៊ីផាន់ ស្រង់យកមកចុះដូចខាងក្រោមនេះជាភស្តុតាងស្រាប់។

តែសមាគម "ខេមរសេហជីវិនី" សូមជម្រាបសួរដល់នារីខ្មែរទាំងអស់ ទាំងក្នុងរាជធានី ទាំងក្នុងខេត្តថា មានយោបល់យល់យើញយ៉ាងណាដែរ ចំពោះការហាមមិនឲ្យស្លៀកពាក់ខ្មៅយ៉ាងនេះ។

យើងមានសេចក្តីសង្ឃឹមថា អស់អ្នកនាងទាំងឡាយដែលជាអ្នកស្នេហាជាតិ ចង់ឲ្យជាតិមានកិត្យានុភាពល្អដែល មុខតែឈឺក្បាលតបនឹងរឿងនេះជាមិនខាន ព្រោះរឿងសម្លៀកបំពាក់ និងពណ៌សម្លៀកបំពាក់ជាគ្រឿងសម្គាល់មួយយ៉ាងសំខាន់របស់ជាតិ"។

ស្ត្រីខ្មែរនឹងអាចចាកចោលសំពត់ខ្មៅតែម្តង ហើយទៅប្រើតែសំពត់ពណ៌សុទ្ធក៏ពុំបានឡើយ។ ដូចជាដើរផ្សារនឹងទៅធ្វើការងប៉ុយរ៉ូជាដើម នឹងចោលសំពត់ខ្មៅសោះពុំកើតទេ។ មួយទៀតសំពត់ខ្មៅខ្ញុំយល់ឃើញថាសមរម្យទៅនឹងអាវពណ៌ណាស់ ព្រោះដូចជាអាវពណ៌ខ្លះប្រើនឹងសំពត់ពណ៌ពុំបាន ដោយមកពីឆើតភ្លោភ្លាវពេក។ ស្ត្រីខ្មែរនៅតាន់ទំនៀមពីបូរាណខ្លះមិនទាន់ចោលអស់សោះនៅឡើយទេ ដូចជាស្រីដែលមានប្តីនឹងមានកូនខ្លះជាច្រើនទៅហើយនឹងនិយមប្រើតែសំពត់ពណ៌ពុំបាន ព្រោះមនុស្សស្រុកយើងមិនទាន់ចុះចិត្តដូចស្រុកគេធំៗដែលគេស៊ីវិល័យណាស់ទៅហើយនោះទេ គឺនៅអេចអូចបូញមាត់បត់ដំដៃជាខ្លាំងណាស់ ។ល។ មួយទៀតសំពត់ពណ៌ស្លៀកដើរផ្សារទិញត្រី ឬទៅជួយបុណ្យសពដូចបុណ្យដារជាដើម តែប្រឡាក់ហើយបោកមិនជ្រះទេ ហើយតែកាលណាបោកមិនជ្រះហើយតើនឹងអាចយកមកស្លៀកដើរចេញក្រៅផ្ទះបានទៀតទេ! មើលទៅប្រហែលថាទេជាដាច់ខាតហើយ! ដូច្នេះគោងផ្ញាស់ថ្មីទៀត។ ឯសំពត់ពណ៌បោកតែ៣ ឬ៤ដងចេញស្វកពណ៌អស់។ ហេតុនេះខ្ញុំយល់ឃើញថា ប្រើសំពត់ពណ៌ចុះជាងសំពត់ខ្មៅណាស់។

បើចុះជាងយ៉ាងនេះស្ត្រីខ្មែរដែលមានប្តី ឬដែលខ្លួនឯងមានបៀវត្សស្តួចស្តើងមិនអាចប្រើតែសំពត់ពណ៌បានទេ លើកលែងតែអ្នកណាដែលមានធនធានច្រើន ឬប្តីប្រាក់ខែច្រើន។ ក្នុងសម័យឥឡូវគួរតែស្ត្រីនិយមតាមទំនើបដែរ គឺគួរតែចោលខ្មៅមែន តែថាលុះត្រាតែរាជការដាក់ទណ្ឌកម្មទើបដើរលឿនទៅមុខព្រមគ្នាបាន។ ដូចជារាជការសៀមបង្ខំឲ្យស្លៀកសំពត់ត្រឹមជង្គង់ និងមិនឲ្យពាក់ស្បែកជើងឈើ។

មួយទៀត ស្ត្រីខ្មែរស្លៀកសមិនបានទេ ព្រោះសម្គាល់ថាជាសម្លៀកបំពាក់សម្រាប់ជូនខ្មោចក្នុងគ្រួសារទៅបូជាឯអារាមណានីមួយ។


ខែរកិច្ចខ្លួន
CARE
OF
THE SELF

ក- សក់

ចាស់ៗនិយាយថា កាលពួកគាត់នៅក្មេង ស្រីក្រមុំច្រើនទុកសក់វែង ក្រោយពេលរៀបការរួច ទើបគេកាត់សក់ខ្លី ស្រួលថែទាំ។ មានន័យថា ក្រោយពេលរៀបការ ពិសេសពេលមានកូន គេលែងសូវគិតគូរពីសម្រស់ហើយ គឺគេចំណាយពេលច្រើនមកគិតពីរឿងជីវភាព និងថែទាំកូនវិញម្តង។ ដូច្នេះពេលដល់វ័យចំណាស់ ស្ត្រីមិនសូវទុកសក់វែងទេ ច្រើនកាត់ខ្លី។ ចំពោះមនុស្សប្រុស ទាំងក្មេង ទាំងចាស់ ភាគច្រើនគេកាត់សក់ខ្លី។ បើនិយាយពីម៉ូតសក់វិញ ក៏មិនសូវស្មុគស្មាញដែរ។ មកដល់ទសវត្ស១៩៥០ ទើបចាប់ផ្តើមមានម៉ូតសក់ប្លែកៗ និងមាននិយមសក់អ៊ុតដូចជាសក់អូមេហ្គា, សក់អូរ៉ាល់ ។ល។ ឯប្រុសវិញនិយមកាត់សក់ហោតិល, សក់ឡុងសុង់ជាដើម។

ចំពោះការថែរក្សាសក់ ត្បិតមិនទាន់មានសាប៊ូ ឬប្រេងសម្ផស្សដូចសព្វថ្ងៃ ក៏គេចេះថែរក្សាសក់ឲ្យបានស្អាតដែរ ហើយរបៀបថែរក្សាសក់នោះខុសប្លែកពីរបៀបរបស់មនុស្សបច្ចុប្បន្ន។ សក់មិនត្រឹមតែជាផ្នែកមួយនៃសម្ផស្សទេ នៅក្នុងទំនៀមទម្លាប់ខ្មែរ សក់មានន័យទាក់ទងនឹងពិធីឆ្លងវ័យ និងជំនឿផ្សេងៗដែលនៅតែមានរហូតមកដល់សព្វថ្ងៃក្នុងសង្គមខ្មែរ។

នៅក្នុងអត្ថបទនេះ យើងនឹងលើកយកបួនចំណុចមកអធិប្បាយ ក្នុងនោះមាន ម៉ូតសក់ខ្លះដែលបានពីការសាកសួរចាស់ៗ, ជាងកាត់សក់, ជំនឿលើសក់ និងការថែរក្សាសក់។

Hair

According to our elderly interviewees, teenage girls used to wear their hair long. After they had married, they cut their hair short so that it was easier to take care of. This could be interpreted to mean that once girls had married, particularly when they had children, they did not think so much about their appearance and rather concentrated on making a livelihood and taking care of their children. Elderly women generally kept their hair short as well. In the past, most boys and men wore their hair short. Hair styles remained simple, and it was only in the 1950s that more complicated styles emerged. Women began to perm their hair in styles called Omega and Aureal, while men began to cut their hair in styles called *howtel* and *long song*.

Although soaps and shampoos were not widely available in the early 20th century, people knew how to keep their hair clean using methods quite different from those used today. In Khmer culture, hair and hair styling was not only thought of as an element of beauty, but also as something which has meaning in rites of passage and various belief systems which endure into the present. In what follows, we discuss some of the hair styles that our elderly interviewees remember, as well as hair cutting, beliefs relating to hair, and the care of the hair.

ម្ជុតសក់

ម្ជុតសក់ក៏មិនខុសប្លែកពីសម្លៀកបំពាក់ដែរ គឺប្រែប្រួលទៅតាមសម័យកាល និងការនិយមរបស់មនុស្សម្នាក់ៗអាស្រ័យទៅលើវ័យផងដែរ។ សក់អាចធ្វើឲ្យមុខមាត់ប្រែប្រួលបាន ដូចអ្នកខ្លះនៅក្មេង តែដល់កាត់សក់មើលទៅដូចជាមនុស្សចាស់ ឯខ្លះឃើញកាន់តែស្អាត និងក្មេងជាងវ័យក៏មាន។ បច្ចុប្បន្នគេខិតខំប្លែម្ជុតឲ្យប្លែកៗ បំពេញតាមសេចក្តីត្រូវការរបស់មនុស្ស។ ម្ជុតសក់ទាំងនោះច្រើនទទួលឥទ្ធិពលពីបរទេស ដូចជាតាមរយៈភាពយន្តអាមេរិកកាំង, ភាពយន្តចិន, ភាពយន្តកូរេ, ភាពយន្តឥណ្ឌា ពិសេសគឺភាពយន្តថៃ ដែលមានឥទ្ធិពលខ្លាំងមកលើស្រទាប់យុវវ័យ។ ម្យ៉ាងទៀតជាងកាត់សក់ច្រើនទៅរៀនកាត់សក់ពីប្រទេសថៃ និងអ្នកខ្លះកាត់សក់តាមគំរូរូបភាពប្លែកៗដែលកាតាឡុកមកពីប្រទេសថៃ។ ស្ត្រីនិយមធ្វើសក់ប្លែកៗតាមកាតាឡុកបរទេស នៅពេលចូលរួមក្នុងពិធីភាត្រីសមោសរ ពិធីមង្គលការ និងពិធីផ្សេងទៀត។ សព្វថ្ងៃនេះ មនុស្សស្រីខ្លះច្រើនទុកសក់ស្ងួត អ្នកខ្លះសក់វែងតែមិនសូវត្រង់ស្អាត គេទៅអ៊ុតសក់ត្រង់ដើម្បីឲ្យទាន់សម័យ ទោះការអ៊ុតនោះមានតម្លៃខ្ពស់ក៏ដោយ។ ខុសប្លែកពីជាងដប់ឆ្នាំមុន ដែលភាគច្រើននិយមអ៊ុតសក់ទាំងស្រី ទាំងប្រុស ដូចជាសក់ស្ពុន, សក់បវរកញ្ញាថៃ, សក់ជាញ់ហាយ[9] ជាដើម។

[9] សក់ជាញ់ហាយជាសក់អ៊ុតមានភ្លីតូចៗដូចសរសៃនំជាញ់ហាយ។

Hair Styles

Like clothing, hair styles change according to individual tastes and the age of the person, as well as to the more general fashions of the particular time. Hair cuts and styling affect people's appearance. If young people cut their hair in a certain way, they can look like adults, while others can improve their appearance or seem younger with a flattering hair style. Today, we see a tendency to want hair styles that are new and different; often these styles distill foreign influences drawn from American, Chinese, Korean, Indian, and particularly Thai films which have a great impact on young viewers. Many hairdressers today have learned to cut hair in Thailand or from Thai hair stylists, and they use printed posters and catalogues from Thailand as models for the hair cuts they give. Cambodian women especially like to do their hair in elaborate ways, often choosing hairstyles modeled on examples found in catalogues when they go to parties, weddings, or for other special occasions. Today, it is fashionable for women to wear their hair long and straight. If their hair is not naturally straight, some women will spend considerable amounts of money to straighten their hair in order to be fashionable. Styles today are very different from those worn more than ten years ago when both male and female clients liked

នៅដើមសតវត្សទី២០ ស្ត្រីភាគច្រើនកាត់សក់ខ្លី។ មនុស្សស្រីដែលមានសក់វែងបួង គេច្រើនសម្គាល់ថាជាស្រីក្រមុំ។ តែក្រោយពេលរៀបការហើយ ទើបគេកាត់សក់ខ្លី។ ចំណែកស្ត្រីជនជាតិចិន ឬខ្មែរកាត់ចិនវិញ ភាគច្រើនទុកសក់វែងបួងរហូតដល់ចាស់។ តាមសម្តីលោកយាយជូ សារឿន អាយុ៧៧ឆ្នាំ នៅខេត្តព្រៃវែង និយាយថា "នៅក្មេងខ្ញុំទុកសក់វែងបួង ហើយអ្នកខ្លះនៅពេលគេការួចមួយខែឬពីរខែ គេកាត់សក់ខ្លី។ តែខ្ញុំទុកសក់វែងបានយូរជាងគេ ព្រោះប្តីខ្ញុំចិន គាត់មិនឲ្យកាត់សក់ខ្លីទេ"។ លោកយាយស៊ីម សារិន អាយុ៧៦ឆ្នាំ នៅខេត្តស្វាយរៀង និយាយថា "សក់ខ្ញុំបួងរហូតដល់អាយុជាង៣០បានកាត់ខ្លី។ ខ្ញុំចូលចិត្តបួងចុកខ្លួនឯង ខ្លះថាខ្ញុំដូចចាម"។ លោកយាយមុិច អាយុ៨៩ឆ្នាំ នៅខេត្តកណ្តាល និយាយថា "នៅក្មេងខ្ញុំទុកជុកដល់អាយុ១៥ឆ្នាំបានកោរ។ ក្រោយពីកោរជុកហើយកាត់តែសក់ផ្ការ៉ូវ ទុកវែងមិនបានទេ ឲ្យតែសក់វែងគៀសដាក់លើត្រចៀកបាន កាត់ទៀតហើយ។ អ្នកខ្លះគេកាត់ស្ទាបចាប ខ្លះកាត់ស្តែក្តោបតាមគេចូលចិត្ត។ កាលជំនាន់ខ្ញុំនៅក្មេងគ្មានសក់វែងដូចសព្វថ្ងៃទេ មានតែត្រឹមស្តែក្តោប។ បើអ្នកណាទុកសក់វែងត្រឹមក ឬបុមបេ ជាស្រីមិនល្អ រកគល់ទៅរកស្រីសំជីង"។ លោកយាយអ៊ុន ឈុំ អាយុ៨៦ឆ្នាំ នៅព្រៃកលាប ក្រុងភ្នំពេញ និយាយថា "ខ្មែរគ្មាននរណាទុកសក់វែងទេ គេកាត់សក់ខ្លី មានតែចិនវាដែលទុកសក់វែង"។ ជាទូទៅមនុស្សប្រុសកាត់

to get perms in styles called *ston*, the [Thai] beauty queen style, and the *bain hoy* style.[7]

At the beginning of the 20th century, most adult Khmer women kept their hair cut short. Women with long hair tied in a bun were generally understood to be virgins. When they married, these women cut their hair short. Chinese or Chinese-Khmer women tended to keep their hair long, tied in buns, for their entire life. According to Ju Saroeun, 77 years old, "When I was young, I wore my hair long, tied in a bun. Most women, when they had been married for a month or two, would cut their hair short. But I kept my hair long for a longer time than the rest because my husband was Chinese and he didn't let me cut my hair short." Sim Saren, 76 years old, told us, "I kept my hair long, tied in a bun, until I was more than 30 years old. Then I cut it short. I liked to tie my hair into a bun myself. Some said that I was like a Cham." Mich, 89 years old, told us, "When I was little, I [wore my hair in] *duk juk* [to shave the head except for a long strand of hair left in the top center]. When I was fifteen, I shaved my head completely. After that, my hair was always cut in the *pka tkow* style. You could not leave your hair long. As soon as our hair reached our ears, we cut it again. Some

[7] The *bain hoy* was a style in which hair is permed into tight waves like the lines on a particular kind of cake.

រូបលេខ ២៥៩៖ ក្មេងទុកសក់ជុក។
(រូបថត៖ បណ្ណសារដ្ឋានជាតិ)

Figure 259: Cambodian children. (Photo: National Archives of Cambodia)

សក់ខ្លីដូចជាសក់ឡុងសុង, សក់ជ្រងផ្ការថ្កូវជាដើម។ មនុស្សប្រុសនៅទីក្រុង (ទសវត្ស១៩៣០) ច្រើនទុកសក់វែង ខ្លះសិតទៅក្រោយ ខ្លះវែកចំហៀង ខ្លះវែកចំកណ្តាល តាមការចូលចិត្តរបស់មនុស្សម្នាក់ៗ។[10] ចំពោះកូនក្មេងច្រើនទុកជុក ហើយបួង បើកូនអ្នកក្រគ្រាន់តែបួង បើកូនអ្នកមានបួងជុករួចមានដោតពិនជាការលំអ។ ជួនទម្លាក់សក់ជុកនោះចុះរួចយកមកសៀតត្រចៀក។

ពេលមានពិធីផ្សេងៗអ្នកដែលមានសក់វែងគឺគ្រាន់តែសិតសក់ឲ្យស្អាត រួចបួង ហើយអ្នកខ្លះមាន

cut their hair in the sparrow wings style. Some cut their hair in the cabbage style. It depended on what they liked. When I was little, they didn't wear their hair long like they do today. It was only as long as the cabbage head style. If someone left their hair long, down to their neck or in the *bombei* style, they were considered a bad woman on their way to becoming a prostitute". Oun Chum, 86 years old, told us, "None of the Khmer kept their hair long. They cut their hair short. Only the Chinese kept their hair long."

In the early 20th century, men generally cut their hair short in styles such as the *long song* and the *chrung pka tkow*. In the 1930s, men living in urban settings began to have slightly longer hair styles which they either combed back, parted on one side, or parted in the middle, according to their individual taste.[8] Children generally either wore their hair long, tied in buns if they were poor, or had the *duk juk* style [in which the head is shaved except for a long strand of hair left in the top center] ornamented with decorative pins if their parents were wealthy. Sometimes children's hair was left to hang long, tucked behind the ears.

For ceremonies and on special occasions, those with long hair generally only

---

[10] លោកមាស ហាំ ក្រមួនលាបមាត់, ទស្សនាវដ្តីកម្ពុជសុរិយា អត្ថបទក្បាលទី១, ឆ្នាំទី៣៧, ឆ្នាំ១៩៦៩។

8 Lok Meas Ham, "Wax to paint the lips" in *Kambuja Surya*, 1965, vol.37, p.280.

ដោតស្នៀតសក់លំអ ទៅតាមធនធានដែលគេមាន។ អ្នកមានសក់ខ្លី គេគ្រាន់តែតម្រឹមជើងសក់ឲ្យគ្នាទៅវិញទៅមក និងមានលាបប្រេងល្ហុង ឬប្រេងដូងដើម្បីឲ្យសក់ទន់ រលោង តែបើអ្នកកាត់សក់ផ្ការថ្កូវលាបឲ្យសក់ឈរជ្រងល្ហ។ រហូតដល់ចុងទសវត្ស១៩៦០ នៅពេលរៀបការនៅតាមស្រុកស្រែចម្ការ គេតែងជួលផ្នួងដើម្បីបួងសក់ឲ្យកូនក្រមុំ។ សក់បួងនោះ គឺជាសក់ដែលតាគ្រូចិនអ្នកផ្នួងបួងឲ្យ ឬយកមកពាក់បន្ថែម និងមានពាក់របៃនៅលើថ្ងាសមើលទៅដូចជាម្កុដ និងមានទម្លាក់ជាអង្កាំរណោងរណោងមកត្របលើថ្ងាស។ ផ្នួងតាលពីសម័យនោះ គឺមានតែផ្នួងសក់, របៃ និងម្សៅប៉ុណ្ណោះ យកមកតែងឲ្យកូនក្រមុំ។ ប្រហែលដូច្នេះហើយ ទើបគេហៅថាអ្នកផ្នួង ដែលមានន័យថាអ្នកមកបួងសក់ឲ្យកូនក្រមុំ។ ម្យ៉ាងទៀតចំពោះមនុស្សស្រី ទោះកាលនៅក្មេងមិនបានធ្វើពិធីកោរជុក ឬបានកោរជុកក៏ដោយ ដល់ពេលរៀបការ គេមានធ្វើពិធីដកជុក គឺគេដកសក់ឲ្យចេញស្នាមជារង្វង់នៅលើក្បាល។ អ៊ំស្រីនៅ ឡៃ អាយុ៦០ឆ្នាំ នៅខេត្តកណ្តាល និយាយថា "កាលខ្ញុំរៀបការ (ឆ្នាំ១៩៦៨) ចាស់ៗឲ្យកាត់សក់ផ្ការថ្កូវ និងដកជុក។ កាលនោះឲ្យតែឃើញអ្នកណាដកសក់អញ្ចឹង ដឹងថាអ្នកនោះទើបរៀបការហើយថ្មីៗ"។ ទំនៀមបែបនេះបានបាត់បង់អស់ហើយចាប់ពីសម័យខ្មែរក្រហម។

ខាងក្រោមនេះ យើងលើកយកម៉ូតសក់ខ្លះៗពិសេសគឺសំដៅម៉ូតសក់នៅដើមសតវត្សទី២០ដល់

combed their hair neatly and wound it into a bun. Some would add decorative hair pins if they had the resources to buy them. People with short hair would trim each other's hair even at the ends, and used papaya or coconut oil to make their hair soft and shiny. Those whose hair was cut in the *pka tkow* style would use oils to make their hair stand up in spikes.

In the countryside, until the end of the 1960s, when a marriage took place, a *phnong* (or special hairdresser) was hired to arrange the bride's hair in an elaborate bun which often required the use of additional hair. The bride wore an ornamental headdress or filigree jewelry piece (like a *mongkot*), traditionally made from beads covering her forehead. In those days, the *phnong* only arranged the hair of the bride and her filigree headdress, as well as powdering the bride's face. Whether girls had the *duk juk* ceremony to shave their head (leaving a single long strand of hair) and wore their hair in this manner or not, when they were about to marry, their parents would hold a ceremony called *dauk juk* in which the hair on the top of the head would be cut in a circle around a single long strand of hair. Nou Lai, 60 years old, told us, "When I married [in 1968], the elders had me cut my hair in *pka tkow* style with *dauk juk*. In those days, you just had to see someone with hair like that to know that

ទសវត្ស១៩៧០ ដូចជាសក់បួង, សក់រេះ, សក់ឡុងសុង, សក់ជ្រងផ្កាថ្លូវ, សក់ស្តេក្តោប, សក់បុមបេ ជាដើម។ ម៉ូតសក់ទាំងអស់នេះ ឃើញនៅមានរហូតដល់សព្វថ្ងៃ ជាពិសេសមនុស្សដែលមានវ័យ៤០ឆ្នាំឡើង។

– *សក់បួង*៖ កំណត់ហេតុរបស់លោក ជីវតាក្វាន់ (នៅចុងសតវត្សទី១៣) បានសរសេរថា ចាប់តាំងពីស្តេច រហូតដល់អ្នកស្រុក ទាំងស្រី ទាំងប្រុស សុទ្ធតែបួងសក់ទាំងអស់។ អ្នកមានឋានៈខ្ពស់បួងសក់មានសៀតស្នៀតសក់ដាំត្បូងជាការលំអ។ តែអ្នកស្រុកបួងសក់ដែរ តែមិនសៀតស្នៀតសក់ និងតុបតែងលំអលើសក់ទេ[11] តាមកំណត់ហេតុនេះបានឲ្យដឹងដែរថា ខ្មែរសម័យនោះ និយមបួងសក់ទាំងស្រីទាំងប្រុស។ តាមការសាកសួរមនុស្សចាស់ៗ មកដល់ទសវត្ស១៩៥០-៦០ អ្នកដែលទុកសក់វែងបួងមានតិចតួចប៉ុណ្ណោះ។

ចំពោះរបៀបបួងសក់ គឺគេទុកសក់ឲ្យវែង កាលណាបួង គេចាប់ទាញសក់ឆ្ពត ហើយមូរចុកមកខាងក្រោយ។ ធម្មតាគេមិនលើកផ្ចង់សក់ឲ្យមកលើខ្ពស់ពេកទេ គឺគេដាក់ឲ្យផ្ចង់នោះ ទាបចុះមកក្រោមលើកញ្ជើងកបន្តិច ពិសេសស្ត្រីមានវ័យចំណាស់ចូលចិត្តបួងសក់បែបនេះ។ បើក្មេងស្រីគឺគេបួងឲ្យខ្ពស់ជាងនេះបន្តិច។ លោកយាយស៊ីម សារិន អាយុ៧៦ឆ្នាំ

they had just gotten married." This tradition disappeared during the Khmer Rouge Regime.

In what follows, we describe some types of hair styles that were popular from the late 19th and early 20th centuries to the 1970s in the region today known as Cambodia. These styles include the bun, the *reh*, the *long song*, *chrung pka tkow*, the cabbage, and the *bombei*. All these styles are still worn today, especially among those over the age of forty.

The bun

The account of Chou Ta-Kuan, the 13th century Chinese traveler, tells us that men and women, from the King to the villager, wore their hair long, pulled back in buns. High ranking officials wore hair pins with precious stones as decorations. Ordinary people wore simple buns without pins to decorate them. This record tells us that people at that time, regardless of their gender, liked to wear their hair in buns. According to our elderly interviewees however, by the 1950s and 1960s, few people still kept their hair long tied in buns.

People who kept their hair long, made a bun by pulling their hair together and rolling it tightly at the back of their head. The bun was generally not worn high on the back of the head, but rather was pinned at the

---

[11] បកប្រែដោយ លី ធាមតេង, *កំណត់ហេតុរបស់ ជីវតាក្វាន់*, ភ្នំពេញ, ឆ្នាំ១៩៧៣។

រូបលេខ ២៦០៖ ស្ត្រីបួងសក់។ តំនូរលើជញ្ជាំងព្រះវិហារវត្តកំពង់ត្រឡាចលើ ដើមសតវត្សទី២០។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 260: Women wearing their hair in buns, as depicted on the walls of Wat Kompong Tralach Leu, early 20th century. (Photo: Reyum)

រូបលេខ ២៦១៖ សក់បួង។ ដកស្រង់ពីព្រឹត្តប័ត្រផ្នែកសង្គមវិជ្ជានៅឥណ្ឌូចិន លេខ៥ ខែ៧–៩ ឆ្នាំ១៩៣០។

Figure 261: Hair worn in a bun. (Photo: *Bulletin of the Society of Indochina*. Vol.5, July-September, 1930)

នៅខេត្តស្វាយរៀង និយាយថា "កាលនៅក្មេង ខ្ញុំចូលចិត្តបួងសក់ ហើយបួងចុក ធ្វើតែខ្លួនឯង ជួនកាលបួងទម្លាក់តែទុង (គេបួងទម្លាក់ផ្នង្គសក់នោះឲ្យធ្លាក់មកដល់កញ្ចឹងក មើលទៅឃើញដូចជាតែសតូទុង) ខ្លះបួងឲ្យផុតពីក"។ ក្រៅពីនេះ នៅមានរបៀបបួងសក់ច្រើនបែបទៀតតាមការនិយមរបស់មនុស្សម្នាក់ៗ។ គេអាចបួងសក់បានទាំងនៅផ្ទះ, ទៅធ្វើការ និងចូលរួមក្នុងពិធីផ្សេងៗ។ លោកយាយប្រាក់ សេង អាយុ៧៦ឆ្នាំ ខេត្តកណ្តាល និយាយថា "ខ្ញុំនៅក្មេងទុកសក់វែងព្រលឹមឡើងសិតសក់បួងទៅចម្ការ។ តែបើមិនទៅចម្ការទេ មិនចាប់សិតទេគ្រាន់តែបួងបានហើយ"។

– សក់ជ្រងផ្កាថ្ពរ៖ សក់នេះមានរូបរាងដូចជាផ្កាថ្ពរ គឺគេកាត់រះខ្លីពីជើងសក់ប្រដេញរហូតដល់លើ ផ្នែកខាងលើក្បាលវែងជាង ហើយឈរត្រង់

nape of the neck. Elderly women particularly liked to wear their hair like this. Younger women and girls wore buns slightly higher on the back of the neck. Sim Saren, 76 years old living in Svay Rieng Province, told us, "When I was young, I liked to wear my hair in a bun and I wrapped it tightly by myself. Sometimes the bun was like the neck of a pelican (the bun was wrapped tightly but allowed to fall to the nape of the neck so that it looked like the bulge in the neck of a pelican), while other times the bun was pinned above the neck." In addition to these simple buns, there were other ways of wrapping the hair into a bun according to individual taste. Wearing hair in a bun was considered appropriate when staying in the house, for working, or for

ឬឈរជ្រង។ អ្នកមានសក់ឈរជ្រងល្អ ចូលចិត្តកាត់ដោយគេយល់ថា សក់នេះជ្រងស្អាត។ សក់ជ្រងផ្កាថ្កូវនេះ នៅដើមសតវត្សទី២០ អ្នកនៅស្រុកស្រែនិយមកាត់។ សក់ម៉ូតនេះ អាចកាត់បានទាំងស្រី ទាំងប្រុស និងតាំងពីពេញវ័យរហូតដល់ចាស់។ តែអ្នកទីក្រុងទាល់តែមានអាយុច្រើនបន្តិចទើបកាត់សក់នេះ។ មនុស្សស្រីចាស់ៗ ដែលពិសាមួរពេលទៅបុណ្យ គាត់តែងតែលាបក្រមួនមាត់ ក្រមួននៅសល់ជាប់ដៃ គាត់តែងយកមកច្របូតសក់ ឬក៏ញីលើជាតដៃ រួចយកមកលាបលើសក់ ដើម្បីឲ្យសក់ឈរជ្រង។ ខ្លះទៀតដែលមានសក់ទន់ គេលាបប្រេងល្ហុងដាក់កំបោរថែមបន្តិច ដើម្បីឲ្យសក់រឹងឈរជ្រង។ សក់ជ្រងផ្កាថ្កូវនេះ ខ្លះហៅសក់ផ្កាថ្កូវ, ខ្លះហៅសក់ជ្រង។ ប៉ុន្តែបើយើងពិនិត្យទៅលើការហៅម៉ូតសក់នេះ ជួនកាលគេហៅ

participating in various ceremonies. Prak Seng, 76 years old, told us, "When I was little, my hair was long. At dawn, I combed my hair, wrapped it into a bun, and went to the fields. If I did not go to the fields, it was not necessary to comb my hair. I just wound it into a bun."

Chrung pka tkow hairstyle

This hairstyle is compared to the spikes of the *tkow* flower. The hair is cut closely up from the nape of the neck, as is done with an electric shaver today. Hair on the top of the head is left slightly longer than the sides and stands up straight. People with thick stiff hair preferred this type of hair cut because their hair spiked beautifully. At the

រូបលេខ ៦៦២៖ សក់ជ្រងផ្កាថ្កូវ, លោកតាហង់ ភួង អាយុ៩៤ឆ្នាំ ខេត្តកណ្តាល។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 262: *Chrong pka tkow* hair style as worn by Hong Phuong, 94 years old, Kandal Province. Photographed 2002. (Photo: Reyum)

រូបលេខ ៦៦៣៖ សក់ជ្រងផ្កាថ្កូវ, លោកយាយ សេង អាយុ៨៦ឆ្នាំ នៅភ្នំពេញ។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 263: *Chrong pka tkow* hair style as worn by Prak Seng, 76 years old. Photographed 2002. (Photo: Reyum)

រូបលេខ ២៦៤៖ សក់ជ្រុងផ្ការ៉ូវ, លោកតាមោត សុខ អាយុ៧៨ ឆ្នាំ នៅភ្នំពេញ។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 264: *Chrung pka tkow* hair style as worn by Mok Sok, 78 years old. Photographed in 2002. (Photo: Reyum)

សក់ផ្ការ៉ូវ ដោយសារគេកាត់វាង់ខ្លីបន្តិច ហើយបើវាង់វែងបន្តិច គេច្រើនហៅសក់ជ្រុង។

– សក់រៈ៖ សក់នេះខាងមុខ គេទុកវែងហើយសិតទៅក្រោយ ជើងសក់ខាងក្រោយគេកាត់រៈខ្លីប្រដេញឡើងលើបន្តិច ឃើញជើងសក់ខាងក្រោយស្មើ។ ជាទូទៅមនុស្សស្រីដែលរៀបការរួច ទើបកាត់សក់បែបនេះ។

– សក់ស្វាបចាប, ស្វាបក្អែក៖ សក់នេះស្រដៀងនឹងសក់រៈដែរ គឺគេកាត់រៈខាងក្រោយបន្តិច ហើយផ្នែកខាងមុខ គេទុកវែងសិតទៅក្រោយ។ ត្រង់ជើងសក់ គេទុកឲ្យវែងធ្លាក់មកត្រឹមស្មើស្លឹកត្រចៀក។ មនុស្សស្រីដែលរៀបការរួចទើបកាត់

beginning of the 20th century, *chrung pka tkow* hairstyle was a popular hair style in the countryside for both men and women from the time they were young adults until they were old. City dwellers generally only had their hair cut in this style as they got older. Elderly women who chewed betel painted their lips with wax when they participated in ceremonies; if they wore their hair in the *chrung pka tkow* style, they would swipe the wax remaining on their hands through their hair to make it stand up more. Others with softer hair used papaya oil mixed with lime to make their hair stiffer so that it would stand up. The *chrung pka tkow* hairstyle was sometimes called the *pka tkow* hairstyle or the *chrung* hairstyle. Generally *pka tkow* means the hair is cut even closer to the head than in the *chrung* hairstyle.

The *reh* style

This hairstyle leaves the hair long in the front, but combed to the back. The ends of the hair in the back are cut evenly and are *reh*, or tapered, up (figures 265-266). Usually women who had already married cut their hair in this style.

The sparrow or crow wing hair cut

Similar to the *reh*, this hair style was tapered in the back, leaving the front hair longer and combed back with hair falling over

រូបលេខ ២៦៥៖ សក់រះ, ម្តាយក្មេកលោកតាជុំ កេន។ ថតទសវត្ស ១៩៥០។ (រូបថត៖ លោកតាជុំ កេន)

Figure 265: *Reh* hairstyle. Photographed in the 1950s. (Photo: Collection of the late Jum Kain)



រូបលេខ ២៦៦៖ សក់រះ, លោកយាយកុំ រីម អាយុ៧២ឆ្នាំ នៅភ្នំពេញ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 266: *Reh* hairstyle. Ram Rem, 72 years old. Photographed 2003. (Photo: Reyum)

រូបលេខ ២៦៧៖ សក់ស្លាបចាប, លោកយាយគួយ គីម អាយុ ៨៥ឆ្នាំ នៅភ្នំពេញ។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 267: Sparrow wing hair style, the late Kuoy Kem. Photographed 2002. (Photo: Reyum)

រូបលេខ ២៦៨៖ សក់ស្លាបចាប លោកយាយហួន អាយុ៧៧ឆ្នាំ នៅភ្នំពេញ។ ថតឆ្នាំ២០០២។ (រូបថត៖ រៃយ៉ំ)

Figure 268: Sparrow wing hair style, Huon, 77 years old. Photographed 2002. (Photo: Reyum)

សក់បៃបនេះ។ លោកយាយភុំ រឹម អាយុ៧២ឆ្នាំ នៅ ច្បារអំពៅ ក្រុងភ្នំពេញ និយាយថា "សក់ស្លាបចាប ដូចសក់រះអញ្ជើងដែរ តែគេទុកជើងសក់ខាងមុខឲ្យវែង ត្រឹមស្មើកត្រចៀក ហើយគេសិតឲ្យត្របលើស្មើក ត្រចៀក។ អ្នកកាត់សក់នេះ ច្រើនតែអ្នកនៅស្រុក ស្រែ ពិសេសអ្នកនៅខេត្តស្វាយរៀង និងព្រៃវែង"។

– សក់ស្ពៃក្តោប៖ គេកាត់ឲ្យឃើញជ៉ោង ដូចស្ពៃក្តោប ហើយគេកាត់ត្រឹមជើងសក់ខាងក្រោយ។ បើអ្នកនោះមានសក់រួញបន្តិចពីកំណើតផង កាត់សក់ ស្ពៃក្តោបឃើញជ៉ោងស្អាត។ មនុស្សស្រីដែលចូល ដល់វ័យចំណាស់បន្តិចទើបកាត់សក់បៃបនេះ។

the ears on both sides (figures 267-268). Women who had already married cut their hair in this style. Ram Rem, 72 years old, told us, "The sparrow wing style is like the *reh* style except the hair is left as long as the ears and is combed to cover the ears. This hairstyle was popular in the countryside, especially in Svay Rieng and Prey Veng Provinces."

The cabbage style

For this hair style, the hair was cut so that it bulged like the head of a cabbage (figures 269-270). The hair was cut evenly in

រូបលេខ ២៦៩៖ សក់ស្ពៃក្តោប ប្រពន្ធលោកតាមុំ សំ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 269: Cabbage hair style. (Photo: Reyum)

រូបលេខ ២៧០៖ សក់ស្ពៃក្តោប, លោកយាយកែត មុិច នៅភ្នំពេញ។ ថតចុងទសវត្ស១៩៦០។ (រូបថត៖ អ្នកម៉ឺងម៉ុម ឯម្មារ៉ែត)

Figure 270: Cabbage hair style worn by Kaet Mich. Photographed in the 1960s. (Photo: Collection of Om Emareth)

រូបលេខ ២៧១៖ សក់បុមបេ។ ដកស្រង់ពីសៀវភៅ វិជ្ជាកាត់ដេរ ដោយខ្លួនឯង ដោយអ៊ាប-ប៊ុត-សុត ទសវត្ស១៩៦០។

Figure 271: *Bombei* hairstyle. Photographed in the 1960s. (Photo: *Sewing by yourself*, by Aap Bun Soth, 1960s)

– *សក់បុមបេ៖ ជាម៉ូតសក់ដែលគេកាត់ត្រឹមពាក់កណ្តាលក តែវែងជាងសក់ស្តេក្តោបបន្តិច ហើយកាត់ឲ្យចុងជើងសក់ចំហៀងកោងមកក្រោមស្អីតត្រចៀក។ សក់នេះ គេក៏អាចហៅថាសក់ជើងកញ្ជើ ឬសក់ក្រឡឹងកក៏បាន។ សក់ម៉ូតនេះ ដំបូងមានតែអ្នកទីក្រុងនិយមកាត់។ នៅស្រុកស្រែចម្ការ ភាគច្រើនគេមិនហ៊ានកាត់សក់នេះទេ បើមាននរណាកាត់ គេនឹងគិតថាជាស្រីមិនល្អ។ តែប្រហែលនៅទសវត្ស១៩៦០ ទើបលែងមានបញ្ហាបែបនេះ។ ភាគច្រើន សក់បែបនេះមានតែមនុស្សស្រីវ័យក្មេងទេដែលនិយមកាត់។ សព្វថ្ងៃ គេមិនហៅសក់បុមបេទេ គេហៅ សក់កាវេ។*

– *សក់ឆ្នង់សុង៖ ជាម៉ូតសក់សម្រាប់មនុស្សប្រុស។ គេកាត់រេជើងសក់ខាងក្រោយឲ្យខ្លី* the back along the nape of the neck. The cabbage hairstyle was especially suitable for those with naturally curly hair, since their hair when cut in this way bulged out. Elderly women tended to cut their hair in this style.

The *bombei* style

For this hairstyle, the hair was cut slightly longer, half way down the neck. The ends of the hair on the side were cut to curve under the ears, covering them. This hair style was also sometimes called *cheung kanyji* (round basket) or *kralung ka* (lathe rounded neck). At first, during the 1950s, only city



រូបលេខ ២៧២៖ សក់ឡុងសុង, លោកតាជុំ កេន។ ថតទសវត្ស១៩៥០។ (រូបថត៖ លោកតាជុំ កេន)

Figure 272: Jum Kain with a *long song* style haircut. Photographed in the 1950s.
(Photo: Collection of Jum Kain)

រូបលេខ ២៧៣៖ សក់កូនទា ឬសក់ហោតិល, រូបថ្ពុកក្មេកលោកតាជុំ កេន។ ថតទសវត្សរ៍១៩៦០។ (រូបថត៖ ត្រួសារលោកតាជុំ កេន)

Figure 273: The duckling or *houtel* haircut. Photographed in the 1960s. (Photo: Collection of Jum Kain)

ហើយខាងលើទុកឲ្យវែងជាង។ ខ្លះសិតវែកចំហៀង ខ្លះសិតមកមុខតាមការចូលចិត្ត។

– សក់ហោតិល ឬកូនទា៖ គេកាត់រៃពីខាងក្រោយឲ្យខ្លីរាបនឹងសាច់ក្បាល។ ចំណែកផ្នែកខាងលើគេទុកវែងជាងសក់ខាងក្រោយ ប្រហែលមួយសង់ទីម៉ែត្រ។ សក់នេះសម្រាប់ក្មេងប្រុស។ បើមនុស្សចាស់ គេកាត់ឲ្យខ្លីជាងនេះ អ្នកខ្លះហៅសក់បែបនេះថា សក់កូនទា។

dwellers cut their hair in this style. In the countryside, women did not yet dare to cut their hair in this style, since the hairstyle was at first considered to be that of an improper or immodest woman. By the 1960s, however, this perception had disappeared. It was mostly young women who wore their hair in this style. Today this hairstyle is called the square style rather than the *bombei* style. We are not sure where the term *bombei* comes from, or whether it had a particular meaning.

Long song style

Men wore their hair in the *long song* style. Hair on the sides and back of the head was cut closely, while the hair on the top of

រូបលេខ ២៧៤៖ សក់កូនទា ឬសក់ហោតិល។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 274: Duckling or *howtel* haircut. Photographed 2003. (Photo: Reyum)

ជាដ៏កាត់សក់

អ្នកចេះកាត់សក់ក៏ដូចអ្នកចេះកាត់សម្លៀកបំពាក់ដែរ។ មុនទសវត្ស១៩៥០ មនុស្សភាគច្រើនចេះកាត់សក់ ពេលត្រូវការកាត់សក់ គេពឹងគ្នាទៅវិញទៅមក ស្រីកាត់ឲ្យស្រីគ្នាឯង ប្រុសកាត់ឲ្យ



រូបលេខ ២៧៥៖ ផ្ទះអ៊ុតសក់ "ផ្ការីកតាមសម័យ" ដកស្រង់ពីកាសែតកម្ពុជា លេខ១៥៩៩ ឆ្នាំ១៩៥០។

Figure 275: "Flower blossoming fashionably", a hair perming house, *Kampuchea* #1599, 1950.

the head was left longer. Sometimes the hair was parted, while other times it was combed forward.

The duckling or *howtel* hairstyle

Hair on the back and sides of the head was cut very short, or even shaved. The hair on the top of the head was left slightly longer (about one centimeter in length). Young men generally left the hair on the top of the head slightly longer, while older men cut the hair on the top of their heads quite closely.

Hair cutters

The practice of hair cutting during the early 20th century was very much like the cutting and sewing of clothing. Before the 1950s, most people had some hair cutting skills, and when hair needed cutting, they relied on each other to cut their hair. Women cut other women's hair, while men cut other men's hair. They learned to cut hair from their elders, and hair cutting was not yet a profession in which money was exchanged. The number of hair styles was limited largely to the *reh* and *chrung pka tkow* styles. Those who were skilled at hair cutting in the countryside always had neighbors asking them to cut their hair. Gradually the profession of hair cutter began to develop, especially in the cities. Mich, 89 years old



រូបលេខ ២៧៦៖ ផ្ទះកាត់សក់ "គេសាសួស្ដី" ដកស្រង់ពីកាសែតកម្ពុជា លេខ១៧៩០ ឆ្នាំ១៩៥១។

Figure 276: Haircutting house. *Kampuchea* #1790, 1951.

រូបលេខ ២៧៧៖ លោកយាយហៀង សុក ជាជាងកាត់សក់តាមផ្ទះ អាយុ៧១ឆ្នាំ នៅស្រុកមុខកំពូល ខេត្តកណ្ដាល។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 277: Huong Sok, a 71 years old haircutter who still rides her bicycle from house to house in Kandal Province, cutting people's hair. Photographed 2003. (Photo: Reyum)

ប្រុសៗ។ គេចេះកាត់តាគ្នា កាត់ដោយគ្មានយកលុយ។ ម្យ៉ាងដោយសារកាលនោះគ្មានម៉ូតសក់ច្រើនមានតែសក់វែង សក់ជ្រងផ្ដាច្ដូវជាដើម។ អ្នកចេះកាត់សក់ណាដែលកាត់សម តែងមានអ្នកស្រុកជាមួយគ្នាមកពីងពាក់ឲ្យជួយកាត់។ ពេលនោះប្រហែលមានអ្នកប្រកបរបរកាត់សក់តិចតួចណាស់ ហើយក៏ប្រហែលជាមានតែនៅទីក្រុង។ លោកយាយមុិច អាយុ៨៥ឆ្នាំ នៅឃុំរកាកោង ខេត្តកណ្ដាល និយាយថា "ពីដើមស្ដីគ្នាកាត់ គ្មានអ្នកណាយកលុយទេ មានតែចេះកាត់គគោក"។ ត្រូសារខ្លះមានឪពុក ឬម្ដាយចេះកាត់សក់

living in Kandal Province, told us, "Before, we cut each other's hair. No one took money for that. There were many people who knew how to cut hair." Some families had a father or mother who knew how to cut hair and they cut all the family members hair. Mom Samuen, 77 years old, told us, "In the 1940s, in Phnom Penh, there began to be places to perm your hair, but mostly it was done in private homes." By the end of the 1940s, barber shops and beauty salons were gradually opening. In the countryside at that time,



រូបលេខ ២៧៨៖ ហាង់កាត់សក់ នៅភ្នំពេញ។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 278: A beauty salon in Phnom Penh. Photographed 2003. (Photo: Reyum)

រូបលេខ ២៧៩៖ តូបកាត់សក់ធម្មតា។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 279: A haircutting stand in Phnom Penh. Photographed 2003. (Photo: Reyum)

គេកាត់សក់ឲ្យមនុស្សទាំងអស់នៅក្នុងគ្រួសារ។ លោកយាយមុម សំអឿន អាយុ៧៧ឆ្នាំ បាននិយាយថា "នៅទសវត្ស១៩៤០ នៅទីក្រុងភ្នំពេញចាប់មានគេអ៊ុតសក់ហើយ តែច្រើនតែអ៊ុតនៅតាមផ្ទះ"។ ដល់ចុងទសវត្ស១៩៤០ ប្រហែលជាចាប់មានបើកផ្ទះកាត់សក់ និងអ៊ុតសក់ជាបណ្តើរៗ។ ពេលនោះនៅស្រុកស្រែចម្ការ ប្រហែលអ្នកស្រុកនៅតែពឹងពាក់គ្នាកាត់សក់ទៅវិញទៅមក។ អ្នកស្រុកភូមិខ្លះក៏ចាប់មានអ្នកប្រកបរបរជាជាង់កាត់សក់ ដោយសារមនុស្សខ្លះគេនិយមម៉ូតសក់ថ្មីៗតាមអ្នកទីក្រុង ហើយអ្នកដែលចេះកាត់ម៉ូតសក់ចាស់ៗមានកាន់តែតិចពិបាករកអ្នកចេះកាត់។ ដូច្នេះចង់កាត់សក់ត្រូវឲ្យលុយជាការដោះដូរ។ មុនដំបូងប្រហែលមិនទាន់មានបើកជាហាង៍ ឬផ្ទះកាត់សក់ទេ គឺដើរកាត់តាមផ្ទះ។ លោកយាយស៊ីម សារិន អាយុ៧៦ឆ្នាំ ខេត្តស្វាយរៀង និយាយថា "ពីដើម

villagers probably continued to rely on each other to cut their hair. Some villagers began to make hair cutting into a profession, however, since some of their neighbors wanted the latest hair styles, following the example of city dwellers. As time went on, the number of people who knew how to cut hair declined and it became difficult to find someone who would volunteer to cut hair. Money began to be exchanged for hair cuts. At first, in the countryside, there were no barber shops or hair cutting stands; instead hair cutters walked through the countryside, cutting people's hair in front of their houses as they went. Sim Saren, 76 years old living in Svay Rieng Province, told us, "Earlier there were many people who knew how to cut hair, so they cut each other's hair. They would cut my hair, and I would cut their hair. After 1950,

រូបលេខ ២៨០៖ សក់បូកគោ។ ស្រង់ពីសៀវភៅ រៀនកាត់ដេរដោយខ្លួនឯង ដោយអ៊ាប-ប៊ុន-សុត ទសវត្សរ៍១៩៦០។

Figure 280: *Bokor* (hump of the cow) hair style. (Photo: *Sewing by yourself*, by Aap Bun Soth, 1960s)

មានអ្នកចេះកាត់ច្រើន ដល់អញ្ចឹងកាត់ប្រវាស់គ្នាគេកាត់ឲ្យខ្ញុំ ខ្ញុំកាត់ឲ្យគេ។ ក្រោយមកឆ្នាំ១៩៥០ក្រោយពីជាវ៉ាំងទៅស្រុកវិញ ដោយសារអ្នកចេះកាត់ខ្លះក៏ស្លាប់ ខ្លះនៅរស់ ទើបមានអ្នកចេះកាត់សក់តិច។គេកាត់សក់យកលុយចាប់ពីពេលនោះមក។ ចំណែកយាយដើរកាត់សក់នោះ មានយួរកន្ត្រកដាក់កាំបិតគោរ, កន្ត្រៃ, ក្រាសជាដើម ដើរកាត់តាមផ្ទះ។ ម្នាក់ជូនកាលកាត់ឲ្យ៣រៀល អ្នកកាត់ល្អ ៥រៀល"។

នៅដើមទសវត្សរ៍១៩៥០ ឃើញមានការផ្សាយពាណិជ្ជកម្មពីផ្ទះកាត់សក់ និងអ៊ុតសក់ផ្សេងៗនៅលើទំព័រកាសែត។ លោកយាយជូ សារឿន when the French went back to their country, some of the people who knew how to cut hair died, while others were still there. There started to be less people who knew how to cut hair. That's when they started to cut hair for money. I walked and cut people's hair [for money], carrying a lidded basket with a razor, scissors, and a comb in it. For one hair cut, I got three *riel*. Those who cut really well asked five *riel* for a haircut."

We begin to find advertisements for private homes offering haircuts and perms in newspapers from the 1950s. According to Ju Saroeun, "When I was forty or so, I got a perm. My husband took me to get a perm in Phnom Penh. When I got back to my village, they all looked at me curiously. They asked me, how much is a perm? Is it hot or not? I

រូបលេខ ២៨១៖ ផ្ទះអ៊ុតសក់សម័យ ដកស្រង់ពីទស្សនាវដ្តីជាតិនិយម ឆ្នាំ១៩៦០។

Figure 281: Hollywood hair perming salon. *The Nationalist*, 1960.

រូបលេខ ២៨២៖ សក់អូមេហ្គា។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 282: An Omega perm. Photographed 2003. (Photo: Reyum)

រូបលេខ ២៨៣៖ សក់អូមេហ្គា។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 283: An Omega perm. Photographed 2003. (Photo: Reyum)

រូបលេខ ២៨៤៖ សក់អូរ៉ាល់។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 284: An Aureal perm Photographed 2003. (Photo: Reyum)

រូបលេខ ២៨៥៖ សក់អូរ៉ាល់។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 285: An Aureal perm Photographed 2003. (Photo: Reyum)

និយាយថា "ដល់ខ្ញុំចាស់ហើយបានអ៊ុតសក់ ប្តីខ្ញុំនាំមកអ៊ុតសក់នៅភ្នំពេញ។ ពេលត្រលប់ទៅស្រុកគេនាំគ្នាមើល គេចង់ដឹង គេសួរខ្ញុំថា អ៊ុតថ្លៃប៉ុន្មាន។ ក្តៅឬមិនក្តៅ។ ស្រុកខ្ញុំមានតែខ្ញុំអ៊ុតសក់មុនគេ"។ លោកយាយខ្លូត សំអុល អាយុ៧១ឆ្នាំ នៅក្រុងភ្នំពេញ និយាយថា "ជំនាន់ខ្ញុំធំហើយ ទើបមានគេអ៊ុតសក់។ ពីដើមមានហាង់អ៊ុតសក់មួយនៅជិតរោងកុនត្រុងកុក (ម្តុំខាងលិចផ្សារកណ្តាល) កាលនោះមានប្តីប្រពន្ធពីរនាក់ ការបានពីរបីខែនាំប្រពន្ធទៅអ៊ុតសក់នៅហាង់មួយហ្នឹង។ អ៊ុតទៅខ្សែភ្លើងអាតេងអាតោង មីអ្នកអ៊ុតសក់ហ្នឹងអាល័យតែមើលគេហៅខ្មោច មនុស្សដែលមកអ៊ុតសក់ហ្នឹងខ្សែភ្លើងឆក់ងាប់រឹងស្តូក"។ មកដល់ទសវត្ស១៩៦០ ការនិយមអ៊ុតសក់មានកាន់តែច្រើនឡើង ដូចជាអ៊ុតសក់អូមេហ្គា, សក់អូរ៉ាល់ជាដើម។

សក់និងជំនឿ

សក់មិនត្រឹមតែសម្រាប់លំអ និងជួយបន្ថែមសម្រស់ដល់មនុស្សម្នាក់ឯងនោះទេ សក់ក៏មានទាក់ទងនឹងជំនឿដែរ។ ដូចជាពិធីឆ្លងវ័យ គឺមានទាក់ទងនឹងសក់តាំងពីគេកើតមករហូតដល់ស្លាប់។ ឧទាហរណ៍ ពេលទារកទើបកើតបាន៧ថ្ងៃ, ១៥ថ្ងៃ ឬ១ខែ គេមានធ្វើពិធីកាត់សក់ព្រៃ ជាពិធីមង្គលដំបូងបំផុតក្នុងជីវិតរបស់គេ និងដើម្បីប្រកាសឲ្យសង្គមទទួលស្គាល់។ ដល់មានអាយុ១២-១៣ឆ្នាំ មានធ្វើពិធីមួយទៀត គឺ

was the first one in my area to get a perm." Khlot Somol, 71 years old living in Phnom Penh, told us, "When I was already grown up, they started to have people giving perms. There was a shop offering perms near the Trong Kok Movie Theater (west of Psar Kandal, the central market). At that time, when a husband and wife had been married for two or three months, the husband would take his wife to go and get her hair permed in that shop. There were electric wires all over that shop. If the person perming your hair was distracted by a funeral procession passing by for a minute, then you could really burn up." In the 1960s, perms such as the Omega and the Aureal became more and more popular.

Beliefs about hair

Hair not only decorated and made a person more beautiful, but was also related to various beliefs concerning rites of passage marking moments in human life. For example, when a new born baby was one week, 15 days, or one month old, the ceremony to cut the baby's hair was held as the first blessing in the baby's life and in order to announce the arrival of the baby to the society as a whole. When a child was 12 to 13 years old, another ceremony was arranged to shave the *juk* [shaving the head of all hair except a strand on the top front of the head] which signaled that the child has passed into puberty.

ពិធីកោរជុក។ គេធ្វើពិធីនេះ ដើម្បីបញ្ជាក់ថាមនុស្ស
ម្នាក់នេះបានឆ្លងពីវ័យកុមារ ទៅជាមនុស្សវ័យជំទង់
ជាវ័យមួយដែលមនុស្សស្រីចូលមួប់ ដើម្បីរៀនវិជ្ជា
ផ្សេងៗ។ ឯមនុស្សប្រុសចូលទៅបួសរៀន ត្រូវកោរ
សក់ គឺបានឆ្លងវ័យមួយពីអ្នកដែលមិនចេះដឹងទៅជា
អ្នកចេះដឹង ឬទៅជាបណ្ឌិត (អ្នកសឹកពីបួសគេច្រើន
ហៅថាអន្ទិត ឬអ្នកអន្ទិត)។ ប្រហែលជា២០ឆ្នាំមុន
នេះ ទំនៀមកាត់សក់ក្នុងពិធីមង្គលការគឺគេកាត់សក់
មែនទែន មិនមែនគ្រាន់តែឧបកិច្ចដូចបច្ចុប្បន្នទេ។ តែ
ទោះជាយ៉ាងណាក៏ដោយ ក៏ស្ថិតនៅក្នុងន័យដូចគ្នា
ដើម្បីបញ្ជាក់ថា គេបានឆ្លងចូលដល់វ័យមានគ្រួសារ
ដែលត្រូវទទួលខុសត្រូវដោយខ្លួនឯង លែងនៅក្មេង
ដូចមុនហើយ។ នៅពេលឈានចូលដល់វ័យចាស់ គេ
តែងកាត់សក់ខ្លី ឬកោរសក់តែម្តង។ ដូច្នេះសក់ គឺជា
និមិត្តរូបសំខាន់មួយនៃការផ្លាស់ប្តូរជាដំណាក់នូវវ័យ
របស់ជីវិតមនុស្សម្នាក់ៗ។

ក្រៅពីពិធីឆ្លងវ័យនៅមានជំនឿជាច្រើនទៀត
ដែលទាក់ទងទៅនឹងសក់។ តាមការសង្កេតក្នុងសង្គម
ខ្មែរ ទោះបីមកដល់បច្ចុប្បន្ននេះក៏ដោយ សក់ជា
ដង្វាយសំខាន់ក្នុងការបន់ស្រន់នានា។ ភាគច្រើនគេ
តែងទៅបន់ស្រន់ចំពោះមុខព្រះក្នុងព្រះវិហារ ឬអ្នកតា
ដែលគេជឿថាមានបារមីសក្តិសិទ្ធិអាចធ្វើឲ្យគេ
សម្រេចតាមបំណងផ្សេងៗ។ អ្នកខ្លះបន់ដោយនិយាយ
ដាក់ថ្វាយជាផ្លែឈើ មាន់ ទា ឬរបស់របរផ្សេងៗ
ដើម្បីដឹងគុណដល់ព្រះ ឬអ្នកតាដែលបានជួយ។ អ្នក

In this life stage, some girls *chol mlup* [literally enter the shade, a period of seclusion] to learn the duties of running a household. Boys entered the monkhood to study and shaved their head entirely to show that they were passing from ignorance to a state of understanding and higher knowledge. In the traditional marriage ceremony, there was also hair cutting which previously - perhaps up to 20 years ago - really meant cutting the hair, not just a ceremonial snipping of a lock as is done today. Whether the hair is really cut or not during the wedding ceremony, the cutting of the hair signifies that the couple has passed to another life stage, and are now no longer children and are responsible for themselves. In old age, people cut their hair short or even shave their heads entirely. Thus hair is an important symbol for the passage of life from one stage to the next.

In addition to the role of hair in these rites of passage, hair holds other meanings as well. Even today in Khmer society, hair is an important offering in prayers. Most people go to pray in front of the Buddha in the *vihear* [temple building] or in front of the *neak ta* [territorial spirit], believing that these figures have the power to make prayers come true. Some people pray while offering fruit, chickens, ducks, or other things in thanks, while others pray by cutting their hair or shaving their heads as an offering. If a child is

ខ្លះទៀត បន់ស្រន់ដោយកាត់សក់ ឬកោរសក់ថ្វាយ។ ឧទាហរណ៍ ក្នុងគ្រួសារមួយ បើមានវង្វេងបាត់កូន ឪពុក ឬម្តាយ គេទៅបន់ព្រះនៅវត្ត ឬអ្នកតាបង់បត់នៅក្នុងភូមិឲ្យជួយបង្ហាញផ្លូវកូនឃើញវិញ នោះឪពុក ឬម្តាយនឹងកោរសក់ ឬកាត់សក់ថ្វាយនៅនឹងកន្លែងដែលបានទៅបែរបន់នោះ។ យើងតែងឮពាក្យថា "កោរសក់លាបំណន់"។ ការបន់ស្រន់ដោយថ្វាយសក់ភាគច្រើនជារឿងដែលសំខាន់បំផុត។ បើរឿងស្រាលល្មម គេគ្រាន់តែបន់ថ្វាយត្រឹមផ្លែឈើ ឬរបស់របរខ្លះៗប៉ុណ្ណោះ។ ម្យ៉ាងទៀត មានមនុស្សខ្លះ ជាពិសេសកូនក្មេងមួយចំនួនទុកសក់វែងតែងឈឺជាញឹកញាប់ ជម្ងឺនេះ គេហៅថាចាញ់សក់។ គេជឿថាកាលណាក្មេងមានសក់វែង ខ្មោចព្រាយចូលចិត្តមកជិត ហើយតែងលង់បន្ទាចក្មេងនោះ។ ហេតុនេះទើបមានឪពុកម្តាយខ្លះកាត់សក់ឲ្យកូនខ្លួនខ្លីបំផុត បើក្មេងស្រីវិញកាត់សក់រចៀបជាក្មេងប្រុសតែម្តង។ ផ្ទុយទៅវិញ ចំពោះអ្នកខ្លះកាលណាកាត់សក់ បែរជាឈឺទៅវិញ ដូចជាអ្នកមានសក់កណ្តាញ់ពីធម្មជាតិ (ដុំសក់ក្រញាញ់ចាក់ស្រែះចូលគ្នា) សូម្បីសិតសក់ ឬកាត់សក់នោះចោលក៏ពុំបានដែរ ទោះជាសក់នោះដុះវែងយ៉ាងណាក៏ដោយ។ គេជឿថាមានជារម៉ាន់នៅនឹងសក់នោះ ហើយជួយថែរក្សា និងផ្តល់សេចក្តីសុខដល់ម្ចាស់ខ្លួននោះផង។ ក្រៅពីនេះ នៅមានជំនឿក្នុងការរើសថ្ងៃកាត់សក់ដើម្បីឲ្យមានសិរីសួស្តី ដូច្នេះទើបកើតមានតម្រាចែងជាទូទៅ។ សូម្បីការស្រូបប្រេងលាបសក់ក៏គេ

lost, for example, the father or mother go to pray to the gods in the temple, the *neak ta*, or to the village spirits for help in showing them where to find their child. If the child is found, the mother or father will shave or cut their hair, offering it at the place where they first prayed. This practice is illuminated in the common saying, "Shave your hair in thanks for a prayer answered." Praying with offerings of hair is only done for very important requests; for smaller prayers regarding more ordinary matters, people only offer fruit or other goods.

Another belief concerns people, particularly children, who have long hair and are often sick. This belief is called *jain sok* or losing to the hair. People believe that long hair makes spirits and ghosts like to come close to a child and haunt he or she. This is why some parents cut the hair of their children very short, cutting girl's and boy's hair in the same style. On the other hand, some people are thought to fall sick because they cut their hair, especially if it is naturally kinky and tangled hair. Even if such hair is combed or cut, people believe the hair cannot be casually thrown away. This is because they believe that the hair has a power which takes care of the person and brings happiness. In addition, Khmer believe in choosing the day for hair cutting carefully so that it will be an auspicious day. For this reason there are charts for choosing auspicious

ត្រូវរើសយកថ្ងៃល្អដែរ។[១៦] មានជំនឿមួយទៀតដែលទាក់ទងនឹងការសក់ដែរ គឺពេលមានមនុស្សក្នុងត្រួសារស្លាប់ត្រូវមានសមាជិកម្នាក់ក្នុងត្រួសារពិសេសមនុស្សដែលអ្នកស្លាប់ស្រឡាញ់ ដើម្បីការសក់បួសមុខភ្លើង។ ការការសក់បួសក្នុងពេលនេះគឺមួយសំដៅទៅលើការគាន់ទុក្ខឲ្យអ្នកស្លាប់ មួយទៀតគឺដើម្បីឧទ្ទិសកុសលផលបុណ្យដល់អ្នកដែលបានស្លាប់ទៅ។ ដូច្នេះយើងឃើញថា សក់មានបង្កប់នូវជំនឿប្លែកៗនៅក្នុងផ្នត់គំនិតខ្មែរ ដែលជំនឿនេះបានបន្តពីជំនាន់មួយទៅជំនាន់មួយ តែពុំដឹងថាជំនឿអស់ទាំងនេះកើតមានក្នុងសង្គមខ្មែរតាំងពីពេលណាឡើយ។

ជំនឿលើសក់ដែលរៀបរាប់ទាំងប៉ុន្មានខាងលើ ជាជំនឿដែលធ្លាប់មានក្នុងសង្គមខ្មែរ ជំនឿទាំងអស់នេះសាបរលាបបន្តិចម្តងៗ ខ្លះជឿ ខ្លះមិនជឿ ពិសេសបច្ចុប្បន្នសង្គមមានការផ្លាស់ប្តូរមនុស្សកាន់តែឃ្លាតឆ្ងាយពីជំនឿផ្សេងៗដោយងាកទៅរកទំនុកចិត្តលើការមើលឃើញផ្ទាល់ភ្នែក ឬវិទ្យាសាស្ត្រច្រើនជាង។

ការថែទាំសក់

ការថែទាំសក់ដើម្បីឲ្យស្អាតបាតក្នុងន័យអនាម័យក្តី និងថែទាំសក់ឲ្យស្រស់ស្អាតក្តី គឺជាទម្លាប់ដែលខ្មែរធ្លាប់មាន។ ប្រហែលមួយសតវត្សមុន របស់

days, even for the day on which to make oils for the hair.[9]

Another belief is also tied to shaving the head. When a close family member dies, another member of the family - particularly one whom the deceased loved - must shave their head and *buos muoy pleung* (light the cremation fire). Shaving the head upon the death of a close family member signifies mourning and the offering of merit to the deceased. Thus we see that there are various beliefs regarding hair in Khmer thought. These beliefs have been passed down from generation to generation. We are not sure for how long such beliefs have been present in Khmer society.

The beliefs about hair described above have traditionally been held in Khmer culture. These beliefs are now fading. Some believe in them while others do not. Today, Khmer society is changing and people leave behind their traditional beliefs and turn more and more to their own observation and scientific thinking.

Care of the hair

Khmer people have a tradition of caring for the hair both to clean it and to make it more beautiful. While today there

---

[១៦] សូមអានសៀវភៅ "ព្រហ្មជាតិកណ្ឌទី៦" សរសេរដោយ នួន ប៊ុត, ភ្នំពេញ, ១៩៦៤។

9 See *Promcheat*, volume 2, by Nuon Bot, Phnom Penh, 1964.

របរប្រើទ្រាស់សម្រាប់ថែរក្សាសក់ដូចជាសាប៊ូជាដើម មិនសម្បូណិប្រើដូចសព្វថ្ងៃទេ។ ម្ល៉ោះហើយ គេថែរក្សាសក់ដោយប្រើរបស់របរផ្នែកពីធម្មជាតិជុំវិញខ្លួន ដូចជាក្បុង ប្រេងលាបសក់ ឬក្រាស់សិតសក់ធ្វើពីឈើជាដើម។ ក្រោយពីបានសាកសួរចាស់ៗ យើងបានដឹងខ្លះពីរបៀបសម្អាត និងថែរក្សាសក់។

– *ការកក់សក់*៖ ក្នុងអំឡុងពេលដែលពុំទាន់មានសាប៊ូប្រើ គេនិយមប្រើទឹកក្បុងដែលធ្វើពីរុក្ខជាតិមួយចំនួន ដើម្បីកក់លាងជម្រះក្អែល ពិសេសអ្នកនៅស្រុកស្រែចម្ការ។ អ្នកខ្លះប្រើក្បុងផ្ដិបន្លា ខ្លះប្រើក្បុងសម្បកផ្លែគគំ ខ្លះប្រើក្បុងផ្កាត្នោតឈ្មោល និងខ្លះទៀតប្រើក្បុងសម្បកចេកណាំវ៉ា។ *ការយករុក្ខជាតិមកធ្វើក្បុងខុសគ្នានេះ គឺអាស្រ័យលើរុក្ខជាតិស្រួលរក ឬនិយមតាមតំបន់មួយ*ៗ។ ក្រៅពីនេះ ខ្លះគេអាចយកស្លឹកអញ្ជាញ, ស្លឹកគ, ផ្លែនរោងព្រៃចាស់,

are innumerable shampoos, conditioners, perfumes, oils and other hair products available, earlier, the Khmer relied on natural ingredients collected from the environment which surrounded them for their hair care products. Through our interviews with the elderly, we have learned some of the ways in which hair used to be cleaned and cared for.

Washing the hair

Before there were manufactured soaps and shampoos available in stores, most people (especially in the countryside) liked to use *deuk kbong* (ash water) made of natural ingredients for washing and cleaning of all sorts. Some people used ash of *pti banlar* [a kind of plant], some used ash of the husk of the *ko* tree seed, others used ash made from male palm tree flowers, while still others used



រូបលេខ ២៨៦៖ ផ្លែក្រូចសើច។ (រូបថត៖ រៃយ៉ំ)

Figure 286: *Kroach saouch* fruit. (Photo: Reyum)

រូបលេខ ២៨៧៖ ស្លឹកអញ្ជាញ។ (រូបថត៖ រៃយ៉ំ)

Figure 287: *Anyjang* leaves. (Photo: Reyum)

ផ្លែក្រូចសើចជាដើម មកកក់សក់។ កក់សក់ទឹកក្បុង ជ្រះក្អែលល្អ ប៉ុន្តែធ្វើឲ្យសក់រីង ដូច្នេះហើយទើបនៅស្រុកស្រែចម្ការខ្លះ គេមិនសូវកក់សក់ញឹកញាប់ទេ។ អ្នកខ្លះ១អាទិត្យ ឬ១ខែទើបកក់សក់ម្តងអ្នកខ្លះទៀតរហូតដល់ពេលក្បាលគេចាប់ផ្តើមរមាស់ទើបគេកក់សក់។ អ្នកខ្លះក្រោយពីកក់ក្បុងហើយ គេកក់ក្រូចសើចពីលើទៀតដើម្បីឲ្យសក់ទន់។ លោកយាយតួយ តឹម អាយុ៨៥ឆ្នាំ នៅខេត្តបាត់ដំបងនិយាយថា"សក់ខ្ញុំវែងដល់ជង្គង់ ខ្ញុំកក់តែក្បុងធ្វើពីសម្បកចេកណាំវ៉ាសក់ទន់ល្អ ១ខែកក់៣-៤ដង។ ខ្ញុំចេះធ្វើក្បុងពីម្តាយខ្ញុំមក។ ហើយខ្ញុំតែងប្រាប់ពីវិធីធ្វើនេះដល់អ្នកភូមិជាមួយគ្នា ដោយខ្ញុំយល់ថាធ្វើក្បុងប្រើមិនចាំបាច់អស់លុយទិញសាប៊ូ។ ម្យ៉ាងគ្រួសារខ្ញុំខ្វះខាតលុយផង"។ នៅដើមសតវត្សទី២០ ប្រហែលជាមានសាប៊ូនាំចូលពីបរទេសខ្លះៗហើយ។ តែដោយសារប្រជាជនភាគច្រើនខ្វះខាតលុយកាក់ ពុំហ៊ានទិញសាប៊ូប្រើ អ្នកខ្លះនៅតែប្រើក្បុងដដែល។ មនុស្សស្រីមានសក់វែងគេច្រើនកក់ទឹកក្បុង ព្រោះបើប្រើសាប៊ូចុះសាប៊ូច្រើន។ ចំណែកបុរស ឬស្ត្រីខ្លះ ដែលកាត់សក់ខ្លីច្រើនប្រើសាប៊ូកក់សក់។ ប្រហែលជាគេគិតថាមិនសូវចំណាយសាប៊ូអស់ច្រើនដូចអ្នកមានសក់វែង។ លោកយាយ អ៊ុន ឈុំ អាយុ៨៦ឆ្នាំ នៅព្រែកលាបនិយាយថា"ខ្ញុំកក់តែសាប៊ូដុំ ជាសាប៊ូធ្លាប ខ្ញុំអត់ដែលកក់ក្បុងទេព្រោះសក់ខ្ញុំកាត់ខ្លី"។ ប្រហែលជានៅដើមទសវត្សរ៍ ១៩៥០ អំណាចរបស់បារាំងនៅស្រុកខ្មែរធ្លាក់ចុះ ធ្វើ

ash made from the peels of the *namvar* banana. The natural ingredients used to make ash soap depended on which of them was readily available, and ingredients for ash shampoo and soap varied by region. Leaves of the *anyjang* shrub and the *ko* tree, and the *nonoug prei chas* and *kroach saouch* fruits were also used to make ash soap for washing hair. Ash soap was good for cleaning and removing dirt, but made the hair stiff; thus in the countryside, people did not generally wash their hair very often. Some people washed their hair once a week or once a month, while others waited until their head itched to wash their hair. Some first washed their hair with *deuk kbong* and then used the juice of the *kroach saouch* fruit as a rinse to soften their hair. The late Kuoy Kem told us, "My hair was long, falling down to my knees. I only washed it with ash water made from the peels of *namvar* bananas. That made my hair soft and beautiful. I washed my hair three or four times a month. My mother taught me how to make the *deuk kbong* [ash water], and I told all the people in the village how to make it because I thought that if we all made it, we wouldn't need to spend money to buy shampoo. Also my family didn't have money."

At the beginning of the 20th century, some ready-made bar soaps probably began to be imported from abroad already. Most local inhabitants, however, did not have money to

ឲ្យប្រទេសផ្សេងអាចនាំចូលផលិតផលរបស់គេមក
ស្រុកខ្មែរកាន់តែច្រើន។ ក្នុងនោះក៏ប្រហែលមាននាំ
ចូលសាប៊ូច្រើនជាងមុន និងមានតម្លៃថោកជាងមុន
ដែលអាចឲ្យប្រជាជនភាគច្រើនអាចទិញប្រើបាន។
លោកយាយរ៉ាំ រីម អាយុ៧៣ឆ្នាំ នៅឃ្លាអំពៅ
ក្រុងភ្នំពេញ និយាយថា"ខ្ញុំធ្លាប់ប្រើទឹកក្បុងកក់សក់
តែក្រោយមកលែងប្រើ ប្រើតែសាប៊ូ។ជួនកាលប្រើ

buy such products and they continued to use homemade ash shampoos. Women with long hair mostly washed their hair using *deuk kbong* since large amounts of store-bought soap would be required to wash their hair. Men and women with short hair cuts began to use ready-made soaps and shampoos as they became available, perhaps aware that they wouldn't use as much shampoo as people with

រូបលេខ ២៨៨៖ ការផ្សាយលក់សាប៊ូ។ ដកស្រង់ពីកាសែតកម្ពុជា
លេខ៣៩៦៧ ថ្ងៃទី៤ ខែកុម្ភៈឆ្នាំ១៩៥៩។

Figure 288: Advertisement for soap. *Kampuchea* #3967, 1959.

long hair. Oun Chum, 86 years old living near Phnom Penh, told us, "I only washed my hair with soap bars called *chaap* soap. I never used *kbong* because my hair was cut short."

At the beginning of the 1950s, as French power in Cambodia declined, other countries began to send more products into Cambodia for sale. More shampoos and soaps at cheaper prices came into Cambodia at this time, allowing more local inhabitants to begin using these products. Ram Rem, 73 years old living near Phnom Penh, told us, "I used to use *deuk kbong* for washing my hair, but later on I stopped using it and began to use store bought soap. Sometimes I used perfumed soap from Vietnam. It was a bar soap with a picture on its package of a woman wearing lots of necklaces. Only old people still used *kbong*." In 1959, we find shampoos being advertised in the newspaper *Kampuchea*. It seems that before the Khmer Rouge Regime, only bar soap was available in Cambodia. Powdered detergents became available in the late 1980s when they were imported from Vietnam. Today, most detergent powders are imported from Thailand. Around 1990, bottled shampoos also began to be available.

Making *kbong* or ash shampoo

Kbong is a material that has many uses in everyday Khmer life. It can be used for

សាប៊ូក្រអូបមកពីយួន ជាសាប៊ូដុំដែលមានចិទ្ធាកខាងក្រៅជារូបមនុស្សស្រីពាក់ខ្សែកច្រើន។ ហើយក្បុងនៅតែចាស់ទេដែលប្រើ"។ នៅឆ្នាំ១៩៥៩ឃើញមានផ្សាយពាណិជ្ជកម្មលក់សាប៊ូក្នុងកាសែតកម្ពុជា។

នៅមុនសម័យខ្មែរក្រហមអាចមានតែប្រភេទសាប៊ូដុំប៉ុណ្ណោះ។ ឯសាប៊ូមេរ៉ាចាប់មានប្រហែលជាចុងទសវត្ស១៩៨០។ ប្រភេទសាប៊ូមេរ៉ាទាំងនោះភាគច្រើននាំមកពីវៀតណាម និងក្រោយពីនោះមកដល់បច្ចុប្បន្នមានសាប៊ូមេរ៉ាមកពីសៀមថែមទៀត។ ចំណែកសាប៊ូប្រភេទទឹកសម្រាប់កក់សក់ចាប់មានប្រហែលជានៅរវាងទសវត្ស១៩៩០មក។

– វិធីធ្វើក្បុង៖ ក្បុងជាសារធាតុមានប្រយោជន៍ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ដូចជាយកទៅកក់សក់ យកទៅលាយជាមួយធ្យងបុកឲ្យម៉ដ្ឋរុំស្រោបពងទាឲ្យមានជាតិប្រៃធ្វើនំចាំង ប្រមោកសូត្រ ជោកខោអាវជាដើម។ ក្នុងចំណុចនេះ យើងសូមមិនរៀបរាប់លម្អិតពីប្រយោជន៍នៃក្បុងប្រើលើអ្វីខ្លះនោះឡើយ គ្រាន់តែចង់បង្ហាញពីវិធីធ្វើក្បុង ដែលចាស់ៗបាននិយាយប្រាប់។[13]

ក្បុងបានមកពីការដុតកម្ទេចរុក្ខជាតិមួយចំនួនមាន សម្បកនិងបណ្តូលផ្លែគគ្រំ, ដើមសន្ទែ, ផ្តៃ

---

13 សូមអានបន្ថែមអត្ថបទស្តីអំពីក្បុង, ដោយលោកមៀច ប៉ុណ្ណ, នៅក្នុងទស្សនាវដ្តីកម្ពុជសូរិយា ឆ្នាំទី៥១ ខែមេសា–មិថុនា ឆ្នាំ ២០០០, ទំព័រ៤១–៤៥។

បន្លា, សម្បកចេកណាំវ៉ា និងផ្តាត្នោតឈ្មោលជាដើម។ គេយកមកហាលឲ្យស្ងួត ដើម្បីងាយស្រួលដុតឲ្យទៅជាផេះ រួចប្រមូលទុកម្តុំ។ បន្ទាប់មក គេច្រោះទឹកបន្តិចៗលើផេះនោះល្មមអាចពូតផ្តុំជារាងដុំៗដែលគេហៅថា "ដុំក្បុង"។ រួចគេយកដុំក្បុងទាំងអស់ទៅរក្សាទុកក្នុងកញ្ជើ ជាល ឬអ្វីផ្សេងទៀតក៏បានដើម្បីទុកប្រើការទៅថ្ងៃមុខ។ នៅពេលត្រូវការទឹកក្បុងប្រើ



រូបលេខ ២៨៩៖ សម្បកចេកណាំវ៉ា។ (រូបថត៖ រៃយ៉ំ)

Figure 289: Peel of the *namvar* banana. (Photo: Reyum)

រូបលេខ ២៩០៖ សម្បកផ្នែកខាងក្នុង។ (រូបថត៖ រៃយ៉ំ)

Figure 290: Peel and inside of the *ko* tree seed. (Photo: Reyum)

washing hair, or it can be mixed with charcoal and ground into a fine powder for rolling duck eggs in to turn them salty. *Kbong* is also used in making various kinds of cakes, for brightening the color of silk, and as a laundry detergent. Instead of focusing on these many uses here, we instead describe ways of making *kbong* recounted to us by our elderly interviewees.[10]

Kbong is the ash resulting from burning various natural materials such as the peel and inside of the ripe *ko* tree seed, the wood of the *sangkai* tree, *pti banlar*, peels of the *namvar* banana, and the male palm tree flower. These natural materials are first dried in the sun so that they are easy to burn to ash. After burning, the ash is collected and water is sprinkled on it to form lumps. These lumps are stored in baskets or other places for use in the future. When *deuk kbong* is used, a lump of *kbong* is taken and broken apart, putting the resulting powder in a cloth with a sieve-like basket underneath. Water is poured onto the cloth, little by little, keeping a dish or jar underneath to catch the *deuk kbong* as it drips down. Good *deuk kbong* will have a dark red color similar to the color of fish sauce, and will taste a little salty at first. Water is continuously added to the ash until the *deuk kbong* tastes

10 For more information on *kbong*, see the article by Meach Bunna in *Kampuchea Surya*, April-May 2000.

រូបលេខ ២៩១៖ ផ្តិបន្លា។ (រូបថត៖ រៃយ៉ំ)

Figure 291: *Pti banlar.* (Photo: Reyum)

រូបលេខ ២៩២៖ ផ្ការនោតឈ្មោ។ (រូបថត៖ រៃយ៉ំ)

Figure 292: Flowers of the male palm tree. (Photo: Reyum)

គេយកដុំក្បុងនោះច្របាច់ឲ្យរាយដាក់ក្នុងក្រណាត់មួយ ដែលមានកញ្រ្ជែងទ្រាប់ពីក្រោម ហើយគេចាក់ទឹកបន្តិចម្តងៗដោយមានផ្តិល ឬក្អមត្រង់ពីក្រោម។ នោះគេនឹងបានទឹកក្បុងល្អ ស្រស់មកមានពណ៌ក្រហមក្រមៅ ស្រដៀងពណ៌ទឹកត្រី និងមានជាតិប្រៃតិចៗ។ កាលណាអស់ទឹក គេចេះតែចាក់ទឹកបន្ថែមរហូតគេភ្លក្សមើលថា ទឹកក្បុងដែលត្រង់បានមានរសជាតិសាបហើយនោះ គេបន្ថែមដុំក្បុង១ ឬ២ដុំក្នុងកញ្រ្ជែងច្រោះទៀត លុះត្រាគេបានចំណុះទឹកក្បុងល្មមគ្រប់គ្រាន់តាមតម្រូវការរបស់គេ។ ក្បុងដែលបានមកពីសម្បក និងបណ្តូលផ្លែតទុំ មានជាតិប្រៃជាងក្បុងដែលធ្វើពីរុក្ខជាតិផ្សេងទៀត។

ចំពោះអ្នកខ្លះគេមិននិយមច្រោះយកទឹកក្បុងរបៀបនេះឡើយ។ គេយកដុំក្បុង ឬផេះដែលដុតហើយដាក់ត្រាំក្នុងទឹកតែម្តង គេទុកឲ្យរង់ថ្លាសិន ទើបគេដួស

bland, not salty. One or two more lumps of *kbong* are added to the cloth above the sieve then, and the process of decanting is continued until there is enough *deuk kbong* for the required purposes. *Kbong* made from the peel and inside of the ripe *ko* tree seed is saltier than *kbong* made from other natural materials.

Some people do not like to make *deuk kbong* in this fashion. Instead they take lumps of *kbong*, or freshly burned ash, and soak it directly in water. They wait for the water to become clear before spooning it for use.

Deuk kbong made from natural vegetation, as described above, is strong enough to use as a shampoo for washing clothing. When used, it makes lots of foam. We are not sure what other natural vegetation can be used to make *kbong* in addition to the natural materials listed above. Today, even

យកទឹកទៅប្រើការ។ ទឹកក្បុងដែលធ្វើពីរុក្ខជាតិដូចពោលខាងលើ មានជាតិប្រៃត្រប់គ្រាន់អាចយកទៅកក់សក់ ឬបោកខោអាវជ្រះក្អែលល្អហើយមានពពុះច្រើន។ ក្រៅពីរុក្ខជាតិខាងលើ យើងពុំបានដឹងថាអាចយកអ្វីផ្សេងមកធ្វើក្បុងបានទៀតឡើយ។

បច្ចុប្បន្ន ទោះបីគេឈប់ប្រើក្បុងកក់សក់ដោយសារមានសាប៊ូត្រប់ប្រភេទសម្រាប់ប្រើក្នុងការដុសលាងជម្រះក្អែល ក៏ក្បុងនៅតែជាវត្ថុចាំបាច់មិនអាចខ្វះបានចំពោះផ្នែកផ្សេងទៀត។ មានមួយចំនួនដែលគេតែងប្រើទឹកក្បុងដើម្បីធ្វើឲ្យនំស្ងិត ដូចជានំលត, នំចាំងជាដើម។

– ការលាបប្រែងសក់៖ សព្វថ្ងៃនេះគ្រឿងសម្ផិតសម្ផាងសក់មានច្រើនប្រភេទ មានតាំងពីថ្នាំ ឬប្រែងលាបធ្វើឲ្យសក់ខ្មៅ សក់ក្រហម សក់ត្រង់ សក់រឹង ទន់រលោង អាចបំពេញតាមតម្រូវការរបស់បុគ្គលម្នាក់ៗ។ ប៉ុន្តែនៅដើមសតវត្សទី២០ ខ្មែរពុំទាន់មានសម្ភារៈ ឬគ្រឿងតុបតែង លាបសក់ទំនើបៗដូច្នេះឡើយ គឺគ្រាន់តែទុកសក់ទៅតាមធម្មជាតិ។ ឯប្រែងសម្រាប់លាបសក់សម័យនោះក៏ខុសប្លែកពីបច្ចុប្បន្ននេះដែរ។ ភាគច្រើនខ្មែរនិយមប្រើប្រែងលាបសក់ដែលស្ងួដោយខ្លួនឯង ដូចជាប្រែងល្ហុង ប្រែងដូងជាដើម។ ចំពោះអ្នកដែលកាត់សក់ជ្រង ហើយមានសក់ទន់ គេនិយមលាបប្រែង លាយកំបោរ ដើម្បីឲ្យសក់រឹង។ លោកយាយណុក អាយុ៧៤ឆ្នាំ នៅខេត្តកណ្តាល និយាយថា "ម្តាយមីងខ្ញុំកាត់សក់ជ្រងផ្កាថ្លូវ

though they have generally stopped using *deuk kbong* for washing since there are so many kinds of ready-made products for washing and cleaning, still it is an essential material which is used for many things including as an ingredient in various kinds of cakes.

Using hair oils

Today there are many hair products on the market. There are oils and dyes, and hair straighteners, as well as products to make your hair stiff, shiny, or soft. All these products allow people to style their hair according to their individual tastes. At the beginning of the 20th century, there was not such an array of modern products and equipment for hair styling. Hair was generally left in its natural condition. Oils used on the hair in those days were different from the store-bought types used today. Khmer liked to use oils which they made themselves from papaya or coconut. Those with soft hair cut in the *chrung* style liked to use hair oil mixed with lime to make their hair stiffer. Nok, 74 years old living in Kandal Province, told us, "My aunt cut her hair in the *chrung pka tkow* style. She liked to use papaya oil mixed with perfume in her hair. She hated coconut oil because she thought that those who used it were like the Cham." Phi, 83 years old living in Kandal Province, told us, "Hair oil made from *kwong* papaya was called sticky oil. If

គាត់ចូលចិត្តលាបប្រេងល្ហុង ដែលលាយទឹកអប់។ គាត់ស្អប់ប្រេងដូង ព្រោះយល់ថាលាបប្រេងដូងដូចចាម"។ លោកយាយតី អាយុ៨៣ឆ្នាំ នៅ ខេត្តកណ្តាល ប្រាប់ថា "យកល្ហុងខ្វងមកស្ង ហៅប្រេងស្អិត បើចង់ឲ្យសក់រឹងនៅជាប់ពុំធ្លាក់ចុះ ពេលលាបត្រូវដាក់កំបោរលាយបន្តិចៗ។ ប្រេងហ្នឹងទិញពីចាមដើរលក់ គេលាបនៅពេលមានវេរៀវទៅបុណ្យទាន ឬការប៉ុណ្ណោះ"។ ចំពោះអ្នកទុកសក់វែង ភាគច្រើនជាស្រីក្រមុំ ឬស្រីជនជាតិចិន គេលាបប្រេងលើសក់អាចជួយឲ្យសក់ទន់ងាយស្រួលសិត។ សម្រាប់អ្នករស់នៅទីក្រុង ពិសេសគ្រួសារអ្នកមានច្រាក់ មានឯាន:ខ្ពស់ា គេនិយមប្រើប្រេងច័ន្ទឬប្រេងក្រមួនដែលនាំចូលមកពីបរទេស។ លោកយាយខ្ួត សំអុល អាយុ៧១ឆ្នាំ នៅភ្នំពេញ ប្រាប់ថា "ខ្ុំធ្លាប់ប្រើប្រេងច័នលាបសក់ ជួនកាលមានប្រើប្រេងដូងដែរ។ ប៉ុន្តែយើងពុំបានដឹងថាប្រេងច័នប្រភេទនោះធ្វើមកពីអ្វីឡើយ"។ នៅមានក្រមួនម្យ៉ាងទៀតដែលធ្វើក្នុងស្រុកខ្មែរ គេនិយមហៅថា "ក្រមួនស្អិត" ធ្វើពីផ្លែសំពោងលាយជាមួយក្រមួនសុទ្ធ។ ស្ត្រីដែលហួបមួនិយមប្រើក្រមួននេះ ពេលហួបមួគាត់លាបក្រមួននេះឲ្យបបូរមាត់ស្អិត ដើម្បីកុំឲ្យទឹកមាត់ស្ងាហៀរចេញមកក្រៅ។ ឯមនុស្សប្រុស មានមេស្រុក មេឃុំ ឬថៅហ្វាយខេត្តជាដើម ប្រើលាបពុកមាត់ដែលពត់ជាវង់ស្មើងក្របី។ យើងសូមមិនរៀបរាប់ពីការធ្វើក្រមួននេះឡើយ ព្រោះមានឯកសារសរសេរចុះផ្សាយតាំងពីឆ្នាំ១៩៦៥មក

you wanted to have stiff hair that would not fall down, then you had to add a little lime to the hair oil. We bought that oil from Cham peddlars who walked through the countryside selling it. Hair oil was only applied on the occasion of going to ceremonies or weddings." Most of the women with long hair were unmarried virgins of Chinese descent. These women used oil to make their hair soft and easy to comb. City dwellers, especially rich and high-ranking people, liked to use oils such as *chan* oil or hair wax imported from abroad. Khlot Somol, 71 years old living in Phnom Penh, told us, "I used to use *chan* oil on my hair. Sometimes I used coconut oil too. We didn't know where *chan* oil came from." There was also a kind of hair wax, made in Cambodia, which people called sticky wax. This wax was made from *samrong* fruit mixed with pure wax. Khmer women who chewed betel liked to use this kind of wax on their lips to make them stick together so that the betel juice did not run out of their mouths. The wax remaining on their fingers after painting their lips was wiped through their hair or was spread on their palms and then applied to the hair so that it stood up in spikes. Male leaders of districts and provinces used this wax on their mustaches to twist them into the shape of water buffalo horns. We do not detail how this sticky wax was made since an article from 1965 has already

ម្ល៉ះ។[១៦] បើតាមការស្មាន ចាប់ពីទសវត្ស១៩៥០ មានប្រជាជនខ្មែរខ្លះប្រើប្រេងម្យ៉ាងទៀតហៅថា "កាយ៉ង់ទីន" ជាប្រេងលាបសក់នាំចូលពីបរទេស។ ប្រជាជនខ្មែរភាគច្រើនមានការខ្វះខាត រួមផ្សំនឹងរបស់នាំចូលមានតម្លៃថ្លៃ គេនិយមប្រើតែប្រេងធ្វើខ្លួនឯងនិងប្រេងដែលចាម និងយួនដើរលក់តាមភូមិ។ បើតាមមនុស្សចាស់ៗដែលធ្លាប់ប្រើ និយាយថា ប្រេងដូងដែលយួនធ្វើមានលាយល្មៀត។ ប្រេងនោះលាបសក់ផង និងអាចលាបឲ្យកូនក្មេងដែលមានជំងឺគ្រុនក្តៅដើម្បីបន្ថយកម្តៅផង។

– របៀបស្រូបប្រេងដូង៖ ដំបូងគេយកផ្លែដូងទុំបកសម្បកចេញ ពុះបំបែក (បើបានដូងដុះកាន់តែល្អ ព្រោះមានប្រេងច្រើន) បន្ទាប់មកគេប្រើខ្នោះគោសសាច់ដូងនោះជាសរសៃល្អិតៗ ចាក់ទឹកចូលប្រហែលជា១ត្រឡាក (ប្រហែល០,៥លីត្រ) សម្រាប់ដូង១ ហើយច្របាច់។ គេប្រើពេលច្របាច់យូរល្មមដៃរ ដើម្បីឲ្យដូងចេញខ្លឹះអស់ ទើបពួតយកកាកដូងចេញ និងប្រើក្រណាត់ស្បៃ ឬកន្ត្រងញីកធ្វើពីប្រូវ ច្រោះយកកាកដូងចេញឲ្យអស់។ រួចគេយកទឹកខ្លឹះនោះទៅរម្ងាស់ទាល់តែដាច់ទឹក (រីងទឹកអស់) នៅសល់ជាតិប្រេងសុទ្ធ គេចាប់ផ្តើមដួសប្រេងនោះ មិនឲ្យដោយកាកដាក់ដប ឬដាក់ក្នុងអ្វីដែលអាចរក្សាប្រេង

detailed its production.[11] Another type of imported hair oil, called *kayong tin*, seems to have been used beginning in the 1950s. However, because people were still poor and imported products were often quite expensive, they still preferred to use hair oils which they had made themselves, or bought locally produced hair oils from Cham and Vietnamese peddlers. According to the elderly who were accustomed to using such products, coconut oil made by the Vietnamese had a saffron additive. This oil could be used on the hair and also was rubbed on children to lower fevers.

Making coconut oil

The skin of a ripe coconut is peeled off and the coconut is split open. Coconuts that already have shoots sprouting out of them are best, since they have a lot of oil. A scraper is used to take the meat out of the coconut, scraping and grating the meat into fine strips. About one coconut shell of water is added to the grated meat of the coconut and this mixture is then repeatedly squeezed to extract the cream of the coconut. After a considerable period of squeezing, the coconut meat is removed and the remaining water and oil mixture is strained, using a cheesecloth or fine

---

[១៦] សូមអានអត្ថបទចុះក្នុងទស្សនាវដ្តីកម្ពុជសូរិយា ដោយលោក មាស ហាំ, ស្តីពី "ក្រមួនលាបមាត់" ក្បាលទី១ ឆ្នាំទី៣៧ ទំព័រ ២៨០ ឆ្នាំ១៩៦៥។

11 "Wax for the lips", Meas Hach, *Kampuchea Surya* #1, 1965.

រូបលេខ ២៩៣៖ ផ្លែដូងដុះ។ (រូបថត៖ រៃយ៉ំ)

Figure 293: Ripe coconut. (Photo: Reyum)



រូបលេខ ២៩៤៖ ផ្លែដូងពុះជាពីរ។ (រូបថត៖ រៃយ៉ំ)

Figure 294: Ripe coconut split open. (Photo: Reyum)

ទុកបានល្អ។ តាមស្មានផ្លែដូង១ស្រុបានប្រេងប្រហែល ២៥០ក្រាម ឬលើសនេះ បើផ្លែដូងធំ និងមានសាច់ក្រាស់។ ជនជាតិចាមនិយមប្រើប្រេងដូងណាស់។

– របៀបស្រែងល្មុង (ឬប្រែងស្អិត)៖ ល្មុងដែលអាចធ្វើប្រេងបាននោះ គឺតែងហៅល្មុងប្រែង។ ល្មុងនេះមានពីរយ៉ាង មួយមានជាងរាងក្រហមលាយស្វាយ និងមួយទៀតជាងពណ៌បៃតងអាចធ្វើប្រេងបានដូចគ្នា។ ល្មុងនេះយើញមានដុះនៅជិតផ្ទះ ឬដុះនៅតាមវាលក្បែរភូមិ ពិសេសតាម

meshed basket made out of bamboo to remove any remaining meat fragments. The oil and water mixture is then simmered for a long time to remove the remaining water until only pure coconut oil remains. This oil is scooped up, removing any remaining meat or fibers, and spooning it into a bottle or another container for storage. An average coconut yields about 250 grams of coconut oil, or slightly more if it is a particularly big fruit with a thick layer of meat.

រូបលេខ ២៩៥៖ ដើមល្មុងប្រែង។ (រូបថត៖ រៃយ៉ំ)

Figure 295: Oil papaya tree. (Photo: Reyum)

Making papaya oil or sticky oil

The type of papaya used to make oil is appropriately called the oil papaya. There are two types of oil papaya, one with reddish purple leaves or fronds, the other with green leaves or fronds. Both types can be used to make oil. Oil papaya are often grown near houses or in fields adjacent to villages, particularly along river banks. The oil

រូបលេខ ២៩៦៖ ផ្លែល្ពង់ប្រេងទុំ។ (រូបថត៖ រៃយ៉ំ)

Figure 296: Ripe fruit on the oil papaya tree. (Photo: Reyum)

រូបលេខ ២៩៧៖ គ្រាប់ល្ពង់ប្រេង។ (រូបថត៖ រៃយ៉ំ)

Figure 297: Seeds of the oil papaya fruit. (Photo: Reyum)

រូបលេខ ២៩៨៖ បុកគ្រាប់ល្ពង់ប្រេង។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 298: Pounding the oil papaya seeds. Photographed 2003. (Photo: Reyum)

មាត់ទន្លេ។ ប្រេងដែលបានពីល្ពង់នេះ គេហៅប្រេងស្អិត។ រៀបស្ងប្រេងល្ពង់មុនដំបូង គេបេះផ្លែល្ពង់ប្រេងទុំ ឬចាស់ល្អ ហាលថ្ងៃឲ្យស្ងួត រួចប្រលេះយកគ្រាប់។ មុនយកទៅស្ងអ្នកខ្លះយកគ្រាប់ល្ពង់នេះទៅលីងសិន ព្រោះគេយល់ថា ប្រេងដែលបានមកមានក្លិនឈ្ងុយ។ បន្ទាប់មកគេយកទៅបុកឲ្យម៉ដ្ឋ ហើយ

produced from the oil papaya is also sometimes called sticky oil.

To make the oil, ripe oil papaya fruit is dried in the sun. The seeds are picked out from the split open fruit. Some people like to roast the papaya seeds first, since they believe that the oil produced will be sweeter smelling if they do so. The seeds are pounded into a powder which is put in water. The water seed mixture is stirred and squeezed to remove the oil from the seeds. The mixture is then sieved to remove all seed and fruit residue. The remaining decanted water is simmered until all the water evaporates, leaving behind the oil. This oil is spooned up and stored for use. In order to have hair oil with a beautiful smell, some people add perfume to it when using the oil, while others pick ginseng leaves and dry them in the sun before adding them to the simmering oil and water mixture.



រូបលេខ ២៩៩៖ ល្ពង់ប្រេងច្របាច់យកទឹកដើម្បីរំងាស់។ ថតឆ្នាំ ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 299: Squeezing the pounded seeds before simmering the water and oil mixture. Photographed 2003. (Photo: Reyum)

រូបលេខ ៣០០៖ ចម្រាញ់យកប្រេងល្ពង់។ (រូបថត៖ រៃយ៉ំ)

Figure 300: Purifying the papaya oil. (Photo: Reyum)

រូបលេខ ៣០១៖ ស្លឹកពោល្យំស្រស់។ (រូបថត៖ រៃយ៉ំ)

Figure 301: Ginseng leaves. (Photo: Reyum)

រូបលេខ ៣០២៖ ស្លឹកពោល្យំហាលស្ងួត។ (រូបថត៖ រៃយ៉ំ)

Figure 302: Dried ginseng leaves. (Photo: Reyum)

លាយទឹកឲ្យល្មម ច្របាច់ឲ្យចេញប្រេងអស់ ទើបដាក់រម្ងាស់លើភ្លើងទាល់តែដាច់ទឹក ទើបគេដួសប្រេងនោះទុកលាបសក់។ ប្រសិនចង់ឲ្យមានក្លិនក្រអូប អ្នកខ្លះគេចាក់ទឹកអប់លាយ (ពេលលាប)។ បើមិនអញ្ចឹងគេបេះស្លឹកពោល្យំហាលថ្ងៃឲ្យស្ងួត រួចដាក់រំងាស់ជាមួយប្រេងដើម្បីឲ្យមានក្លិនក្រអូប។

Combs and hair pins

At the beginning of the 20th century, Khmer did not yet have combs made of plastic for combing their hair as we have today. Combs at that time were made of animal horn or bamboo. The bamboo combs had fine small teeth which they liked to call *snet*; these combs were used for removing fleas

- ក្រាស និងស្នៀតសក់៖ តាមការចងចាំរបស់ចាស់ៗបានឲ្យដឹងថា នៅដើមសតវត្សទី២០ ខ្មែរពុំទាន់មានក្រាសសម្រាប់សិតសក់ធ្វើពីជ័រដូចបច្ចុប្បន្នឡើយ គឺក្រាសដែលគេប្រើនាជំនាន់នោះមានធ្វើពីស្ពឹង និងឫស្សី។ ក្រាសធ្វើពីឫស្សីភាគច្រើនមានធ្មេញតូចៗញឹក គេនិយមហៅ "ស្ពិត"។ គេច្រើនប្រើសម្រាប់សិតចៃ ឬសិតសក់ ចំពោះអ្នកកាត់សក់ខ្លី។ ចំណែកអ្នកទុកសក់វែងច្រើនប្រើក្រាសស្ពឹងធ្មេញរន្ធើលៗហើយធំ។ លោកយាយកៃ រឿង អាយុ ៧៤ឆ្នាំ ខេត្តកណ្តាល ប្រាប់ថា "ក្រាសសិតសក់ពីដើមល្អណាស់ សុទ្ធតែក្រាសស្ពឹងសិតមួយវាមិនងាយខូចទេ"។ ក្រាសនោះមានធ្វើនៅស្រុកខ្មែរ ពីមុនធ្វើពីស្ពឹងក្របី និងឫស្សី។ លោកយាយស៊ឹម សារិន អាយុ៧៦ឆ្នាំ នៅខេត្តស្វាយរៀង ប្រាប់ថា "ពីមុនខ្ញុំសិតសក់និងក្រាសធ្វើពីស្ពឹងក្របី"។ សព្វថ្ងៃក្រាសធ្វើពីស្ពឹងក្របីកម្រមានលក់ ប្រហែលដោយសារពិបាកធ្វើ មានតម្លៃថ្លៃ និងមានប្រភេទក្រាសជ័រចេញច្រើន តម្លៃក៏ថោក។ សព្វថ្ងៃស្ពឹតឫស្សីធ្មេញល្អិតា



រូបលេខ ៣០៤៖ ក្រាសសិតសក់ធ្វើពីស្ពឹង។ (រូបថត៖ រៃយ៉ំ)

Figure 304: A comb made from horn. (Photo: Reyum).



រូបលេខ ៣០៣៖ ក្រាសសិតចៃធ្វើពីឫស្សី។ (រូបថត៖ រៃយ៉ំ)

Figure 303: A flea comb made from bamboo. (Photo: Reyum)

and for combing short hair. People with longer hair generally used horn combs with wider bigger teeth. Kai Rueng, 74 years old living in Kandal Province, told us, “Hair combs were very good then. They were all made of horn. It wasn’t easy to break them.” Combs made in Cambodia were generally made from the horns of water buffalo and from bamboo. Sim Saren, 76 years old living in Svay Rieng Province, told us, “Earlier I combed my hair using a water buffalo horn comb.” Today, combs made from water buffalo horn are rarely sold, perhaps because they are difficult to make and are expensive when compared to the readily available myriad of cheap plastic combs. Fine toothed combs made from bamboo are still sold in markets today and are used particularly in the countryside. Most bamboo combs in use today are imported from Vietnam.

រូបលេខ ៣០៥៖ ក្រាស់សិតចៃមកពី
ខេត្តរតនគីរី។ ថតឆ្នាំ២០០៣។
(រូបថត៖ ឈៃ)

Figure 305: Flea comb from Rattanakiri Province.
(Photo: Reyum)



យើងនៅឃើញមានលក់នៅផ្សារ និងនៅមានប្រើពិសេសអ្នកនៅតាមខេត្តនានា ហើយស្ទិតទាំងនោះភាគច្រើននាំចូលពីប្រទេសវៀតណាម។

នាសម័យមុន មនុស្សស្រីទុកសក់វែងបួងប្រើស្នៀតសក់ជាការលំអ។ លោកលឹម ហោជាង អាយុ ៦៣ឆ្នាំ នៅខេត្តកំពង់ធំ និយាយថា "ក្រមុំជំទង់ច្រើនបួង ហើយមានស្នៀតដោតកុំឲ្យជ្រុះជាយសក់ និងសម្រាប់ការពារខ្លួន។ ស្នៀតមានរំយោល មានធ្វើពីមាស ទង់ហ្វា ច្រាក់ ស្ពាន់"។ តំបន់ខ្លះគេហៅ "យូអ៊ី" ប្រហែលហៅតាមភាសាចិន។ លោកយាយខ្ចូត សំអុល អាយុ៧១ឆ្នាំ នៅភ្នំពេញ និយាយថា "យូអ៊ី មានកំពូល៣ ខ្លះកំពូល៥ អ្នកជូរធ្វើពីមាសមានដាំត្បូង"។ លោកយាយស៊ីម សារិន អាយុ ៧៦ឆ្នាំ នៅខេត្តស្វាយរៀង ក៏បាននិយាយដែរថា "ស្នៀតសក់នេះប្លែកៗពីគ្នា អ្នកខ្លះសៀតចង្កឹះ ខ្លះសៀតឈើ ឬសៀតរោមកាំប្រមា (រោមដែលបាញ់ចេញ)"។ បច្ចុប្បន្នយើងពុំសូវឃើញមានអ្នកប្រើស្នៀតសក់របៀបនេះទៀតទេ។

In the past, women who kept their hair long, wore it in a bun and used hair pins to decorate their hair. Lem Hok Cheang, 63 years old living in Kompong Thom Province, told us, "Many unmarried virgins wore their long hair in buns. They used pins to keep the hair up, and also to protect themselves. The pins had decorative chains hanging from them, and were made from gold, copper and zinc alloys, silver, and later on brass." In some regions they called such pins *yo ei* which perhaps is a Chinese word. Khlot Somol, 71 years old living in Phnom Penh, told us, "*Yo ei* had three decorative ends. Some had five. Rich people made them out of gold with inset precious stones." Sim Saren, 76 years old living in Svay Rieng Province, told us, "There were different kinds of hair pins in use. Some people used chopsticks as hairpins. Others used wooden sticks or the needles of porcupines." These types of hair pins are not seen in use today.

១- ការតុបតែងមុខនិងថែទាំស្បែក

សព្វថ្ងៃការលាបម្សៅ "ម៉ាកគីយេ" មានមនុស្សមួយចំនួនយល់ថា ស្អាតទាន់សម័យ។ ហេតុនេះទើបមានលូតលាស់ហាង់សម្អាងកាយ និងគ្រឿងសម្អាងផ្សេងៗ។ មិនតែប៉ុណ្ណោះនៅមានហាង់វះកាត់កែសម្ផស្ស ផាត់មុខ ត្រាំទឹកដោះគោថែសាច់កើតច្រើនព្រោងព្រាតនៅក្នុងទីក្រុងភ្នំពេញទៀតផង។ បើតាមការសង្កេត សង្គមខ្មែរសព្វថ្ងៃហាក់មានទំនោរទៅរកអ្វីដែលជាផ្នែកខាងសម្ផស្សស្រស់ប្លឹហាហើយថ្លៃក។ នេះប្រហែលមកពីទទួលឥទ្ធិពលតាមរយៈការផ្សព្វផ្សាយនៅលើទូរទស្សន៍ កាសែត ឬទស្សនាវដ្តី

រូបលេខ ៣០៦៖ មជ្ឈមណ្ឌលព្យាបាល និងថែរក្សាសម្ផស្សលុចូ្ប បច្ចុប្បន្ន, នៅតែងផ្លូវនរោត្តម និងផ្លូវអ៊ុតសន់, ឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 306: The Clinique Luxe Beauty Salon, Phnom Penh. Photographed 2003. (Photo: Reyum)

Make up and care of the skin

People think that using powder on the face makes it more beautiful and fashionable. Thus beauty salons have proliferated and many cosmetic products are imported from abroad. In addition, plastic surgery clinics, make up salons, and places to take milk baths for the skin, have sprung up all over Phnom Penh. These days, it seems that people turn to the beautiful, stylish, and different, partly due to the influence of advertising on television and in newspapers and magazines. Fashion trends particularly affect the youth who like to wear the latest styles of clothing, cut their hair in new ways, and make up their faces in ways that they understand to be fashionable.

According to our elderly interviewees, at the beginning of the 20th century, the area today known as Cambodia did not have many ready-made creams and powders for use in making up the self. This did not mean, however, that people did not know how to powder their faces and paint their eyebrows, lips, and fingernails. They simply used other methods than those used today. To keep the skin beautiful and clear, they used saffron powder, while to powder the face, they used a lump powder. Incense paper was used to redden the lips, while eyebrows were outlined using methods of the time. At the end of the

ជាដើម។ យើងឃើញឥទ្ធិពលនេះងាយជ្រួតជ្រាប ចំពោះយុវវ័យខ្លះដែលនិយមស្លៀកខោអាវកាត់សក់ ម៉ូតប្លែកៗ។ គេលាបមុខមាត់តាមការនិយមផ្ទាល់ខ្លួន។

តាមចាស់ៗនិយាយ នៅដើមសតវត្សទី២០ ស្រុកខ្មែរពុំទាន់មានគ្រឿងប្រេងម្សៅសម្រាប់សម្ផាងខ្លួនសម្បុណ៌ដូចបច្ចុប្បន្ននេះឡើយ។ ប៉ុន្តែមិនមែនមានន័យថា គេមិនចេះប្រើម្សៅ តុបតែងមុខ គូរចិញ្ចើម លាបបបូរមាត់ ឬលាបក្រចកនោះទេ។ គ្រាន់តែគេប្រើម្សៅល្បៀតដើម្បីថែសាច់ឲ្យស្អាតស្រស់ថ្លា ឬប្រើម្សៅគ្រាប់សម្រាប់លាបមុខ និងលាបខ្លួន ព្រមទាំងមានក្រដាសប៉ុធូបពណ៌ក្រហមសម្រាប់លាបមាត់ និងចេះគូរចិញ្ចើមតាមរបៀបរបស់គេនាសម័យនោះផង។

ខាងក្រោមនេះ យើងនឹងលើកយក៤ចំណុចមកបង្ហាញ គឺការតុបតែងមុខ (លាបម្សៅ លាបបបូរមាត់ គូរចិញ្ចើម), របៀបធ្វើម្សៅគ្រាប់, លាបល្បៀតថែសាច់និងរបៀបធ្វើ និងការថែទាំក្រចក។

លាបម្សៅ

នៅដើមសតវត្សទី២០ ខ្មែរពុំមានម្សៅលាបមុខប្រើ ក្រៅពីម្សៅគ្រាប់ដែលធ្វើក្នុងស្រុក និងនាំមកពីស្រុកសៀម។ ម្សៅនេះជាគ្រាប់ដូចគ្នា តែខុសគ្នាត្រង់ម្សៅខ្មែរមិនក្រអូប ពេលលាបត្រជាក់ព្រោះម្សៅនេះមានលាយម្ជាងសិលា។ ម្សៅគ្រាប់ខ្មែរមិនដាក់ក្នុងកំប៉ុងទេ គឺគេធ្វើលក់ពាយាល់ដៃ ១ដៃ ៦ដៃ ឬលក់១សេន ២សេន អាស្រ័យតាមអ្នកដែល

1940s, Cambodia began to have relationships with a wider circle of foreign countries. Beauty products such as oils, powders, creams, and perfumes increasingly entered the country in greater and greater numbers. Domestically produced facial powders were also advertised in the newspapers. In what follows, we discuss four aspects of makeup and care of the skin: ways of making up the face (lipstick, facial powder, eyebrow pencils), the way to make lump facial powder, the making and use of saffron to take care of the skin, and ways of doing the nails.

Making up the face

In the early 20th century, only a clump or lump face powder, which was both locally made and imported from Thailand, was available. The locally made powder was similar to the Thai powder, but was not scented. It made the skin feel cool when it was applied. The locally produced lump powder was not put in containers but was sold loose by the handful. One handful cost one to two *centime* usually. The face powder was called by several different names: ***paet nuon*** powder, animal dirt powder, pomegrenate seed powder, canned powder, or lump powder.

According to our elderly interviewees, most women living in Phnom Penh bought facial products at the Neak Duong Store

ទៅរកទិញ។ ម្យ៉ាងទៀតខ្មែរហៅឈ្មោះម្សៅនោះ ខុសគ្នាទៅតាមការនិយម និងតាមតំបន់នីមួយៗ។ ខ្លះហៅម្សៅប៉ែតនួន ខ្លះហៅម្សៅអាចម៍សត្វ ម្សៅគ្រាប់ទទឹម ឬម្សៅគ្រាប់ជារដើម។ ឯម្សៅសៀមដាក់ក្នុងកំប៉ុង ហើយក្រអូប។ តាមការសាកសួរចាស់ៗអ្នកនៅភ្នំពេញភាគច្រើន គេទៅរកទិញម្សៅនៅហាងអ្នកដួង ដែលជាហាងមួយល្បីជាងគេនៅពេលនោះ មានលក់គ្រឿងប្រេងម្សៅ ក្រមួន ទឹកអប់ គ្រឿងប្រាក់ និងក្រណាត់គ្រប់ប្រភេទ។ តាមសម្តី



រូបលេខ ៣០៧៖ ការផ្សាយម្សៅផាត់មុខសម្ងាត់ខ្លួន, ដកស្រង់ពីកាសែតកម្ពុជា លេខ២៥១, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៤៦។

Figure 307: Advertisement for facial powder. *Kampuchea*, #251, January 30, 1946.

which was famous at the time for selling powders, creams, oils, waxes, and perfumes as well as silver jewelry and all kinds of cloth. According to Ram Rem, 72 years old living near Phnom Penh, "The Neak Duong Store was next to the *veal main* [the large field in front of the National Museum], and there was a movie theater near there called the Dara Movie Theater. That area of the city used to be called Psar Signet. When you came out of the Neak Duong Store, you were next to Wat Onalom. That row of stores all sold perfume, *pamuong*, and silk *sarong*. Displays filled that row. There was also a store selling urns for keeping the ashes of those cremated. Everyone called that store the Neak Duong Store." It was not only people living in Phnom Penh who came to buy powder from the Neak Duong Store. Even people from the provinces came to buy beauty products there. Kai Rueng, 73 years old living in Kandal Province, told us, "Earlier there was a clump powder which they called *paet nuon* powder. There was also powder in metal cans brought from Thailand. They brought a lot of that to be sold. As for Khmer beauty products, they were sold at the Neak Duong Store near Wat Onalum. They had a Khmer perfume too. If you wanted a beautiful scent, you would buy the perfume and mix it with facial powder and then put it on the face. That powder felt very cool." Phi, 82 years old born in Kandal

រូបលេខ ៣០៨៖ មេរ្យាលាបមុខយីហោ Tokalon, ដកស្រង់ពី កាសែតកម្ពុជា លេខ១៧២៩, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៥១

Figure 308: Advertisement for Tokalon Facial Powder. *Kampuchea*, #1729, May 4, 1951.

Province, told us, "I only used canned scented powder from Thailand. One can cost one *centime*. Loose clump powder made in Cambodia cost one *centime* for a handful, and there was nothing to wrap it in. It was made in the area of Wat Svay Popey."

My Touch, 70 years old living in Kompong Speu Province, told us, "Earlier, we painted the faces of young virgins with powder that the smugglers bought from Ou Chrou. The powder from Thailand in those days was different from powder today. It smelled very beautifully and they called it Ou Chrou Powder. When one went to a ceremony or wedding, you just needed three small clumps of it, that was enough to cover the face." Long Than, 88 years old living near Phnom Penh, told us, "If you had it [face makeup], you would make up your face. If you didn't, then you didn't. I never made myself up. We were busy. My father climbed palm trees. When I went to the *wat* [temple complex], I would ask them to make up my face with tiny clumps of powder. It wasn't scented. They made that powder themselves. In my house, we didn't make face powder."

According to Sim, 80 years old living in Kompong Cham Province, "Before, they only wore face powder for ceremonies and weddings. They didn't wear it everyday. In those days, if you just sat around putting on makeup like they do today, you wouldn't have

food and would die." Jaing Suon, 79 years old living in Battambang Province, told us, "When I was little and went to the temple, I put on a powder that came in little clumps the size of locust tree seeds. That powder was kept in small cans, the size of condensed milk cans. Mostly we bought that powder at the house of the Chinese who sold various household things. Some people knew how to make that powder themselves."

In Phnom Penh, in addition to the Neak Duong Store, there were French owned stores selling beauty products. Khlot Somol, 71 years old living in Phnom Penh, told us, "*Paet nuon* powder was sold in the markets.

*រូបលេខ៣០៩៖ អតីតទីតាំងហាង*អ្នកដួង *ដែលមានឈ្មោះល្បីនៅទសវត្សរ៍១៩៦០។ សព្វថ្ងៃជាផ្ទះ នៅកែងផ្លូវសម្តេចសុធារស និងផ្លូវលេខ១៧៨ ខាងជើងវាលព្រះមេរុ។ ថតឆ្នាំ២០០៣។*
(រូបថត៖ រ៉ៃយុំ)

Figure 309: The location of the former Neak Duong Store (at the corner of Sothearos Boulevard and Street 178). Photographed 2003. (Photo: Reyum)

*លោកយាយរ៉ាំ រីម អាយុ៧២ឆ្នាំ នៅក្រុងភ្នំពេញ និយាយថា "ហាង*អ្នកដួង *នៅជាប់វាលមេរុ ហើយមានរោងកុនមួយនៅជិតហ្នឹង គេហៅរោងកុនតាភា។ ម្តុំហ្នឹងពីមុនគេហៅផ្សារស៊ីញែក។ ចេញពីហាង*អ្នកដួង *ទៅជាប់វត្តប្រលោម មួយជួរហ្នឹងលក់សុទ្ធតែទឹកអប់ ជាមួង សារុងសូត្រ។ គេដាក់តាំងពេញតែហ្នឹង ហើយក៏មានហាងលក់កោដ្ឋដាក់ឆ្នឹងដែរ។ ម្នាក់ៗ ហៅហាងហ្នឹងថា ហាង*អ្នកដួង*"។ មិនត្រឹមតែអ្នកនៅភ្នំពេញប៉ុណ្ណោះទេ ដែលទៅរកទិញម្យ៉ាងពីហាង*អ្នកដួង *សូម្បីអ្នកនៅតាមខេត្តខ្លះ ក៏មកទិញនៅទីនោះដែរ។ លោកយាយកែ រឿង អាយុ៧៣ឆ្នាំ នៅខេត្តកណ្តាល ប្រាប់ថា "ពីដើមមានម្យ៉ាងដុំ គេហៅម្យ៉ាបែ"តនួន ជួនណាកំប៉ុ"ងដែកយកមកពីសៀម គេយកមកលក់ច្រើនណាស់។ ឯរបស់ខ្មែរយើង លក់នៅហាង*អ្នកដួង *ម្តុំវត្តឧណ្ណាលោម មានលក់ទឹកអប់ខ្មែរដែរ។ បើចង់ក្រអូបទិញទឹកអប់យកមកចាក់លាយជាមួយម្យ៉ាលាប។ ម្យ៉ានោះពេលលាបត្រជាក់ណាស់"។ លោកយាយភី អាយុ៨២ឆ្នាំ នៅខេត្តកណ្តាល បានបន្ថែមទៀតថា "ខ្ញុំលាបតែម្យ៉ាកំប៉ុ"ងមកពីសៀមក្រអូបណាស់ ១កំប៉ុ"ងថ្លៃ១សេន។ បើម្យ៉ាគ្រាប់ធ្វើក្នុងស្រុកខ្មែរ ១សេនបាន១ដៃ ហើយគ្មានអ្វីខ្លះប់ឡើយ។ មានធ្វើនៅស្រុកខ្មែរម្តុំវត្តស្វាយពពែ"។ លោកយាយ ម៉ី ទូច អាយុ៧០ឆ្នាំ នៅខេត្តកំពង់ស្ពឺ ក៏បានប្រាប់ថា "ពីដើមលាបម្យ៉ារូបកូនក្រមុំដែលអ្នកត់ពន្ធពីអូរជ្រៃមក។ ម្យ៉ាសៀមពីដើមមិនដូចម្យ៉ាឥឡូវទេ ក្រអូប

ណាស់ គេហៅម្យ៉ាអូរជ្រៅវា។ ពេលទៅបុណ្យទៅការ មានតែ៣គ្រាប់លាបបានហើយ"។ លោកយាយ ឡង តាន់ អាយុ៨៨ឆ្នាំ និយាយថា "បើមានក៏លាបអត់ក៏ហ៊ីទៅ ខ្ញុំមិនដែលបានធ្វើខ្លួននឹងគេទេ ព្រោះវេល់ ឥពុកជាអ្នកឡើងត្នោត។ បើពេលទៅវត្ត ខ្ញុំធ្លាប់សុំគេលាប ម្យ៉ាគ្រាប់តូចៗ អត់ក្រអូបទេ ព្រោះម្យ៉ាធ្វើខ្លួនឯង ផ្ទះខ្ញុំអត់មានធ្វើទេ"។ ចំពោះលោកយាយ ស៊ីម អាយុ៨០ឆ្នាំ នៅខេត្តកំពង់ចាម យល់ថា "ពីសម័យមុន គេលាបម្យ៉ាតែពេលទៅបុណ្យ ទៅការ គេមិនលាបប្រចាំថ្ងៃឡើយ។ បើសិនណាគេអង្គុយតែធ្វើខ្លួនដូចឥឡូវ អត់បាយងាប់អស់ហើយ!"។ លោកយាយចែង សួន អាយុ៧៩ឆ្នាំ នៅខេត្តបាត់ដំបង និយាយថា "ពីក្មេងពេលទៅវត្តទើបខ្ញុំលាបម្យ៉ាគ្រាប់ប៉ុនៗគ្រាប់ស្លួយ ដាក់ក្នុងកំប៉ុងដូចកំប៉ុងទឹកដោះគោដែរ។ ច្រើនតែទៅទិញម្យ៉ានោះនៅផ្ទះចិនលក់ចាប់ហួយ។ អ្នកខ្លះគេចេះធ្វើម្យ៉ាគ្រាប់នោះប្រើដោយខ្លួនឯង"។ នៅភ្នំពេញ ក្រៅពីហាង៍អ្នកដួង នៅមានហាង៍របស់ជនជាតិចារ៉ាំង៍ដែរ។ លោកយាយខ្លូត សំអុល អាយុ៧១ឆ្នាំ នៅភ្នំពេញ និយាយថា "មានម្យ៉ាប៉ែតនួនលក់នៅតាមផ្សារ។ ពីដើមមានហាង៍ចារ៉ាំង៍មួយនៅមាត់ទន្លេ ខាង៍ជើង៍ផ្សារចាស់ ហៅហាង៍ប្រ៊ូស (Brouse) មានលក់គ្រឿង៍សព្វទាំង៍អស់។ ស្រីៗពីដើមគេមិនមែនអ្នកធ្វើខ្លួនទេ"។

អ្នកនៅស្រុកជនបទធ្ងាយាមិនងាយនឹង៍បានឡើង៍មកដល់ផ្សារធំៗ ឬហាង៍នៅភ្នំពេញឡើយ។ ពួក

Earlier there was a French store along the river, north of Psar Chas [the Old Market] which was called Brouse. It sold all sorts of beauty products. Women in earlier times didn't really make themselves up." People living in the remote countryside far from big markets or stores of Phnom Penh could buy beauty products from peddlers who were primarily Cham, although some Khmer also traveled through the countryside selling cloth, creams, powders, perfumes, needles, scissors, and soap. Ly El, 79 years old living in Kandal Province, who used to travel through the countryside selling such things, told us, "In earlier times, there was *paet nuon* powder which came in small pointed clumps and was scented. Some women, before they would buy the powder, asked for two or three little clumps to mix with water and paint their faces to try it out. When they saw it was a good powder, they would buy it. One packet cost five *centime*." Peddlers did not only accept money in exchange for their goods. They would also accept payments in rice, which they kept for eating along the road while they traveled selling their things. Some women never used facial powder while others were accustomed to using banana leaf powder. Mich, 88 years old living in Kandal Province, told us, "In the time of my mother's oldest sibling, if they wanted face powder, they

តេអាចទិញប្រេងម្សៅ ឬរបស់ផ្សេងៗពីឈ្មួញដែលភាគច្រើនជាជនជាតិចាម និងខ្មែរខ្លះដែលរកស៊ីដើរលក់ក្រណាត់, គ្រឿងប្រេងម្សៅ, ទឹកអប់, ម្ជុល, កន្ត្រៃ, សាប៊ូ ។ល។ លោកតាលី អ៊ិល អាយុ៧៩ឆ្នាំ នៅខេត្តតកណ្តាល ធ្លាប់ដើរលក់គ្រឿងទាំងនោះនៅតាមស្រុកស្រែចម្ការ បានប្រាប់ថា "ពីមុនមានម្សៅប៉ែតនួន ធ្វើជាគ្រាប់តូចៗស្រួចៗហើយក្រអូប។ ស្រីៗខ្លះមុនទិញសុំ២-៣គ្រាប់យកទៅលាយទឹកលាបមុខសិនឃើញល្អបានទិញ មួយកញ្ចប់ថ្លៃ៥សេន"។ លើសពីនេះ គេមិនត្រឹមតែលក់យកលុយមួយមុខទេ គេក៏ដូរអង្ករទុកបរិភោគតាមផ្ទះ ទម្រាំគេលក់របស់របរនោះអស់។ ទោះយ៉ាងណាក៏មានស្ត្រីខ្លះមិនដែលលាបម្សៅសោះ ខ្លះទៀតលាបម្សៅស្លឹកចេក។ លោកយាយមុិច អាយុ៨៨ឆ្នាំ នៅខេត្តកណ្តាល និយាយថា "ជំនាន់បងម្តាយខ្ញុំ បើចង់លាបម្សៅចូលក្នុងចម្ការចេក លាបម្សៅជាប់ស្លឹកចេក រួចទៅឆ្លុះទឹកពាង"។ លោកុយាយគង់ គីម អាយុ៧៩ឆ្នាំ នៅខេត្តតាកែវ ក៏បញ្ជាក់ដែរថា "ទិញម្សៅយកមកធ្វើអី! បើលាបតែម្សៅស្លឹកចេកជ្រា ប៉ាតលើមុខឡើងសស្អាក"។

ដូច្នេះស្ត្រីជំនាន់នោះ ក្រៅពីម្សៅគ្រាប់ពុំមានអ្វីផ្សេងទុកជាគ្រឿងតុបតែងមុខដូចបច្ចុប្បន្នឡើយ។ ម្យ៉ាងមកពីមិនសូវមានលុយកាក់គ្រប់គ្រាន់និងជាប់រវល់ក្នុងការងារស្រែចម្ការ។ មួយថ្ងៃវានៅតែក្រាមកម្តៅថ្ងៃ ពុំមានពេលនឹងអង្គុយធ្វើខ្លួនទេ បើលាបម្សៅអាចធ្វើឲ្យស្បែកមុខជាំខ្មៅ។ ជំនាន់នោះ បើស្ត្រី

would go into the banana plantation and use the powder sticking to the banana leaves, checking their faces in the glassy surface of the water jars." According to Kong Kim, 79 years old living in Takeo Province, "What would you buy powder for? Just use the powder found on the *jway* banana leaves. Pat that on your face and it will be white and beautiful."

Thus, we see that women in earlier times only had simple face powders for making up their faces, not like the huge array of beauty products available today. In those days, they didn't have much spare money to buy what products were available, and they were too busy working in the fields to think of make up. During the day, they were exposed to the sun, and wearing local face powders was thought to make the skin even darker. In those days, if a woman wore make up everyday, they would criticise her, saying that she was a woman who "wanted to be white and beautiful" and therefore not a good woman. It was initially prostitutes from Phnom Penh who began using facial powder, so people in the countryside thought that whoever had a made up face was a prostitute. Today, the habit of making up the face is considered a normal activity and no longer has bad connotations. Even some men use beauty products today to improve their appearance.

ណាលាបម្សៅប្រចាំថ្ងៃ តែតែងរិះគន់ថា ស្ត្រីនោះចង់ស ចង់ស្អាត ហើយគេចាត់ទុកជាស្រីមិនល្អទៀតផង។ ដោយសារមុនដំបូងមានស្រីមិនល្អ ឬស្រីខូចដែលទៅពីភ្នំពេញមានមុខសដោយសារលាបម្សៅ ទើបអ្នកស្រុកឲ្យតែឃើញមានអ្នកណាលាបម្សៅតែងគិតថា ជាស្រីមិនល្អដែរ។ តែសព្វថ្ងៃការផាត់មុខមាត់ក្លាយជារឿងធម្មតាមិនមានអ្វីខុសឆ្គងណាស់ណាទេ សូម្បីមនុស្សប្រុសខ្លះក៏មានប្រើគ្រឿងសម្អាងមុខដែរ។

– របៀបធ្វើម្សៅគ្រាប់៖ យើងលើកយកតែរបៀបធ្វើម្សៅគ្រាប់ខ្មែរតាមការចងចាំរបស់មនុស្សចាស់ដែលធ្លាប់ប្រើប្រាស់ ធ្លាប់ធ្វើ ឬធ្លាប់ឃើញតាំងពីជំនាន់គាត់នៅក្មេងៗ។ លោកយាយមុិច អាយុ៨៨ឆ្នាំ រៀបរាប់ពីការធ្វើម្សៅនោះថា "គេទិញម្ហាងសិលាយកមកបំពងលើភ្លើងឲ្យឡើងផុស យកមកបុកឲ្យម៉ដ្ឋហើយលាយទឹកត្នោអ៊ុនៗឲ្យខាប់ រួចកូរវែក។ បើម្សៅនោះរឹងយើងចាក់ទឹកថែមបន្តិចៗ រួចកូរហូតដល់ម្សៅឡើងម៉ដ្ឋនិងភ្ញី ទើបដួសយកទៅបន្តក់លើស្រទបស្លា ក្រណាត់ ឬក្រដាស រួចហើយយកទៅហាលថ្ងៃឲ្យស្ងួតមែនទែនបានគេយកមកទុក។ គ្រាប់ម៉ាប៊ុនៗមេដៃ មានគ្រាប់ខ្លះធំ ខ្លះតូច មានគេធ្វើលក់នៅផ្សារដែរ មួយគ្រាប់គេលាបបាន២-៣ដង"។ ចំពោះលោកយាយសួង ម៉ាលី អាយុ៧០ឆ្នាំ នៅខេត្តកំពង់ធំ ធ្លាប់ឃើញម្តាយធំគាត់ធ្វើម្សៅគ្រាប់នោះនិយាយថា "មិនដែលទិញម្សៅនៅផ្សារទេ ធ្វើតែខ្លួនឯងម្តាយធំខ្ញុំអ្នកធ្វើ។ គាត់ជាប្រពន្ធថៅហ្វាយស្រុក គាត់

Making lump powder

Here we only discuss some of the ways of making lump facial powder, using information from interviews with elderly persons who made, used, or saw such powders when they were little. Mich, 88 years old, told us, "They would buy plaster [limestone?] and heat it until it bubbles to the surface. Then they pounded it into a fine powder and mixed it with a little water, stirring the mixture to make a thick paste. If the paste was too dry, they added more water and stirred it into a smooth and shiny paste. This paste was spooned onto an areca palm frond, a piece of cloth, or a sheet of paper, and allowed to dry in the sun. The clumped powder was then stored. The lumps of powder were about the size of a thumb, some bigger, some smaller. Some people made this powder and sold it in the market. One lump of powder could be used two or three times to make up the face."



រូបលេខ ៣១០៖ ម្ហាងសិលា។ (រូបថត៖ រៃយ៉ំ)

Figure 310: A soft stone used to make facial powder. (Photo: Reyum)

ទៅទិញម្សៅ (មិនដឹងថាម្សៅអី តែប្រហែលជាម្សៅគ្រាប់) ពីហាង់អ្នកដូង់យកទៅកូរវឺកនឹង់ម្នាង់សិលា បន្ទាប់មកគាត់បន្តក់ជាគ្រាប់តូចៗ រួចដាក់ហាលថ្ងៃឲ្យទាល់តែស្ងួត ការបេះ។ ទើបយកទៅទុកបាន។ ១ឆ្នាំធ្វើ ២តឿ។ ទាល់តែខ្ញុំការអាយុ១៩ឆ្នាំបានមានម្សៅប្រអប់របស់ចាវ៉ាង់លាប។ ពីមុនលាបតែម្សៅលោកអ៊ំធ្វើនោះឯង"។ សព្វថ្ងៃនេះទម្លាប់ធ្វើម្សៅគ្រាប់បានបាត់អស់ទៅហើយ។ ដោយសារមាននាំចូលផលិតផលពីចាវ៉ាង់ ជាប្រទេសមួយដែលល្បីឈ្មោះខាង គ្រឿងសម្អាង ទឹកអប់ ប្រេងម្សៅ ក្រែម ។ល។ ទាល់តែអ្នកមានជីវភាពធូរធារទើបអាចទិញយកមកតុបតែងខ្លួនបាន។ ចាប់ពីទសវត្ស១៩៥០មក ចាប់ផ្តើមមានម្សៅប្រអប់ពីបរទេសចូលក្នុង់ស្រុកជាបន្តបន្ទាប់។

រូបលេខ៣១២៖ ការតែង់ខ្លួនក្នុង់ពិធីរៀបការ នៅខេត្តកំពង់ធំ។ ថត ឆ្នាំ១៩៥៨។ (រូបថត៖ លោកម៉ៃខឺល វិកខឺរី)

Figure 312: Makeup for a wedding in Kompong Thom Province, 1958. (Photo: Dr. Michael Vickery)



រូបលេខ ៣១១៖ ម្សៅគ្រាប់កំបុង់មកពីថៃ។ គ្រាប់ម្សៅមានរូបភាង ដូចម្សៅប៉ែតនួនរបស់ខ្មែរដែរ។ (រូបថត៖ រៃយ៉ំ)

Figure 311: Lump face powder imported in cans from Thailand. This powder had the same kind of clumps as the Khmer *paet nuon* powder. (Photo: Reyum)

According to Suong Mali, 70 years old living in Kompong Thom Province, who used to watch her aunt make this kind of powder, "We never bought powder in the market. We only made it ourselves. My aunt was the one who made it. She was the wife of the district leader. He went to buy powder (I don't know what kind of powder it was, but maybe it was some kind of lump powder) from the Neak Duong Store. She would stir and beat it with limestone plaster. Then she would let this mixture drip down into small lumps that she set in the sun to dry. She would pick up the dried clumps and store them. In a year, she would make about two kilos of that powder. When I married, at the age of 19, then I used French face powder that came in a box. Before that, I only used the powder made by my

ការលាបស្បៃត

នៅមុនទសវត្ស១៩៥០ ខ្មែរពុំសូវមានគ្រឿងសម្រាប់ស្អិតស្អាងសម្បុរដូចសព្វថ្ងៃឡើយ។ គេយកមើមរុក្ខជាតិខ្លះដូចជា ពន្លែ ស្បៃត ឬសម្បកដើមព្រហូត ថ្នែធ្វើជាម្សៅលាបសាច់ ដើម្បីរក្សាស្បែក។ អ្នកមានជីវភាពធូរធារ ពេលកូនស្រីពេញវ័យគ្រប់ការភ្លាម គេមានទំនៀមឲ្យចូលម្ជុំ ថែទាំសាច់ដោយលាបស្បៃតរាល់ថ្ងៃ។ ប៉ុន្តែមានតែនារីខ្លះៗនៅតាមតំបន់មួយចំនួនប៉ុណ្ណោះ មិនមែនគ្រប់នារីខ្មែរសុទ្ធតែធ្លាប់បានចូលម្ជុំនោះឡើយ។ ក្នុងចំណុចនេះ យើងលើកយកវិធីថែសាច់របស់នារីទូទៅ មិនសង្កត់ធ្ងន់លើការថែខ្លួនរបស់នារីចូលម្ជុំនោះឡើយ។

ភាគច្រើននៅមុនពេលជិតរៀបការ២ ឬ៣ថ្ងៃ នារីដែលជាកូនក្រមុំតែងលាបម្សៅស្បៃតសម្អិតសម្អាងខ្លួនប្រាណឲ្យឃើញស្បែករលោងស្អាត ដូចជាលោកយាយឡុង តាន់ អាយុ៨៨ឆ្នាំ បាននិយាយថា "ស្រីក្រមុំកូនគេអ្នកមានពេលជិតរៀបការ គេថែសាច់ដោយលាបស្បៃត លាបដៃ លាបជើង លាបកតែមុខអត់លាបទេ។ ចំណែកខ្ញុំមិនដែលស្គាល់សាច់ស្បៃតសោះហើយ រវល់រកខុសវាល់ស្លាច"។ ដូចគ្នាដែរលោកយាយស៊ីម អាយុ៨០ឆ្នាំ ប្រាប់ថា "ដូចថាស្អែកចូលកោងការកូនក្រមុំលាបស្បៃតពីថ្ងៃនេះទៅគេបុកស្បៃតលាបសម្អិតសម្អាងខ្លួនប្រាណ ដៃជើងរួចគេមុជទឹក ហើយគេយកម្សៅមកលាបខ្លួនបន្ថែមទៀត"។ ចំណែកលោកយាយជួ សារឿន អាយុ៧៧ aunt." The tradition of making face powder has almost completely disappeared today. Beginning in the 1950s, more and more packaged facial powders were imported from abroad, particularly from France which is famous for its beauty products, perfumes, oils, powders, and creams. It was only as people's living standards improved, however, that they could afford to buy such product, and to wear makeup on a regular basis.

Saffron for the care of the skin

Before the 1950s, there were not so many ready-made beauty products available for the care of the skin. Therefore, people used various roots and natural ingredients such as saffron, the bark of the *prahoat* tree, and ginger as ingredients for making powders to care for and protect the skin. Girls from well off families who had reached puberty and were becoming marriageable generally *chol mlup* (literally, enter the shade, a period of relative isolation in which girls were taught householding skills). During this period, they cared for their skin by putting saffron on it every day. Not every girl in every region of Cambodia underwent this ritual. Here, we discuss more ordinary care of the skin without focusing on the special rituals of skin care associated with *chol mlup*.

Most girls, about two or three days before their wedding, would put saffron

រូបលេខ ៣១៣៖ ម៉ើម និងម្សៅល្មៀត។ (រូបថត៖ រៃយ៉ំ)

Figure 313: Saffron. (Photo: Reyum) .

រូបលេខ ៣១៤៖ ម៉ើមពន្លែ។ (រូបថត៖ រៃយ៉ំ)

Figure 314: Ginger. (Photo: Reyum) .

ឆ្នាំ នៅខេត្តព្រៃវែង ធ្លាប់ចូលម្ជុំរយៈពេលជាង១ឆ្នាំ បានបង្ហាញពីរបៀបធ្វើម្សៅល្មៀតខ្លះៗថា នៅពេលគាត់ចូលម្ជុំ គាត់លាបល្មៀត និងម្សៅទិញពីហាង អ្នកដូង។ ម្សៅល្មៀតគាត់បុកខ្លួនឯង។ ល្មៀតនោះ គោសសម្បកចេញឲ្យស្អាត យកទៅស្ងោរ ដាក់អំបិលបន្តិច សាច់ជូរបន្តិច (ដើម្បីកាត់ជ័រល្មៀត)។ ពេលពុះស្រង់យកមកចិតជាចំណិតៗ ដាក់ហាលឲ្យស្ងួត យកមកបុកឲ្យម៉ដ្ឋ។ ពេលងូតទឹកហើយ (ពេលព្រលប់) ជូតខ្លួនឲ្យស្ងួតទើបយកម្សៅល្មៀតឈ្មីលាបសពួខ្លួន។ ព្រលឹមឡើងទើបងូតទឹកសម្អាត។ បើអ្នកខុសប្រាហ៍ លាបពីរដង ខ្លះលាបបីដងក្នុងមួយថ្ងៃ តាមពេលទំនេរ ឬមិនទំនេរ។ ការធ្វើម្សៅល្មៀតនេះ បើធ្វើលក់គេយកតែល្មៀតតូចៗ ហើយមានលាយកន្ទក់ខ្លះ និងមិនដាក់ថែមជាតិជូរទេ។ បើធ្វើសម្រាប់ប្រើខ្លួនឯង ច្រើនយកក្បាលល្មៀត ព្រោះក្បាលល្មៀតសម្បូណ៌ជាតិម្សៅ និងមានតម្លៃថ្លៃជាងល្មៀតតូចៗ។ លោក

powder all over their body to make their skin shiny, whiter and more beautiful. Long Than, 88 years old, told us, "The girls of rich people who were about to marry would take care of their skin by using saffron, putting it on their arms, legs, and neck. They wouldn't put it on their faces however. I never used saffron. I was busy looking for firewood every afternoon." Sim, 80 years old, confirmed that, "The virgin who was going to marry tomorrow, would use saffron today. They pounded saffron and put it on their body, arms, and legs. Then they would bathe and put saffron powder on again." Ju Saroeun, 79 years old living in Prey Veng Province, who *chol mlup* for more than one year, showed us how to make saffron powder. She said that during the time she *chol mlup* she used both saffron powder which she made herself and a powder bought at Neak Duong Store in Phnom Penh. In order to make the

យាយម៉ុល អាយុ៨៤ឆ្នាំ នៅខេត្តកំពង់ស្ពឺ គាត់ពុំ
ដែលលាបម្សៅល្មៀតទេ តែផ្ទះគាត់ដាំល្មៀតដើម្បី
ធ្វើម្សៅលក់។ ចំពោះវិធីធ្វើវិញពុំខុសពីលោកយាយ
ជូ សារឿន ឡើយ។ ក្រោយពីបុកល្មៀតម៉ដ្ត គាត់យក
មកវែងនីងស្បៃ បន្ទាប់មកខូបម្សៅល្មៀតជាកញ្ចប់ៗ
ទុកលក់។ ស្ត្រីខ្លះទិញម្សៅល្មៀតយកទៅលាបខ្លួន ឬ
លាបមុខ។ ហើយអ្នកខ្លះទៀតមានដាក់ថែមពន្លៃ និង
ម្ហូរក្រសាំង ឬអំពិលលាយឲ្យឡើងខាប់ៗបានយកមក
លាបឲ្យសព្វខ្លួន។ គេច្រើនលាបពេលយប់ ភ្ញាក់ឡើង
ទើបគេងូតទឹកជម្រះចេញ។ ពេលលាបម្សៅល្មៀត គេ
មិនដើរហាលថ្ងៃឡើយ ព្រោះពេលលាបល្មៀតហើយ
ដើរហាលថ្ងៃអាចធ្វើឲ្យសាច់ឡើងខ្មៅ។ ចំពោះអ្នក
កើតចែងថ្ងៃ ក្រោយពេលងូតទឹកហើយ គេលាបម្សៅ
ល្មៀតលាយជាមួយក្រូចស៊ើច បើអ្នកកើតរមាស់
លាយកំបោរបន្តែម។ គេលាងចេញក្រោយពេលស្ងួត
ឬផ្ទាប់ទុកមួយយប់ ស្អែកព្រឹកចាំលាងចេញក៏បាន។
មិនតែប៉ុណ្ណោះនៅវដ្តវារ៉ា គេលាបម្សៅល្មៀតសុទ្ធ
ដើម្បីការពារភាពត្រជាក់បានខ្លះដែរ។ អ្នកលាបម្សៅ
ល្មៀតភាគច្រើនជាស្ត្រីក្រមុំ។ បើអ្នកមានផ្ដៃពោះ គេ
បុកពន្លៃដាក់ត្រាំក្នុងស្រាទុក៣-៤ខែ មុនឆ្ងន់ទន្លេ
ហើយពេលខ្លះគេលាយល្មៀតថែមបន្តិចផង។ នៅ
ពេលឆ្ងន់ទន្លេហើយ គេផ្សំថ្នាំខ្មែរ យកមកដាំឲ្យពុះ
ស្ពង់ខ្លួនពី៣ថ្ងៃទៅ១អាទិត្យ។ ពេលស្ពង់ហើយ គេងូត
ទឹក រួចទើបយកស្រាត្រាំពន្លៃលាយរមៀតនោះមក
លាបពេញខ្លួន ធ្វើឲ្យសាច់ឡើងម៉ដ្ត។

saffron powder, the skin of the saffron was scraped off and then the root was boiled with a little salt and white alum. When this mixture boiled, the water was poured out and the remaining saffron was sliced and spread to dry. When dry, the saffron was pounded into a fine powder. After the evening bath, when the young women had dried their bodies, they would take the saffron powder and rub it over their entire bodies. In the morning, they would wash it off. If someone was diligent and had the free time, this process was repeated two or three times a day.

If saffron powder was made for sale, they used small pieces of saffron root and mixed it with rice bran; no sour ingredients were added. If, however, saffron powder was made for one's own use, then the head of the saffron root was used since this was the most expensive part with the most strength. Mul, 84 years old living in Kompong Speu Province, told us that she never used saffron powder, but that her family grew saffron in order to make the powder and sell it. Her description of making saffron powder was similar to that of Ju Saroeun, noted above. After the root had been pounded into a fine powder, she sieved the powder through a cheesecloth and then wrapped it in packets for sale.

Some women bought saffron to put on their bodies, while others bought it to put

ក្រៅពីមេម្ដាយស្ទើតគេអាចប្រើសម្បកដើមព្រហូតដុសលាបស្បែកបានដែរ។ លោកយាយជួន ផល អាយុ៧០ឆ្នាំ រៀបរាប់ថា "ថែរក្សាសាច់គេលាបសម្បកព្រហូត។ ក្រមុំរៅផ្ទះជិតគ្នាតែពេលយប់ឡើងមកជុំគ្នារៅផ្ទះណាមួយអញ្ចឹងទៅ រួចយកសម្បកព្រហូតដុសនឹងអំបែងពាង ដោយមានលាយទឹក ឬស្រាបន្តិចា ពេលចេញកំទេចម៉ដ្ឋខាប់ហើយយកមកលាបខ្លួន។ ដោយសាររបៀបធ្វើយូរ ទើបចូលចិត្តលាបដោយមានគ្នាច្រើន ដើម្បីជួយគ្នាធ្វើនិងលាបឲ្យគ្នាទៅវិញទៅមក។ ពេលលាបហើយពាក់អាវដៃវែងនាំគ្នាទៅដេកផ្ទះរៀងៗខ្លួន។ ដល់ព្រលឹមឡើងងូតទឹកចេញ ឃើញសាច់ឡើងខ្ចី"។

អ្វីដែលបានរៀបរាប់ខាងលើ ជាវិធីថែរក្សាស្បែករបស់នារីខ្មែរមានតាំងពីយូរមកហើយ។ ប៉ុន្តែយើងមិនបានដឹងច្បាស់ថា វិធីនេះខ្មែរមានតាំងពី



រូបលេខ ៣១៥៖ សម្បកព្រហូត។ (រូបថត៖ រៃយ៉ំ)

Figure 315: The bark of the *prahoat* tree. (Photo: Reyum)

on their face. Others liked to add ginger, the sour fruit *krasaing*, or tamarind to the powder to make it thicker before applying it all over their bodies. Saffron powder was generally applied at night. When women woke in the morning, they washed it off. When covered with saffron powder, one could not walk in the sun since in the light, saffron can darken the skin. Those with rashes or blisters sometimes used saffron powder after bathing, mixing it with juice of the *kroach saouch* [a kind of lime or lemon] as a medicine. For itchy skin or scabies, saffron powder was mixed with lime and applied to the skin. For these skin remedies, the saffron powder was washed off as soon as it had dried, or was left on for one night and then washed off the next morning. In addition to these medicinal uses, saffron powder was rubbed on the body during the cold season because it was thought to protect against the cold.

Mostly it was young women who used saffron powder to care for their skin just before they married. Women who were pregnant took *panlai* [a kind of ginger] and pounded it, soaking it in alcohol for three to four months prior to giving birth. Sometimes they pounded a bit of saffron into the mixture as well. When a woman had given birth, those helping her would boil Khmer medicine and heat the body of the new mother for a period



រូបលេខ ៣១៦៖ សម្បកអំពិល។ (រូបថត៖ រៃយ៉ំ)

Figure 316: The bark of the tamarind tree.
(Photo: Reyum)

ពេលណាៗ ឬមួយគេមានគំនិតកែថ្លៃខ្លួនឯង ឬអាចទទួលឥទ្ធិពលពីណាក៏យើងមិនបានដឹង។ ជនជាតិកូឡាដែលរស់នៅប៉ៃលិន គេមានវិធីថែរក្សាស្បែករបស់គេប្រហាក់ប្រហែលនឹងជនជាតិខ្មែរដែរ។ ឧទាហរណ៍អ្នកមីងសៃអាយុ៥៧ឆ្នាំ ជាជនជាតិកូឡា សព្វថ្ងៃនៅស្រុកសំឡូតក្រុងប៉ៃលិន "ពាយ"រាប់ថា "មនុស្សប្រុសក៏គេធ្វើខ្លួនដែរ តែគេមិនមែនលាបម្សៅដូចយើងឥឡូវនេះទេ។ គេស្មៅសម្បកដើមអំពិលដាក់ហាលក្តៅហើយគេមានថ្មរលោងដូចត្បាល់អញ្ចឹង តែវាវាក់ គេយកសម្បកអំពិលទៅដុសនឹងត្បាល់នោះឯង រួចគេចាក់មេម្សៅគ្រាបចូល។ មេម្សៅគ្រាប់ដាក់កំប៉ុងដូចកំប៉ុងទឹកដោះគោដែរ គេញីចដាក់ក្នុងទឹកដែលបានពីដុសសម្បកអំពិលនោះ រួចហើយគេយកលាបសាច់លាបមុខ លាបបានទាំងថ្ងៃ ទាំងយប់។ លាបហើយស្មៅបសាច់ឡើងត្រជាក់ល្អក។ បើមិនអញ្ចឹងទេ គេបុក

of three days to a week. After this process was completed, the new mother was washed and then rubbed with the alcohol ginger-saffron mixture all over her body in order to make her skin smooth.

Other than saffron powder, the bark of the *prahoat* tree was used to scrub and rub on the skin. Juon Pol, 70 years old, told us "We used the bark of the *prahoat* tree to care for the skin. Young virgin girls in adjoining houses would always meet in the evening in one house or the other. They took pieces of bark from the *prahoat* tree and scraped them with broken bits of water jar, adding water or alcohol to the fibrous pulp. When bits of bark had been removed and the mixture was smooth and thick, they would apply it to their skin. Since it took a long time, they liked to do this together, helping each other apply it all over. When they had coated their skin, they would put their long sleeved shirts back on and go to sleep, each in their own house. In the morning they would wash the mixture off and you could see that their skin was fresh and new."

What we have described above are ways of taking care of the skin which Khmer women have traditionally followed since a long time ago. We don't know for sure when these ways of taking care of the skin were developed, or whether these methods are

ស្ងៀតឲ្យម៉ដ្ឋច្រោះឲ្យស្អាត ត្រង់យកទៅលាយជាមួយទឹកសម្បកអំពិល ហើយលាយមេរ៉ាលាបតែម្តង"។ ដូច្នេះយើងឃើញថាជនជាតិកូឡាប្រើមើម ឬសម្បកវុក្ខជាតិយកមកធ្វើជាគ្រឿងថែសាច់ដែរ។

បើគិតពីរបៀបប្រើមើមវុក្ខជាតិ ជារបៀបប្រពៃណីមួយ ទោះជាសព្វថ្ងៃមិនសូវប្រើ ដោយសារមានផលិតផលលក់ស្រាប់ក្នុងផ្សារ។ ម្យ៉ាងទៀតការថែទាំខ្លួនបែបប្រពៃណីនេះ ឲ្យតម្លៃខ្ពាំងក្នុងការថែរក្សាសុខភាពស្បែកច្រើនជាង។ ប្រហែលក្នុងសង្គមនោះគេនៅតែមានជំនឿច្រើនលើស្រីត្រប់លក្ខណ៍ មានអត្តចរិកល្អ ខុសប្រាហ៍ធ្វើការផ្ទះ។ ក្រៅពីពេលទៅបុណ្យ និងរៀបការ ស្ត្រីភាគច្រើនពុំមានបើកទូលាយឲ្យធ្វើខ្លួន ជាត់មុខមាត់ដូចនារីសម័យក្រោយឡើយ។

លាបបបូរមាត់

នៅមុនទសវត្សរ៍១៩៥០ ខ្មែរពុំសូវមានប្រភេទក្រែមលាបបបូរមាត់ដូចសព្វថ្ងៃឡើយ គេមានតែក្រដាសពុំធូបពណ៌ក្រហម ប្រើលាបបបូរមាត់។ ខ្មែរមិនមានពាក្យ"ក្រែម"នេះទេ គឺហៅតាមភាសាបារាំង " Créme " ខ្មែរមានតែពាក្យថា"ក្រមួនមាត់"។ នៅដើមសតវត្សទី២០ ស្ត្រីដែលរៀបការរួចគេទម្លាប់ពិសាស្លាមួដែលជាហេតុធ្វើឲ្យបបូរមាត់ក្រហម និងមានលាបក្រមួនមាត់ផង។ ចំពោះនារីក្មេងៗ ឬស្រីក្រមុំពេលមានពិធីបុណ្យ ពិសេសពេលរៀបការ តែងយកក្រដាសធូបមកបៀមឲ្យបបូរមាត់ក្រហម។ លោក

indigenous or were brought from abroad. The Kola, an ethnic group living in Pailin (along the border to Thailand) have very similar methods of skin care. For example, Ming Say, a 57 year old Kola woman living in Pailin, told us, "Men took care of their skin too, but they didn't use powder like we do today. They peeled off the bark of the tamarind tree and let it dry in the heat. They had a polished stone like a mortar and pestle but more shallow. They took the tamarind bark and rubbed it on this stone, adding lump face powder. The lump face powder came in cans like condensed milk cans. They would crush the clumps into the liquid fibers which they had rubbed from the tamarind bark. Then they would apply that mixture on their body and face. They did this both day and night. It made the skin feel cool. If they did not follow this method, then they would pound saffron to a fine powder, filtering and decanting it until it was clean and then mixing it with the liquid from the tamarind bark and adding crushed lump powder and using that on their skin." We can see then that the Kola used roots and bark to take care of their skin in very similar ways to the Khmer.

The use of roots and natural vegetation to make beauty and skin care products was a traditional habit which today has been superceded by the practice of buying readymade goods in stores. The traditional

ways of skin care seem to have focused on the health of the skin and the comfort of people. A certain deemphasis on beauty and the presentation of the self for others is confirmed in the traditional understanding that women were valued for their modest character and industriousness in house work, rather than for their visual appearance. A girl who was competent in all household and domestic matters was called a girl "with all characteristics." Other than for ceremonial gatherings or marriages, women traditionally did not make themselves up like women in later times, at least since the 1950s, have done.

Lipstick

Before the 1950s, there were not as many readymade lipsticks available as there are now, and the red paper wrapped around incense was generally used in order to color the lips. The word today used for lipstick in the Khmer language is the French word *créme*, indicating its foreign origin.

In the early 20th century, women who were already married generally chewed betel which turned their lips red. When they went to ceremonies or participated in special events, they would paint their lips with wax so that their lips would stick together and the betel juice would not run out of their mouth and stain their shirt or *sampot*. Younger unmarried women, when participating in

យាយច្រាក់ សេង អាយុ៧៥ឆ្នាំ នៅខេត្តកណ្តាល និយាយថា "ពេលការខ្ញុំអង្គុយផ្តិតបបូរមាត់នឹងក្រដាសធូបក្រហមា"។ លោកយាយជួន ផល អាយុ៧០ឆ្នាំ នៅភ្នំពេញ បានច្រាប់ថា "គ្មានក្រែមលាបដូចសម័យនេះទេ បើចង់លាបមានក្រដាសក្រែមក្រហមាយកមកជូតលើមាត់"។ លោកយាយគង់ គីម អាយុ៨៥ឆ្នាំ នៅខេត្តបាត់ដំបង ក៏បានបញ្ជាក់ថា "បើចង់ឲ្យបបូរមាត់ក្រហម ហែកក្រដាសក្រហមរុំធូបមកបិទលើបបូរមាត់ គឺលាបតែមួយពេលការហ្នឹងទេ រួចហើយមិនដែលចេះលាបអីឡើយ"។ លោកយាយ ណុក អាយុ៧៤ឆ្នាំ នៅខេត្តកណ្តាល និយាយថា "បើចង់លាបក្រែម យកក្រដាសធូបក្រហមដូចស័ក្តអញ្ចឹងយកមកបៀមទៅ ឡើងក្រហមចែសល្អណាស់"។ ប៉ុន្តែនៅតំបន់ខ្លះ ដូចជានៅស្រុកព្រៃកប្បាស ខេត្តតាកែវ គេមិនប្រើក្រដាសធូបក្រហមទេ គេយកជាតិហិង្គុលមកប្រើ ដូចលោកតាលី វ សាងម

រូបលេខ ៣១៧៖ ជាតិហិង្គុល។ (រូបថត៖ រៃយ៉ំ)

Figure 317: Vermilion. (Photo: Reyum)

ceremonies or getting married themselves, pressed incense paper to their lips in order to color them. Prak Seng, 75 years old living in Kandal Province, told us, "When I was preparing to get married, I sat and dabbed my lips with red incense paper." Juon Pol, 70 years old living in Phnom Penh, told us, "There was no lipstick like today. If you wanted to paint your lips, there was only red paper to wipe them with." According to Kong Kim, 85 years old living in Battambang Province, "If you want red lips, take the red paper wrapped around incense and stick it on your lips. I only did that once when I got married. After that I never did it again." Nok, 74 years old living in Kandal Province, told us, "If you wanted to paint your lips, you took the red incense paper that was like *leak* [a kind of natural red coloring] and held it pressed to your lips. They would become very red and beautiful." In some areas of the countryside, however, such as in the district of Prek Kabas, Takeo Province, they did not use this red paper. The late Liv Sa Aem, who was born in the area, told us that in his district they used vermilion to paint their lips. It was very red and stuck to the lips for a long time. According to the notes of Chou Ta-Kuan, the people of Chenla (an ancient Kingdom once flourishing in part of the area of present day Cambodia) used vermilion imported from China. Today, vermilion is

នៅស្រុកព្រៃកប្បាស បានបញ្ជាក់ថា នៅស្រុកគាត់ គេយកជាតិហិង្គុលលាបបបូរមាត់ ពណ៌ក្រហមា លាបជាប់បានយូរល្អណាស់។ បើតាមកំណត់ហេតុ លោកជីវតាខ្វាន់ថា "អ្នកស្រុកចេនឡាមានប្រើជាតិ ហិង្គុលនាំមកពីស្រុកចិន"។ សព្វថ្ងៃជាតិហិង្គុលនេះ មានលក់នៅហាង៥ំាចិនក្នុងក្រុងភ្នំពេញ ប្រើផ្សំធ្វើថ្នាំ ព្យាបាលជម្ងឺផ្សេងៗ មិនប្រើលាបបបូរមាត់ទៀតទេ។

ដូច្នេះនៅពេលមិនទាន់មានក្រែមប្រើ ស្ត្រី ខ្មែរភាគច្រើនប្រើក្រដាសធូប។ ការស្រាវជ្រាវនេះពុំ បានធ្វើលម្អិតគ្រប់តំបន់ ដូច្នេះក្រៅពីក្រដាសធូប និង ជាតិហិង្គុល យើងមិនបានដឹងថាមានអ្វីទៀតដែលនារី ខ្មែរធ្លាប់យកមកលាបបបូរមាត់ឡើយ។

របៀបគួរចិញ្ចើម

លោកយាយពៅ ហ្គិចឡាំង អាយុ៩០ឆ្នាំ នៅខេត្តកណ្តាល និយាយថា "កាលពីជំនាន់ខ្ញុំនៅ ក្មេងពេលរៀបការទើបគេគូរចិញ្ចើមឲ្យកូនក្រមុំ។ នៅ ស្រុកខ្ញុំ បើគេចង់គូរចិញ្ចើមឲ្យខ្មៅហើយកោងស្អាត គេយកស្លឹកត្នោតដុតកម្ទេចឲ្យខ្ចោចខ្មៅ រួចយកទៅ បុកឲ្យម៉ដ្ឋ ហើយយកដៃផ្តិតលាបលើចិញ្ចើមឲ្យទាល់ តែឡើងខ្មៅស្អាត ជានគេឈប់លាប"។ នេះជាវិធី មួយដែលចាស់ធ្លាប់ប្រើសម្រាប់គូរចិញ្ចើម ក្រៅពី នេះនៅតំបន់ផ្សេងទៀតមានរបៀបគូរចិញ្ចើមខុសពី ការនិយាយខាងលើ។ លោកតាលីវ សាឯម អាយុ ៦៨ឆ្នាំ បានប្រាប់ថា "ស្រុកពីដើម មានតែកូនក្រមុំ

ដែលត្រូវរៀបការទេ ទើបគេគោរ និងតូចិញ្ចើមឲ្យ គឺគេយកស្លឹកម្ទូដាក់រោលលើផ្សែងភ្លើងចង្កៀងប្រេងកាត រួចយកម្រែងភ្លើងដែលជាប់នឹងស្លឹកម្ទូនោះ ទៅកូរជាមួយក្រមួនលាបសក់បន្តិច ឲ្យខ្មៅសព្វហើយបានយកទៅជូត ឬលាបលើចិញ្ចើម។ បើអត់ចង្កៀងប្រេងកាតគេដុតចន្ទុះក៏បាន។ បើមិនអញ្ចឹងទេគេកាត់សក់យើងហ្នឹង (ឲ្យប៉ុនចិញ្ចើម) យកទៅបូតជាមួយក្រមួនឲ្យឡើងកោងស្អាត រួចយកមកបិទលើចិញ្ចើមតែម្តង។ បិទជាប់ជាមួយកោមចិញ្ចើមមិនងាយរបេះទេ"។

sold in traditional Chinese medicine shops in Phnom Penh. Used as an ingredient for various medicines, vermilion is no longer used to paint the lips red.

In general, before there were readymade lipsticks for sale in the stores, most Khmer women used incense paper to color their lips. Since our research is not comprehensive and does not cover all regions of Cambodia, we are not sure what other things Khmer women used to color the lips in addition to incense paper and vermilion.

ការលាបក្រចក

ការលំអក្រចកមានចំពោះតែនារីប៉ុណ្ណោះ តាមការចងចាំរបស់ចាស់ៗខ្លះបានឲ្យដឹងថា ស្ត្រីកាលពី៨០-៩០ឆ្នាំមុន ចេះលាបលំអលើក្រចកពេលដែលខ្លួនត្រូវរៀបការ ឬទៅបុណ្យទាន។ តែក្នុងសម័យនោះគេនិយមហៅថា"បន្ទុំក្រចក"។ លោកតា ទៀង ស៊ូ អាយុ៧៦ឆ្នាំ នៅខេត្តតាកែវ និយាយថា "បើចង់លាបក្រចក គេបន្ទុំដើមកំភែម គឺយកស្លឹកកំភែមមកវ៉ៃឲ្យម៉ដ្ឋ ហើយយកទៅដាក់លើក្រចក រួចយកស្លឹកចេក ឬក្រណាត់មកពុំពីលើទុកមួយយប់ ស្អែកឡើងក្រហមព្រឿងៗ ជាប់បានយូរណាស់"។ ឯលោកយាយស៊ីម សារិន អាយុ៧៦ឆ្នាំ នៅខេត្តស្វាយរៀង ប្រាប់ថា "ពីដើមអត់មានថ្នាំលាបក្រចក គេយកស្លឹកកំភែមច្របាច់ឲ្យម៉ដ្ឋ លាយជាមួយកំបោរ ហើយយកមកដាក់លើក្រចក រួចបន្ទុំមួយយប់ឲ្យក្រចក

Outlining the eyebrows

Pou Kech Lang, 96 years old living in Kandal Province, told us, "When I was young, it was only brides who would outline their eyebrows for their wedding. In my district, if they wanted their eyebrows to look blacker and be more beautifully curved, they took palm fronds and roasted them until they were scorched. They pounded the charred fronds into a fine powder which they dabbed onto their fingers and used to outline their eyebrows until they became black and beautiful." This was one traditional method by which eyebrows were outlined. Other regions had different ways of outlining the eyebrows. The late Liv Sa Aem told us, "Earlier in the countryside, it was only the virgins getting married who shaved their eyebrows and then drew them on again. They

ឡើងក្រហម"។ ការយកស្លឹកកំតេមមកបន្ទុំក្រចកមិនត្រឹមតែធ្វើឲ្យក្រចកក្រហមព្រឿងៗនោះទេ ថែមទាំងធ្វើឲ្យក្រចករឹងទៀតផង។ ក្រៅពីស្លឹកកំតេម គេបន្ទុំក្រចកដោយប្រើគ្រាប់ជម្ពូស្រស់។ លោកតាលី វ សាឯម អាយុ៦៧ឆ្នាំ បាននិយាយថា "គេបន្ទុំក្រចក ដោយបេះគ្រាប់ជម្ពូច្រចាច់លាបលើក្រចក។ បើគេចង់លាបក្រហមខ្លី គេបេះផ្លែនៅខ្ចី បើពណ៌ក្រាលគេបេះផ្លែជិតទុំ។ ហើយស្រុកពីដើមអត់ហៅលាបទេ គេហៅ

រូបលេខ ៣១៨៖ ដើមកំតេម។ (រូបថត៖ រៃយ៉ំ)

Figure 318: The *kompain* tree. (Photo: Reyum)

រូបលេខ ៣១៩៖ ផ្លែជម្ពូ។ (រូបថត៖ រៃយ៉ំ)

Figure 319: The *jumpuh* fruit. (Photo: Reyum)

took betel leaves and roasted them in the smoke of a kerosene lamp. They took the ash from those leaves and mixed it with a little hair wax so that it was really black. Then they wiped or painted that on as eyebrows. If there was no kerosene lamp to use, they used a torch instead to smoke the leaves. If neither of these two ways was used, then they would sometimes cut a length of the hair of the bride, the length of the desired eyebrow shape, smooth it with wax until it was beautifully curved, and then stick it to the eyebrow. It really stuck to the natural eyebrow hairs and was difficult to take off."

Painting the nails

In the past, only Khmer women painted their nails. According to our elderly interviewees, 80 to 90 years ago, women were painting their nails only for special occasions such as their wedding or for ceremonies. In those times, they called the coloring of the nails, reddening or ripening the nails.

Dieng Su, 76 years old living in Takeo Province, told us, "To color your nails, ripened them with the *kompain* tree, taking its leaves and crumbling them into a fine powder. This powder is put on the nails and then the nails are wrapped in banana leaves or cloth for one night. The next day, your nails will be really red and this color will last for a long time." Sim Saren, 76 years old living in

រូបលេខ ៣២០៖ ដើមជម្ពូ។ (រូបថត៖ រៃយ៉ំ)

Figure 320: The *jumpuh* tree. (Photo: Reyum)

បន្ទុំក្រចក"។ លោកយាយកែ រឿង អាយុ៧៣ឆ្នាំ នៅខេត្តកណ្តាល ប្រាប់ថា "បើអ្នកណាលាបថ្នាំក្រចក សុទ្ធតែស្រីមិនល្អ ពីដើមគេមិនចេះតែលាបទេ ពេលមានវេលាការ ឬបុណ្យប៉ានគេលាប"។ បើតាមសំដីលោកយាយបញ្ជាក់ថា ពេលនោះមានថ្នាំក្រចកហើយ គឺប្រហែលសម័យសង្គមរាស្ត្រនិយម។

ចំពោះការថែសម្អាតក្រចក គឺពុំមានកន្ត្រៃសម្រាប់កាត់ក្រចកប្រគេនដូចសព្វថ្ងៃនេះទេ។ អ្នកនៅស្រុកស្រែចម្ការគេច្រើនប្រើកន្ត្រៃកាត់ខោអាវ ឬខាំហ្មឹងធ្មេញតែម្តង។ ឯអ្នកនៅភ្នំពេញភាគច្រើនគេមានកន្ត្រៃម្យ៉ាងស្រដៀងកន្ត្រៃកាត់សក់ដើម្បីកាត់ក្រចក។ បើគេចង់សម្អាតក្រចកគេប្រើផ្លែក្រូចឆ្មារដុស។ យើង

Svay Rieng Province, told us, "In earlier times, there was no nail polish. They took *kompain* leaves and crushed them, mixing them with lime. They put this mixture on the finger nails, wrapping them up for one night to redden the nails. Applying *kompain* leaves to the nails not only reddened them but made the nails harder as well.

In addition to the leaves of the *kompain* tree, they also could redden the fingernails using the seeds of the *jumpuh* fruit. The late Liv Sa Aem told us, "They reddened the nails by picking the *jumpuh* fruit, crushing them, and applying them to the nails. For a light red nail color, they used the unripe fruit. For a deeper red nail color, they used the almost ripe fruit. Earlier, in the countryside, they didn't call it painting or polishing the nails. Instead they called it to redden or ripen the nails." Kai Rueng, 73 years old living in Kandal Province, told us, "Only those considered to be bad women painted their fingernails. Before, women didn't paint their nails unless they were getting married or going to special ceremonies." Kai Rueng remembers that there was already manufactured nail polish available during the Sangkum Reastr Niyum, but we are not sure of the exact date when manufactured nail polishes first began to be imported into Cambodia. In earlier times, nail clippers such as those used today were not

ចានដីឥដ្ឋទៀតថានៅដើមសតវត្សទី២០ក៏គេនិយមទុកក្រចកវែងៗដែរ ជាពិសេសត្រួសារអ្នកមានជួរធារ។

ការថែធ្មាំធ្មេញ

បើមើលការផ្សាយពាណិជ្ជកម្មថ្នាំដុសធ្មេញនោះ គេសរសើរថាថ្នាំដុសធ្មេញសស្អាតល្អ។ តែតាមចាស់ៗនិយាយ ពីមុនគេនិយមធ្មេញខ្មៅទៅវិញ។ គេយល់ថាស្ត្រីដែលមានធ្មេញខ្មៅ ជាស្ត្រីដែលស្រស់ស្អាត ស្ត្រីមានធ្មេញសមើលទៅស្អុកស្អាំង។ តាមយើងស្មានធ្មេញខ្មៅបណ្តាលមកពីស៊ីម្ចូ។

ខ្មែរមានទំនៀមហូបម្ចូ តាំងពីយូរយារមកហើយ ដោយបន្តជាប់មកទល់សព្វថ្ងៃ យើងឃើញមាននៅសល់អ្នកហូបម្ចូ ភាគច្រើនជាមនុស្សស្រីចំណាស់អាយុជាង៥០ឆ្នាំឡើង ចំណែកមនុស្សប្រុសដែលហូបម្ចូមានតិចតួចបំផុត។ ខ្មែរមានទម្លាប់យកម្ចូស្ងោសម្រាប់ទទួលភ្ញៀវ និងជាការគួរសមដំបូងបំផុតរបស់ម្ចាស់ផ្ទះជាមួយភ្ញៀវ។ ការហូបម្ចូច្រើនធ្វើឲ្យជាតិជ័រនៃស្លឹកម្ចូ ផ្អែស្ងោ និងកំបោរកាន់ជាប់ធ្មេញឡើងខ្មៅ និងធ្វើឲ្យបបូរមាត់ពណ៌ក្រហមទៀតផង។ នៅស្រុកខ្មែរស្ត្រីភាគច្រើនហូបម្ចូ និងមានបុរសមួយចំនួនប៉ុណ្ណោះដែលចូលចិត្តហូប។ ការទម្លាប់ហូបម្ចូនេះយើងពុំដឹងថា ចាប់មានតាំងពីពេលណានោះឡើយ។ ស្ត្រីដែលហូបម្ចូភាគច្រើនជាស្ត្រីដែលបានរៀបការរួចមានន័យថា ស្ត្រីដែលមានធ្មេញខ្មៅភាគច្រើនក៏ជាស្ត្រីមានប្តីហើយដែរ។ លោកយាយចែង សួន អាយុ

yet available. People in the countryside either used regular scissors to cut their nails, or bit their nails to keep them short. In Phnom Penh, there were nail scissors similar to small regular scissors that began to be used. Nails were cleaned by rubbing them with lemon halves. We know that in the early 20th century, rich people kept their nails long, probably as a sign that they no longer had to work with their hands.

Teeth

If one considers toothpaste advertising today, almost all advertisements emphasize white teeth. According to our elderly interviewees however, more than one hundred years ago, people liked black teeth more. Women with black teeth were considered beautiful, while women with white teeth were thought to be deathly pale. We can see therefore that notions of beauty change from generation to generation.

The black teeth which Khmer were used to having more than one hundred years ago, came from chewing betel. Khmer people had a longstanding habit of chewing betel, and they continue to do so today, although most of the people who still chew betel are elderly women over the age of fifty. Only a few men still chew betel today. In the past, offering betel to visitors was considered to be the polite way to receive guests. If one chews

៧៩ឆ្នាំ នៅខេត្តបាត់ដំបង ប្រាប់ថា"ពេលខ្ញុំរៀបការ
ហើយ ម៉ែប្រាប់ឲ្យខ្ញុំហូបម្ទូមួយម៉ាត់ទៅកុំឲ្យធុំមាត់"។
ពេលហូបរួចគេតែងយកសម្បកស្វាមកដុសធ្មេញជា
ច្រើនសារធ្វើឲ្យធ្មេញរលោងភ្លឺ។ អ្នកហូបម្ទូស្ទើរតែ
លែងខ្វល់ពីការដុសសម្អាតធ្មេញ ព្រោះហូបម្ទូអាច
កំចាត់ការធុំក្លិនមាត់បាន។ លោកយាយមុម សំអឿន
អាយុ៧៧ឆ្នាំ និយាយថា "ពីដើមស្ត្រីខ្មែរធ្មេញស
គ្មានទេ សុទ្ធតែធ្មេញខ្មៅទាំងអស់ ហើយហូបម្ទូធ្វើឲ្យ
ធ្មេញមាំ ព្រោះកំបោរកាន់ធ្មេញជាប់ណាស់"។ អ្នក
ខ្លះចង់ឲ្យធ្មេញខ្លួនកាន់តែខ្មៅរលោងឆាប់គេយកសាច់

រូបលេខ ៣២១៖ លោកយាយគុជ ឡុង អាយុ៩០ឆ្នាំ នៅខេត្ត
កណ្តាល។ ថតឆ្នាំ២០០៣។ (រូបថត៖ រៃយ៉ំ)

Figure 321: Koch Long, 90 years old living in Kandal Province. Photographed 2003. (Photo: Reyum)

betel regularly over a long period of time, the acid of the betel leaves, the areca palm, and the lime sticks to the teeth and turns them black. The lips of the betel chewer gradually turn red as well.

We do not know when the habit of chewing betel began in the region today known as Cambodia. Most of the women who chewed betel were already married so that most women with black teeth already had a husband. Jaing Suon, 79 years old living in Battambang Province, told us, "When I had already married, my mother told me to chew betel so that my breath would be fresh." When women finished chewing betel, they were accustomed to taking the peel of the areca palm and pushing it along their teeth many times to make their teeth shiny. Women who chewed betel generally did not use anything else to clean their teeth since chewing betel eliminated bad breath. Mom Samuen, 77 years old, told us, "Earlier, no Khmer woman had white teeth. They all had black teeth. Chewing betel made the teeth strong because the lime stuck to the teeth." Some people who wanted to have even blacker and shinier teeth quickly would crush copper sulfate to a powder, mix it with a little water, and then brush it onto the teeth. In those days, if a woman was married and still had white teeth, she would be criticized. Beginning in the 1950s, however, those who

ជូរខៀវបុកឲ្យម៉ដ្ឋហើយលាយទឹកបន្តិច រួចយកមកដុសរលើធ្មេញ។ ក្នុងជំនាន់នោះស្ត្រីណាដែលមានប្តីហើយនៅមានធ្មេញសច្បាស់ជាមានគេរិះគន់ពុំខាន។ ក្រោយមកចាប់ពីទសវត្ស១៩៥០ អ្នកដែលបានចូលរៀន និងចូលធ្វើការងារជាការកាន់តែច្រើន ពួកគេច្រើនទុកធ្មេញស និងចោះបង់ទម្លាប់ហូបម្ទេដែលធ្វើឲ្យធ្មេញខ្មៅ ដោយគេយល់ថា អ្នកមានធ្មេញខ្មៅជាមនុស្សចូលមិនចុះក្នុងសង្គមទាន់សម័យ។

បើនិយាយពីវិធីរក្សា និងសម្អាតធ្មេញវិញគឺមុនប្រើថ្នាំដុសធ្មេញដូចសព្វថ្ងៃ គឺគេប្រើផេះ ធ្យូង អំបិល និងខ្សាច់ម៉ដ្ឋ មកដុសសម្អាតធ្មេញ ដោយប្រើម្រាមដៃដុស។ លោកតាជុំ កេន អាយុ៨៣ឆ្នាំ នៅខេត្តព្រៃវែង និយាយថា "ខ្ញុំប្រើតែម្រាមដៃទទេដុសធ្មេញ ពេលខ្ពុរទឹកយកម្រាមដៃដុសសង្កត់ត្រង់អញ្ចាញ និងគល់ថ្ពាមឲ្យខ្លាំងៗ វាធ្វើឲ្យធ្មេញតាប់ជាប់គ្នាឡើងណែន។ ពេលណាឈឺធ្មេញតិចៗដុសអញ្ចឹងតែ២-៣ដង ជាត់ឈឺធ្មេញដែរ"។ ពេលឈឺធ្មេញខ្លាំង អ្នកខ្លះយកអំបិលញាត់ចំកន្លែងដែលឈឺនោះ។ អ្នកខ្លះទៀតដំមើមខ្ទឹមញាត់ ឬបុកស្លឹកម្រះក្រៅញាត់ក៏បាន។ ក្រៅពីនេះមានអ្នកខ្លះយកដើមស្វាយទៅស្ងោរលាយជាមួយអំបិល គឺស្ងោរទឹក៣យកទឹក១ (ទឹក៣ផ្តិល គេស្ងោរឲ្យរីងសល់តែទឹក១ផ្តិល) រួចយកមកបៀមរហូតដល់ជាត់ឈឺធ្មេញ ទើបគេឈប់បៀម។ បើកើតជម្ងឺឈាមធ្មេញ អ្នកនៅស្រុកស្រែភាគច្រើនប្រើជ័រស្វាយលាបតាមជើងធ្មេញ។

went to school and began to work as civil servants stopped chewing betel and left their teeth white. Betel chewing caused the mouth to salivate and the resulting spitting and staining in public places began to be considered disorderly at this time. Particularly in urban areas, betel chewing came to be considered primitive and unfashionable.

Those who did not chew betel (young girls and most men) used various methods to clean and care for their teeth. Prior to the time that readymade toothpaste and toothbrushes were available, they generally used ash, charcoal, salt, or fine sand, rubbed on the teeth with a finger. The late Jum Kain told us, "I just used my bare fingers to brush my teeth. When I gargled water, I would take my fingers and rub them along the gums and teeth, pressing hard. That made the teeth stick together tightly. Whenever I had a little tooth pain, I would brush my teeth like that three or four times and the pain went away." For bad toothaches, most people would put salt on the spot that hurt. Others pounded onions and applied them to the painful spot. *Mich pou*, or sweet basil, was also sometimes pounded and applied to sore teeth. Another remedy for tooth pain was to boil the wood of the *smay* tree with salt, reducing the mixture by two thirds before use. The resulting reduced liquid was held in the mouth until the pain

ក្រវិលដិនកដ

អលង្ការជាគ្រឿងសម្រាប់លំអខ្លួនផង និងបញ្ជាក់ពីធនធានរបស់មនុស្សផង។ គ្រឿងអលង្ការមានដូចជាក្រវិល, ខ្សែក, កងដៃ, កងជើង, ខ្សែធ្វើងជាដើម។ បច្ចុប្បន្នមានអ្នកខ្លះយល់ថាការពាក់មាសពេជ្រ ជាការលើកកាសី។ មនុស្សស្រីភាគច្រើនចាត់ទុកគ្រឿងអលង្ការជាវត្ថុដ៏សំខាន់ តែចំពោះមនុស្សប្រុសមិនសូវពាក់ច្រើនដូចមនុស្សស្រីឡើយ។

ពីមុនគ្រឿងអលង្ការច្រើនធ្វើពីមាស ប្រាក់ និងទង់ហ្វា។[19] ម្យ៉ាងមិនសូវមានម៉ូតច្រើនដូចសព្វថ្ងៃដែរ។ ម៉ូតក្រវិលមាន ការវទង់ត្រង់ ការតម្ពក់ ទំហ្វិ ជាដើម។ ការវទង់ត្រង់ គេមានត្បូងមួយគ្រាប់ ឬធ្វើពីមាសសុទ្ធ ទង់ធំវែង ហើយត្រង់ចុងនៅកណ្តាលនិងរាងស្តួចនៅខាងចុង។ ទង់ការនោះធំ ដូច្នេះមុនពាក់ គេយកគល់ខ្ទឹមស មកសិតត្រង់រន្ធត្រចៀកដែលចោះនោះ។ គល់ខ្ទឹមសកាលណាត្រូវទឹកយូរទៅវីតធំធ្វើឲ្យរន្ធត្រចៀកមានប្រហោងកាន់តែធំដែរ។ មើលតែឈ្មួមអាចសិកទង់ការចូលបានហើយ ទើបគេដកទង់ខ្ទឹមចេញ ហើយយកការមកពាក់។ ទង់ការនោះគេធ្វើឲ្យមានប្រហោងក្នុង មិនសូវធ្វើតាន់ទេ ព្រោះបើធ្វើតាន់វាធ្ងន់ ពាក់យូរទៅនឹងដាច់ស្តើកត្រចៀក។ អ្នក

[19] ទង់ហ្វាមានតម្លៃថោកជាងមាស។ នៅចុងសតវត្សទី១៩ ដើមសតវត្សទី២០ អ្នកក្រនិយមប្រើទង់ហ្វានេះណាស់។ តែមកដល់សព្វថ្ងៃមិនឃើញមានប្រើទេ។

disappeared. For bleeding gums, people in the countryside applied the resin of the *smay* tree.

Earrings and Bracelets

Traditionally, jewelry was worn both to decorate the self and to display wealth. Types of jewelry included earrings, necklaces, bracelets, ankle bracelets, and decorative chains worn across the chest. Today, some people believe that by wearing gold and diamonds, they will be lucky. In earlier times, most Khmer jewelry was made from gold, silver, or various copper alloys.[12] There were not as many different styles of jewelry as are found today.

Traditionally, types of Khmer earrings included the *kao dong trong*, the *kao tompok*, and the *domhu*. The *kao dong trong* had a rounded front either inset with a stone or made from solid gold. This front was attached to a cylinder which bulged slightly in the middle and was pointed at the back end. The cylinder, which was quite thick, was inserted into the ear hole. In order to be able to insert the *kao dong trong*, pieces of garlic were inserted into the hole of the ear first. The stalk of garlic expanded when it came into contact with water, and thus the inserted garlic would gradually widen the ear hole

12 Copper alloys were cheaper than gold, and were used by poorer people to make jewelry during the early 20th century.

ពាក់ការទង់ត្រង់ច្រើនមានប្រហោងត្រចៀកធំ។ ការតម្ពក់ មើលពីខាងមុខមានរូបរាងដូចការទង់ត្រង់ដែរតែខុសគ្នាត្រង់ទង់សម្រាប់សឹកត្រចៀក ទង់វាខ្លីជាងតម្ពក់។ ការទង់ត្រង់ និងការតម្ពក់ សព្វថ្ងៃច្រើនអ្នកនៅកម្ពុជាក្រោម និងអ្នកស្រុកខ្មែរនៅមានពាក់។ ទំហូ គឺមានដាំត្បូង ឬពេជ្រធំមួយគ្រាប់នៅកណ្តាល និងមានឡោមត្បូងតូចជុំវិញ ហើយទង់គេធ្វើដោយមានមួលខ្លៅ ដើម្បីដាក់សន្ទះមួយ។ ទំហូនេះគេដាំត្បូង និងរចនាតាមការនិយមរបស់គេ ច្រើនអ្នកមាន និងអ្នកដែលនៅទីក្រុងពាក់។ ក្រោយមកប្រហែលទសវត្ស១៩៥០ អ្នកខ្លះបានច្នៃការដោយមានដាំត្បូងរាងកញ្ចុំតាមទំហូដែរ ចំណែកទង់នៅរក្សាទ្រង់ទ្រាយដដែលហើយគេនៅតែហៅថា ការដដែល។

នៅមុនទសវត្ស១៩៥០ ការចោះត្រចៀកអ្នកខ្លះយកម្ជុលដេរ ខ្លះយកម្ជុលសម្រាប់ចាក់ថ្នាំមកចោះ (អ្នកទីក្រុង)។ ម្ជុលនោះមុននឹងយកមកចោះត្រចៀកគេតែងតែដុតចុងវាជាមុនសិន ដើម្បីឲ្យងាប់មេរោគ។ តាមលោកយាយមុម សំអឿន អាយុ៧៦ឆ្នាំ និយាយថា "គេចោះត្រចៀកនៅពេលកើតមក ខ្លះដោតលួស (ដែលមិនច្រែះ) ខ្លះដោតអំបោះ ខ្លះទៀតយកក្រវិលពុកបង្គងមកពាក់តែម្តង។ ការចោះត្រចៀកគេធ្វើនៅពេលបង្កក់ឆ្មប គឺគេឲ្យឆ្មបចោះឲ្យ។ តែបើបងខ្ញុំប្រហែលពេលគាត់ចេះអង្គុយ ទើបចោះត្រចៀក។ គេយកម្ជុលមកចោះដោយយកខ្ទឹមកន្ទាប់ខាងក្រោយ ឬលាបប្រេងកូឡា ដើម្បីកុំឲ្យមានដំបៅ

sufficiently to insert the *kao dong trong* earring. The *kao dong trong* earrings were generally hollow so that they were not too heavy and would not rip the ear hole with extended wearing. Those who wore the *kao dong trong* style earrings generally had large open ear holes.

The *kao tompok* earring, or the hook earring, looked the same as the *kao dong trong* earring from the front with a simple round gold circle. However, instead of a straight cylinder going back, the *kao tompok* earring was hooked or curved into a circle. These two types of earrings are still worn today by people living in the countryside of Cambodia, and in Kampuchea Krom (southern Vietnam).

The front of the *domhu* earring had a central stone or diamond, surrounded by a circle of smaller stones or diamonds attached to a simple straight stem. A back was screwed onto the end of this stem to hold the earring in the ear. The design of the central stone and its surrounding stones depended on the taste of the wearer. Generally only rich people and urban dwellers could afford to wear this type of earring. In the 1950s, the *kao dong trong* earring began to be adapted to have a front like the *domhu*, with an inset stone surrounded by small stones or a simple cluster of little stones. The bulging cylinder back stayed the same and these types of earrings were still called *kao dong trong* earrings.

រូបលេខ ៣២២៖ អ្នកស្រុកនៅខេត្តកំពង់ស្ពឺ មានពាក់កាវខងត្រង់ធ្វើអំពីមាស។ ថតឆ្នាំ២០០៣។ (រូបថត៖ ឈៃ)

Figure 322: A villager in Kompong Speu Province, wearing *kao dong trong* earrings made of gold. Photographed 2003. (Photo: Reyum)



រូបលេខ ៣២៣៖ កាវតម្ពក់។ (រូបថត៖ ឈៃ)

Figure 323: *Kao tompok* earrings. (Photo: Reyum)

ឬហើម។ គេត្រូវចោះឲ្យចំក្រយៅចាក់ស៊ីកអំបោះតែម្តង។ ខ្ញុំពីក្មេងមិនពាក់រយ៉ាទេ ពាក់ក្រវិលមូល (ក្រវិលពុកបង្គង)។ ដល់ក្រមុំទើបពាក់ទំហួ មានដាំត្បូងទាំងគ្រាប់ ឬពេជ្រចំហៀងធំមួយកណ្តាលហើយទ្បាមជុំវិញ។ ឆ្នាំ១៩៣៤–៣៥ គេពាក់គ្លិប (clip) ភាងដូចទំហួដែរ តែមិនចោះធ្វើទងទេ គេដាក់កិប។ ខ្លះ

Before the 1990s, some people pierced ears using sewing needles, while others (generally living in the cities) pierced their ears using needles for injecting medicine. Before using these types of needles, the end of the needle was heated to sterilize it. According to Mom Samuen, 76 years old, "They pierced the ears when you were born. Some inserted wire that was not rusty into the hole, while others inserted cotton thread. Still others immediately inserted a small ring earring. Piercing ears was often done during the ceremony for naming the baby and giving gifts to the midwife who had delivered the baby. The midwife was the one who pierced the ears. My older sister, however, only had her ears pierced when she knew how to sit up already. They used a needle to pierce her ears, holding a piece of ginger behind the ear. They used tiger balm so that there would not be an infection or swelling. They pierced the ear in the middle of the lobe, and then inserted cotton thread to keep the hole open. When I was little, I never wore dangling earrings. I wore small ring earrings. When I reached puberty, then I wore *domhu* studded with little stones or with a diamond in the middle surrounded by other stones. In 1934 or 1935, they started to have an earring like the *domhu* which did not require ear piercing because it had a clip to hold the earring to the ear. Some wore earrings like that with clusters of stones

គេដាំត្បូងដូចជាទំហំដៃរតាមដែលគេស្រឡាញ់"។ ចំណែកលោកយាយភី អាយុ៨៣ឆ្នាំ នៅខេត្តកណ្តាល ក៏បាននិយាយដែរថា "ខ្ញុំនៅពីក្មេងពេលនៅផ្ទះពាក់តែក្រវិលពុកបង្គន់ ដល់ពេលមានបុណ្យពាក់ទំហូត្បូងកញ្ចុំ ដាក់ពេជ្រចំហៀង រីឯការមានតែមនុស្សចាស់ទេដែលពាក់។ ហើយមានពាក់កងអង្កាំ៣ជុំម្ខាងផង"។ តាមការសម្ភាសន៍ចាប់ពីចុងសតវត្សទី១៩ ជាទូទៅមនុស្សប្រុសមិននិយមចោះត្រចៀកទេ មានតែមនុស្សស្រីប៉ុណ្ណោះ។ ការចោះត្រចៀកជាទម្លាប់មួយសម្រាប់មនុស្សស្រី ព្រោះបញ្ជាក់ពីភេទ និងជួយលើកសម្រស់នារីឲ្យកាន់តែស្អាតមួយកម្រិតទៀត។

បើក្មេងប្រុសចោះត្រចៀកមួយចំហៀងគេមានជំនឿថា ក្មេងនោះមានពងកោប ឬទក (គឺតូចមួយចំហៀង ធំមួយចំហៀង) គេចោះត្រចៀកពាក់ក្រវិលមួយចំហៀងខាងកោបនោះ ដើម្បីឲ្យវាជម្ងឺតាវិញ។ អ្នកខ្លះទៀតមានជំនឿថា បើមានកូនកើតមកចេះតែស្លាប់ ឬអារ៉ែ ពេលដែលកូនកើតមកលើកក្រោយនឹងចោះត្រចៀកឲ្យ ដើម្បីកុំឲ្យអារ៉ែទៀត។

បច្ចុប្បន្នការចោះត្រចៀកនៅស្រុកស្រែចម្ការនៅតែមានធ្វើតាមរបៀបបុរាណ ការចោះត្រចៀកបែបនេះ នៅសម័យមុនគេមិនយកលុយទេ។ នៅទសវត្ស១៩៨០ នៅភ្នំពេញនៅមានមនុស្សស្រីវ័យចំណាស់ខ្លះ ប្រកបរបរដើរចោះត្រចៀកនៅតាមផ្ទះ។ មកដល់ទសវត្ស១៩៩០ អ្នកប្រកបរបរបែបនេះលែងសូវមានហើយ។ ក្មេងខ្លះកើតមកឲ្យពេទ្យចោះឲ្យ។

like the *domhu*." Phi, 83 years old living in Kandal Province, told us, "When I was little, at home I only wore small ring earrings. For ceremonies, I wore *domhu* earrings with clusters of stones and diamonds. It was only elderly women who wore *kao dong trong* earrings. I also wore a bead bracelet wrapped around each wrist three times." According to our elderly interviewees, men generally did not pierce their ears at the end of the 19th century. Only women pierced their ears at that time in order to increase their beauty.

Some beliefs did cause baby boys to have their ears pierced however. If a baby boy had uneven sized testicles, an earring was put in the ear on the side of the smaller testicle. This was believed to make the testicle grow into the appropriate size. Some people believed that if one had a still-born baby, or a baby that died soon after birth, the next child whether it was a boy or a girl should immediately have its ears pierced so that it would live.

Today, in the countryside, ears are still often pierced using traditional methods. In the old days, piercing ears was not commercialized and no money was exchanged for ear piercing. In the 1980s in Phnom Penh, however, some elderly women began to make a business of going from house to house and piercing ears for money. These walking piercers disappeared in the 1990s as people

ម្យ៉ាងទៀតអ្នកខ្លះដែលមិនបានចោះត្រចៀកកាលនៅតូច គេមានរបៀបចោះដោយមិនធ្វើឲ្យឈឺចាប់ គឺគេប្រើឧបករណ៍ម្យ៉ាងសម្រាប់បាញ់ ដោយតួរសញ្ញាមួយនៅលើត្រចៀកចំកន្លែងត្រូវចោះ។ នៅលើឧបករណ៍គេមានដាក់ក្រវិលរួចស្រេច ហើយគេបាញ់ក្រវិលដោតចូលជាប់ត្រចៀកស្រេចតែម្តង។ ដូច្នេះសព្វថ្ងៃមាននារីខ្លះទៀតចោះត្រចៀកច្រើនកន្លែងដោយពាក់ក្រវិលបន្តគ្នា។ មនុស្សប្រុសខ្លះក៏ចោះត្រចៀកពាក់ដែរ។ អ្នកទាំងនេះភាគច្រើនជាអ្នកលេងខ្លួន និងចង់ឲ្យស្អាតសង្ហាប្លែកពីអ្នកដទៃ និងទាន់សម័យ។

ក្រៅពីពាក់ក្រវិល ក្មេងស្រីទាំងនៅទីក្រុង និងស្រុកស្រែ និយមពាក់កងនៅជើងទាំងសងខាង គេហៅថាកងជើង។ អ្នកខ្លះពាក់រហូតដល់រៀបការហើយទើបឈប់ ខ្លះពាក់រហូតដល់ចាស់ក៏មាន។ កូនអ្នកមានពាក់កងជើងធ្វើពីមាស កូនអ្នកមធ្យមពាក់កងធ្វើពីប្រាក់ កូនអ្នកក្រពាក់កងធ្វើពីទង់ហ្វា។ ជួលកាលពាក់តែមួយជាន់ ជួនកាលពាក់ច្រើនជាន់ទៅតាមការនិយម និងធនធានដែលគេមាន។ ការពាក់កងជើងអ្នកស្រុកទន្លេមិនសូវនិយមពាក់ទេ។ ចំពោះកងដៃ គេពាក់ម៉ូតដូចកងជើងដែរ ខ្លះគេធ្វើក្បាច់ផ្សេងដូចជា ក្បាច់កងឈ្លីង ក្បាច់នាគជាដើម។ ឯខ្សែដៃមុនដំបូងមានតែអ្នកទីក្រុងពាក់។ ក្រៅពីនេះមានអ្នកខ្លះពាក់ខ្សែកខ្លះពាក់ខ្សែធៀងមួយខ្សែ ឬពីខ្សែតាមទម្លាប់របស់គេ។ សព្វថ្ងៃកងជើង និងខ្សែពាក់ធៀង លែងឃើញមានពាក់ហើយ លើកលែងតែពេលរៀបការ។

increasingly relied on doctors and medical clinics to pierce their ears. Older girls who did not have their ears pierced when they were little began to make use of new relatively painless ways of piercing the ears with tools that shoot the earring directly into the ear as it is pierced. Some women today pierce their ears in several places in order to be able to wear more earrings. Young men have also started to pierce their ears these days. Those who do so are generally fashion conscious and wish to look different from everyone else.

In addition to wearing earrings and bracelets, young girls in the city and the countryside traditionally wore bracelets on both their ankles. Some wore these ankle bracelets until they married, while other women wore them until they were old. Girls with rich parents wore gold ankle bracelets, while girls of middle class parents wore silver ankle bracelets. Poor girls generally wore ankle bracelets made of copper alloys and brass. Some girls wore single ankle bracelets while others wore several on each ankle, depending on their taste as well as on their family resources. Wearing ankle bracelets was less popular among those living along the rivers. Wrist bracelets were generally the same style as ankle bracelets (figure 324), with inscribed ornamental patterns as well as decorative endings such as a serpent head and tail. Chain bracelets were first worn by city dwellers, as

រូបលេខ ៣២៤៖ កងជើងមានក្បាច់។ (រូបថត៖ រៃយ៉ំ)

Figure 324: Ankle bracelets with ornamental patterning or *kbach*. (Photo: Reyum)

ដូច្នេះរាល់វិធីតុបតែងខ្លួនរបស់ស្ត្រីដែលអធិប្បាយពីខាងលើ សព្វថ្ងៃស្ទើរតែលែងមានអ្នកធ្វើដូច្នោះទៀតហើយ។ ដោយសារបច្ចុប្បន្នមានគ្រឿងសម្អាងខ្លួនលក់ស្រាប់ ងាយស្រួល ដោយមិនប្រើពេលច្រើនក្នុងការធ្វើ ហើយតម្លៃថោកទៀតផង។ ចំពោះការហាមឃាត់ស្រីក្រមុំលាបបបូរមាត់ ឬថ្នាំក្រចកពណ៌ក្រហមខ្លាំងពេកនោះបានជាប់ជាទំនៀមដល់បច្ចុប្បន្ន។ នារីមួយចំនួនធំគេមិនសូវហ៊ានលាបមុខមាត់ ឬស្បៃកពាក់ពណ៌ឆើតឆេតទេ ដូចជាពណ៌ក្រហម លឿងឬលឿងទុំជាដើម។

were necklaces and ornamental chains worn obliquely across the chest. Today, ankle bracelets and oblique chest chains are generally no longer worn by women except when they wear ceremonial costumes during their wedding ceremony.

Very few people today use any of the methods of make up, care of the skin, or nail care described above. Today there are many ready-made manufactured beauty and skin products which are affordable, easy to use, and which save the time required to make the beauty products described above. Among the elderly today, there is still a feeling however that young girls should not paint their lips or nails too much.

បញ្ជីអ្នកដែលយើងបានយក
សេចក្តីសម្ភាសន៍មកប្រើក្នុងស្នាដៃ

LIST OF INTERVIEWEES

លោកយាយកៃ រឿង
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២៩។

Kai Rueng, born in 1929
in Kandal Province.

លោកយាយខ្លូត សំអុល
កើតនៅភ្នំពេញ ឆ្នាំ១៩៣២។

Khlot Somol, born in 1932
in Phnom Penh.

លោកយាយគង់ គីម
កើតនៅខេត្តតាកែវ ឆ្នាំ១៩២៣។

Kong Kim, born in 1923
in Takeo Province.

លោកយាយគួយ គីម កើតនៅ
ខេត្តបាត់ដំបង ឆ្នាំ១៩១៨–២០០៣។

The late Kuoy Kem
(1918-2003), born in
Battambang Province.

អ៊ីស្រ៊ី ង៉ា ធំ
កើតនៅខេត្តបាត់ដំបង ឆ្នាំ១៩៣៩។

Nga Thom, born in 1939 in
Battambang Province.

លោកយាយចៃង សួន
កើតនៅខេត្តបាត់ដំបង ឆ្នាំ១៩២៣។

Jaing Suon, born in 1923
in Battambang Province.

លោកយាយឆាយ លីមឃីម
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២១។

Chay Lim Khim, born in
1921 in Kandal Province.



លោកតាជា រ័ត្ន
កើតនៅខេត្តកណ្តាល ឆ្នាំ១៩១៣។

Chea Rot, born in 1913
in Kandal Province.

លោកតាជា សំរិទ្ធ
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២៨។

Jea Somrith, born in 1928
in Phnom Penh.

លោកយាយជូ សារឿន
កើតនៅខេត្តព្រៃវែង ឆ្នាំ១៩២៦។

Ju Saroeun, born in 1926
in Prey Veng Province.



លោកអឹជិន សាមឿន
កើតនៅខេត្តព្រៃវែង ឆ្នាំ១៩៣៨។

Gin Sameun, born in 1938
in Prey Veng Province.



លោកតាជុំ កេន កើតនៅ
ខេត្តព្រៃវែង ឆ្នាំ១៩២០–២០០៣។

The late Jum Kain
(1920-2003), born in
Prey Veng Province.

លោកយាយជួន ផល
កើតនៅភ្នំពេញ ឆ្នាំ១៩៣៣។

Juon Pol, born in 1933
in Phnom Penh.



លោកតាឈុំ ឃុត
កើតខេត្តសៀមរាប ឆ្នាំ១៩៣៣។

Chum Kut, born in 1933
in Siem Reap Province.

លោកយាយឌួក
កើតនៅខេត្តព្រៃវែង ឆ្នាំ១៩២១។

Duock, born in 1921
in Prey Veng Province.

លោកយាយណុក
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២៩។

Nok, born in 1929
in Kandal Province.

លោកតាឌៀង ស៊ូ
កើតនៅខេត្តតាកែវ ឆ្នាំ១៩២៧។

Dieng Su, born in 1927
in Takeo Province.



លោកយាយនោង
កើតនៅខេត្តសៀមរាប ឆ្នាំ១៩២១។

Nong, born in 1921
in Siem Reap Province.



លោកយាយនៅ ឡៃ
កើតនៅខេត្តកណ្តាល ឆ្នាំ១៩៤៣។

Nou Lai, born in 1943
in Kandal Province.

លោកយាយប្រាក់ សេង
កើតនៅខេត្តកណ្តាល ឆ្នាំ១៩៤៧។

Prak Seng, born in 1927
in Kandal Province.

លោកយាយពិន
កើតនៅខេត្តកណ្តាល ឆ្នាំ១៩៤៧។

Pin, born in 1927
in Kandal Province.



លោកយាយគៅ ហ៊ុចឡាំង
កើតនៅខេត្តកណ្តាល ឆ្នាំ១៩០៧។

Pou Kech Lang, born in 1907
in Kandal Province.

លោកយាយគី
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២០។

Phi, born in 1920
in Kandal Province.

លោកយាយមុម សំអឿន
កើតនៅភ្នំពេញ ឆ្នាំ១៩៤៧។

Mom Samuen, born in 1927
in Phnom Penh.

លោកយាយមុិច
កើតនៅខេត្តកណ្តាល ឆ្នាំ១៩១៤។

Mich, born in 1914
in Kandal Province.

លោកយាយមុី យោង
កើតនៅខេត្តកំពង់ចាម ឆ្នាំ១៩៣១។

Mai Yaung, born in 1931
in Kampong Cham Province.

លោកតាលី សុវី
កើតនៅខេត្តព្រៃវែង ឆ្នាំ១៩៤៨។

Ly Sovy, born in 1928
in Prey Veng Province.

លោកអឹលម៉ែម ហោជាង
កើតនៅខេត្តកំពង់ធំ ឆ្នាំ១៩៤០។

Lem Hok Cheang, born in 1940
in Kompong Thom Province.

លោកតាលី អែល
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២៣។

Ly El, born in 1923
in Kandal Province.

លោកតាលីវ សាឯម កើតនៅ
ខេត្តតាកែវ ឆ្នាំ១៩៣៥-២០០៣។

The late Liv Sa Aem
(1935-2003), born in
Takeo Province

លោកយាយរ៉ាំ រីម
កើតនៅភ្នំពេញ ឆ្នាំ១៩៣១។

Ram Rem, born in 1931
in Phnom Penh.

លោកយាយស៊ីម
កើតនៅខេត្តកំពង់ចាម ឆ្នាំ១៩២៣។

Sim, born in 1923
in Kampong Cham Province.

លោកយាយស្រី សម្បត្តិ
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២៦។

Srei Sambath, born in 1926
in Kandal Province.



លោកយាយស៊ីម សារិន
កើតនៅខេត្តស្វាយរៀង ឆ្នាំ១៩២៧។

Sim Saren, born in 1927
in Svay Rieng Province.



លោកយាយសួង ម៉ាលី
កើតនៅខេត្តកំពង់ធំ ឆ្នាំ១៩៣១។

Suong Mali, born in 1931
in KompongThom Province.

លោកតាស្នួន
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២៩។

Sgnuon, born in 1929
in Kandal Province.



លោកយាយសែម ឡាប
កើតនៅខេត្តសៀមរាប ឆ្នាំ១៩២៦។

Saim Laap, born in 1926
in Siem Reap Province.

លោកយាយហង់ ឈួន
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២០។

Hong Chuon, born in 1920
in Kandal Province.

លោកតាហង់ ភួង
កើតនៅខេត្តកណ្តាល ឆ្នាំ១៩០៩។

Hong Phuong, born in 1909
in Kandal Province.

លោកយាយហួន
កើតនៅខេត្តកំពង់ចាម ឆ្នាំ១៩២៦។

Huon, born in 1926
in Kampong Cham Province.

លោកយាយឡុង តាន់ កើតនៅ
ខេត្តកណ្តាល ឆ្នាំ១៩១៤–២០០៣។

The late Long Than
(1914-2003), born in
Kandal Province.

លោកយាយអ៊ុំ យៀម
កើតនៅខេត្តសៀមរាប ឆ្នាំ១៩៣៩។

Om Yuem, born in 1939
in Siem Reap Province.

លោកយាយអ៊ុង សុក
កើតនៅខេត្តកណ្តាល ឆ្នាំ១៩២៣។

Ong Sok, born in 1923
in Kandal Province.

លោកយាយអ៊ុន ឈុំ
កើតនៅភ្នំពេញ ឆ្នាំ១៩១៧។

Oun Chum, born in 1917
in Phnom Penh.



លោកតាអឿន ខ្ចៃ
កើតនៅខេត្តសៀមរាប ឆ្នាំ១៩២១។

Oeun Klainh, born in 1921
in Siem Reap Province.

ឯកសារពិគ្រោះ

១- កាសែតកម្ពុជា លេខ៤៧៧ ចុះថ្ងៃទី២១ វិច្ឆិកា ឆ្នាំ១៩៤៦។

កាសែតកម្ពុជា លេខ១៧៧៦ ឆ្នាំទី១០ ខែកក្កដា ឆ្នាំ១៩៥១។

កាសែតកម្ពុជា លេខ១៧៧៧-១៧៧៨ ឆ្នាំទី១១ ខែកក្កដា ឆ្នាំ១៩៥១។

២- ជា ពិសី "តម្បាញក្រមាខ្មែរ" និក្ខេបបទបញ្ចប់បរិញ្ញាប័ត្រផ្នែកបុរាណវិទ្យា ភ្នំពេញ ឆ្នាំ១៩៩៤។

៣- តូច ឈួង "ចាត់ដំបងសម័យលោកម្ចាស់" ភ្នំពេញ ឆ្នាំ១៩៩៤។

៤- ទស្សនាវដ្តីសម្រាប់គ្រូបង្រៀន ឆ្នាំទី៣ លេខ៥ ឆ្នាំ១៩៥១-៥២។

៥- ទស្សនាវដ្តី "នារី" ឆ្នាំទី១ លេខ១ ខែមករា ឆ្នាំ១៩៤៩។

ទស្សនាវដ្តី "នារី" ឆ្នាំ១៩៥១។

៦- ទស្សនាវដ្តី "គូមិយើង" ចុះខែមករា ឆ្នាំ១៩៦១។

៧- នួន ប៊ុត "ព្រហ្មជាតិ" កណ្ឌ ទី២ ភ្នំពេញ ឆ្នាំ១៩៦៤។

៨- មាស ហាំ "ក្រមួនលាបមាត់" ទស្សនាវដ្តីកម្ពុជសុរិយា អត្ថបទក្បាលទី១ ឆ្នាំទី៣៧ ឆ្នាំ១៩៦៥ ទំព័រ២៨០។

៩- មៀច ប៉ុណ្ណ "វិធីធ្វើក្បង" ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំទី៥១ ខែមេសា-មិថុនា ឆ្នាំ២០០០ ទំព័រ៩១។

១០- លី ធាមតេង "កំណត់ហេតុរបស់ជីវតាខ្វាន់" ភ្នំពេញ ឆ្នាំ១៩៧៣។

១១- សម្តេចជួន ណាត "វចនានុក្រមខ្មែរ" (ភាគ១-២) ភ្នំពេញ ឆ្នាំ១៩៦៧-៦៨។

១២- សេក-ថ្នៅវ-សុំម "ផ្ទាស់ផ្ទាល់ និងទម្ងន់ប្រើប្រាស់នៅប្រទេសកម្ពុជា" សិក្ខាឯកលេខនា ឆ្នាំ១៩៦៧។

១៣- អ៊ាប-ប៊ុន-សិត "វិជ្ជាកាត់ដេរដោយខ្លួនឯង" ទស្សវត្ស១៩៦០។

រយៈពេលពីរឆ្នាំកន្លងមកនេះ អ្នកស្រាវជ្រាវរៃអំមួយក្រុម បានសម្ភាសន៍មនុស្សចាស់ជាច្រើន ក្នុងគោលបំណងធ្វើជាទិន្នន័យសម្រាប់ស្រាវជ្រាវប្រវត្តិសាស្ត្រ។ ដោយយោងទៅលើទិន្នន័យនេះ យើងបានប្រមូលផ្តុំពត៌មានទាក់ទងនឹងការស្លៀកពាក់ និងថែរក្សាខ្លួន តាមទម្លាប់បុរាណនៅក្នុងស្រុកខ្មែរ ពោលគឺមុនពេលមានរបស់របរផលិតដោយឧស្សាហកម្មទំនើប។ យើងបានចងក្រងពត៌មានទាំងនោះធ្វើជាសៀវភៅ រួមមាន៦ជំពូក ផ្តោតលើការវិត្តន៍នៃសម្លៀកបំពាក់, ប្រភេទក្រណាត់, វិធីកាត់ដេរនិងប្រភេទថ្នេរដេរដោយដៃ និងរបៀបថែរក្សាខ្លួន ។ល។

For the last two years, a team of Reyum researchers have been interviewing elderly Cambodians about their lives in order to compile a Memory Bank of everyday life in late 19th and 20th century Cambodia. For this particular book, the researchers have focused on the topic of clothing and the care of the self, illuminating traditional types of clothing and longstanding habits of bodily care found in Cambodia before modernisation. The book details traditional types of cloth and clothing, ways of cutting, sewing, and keeping clothing, as well as habits of beauty and care used prior to the advent of readymade manufactured products.

ឧបត្ថម្ភដោយ *With the support of*

The Rockefeller Foundation

ISBN 1-58886-046-9

9 781588 860460